# សេចក្តីព្រាង

# ក្រមបរិស្ថាន និងធនធានធម្មជាតិ

## កំណែ៩.១ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧

# មាតិកា

**គន្លឹះទី១ បទប្បញ្ញត្តិទូទៅ**............................................................................................................១

មាតិកាទី១ បទប្បញ្ញត្តិទូទៅ............................................................................................................១

ជំពូកទី១ គោលដៅ គោលបំណង និងវិសាលភាព ...............................................................................១

ជំពូកទី២ គោលការណ៍ទូទៅ ......................................................................................................... ៣

ជំពូកទី៣ សមត្ថកិច្ចក្រសួង ស្ថាប័នពាក់ព័ន្ធវិស័យបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ.....................៦

មាតិកាទី២ ការចូលរួមជាសាធារណៈ.................................................................................................. ៧

ជំពូកទី១ សិទ្ធិនិងការការពារ សម្រាប់ការចូលរួមជាសាធារណៈ ....................................................... ៧

ជំពូកទី២ ការចូលរួមជាសាធារណៈរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងការសម្រេចចិត្តអំពីបរិស្ថាន និងធនធានធម្មជាតិ........................................................................................................ ១០

ជំពូកទី៣ វិធានការកាត់បន្ថយ .................................................................................................... ១១

មាតិកាទី៣ សិទ្ធិទទួលបានព័ត៌មានបរិស្ថាន.......................................................................................១២

ជំពូកទី១ បទប្បញ្ញត្តិទូទៅ.........................................................................................................១២

ជំពូកទី២ ការផ្តល់ព័ត៌មានដោយរាជរដ្ឋាភិបាល និងម្ចាស់គម្រោង ................................................... ១៤

ផ្នែកទី១ បទប្បញ្ញត្តិទូទៅ .................................................................................................. ១៤

ផ្នែកទី២ បញ្ជីព័ត៌មានបរិស្ថានរដ្ឋ ....................................................................................... ១៥

ផ្នែកទី៣ បញ្ជីនៃលិខិតអនុញ្ញាត និងការឯកភាព.................................................................... ១៦

ផ្នែកទី៤ បញ្ជីសវនកម្មបរិស្ថាន .........................................................................................១៧

ផ្នែកទី៥ មជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា..........................................................................១៧

ជំពូកទី៣ ព័ត៌មានសម្ងាត់........................................................................................................... ១៩

ជំពូកទី៤ ការស្នើសុំព័ត៌មាន .........................................................................................................២០

ជំពូកទី៥ បណ្ដឹង និងការអនុវត្តច្បាប់ ....................................................................... ២១

**គន្ថីទី២ ការវាយតម្លៃ និងការអង្កេតតាមដានបរិស្ថាន** .......................................................... ២២

មាតិកាទី១ ការវាយតម្លៃហានិភ័យ និងការវាយតម្លៃហានិភ័យនៃនិរន្តភាព................................................ ២២

ជំពូកទី១ ការវាយតម្លៃហានិភ័យ.............................................................................................. ២២

ជំពូកទី២ ការវាយតម្លៃហានិភ័យនិរន្តភាព................................................................................ ២៤

មាតិកាទី២ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត................................................................................ ២៥

ជំពូកទី១ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត.............................................................................. ២៥

ជំពូកទី២ នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត...................................................................... ២៦

មាតិកាទី៣ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន................................................................................ ២៨

ជំពូកទី១ បទប្បញ្ញត្តិទូទៅ...................................................................................................... ២៨

ជំពូកទី២ គោលការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន .......................................................... ៣០

ជំពូកទី៣ អង្គភាពទទួលខុសត្រូវ................................................................................................ ៣០

ជំពូកទី៤ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន................................................................ ៣៣

ផ្នែកទី១ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងស្នើសុំ .......................................... ៣៣

ផ្នែកទី២ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងដែលមានស្រាប់ និងកំពុងដំណើរការ ... ៤១

ផ្នែកទី៣ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះការប្រែប្រួលអាកាសធាតុ.............................. ៤១

ផ្នែកទី៤ ការវាយតម្លៃហេតុប៉ះពាល់សុខភាព និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាបណ្ដុំ ....... ៤២

ជំពូកទី៥ ការចូលរួមជាសាធារណៈ........................................................................................ ៤៤

ជំពូកទី៦ ផែនការគ្រប់គ្រងបរិស្ថាន និងការអង្កេតតាមដានគម្រោង.................................................. ៤៧

ជំពូកទី៧ ការវាយតម្លៃហេតុប៉ះពាល់ឆ្លងដែន .......................................................................... ៥០

មាតិកាទី៤ សវនកម្មបរិស្ថាន ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍............................................ ៥០

ជំពូកទី១ សវនកម្មបរិស្ថាន ..... ៥០

ជំពូកទី២ ការតែងតាំង និងលក្ខណៈសម្បត្តិរបស់សវនករបរិស្ថាន..... ៥២

**គន្ថីទី៣ ការគ្រប់គ្រងបរិស្ថាន និងយន្តការនិរន្តរភាព**..... ៥២

មាតិកាទី១ ការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ..... ៥២

ជំពូកទី១ គោលការណ៍ និងការរៀបចំផែនការគ្រប់គ្រងគ្រោះមហន្តរាយ ..... ៥២

មាតិកាទី២ ការប្រែប្រួលអាកាសធាតុ..... ៥៤

ជំពូកទី១ បទប្បញ្ញត្តិទូទៅ..... ៥៤

ជំពូកទី២ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ..... ៥៥

ជំពូកទី៣ ការអនុវត្តនូវការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ..... ៥៦

ជំពូកទី៤ ការអង្កេតតាមដាន និងការវាយតម្លៃការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ..... ៥៩

ជំពូកទី៥ ព័តមានស្តីពីការប្រែប្រួលអាកាសធាតុ..... ៦១

ផ្នែកទី១ បញ្ជីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ ..... ៦៤

ផ្នែកទី២ បញ្ជីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ថ្នាក់ជាតិ..... ៦៤

ជំពូកទី៦ ការកសាងសមត្ថភាពស្ថានប័ន ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិជ្ជា និងចំណេះដឹង..... ៦៥

ជំពូកទី៧ ក្របខ័ណ្ឌហិរញ្ញប្បទាន សម្រាប់ការប្រែប្រួលអាកាសធាតុ..... ៦៦

ផ្នែកទី១ ការបែងចែកធនធានសម្រាប់ការប្រែប្រួលអាកាសធាតុនៅក្នុងថវិកាជាតិ និងថវិកាថ្នាក់ក្រោមជាតិ..... ៦៧

ផ្នែកទី២ ការលើកកម្ពស់ ការវិនិយោគលើអាកាសធាតុដែលមានលក្ខណៈឆ្លាតវៃពីវិស័យឯកជន... ៦៨

ផ្នែកទី៣ ការកៀរហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុពីបរទេស ..... ៦៨

ផ្នែកទី៤ ការលើកកម្ពស់យន្តការហិរញ្ញវត្ថុអាកាសធាតុដែលផ្អែកលើលទ្ធផល..... ៦៩

មាតិកាទី៣ ការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តភាព..... ៦៩

ជំពូកទី១ បទប្បញ្ញត្តិទូទៅ..... ៦៩

ផ្នែកទី១ ការលើកកម្ពស់ការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តភាព....................................៧០
ផ្នែកទី២ លទ្ធកម្មប្រកបដោយនិរន្តភាព....................................................................................៧១
ផ្នែកទី៣ ការដាក់ស្លាកសញ្ញាបរិស្ថានដោយស្ម័គ្រចិត្ត..................................................................៧៤
ផ្នែកទី៤ ការវាយតម្លៃប្រសិទ្ធផលនៃធនធាន................................................................................៧៥
ផ្នែកទី៥ ការទទួលខុសត្រូវបន្ថែមរបស់ផលិតករ.........................................................................៧៧
មាតិកាទី៤ ការរៀបចំផែនការប្រើប្រាស់បរិស្ថានដីធ្លី និងនិរន្តរភាពទីក្រុង.......................................៧៧
ជំពូកទី១ បទប្បញ្ញត្តិទូទៅ...................................................................................................៧៧
ជំពូកទី២ តួនាទី និងការទទួលខុសត្រូវ.....................................................................................៧៨
ជំពូកទី៣ ការរៀបផែនការដីបរិស្ថាន.........................................................................................៨០
ជំពូកទី៤ និរន្តរភាពទីក្រុង.....................................................................................................៨៤
ផ្នែកទី១ ស្ថាប័នទទួលខុសត្រូវ...............................................................................................៨៤
ផ្នែកទី២ គណៈកម្មការនិរន្តរភាពទីក្រុង....................................................................................៨៤
មាតិកាទី៥ និរន្តរភាពទេសចរណ៍...........................................................................................៨៦
ជំពូកទី១ ការអភិវឌ្ឍនិរន្តរភាពទេសចរណ៍.................................................................................៨៦
ជំពូកទី២ ទេសចរណ៍ធម្មជាតិដែលផ្អែកលើសហគមន៍គ្រប់គ្រងរួមគ្នា...........................................៨៧
មាតិកាទី៦ និរន្តរភាពថាមពល...............................................................................................៨៨
ជំពូកទី១ ថាមពលប្រកបដោយនិរន្តរភាព.................................................................................៨៨
ជំពូកទី២ ការរៀបចំផែនការនិរន្តរភាពថាមពល.........................................................................៨៩
ជំពូកទី៣ ការលើកកម្ពស់នូវបច្ចេកវិជ្ជាមេត្រីបរិស្ថាន..................................................................៩១
ជំពូកទី៤ ការត្រួតពិនិត្យគុណភាពផលិតផលសម្រាប់ផលិតថាមពលប្រកបដោយនិរន្តរភាព...............៩៤
ជំពូកទី៥ ក្របខ័ណ្ឌទៅតាមប្រភេទថាមពល ឬគម្រោងអគ្គីសនី....................................................៩៥

ផ្នែកទី១ ថាមពលពន្លឺព្រះអាទិត្យ ........ ៩៥

ផ្នែកទី២ ថាមពលនុយក្លេអ៊ែរ ........ ៩៧

ផ្នែកទី៣ ការភ្ជាប់ប្រព័ន្ធចែកចាយ និងបណ្ដាញតចូល ........ ៩៧

ជំពូកទី៦ ប្រសិទ្ធផលថាមពល ........ ៩៩

មាតិកាទី៧ ឧស្សាហកម្មនិស្សារណកម្មប្រកបដោយការទទួលខុសត្រូវ ........ ៩៩

ជំពូកទី១ វិសាលភាព និងការរៀបចំផែនការបរិស្ថានសម្រាប់ឧស្សាហកម្មនិស្សារណកម្ម ........ ៩៩

ជំពូកទី២ បច្ចេកវិជ្ជាដ៏ល្អបំផុតដែលអាចស្វែងរកបានសម្រាប់ឧស្សាហកម្មនិស្សារណកម្ម ........ ១០២

ជំពូកទី៣ ការប្រើប្រាស់ស្យានីត និងបារ៉ត នៅក្នុងការធ្វើអាជីវកម្មរ៉ែមាស និងប្រាក់ ........ ១០៣

ជំពូកទី៤ ការលាតត្រដាងព័ត៌មាន ........ ១០៥

**គន្ថីទី៤ ការគ្រប់គ្រងប្រកបនិរន្តរភាពនៃធនធានធម្មជាតិ ........ ១០៦**

មាតិកាទី១ របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ........ ១០៦

ជំពូកទី១ នីតិវិធីនៃការបង្កើត និងការលុបចោលចំណាត់ថ្នាក់ ........ ១០៦

ជំពូកទី២ ការគ្រប់គ្រង ការប្រើប្រាស់ និងលក្ខខណ្ឌតម្រូវផ្សេងទៀត ........ ១០៨

ជំពូកទី៣ របៀងអភិរក្សជីវៈចម្រុះថ្មី និងឋានៈនៃតំបន់ការពារធម្មជាតិបច្ចុប្បន្ន ........ ១០៩

មាតិកាទី២ ការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិបច្ចុប្បន្ន ........ ១១០

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ........ ១១០

ជំពូកទី២ ស្ថាប័នទទួលខុសត្រូវ ........ ១១១

ជំពូកទី៣ ការរៀបចំផែនការប្រើប្រាស់ដី នៅក្នុងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ........ ១១៦

ជំពូកទី៤ តំបន់គ្រប់គ្រងនៃរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ........ ១២០

ជំពូកទី៥ ផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រសម្រាប់របៀងអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ........ ១២៥

ជំពូកទី៦ លិខិតអនុញ្ញាត និងការឯកភាព ........ ១២៧

ជំពូកទី៧ ការអង្កេតតាមដាន និងការវាយតម្លៃការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ ............................ ១៣៣
មាតិកាទី៣ ការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិ ............................ ១៣៤
ជំពូកទី១ ការបង្កើតក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា ............................ ១៣៤
ជំពូកទី២ ការអនុវត្តក្របខ័ណ្ឌនៃការគ្រប់គ្រងរួមគ្នា ............................ ១៣៥
ជំពូកទី៣ រយៈពេលនៃការគ្រប់គ្រងរួមគ្នា និងសិទ្ធិដីធ្លី ............................ ១៤០
មាតិកាទី៤ ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ............................ ១៤២
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ............................ ១៤២
ជំពូកទី២ អង្គភាពដែលមានការទទួលខុសត្រូវ ............................ ១៤៣
ជំពូកទី៣ ការធ្វើចំណាត់ថ្នាក់ព្រៃឈើដែលគ្រប់គ្រងប្រកបដោយនិរន្តរភាព ............................ ១៤៥
ជំពូកទី៤ ការរៀបចំផែនការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាព ............................ ១៤៨
ជំពូកទី៥ លិខិតអនុញ្ញាត និងការឯកភាព ............................ ១៤៩
ជំពូកទី៦ សិទ្ធិអ្នកប្រើប្រាស់ជាប្រពៃណី ............................ ១៥១
ជំពូកទី៧ ផែនការ និងរបាយការណ៍គ្រប់គ្រងសកម្មភាពពាណិជ្ជកម្ម ............................ ១៥២
ជំពូកទី៨ ប្រាក់កម្រៃ និងបុព្វលាភស្ដីពីផលព្រៃឈើ ............................ ១៥៣
ជំពូកទី៩ យន្តការផ្សេងៗសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ............................ ១៥៥
មាតិកាទី៥ ការការពារ ការអភិរក្ស និងការគ្រប់គ្រងសត្វព្រៃ ............................ ១៥៧
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ............................ ១៥៨
ជំពូកទី២ ការធ្វើចំណាត់ថ្នាក់ប្រភេទសត្វព្រៃ ............................ ១៦២
ជំពូកទី៣ ការហាមឃាត់ចំពោះការបរបាញ់ ............................ ១៦៥
ជំពូកទី៤ ករណីលើកលែងសម្រាប់ការបរបាញ់សត្វព្រៃ ............................ ១៦៨
ផ្នែកទី១ ការត្រួតពិនិត្យការបង្កគ្រោះថ្នាក់ដល់ជីវិតសត្វព្រៃ ............................ ១៦៨

ផ្នែកទី២ គ្រឹះស្ថានឧទ្យានសត្វព្រៃ ........................................................................ ១៧០

ជំពូកទី៥ លិខិតអនុញ្ញាតបរបាញ់........................................................................................ ១៧១

ជំពូកទី៦ ការហាមឃាត់ចំពោះការធ្វើអាជីវកម្ម ការជួញដូរ ឬការធ្វើពាណិជ្ជកម្មសត្វព្រៃ សត្វដែលប្រម៉ាញ់បាន បំណែកសត្វ និងគ្រប់ផលិតផលពីសត្វព្រៃគ្រប់ប្រភេទ ................................................. ១៧៥

ជំពូកទី៧ អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិនៃប្រភេទសត្វព្រៃ និងរុក្ខជាតិ ដែលកំពុងរងគ្រោះថ្នាក់ ... ១៧៦

ជំពូកទី៨ កិច្ចសហប្រតិបត្តិការអន្តរជាតិ.........................................................................................១៧៧

ជំពូកទី៩ ផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ និងរុក្ខជាតិ .................................................... ១៧៨

ជំពូកទី១០ ការគ្រប់គ្រងការបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃ ...... ..........................................................................................................១៨១

ជំពូកទី១១ ការគ្រប់គ្រងទៅលើសត្វព្រៃ និងផ្នែកនៃសត្វព្រៃដែលបានរឹបអូស ..................................១៨៤

ជំពូកទី១២ ការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វព្រៃ....................................................................... ១៨៧

ជំពូកទី១៣ ការតាមដានសុខភាពសត្វព្រៃ.....................................................................................១៩១

ជំពូកទី១៤ លិខិតបទដ្ឋានទូទៅ.................................................................................................. ១៩៣

មាតិកាទី៦ កិច្ចការពាររុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ ............................................១៩៤

ជំពូកទី១ បទប្បញ្ញត្តិទូទៅ.............................................................................................................១៩៤

ជំពូកទី២ ការធ្វើចំណាត់ថ្នាក់នៃប្រភេទរុក្ខជាតិ.............................................................................១៩៦

ជំពូកទី៣ ការហាមឃាត់ទៅលើសកម្មភាពដែលប៉ះពាល់ចំពោះទីជម្រក និងប្រភេទរុក្ខជាតិ ដែលទទួលរងគ្រោះថ្នាក់ និងការប្រមូលយករុក្ខជាតិ .................................................................................... ២០០

ជំពូកទី៤ ការផ្តល់លិខិតអនុញ្ញាតសម្រាប់គោលបំណងពិសេស................................................... ២០០

ជំពូកទី៥ ផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទរុក្ខជាតិ .....................................................២០២

ជំពូកទី៦ ការធ្វើចំណាត់ថ្នាក់នៃប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ ....................................... ២០៤

ជំពូកទី៧ ផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី ដែលទទួលរងគ្រោះថ្នាក់ ................ ២០៦

ជំពូកទី៨ ការគ្រប់គ្រងប្រភេទរុក្ខជាតិរាតត្បាត ........ ២០៨

ជំពូកទី៩ ការគ្រប់គ្រងរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ដែលរឹបអូសបាន ឬផលដែលកើតចេញពីរុក្ខជាតិដែលបានរឹបអូស ........ ២០៩

ជំពូកទី១០ លិខិតបទដ្ឋានគតិយុត្តសម្រាប់ការពាររុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលរងគ្រោះថ្នាក់ ........ ២១០

មាតិកាទី៧ ការគ្រប់គ្រងតំបន់ឆ្នេរ ........ ២១០

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ........ ២១១

ជំពូកទី២ អនុតំបន់ឆ្នេរ ........ ២១២

ជំពូកទី៣ ការរៀបចំផែនការសម្រាប់ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពទៅលើតំបន់ឆ្នេរ ........ ២១២

ជំពូកទី៤ ការចូលរួមជាសាធារណៈ នៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ ........ ២១៤

មាតិកាទី៨ ការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តភាព ........ ២១៥

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ........ ២១៥

ផ្នែកទី១ គោលដៅ និងគោលការណ៍ ........ ២១៥

ផ្នែកទី២ ម្ចាស់កម្មសិទ្ធិលើទឹក និងធនធានទឹក ........ ២១៦

ជំពូកទី២ ការទទួលខុសត្រូវផ្នែកធនធានទឹក ........ ២១៦

ផ្នែកទី១ ការទទួលខុសត្រូវរបស់សាមីក្រសួង ........ ២១៦

ផ្នែកទី២ ការសម្របសម្រួលរបស់រាជរដ្ឋាភិបាល ........ ២១៩

ជំពូកទី៣ ការរៀបចំផែនការធនធានទឹក ........ ២២០

ផ្នែកទី១ គោលដៅ និងគោលការណ៍ ........ ២២០

ផ្នែកទី២ ផែនការធនធានទឹកអាងទន្លេ ........ ២២២

ផ្នែកទី៣ ផែនការធនធានទឹកអាងទន្លេ ........ ២២៣

ជំពូកទី៤ ការផ្តល់ការអនុញ្ញាត ........ ២២៩

ផ្នែកទី១ បទប្បញ្ញត្តិទូទៅ ..... ២២៩
ផ្នែកទី២ អាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធ ..... ២៣១
ផ្នែកទី៣ សិទ្ធិទទួលបានទឹក ..... ២៣១
ផ្នែកទី៤ កិច្ចការពារទាក់ទងនឹងទន្លេ និងស្ទឹង ..... ២៣៥
ផ្នែកទី៥ អ្នកអភិវឌ្ឍទឹកក្រោមដី ..... ២៣៦
ផ្នែកទី៦ ការដកហូតការអនុញ្ញាត ..... ២៣៧
ជំពូកទី៥ ការតម្រូវឲ្យមានការអនុញ្ញាត ..... ២៣៨
ជំពូកទី៦ ការរៀបចំអន្តរកាល ..... ២៣៨
មាតិកា៩ និរន្តរភាពជលផល ..... ២៣៩
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ..... ២៣៩
ជំពូកទី២ និរន្តរភាពនៃការគ្រប់គ្រងជលផលទឹកសាប និងទឹកសមុទ្រ ..... ២៤១
ជំពូកទី៣ វារីវប្បកម្ម ..... ២៤៥
**គន្ថីទី៥ ការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ..... ២៤៦**
មាតិកាទោល ការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ..... ២៤៦
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ..... ២៤៦
ជំពូកទី២ ការទទួលខុសត្រូវសម្រាប់កិច្ចការពារបេតិកភណ្ឌវប្បធម៌ ..... ២៤៧
ផ្នែកទី១ ក្រសួង ស្ថាប័នមានសមត្ថកិច្ចដែលមានស្រាប់ ..... ២៤៧
ផ្នែកទី២ ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ..... ២៤៨
ជំពូកទី៤ ការបង្កើតបញ្ជីបេតិកភណ្ឌជាតិ ..... ២៥០
ជំពូកទី៥ ការរៀបចំតំបន់ការពារបេតិកភណ្ឌជាតិ ..... ២៥៣
ជំពូកទី៦ ការបង្កើតតំបន់ការពារបេតិកភណ្ឌទីក្រុង ..... ២៥៣

ជំពូកទី៧ កិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ........................................................................ ២៥៣

ផ្នែកទី១ ការប្រទះឃើញដោយចៃដន្យ ក្នុងអំឡុងពេលនៃការកំទេចចោល ការសាងសង់ ឬ សកម្មភាពដទៃទៀត........................................................................ ២៥៣

ផ្នែកទី២ ការការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងក្នុងសមុទ្រ........................................ ២៥៥

ផ្នែកទី៣ លិខិតអនុញ្ញាតសម្រាប់គម្រោងអភិវឌ្ឍដែលប៉ះពាល់ដល់បេតិកភណ្ឌវប្បធម៌ ............ ២៥៧

ជំពូកទី៨ អង្គភាពបុរាណវត្ថុវិទ្យា ........................................................................ ២៥៧

ជំពូកទី៩ ការដោះស្រាយវិវាទ និងបទបញ្ហាបន្ទាន់........................................................................ ២៥៨

ជំពូកទី១០ ផែនការគ្រប់គ្រងបេតិកភណ្ឌ........................................................................ ២៥៩

ជំពូកទី១១ ការលើកកម្ពស់ និងការការពារបេតិកភណ្ឌអរូបិយ........................................ ២៦០

ជំពូកទី១២ ការអប់រំ និងការយល់ដឹង........................................................................ ២៦០

ជំពូកទី១៣ បទប្បញ្ញត្តិប្រឆាំងនឹងការជួញដូរ........................................................................ ២៦១

**គន្លឹះទី៦ ការគ្រប់គ្រងសំណល់ និងការបំពុល**........................................................................ ២៦១

មាតិកាទី១ កាតព្វកិច្ចទូទៅចំពោះការត្រួតពិនិត្យការបំពុល........................................ ២៦១

ជំពូកទី១ ការហាមឃាត់ស្តីពីការបំពុល........................................................................ ២៦១

ជំពូកទី២ លិខិតអនុញ្ញាត និងការឯកភាព........................................................................ ២៦២

មាតិកាទី២ ស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ ........................................ ២៦២

ជំពូកទី១ ការបង្កើតស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ........................................ ២៦២

ជំពូកទី២ ការអនុវត្តស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ ........................................ ២៦៤

ជំពូកទី៣ ស្តង់ដារ គុណភាពបរិស្ថាន ឬស្តង់ដារសំណល់រាវអន្តរកាល ........................................ ២៦៤

មាតិកាទី៣ ការគ្រប់គ្រងសារធាតុគ្រោះថ្នាក់ ........................................................................ ២៦៦

ជំពូកទី១ បទប្បញ្ញត្តិទូទៅ........................................................................ ២៦៦

ជំពូកទី២ ការហាមឃាត់សារធាតុគ្រោះថ្នាក់ ........................................................................ ២៦៧

ជំពូកទី៣ ការចុះបញ្ជី និងការលាតត្រដាងព័ត៌មានអំពីសារធាតុគ្រោះថ្នាក់ ..... ២៧០
ជំពូកទី៤ ការដាក់ស្លាកសញ្ញាសារធាតុគ្រោះថ្នាក់ ..... ២៧២
ជំពូកទី៥ ការដឹកជញ្ជូន ការប្រើប្រាស់ និងការបោះបង់ចោលសារធាតុគ្រោះថ្នាក់ ..... ២៧២
ជំពូកទី៦ សុវត្ថិភាពនៃសារធាតុគ្រោះថ្នាក់ ការទប់ស្កាត់គ្រោះថ្នាក់ ការត្រៀមលក្ខណៈ និងការឆ្លើយតបនានា ..... ២៧៤
មាតិកាទី៤ ការគ្រប់គ្រងសំណល់ ..... ២៧៦
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ..... ២៧៦
ជំពូកទី២ ការធ្វើចំណាត់ថ្នាក់សំណល់ ..... ២៧៨
ជំពូកទី៣ ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ..... ២៧៩
ជំពូកទី៤ ការគ្រប់គ្រងសំណល់រឹង ..... ២៧៩
មាតិកាទី៥ ការត្រួតពិនិត្យការបំពុលទឹក ..... ២៨០
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ..... ២៨០
ជំពូកទី២ ការត្រួតពិនិត្យប្រភពបំពុលទឹកជាក់លាក់ ..... ២៨១
ជំពូកទី៣ ការត្រួតពិនិត្យប្រភពបំពុលទឹកមិនជាក់លាក់ ..... ២៨២
ជំពូកទី៤ ការអង្កេតតាមដានប្រភពបំពុលទឹកជាក់លាក់ ..... ២៨៣
ជំពូកទី៥ ការធ្វើប្រព្រឹត្តកម្ម និងការប្រើប្រាស់សារឡើងវិញនូវទឹកកខ្វក់ និងសំណល់ ..... ២៨៤
ជំពូកទី៦ ការផ្តល់វិញ្ញាបនបត្រនៃប្រតិបត្តិករ ..... ២៨៥
ជំពូកទី៧ ការត្រួតពិនិត្យការបំពុលសមុទ្រ ..... ២៨៦
មាតិកាទី៦ ការត្រួតពិនិត្យការបំពុលខ្យល់ ..... ២៨៦
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ..... ២៨៦
ជំពូកទី២ ការបំពុលខ្យល់ពីប្រភពចល័ត ..... ២៨៧
ជំពូកទី៣ ការបំពុលខ្យល់ពីប្រភពអចល័ត ..... ២៨៩

ជំពូកទី៤ លិខិតអនុញ្ញាតក្នុងការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័ត ............................. ២៩១

ជំពូកទី៥ ការគ្រប់គ្រង និងការត្រួតពិនិត្យគុណភាពបរិយាកាស ................................................. ២៩៤

ជំពូកទី៦ វិញ្ញាបនបត្ររបស់ប្រតិបត្តិករ ........................................................................................ ២៩៧

ជំពូកទី៧ ការបំពុលខ្យល់ឆ្លងដែន .............................................................................................. ២៩៧

ជំពូកទី៨ សារធាតុបំផ្លាញស្រទាប់អូហ្សូន ........................................................................... ២៩៨

មាតិកាទី៧ ការត្រួតពិនិត្យសំឡេង និងរំញ័រ ............................................................................. ២៩៩

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ......................................................................................................... ២៩៩

ជំពូកទី២ លិខិតបទដ្ឋានគតិយុត្តស្តីពីសំឡេង និងរំញ័រ ........................................................... ២៩៩

មាតិកាទី៨ ការស្តារឡើងវិញនូវទីតាំងដែលទទួលរងការបំពុល ........................................................... ៣០០

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ......................................................................................................... ៣០០

ជំពូកទី២ ការរាយការណ៍អំពីផលប៉ះពាល់បរិស្ថាន ................................................................. ៣០១

ជំពូកទី៣ ការស៊ើបអង្កេត និងការស្តារឡើងវិញ ........................................................................ ៣០១

ជំពូកទី៤ ការអង្កេតតាមដានការស្តារឡើងវិញ ......................................................................... ៣០២

ជំពូកទី៥ ការចេញវិញ្ញាបនបត្រនៃការបំពេញចប់ការស្តារឡើងវិញ ................................................ ៣០៣

មាតិកាទី៩ ប្រព័ន្ធថ្នាក់ជាតិស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី ........................................ ៣០៤

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ......................................................................................................... ៣០៤

ជំពូកទី២ ប្រព័ន្ធថ្នាក់ជាតិស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី ................................... ៣០៥

**គន្ថីទី៧ ការអប់រំ និងការយល់ដឹងពីបរិស្ថាន** ........................................................................ ៣០៥

មាតិកាទោល ការអប់រំ និងការយល់ដឹងពីបរិស្ថាន ........................................................................ ៣០៦

ជំពូកទី១ ការបណ្តុះបណ្តាលស្តីពីការការពារបរិស្ថាន ការអភិរក្សធនធានបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ........................................................................................................ ៣០៦

ជំពូកទី២ បណ្ឌិតសភាជាតិបណ្តុះបណ្តាលបរិស្ថាន និងធនធានធម្មជាតិ ....................................... ៣០៧

ជំពូកទី៣ ការយល់ដឹង ........ ៣០៨

ជំពូកទី៤ ការអប់រំក្នុងប្រព័ន្ធ ........ ៣០៨

ជំពូកទី៥ ការស្រាវជ្រាវ និងនវានុវត្តន៍ ........ ៣១០

ជំពូកទី៦ លិខិតបទដ្ឋាន និងក្របខ័ណ្ឌប្រតិបត្តិការ ........ ៣១១

**គន្ថីទី៨ វិធានការសេដ្ឋកិច្ច គណនី ថ្លៃ និងមូលនិធិផ្នែកបរិស្ថាន ........ ៣១២**

មាតិកាទី១ វិធានការសេដ្ឋកិច្ច និងគណនី ........ ៣១២

ជំពូកទី១ វិធានការសេដ្ឋកិច្ច ........ ៣១២

ជំពូកទី២ គណនី ........ ៣១៦

មាតិកាទី២ ថ្លៃ និងបន្ទុកសេវាបរិស្ថាន មូលនិធិ និងការគ្រប់គ្រងមូលនិធិ ........ ៣១៦

ជំពូកទី១ ថ្លៃ និងបន្ទុកសេវាបរិស្ថាន ........ ៣១៦

ជំពូកទី២ មូលនិធិបរិស្ថាន និងការគ្រប់គ្រងមូលនិធិ ........ ៣១៩

ផ្នែកទី១ មូលនិធិបរិស្ថាន និងសង្គម ........ ៣១៩

ផ្នែកទី២ មូលនិធិភារៈគ្រប់គ្រងបរិស្ថាន ........ ៣២០

ផ្នែកទី៣ មូលនិធិដទៃទៀត ........ ៣២៨

ជំពូកទី៣ ហិរញ្ញប្បទានសម្រាប់ការបិទ ការស្តារនីតិសម្បទា ការផ្តល់ដំណោះស្រាយ និងការស្តារឡើងវិញនៃសកម្មភាពដែលធ្វើឲ្យប៉ះពាល់បរិស្ថាន ........ ៣២៩

ជំពូកទី៤ បទប្បញ្ញត្តិផ្សេងៗទៀត ........ ៣៣២

**គន្ថីទី៩ បទល្មើសបរិស្ថាន និងធនធានធម្មជាតិ ........ ៣៣២**

មាតិកាទី១ នីតិវិធីដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ........ ៣៣៣

ជំពូកទី១ នីតិវិធីដោះស្រាយបណ្តឹងបរិស្ថាននិងធនធានធម្មជាតិដែលមានលក្ខណៈរដ្ឋប្បវេណីនិងរដ្ឋបាល ........ ៣៣៣

ផ្នែកទី១ បណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ........ ៣៣៣

ផ្នែកទី២ ភាគីនៃបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិ ..................................................... ៣៣៤

ផ្នែកទី៣ ការដោះស្រាយបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិក្រៅប្រព័ន្ធតុលាការ .................. ៣៣៦

ផ្នែកទី៤ ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិក្នុងប្រព័ន្ធតុលាការ........................ ៣៤៦

ជំពូកទី២ នីតិវិធីដោះស្រាយបទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលមានចរិកលក្ខណៈព្រហ្មទណ្ឌ .........
.................................................................................................................... ៣៥០

ផ្នែកទី១ នីតិវិធីនៃការស៊ើបអង្កេត ការស៊ើបសួរ ការចោទប្រកាន់ និងការជំនុំជម្រះ .................. ៣៥០

ផ្នែកទី២ ភស្តុតាងក្នុងរឿងក្ដីបរិស្ថាន និងធនធានធម្មជាតិ ................................................ ៣៥១

ផ្នែកទី៣ ការចាត់ចែងរក្សាការពារក្នុងរឿងក្ដីបរិស្ថាន និងធនធានធម្មជាតិ.............................. ៣៥៣

មាតិកាទី២ មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាននិងធនធានធម្មជាតិ មន្ត្រីការពារបេតិកភណ្ឌ និងមន្ត្រីអធិការកិច្ចបរិស្ថាន
.......................................................................................................................... ៣៥៦

ជំពូកទី១ មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ.................................................. ៣៥៦

ផ្នែកទី១ មន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ......................................... ៣៥៩

ផ្នែកទី២ មន្ត្រីនគរបាលយុត្តិធម៌នៃការប្រែប្រួលអាកាសធាតុ ............................................. ៣៦០

ផ្នែកទី៣ មន្ត្រីនគរបាលយុត្តិធម៌នៃរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលកំណត់ ឬ
បង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ.......................................................... ៣៦០

ផ្នែកទី៤ មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិចំពោះបទល្មើសសត្វព្រៃ............៣៦៣

ផ្នែកទី៥ មន្ត្រីនគរបាលយុត្តិធម៌ការពារបេតិកភណ្ឌ ......................................................... ៣៦៥

ជំពូកទី២ មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ........................................................ ៣៦៦

ផ្នែកទី១ បទប្បញ្ញត្តិទូទៅ .......................................................................................... ៣៦៦

ផ្នែកទី២ មន្ត្រីអធិការកិច្ចវាយតម្លៃហេតុប៉ះពាល់បរិស្ថាន.................................................. ៣៦៨

ផ្នែកទី៣ មន្ត្រីការពារបេតិកភណ្ឌ.................................................................................. ៣៦៩

ផ្នែកទី៤ មន្ត្រីអធិការកិច្ចការបំពុលបរិស្ថាន.................................................................... ៣៦៩

មាតិកាទី៣ ការស្តារឡើងវិញ និងសំណងលើការខូចខាតបរិស្ថាន ...... ៣៧៤

ជំពូកទី១ យន្តការវាយតម្លៃទំហំខូចខាតបរិស្ថាន ...... ៣៧៤

ជំពូកទី២ ការទទួលខុសត្រូវ ...... ៣៧៥

ជំពូកទី៣ ការការពារ និងករណីលើកលែងចំពោះការការពារ ...... ៣៧៦

ជំពូកទី៤ សំណងផ្នែកបរិស្ថាន ...... ៣៧៧

ជំពូកទី៥ ក្រុមការងាររៀបចំផែនការស្តារឡើងវិញ និងដំណើរការវាយតម្លៃសំណងការខូចខាត ...... ៣៨០

ជំពូកទី៦ លក្ខខណ្ឌតម្រូវនៃការទូទាត់ និងការចរចារអំពីការស្តារឡើងវិញ ...... ៣៨២

ជំពូកទី៧ សិទ្ធិអំណាចនៃការចេញបទបញ្ជាផ្នែករដ្ឋបាល ...... ៣៨៤

ជំពូកទី៨ សិទ្ធិអំណាចក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្នុងការប្រមូលថវិកាបង់ថ្លៃនៃការស្តារបរិស្ថានឡើងវិញ ...... ៣៨៤

មាតិកាទី៤ បទល្មើសបរិស្ថាន និងធនធានធម្មជាតិ ...... ៣៨៥

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ...... ៣៨៥

ជំពូកទី២ បទល្មើសពាក់ព័ន្ធនឹងការចូលរួមជាសាធារណៈ ...... ៣៨៩

ជំពូកទី៣ បទល្មើសពាក់ព័ន្ធនឹងការវាយតម្លៃហានិភ័យ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... ៣៩១

ជំពូកទី៤ បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន ...... ៣៩៨

ជំពូកទី៥ បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃធនធានធម្មជាតិ ...... ៤០០

ជំពូកទី៦ បទល្មើសពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌ ...... ៤០៨

ជំពូកទី៧ បទល្មើសពាក់ព័ន្ធនឹងសំណល់ និងការបំពុល ...... ៤០៩

ជំពូកទី៨ បទល្មើសពាក់ព័ន្ធវិធានការសេដ្ឋកិច្ច គណនី ថ្លៃ និងមូលនិធិផ្នែកបរិស្ថាន ...... ៤១៨

**គន្ថីទី១០ អន្តរប្បញ្ញត្តិ** ...... ៤១៩

ជំពូកទោល អន្តរប្បញ្ញត្តិ ...... ៤១៩

**គន្លឹទី១១ អវសានប្បញ្ញត្តិ**........................................................................................................ ៤២០

ជំពូកទោល អវសានប្បញ្ញត្តិ ............................................................................................ ៤២០

# គន្ថីទី១
# បទប្បញ្ញត្តិទូទៅ
## មាតិកាទី១
## បទប្បញ្ញត្តិទូទៅ
### ជំពូកទី១
### គោលដៅ គោលបំណង និងវិសាលភាព

**មាត្រា១** ._ គោលដៅ

ក្រមបរិស្ថាន និងធនធានធម្មជាតិនេះ មានគោលដៅ ក្នុងការជំរុញឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារបរិស្ថាន ការអភិរក្ស ការគ្រប់គ្រង និងការស្តារឡើងវិញនូវធនធានធម្មជាតិ និងវប្បធម៌ ។

**មាត្រា២** ._ គោលបំណង

ក្រមបរិស្ថាន និងធនធានធម្មជាតិមានគោលបំណង ដូចខាងក្រោម ៖

១- ការពារបរិស្ថាន បញ្ចៀស និងកាត់បន្ថយគ្រោះមហន្តរាយ និងការខូចខាតបរិស្ថាន។

២- ថែរក្សា គ្រប់គ្រង និងលើកស្ទួយជីវៈចម្រុះ ធនធានធម្មជាតិ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ។

៣- ថែរក្សា និងលើកកម្ពស់ធនធានវប្បធម៌ជាតិនៃព្រះរាជាណាចក្រកម្ពុជា ថែរក្សាវិមានបុរេប្រវត្តិសាស្ត្រ និងប្រវត្តិសាស្ត្រ និងវត្ថុបុរាណ និងបុរាណវត្ថុវិទ្យា ផ្ទៃខាងលើដី និងក្រោមដី ព្រមទាំងការពារ និងស្តារឡើងវិញនូវទីតាំងប្រវត្តិសាស្ត្រនានា ។

៤- ធានា និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

៥- លើកកម្ពស់ និងការពារសិទ្ធិបុគ្គល និងសម្ហភាព របស់ជនជាតិដើមភាគតិចក្នុងដំណើរការគ្រប់គ្រង ការពារ និងការអភិរក្សធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៦- ធានា និងដាក់បញ្ចូលយ៉ាងពេញលេញនូវកិច្ចគាំពារបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពទៅក្នុងផែនសេដ្ឋកិច្ចថ្នាក់ជាតិ និងថ្នាក់តំបន់ស្តីពីផែនការគ្រប់គ្រងធនធានធម្មជាតិ ។

៧- លើកទឹកចិត្ត និងលើកស្ទួយសិទ្ធិរបស់អង្គការជាតិ និងអន្តរជាតិ នៅក្នុងកិច្ចដំណើរការនៃការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៨- ធានាថា ការពិចារណាទាំងអស់ អំពីបរិស្ថាន ត្រូវបានដាក់បញ្ចូលយ៉ាងពេញលេញ ទៅក្នុងការរៀបចំផែនការ និងការធ្វើការសម្រេចចិត្តថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ។

៩- លើកកម្ពស់វិធីសាស្ត្រដែលមានការសហការគ្នា មានតម្លាភាព និងមានការចូលរួមសម្រាប់កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដោយមានការចូលរួមពីសំណាក់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សហគមន៍ អ្នកកាន់កាប់ដីធ្លី ជនជាតិដើមភាគតិច និងជនដែលងាយរងគ្រោះ មានជាអាទិ៍ ជនជាតិភាគតិច ស្ត្រី យុវជន ជនពិការ និងជនដែលគេមិនសូវយកចិត្តទុកដាក់ ។

១០- លើកកម្ពស់ការទទួលខុសត្រូវផ្នែកបរិស្ថានជាលក្ខណៈអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

១១- ពង្រឹងការអនុវត្តលិខិតតូបករណ៍គតិយុត្តអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាភាគីហត្ថលេខី និង

១១- អនុវត្តគោលការណ៍ច្បាប់សំខាន់ៗ និងគោលនយោបាយបរិស្ថាន ដូចមានចែងនៅក្នុងក្រមនេះ ។

**មាត្រា៣** ._ វិសាលភាព

ក្រមបរិស្ថាន និងធនធានធម្មជាតិ មានវិសាលភាពអនុវត្តលើរាល់សកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រមនេះមានវិសាលភាពអនុវត្តចំពោះគោលនយោបាយ ផែនការសកម្មភាព និងវិធានការនានាដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។

ក្រមនេះមានវិសាលភាពអនុវត្តផងដែរ លើរាល់សកម្មភាពរបស់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈ នីតិបុគ្គលឯកជនដែលធ្វើប្រតិបត្តិការទាំងក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា ដែលបង្កផលប៉ះពាល់ ឬជះឥទ្ធិពលទៅលើបរិស្ថាន ឬធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

ក្រមនេះក៏ប្រើប្រាស់ជាមូលដ្ឋាន ដើម្បីអនុវត្តតាមខ្លឹមសារសិទ្ធិសញ្ញាអន្តរជាតិ ឬកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

**មាត្រា៤** ._ កាតព្វកិច្ចបញ្ចៀសការខូចខាតបរិស្ថាន

រូបវន្តបុគ្គល ឬ នីតិបុគ្គល មិនត្រូវចាប់ផ្ដើមសកម្មភាពណាមួយ ដែលបង្ក ឬ ទំនងជាបង្ក ការខូចខាតបរិស្ថាន ឬ លើកលែងតែរូបវន្តបុគ្គល ឬ នីតិបុគ្គលនោះ ចាត់វិធានការសមហេតុផល ក្នុងការ

ការពារបរិស្ថាន និងធនធានធម្មជាតិ និងការពារ ឬ កាត់បន្ថយការខូចខាតបរិស្ថាននោះឱ្យដល់កម្រិតអប្បបរមា ។

## ជំពូកទី២
## គោលការណ៍ទូទៅ

**មាត្រា៥** ._ គោលការណ៍នៃការចូលរួមជាសាធារណៈ

បុគ្គលទាំងឡាយណា ដែលអាចទទួលរងនូវផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោលដោយសារការសម្រេចចិត្តណាមួយទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិចូលរួមផ្តល់មតិយោបល់ទាន់ពេលវេលា និងបន្ទាប់ពីទទួលបានព័ត៌មាន មុនពេលដែលការសម្រេចចិត្តនោះត្រូវបានធ្វើឡើងតាមរយៈដំណើរការមួយ ប្រកបដោយតម្លាភាព ការចូលរួម និងគណនេយ្យភាព ។

**មាត្រា៦** ._ គោលការណ៍នៃការទទួលបានព័ត៌មានបរិស្ថាន

រូបវន្តបុគ្គល នីតិបុគ្គលទាំងអស់ មានសិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ ។

រាល់ព័ត៌មានស្តីពីការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ត្រូវធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់សាធារណជន ដើម្បីបង្កើតឱកាសជាអតិបរមា សម្រាប់ការចូលរួមជាសាធារណៈនៅក្នុងការធ្វើផែនការ និងការសម្រេចចិត្ត ដែលបង្កផលប៉ះពាល់ដល់សង្គម និងបរិស្ថាន ។

**មាត្រា៧** ._ គោលការណ៍នៃការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព

រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងអស់ មានសិទ្ធិទទួលបាននូវដំណោះស្រាយផ្នែករដ្ឋបាល និងផ្នែកតុលាការ ឬក៏មធ្យោបាយសមស្របដទៃទៀត ដើម្បីសម្រេចបាននូវការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ប្រកបដោយប្រសិទ្ធភាព ។

ត្រូវបង្កើតឲ្យមានយន្តការ និងនីតិវិធីដោះស្រាយវិវាទមួយ ប្រកបដោយប្រសិទ្ធភាព និងមិនលម្អៀង ដើម្បីពង្រឹងនូវសិទ្ធិខាងផ្នែកនីតិវិធី លើកកម្ពស់ការអនុលោមតាមច្បាប់ និងដាក់ទណ្ឌកម្មដល់ជនទាំងឡាយណា ដែលបង្កការខូចខាតដល់បរិស្ថាន សង្គម និងធនធានធម្មជាតិ ។

**មាត្រា៨** ._ គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល

រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ ដែលបានបង្កឲ្យមានការខូចខាតចំពោះបរិស្ថាន និងសង្គម ត្រូវទទួលបន្ទុកក្នុងការចំណាយលើការជួសជុល និងលើវិធានការទប់ស្កាត់ បញ្ចៀស និងកាត់បន្ថយការខូចខាតបរិស្ថាន និងសង្គម ។

**មាត្រា៩** ._ គោលការណ៍ប្រុងប្រយ័ត្នជាមុន

ក្នុងស្ថានភាពដែលបរិស្ថានអាចប្រឈមនឹងការគំរាមកំហែងនៃការខូចខាតយ៉ាងធ្ងន់ធ្ងរ ដែលមិនអាចជួសជុលឲ្យដូចដើមវិញបាន នោះកង្វះខាតនូវភាពប្រាកដប្រជាពេញលេញផ្នែកវិទ្យាសាស្ត្រ មិនត្រូវយកមកប្រើប្រាស់ជាមូលហេតុ ក្នុងការពន្យារការចាត់វិធានការ ក្នុងការ ទប់ស្កាត់នូវការធ្វើឲ្យខូចខាតដល់បរិស្ថានបានឡើយ ។

**មាត្រា១០** ._គោលការណ៍នៃការទប់ស្កាត់

ត្រូវចាត់វិធានការដើម្បីកាត់បន្ថយ ឬទប់ស្កាត់ ការខូចខាតដល់បរិស្ថាន មុនពេលការខូចខាតនោះកើតមានឡើង តាមរយៈការទប់ស្កាត់ជាជាងការប៉ុនប៉ងក្នុងការជួសជុលនូវការខូចខាតណាមួយ ដែលមិនអាចធ្វើឱ្យដូចដើមវិញបាន ដែលអាចកើតឡើង ។

**មាត្រា១១** ._ គោលការណ៍សមធម៌រវាងជំនាន់បច្ចុប្បន្ន និងអនាគត

សិទ្ធិក្នុងការធ្វើការអភិវឌ្ឍ មានជាអាទិ៍ ការសម្រេចចិត្តនានា ដែលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ ត្រូវតែអនុវត្តឲ្យបាន ដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍ ក៏ដូចជាតម្រូវការសង្គម និងបរិស្ថាន របស់មនុស្ស ទាំងក្នុងជំនាន់បច្ចុប្បន្ន និងអនាគត ប្រកបដោយលក្ខណៈសមធម៌ ។

**មាត្រា១២** ._ គោលការណ៍ គ្មានការខាតបង់សុទ្ធ

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងរូបវន្តបុគ្គល និងនីតិបុគ្គលទាំងអស់ ត្រូវធានាថា សកម្មភាពរបស់ខ្លួនមិនបណ្តាលឱ្យមានការខាតបង់សុទ្ធណាមួយ នៃសន្និធិធនធានធម្មជាតិ ដែលមានជីវិត និងដែលទាក់ទងនឹងលំហូរនៃទំនិញ និងសេវាកម្មនានា របស់ព្រះរាជាណាចក្រកម្ពុជា នោះឡើយ ។ នៅក្នុងករណីដែលមានការខាតបង់កើតឡើង ការខាតបង់ទាំងនេះត្រូវកាត់បន្ថយ តាមរយៈសកម្មភាពដែលសម្រេចបាននូវផលចំណេញសមមូលខាងផ្នែកអេកូឡូស៊ី នៅក្នុងតំបន់មួយទៀត ។

**មាត្រា១៣** ._ គោលការណ៍ នៃការធ្វើការសម្រេចចិត្តដោយផ្អែកលើភស្តុតាង

ការធ្វើការសម្រេចចិត្តទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានមានតម្លាភាព និងផ្អែកលើភស្តុតាងជាមូលដ្ឋាន ដោយប្រើប្រាស់ព័ត៌មានដ៏ប្រសើរបំផុតដែលអាចស្វែងរកបាន ។ ព័ត៌មានទាំងនោះ អាចមានលក្ខណៈវិទ្យាសាស្ត្រ ឬបច្ចេកទេស និងអាចជាទិន្នន័យដែលប្រមូលបានមកពីសហគមន៍ និងចំណេះដឹងរបស់ជនជាតិដើមម្ចាស់ស្រុកផងដែរ ។

**មាត្រា១៤**._ គោលការណ៍ សមភាពយេនឌ័រក្នុងការការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ

សមធម៌យេនឌ័រ និងការចូលរួមរបស់ស្ត្រីនៅក្នុងរាល់ទិដ្ឋភាពទាំងអស់ទាក់ទងនឹងការសម្រេចចិត្តអំពីបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលបាននូវការលើកកម្ពស់ និងការលើកទឹកចិត្ត ។

**មាត្រា១៥**._ គោលការណ៍ ប្រយោជន៍សាធារណៈ

ផលប្រយោជន៍សាធារណៈ ត្រូវមានឧត្តមភាពជាងប្រយោជន៍បុគ្គលឯកជន ឬ នីតិបុគ្គលឯកជន នៅក្នុងគ្រប់ការសម្រេចចិត្តទាំងអស់ ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១៦**._ គោលការណ៍ សមាហរណកម្ម ឬការបញ្ជ្រាប

គោលបំណងនៃការការពារបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ត្រូវដាក់បញ្ចូលទៅក្នុងការរៀបចំផែនការអភិវឌ្ឍ និងការធ្វើការសម្រេចចិត្ត ដែលតម្រូវឲ្យមានការដាក់បញ្ចូលនូវការការពារបរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ច និងសិទ្ធិខាងផ្នែកបរិស្ថាន ទៅក្នុងដំណាក់កាលផ្តួចផ្តើមដំបូងនៃការធ្វើច្បាប់ និងគោលនយោបាយ និងដំណាក់កាលនៃការអនុវត្តគោលនយោបាយ និងច្បាប់ផងដែរ។

**មាត្រា១៧**._ គោលការណ៍ អ្នកប្រើប្រាស់ជាអ្នកបង់ថ្លៃ

អ្នកប្រើប្រាស់ធនធានធម្មជាតិ ត្រូវបង់ថ្លៃចំណាយដោយផ្ទាល់ ឬប្រយោល សម្រាប់ការប្រើប្រាស់ ឬផលប៉ះពាល់ ដែលកើតចេញពីការប្រើប្រាស់ធនធានធម្មជាតិ ។

**មាត្រា១៨**._ គោលការណ៍ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ សម្រាប់សហគមន៍ជនជាតិដើមភាគតិច

សកម្មភាព ឬ គម្រោងដែលស្នើសុំ ដែលអាចប៉ះពាល់ដល់ដីធ្លី ឬធនធានដទៃទៀត ជាពិសេស ដែលទាក់ទងទៅនឹងការអភិវឌ្ឍ ការប្រើប្រាស់ និងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ត្រូវទទួលនូវការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ របស់ជនជាតិដើមភាគតិច ។

## ជំពូកទី៣
## សមត្ថកិច្ចក្រសួង ស្ថាប័នពាក់ព័ន្ធវិស័យបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ

**មាត្រា១៩ .**_ វិសាលភាពនៃការអនុវត្តសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច

ក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ត្រូវមានសិទ្ធិអំណាចក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនដូចមានចែងក្នុងក្រមនេះ និង លិខិតបទដ្ឋានគតិយុត្តតាមវិស័យនីមួយៗផ្សេងទៀតរបស់ខ្លួនផងដែរ ។

ក្នុងករណីដែលមានបទប្បញ្ញត្តិនៃក្រមនេះចែងអំពីការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននីមួយៗ មិនស្របគ្នា ឬមានភាពមិនច្បាស់លាស់ជាមួយនឹងលិខិតបទដ្ឋានគតិយុត្តពិសេសដោយឡែកនីមួយៗផ្សេងទៀត បទប្បញ្ញត្តិដែលមានចែងក្នុងក្រមនេះ ត្រូវយកមកបកស្រាយ និងត្រូវមានឧត្តមានុភាពជាង ។

**មាត្រា២០ .**_ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចធ្វើការពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិទាំងអស់ ត្រូវមានកាតព្វកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម៖

១- អនុវត្តការទទួលខុសត្រូវ និងកាតព្វកិច្ច ក្នុងការអនុវត្តបទប្បញ្ញត្តិនៃក្រមនេះ

២- ចាត់វិធានការចាំបាច់នានា ក្នុងការដោះដូរព័ត៌មាននានា ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

៣- កសាងសមត្ថភាព និងការយល់ដឹងដល់បុគ្គលិកក្រោមចំណុះរបស់ខ្លួនឲ្យមានការយល់ដឹងអំពីខ្លឹមសារនៃក្រមនេះ ។

៤- លើកកម្ពស់ឲ្យមានប្រសិទ្ធភាពចំពោះសិទ្ធិទទួលបានព័ត៌មានបរិស្ថាន និងការចូលរួមជាសាធារណៈពាក់ព័ន្ធវិស័យបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ។

៥- រៀបចំយន្តការដោះស្រាយវិវាទ និងផ្តល់ដំណោះស្រាយចំពោះបណ្តឹងពាក់ព័ន្ធ នឹងបរិស្ថាន និងធនធានធម្មជាតិ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួននិងគ្រប់គ្រងធនធានធម្មជាតិក្នុងករណីដែលក្រមនេះ និង លិខិតបទដ្ឋានគតិយុត្តដទៃទៀត បានផ្តល់អំណាចឲ្យ ។

៦- សម្របសម្រួលចំពោះការរៀបចំផែនការ ការដាក់ចេញកម្មវិធី ការសម្រេចចិត្ត និងការអនុវត្តនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីធានាថាគ្រប់សកម្មភាពទាំងអស់ស្របទៅតាម គោលបំណងនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងក្រមនេះ ។

## មាតិកាទី២
## ការចូលរួមជាសាធារណៈ
## ជំពូកទី១
## សិទ្ធិ និងការការពារ សម្រាប់ការចូលរួមជាសាធារណៈ

**មាត្រា២១ ._** សិទ្ធិក្នុងការចូលរួមជាសាធារណៈ

រូបវន្តបុគ្គលគ្រប់រូប មានសិទ្ធិក្នុងការចូលរួមជាសាធារណៈតាមរយៈដូចខាងក្រោម ។ រូបវន្តបុគ្គលគ្រប់រូប អាចអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការចូលរួមសាធារណៈ តាមរយៈ ៖

១- រាយការណ៍ទៅកាន់អាជ្ញាធរពាក់ព័ន្ធ និងផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាព ឬការសម្រេចចិត្តណាមួយ ដែលអាចនឹងមានផលប៉ះពាល់ទៅលើបរិស្ថាន និងធនធានធម្មជាតិ ។

២- លើកឡើងនូវសំណួរ និងស្នើឲ្យមានការបញ្ជាក់ឲ្យច្បាស់អំពីការជំទាស់ និងការជួបប្រជុំ ដើម្បីពិភាក្សា ដោយគ្មានអំពើហិង្សា អំពីសកម្មភាព ឬ សេចក្តីសម្រេចណាមួយ ដែលអាចប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ និង

៣- ដាក់ពាក្យបណ្តឹង ឬណ្តឹងជំទាស់ទៅនឹងសកម្មភាព ឬសេចក្តីសម្រេច ទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមការងារដោះស្រាយវិវាទបរិស្ថាន ឬតុលាការមានសមត្ថកិច្ច ស្របទៅតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងគន្ថីទី៩នៃក្រមនេះ ។

**មាត្រា២២ ._** សិទ្ធិទទួលបានការការពារចំពោះការគំរាមកំហែង និងការសងសិក

បុគ្គលគ្រប់រូបដែលអនុវត្តសិទ្ធិក្នុងការចូលរួមជាសាធារណៈដូចមានចែងក្នុងមាត្រា២១ខាងលើ ត្រូវរួចផុតពីការគំរាមកំហែង និងការសងសឹកតាមគ្រប់មធ្យោបាយនានា ។ រាល់សកម្មភាពក្នុងការចូលរួមជាសាធារណៈដែលស្របតាមមាតិកានេះ មិនត្រូវទទួលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬប្រឈមនឹងបណ្តឹងទាមទារផ្នែករដ្ឋប្បវេណីណាមួយឡើយ ។

សិទ្ធិក្នុងការទទួលបានការការពារពីការគំរាមកំហែង ឬ ការសងសឹក ចំពោះការចូលរួមជាសាធារណៈ មិនត្រូវរួចផុតពីការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬបណ្តឹងទាមទារផ្នែករដ្ឋប្បវេណីឡើយ ក្នុងករណីដែលបុគ្គលដែលបានចូលរួមជាសាធារណៈប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយដូចមានចែងក្នុងក្រមនេះ ឬក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឬបង្កឲ្យមានអំពើអនីត្យានុកូលណាមួយ ដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២៣ ._** លក្ខណៈវិនិច្ឆ័យសម្រាប់ការចូលរួមជាសាធារណៈ

គ្រប់ម្ចាស់គម្រោងទាំងអស់ និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវធានាថា កិច្ចដំណើរការចូលរួមជាសាធារណៈ សម្រាប់រាល់សកម្មភាព ឬវិធានការ ដែលមានជាអាទិ៍ វិធានការរដ្ឋបាល កិច្ចព្រមព្រៀងបរិស្ថាន គោលនយោបាយដែលបានស្នើសុំ កម្មវិធី គម្រោង ផែនការ សកម្មភាព ឬការសម្រេចចិត្ត ឬ ការបង្កើតច្បាប់ និងលិខិតបទដ្ឋាន ដែលទាក់ទងទៅនឹងបញ្ហាណាមួយ ដែលមានចែងក្នុងក្រមនេះ ត្រូវធ្វើឡើងស្របតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

ក- ការជូនដំណឹងដំបូង៖ ម្ចាស់គម្រោង និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវធានាថា ការជូនដំណឹងជាសាធារណៈ ត្រូវបានធ្វើឡើង នៅក្នុងលក្ខណៈមួយដែលនឹងអនុញ្ញាតឱ្យមានពេលវេលាគ្រប់គ្រាន់ សម្រាប់ការចូលរួមជាសាធារណៈ នៅក្នុងកិច្ចដំណើរការនៃការធ្វើការសម្រេចចិត្តដែលពាក់ព័ន្ធ ។

ខ- ព័ត៌មានដែលអាចទទួលបាន៖ ម្ចាស់គម្រោង និងក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវផ្តល់ព័ត៌មានដែលចាំបាច់ ទៅកាន់អ្នកចូលរួមដែលមានការចាប់អារម្មណ៍ ឲ្យបានទាន់ពេលវេលា ដើម្បីឲ្យអ្នកចូលរួមទាំងនោះបានចូលរួម ក្នុងដំណើរការធ្វើការសម្រេចចិត្តដែលពាក់ព័ន្ធ ត្រូវធ្វើការពិចារណាលើផ្នែកភាសាដែលសមរម្យ សម្រាប់ព័ត៌មាននេះ និងតម្រូវការក្នុងការប្រើប្រាស់ មធ្យោបាយដែលមានលក្ខណៈរសើបខាងផ្នែកវប្បធម៌ ។

គ- ការចែករំលែកចំណេះដឹង៖ ម្ចាស់គម្រោងឬ ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបង្កើតគម្រោង ផែនការ សកម្មភាព ឬការសម្រេចចិត្ត មានជាអាទិ៍ ការបង្កើតគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដោយឈរលើមូលដ្ឋាននៃចំណេះដឹងខាងផ្នែកបច្ចេកទេស វិទ្យាសាស្ត្រ ចំណេះដឹងសហគមន៍ និងប្រពៃណីជនជាតិដើមភាគតិច ។ ចំណេះដឹង កង្វល់ តម្លៃ និងទស្សនៈទាំងឡាយ ត្រូវមានការចែករំលែក ដោយបើកចំហ ដោយគោរព និងទាន់ពេលវេលា ។ ការចែករំលែកចំណេះដឹងទាំងនេះ ក៏ត្រូវរាប់បញ្ចូលទាំងព័ត៌មានស្តីពីផលវិបាកនានាពេលខាងមុខ នៃគម្រោង ផែនការ សកម្មភាព ឬការសម្រេចចិត្តផងដែរ ។

ឃ- ភាពប្រែប្រួលចំពោះតម្លៃសហគមន៍៖ ម្ចាស់គម្រោង និងក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តដំណើរការនៃការចូលរួមជាសាធារណៈ ដោយគោរពទៅតាមតម្រូវការ និងតម្លៃនៃសហគមន៍ផ្សេងៗដែលបានចូលរួម ។

ង- ការកំណត់ពេលវេលាសមរម្យ៖ ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវផ្តល់ឲ្យសាធារណជននូវពេលវេលាដែលសមរម្យ និងប្រកបដោយយុត្តិធម៌ ដើម្បីធ្វើការវាយតម្លៃ និងដើម្បីធ្វើការឆ្លើយតបទៅលើព័ត៌មានដែលបានផ្តល់ឲ្យអំពីគម្រោងដែលបានស្នើ សកម្មភាព ឬការសម្រេចចិត្ត មានជាអាទិ៍ ការបង្កើតគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ។

ច- កម្រិតត្រឹមត្រូវនៃការចូលរួម ៖ ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវផ្តល់ជូននូវកម្រិតនៃការចូលរួម ដែលប្រហាក់ប្រហែលគ្នាទៅតាមទំហំនៃផលប្រយោជន៍សាធារណៈ ។

ឆ- ដំណើរការដែលអាចកែសម្រួលបាន៖ គ្រប់ដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវមានភាពបត់បែន និងអាចកែសម្រួលបាន ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុកដែលសមហេតុផលរបស់អ្នកចូលរួម ។ ម្ចាស់គម្រោង និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវរចនា អនុវត្ត និង កែសម្រួលដំណើរការនៃការចូលរួមជាសាធារណៈ តាមភាពចាំបាច់ដើម្បីបំពេញតម្រូវការ និងកាលៈទេសៈរបស់គម្រោង ផែនការ សកម្មភាព ឬការសម្រេចចិត្តណាមួយ និងដើម្បីឆ្លុះបញ្ចាំងអំពីតម្រូវការ និងការបង្ហាញនូវការពេញចិត្តរបស់អ្នកចូលរួម ។

ជ-លទ្ធផលដែលមានតម្លាភាព៖ គ្រប់មតិយោបល់របស់សាធារណជន ត្រូវមានការពិចារណា នៅក្នុងដំណើរការនៃការសម្រេច ។ នៅក្នុងដំណាក់កាលចុងក្រោយនៃដំណើរការនៃការចូលរួមជាសាធារណៈ ម្ចាស់គម្រោងទាំងអស់ និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវផ្តល់ព័ត៌មាន និងហេតុផល ចំពោះការពិចារណា ឬមិនពិចារណាលើធាតុចូលរបស់សាធារណជន និងដែលប៉ះពាល់ ដល់ការសម្រេចចិត្តចុងក្រោយ ។

**មាត្រា២៤** ._ លក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ

មុននឹងធ្វើការសម្រេចចិត្ត ឬឯកភាពណាមួយ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃក្រមនេះ ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវយល់ស្របថាការចូលរួមជាសាធារណៈដែលពេញលេញ បានកើតមានឡើងដូចខាងក្រោម៖

ក- ព័ត៌មានដែលពាក់ព័ន្ធទាំងអស់ត្រូវបានលើកបង្ហាញតាមមធ្យោបាយសមស្រប ដោយស្របទៅនឹងតម្រូវការរបស់អ្នកពាក់ព័ន្ធ ។

ខ- អ្នកពាក់ព័ន្ធមានពេលវេលា និងឱកាសគ្រប់គ្រាន់ក្នុងការពិចារណាទៅលើព័ត៌មានពាក់ព័ន្ធនេះ ។

គ- អ្នកពាក់ព័ន្ធអាចដាក់ជូនមតិយោបល់ ធាតុចូល និងសំណូមពរនានា ទៅកាន់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ មុននឹង ការសម្រេចចិត្ត ឬការឯកភាព ត្រូវបានឡើង ។

ឃ- ក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធបានដោះស្រាយទៅលើមតិយោបល់ ធាតុចូល និងសំណូមពរនានានេះដែលធ្វើឡើងដោយអ្នកពាក់ព័ន្ធ ។

ង- ការចូលរួមជាសាធារណៈត្រូវមានលក្ខណៈសមស្រប និងដើម្បីធ្វើការសម្រេចចិត្ត ឬការផ្តល់ការឯកភាពណាមួយ ។

**មាត្រា២៥ ._** នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការចូលរួមសាធារណៈ ។ ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ ទាក់ទងនឹងវិស័យនីមួយរបស់ខ្លួន ស្របតាម បទប្បញ្ញត្តិនៅក្នុងមាតិកានេះ ។

## ជំពូកទី២
## ការចូលរួមជាសាធារណៈរបស់សហគមន៍ជនជាតិដើមភាគតិច នៅក្នុងការសម្រេចចិត្តអំពីបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា២៦ ._** ការចូលរួមប្រកបដោយប្រសិទ្ធភាពនៃជនជាតិដើមភាគតិច

ម្ចាស់គម្រោង ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ឱកាសឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ជនជាតិដើមភាគតិច ដែលអាចទទួលរងផលប៉ះពាល់ដោយសេចក្តីសម្រេចទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ និងត្រូវតែទទួលបាននូវការយល់ព្រមដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ពួកគេ មុនពេលដែលសេចក្តីសម្រេចនោះត្រូវបានធ្វើឡើង ។ ការចូលរួមត្រូវតែផ្តល់ជូនឱ្យបានទាន់ពេលវេលា ហើយអ្នកចូលរួមត្រូវទទួលបានការជូនដំណឹងពេញលេញអំពីព័ត៌មានពាក់ព័ន្ធទាំងអស់ នៅក្នុងទម្រង់ និងភាសាដែលសមរម្យ ។

**មាត្រា២៧ ._** ការយល់ព្រមជាមុន ដោយសេរី

ក្រសួង ស្ថាប័នពាក់ព័ន្ធ មិនត្រូវឯកភាពលើផែនការ កម្មវិធី ឬ សំណើរគម្រោង ដែលអាចប៉ះពាល់ដល់ជនជាតិដើមភាគតិច ដោយគ្មានការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ជនជាតិដើមភាគតិចបានឡើយ ។

**មាត្រា២៨ ._** នីតិវិធីសម្រាប់ការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិច

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតឧបករណ៍គតិយុត្តស្តីពីនីតិវិធីសម្រាប់ការពិគ្រោះយោបល់ និងការចូលរួមជាសាធារណៈរបស់ជនជាតិដើមភាគតិច នៅក្នុងការសម្រេចចិត្ត ដែលប៉ះពាល់ដល់ដី និងសហគមន៍របស់ជនជាតិដើមភាគតិច ។

## ជំពូកទី៣
## វិធានការកាត់បន្ថយ

**មាត្រា២៩ ._** លក្ខខណ្ឌតម្រូវសម្រាប់វិធានការកាត់បន្ថយផលប៉ះពាល់

ប្រសិនបើវិធានការកាត់បន្ថយ មានសារៈសំខាន់សម្រាប់ការសម្រេចចិត្តណាមួយ ដែលនឹងជះឥទ្ធិពលជាសំខាន់ទៅលើសហគមន៍មូលដ្ឋាន នោះម្ចាស់គម្រោង និងក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវៈ

ក- ពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ ដើម្បីកំណត់ឲ្យច្បាស់ពីផលប៉ះពាល់ និងយល់ព្រមទៅលើវិធានការណ៍កាត់បន្ថយ និងការចាត់ចែងបែងចែកផលប្រយោជន៍ ។

ខ- ធានាថា វិធានការកាត់បន្ថយមានលក្ខណៈសមរម្យ មាននិរន្តរភាព និងត្រូវបានគ្រប់គ្រងដោយការប្តេជ្ញាចំពោះការមិនរើសអើង មានជាអាទិ៍ ការរើសអើងអំពីយេនឌ័រ និងត្រូវធានាថាមានការយកចិត្តទុកដាក់ជាពិសេសចំពោះជនដែលងាយរងគ្រោះ និងជនដែលងាយរងហានិភ័យខ្ពស់ ពីផលប៉ះពាល់ដែលអាចកើតមានឡើងពីការសម្រេចចិត្តនោះ ។

**មាត្រា៣០ ._** ការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត

ការតាំងទីលំនៅថ្មីដោយមិនស្មគ្រ័ចិត្ត អាចតម្រូវឱ្យមាន ចំពោះគម្រោងស្នើសុំ ម្ចាស់គម្រោង និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវធានាថា សហគមន៍ដែលរងផលប៉ះពាល់ ត្រូវបានផ្តល់ឱកាសដើម្បីចូលរួមនៅ ក្នុងការពិចារណាទៅលើជម្រើសផ្សេងៗ ដើម្បីបញ្ចៀស ឬកាត់បន្ថយជាអប្បបរមានូវការតាំងទីលំនៅជាថ្មី ។ ឱកាសក្នុងការចូលរួមបែបនេះ ត្រូវតែរួចផុតពីការគំរាមកំហែង ការកេងចំណេញ និងការបង្ខិតបង្ខំ ។

**មាត្រា៣១ ._** ការរៀបចំផែនការការតាំងទីលំនៅថ្មី

ក្នុងករណីដែលការតាំងទីលំនៅថ្មី មិនអាចជៀសវាងបាន ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវធានាថា សហគមន៍ដែលរងផលប៉ះពាល់ ត្រូវបានផ្តល់នូវឱកាស នៅក្នុងការចូលរួមរៀបចំផែនការតាំងទីលំនៅថ្មី ដើម្បីៈ

- កាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ជាអវិជ្ជមាននៃការតាំងទីលំនៅថ្មី ។
- ធានាឱ្យបាននូវឱកាសសម្រាប់ជីវភាពរស់នៅនាពេលអនាគត និងការទទួលបានសេវាសង្គមស្មើនឹង ឬប្រសើរជាងលក្ខខណ្ឌ មុនពេលធ្វើការតាំងទីលំនៅថ្មី និង
- ធានាឱ្យបានថា សំណងដែលសងដោយម្ចាស់គម្រោង ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់ទ្រព្យដែលបាត់បង់ និងផលប៉ះពាល់ទៅលើជីវភាពរស់នៅ គឺមានភាពយុត្តិធម៌ សម

ធម៌ និងអាចទទួលយកបាន ហើយក្នុងកម្រិតអប្បបរមា ស្មើនឹងតម្លៃទីផ្សារបូករួមទាំងតម្លៃប្រតិបត្តិការ ។

## មាតិកាទី៣
## សិទ្ធិទទួលបានព័ត៌មានបរិស្ថាន
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៣២ .**_ កាតព្វកិច្ចក្នុងការបើកបង្ហាញ និងចែកចាយព័ត៌មាន

គ្រប់ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបើកបង្ហាញ និងដាក់ជូនរាល់ព័ត៌មានពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា៣៤ នៃក្រមនេះ ដើម្បីទទួលការពិនិត្យ នៅមុនពេលចេញសេចក្តីសម្រេចណាមួយដែលពាក់ព័ន្ធទៅនឹងបរិស្ថាន ឬធនធានធម្មជាតិ វិធានការផ្នែករដ្ឋបាល និងផ្នែកច្បាប់ ការព្រមព្រៀងផ្នែកបរិស្ថាន គោលនយោបាយដែលបានស្នើ កម្មវិធី ផែនការ សកម្មភាព ឬសេចក្តីសម្រេចផ្សេងទៀតស្របតាមក្រមនេះ ។

ព័ត៌មានបែបទាំងនេះត្រូវដាក់ជូន និងបើកបង្ហាញ ដើម្បីធានាបានថា គ្រប់អ្នកពាក់ព័ន្ធ ដូចជាជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ មានឱកាសចូលរួមប្រកបដោយប្រសិទ្ធភាព នៅក្នុងដំណើរការនៃការសម្រេចចិត្តដូចមានចែងក្នុងក្រមនេះ ។ ទម្រង់បែបបទ និងរបៀបនៃការបើកបង្ហាញព័ត៌មានត្រូវកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និង ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធដទៃទៀត ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីទម្រង់បែបបទ និងនីតិវិធីនៃការចែកចាយព័ត៌មាន ដែលត្រូវដាក់ឱ្យសាធារណៈជន អាចស្វែងរកបាន ។

**មាត្រា៣៣ .**_សិទ្ធិនៃការស្នើសុំព័ត៌មាន

រូបវន្តបុគ្គលគ្រប់រូបមានសិទ្ធិស្នើសុំរាល់ព័ត៌មានដែលពាក់ព័ន្ធទៅនឹងបញ្ហាទាំងឡាយដូចមានចែងក្នុងក្រមនេះ ស្របតាមមាត្រា៣៤ នៃក្រមនេះ ពីក្រសួង ស្ថាប័ន និងម្ចាស់គម្រោងដែលពាក់ព័ន្ធ ។ ម្ចាស់គម្រោង និងក្រសួង ស្ថាប័ន ត្រូវទទួលខុសត្រូវផ្តល់ព័ត៌មានដែលបានស្នើសុំដល់អ្នកស្នើសុំស្របតាមលក្ខខណ្ឌនៃការរក្សាជាការសម្ងាត់ ដូចមានចែងក្នុងជំពូកទី៣ នៃមាតិកានេះ ។

**មាត្រា៣៤ .**_ ព័ត៌មានពាក់ព័ន្ធ

ព័ត៌មានពាក់ព័ន្ធទៅនឹងបញ្ហាទាំងឡាយដូចមានចែងក្នុងក្រមនេះមានដូចខាងក្រោម៖

ក- ស្ថានភាពនៃធាតុផ្សំរបស់បរិស្ថាន រួមមាន ខ្យល់ បរិយាកាស ទឹក ដី ផ្ទៃដី តំបន់ទេសភាព និងតំបន់ធម្មជាតិ រួមមាន អាកាសធាតុ ការព្យាករណ៍អំពីអាកាសធាតុ តំបន់ដីសើម តំបន់សមុទ្រ និងតំបន់ឆ្នេរ ជីវៈចម្រុះ និងធាតុផ្សំនៃជីវៈចម្រុះ រួមមាន សារពាង្គកាយកែច្នៃហ្សែន និងអន្តរកម្មនៃធាតុផ្សំទាំងនេះ ។

ខ- កត្តានានា មានជាអាទិ៍ សារធាតុ ថាមពល សំឡេង វិទ្យុសកម្ម សំណល់ ដូចជា សំណល់វិទ្យុសកម្មជាដើម ការបំភាយឧស្ម័ន ការហៀរចេញ និងការបញ្ចេញចូលទៅក្នុងបរិស្ថាននានា ដែលប៉ះពាល់ ឬអាចនឹងប៉ះពាល់ដល់ធាតុផ្សំទាំងឡាយនៃបរិស្ថាន ។

គ- វិធានការ មានជាអាទិ៍ គោលនយោបាយ ច្បាប់ ផែនការ កម្មវិធី ការព្រមព្រៀងផ្នែកបរិស្ថាន និងសកម្មភាព ដែលប៉ះពាល់ ឬអាចនឹងប៉ះពាល់ដល់ធាតុផ្សំ និងកត្តានានា ដូចបានរៀបរាប់ខាងលើ ក៏ដូចជា វិធានការ និងសកម្មភាពនានា ដែលត្រូវបានតាក់តែងដើម្បីការពារធាតុផ្សំទាំងនោះ ។

ឃ- សនិទានភាពនៃវិធានការ មានជាអាទិ៍ ការវិភាគអំពីវដ្តជីវិត ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការវាយតម្លៃអំពីភាពងាយរងគ្រោះ ការវិភាគអំពីផលចំណេញ ក៏ដូចជា ការវិភាគ និងការសន្មតដទៃៗទៀត ។

ង- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត និងព័ត៌មាននានា ដែលតម្រូវដោយច្បាប់ មានជាអាទិ៍ របាយការណ៍ដែលម្ចាស់គម្រោងបានបង្កើតពាក់ព័ន្ធទៅនឹងកាតព្វកិច្ចនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ខ្លួន ព័ត៌មានអំពីការអនុលោមតាមការវាយតម្លៃបែបនេះ ដែលរួមមាន ការអង្កេតតាមដាន ការរៀបចំរបាយការណ៍ ការអនុវត្ត និងការបិទសកម្មភាពនានា រាល់ការឯកភាព និងលិខិតអនុញ្ញាត ក៏ដូចជា លក្ខខណ្ឌដូចបានភ្ជាប់ទៅនឹងការឯកភាព និងលិខិតអនុញ្ញាតទាំងនោះ និងលទ្ធផលរបស់គណៈកម្មការ ឬ ក្រុមការងារស៊ើបអង្កេតពីសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងធនធានធម្មជាតិ ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ច- ទំនាក់ទំនងផ្នែកមុខរបរ និងស្ថាប័ន របស់ម្ចាស់គម្រោង មានជាអាទិ៍ សហគ្រាសពាណិជ្ជកិច្ច ឬស្ថាបន័ផ្តល់កម្ចីជាតិ ឬអន្តរជាតិ ដទៃទៀត ដែលឧបត្ថម្ភដល់គម្រោង ឬសកម្មភាពដែលពាក់ព័ន្ធ ជាលក្ខណៈកម្ចីឥណទាន ឬជំនួយផ្នែកបច្ចេកទេស ។

ឆ- លក្ខខណ្ឌនៃការមិនអនុលោមតាម ឬការបំពានច្បាប់ គោលនយោបាយ លិខិតបទដ្ឋាន និងការព្រមព្រៀង អំពីបរិស្ថាន ។

ជ- គ្រប់របាយការណ៍អង្កេតតាមដាន និងសវនកម្មបរិស្ថាន ។

ឈ- ព័ត៌មានទាំងឡាយស្តីពីហានិភ័យនៃអាកាសធាតុ និងបរិស្ថាន ដែលប៉ះពាល់ដល់ស្ថានភាពនៃសុខភាព និងសុវត្ថិភាពរបស់មនុស្ស តំបន់វប្បធម៌ និងរចនាសម្ព័ន្ធនៃសំណង់នានា ។

ញ- ការវិភាគអំពីតម្លៃ និងគុណសម្បត្តិនានា ក៏ដូចជា សម្មតិកម្មផ្នែកសេដ្ឋកិច្ច ដែលប្រើក្នុងក្របខ័ណ្ឌនៃការសម្រេចចិត្ត និងសកម្មភាពដែលពាក់ព័ន្ធទៅនឹងកត្តា ធាតុផ្សំ និងវិធានការ ដូចមានចែងក្នុងចំណុច ក. ខ. និង គ. ខាងលើ ។

ដ- របាយការណ៍ស្តីពីការអនុវត្តវិធានការដូចបានរៀបរាប់ក្នុងចំណុច គ. ខាងលើ និងនៅក្នុងការអនុវត្តកិច្ចព្រមព្រៀងស្តីពីបរិស្ថានពហុភាគី ។

ឋ- ព័ត៌មានស្តីពីការទទួលបានចំណាត់ការលើនីតិវិធីផ្នែករដ្ឋបាល និងផ្នែកតុលាការពាក់ព័ន្ធទៅនឹងបញ្ហាបរិស្ថាន ។

ឌ- រាល់ព័ត៌មានផ្សេងទៀត ដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន កំណត់ថាជាព័ត៌មានដែលពាក់ព័ន្ធ ។

**មាត្រា៣៥** ._ ការកំណត់ថាជាព័ត៌មានសាធារណៈ

រាល់ព័ត៌មានពាក់ព័ន្ធដូចបានកំណត់ក្នុងមាត្រា៣៤ នៃមាតិកានេះ ដែលត្រូវផ្តល់ជូនទៅម្ចាស់គម្រោង ឬអង្គភាពរាជរដ្ឋាភិបាលដែលពាក់ព័ន្ធស្របតាមក្រមនេះ ត្រូវកំណត់ថាជាព័ត៌មានសាធារណៈ លើកលែងតែព័ត៌មាននោះ ត្រូវបានចាត់ទុកជាព័ត៌មានសម្ងាត់ ដូចមានចែងក្នុងជំពូកទី៣ នៃមាតិកានេះ ។

## ជំពូកទី២
## ការផ្តល់ព័ត៌មានដោយរាជរដ្ឋាភិបាល និងម្ចាស់គម្រោង
### ផ្នែកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៣៦** ._ សិទ្ធិទទួលបានព័ត៌មានពាក់ព័ន្ធជាសាធារណៈ

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវធានាឲ្យបាននូវការទទួលបានព័ត៌មានសាធារណៈដែលពាក់ព័ន្ធ ដូចបានកំណត់នៅក្នុងមាត្រា៣៤ នៃមាតិកានេះ ស្របតាមលក្ខខណ្ឌតម្រូវនៃកិច្ចព្រមព្រៀងពហុភាគី ច្បាប់ជាតិ និងកាតព្វកិច្ចពាក់ព័ន្ធដទៃៗទៀត ។

**មាត្រា៣៧** ._ ប្រព័ន្ធទទួលបានព័ត៌មានជាសាធារណៈ

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដោយមានការឧបត្ថម្ភពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង្កើតប្រព័ន្ធទទួលបានព័ត៌មានសាធារណៈ ដើម្បីផ្តល់ឲ្យសាធារណជននូវរាល់ព័ត៌មានសាធារណៈតាមការតម្រូវនៃក្រមនេះ ។

**មាត្រា៣៨** ._ នីតិវិធី ការកំណត់ពេលវេលា និងទម្រង់បែបបទនៃការចែកចាយព័ត៌មាន

គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ អាចបង្កើតនីតិវិធី ការកំណត់ពេលវេលានិងទម្រង់បែបបទ ដែលមានលក្ខណៈជាលិខិតបទដ្ឋានគតិយុត្ត ក្នុងការចែកចាយព័ត៌មានដែលពាក់ព័ន្ធ នៅលើប្រព័ន្ធទទួលបានព័ត៌មានជាសាធារណៈដែលពាក់ព័ន្ធ ។

**មាត្រា៣៩** ._ ដំណើរការនៃការទទួល និងការបញ្ចូលព័ត៌មាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើតដំណើរការមួយក្នុងការទទួល និងដាក់បញ្ចូលព័ត៌មានទាំងឡាយដែលទទួលបានពីសាធារណជន ពីប្រភពផ្សេងៗទៀត និងជាព័ត៌មានដែលត្រូវផ្តល់មកឲ្យអ្នកធ្វើការសម្រេចចិត្តថ្នាក់ជាតិ និងក្រោមជាតិផងដែរ ។

**មាត្រា៤០** ._ កាតព្វកិច្ចរបស់ម្ចាស់គម្រោង

ម្ចាស់គម្រោង ត្រូវធានាឱ្យមានការទទួលបានព័ត៌មានពាក់ព័ន្ធជាសាធារណៈ ដូចមានកំណត់នៅក្នុងមាត្រា៣៩ នៃមាតិកានេះ ទាក់ទងនឹងគម្រោង និងសកម្មភាពនានា ។ ម្ចាស់គម្រោង ដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃមាតិកានេះ ត្រូវដាក់ព័ត៌មានទាំងនេះឱ្យសាធារណៈជនអាចស្វែងរកបាន ចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយ តាមការស្នើសុំ ។

## ផ្នែកទី២
## បញ្ជីព័ត៌មានបរិស្ថានរដ្ឋ

**មាត្រា៤១** ._ ការបង្កើតបញ្ជីព័ត៌មានបរិស្ថានរដ្ឋ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតបញ្ជីព័ត៌មានបរិស្ថានរដ្ឋ ។

បញ្ជីព័ត៌មានបរិស្ថានរដ្ឋ ត្រូវដាក់ចូលនូវព័ត៌មាន ដែលបានផ្តល់ជូនមកក្រសួង ស្ថាប័ន ស្របតាមលក្ខខណ្ឌតម្រូវនៃក្រមនេះ ។

**មាត្រា៤២** ._ ការទទួលបានព័ត៌មានជាសាធារណៈ

បញ្ជីព័ត៌មានបរិស្ថានរដ្ឋ ត្រូវតែជាព័ត៌មាន ដែលសាធារណជនអាចស្វែងរកបាន ។

**មាត្រា៤៣** ._ ការទទួលខុសត្រូវ ការកំណត់ពេលវេលា និងនីតិវិធី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយ សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីការទទួលខុសត្រូវក្នុងការប្រមូលព័ត៌មានបរិស្ថាន និងការអង្កេតតាមដានផ្នែកបរិស្ថាន សម្រាប់គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ការកំណត់ពេលវេលា និងនីតិវិធីក្នុងការប្រមូល និងចែកចាយព័ត៌មាន ទៅតាមការតម្រូវឲ្យមានក្នុងបញ្ជីព័ត៌មានបរិស្ថានរដ្ឋ ។

## ផ្នែកទី៣
## បញ្ជីនៃលិខិតអនុញ្ញាត និងការឯកភាព

**មាត្រា៤៤** ._ ការបង្កើត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវបង្កើតបញ្ជីនៃលិខិតអនុញ្ញាត និងការឯកភាពនានា ។

**មាត្រា៤៥** ._ ប្រភេទនៃព័ត៌មាន

បញ្ជីនៃលិខិតអនុញ្ញាត និងការឯកភាពនានា ត្រូវដាក់បញ្ចូលនូវលិខិតអនុញ្ញាត អាជ្ញាបណ្ណ និងការឯកភាពទាំងអស់ ដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ស្របតាមក្រមនេះ ។

បញ្ជីនៃលិខិតអនុញ្ញាត និងការឯកភាពនានា ត្រូវដាក់បញ្ចូលនូវលិខិតអនុញ្ញាតទាំងអស់ ដែលតម្រូវឱ្យមាន ដើម្បីអាចអនុវត្តសកម្មភាព ឬ គម្រោងអភិវឌ្ឍ ដែលស្ថិតនៅក្រោមក្រមនេះ ព្រមទាំងលក្ខខណ្ឌពាក់ព័ន្ធនានាដែលភ្ជាប់ជាមួយនឹងលិខិតអនុញ្ញាតទាំងនោះ និងរបាយការណ៍អង្កេតតាមដាន ដែលតម្រូវឱ្យមាននៅក្រោមលិខិតអនុញ្ញាតទាំងនោះ ។

**មាត្រា៤៦** ._ ការស្វែងរកបានរបស់សាធារណៈជន

បញ្ជីនៃលិខិតអនុញ្ញាត និងការឯកភាព ត្រូវដាក់ឱ្យសាធារណៈជនអាចស្វែងរកបាន ។

**មាត្រា៤៧** ._ ទម្រង់បែបបទ ការកំណត់ពេលវេលា និង នីតិវិធី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីទម្រង់បែបបទ ការកំណត់ពេលវេលា និងនីតិវិធី សម្រាប់ការផ្សព្វផ្សាយព័ត៌មាន ដែលចាំបាច់ត្រូវដាក់ឱ្យសាធារណៈជនអាចស្វែងរកបាននៅលើបញ្ជីនៃលិខិតអនុញ្ញាត និងការឯកភាព ។

## ផ្នែកទី៤
## បញ្ជីសវនកម្មបរិស្ថាន

**មាត្រា៤៨** ._ ការបង្កើតបញ្ជីសវនកម្មបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវបង្កើតបញ្ជីសវនកម្មបរិស្ថាន ។

បញ្ជីសវនកម្មបរិស្ថាន ត្រូវបញ្ចូលគ្រប់សវនកម្មដែលតម្រូវឲ្យមានក្នុងការអនុវត្តសកម្មភាព ឬការអភិវឌ្ឍនានា ដូចមានចែងក្នុងក្រមនេះ និងរាល់លក្ខខណ្ឌដែលទាក់ទង ដូចមានភ្ជាប់ទៅនឹងលិខិតអនុញ្ញាត ។

**មាត្រា៤៩** ._ ការស្វែងរកបានជាសាធារណៈ

បញ្ជីសវនកម្មបរិស្ថាន ត្រូវតែជាព័ត៌មានដែលសាធារណជនអាចស្វែងរកបាន ។

**មាត្រា៥០** ._ ការទទួលខុសត្រូវ ការកំណត់ពេលវេលា និងនីតិវិធី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីទម្រង់បែបបទ ការកំណត់ពេលវេលា និងនីតិវិធីនៃការចែកចាយព័ត៌មាន ដែលត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាននៅលើបញ្ជីសវនកម្មបរិស្ថាន ។

## ផ្នែកទី៥
## មជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា

**មាត្រា៥១** ._ ការបង្កើតមជ្ឈមណ្ឌលផែនទីបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតមជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ។

**មាត្រា៥២** ._ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំមជ្ឈមណ្ឌលផែនទីបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុក រៀបចំ មជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ត្រូវ ៖

ក- ខិតខំចងក្រងទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី ព័ត៌មាន និងរបាយការណ៍អំពីធនធានធម្មជាតិ និងការកំណត់ទីតាំងជីវៈចម្រុះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលផលិតដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងគោលបំណងដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ព័ត៌មាន និងទិន្នន័យបរិស្ថាន ។ មជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ត្រូវដាក់ជូននូវទិន្នន័យ និងព័ត៌មានបែបទាំងនេះជាសាធារណៈដោយគ្មានការរឹតបន្តឹងឡើយ ។

ខ- ខិតខំរៀបចំគ្រប់ព័ត៌មានដែលផ្តល់ទៅឲ្យមជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជាសម្រាប់ការប្រើប្រាស់របស់សាធារណជន លើកលែងតែព័ត៌មានដែលក្រសួង ស្ថាប័ន ទទួលបន្ទុករៀបចំមជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា កំណត់ថាចាំបាច់ត្រូវរក្សាទុកសម្រាប់កិច្ចការពារប្រភេទសត្វកម្រ ឬងាយរងគ្រោះ កិច្ចការពារធនធានវប្បធម៌ ឬបញ្ហាសន្តិសុខជាតិ។ ករណីមានព័ត៌មានដែលត្រូវបានរក្សាជាការសម្ងាត់បែបនេះ ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំមជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ត្រូវផ្តល់ការពន្យល់ និងបកស្រាយជាលាយល័ក្ខអក្សរឲ្យបានជាក់លាក់ ។

គ- ផ្តល់ឱកាសធ្វើការសម្រេចចិត្តក្នុងការលាក់ទុកទិន្នន័យមិនឲ្យសាធារណជនដឹងឮដែលការនេះ ត្រូវមានការពិនិត្យដោយការិយាល័យនៃរដ្ឋមន្ត្រីទទួលបន្ទុក រៀបចំមជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ។ សេចក្តីសម្រេចរបស់រដ្ឋមន្ត្រី ត្រូវទទួលការពិនិត្យដោយក្រុមប្រឹក្សាដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

ឃ- រៀបចំស្តង់ដារនានាសម្រាប់ការប្រមូលព័ត៌មានថ្មីៗអំពីភូមិសាស្ត្រនៃការប្រើប្រាស់ដី និងការរក្សាទុកនូវទិន្នន័យដែលមានស្រាប់ ។

ង- តម្រូវឲ្យរាល់ព័ត៌មាន ត្រូវប្រគល់មកឲ្យមជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ត្រូវធ្វើតាមទម្រង់ស្តង់ដារបច្ចេកទេស ដែលកំណត់ដោយមជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ។

ច- តម្រូវឲ្យរាល់ទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដីដែលផ្តល់ទៅឲ្យមជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ត្រូវភ្ជាប់ទៅដោយបណ្តុំព័ត៌មានពាក់ព័ន្ធដែលមានស្រាប់ ។

ឆ- តម្រូវឲ្យរាល់ព័ត៌មានអំពីភូមិសាស្ត្រនៃការប្រើប្រាស់ដីដែលផ្តល់មកឲ្យមជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ត្រូវធានាថាមានគុណភាព និងជ- ធានាថា ព័ត៌មាន និងទិន្នន័យដែលប្រមូលបាន ពាក់ព័ន្ធទៅនឹងប្រធានបទ ឬវិស័យណាមួយ មិនមានការចម្លងជាឯកសារដើមរវាងអង្គភាពរាជរដ្ឋាភិបាលនោះទេ ហើយត្រូវមានប្រភពដែលជាអង្គភាពទទួលបន្ទុកជាផ្លូវការសម្រាប់ទិន្នន័យដែលផ្តល់មកទៅតាមប្រធានបទ ឬវិស័យនោះ ។

**មាត្រា៥៣** ._ ការទទួលខុសត្រូវដោយឆន្ទានុសិទ្ធិ

មជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ត្រូវមានសិទ្ធិដូចតទៅ៖

ក- ផលិតផែនទី និងផលិតផលទិន្នន័យជារូបភាព ហើយធ្វើការផ្តល់ជូននូវព័ត៌មានទាំងនោះ ទៅឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីសម្រួលដល់ការបំពេញតាមតួនាទី និងសមត្ថកិច្ចពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព ។

ខ- ផលិតផែនទី និងផលិតផលទិន្នន័យជារូបភាព សម្រាប់ការអប់រំ និងការផ្សព្វផ្សាយជាសាធារណៈ ក្នុងការលើកកម្ពស់ការយល់ដឹងអំពីការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

គ- បង្កើតនូវនីតិវិធីនៃការធានាបាននូវគុណភាព និងការគ្រប់គ្រងគុណភាព ទៅលើផែនទី និងផលិតផលទិន្នន័យជារូបភាព ដែលផលិតដោយមជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ។

ឃ- ផ្តល់ការថែទាំ ជួសជុល ធ្វើបច្ចុប្បន្នភាព និងការប្រើប្រាស់បាននូវប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃការប្រើប្រាស់ដីធ្លី ដែលបង្ហោះដោយមជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ។

ង- លើកកម្ពស់ ផលិតកម្មដោយសហការគ្នា ការប្រើប្រាស់ និងការវិភាគទៅលើទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដីធ្លី ពីចំណោមក្រសួងជាច្រើន ។

## ជំពូកទី៣
## ព័ត៌មានសម្ងាត់

**មាត្រា៥៤**._ សិទ្ធិស្នើសុំឲ្យមានការកំណត់ជាព័ត៌មានសម្ងាត់

រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធដូចត្រូវបានកំណត់ក្នុងមាត្រា៣៩ នៃក្រមនេះ ទៅកាន់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ដែលយល់ថាព័ត៌មានមួយចំនួន ឬព័ត៌មានទាំងអស់ គួរត្រូវបានកំណត់ថាជាព័ត៌មានសម្ងាត់ នោះមានសិទ្ធិស្នើសុំការកំណត់ជាព័ត៌មានសម្ងាត់ និងការលាក់ទុកមិនឲ្យមានការបើកបង្ហាញដល់សាធារណជន ។

**មាត្រា៥៥**._ ការស្នើសុំហេតុផល

រាល់ព័ត៌មានពាក់ព័ន្ធ ដែលត្រូវបានកំណត់ក្នុងមាត្រា៣៩ នៃក្រមនេះ ហើយត្រូវបានស្នើសុំឲ្យមានការកំណត់ជាព័ត៌មានសម្ងាត់ ត្រូវធ្វើការផ្តល់ឲ្យ ដោយឡែកពីព័ត៌មានផ្សេងទៀត ដោយភ្ជាប់មកជាមួយនូវការស្នើសុំទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយបញ្ជាក់ពីហេតុផលនានាសម្រាប់ការកំណត់ជាព័ត៌មានសម្ងាត់ ។

**មាត្រា៥៦** ._ ចំណុចពិចារណា

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានស្នើសុំឲ្យមានការកំណត់ព័ត៌មានជាព័ត៌មានសម្ងាត់ ត្រូវចង្អុលបង្ហាញពីចំណុចពិចារណាក្នុងការកំណត់ជាព័ត៌មានសម្ងាត់ និងត្រូវបង្ហាញថា ការខូចខាតនាពេលខាងមុខ ដែលបង្កដោយការបើកបង្ហាញព័ត៌មាន នឹងមានទំហំធំជាងប្រយោជន៍សាធារណៈដែលបានដោយការបើកបង្ហាញនូវព័ត៌មានទាំងនោះ ។

**មាត្រា៥៧** ._ ការកំណត់

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវពិចារណាអំពីសំណើឲ្យមានការកំណត់ជាព័ត៌មានសម្ងាត់ រួចធ្វើការកំណត់ថា យល់ព្រម ឬបដិសេធទៅលើសំណើ ក្នុងរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃ ។

**មាត្រា៥៨** ._ ព័ត៌មានសម្ងាត់

ក្នុងករណីដែលក្រសួង ស្ថាប័នពាក់ព័ន្ធ យល់ព្រមតាមការស្នើសុំឲ្យមានការកំណត់ជាព័ត៌មានសម្ងាត់ នោះព័ត៌មានទាំងនោះត្រូវមានស្លាកសម្គាល់ជាព័ត៌មានសម្ងាត់ ហើយមិនត្រូវមានការបញ្ចេញ និងមិនត្រូវមានការចែកចាយជាសាធារណៈនោះទេ ។

**មាត្រា៥៩** ._ សេចក្តីសម្រេចជាលាយល័ក្ខអក្សរ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចេញសេចក្តីសម្រេចជាលាយល័ក្ខអក្សរ ឆ្លើយតបទៅនឹងសំណើឲ្យមានការពិនិត្យឡើងវិញនូវព័ត៌មានដែលសម្រេចថាជាព័ត៌មានសម្ងាត់ មិនឲ្យលើសពី ៤៥(សែសិបប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលសំណើ ។ សេចក្តីសម្រេចជាលាយល័ក្ខអក្សរ ត្រូវមានហេតុផលត្រឹមត្រូវ និងត្រូវដាក់ជូនជាសាធារណៈបន្ទាប់ពីបានចេញរួចហើយ ។

## ជំពូកទី៤
## ការស្នើសុំព័ត៌មាន

**មាត្រា៦០** ._ សិទ្ធិស្នើសុំព័ត៌មានសាធារណៈ

រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់រូប ត្រូវមានសិទ្ធិធ្វើការស្នើសុំទៅកាន់ម្ចាស់គម្រោង ឬក្រសួងស្ថាប័នពាក់ព័ន្ធ ឲ្យផ្តល់ជូនព័ត៌មានពាក់ព័ន្ធ ដូចបានកំណត់ក្នុងមាត្រា៣៤ នៃក្រមនេះ លើកលែងតែព័ត៌មាននោះត្រូវបានកំណត់ថាជាព័ត៌មានសម្ងាត់ ។

**មាត្រា៦១** ._ លក្ខខណ្ឌរបស់ក្រសួង ស្ថាប័ន ក្នុងការបដិសេធសំណើ

ក្រសួង ស្ថាប័នពាក់ព័ន្ធ មានសិទ្ធិបដិសេធការស្នើសុំព័ត៌មាន ក្នុងករណីៈ

១- មិនមានព័ត៌មានដែលបានស្នើសុំ

២- សំណើមិនមានហេតុផលត្រឹមត្រូវ ឬ

៣- សំណើដែលមានទម្រង់ទូលំទូលាយពេក ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ មិនត្រូវបដិសេធសំណើសុំព័ត៌មាននោះទេ ក្នុងករណីដែលសំណើរដែលបានស្នើសុំ ត្រូវបានផ្តល់ឲ្យកាលពីមុនរួចហើយ ឬមិនទាន់ត្រូវបានកំណត់ថា ជាព័ត៌មានសម្ងាត់នៅឡើយ ។

នៅក្នុងករណីក្រសួង ស្ថាប័នពាក់ព័ន្ធ បដិសេធលើសំណើក្នុងការបើកបង្ហាញព័ត៌មាន ស្របតាមមាត្រានេះ ក្រសួង ស្ថាប័ននោះ ត្រូវផ្តល់ហេតុផលជាលាយល័ក្ខអក្សរទៅកាន់អ្នកស្នើសុំ ។

**មាត្រា៦២** ._ លក្ខខណ្ឌរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលក្នុងការបដិសេធសំណើ

ក្នុងករណីរូបវន្តបុគ្គល ឬនីតិបុគ្គល ធ្វើការស្នើសុំឲ្យមានការបើកបង្ហាញព័ត៌មាន មកកាន់ម្ចាស់គម្រោងស្របតាមជំពូកនេះ នោះម្ចាស់គម្រោង អាចបដិសេធក្នុងការបើកបង្ហាញព័ត៌មាន នៅក្នុងករណីដែលៈ

ក- ខ្លួនមិនមានព័ត៌មានដែលបានស្នើសុំ

ខ- សំណើមិនមានហេតុផលត្រឹមត្រូវ ឬ

គ- សំណើដែលមានទម្រង់ទូលំទូលាយពេក ។

ម្ចាស់គម្រោងមិនត្រូវធ្វើការបដិសធការស្នើសុំព័ត៌មាននោះទេ  ករណីដែលព័ត៌មានដែលបានស្នើសុំ ត្រូវបានផ្តល់ជូនពីមុនរួចហើយ ឬត្រូវបានកំណត់ថា មិនមែនជាព័តិសម្ងាត់ ។

ក្នុងករណីម្ចាស់គម្រោងបដិសេធលើសំណើក្នុងការបើកបង្ហាញព័ត៌មាន ដែលត្រូវបានកំណត់ក្នុងមាត្រានេះ នោះត្រូវផ្តល់ហេតុផលជាលាយល័ក្ខអក្សរទៅកាន់អ្នកស្នើសុំ ។

**មាត្រា៦៣** ._ នីតិវិធី ការកំណត់ពេលវេលា និងទម្រង់បែបបទ

ក្រសួង ស្ថាប័នពាក់ព័ន្ធអាចបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធី ការកំណត់ពេលវេលា និងទម្រង់បែបបទក្នុងការស្នើសុំព័ត៌មាន និងអាចបង្កើតការិយាល័យទទួលបន្ទុកមួយ ។

## ជំពូកទី៥
## បណ្តឹង និងការអនុវត្តច្បាប់

**មាត្រា៦៤** ._ សិទ្ធិក្នុងការដាក់ពាក្យបណ្តឹង

បុគ្គលទាំងឡាយ ដែលមិនមានការពេញចិត្តចំពោះសេចក្តីសម្រេចដែលធ្វើឡើងដោយម្ចាស់គម្រោង ឬ ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ទាក់ទងទៅនឹងបទប្បញ្ញត្តិស្តីពីព័ត៌មានបរិស្ថាន ឬការកំណត់ពីភាពជាសម្ងាត់នៃព័ត៌មានបរិស្ថានណាមួយ ត្រូវមានសិទ្ធិប្តឹងទៅតុលាការ ឬក្រុមប្រឹក្សាដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដូចត្រូវបានកំណត់ក្នុងគន្ថីទី៩ នៃក្រមនេះ ។

**មាត្រា៦៥**._ នីតិវិធីក្នុងការតាមដាន និងការអនុវត្តច្បាប់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តមួយស្តីពីនីតិវិធីសម្រាប់តាមដាន និងពង្រឹងការអនុវត្តនៃមាតិកានេះ ដែលមានជាអាទិ៍ ទម្រង់បែបបទនៃការរៀបចំរបាយការណ៍ សូចនករ យន្តការផ្តល់មតិយោបល់ ការបណ្តឹងបណ្តាល និងធនធាននានា ក្នុងការរៀបចំរបាយការណ៍ ។

## គន្ថីទី២
## ការវាយតម្លៃ និងការអង្កេតតាមដានបរិស្ថាន
## មាតិកាទី១
## ការវាយតម្លៃហានិភ័យ និងការវាយតម្លៃហានិភ័យនៃនិរន្តរភាព
## ជំពូកទី១
## ការវាយតម្លៃហានិភ័យ

**មាត្រា៦៦**._ វិសាលភាពនៃការអនុវត្ត

ការវាយតម្លៃហានិភ័យ ត្រូវធ្វើឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ច មុននឹងចេញសេចក្តីសម្រេច និងការឯកភាពទាំងអស់ រួមមានការចេញលិខិតអនុញ្ញាត ឬ ការឯកភាព នៅក្រោមក្រមនេះ សម្រាប់សកម្មភាព ឬ គម្រោង ដែលអាចមានផលប៉ះពាល់បរិស្ថានគួរឲ្យកត់សម្គាល់ ។ ការវាយតម្លៃហានិភ័យអាចត្រូវបានរៀបចំ ជាផ្នែកមួយនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៦៧**._ គោលដៅនៃការវាយតម្លៃហានិភ័យ

ការវាយតម្លៃហានិភ័យ ត្រូវប្រើប្រាស់ដើម្បី៖

ក- កំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យដែលអាចកើតឡើងចំពោះបរិស្ថាន សុវត្ថិភាពសាធារណៈ និងសុខភាពមនុស្ស ដែលបណ្តាលមកពី ការសម្រេចចិត្ត ការឯកភាព សកម្មភាព ឬ គម្រោង នៅក្រោមក្រមនេះ ។

ខ- កំណត់អត្តសញ្ញាណ និង វាយតម្លៃហានិភ័យជាក់ស្តែង ចំពោះបរិស្ថាន សុវត្ថិភាពសាធារណៈ និងសុខភាពមនុស្ស ដែលបណ្តាលមកពីការសម្រេចចិត្ត ការឯកភាព សកម្មភាព ឬ គម្រោង នៅក្រោមក្រមនេះ ។

គ- កំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យដែលអាចកើតឡើង ឬ ហានិភ័យជាក់ស្តែង ចំពោះបរិស្ថាន សុវត្ថិភាពសាធារណៈ និងសុខភាពមនុស្ស ស្របតាមគន្លឹះទី៦ មាតិកាទី៤ និង មាតិកាទី៥ នៃក្រមនេះ ។

**មាត្រា៦៨** ._ គោលបំណង

ការវាយតម្លៃហានិភ័យ ត្រូវអនុវត្តដើម្បី៖

ក- កំណត់អត្តសញ្ញាណ និងផ្តល់អាទិភាពដល់សកម្មភាពនានាដែលត្រូវអនុវត្ត ។

ខ- ជួយនៅក្នុងការបែងចែកធនធានដើម្បីកាត់បន្ថយជាអប្បរមានូវការខូចខាតបរិស្ថាន ។

គ- កំណត់អំពីកម្រិតនៃការស្តារឡើងវិញដែលចាំបាច់ ដើម្បីជួសជុលផលប៉ះពាល់បរិស្ថានអវិជ្ជមាន ។

ឃ- កំណត់អំពីពេលវេលាដែលការស្តារឡើងវិញអាចត្រូវបានបញ្ចប់ និងបំពេញចប់សព្វគ្រប់ ។

ង- ធានាថាមានមូលនិធិសម្រាប់ការស្តារឡើងវិញនូវការខូចខាតបរិស្ថាន ដែលបង្កឡើងដោយសកម្មភាព ឬ គម្រោង ។

ច- ជូនដំណឹងដល់សាធារណជន និង

ឆ- ទប់ស្កាត់ និងកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់បរិស្ថានអវិជ្ជមាន ។

**មាត្រា៦៩** ._ លក្ខខណ្ឌតម្រូវសម្រាប់ទីប្រឹក្សាដែលមានការទទួលស្គាល់

រាល់ការវាយតម្លៃហានិភ័យទាំងអស់ ត្រូវធ្វើឡើងដោយទីប្រឹក្សាដែលមានការទទួលស្គាល់ ឬ ដែលទទួលបានការឯកភាព ដើម្បីអនុវត្តការងារនេះ ពីសំណាក់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ។ ទីប្រឹក្សានេះ អាចជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា៧០** ._ លិខិតបទដ្ឋានគតិយុត្ត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃហានិភ័យ មានជាអាទិ៍ គោលការណ៍ណែនាំស្តីពីខ្លឹមសារ និងទម្រង់នៃរបាយការណ៍វាយតម្លៃហានិ

ភ័យ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងលក្ខណៈសម្បត្តិដែលតម្រូវឱ្យមានសម្រាប់ទីប្រឹក្សាវាយតម្លៃហានិភ័យដែលមានការទទួលស្គាល់ និងដែលទទួលបានការឯកភាព ដោយប្រើប្រាស់នូវទម្លាប់អនុវត្តដ៏ប្រសើរបំផុត និងគោលការណ៍ផ្នែកវិទ្យាសាស្ត្រ និងគោលការណ៍វាយតម្លៃហានិភ័យដែលត្រឹមត្រូវ ។

**មាត្រា៧១** ._ របាយការណ៍

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬ ក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ត្រូវធានាថា របាយការណ៍នៃលទ្ធផលនៃការវាយតម្លៃហានិភ័យនីមួយៗ ត្រូវបានរៀបចំ ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃហានិភ័យ ។ របាយការណ៍វាយតម្លៃហានិភ័យបែបនេះ ត្រូវរៀបចំ និងសម្រេចជាចុងក្រោយដោយទីប្រឹក្សា ដែលមានការទទួលស្គាល់ ឬ ទទួលបានការឯកភាព ក្នុងការអនុវត្តការងារបែបនេះ ពីសំណាក់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬ ក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា៧២** ._ការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យដោយក្លែងបន្លំ

ទីប្រឹក្សារៀបចំរបាយការណ៍វាយតម្លៃហានិភ័យ ត្រូវទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យស្របគោលការណ៍ដែលបានចែងក្នុងមាត្រា៦៧ មាត្រា៦៨ និងមាត្រា៧០ ។

**មាត្រា៧៣** ._ការទទួលបានព័ត៌មាន

ប្រព័ន្ធគ្រប់គ្រងទិន្នន័យអំពីសកម្មភាពនៃការវាយតម្លៃហានិភ័យទាំងអស់ និងរបាយការណ៍វាយតម្លៃហានិភ័យដែលត្រូវបានបញ្ចប់ ត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន ដោយក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថាន ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មាន នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យបែបនេះ ត្រូវរក្សាដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

## ជំពូកទី២
## ការវាយតម្លៃហានិភ័យនិរន្តរភាព

**មាត្រា៧៤** ._ ការវាយតម្លៃហានិភ័យនិរន្តរភាព

រាល់ស្ថាប័នហិរញ្ញវត្ថុ និងនីតិបុគ្គល ដែលផ្តល់ការធានាផ្នែកហិរញ្ញវត្ថុ ការធានារ៉ាប់រងហិរញ្ញវត្ថុ ឬកម្ចី ចំពោះសកម្មភាព ឬ គម្រោង ត្រូវអនុវត្តការវាយតម្លៃហានិភ័យនៃនិរន្តរភាព ដើម្បីកំណត់ថា

សកម្មភាព ឬ គម្រោងដែលបានស្នើឡើង ត្រូវបានវាយតម្លៃ និងពិចារណា ដោយពេញលេញអំពីហេតុប៉ះពាល់បរិស្ថានដែលអាចកើតឡើង នៅក្នុងការរចនា ការគ្រប់គ្រងបរិស្ថាន ប្រតិបត្តិការ និង ការបិទសកម្មភាព ឬ គម្រោងដែលបានស្នើឡើង ។

**មាត្រា៧៥** ._ ការវាយតម្លៃថ្លៃចំណាយ

ការវាយតម្លៃហានិភ័យនៃនិរន្តរភាព ត្រូវធានាថា ការសិក្សាបុរេលទ្ធភាពសម្រាប់សកម្មភាព ឬ គម្រោង ដែលបានស្នើឡើង មានដាក់បញ្ចូលនូវថ្លៃចំណាយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមូលនិធិពេញលេញនៃវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន រួមបញ្ចូល ថ្លៃចំណាយជានិរន្តរនៃផែនការគ្រប់គ្រងបរិស្ថាន ការទទួលខុសត្រូវទាំងអស់សម្រាប់ការដោះស្រាយ និងសំណងសម្រាប់ការខូចខាតបរិស្ថាន ការបង់ប្រាក់ទាំងអស់ដែលតម្រូវឲ្យមានសម្រាប់សេវាប្រព័ន្ធអេកូឡូស៊ី និងការធានាផ្នែកហិរញ្ញវត្ថុដែលគ្រប់គ្រាន់សម្រាប់ការបិទ ការស្តារឡើងវិញ ការជួសជុល ឬ ការបញ្ចប់គម្រោង តាមភាពចាំបាច់ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ដែលពាក់ព័ន្ធ ។

**មាត្រា៧៦** ._ ការទទួលខុសត្រូវនៅក្នុងករណីដែលគ្មានការវាយតម្លៃហានិភ័យនៃនិរន្តរភាព

រាល់ស្ថាប័នហិរញ្ញវត្ថុ និងនីតិបុគ្គល ដែលផ្តល់ការធានាផ្នែកហិរញ្ញវត្ថុ ការធានារ៉ាប់រងហិរញ្ញវត្ថុ ឬកម្ចី ចំពោះសកម្មភាព ឬ គម្រោង ដែលមិនអនុវត្តការវាយតម្លៃហានិភ័យនៃនិរន្តរភាព ត្រូវទទួលខុសត្រូវចំពោះការខូចខាត ឬសំណងលើការខូចខាត សម្រាប់ផលប៉ះពាល់ដែលគួរឱ្យកត់សម្គាល់លើបរិស្ថាន ដែលបង្កឡើងដោយសមកម្មភាព ឬ គម្រោងនានា ។

## មាតិកាទី២
## ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ
## ជំពូកទី១
## ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

**មាត្រា៧៧** ._ ក្របខ័ណ្ឌនៃការវាយតម្លៃបរិស្ថាន

ការពិចារណាអំពីបរិស្ថាន ត្រូវដាក់បញ្ចូលទៅក្នុងការបង្កើតគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងនៅពេលពិនិត្យមតិយោបល់ដែលទទួលបានមកពីអ្នកពាក់ព័ន្ធនានា ។

**មាត្រា៧៨** ._ ការទទួលខុសត្រូវ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវទទួលខុសត្រូវដូចខាងក្រោម៖

ក- ធ្វើការសម្រេចចិត្តចុងក្រោយអំពីដំណើរការនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ខ- កំណត់វិស័យអភិវឌ្ឍសំខាន់ៗ ដែលតម្រូវឲ្យមានការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

គ- ត្រូវសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានបង្កើតលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការវាយតម្លៃបរិស្ថានយុទ្ធសាស្ត្រនេះ ។

ឃ- កំណត់រចនាសម្ព័ន្ធនៃរបាយការណ៍ស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

## ជំពូកទី២
## នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

**មាត្រា៧៩** ._ សំណើដែលអាចអនុវត្តបាន

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវធ្វើឡើងលើសំណើណាដែល៖

ក- ទំនងជានឹងមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ដល់បរិស្ថាន ឬ

ខ- ទាក់ទងទៅនឹងវិស័យណាមួយ ដែលបានកំណត់ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។

**មាត្រា៨០** ._ ការអនុវត្តការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីផ្តល់នូវព័ត៌មានលម្អិតបន្ថែមទៀតស្តីពីនីតិវិធីនៃការអនុវត្តការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ នៅក្នុងមាតិកានេះ ដែលមានជាអាទិ៍៖

ក- ប្រតិបត្តិការលម្អិតនៃនីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនៅក្នុងមាតិកានេះ ។

ខ- លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់សក្តានុពលនៃសំណើដែលអាចមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ ។

គ- ការអនុវត្តបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានពត៌មានបរិស្ថាននៅក្នុងគន្លឹទី១ មាតិកាទី២ នៃក្រមនេះ និងគន្លឹទី១ មាតិកាទី៣ នៃក្រមនេះ និង

ឃ- ខ្លឹមសារ និងរចនាសម្ព័ន្ធ (ទម្រង់) នៃរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៨១** ._ នីតិវិធី

នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវដាក់បញ្ចូលនូវដំណាក់កាលដូចខាងក្រោម៖

១- ការធ្វើចំណាត់ថ្នាក់គម្រោង ។

២- ការកំណត់វិសាលភាពគម្រោង ។

៣- ការរៀបចំសេចក្តីព្រាងរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

៤- ការចូលរួមជាសាធារណៈលើសេចក្តីព្រាងរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

៥- ការរៀបចំរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រចុងក្រោយ ។

៦- សេចក្តីសម្រេចលើរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

៧- ការអនុវត្តរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រចំពោះសំណើ ។

**មាត្រា៨២** ._ សមត្ថកិច្ច

ក្រសួង ស្ថាប័ន ដែលទទួលខុសត្រូវក្នុងការអនុវត្តនីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវតែជាក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចលើវិស័យ ដែលជាកម្មវត្ថុនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៨៣** ._ ការចូលរួមជាសាធារណៈក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

បទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន នៅក្នុងគន្ថីទី១ មាតិកាទី២ នៃក្រមនេះ និងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ត្រូវយកមកអនុវត្តនៅគ្រប់ដំណាក់កាលទាំងអស់ នៅក្នុងកិច្ចដំណើរការនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៨៤** ._ ការចូលរួមពីសំណាក់ស្ត្រី និងជនងាយរងគ្រោះ

ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធនឹងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវផ្តល់ឱកាសដល់ស្ត្រី កុមារ ជនពិការ ជនងាយរងគ្រោះ ក្រុមជនជាតិភាគតិច និងជនជាតិដើមភាគតិចចូលរួមក្នុងកិច្ចដំណើរការនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៨៥** ._ ការវិភាគអំពីការប្រែប្រួលអាកាសធាតុនៅក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយមានកិច្ចសហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធានាថារាល់គម្រោង និងសកម្មភាពទាំងអស់ ដែល

តម្រូវឱ្យមានការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដាក់បញ្ចូលនូវការវិភាគលើការពិចារណាអំពីការប្រែប្រួលអាកាសធាតុក្នុងការវាយតម្លៃខាងលើ ។

**មាត្រា៨៦** ._ ការអនុវត្តនូវរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវដាក់បញ្ចូលនូវលទ្ធផលនៃការរកឃើញ និងសេចក្តីសម្រេចចិត្តដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពទៅក្នុងសំណើដែលក្រសួង ស្ថាប័ននីមួយៗបានស្នើឡើងមុនពេលដែលសំណើដែលបានស្នើឡើងនេះត្រូវបានធ្វើការសម្រេចជាចុងក្រោយ ហើយត្រូវបង្ហាញនៅក្នុងសំណើចុងក្រោយ អំពីវិធីដែលលទ្ធផល និងសេចក្តីសម្រេចនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវបានដាក់បញ្ចូលគ្នា រួមមាន មូលហេតុសម្រាប់ការកែប្រែ ដែលត្រូវបានធ្វើឡើង ឬ មិនបានធ្វើឡើង និងសម្រាប់ជម្រើសនានា ដែលត្រូវបានជ្រើសរើស ឬ មិនបានជ្រើសរើស ។

ក្រសួង ស្ថាប័នដែលជាម្ចាស់សំណើ ត្រូវធ្វើបទបង្ហាញពីសំណើចុងក្រោយរបស់ខ្លួន ដោយក្នុងនោះ ត្រូវបង្ហាញពីរបៀបនៃការអនុវត្តសេចក្តីសម្រេច និងលទ្ធផលនៃរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៨៧** ._ ការអង្កេតតាមដាន

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវបង្កើតកម្មវិធីដើម្បីអង្កេតតាមដានផលប៉ះពាល់បរិស្ថាន ដែលបណ្តាលមកពីការអនុវត្តសំណើដែលបានស្នើឡើង ។

លទ្ធផលនៃរបាយការណ៍អង្កេតតាមដានការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវដាក់ឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាធារណជន អាចស្វែងរកបាន ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ ។

## មាតិកាទី៣
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៨៨** ._ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

មាតិកានេះ កំណត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលកើតចេញពីរាល់គម្រោងអភិវឌ្ឍដែលអាចនឹងបង្កផលប៉ះពាល់ដល់បរិស្ថាន សុខភាព សង្គម សេដ្ឋកិច្ច និងវប្បធម៌ ។

**មាត្រា៨៩** ._ គោលបំណងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានគោលបំណងដូចខាងក្រោមៈ

ក- កំណត់ឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើគម្រោងអភិវឌ្ឍទាំងសាធារណៈ និងឯកជន មុននឹងដាក់ជូនអង្គភាពមានសមត្ថកិច្ច ឬក្រសួងសាមី និង/ឬរាជរដ្ឋាភិបាលសម្រេច ។

ខ- លើកកម្ពស់ការចូលរួមជាសាធារណៈ និងសិទ្ធិរបស់សាធារណជនគ្រប់រូបក្នុងការទទួលបានព័ត៌មានស្ដីពីគម្រោងអភិវឌ្ឍ ដែលអាចបង្កផលប៉ះពាល់ ចំពោះបរិស្ថាន សុខភាព សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួន ។

គ- ធានាការអនុវត្តសកម្មភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ធ្វើឡើងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងសមធម៌សង្គម ។

ឃ- លើកកម្ពស់ប្រសិទ្ធភាពនៃការបង្កើត និងតាមដានការអនុវត្តវិធានការបង្ការ បញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ព្រមទាំងវិធានការជួសជុល ស្ដារ ឬសំណងខូចខាតទាំងឡាយដែលបង្កឡើងដោយគម្រោងអភិវឌ្ឍ ។

**មាត្រា៩០** ._ ក្របខ័ណ្ឌនៃការអនុវត្តចំពោះការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តចំពោះគម្រោងអភិវឌ្ឍទាំងសាធារណៈ និងឯកជន ដែលជាគម្រោងស្នើសុំ គម្រោងមានស្រាប់ និងគម្រោងកំពុងដំណើរការនៅក្នុងទឹកដីព្រះរាជាណាចក្រកម្ពុជា ។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តចំពោះ រាល់គម្រោងអភិវឌ្ឍ ដែលមិនទាន់បានសិក្សា វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយរាប់បញ្ចូលទាំងគម្រោងដែលទទួលបាន ឬពុំទាន់ទទួលបានលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ សេចក្ដីសម្រេចពីក្រសួង ឬស្ថាប័នមានសមត្ថកិច្ច អនុម័តគម្រោង ។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តផងដែរ ចំពោះគម្រោងអភិវឌ្ឍទាំងឡាយណាដែលអាចបង្កឲ្យមានផលប៉ះពាល់ឆ្លងដែនដល់បរិស្ថាន សុខភាព សេដ្ឋកិច្ច សង្គម និងវប្បធម៌ ល្មឹកណាមានការទទួលស្គាល់ពីកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី សន្ធិសញ្ញាអន្តរជាតិស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដែលព្រះរាជាណាចក្រកម្ពុជាជាហត្ថលេខី ។

លក្ខណៈវិនិច្ឆ័យ និងចំណាត់ថ្នាក់ប្រភេទគម្រោង ដែលត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នឹងត្រូវកំណត់លិខិតបទដ្ឋានគតិយុត្តដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៩១** ._ គម្រោងលើកលែង

ក្រមនេះមិនអនុវត្តចំពោះគម្រោងអភិវឌ្ឍ ឬសកម្មភាពរបស់រដ្ឋ ដែលបានអនុម័តដោយរាជរដ្ឋាភិបាល ឬរដ្ឋសភា ហើយដែលចាត់ទុកជាគម្រោងចាំបាច់ និងបន្ទាន់ទាក់ទងនឹងសន្តិសុខជាតិ បូរណភាពទឹកដី អធិបតេយ្យជាតិ ឬការគ្រប់គ្រងគ្រោះមហន្តរាយនានា ។

## ជំពូកទី២
## គោលការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា៩២** ._ គោលការណ៍គ្រឹះនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

រាល់គម្រោងអភិវឌ្ឍ ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់ទៅលើបរិស្ថាន សេដ្ឋកិច្ច សង្គម សុខភាព និងវប្បធម៌ ដោយមានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានជាមុនសិន មុននឹងបញ្ជូនទៅរាជរដ្ឋាភិបាលសម្រេច ។

រាល់ការចេញអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតលើគម្រោងអភិវឌ្ឍនានាដោយក្រសួង ស្ថាប័នអនុម័តគម្រោង ត្រូវធ្វើឡើងអនុលោមតាមលក្ខខណ្ឌដែលកំណត់នៅក្នុងលិខិត និងវិញ្ញាបនបត្រវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬសេចក្តីសម្រេចនានាដែលផ្ទុយនឹងស្មារតីនៃបទប្បញ្ញត្តិនេះត្រូវទុកជាមោឃៈ ។

**មាត្រា៩៣** ._ គោលការណ៍ទូទៅ

កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នឹងយកជាការបាន លុះត្រាតែកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះ ធ្វើឡើងស្របតាមលក្ខខណ្ឌ និងគោលការណ៍ទូទៅនានាដែលបញ្ញត្តិទុកក្នុងក្រមនេះ ។

**មាត្រា៩៤** ._ គោលការណ៍ប្រុងប្រយ័ត្នជាមុន

គោលការណ៍ប្រុងប្រយ័ត្នជាមុន ចំពោះហានិភ័យដែលអាចបង្កឡើងដោយផ្ទាល់ ឬដោយប្រយោលពីការអនុវត្តគម្រោងអភិវឌ្ឍត្រូវអនុវត្ត ដូចគ្នាដូចមានចែងក្នុងមាត្រា៩ នៃក្រមនេះ ។

## ជំពូកទី៣
## អង្គភាពទទួលខុសត្រូវ

**មាត្រា៩៥** ._ សមត្ថកិច្ចទទួលខុសត្រូវ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាល ដែលមានសមត្ថកិច្ចផ្ដាច់មុខសម្រាប់គ្រប់គ្រងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានមានភារកិច្ច និងតួនាទីដូចខាងក្រោម៖

ក- បង្កើតគណៈកម្មការជំនាញត្រួតពិនិត្យ តាមការចាំបាច់ ។

ខ- ចេញលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

គ- អនុម័តលិខិតបទដ្ឋានគតិយុត្តស្ដីពីលក្ខណៈវិនិច្ឆ័យនៃការធ្វើចំណាត់ថ្នាក់គម្រោង ។

ឃ- កំណត់លក្ខណៈវិនិច្ឆ័យនៃវិសាលភាពគម្រោង និងលក្ខខណ្ឌការងារ ។

ង- អនុម័តលិខិតបទដ្ឋានគតិយុត្តនានា ស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬ ផែនការគ្រប់គ្រងបរិស្ថាន ។

ច- អនុវត្តគោលការណ៍នានាដែលបានឯកភាព និងអនុវត្តដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬផែនការគ្រប់គ្រងបរិស្ថាន។

ឆ- អនុម័តលិខិតបទដ្ឋានគតិយុត្តស្ដីពីការចូលរួមជាសាធារណៈក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ជ- កំណត់លក្ខខណ្ឌ លក្ខណៈសម្បត្តិ បែបបទនិងនីតិវិធីសម្រាប់ការចុះបញ្ជីទីប្រឹក្សានៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ឈ- បង្កើត និងអភិវឌ្ឍ ក្របខ័ណ្ឌច្បាប់នានា សម្រាប់អនុវត្តចំពោះការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ជាអាទិ៍ លិខិតបទដ្ឋានគតិយុត្ត លិខិតបទដ្ឋានគតិយុត្ត និងវិធីសាស្រ្តវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ។

**មាត្រា៩៦** ._ ការទទួលខុសត្រូវអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺជាសេនាធិការផ្ទាល់ របស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានរចនាសម្ព័ន្ធចាត់តាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ការរៀបចំ និងប្រព្រឹត្តទៅនៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៩៧** ._ សមត្ថកិច្ចរបស់អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសមត្ថកិច្ចដូចខាងក្រោម៖

ក- ត្រួតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងចេញលិខិតអនុញ្ញាត និងសេចក្តីសម្រេចនានាពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អនុលោមតាមច្បាប់ និងនីតិវិធីជាធរមានបន្ទាប់ពីមានសេចក្តីសម្រេចពីរដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ខ- តាមដាន ត្រួតពិនិត្យ ធ្វើអធិការកិច្ច អង្កេត ស្រាវជ្រាវ ណែនាំ និងចាត់វិធានការដោយខ្លួនឯង ឬដោយសហការជាមួយអ្នកពាក់ព័ន្ធ ចំពោះការអនុវត្តគម្រោង និងសកម្មភាពគ្រប់ប្រភេទ ។

**មាត្រា៩៨** ._ ភារកិច្ច និងតួនាទី

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានភារកិច្ច និងតួនាទីដូចខាងក្រោម៖

ក- ទទួលបន្ទុកអនុវត្តច្បាប់នេះ ក្រោមការត្រួតពិនិត្យពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ខ- ទទួលបន្ទុកធ្វើចំណាត់ថ្នាក់គម្រោង កំណត់វិសាលភាពនៃគម្រោង និងលក្ខខណ្ឌការងារ ពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងឯកសារទាំងអស់ដែលពាក់ព័ន្ធ និងធានាឲ្យមានការចូលរួមជាសាធារណៈអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ ។

គ- ចុះអង្កេត និងតាមដានរាល់សកម្មភាពគម្រោងទៅតាមផែនការអង្កេតតាមដាន និងគ្រប់គ្រងបរិស្ថាន ក្រោយពីម្ចាស់គម្រោងទទួលបានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធានាការគោរពច្បាប់ ។

**មាត្រា៩៩** ._ សិទ្ធអំណាចរបស់មន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

មន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន មានសិទ្ធិ អំណាចដូចខាងក្រោម៖

ក- ធ្វើអធិការកិច្ចតាមដាន និងត្រួតពិនិត្យការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន លិខិតបទដ្ឋានគតិយុត្តនានា កិច្ចសន្យាការពារបរិស្ថាន ស្តង់ដារផែនការគ្រប់គ្រងបរិស្ថាន និងលក្ខខណ្ឌតម្រូវផ្នែកបរិស្ថានដែលពាក់ព័ន្ធផ្សេងៗទៀត ។ ក្នុងករណីចាំបាច់ មន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អាចបង្គាប់ឲ្យម្ចាស់គម្រោងផ្អាកសកម្មភាពមួយផ្នែក ឬទាំងស្រុងជាបណ្តោះអាសន្ន ឬបិទទីតាំងជាបណ្តោះអាសន្ន ។

ខ- ពិនិត្យកំណត់ត្រា ឯកសារ ទិន្នន័យអេឡិចត្រូនិក ស្តីពីការគ្រប់គ្រងបរិស្ថាន និងកំណត់ត្រា ដទៃទៀត ស្តីពីគម្រោងអភិវឌ្ឍ និងការប្រតិបត្តិគម្រោង ។

គ- ស្តាប់ និងធ្វើកំណត់ហេតុស្តាប់ចម្លើយរបស់កម្មករ និយោជិត តំណាងម្ចាស់គម្រោង និងបុគ្គលពាក់ព័ន្ធនានា ។

ឃ- បង្គាប់ឲ្យកម្មករ និយោជិត អភិបាល អ្នកតំណាងស្របច្បាប់ និងភ្នាក់ងារនៃគម្រោងអភិវឌ្ឍ ផ្តល់នូវរាល់ព័ត៌មាន ឯកសារជាលាយលក្ខណ៍អក្សរ ផែនការក៏ដូចជាកំណត់ត្រា គ្រប់ប្រភេទដែលពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ។

ង- មានសិទ្ធិចុះឆែកឆេរទីតាំងគម្រោង និងចាប់យកវត្ថុតាង ក្នុងករណីដែលសង្ស័យថាមានអំពើល្មើសនឹងច្បាប់ ឬបទប្បញ្ញត្តិនានាស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ។

ច- ជួបប្រជុំជាមួយប្រធានក្រុមប្រឹក្សាភិបាល តំណាងស្របច្បាប់ និងកម្មករ និយោជិតនៃគម្រោងយ៉ាងតិច ១ (មួយ) ឆ្នាំម្តង ដើម្បីធ្វើការវាយតម្លៃការអនុវត្តច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត ។

ឆ- ធ្វើកំណត់ហេតុឆែកឆេរ និងចាប់យកវត្ថុតាងនានា ដើម្បីកសាងសំណុំរឿងនៃការប្រព្រឹត្តល្មើសនឹងច្បាប់នេះ ដើម្បីចាត់ការតាមនីតិវិធីជាធរមាន ។

**មាត្រា១០០ .**_ ការអនុវត្តភារកិច្ច និងតួនាទីរបស់មន្ទីរបរិស្ថានរាជធានី ខេត្ត

មន្ទីរបរិស្ថានរាជធានី ខេត្ត ចូលរួមអនុវត្តភារកិច្ច និងតួនាទីដូចមានចែងក្នុងក្រមនេះ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងការចាត់តាំងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

## ជំពូកទី៤
## កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
## ផ្នែកទី១
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងស្នើសុំ

**មាត្រា១០១ .**_ ការធ្វើចំណាត់ថ្នាក់គម្រោង

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវកំណត់ចំណាត់ថ្នាក់លើគម្រោងអភិវឌ្ឍ ដើម្បីតម្រូវឲ្យម្ចាស់គម្រោងរៀបចំនូវឯកសារ ដូចខាងក្រោម ៖

១- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន ។

២- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន ។

៣- កិច្ចសន្យាការពារបរិស្ថាន ។

ប្រភេទគម្រោង ដែលតម្រូវឲ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

គម្រោងដែលតម្រូវឲ្យរៀបចំកិច្ចសន្យាការពារបរិស្ថាន ត្រូវភ្ជាប់ជាមួយគោលការណ៍បច្ចេកទេស ជាអាទិ៍ ផែនការគាំពារបរិស្ថាន ដោយត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចកំណត់ចំណាត់ថ្នាក់គម្រោងបន្ថែមទៀត ដោយផ្អែកលើទំហំនៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា១០២** ._ ការផ្ទេរ ឬផ្លាស់ប្តូរម្ចាស់គម្រោង

ក្នុងករណីដែលមានការផ្ទេរ ឬផ្លាស់ប្តូរម្ចាស់គម្រោង ដោយហេតុណាមួយ នោះលិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និង/ឬ ពេញលេញ ព្រមទាំងកិច្ចសន្យា និងលក្ខខណ្ឌទាំងអស់ដែលចែងក្នុងវាក្យខណ្ឌនេះ ត្រូវផ្ទេរទៅម្ចាស់ថ្មីដោយស្វ័យប្រវត្តិ ។ កិច្ចសន្យាផ្ទេរ ឬការផ្លាស់ប្តូរម្ចាស់គម្រោងមានសុពលភាពអនុវត្ត លុះត្រាតែការផ្ទេរ ឬការផ្លាស់ប្តូរនោះ ធ្វើឡើងបន្ទាប់ពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ទទួលបានការជូនដំណឹងអំពីការផ្លាស់ប្តូរនោះ ។

**មាត្រា១០៣** ._ លក្ខខណ្ឌតម្រូវនៃការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ត្រូវធ្វើឡើងសម្រាប់៖

១. គម្រោងនានាដែលមានរៀបរាប់ក្នុងលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬ

២. គម្រោងនានា ដែលបានរៀបចំជាកិច្ចសន្យាការពារបរិស្ថាន ហើយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន តម្រូវឲ្យធ្វើរបាការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ។

នៅពេលដែលគម្រោងស្នើឡើង ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនោះ ម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំសេចក្តីព្រាងលក្ខខណ្ឌការងារ ដោយអនុលោមតាមបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន រួចដាក់សុំការអនុម័តជាស្ថាពរពីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ផ្អែកលើលក្ខខណ្ឌការងារដែលទទួលបានការឯកភាព ។

**មាត្រា១០៤ .**_ លក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវធ្វើឡើងសម្រាប់៖

១- គម្រោងដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬ

២- គម្រោងដែលទទួលបានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ហើយលទ្ធផលនៃការសិក្សានេះពិនិត្យឃើញថាមានការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម ហើយក្រសួងទទួលបន្ទុកវិស័យបរិស្ថានតម្រូវឲ្យមានការសិក្សារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

នៅពេលដែលគម្រោងស្នើសុំ តម្រូវឲ្យធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំសេចក្ដីព្រាងលក្ខខណ្ឌការងារដោយអនុលោមតាមបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន រួចដាក់សុំការអនុម័តជាស្ថាពរ ពីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ផ្អែកលើលក្ខខណ្ឌការងារដែលទទួលបានការឯកភាព ។

**មាត្រា១០៥ .**_ មតិយោបល់របស់គណៈកម្មការជំនាញត្រួតពិនិត្យ

រាល់គម្រោងអភិវឌ្ឍនានា ដែលតម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញចាំបាច់ត្រូវមានមតិបច្ចេកទេសរបស់គណៈកម្មការជំនាញត្រួតពិនិត្យ ។

គណៈកម្មការជំនាញត្រួតពិនិត្យនេះរួមមានសមាសភាពនៃមន្ត្រីមកពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញឯករាជ្យ ដែលមានគុណសម្បត្តិ និងបទពិសោធន៍សមស្របក្នុងការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

សមាជិកគណៈកម្មការជំនាញត្រួតពិនិត្យនេះ អាចមានការប្រែប្រួលពីគម្រោងមួយទៅគម្រោងមួយតាមការជ្រើសរើសរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាស្រ័យទៅតាមទិដ្ឋភាពបច្ចេកទេសនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃការបង្កើតគណៈកម្មការជំនាញត្រួតពិនិត្យនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

សមាជិកនៃគណៈកម្មការជំនាញត្រួតពិនិត្យ ត្រូវបានទូទាត់ប្រាក់កម្រៃសម្រាប់ការបម្រើការងាររបស់ខ្លួន ដោយផ្អែកលើការព្រមព្រៀង រវាងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន សមាជិកនិងម្ចាស់គម្រោង ។

**មាត្រា១០៦** ._ លក្ខខណ្ឌតម្រូវក្នុងការធ្វើកិច្ចសន្យាការពារបរិស្ថាន

កិច្ចសន្យាការពារបរិស្ថាន ត្រូវធ្វើឡើងសម្រាប់គម្រោងនានាដែលមានរៀបរាប់ក្នុងលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬគម្រោងដែលមានទំហំហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គមតិចតួច ។

នៅពេលដែលគម្រោងស្នើឡើងត្រូវធ្វើត្រឹមកិច្ចសន្យាការពារបរិស្ថាន ម្ចាស់គម្រោងត្រូវចុះកិច្ចសន្យាការពារបរិស្ថាន ដោយត្រូវភ្ជាប់ជាមួយគោលការណ៍បច្ចេកទេស មានជាអាទិ៍ ផែនការគាំពារបរិស្ថាន និងឯកសារពាក់ព័ន្ធ រួចដាក់សុំការអនុម័តជាស្ថាពរពីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

គំរូកិច្ចសន្យាការពារបរិស្ថាន និងផែនការគាំពារបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា១០៧** ._ សុពលភាពនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ អាចយកជាបានការលុះត្រាតែៈ

១- របាយការណ៍នោះត្រូវបានរៀបចំឡើង ដោយនីតិបុគ្គលដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានបានផ្តល់ជូននូវនីតិសម្បទាជាក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

២- របាយការណ៍នោះត្រូវ តាក់តែងឡើងស្របតាមនីតិវិធី លក្ខខណ្ឌ និងលិខិបទដ្ឋានគតិយុត្តដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា១០៨** ._ ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលជារូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវតែមានសញ្ជាតិខ្មែរ និងមានប្រធានក្រុមការងារជាទីប្រឹក្សាដែលទទួលបាននីតិសម្បទាពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

បុគ្គលជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានគ្រប់រូប ត្រូវចុះបញ្ជីនៅក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានជាមុនសិន មុននឹងប្រកបវិជ្ជាជីវៈរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជាមួយក្រុមហ៊ុនទីប្រឹក្សា ។

វិញ្ញាបនបត្រនៃការចុះបញ្ជី ផ្តល់នីតិសម្បទាជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវមានរយៈពេលសុពលភាពអតិបរិមា ៥ (ប្រាំ) ឆ្នាំ ហើយអាចបន្តសាជាថ្មីបាន ។

លក្ខណៈសម្បត្តិ បែបបទ លក្ខខណ្ឌ និងនីតិវិធីសម្រាប់ចុះបញ្ជីដើម្បីទទួលបាននីតិសម្បទាជាទីប្រឹក្សា ។

រូបវន្តបុគ្គល ឬនីតិបុគ្គលសម្រាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក៏ដូចជាការបន្តសុពលភាពនៃការចុះបញ្ជីសារជាថ្មី ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថាន ។

**មាត្រា១០៩** ._ រយៈពេលនៃការពិនិត្យ និងផ្តល់យោបល់ លើកិច្ចសន្យាការពារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានមានរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីពិនិត្យ ផ្តល់យោបល់ ឯកភាព បដិសេធ ឬតម្រូវឲ្យកែសម្រួល ឬកែតម្រូវ លើកិច្ចសន្យាការពារបរិស្ថាន និងផែនការគាំពារបរិស្ថាន ។ រយៈពេលនេះគិតចាប់ពីកាលបរិច្ឆេទដែលខ្លួនទទួលបានពាក្យសុំពិនិត្យលើកិច្ចសន្យាការពារបរិស្ថាន ផែនការគាំពារបរិស្ថាន និងឯកសារពាក់ព័ន្ធ ។

**មាត្រា១១០** ._ រយៈពេលនៃការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលខ្លួនទទួលបានរបាយការណ៍នោះ ។ រយៈពេល ៦០ (ហុកសិប) ថ្ងៃនេះ ត្រូវអស់សុពលភាព នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានបានផ្តល់យោបល់របស់ខ្លួន ទោះបីជាយោបល់នោះជាយោបល់បដិសេធ យោបល់ឯកភាព ឬជាយោបល់បង្គាប់ឲ្យមានការកែប្រែ ឬកែលម្អរបាយការណ៍ដែលខ្លួនពិនិត្យក៏ដោយ ។

រយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ សម្រាប់ពិនិត្យ និងផ្តល់យោបល់ខាងលើ ត្រូវចាប់ផ្តើមរាប់សារជាថ្មី នៅពេលដែលក្រសួង ស្ថាប័នទទួលបានពាក្យស្នើសុំឲ្យពិនិត្យ ព្រមទាំងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ដែលម្ចាស់គម្រោងបានធ្វើការកែតម្រូវរួចជាស្ថាពរ ស្របតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំ ដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានបានផ្តល់ជូននាគ្រាមុនៗ ។

ម្ចាស់គម្រោង ត្រូវទទួលខុសត្រូវ ចំពោះព្យសនកម្មនានា ដែលបង្កឡើងដោយកំហុសរបស់ខ្លួន ដែលបណ្តាលមកពីការយឺតយ៉ាវ ឬការខកខានមិនបានធ្វើការកែសម្រួលឲ្យត្រូវតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំខាងលើ ។

**មាត្រា១១១ .**_ រយៈពេលនៃការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់ លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលខ្លួនទទួលបានរបាយការណ៍នោះ ។ រយៈពេល៩០(កៅសិប)ថ្ងៃនេះ ត្រូវអស់សុពលភាពនៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានបានផ្តល់យោបល់របស់ខ្លួន ទោះបីជាជាយោបល់នោះជាយោបល់បដិសេធ យោបល់ឯកភាព ឬជាយោបល់បង្គាប់ឲ្យមានការកែប្រែ ឬកែលម្អរបាយការណ៍ដែលខ្លួនពិនិត្យក៏ដោយ ។

រយៈពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ សម្រាប់ពិនិត្យ និងផ្តល់យោបល់ខាងលើ ត្រូវចាប់ផ្តើមរាប់សារជាថ្មី នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានទទួលបានពាក្យស្នើសុំឲ្យពិនិត្យ ព្រមទាំងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលម្ចាស់គម្រោងបានធ្វើការកែតម្រូវរួចជាស្ថាពរ ស្របតាមសេចក្តីបង្គាប់ ឬណែនាំដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានបានផ្តល់ជូនកាលពីពេលមុនៗ ។

ម្ចាស់គម្រោង ត្រូវទទួលខុសត្រូវ ចំពោះព្យសនកម្មនានាដែលបង្កឡើងដោយកំហុសរបស់ខ្លួនដែលបណ្តាលមកពីការយឺតយ៉ាវ ឬការខកខានមិនបានធ្វើការកែសម្រួលឲ្យត្រូវតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំខាងលើ ។

**មាត្រា១១២ .**_ កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ

ក្នុងអំឡុងពេលនៃការពិនិត្យ និងផ្តល់យោបល់ដែលកំណត់ក្នុងមាត្រា១១០ និង មាត្រា១១១ នៃក្រមនេះ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់របស់ខ្លួន ចំពោះរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ បន្ទាប់ពី៖

ក- ស្តាប់និងពិចារណាលើបទបង្ហាញ និងការការពារជាផ្លូវការរបស់ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា ។

ខ- ពិចារណាលើមតិយោបល់ របស់អ្នកដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល មតិសាធារណជនពាក់ព័ន្ធ និងសង្គមស៊ីវិល ។

គ- ពិចារណាមតិយោបល់របស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ និង

ឃ- ពិចារណាមតិរបស់គណៈកម្មការជំនាញត្រួតពិនិត្យដែលបានស្នើឡើង ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវទទួលខុសត្រូវ ក្នុងការរៀបចំឲ្យមានដំណើរការចូលរួមជាសាធារណៈ ប្រកបដោយសមធម៌ ដោយអញ្ជើញតំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ

អាជ្ញាធរដែនដី សង្គមស៊ីវិល និងអ្នកដែលទទួលរងការប៉ះពាល់ ឲ្យចូលរួមផ្តល់មតិយោបល់ចំពោះគម្រោងដែលបានស្នើឡើងនោះ ។

**មាត្រា១១៣ ._** ការឯកភាព ឬបដិសេធ ឬបង្គាប់ឲ្យកែប្រែ ឬកែតម្រូវលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ

ការផ្តល់យោបល់ឯកភាព ឬបដិសេធ ឬបង្គាប់ឲ្យមានការកែប្រែ ឬកែតម្រូវផ្សេងៗទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវធ្វើឡើងដោយពិចារណាលើគុណសម្បត្តិ និងគុណវិបត្តិខាងផ្នែកបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ តាមរយៈការពិនិត្យជាអាទិ៍ វិសាលភាពនៃគម្រោង ទីតាំងភូមិសាស្ត្រ សក្តានុពលនៃហេតុប៉ះពាល់ លក្ខណៈពិសេសដទៃទៀតរបស់គម្រោងនីមួយៗ និងប្រសិទ្ធភាពនៃការអនុវត្តវិធានការគ្រប់គ្រង និង/ឬការពារគុណភាពបរិស្ថាន និងកាត់បន្ថយហេតុប៉ះពាល់ចំពោះសង្គម អនុលោមតាមកម្រិតវិវឌ្ឍន៍នៃបច្ចេកវិជ្ជា និងវិទ្យាសាស្ត្រ ។

ក្នុងករណីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ផ្តល់យោបល់ឯកភាព លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវចេញលិខិតនិងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងនោះ ដោយភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន ។

ក្នុងករណី ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានបដិសេធលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវបញ្ជាក់ពីហេតុផលនៃសេចក្តីសម្រេចរបស់ខ្លួន ។

ក្នុងករណីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ផ្តល់យោបល់បង្គាប់ឲ្យធ្វើការកែប្រែ ឬកែតម្រូវលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ នោះក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវភ្ជាប់ហេតុផល និងចង្អុលបង្ហាញដោយច្បាស់ៗ នូវចំណុចត្រូវកែប្រែ ឬកែតម្រូវ ។

**មាត្រា១១៤ ._** ការផ្តល់លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍ឯកភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះទីតាំងតំបន់ជនជាតិដើមភាគតិច

មុនសម្រេចផ្តល់នូវលិខិតនិង វិញ្ញាបនបត្រឯកភាព លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងអភិវឌ្ឍ ដែលមានទីតាំងស្ថិតនៅតំបន់ ដែលមានជនជាតិដើមភាគតិចរស់នៅ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន សមាជិកនៃគណៈកម្មការជំនាញត្រួតពិនិត្យ ឬអ្នកពាក់ព័ន្ធក្នុងការចូលរួមក្នុងការសម្រេច ត្រូវធ្វើការយកចិត្តទុកដាក់ និងពិចារណាខ្ពស់ចំពោះគម្រោងនោះដើម្បី

បញ្ចៀសផលប៉ះពាល់អវិជ្ជមាន ជាអាទិ៍ វប្បធម៌ ទំនៀមទំលាប់ ប្រពៃណី  ការប្រកបរបរចិញ្ចឹមជីវិត ទ្រព្យសម្បត្តិ ដល់សហគមន៍ជនជាតិដើមភាគតិច ។

**មាត្រា១១៥ .**_ ការបដិសេធ ឬបង្គាប់ឲ្យកែប្រែឬកែតម្រូវ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវផ្ញើសេចក្តីសម្រេចបដិសេធ ឬសេចក្តីបង្គាប់ឲ្យមានការកែប្រែ ឬកែតម្រូវជាលាយលក្ខណ៍អក្សររបស់ខ្លួន រួមទាំងហេតុផល ឬលក្ខខណ្ឌ និង/ឬ ចំណុចនានាដែលត្រូវកែប្រែ ឬកែតម្រូវ ជូនទៅម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាសម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន  ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវផ្ញើលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន រួមទាំងកិច្ចសន្យាការពារបរិស្ថាន ជូនដល់ម្ចាស់គម្រោង និងក្រសួង ឬស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធជាអាទិ៍ ក្រសួង ឬស្ថាប័នអនុម័តគម្រោង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា  មន្ទីរបរិស្ថានរាជធានី ខេត្ត និងក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវផ្សព្វផ្សាយសេចក្តីសម្រេចឯកភាពរបស់ខ្លួន រួមទាំងផែនការគ្រប់គ្រងបរិស្ថាន និងលក្ខខណ្ឌពាក់ព័ន្ធខាងលើ ជូនដល់សាធារណជន តាមរយៈការដាក់បង្ហោះនៅលើគេហទំព័ររបស់ខ្លួន និង/ឬ តាមរយៈការបោះពុម្ពផ្សាយតាមសារព័ត៌មាន អនុលោមតាមកាលៈទេសៈ និងភាពចាំបាច់ ។

**មាត្រា១១៦ .**_ ការហាមឃាត់ចំពោះសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោង

ម្ចាស់គម្រោងមិនត្រូវចាប់ផ្តើមសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោង មុនពេលទទួលបានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។ ក្នុងករណីដែលគម្រោងអភិវឌ្ឍគ្មានលិខិត និងវិញ្ញាបនបត្រ ឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានមានសិទ្ធិសម្រេចផ្អាកសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោង ទាំងស្រុង ។

រាល់កិច្ចព្រមព្រៀងសម្បទាន ដែលផ្តល់ជូនដោយរាជរដ្ឋាភិបាលកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត ត្រូវមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាផ្លូវការដោយភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន ។

**មាត្រា១១៧ .**_ រយៈពេលនៃលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសុពលភាព សម្រាប់រយៈពេលវដ្តនៃគម្រោង ។ ក្នុងករណីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានពិនិត្យឃើញថាមានការផ្លាស់ប្តូរផែនការមេ ឬ/និង របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ លែងមានលក្ខណៈសមស្រប ឬមិនមានប្រសិទ្ធភាពក្នុងការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានមានសិទ្ធិតម្រូវឲ្យម្ចាស់គម្រោង រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានឡើងវិញ ឬ/និងធ្វើបច្ចុប្បន្នភាព របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីទទួលបានជាថ្មីនូវលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន តាមលក្ខខណ្ឌកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

## ផ្នែកទី២
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងដែលមានស្រាប់ និងកំពុងដំណើរការ

**មាត្រា១១៨ ._** ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះបាល់បរិស្ថានដំបូង ឬពេញលេញ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវពិគ្រោះយោបល់ជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តផ្អែកលើការធ្វើចំណាត់ថ្នាក់គម្រោងសម្រាប់ប្រភេទគម្រោងដែលមិនបានអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីតម្រូវឲ្យម្ចាស់គម្រោងទាំងនោះ រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ចំពោះគម្រោងដែលមានស្រាប់ និងកំពុងដំណើរការ ។

គោលការណ៍ណែនាំត្រូវបោះពុម្ពផ្សព្វផ្សាយក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីពេលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានសម្រេចលើលិខិតបទដ្ឋានគតិយុត្តទាំងនេះ ។

ម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញឲ្យបានចប់ ហើយត្រូវដាក់ឯកសារទាំងនេះ ទៅក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានដើម្បីពិនិត្យ ផ្តល់យោបល់ ក្នុងរយៈពេលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវពិនិត្យ ផ្តល់យោបល់ និងសម្រេចលើរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដោយយោងទៅតាមបទប្បញ្ញត្តិ នៃជំពូកទី៤ នៃក្រមនេះ ។

## ផ្នែកទី៣
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះការប្រែប្រួលអាកាសធាតុ

**មាត្រា១១៩ ._** ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះការប្រែប្រួលអាកាសធាតុ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវដាក់បញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់នៃគម្រោងស្នើសុំដែលបង្កឲ្យមានការប្រែប្រួលអាកាសធាតុរួមមាន ការគណនាបរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់គម្រោងអភិវឌ្ឍ រួមបញ្ចូលការវិភាគលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នាពេលអនាគត ។

ម្ចាស់គម្រោងត្រូវសិក្សាអំពីជម្រើសថាមពលនានា ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាប និងសិក្សាអំពីតម្រូវការក្នុងការកាត់បន្ថយការប្រែប្រួលចំពោះការផ្គត់ផ្គង់ទឹក ដែលបណ្តាលមកពីកត្តាអាកាសធាតុ ។

**មាត្រា១២០ ._** ការវិភាគ និងវាយតម្លៃពីសក្តានុពលនៃផលប៉ះពាល់ចំពោះការប្រែប្រួលអាកាសធាតុ

រាល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវវិភាគ និងវាយតម្លៃ ពីសក្តានុពលនៃផលប៉ះពាល់ និងភាពងាយរងគ្រោះនៃគម្រោង ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងសកម្មភាពអភិវឌ្ឍដែលអាចរងនូវអតុល្យភាពដោយសារលក្ខខណ្ឌបរិស្ថានដែលរងការប៉ះពាល់ ដើម្បីសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច ដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច ដែលជាទិសដៅចម្បងនៃការអភិវឌ្ឍបៃតង ។

ក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោងត្រូវដាក់បញ្ចូលនូវការវាយតម្លៃហានិភ័យ ភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ ភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីស្នើនូវវិធានការកាត់បន្ថយផលប៉ះពាល់នូវហានិភ័យនៃការប្រែប្រួលអាកាសធាតុ និង ដាក់បញ្ចូលនូវរាល់ផែនការឆ្លើយតបបន្ទាន់ និងជម្រើសបច្ចេកវិជ្ជា ដើម្បីទប់ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ។

## ផ្នែកទី៤
## ការវាយតម្លៃហេតុប៉ះពាល់សុខភាព និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាបណ្តុំ

**មាត្រា១២១ ._** ការវាយតម្លៃហេតុប៉ះពាល់សុខភាព

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ត្រូវរាប់បញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់សុខភាពដែលមានជាអាទិ៍៖

ក- ទិន្នន័យមូលដ្ឋានស្តីពីសុខភាពនៅក្នុងតំបន់គម្រោង និងរបស់ប្រជាជនដែលរងផលប៉ះពាល់ ។

ខ- ការពិពណ៌នា អំពីផលប៉ះពាល់នៃគម្រោងដែលអាចមាន ដោយសារការសាងសង់លំហូរប្រជាជន និងការផ្លាស់ប្តូរចំពោះបរិស្ថាន ។

គ- វិធានការកាត់បន្ថយផលប៉ះពាល់ ដើម្បីកាត់បន្ថយ ឬលុបបំបាត់ផលប៉ះពាល់អវិជ្ជមាននៃគម្រោង និងវិធានការដែលត្រូវដាក់ឲ្យអនុវត្តដោយម្ចាស់គម្រោង ដើម្បីកែលម្អសុខភាពរបស់សហគមន៍មូលដ្ឋាន ។

ឃ- បញ្ហានានាទាក់ទងនឹងការអង្កេតតាមដានសុខភាព និងការគ្រប់គ្រងផលប៉ះពាល់ដែលនៅសល់ក្នុងរយៈពេលខ្លី និងវែង សម្រាប់គម្រោង ។

**មាត្រា១២២ .**_ ការវិភាគពីហានិភ័យនៃការវាយតម្លៃហេតុប៉ះពាល់សុខភាព

ក្នុងការវាយតម្លៃហេតុប៉ះពាល់សុខភាព ម្ចាស់គម្រោងត្រូវ៖

ក- លើកផែនការគ្រប់គ្រងសុវត្ថិភាព និងសុខភាពជាផ្នែកមួយនៃការវាយតម្លៃហេតុប៉ះពាល់សុខភាព សម្រាប់បរិស្ថានការងារ ដោយវិភាគពីហានិភ័យដែលពាក់ព័ន្ធ និងប្រភេទនៃកត្តាគ្រោះថ្នាក់ក្នុងទីតាំងគម្រោង ជាអាទិ៍ កត្តាគ្រោះថ្នាក់ផ្នែករូបសាស្ត្រ គីមីសាស្ត្រ ជីវសាស្ត្រ និងវិទ្យុសកម្ម ។

ខ- កំណត់ និងវាយតម្លៃពីគ្រោះហានិភ័យ និងសក្តានុពលនៃផលប៉ះពាល់ទៅលើសុវត្ថិភាព និងសុខភាព របស់សហគមន៍ក្នុងដំណាក់កាលរចនាគម្រោង សាងសង់គម្រោង ប្រតិបត្តិគម្រោង និងបញ្ចប់គម្រោង ព្រមទាំងលើកវិធានការការពារ និងផែនការគ្រប់គ្រងផលប៉ះពាល់នៅក្នុងដំណាក់កាលទាំងនេះ ។

**មាត្រា១២៣ .**_ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាបណ្តុំ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវវិភាគនិងវាយតម្លៃពីបណ្តុំនៃផលប៉ះពាល់ដែលបង្កឡើងដោយគម្រោងដែលមានស្រាប់ និងគម្រោងក្នុងពេលអនាគត នៅជុំវិញនៃទីតាំងគម្រោងទាំងនោះ ដែលអាចបង្កើតឲ្យមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ ដល់បរិស្ថាន ឬសង្គម ។

នៅក្នុងរបាយការណ៍វាយតម្លៃបណ្តុំនៃផលប៉ះពាល់ ម្ចាស់គម្រោងត្រូវវាយតម្លៃសមត្ថភាពនៃធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ដើម្បីគិតគូរអំពីផលប៉ះពាល់បន្ថែមផ្អែកលើកត្តាពេលវេលា ស្ថានភាពភូមិសាស្ត្រ និងសកម្មភាពរបស់គម្រោងនានាដែលនៅជុំវិញទីតាំងគម្រោង ។

ម្ចាស់គម្រោងត្រូវពិចារណាអំពី ជម្រើសនៃវិធានការកាត់បន្ថយបណ្តុំនៃផលប៉ះពាល់ផ្សេងៗ ដើម្បីកាត់បន្ថយ ឬបញ្ចៀស បណ្តុំនៃផលប៉ះពាល់ដែលគួរឲ្យកត់សម្គាល់ទាំងនោះ ។

## ជំពូកទី៥
## ការចូលរួមជាសាធារណៈ

**មាត្រា១២៤** ._ គោលបំណងនៃការចូលរួមជាសាធារណៈ

គោលបំណងចម្បងនៃការចូលរួមជាសាធារណៈ គឺដើម្បីធានាថា អ្នកដែលទទួលរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធ ៖

ក- បានទទួលដំណឹងគ្រប់ជ្រុងជ្រោយអំពីគម្រោង ។

ខ- មានឱកាសចូលរួមក្នុងកិច្ចពិភាក្សា និងកិច្ចដំណើរការនៃការធ្វើសេចក្ដីសម្រេចពាក់ព័ន្ធនឹងគម្រោង ។

គ- មានឱកាសចូលរួមក្នុងការអង្កេតតាមដានគម្រោង ។

ម្ចាស់គម្រោងដែលត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវដាក់បញ្ចូលការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈ ពីរដ្ឋបាលថ្នាក់មូលដ្ឋាន សង្គមស៊ីវិល តំណាងសហគមន៍ ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត ទៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅដំណាក់កាលរៀបចំផែនការគម្រោង ដើម្បី៖

ក- កំណត់ផ្នែកដែលមានសារៈសំខាន់ផ្នែកបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

ខ- ប្រមូលមតិយោបល់ពីអ្នកពាក់ព័ន្ធ និងដាក់បញ្ចូលមតិយោបល់ទាំងនោះ ទៅក្នុងកិច្ចដំណើរការនៃការធ្វើសេចក្ដីសម្រេច ។

គ- ពិនិត្យគម្រោងស្នើសុំ និងពន្យល់ពីផលប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

ឃ- ពិចារណាជម្រើសដទៃទៀត និងវិធានការកាត់បន្ថយផលប៉ះពាល់នានា ។

នីតិវិធីនៃការចូលរួមជាសាធារណៈ នៅក្នុងដំណាក់កាលសិក្សាពិគ្រោះយោបល់ ការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការអង្កេតតាមដានគម្រោង ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា១២៥** ._ មតិយោបល់របស់សាធារណជន

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវ៖

ក- កត់ត្រាទុកនូវយោបល់របស់សាធារណជនដែលបានចូលរួម នៅក្នុងដំណាក់កាលរៀបចំផែនការ និងដំណាក់កាលអនុវត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ខ- ផ្ដោតលើបញ្ហានានា ដែលលើកឡើងដោយស្ត្រី និងបណ្ដាជនដែលអាចទទួលរងគ្រោះខ្លាំងបំផុត ពីផលប៉ះពាល់ដែលអាចកើតមានពីគម្រោងដែលបានស្នើឡើង ។

គ- ដាក់បញ្ចូលនូវសេចក្តីលំអិត អំពីផលប៉ះពាល់របស់គម្រោងដល់សាធារណជន និងការទទួលយក ឬបដិសេធសំណើរបស់សាធារណជន ។

ឃ- ផ្តល់ហេតុផលនៃការបដិសេធឲ្យបានច្បាស់លាស់ នៅក្នុងករណីដែលម្ចាស់គម្រោងបដិសេធសំណើរបស់សាធារណជន ។

**មាត្រា១២៦** ._ ការយល់ព្រមជាមុនដោយសេរីនិងបន្ទាប់ពីជ្រាបព័ត៌មានគ្រប់ជ្រុងជ្រោយដល់សហគមន៍

កិច្ចដំណើរការចូលរួមសាធារណៈត្រូវធានាថា មានការយល់ព្រមពីសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ចំពោះវិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នើឡើង ដោយផ្អែកលើគោលការណ៍យល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីជ្រាបព័ត៌មានគ្រប់ជ្រុងជ្រោយ ។

ក្នុងវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាននេះ ម្ចាស់គម្រោងត្រូវ ៖

ក- កំណត់វិធានការនានា ក្នុងការលើកកម្ពស់ជីវភាព និងជួយដល់អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ។

ខ- ធានាថា អ្នកដែលទទួលរងផលប៉ះពាល់ បានចូលរួមក្នុងការរៀបចំការផ្លាស់ទីលំនៅថ្មី ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការផ្លាស់ទីលំនៅថ្មីឲ្យបានកម្រិតអប្បបរមា ក្នុងការធានាថា សំណងលើការបាត់បង់ទ្រព្យសម្បត្តិ ត្រូវបានដោះស្រាយដោយយុត្តិធម៌សមស្របជាមុនសិន និងដែលទទួលយកបានតាមតម្លៃទីផ្សារ ហើយវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថានមានលក្ខណៈត្រឹមត្រូវ ។

ក្នុងករណីដែលសហគមន៍ដែលរងផលប៉ះពាល់ មិនយល់ស្របចំពោះវិធានការកាត់បន្ថយនានាដែលម្ចាស់គម្រោងបានស្នើខាងលើ គម្រោងអភិវឌ្ឍនៅតែបន្តដដែល ប៉ុន្តែម្ចាស់គម្រោងត្រូវកំណត់ រកវិធានការកាត់បន្ថយផលប៉ះពាល់ផ្សេងទៀត ឬដោះស្រាយរាល់ផលប៉ះពាល់នោះដល់សហគមន៍ ។

នីតិវិធីនៃការដោះស្រាយសំណងដល់សហគមន៍ដែលទទួលរងផលប៉ះពាល់ និងនីតិវិធីនៃការផ្លាស់ប្តូលំនៅថ្មី ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

បែបបទ និងនីតិវិធីនៃការទូទាត់សំណងការខូចខាត ដល់សហគមន៍ទទួលរងផលប៉ះពាល់ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា១២៧ ._** ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីជ្រាបព័ត៌មានគ្រប់ជ្រុងជ្រោយចំពោះជនជាតិដើមភាគតិច

ការចូលរួមជាសាធារណៈសម្រាប់សហគមន៍ជនជាតិដើមភាគតិច កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវតម្រូវឲ្យម្ចាស់គម្រោងជូនដំណឹងដល់សហគមន៍អំពីវិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នើឡើង មុនពេលដែលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវបញ្ជូនទៅក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ ម្ចាស់គម្រោងត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ដល់សហគមន៍ជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ ក្នុងការពិចារណាលើវិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នើឡើងនោះ ។ សហគមន៍ជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ ត្រូវឯកភាពលើវិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នើឡើងនោះ ដោយពុំមានទទួលរងសម្ពាធ ឬការបង្ខិតបង្ខំ ពីរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយនោះឡើយ ។

សហគមន៍ជនជាតិដើមភាគតិចដែលពាក់ព័ន្ធមានសិទ្ធិទទួលបាននូវការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ចំពោះការឯកភាពលើគម្រោងអភិវឌ្ឍណាមួយ ដែលអាចប៉ះពាល់ដល់ ដីធ្លីរបស់ពួកគេ ។

**មាត្រា១២៨ ._** ការចូលរួមជាសាធារណៈលើវិធានការកាត់បន្ថយ

កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវស្វែងរកនូវការយល់ព្រមពីអ្នកទទួលរងផលប៉ះពាល់ពីគម្រោង ចំពោះវិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នើឡើង ។ ម្ចាស់គម្រោងត្រូវផ្តល់នូវសេចក្តីព្រាងនៃផែនការគ្រប់គ្រងបរិស្ថាន ដែលត្រូវអនុញ្ញាតឲ្យមានការចូលរួមជាសាធារណៈ នៅក្នុងដំណើរការអង្កេតតាមដាន និងការគោរពតាមលក្ខខណ្ឌដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាននោះ ។

របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន ត្រូវពិចារណាអំពីមតិយោបល់នានា របស់អ្នកទទួលរងផលប៉ះពាល់ ចំពោះវិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នើឡើង ។

**មាត្រា១២៩ ._** ការផ្សព្វផ្សាយជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវធានាថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងឯកសារពាក់ព័ន្ធ រួមមាន លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយអ្នកពាក់ព័ន្ធ និង សហគមន៍ ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង អាចទទួលបានព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ ។

ម្ចាស់គម្រោងត្រូវធ្វើការផ្សព្វផ្សាយជាសារធារណៈ តាមរយៈគេហទំព័ររបស់ខ្លួន យ៉ាងហោច ណាស់ នូវឯកសារថតចម្លងនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ផែនការគ្រប់គ្រងបរិស្ថាននៃគម្រោង ផែនទី និងផែនការនៃគម្រោង ព្រមទាំងបណ្តាវិធានការកាត់ បន្ថយផលប៉ះពាល់នៃគម្រោងដែលត្រូវបានស្នើឡើង ។

នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ត្រូវកំណត់ដោយលិខិត បទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

## ជំពូកទី៦
## ផែនការគ្រប់គ្រងបរិស្ថាន និងការអង្កេតតាមដានគម្រោង

**មាត្រា១៣០ .**_ ការត្រួតពិនិត្យ និងអង្កេតតាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងមន្ទីរបរិស្ថានរាជធានី ខេត្ត ជាអាជ្ញាធរត្រួតពិនិត្យ លើផែនការគ្រប់គ្រងបរិស្ថាន និងអង្កេតតាមដានសកម្មភាពអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ ម្ចាស់គម្រោង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ ។

**មាត្រា១៣១ .**_ ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថានត្រូវរៀបចំដោយម្ចាស់គម្រោង ។

ផែនការគ្រប់គ្រងបរិស្ថាន ត្រូវដាក់បញ្ចូលលក្ខខណ្ឌតម្រូវនៃការការពារ ការកាត់បន្ថយ ការអង្កេតតាមដាន និងការគ្រប់គ្រង ដែលបានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ បរិស្ថានដំបូង និងពេញលេញ ។

ផែនការគ្រប់គ្រងបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ដោយអនុលោមតាមការវិវឌ្ឍន៍ ជាក់ស្តែងនៃស្តង់ដារបរិស្ថាន ឬការអនុវត្តជាក់ស្តែងដែលទទួលស្គាល់ជាទូទៅក្នុងវិស័យនីមួយៗ ឬ ការប្រែប្រួលស្ថានភាពផ្សេងៗនៃគម្រោង ។

**មាត្រា១៣២ .**_ ប្រព័ន្ធគ្រប់គ្រងបរិស្ថានផ្ទៃក្នុង

រាល់គម្រោងអភិវឌ្ឍ និងអ្នកប្រតិបត្តិការគម្រោង ត្រូវបង្កើត និងរក្សាប្រព័ន្ធគ្រប់គ្រងបរិស្ថានផ្ទៃ ក្នុង ដែលត្រូវធានាឲ្យមាននូវនីតិវិធី និងវិធីសាស្ត្រអង្កេតតាមដានដោយខ្លួនឯង ដូចមានចែងក្នុង ផែនការគ្រប់គ្រងបរិស្ថានរបស់ខ្លួន ។

ក្នុងករណីផលប៉ះពាល់បរិស្ថាន មានទំហំធំជាងផលប៉ះពាល់ដែលត្រូវបានប៉ាន់ប្រមាណនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ក្រសួងទទួលបន្ទុកវិស័យបរិស្ថានតម្រូវឲ្យចាត់វិធានការកែតម្រូវផលប៉ះពាល់ភ្លាមៗឬកែតម្រូវផែនការគ្រប់គ្រងបរិស្ថាន ។

ផែនការគ្រប់គ្រងបរិស្ថានដែលបានកែតម្រូវរួច និងកម្មវិធីអង្កេតតាមដាន ត្រូវទទួលបានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ រយៈពេលកំណត់ ដើម្បីធ្វើការកែតម្រូវ ឬកែលម្អជាថ្មីឡើងវិញ ត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរដោយភាគីពាក់ព័ន្ធ ។

ម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថានរៀងរាល់ ៣(បី)ខែម្តង ហើយបញ្ជូនមកអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីពិនិត្យ និងវាយតម្លៃ ។ អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសិទ្ធិចុះត្រួតពិនិត្យដល់កន្លែង និងផ្ទៀងផ្ទាត់លទ្ធផល នៃការអង្កេតតាមដានរបស់ម្ចាស់គម្រោង ។

**មាត្រា១៣៣**._ សិទ្ធិរាយការណ៍ពីបញ្ហាបរិស្ថាន

អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង និងអ្នកពាក់ព័ន្ធនានា ត្រូវមានសិទ្ធិរាយការណ៍ពីបញ្ហា និងក្តីកង្វល់បរិស្ថាន និងសង្គម ជូនដល់ម្ចាស់គម្រោង និងដាក់បណ្តឹងទៅស្ថាប័នមានសមត្ថកិច្ច ។

ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវឆ្លើយតបចំពោះបណ្តឹង ឬញត្តិ ហើយដោះស្រាយបញ្ហាបរិស្ថាន និងសង្គម ដែលពាក់ព័ន្ធ តាមពេលវេលាកំណត់សមស្រប និងផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធតាមស្ថានភាពជាក់ស្តែង ។

បែបបទ និងនីតិវិធីនៃការដោះស្រាយបណ្តឹង ឬញត្តិនេះត្រូវកំណត់យោងតាមនីតិវិធីនៃការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានចែងក្នុងក្រមនេះ ។

**មាត្រា១៣៤**._ គម្រោងតម្រូវធ្វើសវនកម្មបរិស្ថានខាងក្រៅ

គម្រោងនានាដែលត្រូវបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានស្តីពីបញ្ជីនៃគម្រោងដែលតម្រូវឲ្យមានការធ្វើសវនកម្មបរិស្ថានខាងក្រៅ ត្រូវធ្វើសវនកម្មដោយសវនករបរិស្ថានខាងក្រៅ ដែលមានលក្ខណៈសម្បត្តិដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែក របស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ស្តីពីការធ្វើសវនកម្មបរិស្ថានខាងក្រៅ ។

សវនករបរិស្ថានខាងក្រៅ មានភារកិច្ច និងតួនាទីដូចខាងក្រោម៖

ក- ជួយជ្រោមជ្រែងក្នុងការកត់ត្រាកំណត់ត្រាបរិស្ថានឲ្យបានត្រឹមត្រូវនិងពេញលេញ។

ខ- ផ្តល់មតិយោបល់សវនកម្មវិជ្ជាជីវៈមានជាអាទិ៍ របាយការណ៍បរិស្ថានដែលបង្ហាញនូវទិដ្ឋភាពពេញលេញ និងសមស្របអំពីការគ្រប់គ្រងបរិស្ថាននៃគម្រោង ឬការប្រតិបត្តិការរបស់គម្រោង ។

គ- ពិនិត្យភាពគ្រប់គ្រាន់នៃការអនុវត្ត នីតិវិធីនៃការគ្រប់គ្រង និងការអង្កេតតាមដានបរិស្ថានផ្ទៃក្នុង ព្រមទាំងការផ្តល់អនុសាសន៍ដើម្បីកែលម្អ ។

ឃ- ផ្តល់ព័ត៌មានអំពីភាពមិនប្រក្រតី និងការខ្វះចន្លោះក្នុងការគ្រប់គ្រងបរិស្ថានផ្ទៃក្នុងរបស់ខ្លួន ។

សំណៅមួយច្បាប់នៃរបាយការណ៍សវនកម្ម ដែលធ្វើឡើងដោយសវនករបរិស្ថានខាងក្រៅ ត្រូវប្រគល់ជូនក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា១៣៥** ._ ការរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន

គម្រោងអភិវឌ្ឍនីមួយៗត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោងដូចតទៅៈ

ក- របាយការណ៍រៀងរាល់ ៣(បី) ខែ ដែលរាយកាណ៍ពីលទ្ធផលទាំងអស់នៃការអង្កេតតាមដាន និងការគ្រប់គ្រងបរិស្ថាន ដែលត្រូវបញ្ជូនទៅអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ខ- ក្នុងរយៈពេល ៣ (បី) ខែ បន្ទាប់ពីបញ្ចប់ឆ្នាំហិរញ្ញវត្ថុនីមួយៗ ម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ប្រចាំឆ្នាំ ដែលដាក់បញ្ចូលមតិយោបល់របស់សវនករស្តីពីបរិស្ថាន ។

គ- ផ្តល់សំណៅរបាយការណ៍បរិស្ថានប្រចាំឆ្នាំ នៃគម្រោងដល់សាធារណជន តាមការស្នើសុំដោយឥតគិតថ្លៃ ។

ឃ- ផ្តល់សំណៅអេឡិចត្រូនិក ដែលត្រូវបង្ហោះលើគេហទំព័រជាសាធារណៈ របស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងដោយម្ចាស់គម្រោង នៅលើគេហទំព័រ សាធារណៈ ។

**មាត្រា១៣៦** ._ ការៀបចំបញ្ជូនរបាយការណ៍ប្រចាំត្រីមាស និងឆមាស

គម្រោងអភិវឌ្ឍ ដែលមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបញ្ជូនរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆមាស ទៅអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានទាក់ទងនឹងការអង្កេតតាមដាន និងការគ្រប់គ្រងបរិស្ថានរបស់ខ្លួន ។

ម្ចាស់គម្រោងមានកាតព្វកិច្ចត្រូវរាយការណ៍ភ្លាមៗ អំពីបញ្ហាបរិស្ថានសំខាន់ដល់អាជ្ញាធរដែលពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច និងដល់សាធារណជន ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន ឬសង្គម ។

ម្ចាស់គម្រោង ត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាននៃគម្រោង ដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន តាមការស្នើសុំរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

## ជំពូកទី៧
## ការវាយតម្លៃហេតុប៉ះពាល់ឆ្លងដែន

**មាត្រា១៣៧ .**_ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន

គម្រោងដែលអាចមានផលប៉ះពាល់បរិស្ថានឆ្លងដែន ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ស្តីពីលក្ខណៈវិនិច្ឆ័យកំណត់ពីសញ្ញាណនៃផលប៉ះពាល់បរិស្ថានឆ្លងដែន និងឈានទៅដល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ។

បែបបទ និងនីតិវិធី នៃការអនុវត្តការវាយតម្លៃហេតុប៉ះពាល់ឆ្លងដែន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដាច់ដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

## មាតិកាទី៤
## សវនកម្មបរិស្ថាន ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍
## ជំពូកទី១
## សវនកម្មបរិស្ថាន

**មាត្រា១៣៨ .**_ សវនកម្មបរិស្ថាន

ការអនុវត្តគម្រោង ឬសកម្មភាពណាមួយដែលទទួលបានការឯកភាព ឬលិខិតអនុញ្ញាតត្រូវមានការធ្វើសវនកម្មបរិស្ថាន ដែលមានលក្ខណៈឯករាជ្យនិងត្រូវបានចងក្រងទុកជាឯកសារ ។

ការធ្វើសវនកម្មបរិស្ថានមានដូចខាងក្រោម៖

ក- ពិនិត្យ និងបញ្ជាក់ពីគម្រោង ឬសកម្មភាពណាមួយដែលអនុលោមតាមលក្ខខណ្ឌតម្រូវរបស់ក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ខ- កំណត់បង្ហាញផលប៉ះពាល់បរិស្ថានរបស់គម្រោង ឬសកម្មភាពមួយ ។

គ- កំណត់ និងបង្ហាញពីវិធានការណាមួយដែលអាចអនុវត្តបាន ដើម្បីធ្វើការកែតម្រូវឲ្យស្របតាមលក្ខខណ្ឌតម្រូវ ។

ឃ- កាត់បន្ថយហេតុប៉ះពាល់បរិស្ថានជាអប្បបរិមា ។

**មាត្រា១៣៩** ._ វិសាលភាពនៃគម្រោង ឬសកម្មភាពដែលត្រូវធ្វើសវនកម្មបរិស្ថាន

គម្រោង ឬសកម្មភាពដែលជាកម្មវត្ថុនៃការធ្វើសវនកម្មបរិស្ថាន និងនីតិវិធីនៃការធ្វើសវនកម្មបរិស្ថាន រួមបញ្ចូល រយៈពេលជាក់លាក់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា១៤០** ._ ការចំណាយចំពោះការធ្វើសវនកម្មបរិស្ថាន

រាល់ការចំណាយ ដែលទាក់ទិនជាមួយការធ្វើសវនកម្មបរិស្ថាន ត្រូវស្ថិតក្រោមការទទួលខុសត្រូវរបស់ប្រតិបត្តិករ ឬម្ចាស់គម្រោង ។

**មាត្រា១៤១** ._ ការខកខាន មិនបានធ្វើតាមបទបញ្ជា ឬលក្ខខណ្ឌតម្រូវ

ក្នុងករណីដែលគម្រោង ឬសកម្មភាពណាមួយ ខកខានមិនបានធ្វើតាមបទបញ្ជា ឬលក្ខខណ្ឌតម្រូវក្នុងការធ្វើសវនកម្មបរិស្ថាន ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬសវនករបរិស្ថានដែលត្រូវបានទទួលស្គាល់ និងបានតែងតាំងដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបានអនុញ្ញាតឲ្យធ្វើសវនកម្មបរិស្ថាន និងអាចចូលទៅកាន់ ទីតាំង ដើម្បីធ្វើសវនកម្មបរិស្ថានលើគម្រោង ឬសកម្មភាពណាមួយនោះ ។

ម្ចាស់គម្រោង ឬប្រតិបត្តិករ គម្រោង ឬសកម្មភាព ត្រូវផ្តល់ជូន ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានវិញសម្រាប់ការចំណាយដែលទាក់ទងទៅនឹងសវនកម្មបរិស្ថានដែលធ្វើឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬសវនករបរិស្ថានដែលបានតែងតាំងដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា១៤២** ._ ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលតម្រូវឱ្យមានការឯកភាព ឬលិខិតអនុញ្ញាត ស្របតាមក្រមនេះ ត្រូវអនុវត្តការអង្កេតតាមដាន និងរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន ស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងនៅក្នុងក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ។

**មាត្រា១៤៣** ._ ដំណោះស្រាយផលប៉ះពាល់

ក្នុងករណីដែលសវនកម្មបរិស្ថានបង្ហាញឲ្យឃើញថា ផលប៉ះពាល់របស់គម្រោង និងឬសកម្មភាពនោះធំជាងអ្វីដែលបានប៉ាន់ប្រមាណនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬផែនការគ្រប់គ្រងបរិស្ថាន

ដែលពាក់ព័ន្ធ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវចាត់វិធានការភ្លាមៗដើម្បីដោះស្រាយផលប៉ះពាល់ទាំងនោះ និងបញ្ជាឲ្យធ្វើការកែតម្រូវលើផែនការគ្រប់គ្រងបរិស្ថានឲ្យបានសមស្រប ដើម្បីបញ្ចៀសផលប៉ះពាល់នៅពេលអនាគត ។

**មាត្រា១៤៤ ._** សិទ្ធិទទួលបានព័ត៌មាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវដាក់របាយការណ៍សវនកម្មបរិស្ថានឲ្យសាធារណជនអាចស្វែងរកបាន ក្រោយពេលដែលសវនកម្មបរិស្ថាននោះ ត្រូវបានដាក់បញ្ជូនទៅកាន់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន ។

## ជំពូកទី២
## ការតែងតាំង និងលក្ខណៈសម្បត្តិរបស់សវនករបរិស្ថាន

**មាត្រា១៤៥ ._** លក្ខខណ្ឌតម្រូវក្នុងការទទួលបាននីតិសម្បទា

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបាននីតិសម្បទាស្របតាមមាតិកានេះ និងលិខិតបទដ្ឋានគតិយុត្ត ដែលត្រូវបានចេញស្របតាមមាតិកានេះ ត្រូវទទួលបានការអនុញ្ញាតឱ្យអនុវត្តសវនកម្មបរិស្ថាន ។ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលអនុវត្តសវនកម្មបរិស្ថាន ត្រូវទទួលនីតិសម្បទា និងការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ នីតិវិធី និងគោលការណ៍ណែនាំក្នុងការទទួលស្គាល់សវនកម្មបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

## គន្ថីទី៣
## ការគ្រប់គ្រងបរិស្ថាន និងយន្តការនិរន្តរភាព
## មាតិកាទី១
## ការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ
## ជំពូកទី១
## គោលការណ៍ និងការរៀបចំផែនការគ្រប់គ្រងគ្រោះមហន្តរាយ

**មាត្រា១៤៦ ._** ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានលើការគ្រប់គ្រងគ្រោះមហន្តរាយ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវគាំទ្រ និងសហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងការបំពេញមុខងារដូចខាងក្រោម៖

១- ដើម្បីរៀបចំ បង្កើត វិធីសាស្ត្រនៃការការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ដែលមានលក្ខណៈទូលំទូលាយ រួមគ្នា និងមានសកម្មភាពមុន ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយ ដែលបង្កឡើងដោយធម្មជាតិ ឬមនុស្សទៅកាន់បរិស្ថាន ។

២- ត្រៀមបង្ការ កាត់បន្ថយ និងរៀបចំ មុនពេលមានគ្រោះមហន្តរាយ ការឆ្លើយតបសង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ និង ការស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ ។

៣- គាំទ្រដល់ការអនុវត្តតួនាទីភារកិច្ច និងតួនាទីរបស់គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយជាធរមាន ។

៤- រកបុព្វហេតុ ឬសគល់នៃភាពងាយរងគ្រោះចំពោះគ្រោះមហន្តរាយដែលមានសក្តានុពល និងគ្រោះមហន្តរាយដែលមានស្រាប់ ។

៥- ពង្រឹងសមត្ថភាពស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ទៅលើការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យ គ្រោះមហន្តរាយ ។

៦. ធ្វើការជាមួយសហគមន៍មូលដ្ឋាន ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បី បង្កើតភាពធន់របស់សហគមន៍មូលដ្ឋានទៅនឹងគ្រោះមហន្តរាយ រួមមានផលប៉ះពាល់ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុជាអាទិ៍ ។

**មាត្រា១៤៧** ._ ការរៀបចំផែនការ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយដែលប៉ះពាល់ទៅដល់បរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវគាំទ្រ និងសហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដើម្បីបំពេញកិច្ចការដូចខាងក្រោម៖

១- ជួយរៀបចំផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដែលផ្តោតទៅលើគ្រោះមហន្តរាយ ដែលបង្កឡើងដោយធម្មជាតិ ឬមនុស្ស ដែលប៉ះពាល់ទៅដល់បរិស្ថាន ។

២- រៀបចំបង្កើត និងអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដើម្បីធ្វើការសិក្សាប៉ាន់ប្រមាណហានិភ័យ និងរិះរកបច្ចេកទេស សម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងរៀបចំបង្កើតផែនការត្រៀមបម្រុងសម្រាប់ជំនួយគ្រោះមហន្តរាយ ដែលបង្កឡើងដោយធម្មជាតិ ឬមនុស្ស ដែលប៉ះពាល់ទៅដល់បរិស្ថាន និងការឆ្លើយតបសង្គ្រោះបន្ទាន់ ។

**មាត្រា១៤៨ .**_ ការយល់ដឹង ការបណ្តុះបណ្តាល និងការអប់រំ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវគាំទ្រ និងសហការជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ លើកកម្ពស់ ការយល់ដឹងជាសាធារណៈ រៀបចំបង្កើត និងផ្តល់ការបណ្តុះបណ្តាល និងការអប់រំ និងលើកទឹកចិត្តឲ្យមានការ ចូលរួម ពាក់ព័ន្ធទៅនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការត្រួតពិនិត្យ និងការត្រៀមបង្ការគ្រោះមហន្តរាយ រួមមានការបង្កើតប្រព័ន្ធប្រកាសឲ្យដឹងមុនជាអាទិ៍ ។

**មាត្រា១៤៩ .**_ ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន

ការរៀបចំបង្កើត ការធ្វើទំនើបនីយកម្ម និងការចែកចាយអំពីព័ត៌មាន និងការធ្វើផែនការកាត់បន្ថយ ហានិភ័យគ្រោះមហន្តរាយ ត្រូវអនុលោមទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ដែលមានចែងនៅក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។

**មាត្រា១៥០ .**_ លក្ខខណ្ឌតម្រូវក្នុងការពិគ្រោះយោបល់

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវពិគ្រោះយោបល់ ជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្នុងការបង្កើតលិខិតបទដ្ឋានគតិយុត្ត និងការរៀបចំផែនការគ្រប់គ្រងគ្រោះមហន្តរាយដ៏ទៃទៀតទាំងអស់ ដែលពាក់ព័ន្ធទៅនឹងគ្រោះមហន្តរាយ ដែលបង្កឡើងដោយធម្មជាតិ ឬមនុស្ស ដែលប៉ះពាល់ទៅ ដល់បរិស្ថាន ។

## មាតិកាទី២
## ការប្រែប្រួលអាកាសធាតុ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១៥១ .**_ វិសាលភាពនៃការអនុវត្ត

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងរដ្ឋបាល និងការសម្របសម្រួលលើសកម្មភាពដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ ស្របតាមក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដ៏ទៃទៀត ។ ក្រសួង ស្ថាប័នពាក់ព័ន្ធ ទទួលខុសត្រូវស្របតាមមុខងាររៀងៗខ្លួន ។

**មាត្រា១៥២ ._** តួនាទី និងការទទួលខុសត្រូវ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវ ដឹកនាំការចរចាអំពីការប្រែប្រួលអាកាសធាតុជាលក្ខណៈអន្តរជាតិ ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស តាមរយៈអគ្គលេខាធិការដ្ឋានរបស់ខ្លួន និង ពាក់ព័ន្ធដទៃទៀត ទៅដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើរតួនាទីជាអង្គភាពបង្គោល ជាមួយអ្នកពាក់ព័ន្ធដទៃទៀតអំពីគោលនយោបាយ និងការរៀបចំកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុ និងផ្តល់អនុសាសន៍អំពីវិធានការជាគោលនយោបាយជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី២
## គោលនយោបាយ យុទ្ធសាស្ត្រ ផែនការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

**មាត្រា១៥៣ ._** ផែការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ

ដោយអនុលោមតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣នៃក្រមនេះ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវបង្កើត ធ្វើបច្ចុប្បន្នភាព និងសម្រប សម្រួលផែនការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុរយៈពេលវែង ដោយដោះស្រាយអំពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ការបន្សាំ ហិរញ្ញវត្ថុ ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិជ្ជា និងការកសាងសមត្ថភាព ស្របតាមគោលនយោបាយជាតិពាក់ព័ន្ធស្តីពីការប្រែប្រួលអាកាសធាតុ និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

**មាត្រា១៥៤ ._** ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំផែនការត្រូវៈ

ក- ដាក់បញ្ចូលការពិចារណាអំពីការប្រែប្រួលអាកាសធាតុ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

ខ- បង្កើតសេចក្តីណែនាំស្តីពីការអនុលោមតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

គ- ផ្តល់ការណែនាំដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធ និងធានាឲ្យបាននូវការគោរពតាមច្បាប់ ដោយសហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។

**មាត្រា១៥៥ ._** ផែនការតាមវិស័យ គម្រោងថវិកា និងក្របខ័ណ្ឌ

ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវកំណត់ ដាក់បញ្ចូល និងអនុវត្តសកម្មភាពឆ្លើយតបចំពោះ ការប្រែប្រួលអាកាសធាតុ ចូលទៅក្នុងផែនការតាមវិស័យពាក់ព័ន្ធទាំងអស់ គម្រោងថវិកា និងក្របខ័ណ្ឌនៃការអង្កេតតាមដាន ស្របតាមគោលនយោបាយជាតិស្តីពីការប្រែប្រួលអាកាសធាតុពាក់ព័ន្ធ លិខិត

បទដ្ឋានគតិយុត្តដែលចេញដោយក្រសួងពាក់ព័ន្ធ និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវផ្តល់យោបល់ផ្នែកបច្ចេកទេសស្តីពីការដាក់បញ្ចូលសកម្មភាពឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការតាមវិស័យ គម្រោងថវិកា និងក្របខ័ណ្ឌនានា ។

**មាត្រា១៥៦** ._ ការរៀបចំផែនការអភិវឌ្ឍ និងវិនិយោគ

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំផែនការ គណៈកម្មការ ជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវពិចារណាអំពីផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុ នៅក្នុងការរៀបចំ ផែនការអភិវឌ្ឍ និងវិនិយោគទាំងអស់ ។

អជ្ញាធរថ្នាក់ក្រោមជាតិទាំងអស់ ត្រូវសហការជាមួយមន្ទីរខេត្តនៃក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីដាក់បញ្ចូលផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងវិធានការឆ្លើយតបនៅក្នុង ការរៀបចំផែនការអភិវឌ្ឍ និងវិនិយោគ រួមមានការរៀបចំផែនការប្រើប្រាស់ដីជាអាទិ៍ ។ សកម្មភាពនៃការប្រែប្រួលអាកាសធាតុ ដែលហួសពីសមត្ថភាពហិរញ្ញវត្ថុ ឬ សមត្ថកិច្ចភូមិសាស្ត្រនៃអជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវបញ្ជូនទៅថ្នាក់លើដើម្បីពិចារណា ។

**មាត្រា១៥៧** ._ ផែនការ និងយុទ្ធសាស្ត្រឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

អជ្ញាធរថ្នាក់ក្រោមជាតិទាំងអស់ត្រូវរចនា និងអនុវត្តផែនការ និងយុទ្ធសាស្ត្រ ក្នុងការឆ្លើយ តបចំពោះការប្រែប្រួលអាកាសធាតុ ស្របតាមគោលនយោបាយជាតិស្តីពីការប្រែប្រួលអាកាសធាតុពាក់ព័ន្ធ ដោយសហការជាមួយមន្ទីរខេត្តនៃក្រសួង និងស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី៣
## ការអនុវត្តនូវការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

**មាត្រា១៥៨** ._ ប្រភេទនៃការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីអនុវត្តន៍ការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ដូចខាងក្រោម៖

ក- វិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ មានជាអាទិ៍៖

១- ការវាយតម្លៃភាពងាយរងគ្រោះនៃប្រព័ន្ធជីវសាស្ត្រ សង្គម និងសេដ្ឋកិច្ចចំពោះ ការប្រែប្រួលអាកាសធាតុ រួមមាន វិស័យដែលងាយទទួលរងបញ្ហាអាកាសធាតុ និង តំបន់ភូមិសាស្ត្រ ដែលងាយទទួលរងគ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ និង កំណត់ឱកាសសម្រាប់ការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុជាអាទិ៍ ។

២- ការបង្កើត និងអនុវត្តហេដ្ឋារចនាសម្ព័ន្ធដែលធន់ស៊ាំទៅនឹងអាកាសធាតុ និងដែលប្រើប្រាស់កាបូនទាប រួមមាន សម្រាប់វិស័យកសិកម្ម ជលផល ដឹកជញ្ជូន និងថាមពលជាអាទិ៍ ។

៣- ការបង្កើត និងអនុវត្តវិធានការគ្រប់គ្រងសម្រាប់តំបន់ការពារធម្មជាតិ ដើម្បីបន្ស៊ាំទៅនឹង ការប្រែប្រួលអាកាសធាតុ ។

៤- ការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធផ្តល់ព័ត៌មានជាមុន និងការផ្សព្វផ្សាយព័ត៌មានអាកាសធាតុទាន់ពេលវេលា ។

៥- ការលើកកម្ពស់ទម្លាប់នៃការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ដែលបង្កើនភាពធន់ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

៦- ការលើកកម្ពស់ការទទួលបានថាមពល ទឹក ការដឹកជញ្ជូន សេវាសុខភាព និងអនាម័យ ដែលអាចលៃលកបាន ជាពិសេស ដោយមានគោលដៅចំពោះប្រជាពលរដ្ឋ ដែលងាយរងគ្រោះបំផុត ។

ខ- វិធានការកាត់បន្ថយការប្រែប្រួលអាកាសធាតុ មានជាអាទិ៍៖

១- លើកកម្ពស់ និងធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធផលថាមពលទូទាំងព្រះរាជាណាចក្រកម្ពុជា ។

២- លើកកម្ពស់ និងការបង្កើត និងការប្រើប្រាស់នូវថាមពលកកើតឡើងវិញ ទូទាំងគ្រប់វិស័យទាំងអស់ ។

៣- បង្កើនផលិតកម្មថាមពលតាមបណ្តាញវិមជ្ឈការដែលមានភាពធន់ស៊ាំ និងផលិតកម្មថាមពលក្រៅបណ្តាញ ។

៤- លើកកម្ពស់ការបង្កើត និងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈទ្រង់ទ្រាយធំ និងការប្រើប្រាស់ការដឹកជញ្ជូនដែលប្រើប្រាស់ឥន្ធនៈប្រកបដោយប្រសិទ្ធផល និងការដឹកជញ្ជូនដែលប្រើប្រាស់កាបូនទាប ។

៥- បង្កើនគម្របព្រៃឈើ និងលើកកម្ពស់ការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃព្រៃផ្តល់ផល និងយន្តការដើម្បីលើកកម្ពស់ការអភិរក្សព្រៃឈើ រួមមានកម្មវិធីរេដបូកជាអាទិ៍ ។

៦- លើកកម្ពស់ទម្លាប់គ្រប់គ្រងការប្រើប្រាស់ដីដោយត្រឹមត្រូវ ដើម្បីការពារអាងកាបូន និងដាក់កម្រិតចំពោះការបំភាយឧស្ម័នផ្ទះកញ្ចក់ ។

គ- សកម្មភាពផ្តល់លទ្ធភាពនានា មានជាអាទិ៍៖

១- ពង្រឹងសមត្ថភាពស្ថាប័ន និងបច្ចេកទេស ដើម្បីអនុវត្តន៍ការឆ្លើយតបចំពោះ បញ្ហាអាកាសធាតុ ។

២- ពង្រឹងចំណេះដឹងការប្រែប្រួលអាកាសធាតុស្តីពីការបន្សាំ និងទម្លាប់អនុវត្ត ការកាត់បន្ថយ និង បច្ចេកវិជ្ជានានា ដែលសមរម្យបំផុតចំពោះបរិបទកម្ពុជា ។

៣- លើកកម្ពស់ការស្រាវជ្រាវ ការផ្ទេរបច្ចេកវិជ្ជា ការអប់រំ កិច្ចសហកាអន្តរជាតិ នៅក្នុងគ្រប់តំបន់ទាំងអស់នៃការប្រែប្រួលអាកាសធាតុ ។

៤- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុ ។

៥- កៀងគរហិរញ្ញវត្ថុអាកាសធាតុ ។

**មាត្រា១៥៩** ._ ការសម្របសម្រួលកិច្ចសហការ និងការបង្កើតភាពជាដៃគូ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវៈ

ក- សម្របសម្រួលកិច្ចសហការជាលក្ខណៈអន្តរក្រសួង និងការចូលរួមរបស់អជ្ញាធរថ្នាក់ក្រោមជាតិក្នុងការរចនា និងការអនុវត្តសកម្មភាពការប្រែប្រួលអាកាសធាតុ រួមមាននូវការផ្តល់យន្តការសម្រាប់ការសម្រេចចិត្តផ្នែកបច្ចេកទេសជាលក្ខណៈអន្តរក្រសួងជាអាទិ៍ ។

ខ- បង្កើតភាពជាដៃគូ និងអនុស្សារណៈយោគយល់សម្រាប់ការអនុវត្ត និងបង្កើន ការឆ្លើយតប និងកិច្ចអន្តរាគមន៍នៃការប្រែប្រួលអាកាសធាតុរវាងរដ្ឋាភិបាល និងអង្គភាព មិនមែនរដ្ឋាភិបាល រួមមានសកម្មភាពនៃការកាត់បន្ថយសមស្របជាលក្ខណៈជាតិជាអាទិ៍ ។

**មាត្រា១៦០** ._ ការប្រែប្រួលអាកាសធាតុក្នុងសកម្មភាពអនុវត្ត

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរួមបញ្ចូលនូវការពិចារណាអំពីការប្រែប្រួលអាកាសធាតុទៅក្នុងការរចនានូវរាល់សកម្មភាពអនុវត្តទាំងអស់ និងពិចារណាទៅលើផលប៉ះពាល់នៃសកម្មភាពនោះ ទៅលើការបំភាយឧស្ម័នផ្ទះកញ្ចក់ ការប្រឈមទៅនឹងហានិភ័យអាកាសធាតុ និងសមត្ថភាពបន្សាំ ។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវផ្តល់ដំបូន្មានផ្នែកបច្ចេកទេសទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធទៅលើការរចនានូវសកម្មភាពអនុវត្តន៍ រួមមានវិធានការណ៍ បច្ចេកទេស និង ដំណើរការ ឆ្លើយតបទៅលើការសាកល្បងតាមផ្នែកជាក់លាក់មួយៗជាអាទិ៍ ។

**មាត្រា១៦១** ._ ការប្រែប្រួលអាកាសធាតុក្នុងការធ្វើការសម្រេចចិត្ត

ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវធានាថាត្រូវធ្វើការពិចារណាអំពីការប្រែប្រួលអាកាសធាតុក្នុងដំណើការធ្វើការសម្រេចចិត្តពាក់ព័ន្ធទាំងអស់ទាក់ទិននឹងការអនុវត្តសកម្មភាពក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទាំងនោះ ។

**មាត្រា១៦២** ._ លិខិតបទដ្ឋានគតិយុត្តសម្រាប់ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ លិខិតបទដ្ឋានគតិយុត្តត្រូវធ្វើបច្ចុប្បន្នកម្មរៀងរាល់ ៥ (ប្រាំ)ឆ្នាំម្តង។

## ជំពូកទី៤
## ការអង្កេតតាមដាន និងការវាយតម្លៃការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

**មាត្រា១៦៣** ._ ក្របខ័ណ្ឌអង្កេតតាមដាន និងការវាយតម្លៃថ្នាក់ជាតិ

ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំផែនការ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដ៏ទៃទៀត ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវបង្កើតនិងគ្រប់គ្រងក្របខ័ណ្ឌអង្កេតតាមដាន និងការវាយតម្លៃថ្នាក់ជាតិ ដើម្បីតាមដានវឌ្ឍនភាពរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការដោះស្រាយ បញ្ហាប្រឈមដែលបង្កដោយការប្រែប្រួលអាកាសធាតុ និងជូនដំណឹងអំពីការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាព នៃការឆ្លើយតបទៅលើការប្រែប្រួលអាកាសធាតុរបស់ព្រះរាជាណាចក្រកម្ពុជា ។

ក្របខ័ណ្ឌនេះត្រូវរួមមានការវិភាគនូវកម្រិតត្រៀមរួចរាល់នៃស្ថាប័នរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តការឆ្លើយតបទៅលើការប្រែប្រួលអាកាសធាតុរបស់ព្រះរាជាណាចក្រកម្ពុជាប្រកបដោយប្រសិទ្ធភាព ក៏ដូចជាការធ្វើកិច្ចអន្តរាគមន៍អាកាសធាតុក្នុងការកាត់បន្ថយភាពងាយរងគ្រោះ និងបន្ថយការបំភាយកាបូនឲ្យស្ថិតក្នុងកម្រិតទាប និងផ្លាស់ប្តូរទៅរកការអភិវឌ្ឍដែលមានលក្ខណៈធន់ស៊ាំដោយប្រើកាបូនទាប ។

**មាត្រា១៦៤** ._ ក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃតាមវិស័យ

ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវបង្កើត និងគ្រប់គ្រងនូវក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលបរិស្ថានតាមវិស័យដើម្បីតាមដានប្រសិទ្ធភាពនៃការឆ្លើយតបវិធានការណ៍ដែលដាក់ចេញក្នុងផែនការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមវិស័យពាក់ព័ន្ធ ដោយមានការគាំទ្រពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងធ្វើរបាយការណ៍ជាទៀងទាត់ទៅកាន់ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។ ក្របខ័ណ្ឌនេះត្រូវធ្វើឡើងស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលចេញដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។

**មាត្រា១៦៥** ._ លិខិតបទដ្ឋានគតិយុត្ត សម្រាប់ក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវចេញនូវលិខិតបទដ្ឋានគតិយុត្ត សម្រាប់ ការបង្កើត និងគ្រប់គ្រងក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលតាមវិស័យក្នុងរយៈពេល ១ (មួយ)ឆ្នាំ

នៃការអនុម័យក្រមនេះ ។ លិខិតបទដ្ឋានគតិយុត្តនេះ ត្រូវអនុលោមតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាននៃក្រមនេះ ។

**មាត្រា១៦៦** ._ សកម្មភាពអង្កេតតាមដាន និងវាយតម្លៃ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវសម្របសម្រួល និងសកម្មភាពអង្កេតតាមដាន និងវាយតម្លៃដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវសកម្មភាពអង្កេតតាមដាន និងវាយតម្លៃដែលតម្រូវទាំងអស់ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃមាតិកានេះ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

អជ្ញាធរថ្នាក់ក្រោមជាតិទាំងអស់ ត្រូវធ្វើសកម្មភាពអង្កេតតាមដាន និងវាយតម្លៃ ស្របតាមក្របខ័ណ្ឌ និងលិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដាននិងការវាយតម្លៃតាមវិស័យ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងដោយសហការជាមួយមន្ទីខេត្តនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។

**មាត្រា១៦៧** ._ ការរៀបចំរបាយការណ៍ស្តីពីការអង្កេតតាមដាន និងការវាយតម្លៃ

រាល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវរាយការណ៍ឲ្យទាន់ពេលវេលាទៅកាន់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពស្តីពីសូចនករពាក់ពន្ធ័នៃក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃថ្នាក់ជាតិ លិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដាន និងវាយតម្លៃដែលពាក់ព័ន្ធ នឹងការប្រែប្រួលអាកាសធាតុដទៃទៀត និងស្តីពីក្របខ័ណ្ឌស្តីពីការអង្កេតតាមដាននិងការវាយតម្លៃ តាមវិស័យស្របជាមួយនឹងលិខិតបទដ្ឋានគតិយុត្ត។ របាយការណ៍នេះ ត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ដែលមានចែងក្នុងគន្លឹទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។

**មាត្រា១៦៨** ._ ការរៀបចំរបាយការណ៍ជាអន្តរជាតិ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរាយការណ៍ទៅកាន់អង្គការអន្តរជាតិ ស្តីពីការអនុវត្តរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការឆ្លើយតបទៅលើការប្រែប្រួលអាកាសធាតុ រួមមានការប្រព្រឹត្តស្របតាមកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយនិរន្តភាព ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខីជាអាទិ៍ ។

**មាត្រា១៦៩** ._ លិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការចាត់វិធានការណ៍ ការរៀបចំរបាយការណ៍ ការផ្ទៀងផ្ទាត់ និងការវាយតម្លៃ សម្រាប់ការប្រែប្រួលអាកាសធាតុ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្ដីពីការបង្កើត និងការគ្រប់គ្រងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការចាត់វិធានការណ៍ ការធ្វើរបាយការណ៍ ការផ្ទៀងផ្ទាត់ និងការវាយតម្លៃជាក់លាក់ ដោយធ្វើការពិគ្រោះយោបល់ជាមួយគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អនុលោមតាមបទបញ្ញត្តស្ដីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។ លិខិតបទដ្ឋានគតិយុត្តនេះ ត្រូវអនុលោមតាមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ និងលក្ខខណ្ឌតម្រូវនៃយន្តការហិរញ្ញវត្ថុស្ដីពី អាកាសធាតុដែលផ្អែកលើលទ្ធផល ។

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវបង្កើត គ្រប់គ្រង និងអនុវត្តន៍ចំពោះលិខិតបទដ្ឋានគតិយុត្ត និង នីតិវិធីទាក់ទងនឹងការចាត់វិធានការណ៍ ការរៀបចំរបាយការណ៍ និងការផ្ទៀងផ្ទាត់ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដូចដែលចេញដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និង ស្របតាមបទបញ្ញត្តស្ដីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានក្នុងគន្ថីទី១ មាតិកាទី២ និងទី៣ នៃក្រមនេះ ។ អជ្ញាធរថ្នាក់ក្រោមជាតិទាំងអស់ ត្រូវជួយអជ្ញាធរពាក់ព័ន្ធក្នុងការអនុវត្តនីតិវិធីទាក់ទងនឹងការចាត់វិធានការណ៍ ការរៀបចំរបាយការណ៍ និងការផ្ទៀងផ្ទាត់ ស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីពាក់ព័ន្ធ ។

**មាត្រា១៧០** ._ ការបញ្ជ្រាបនូវក្របខ័ណ្ឌអង្កេតតាមដាននិងវាយតម្លៃទៅលើការប្រែប្រួលអាកាសធាតុ

គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធទាំងអស់ ត្រូវបញ្ជ្រាបក្របខ័ណ្ឌ អង្កេតតាមដាន និងវាយតម្លៃទៅលើការប្រែប្រួលអាកាសធាតុតាមផ្នែក ទៅក្នុងលិខិតបទដ្ឋានគតិយុត្តនៃការអង្កេតតាមដាន និងការវាយតម្លៃទៅលើការប្រែប្រួលអាកាសធាតុ ។

## ជំពូកទី៥
## ព័ត៌មានស្ដីពីការប្រែប្រួលអាកាសធាតុ

**មាត្រា១៧១** . _ព័ត៌មានស្ដីពីការប្រែប្រួលអាកាសធាតុ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវដើម្បីប្រមូល ធ្វើបច្ចុប្បន្នភាព គ្រប់គ្រង និងដាក់ឲ្យសាធារណជនអាចស្វែងរកបានបាននូវព័ត៌មានស្ដីពីការប្រែប្រួលអាកាសធាតុទាំងឡាយដែលពាក់ព័ន្ធទៅនឹងការអនុវត្តការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការប្រែប្រួលអាកាសធាតុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនការ ក្រសួង ស្ថាប័នទទួលបន្ទុកស្ថិតិថ្នាក់ជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ស្របតាមបទបញ្ញត្តស្ដីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។

ព័ត៌មានស្ដីពីការប្រែប្រួលអាកាសធាតុ មានជាអាទិ៍៖

ក-ការកំណត់ទីតាំងនៃហានិភ័យពាក់ព័ន្ធទៅនឹងអាកាសធាតុ សេណារីយ៉ូនៃ ការប្រែប្រួលអាកាសធាតុ និងការវាយតម្លៃភាពងាយរងគ្រោះ និងជម្រើស និងសមត្ថភាព ក្នុងការបន្សាំ ។

ខ-កម្រិតនៃការបំភាយឧស្ម័នដោយសារការបំផ្លាញព្រៃឈើ និងកត្តានានាអំពីការបំភាយ ឧស្ម័ន ដែលបានសន្មត ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

គ-ប្រភព និងការបំភាយឧស្ម័នផ្ទះកញ្ចក់ ។

ឃ-ជម្រើសក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការលើកកម្ពស់ភាពធន់ស៊ាំ ដែលមានជាតិកាបូនតិច ។

ង-ការកាត់បន្ថយការបំភាយឧស្ម័នដែលមានការបញ្ជាក់ពីការចូលរួមអនុវត្តរបស់ព្រះរាជាណាចក្រកម្ពុជានៅក្នុងយន្តការហិរញ្ញប្បទានអាកាសធាតុដែលផ្អែកលើលទ្ធផល ។

ច-ការកំណត់ទីតាំងនៃគម្រោង និងអន្តរាគមន៍នានាដែលពាក់ព័ន្ធទៅនឹងការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលមានប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមមាន ការពិនិត្យតាមដានជំនួយក្រៅស្រុកដែលទទួលបានផងដែរ ជាអាទិ៍ ។

ឆ-ទម្លាប់នៃការកាត់បន្ថយ និងការបន្សាំល្អបំផុត ដែលស្របតាមបរិបទនៃព្រះរាជាណាចក្រកម្ពុជា មានជាអាទិ៍ លទ្ធភាព និងប្រសិទ្ធភាពតម្លៃនៃការធ្វើអន្តរាគមន៍ និងមេរៀនដែលបានយល់ដឹងពីគម្រោង និងអន្តរាគមន៍ ដែលបានអនុវត្តន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមមាន ការសាកល្បង ឬការដកពិសោធន៍បច្ចេកវិជ្ជានានាក្នុងការកាត់បន្ថយ និងការ បន្សាំថ្មីៗ ជាអាទិ៍។

ជ-ការរៀបចំរបាយការណ៍ដែលបានពីឧបករណ៍អង្កេតតាមដាន និងវាយតម្លៃទៅលើការប្រែប្រួលអាកាសធាតុ ស្របតាមមាតិកានេះ ។

**មាត្រា១៧២** ._ កិច្ចសហការដើម្បីដាក់ព័ត៌មានអំពីការប្រែប្រួលអាកាសធាតុឲ្យសាធារណជនអាចស្វែងរកបាន

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវរួមសហកាជាមួយក្រុម ប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព ដើម្បីប្រមូល ធ្វើបច្ចុប្បន្នភាព គ្រប់គ្រង និងដាក់ឲ្យសាធារណជន អាចប្រើប្រាស់បាននូវព័ត៌មានអំពីការប្រែប្រួលអាកាសធាតុទាំងឡាយទៅតាមវិស័យរបស់ខ្លួន ព្រមទាំងព័ត៌មានអំពីការអនុវត្តការធ្វើអន្តរាគមន៍ទៅលើការប្រែប្រួលអាកាសធាតុ រួមមានលទ្ធផលទាំងឡាយនៃសូចនករអង្កេតតាមដាន និងវាយតម្លៃដែលពាក់ព័ន្ធ និងមេរៀនដែលបាន យល់ដឹងពីការអនុវត្តសកម្មភាពសាកល្បងនានា ជាអាទិ៍ ។ ព័ត៌មាននេះត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ។

**មាត្រា១៧៣** . _ លិខិតបទដ្ឋានគតិយុត្ត ស្តីពីព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ

ក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ស្តីពីការផលិត និងការគ្រប់គ្រងទិន្នន័យ និងព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ រួមមាន វិធីសាស្ត្រ នីតិវិធី នៃការប្រមូលទិន្នន័យ និងលក្ខខណ្ឌតម្រូវនៃការបើកបង្ហាញព័ត៌មាន ជាអាទិ៍។

**មាត្រា១៧៤** . _ កិច្ចព្រមព្រៀងស្តីពីការផលិតទិន្នន័យ និងការចែករំលែកទិន្នន័យ

ក្រុមប្រឹក្សាអភិវឌ្ឍន៍ប្រកបដោយចីរភាព អាចចុះកិច្ចព្រមព្រៀងស្តីពីការផលិតទិន្នន័យ និងការចែក រំលែកទិន្នន័យ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងនីតិបុគ្គលសាធារណៈ និងឯកជននានា ដើម្បីពង្រឹង និងបង្កើនការទទួលបានទិន្នន័យ និងព័ត៌មានអំពីការប្រែប្រួលអាកាសធាតុដែលមានការធានាបានទៅលើគុណភាព និងដែលពាក់ព័ន្ធទៅ នឹងការអនុវត្តការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៧៥** . _ ការរៀបចំរបាយការណ៍ព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ និងអង្គភាពសាធារណៈ និងឯកជន ក្នុងកិច្ចសហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ត្រូវ៖

ក-រៀបចំរបាយការណ៍ស្តីពីការបំភាយឧស្ម័នផ្ទះកញ្ចក់តាមវិស័យ និងដែនសមត្ថកិច្ចរបស់ខ្លួន ។

ខ-រៀបចំរបាយការណ៍អំពីការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់ ចេញពីយន្តការហិរញ្ញប្បទានអាកាសធាតុដែលផ្អែកលើលទ្ធផល ។

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំរបាយការណ៍ជូនដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព អំពីវឌ្ឍនៈភាពនៃការអនុវត្តការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដែលក្នុងនោះ រួមមាន លទ្ធផលនៃសូចនករអង្កេតតាមដាន និងវាយតម្លៃតាមវិស័យដែលមានស្រាប់ ជាអាទិ៍។

**មាត្រា១៧៦** . _ ប្រព័ន្ធទទួលបានព័ត៌មានជាសាធារណៈ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបង្កើត និងគ្រប់គ្រងប្រព័ន្ធទទួលបានព័ត៌មានជាសាធារណៈ ដើម្បីបង្រួមបង្រួមព័ត៌មានទាំងអស់អំពីការប្រែប្រួលអាកាសធាតុដែលផលិតដោយ រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ។ ប្រព័ន្ធនេះ ត្រូវបង្កើតឡើង ស្របតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវរួមសហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បង្កើត និងធ្វើបច្ចុប្បន្នភាពជាប្រចាំទៅលើប្រព័ន្ធ ព័ត៌មាននេះ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលចេញដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។

## ផ្នែកទី១
## បញ្ជីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់

**មាត្រា១៧៧ .** _ការបង្កើតសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបង្កើត និងគ្រប់គ្រងបញ្ជីសារពើភណ្ឌឧស្ម័ន ផ្ទះកញ្ចក់ថ្នាក់ជាតិ ដែលសាធារណជនអាចប្រើប្រាស់បាន ស្របតាមវិធាន និងការណែនាំជាអន្តរជាតិដែលពាក់ព័ន្ធ ។

**មាត្រា១៧៨ .** _លិខិតបទដ្ឋានគតិយុត្តស្តីពីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ស្តីពីការប្រមូល ការផលិត និងការធានាបាននូវគុណភាព និងការប្រគល់ទិន្នន័យក្នុងបញ្ជីសារពើភណ្ឌ រួមមាន ការបង្កើតកត្តានៃការបំភាយឧស្ម័នដែលពាក់ព័ន្ធសម្រាប់ប្រភេទ ឬក្រុមនៃប្រភពបញ្ចេញ និងកន្លែង ផ្ទុកឧស្ម័ន ការបង្កើតកម្រិតនៃការបំភាយឧស្ម័នដោយសារការបំផ្លាញព្រៃឈើ ដែលបានសន្មត ការប្រមូលទិន្នន័យអំពីសកម្មភាព និងលក្ខខណ្ឌតម្រូវនៃការរៀបចំរបាយការណ៍ ជាអាទិ៍ ។ លិខិតបទដ្ឋានគតិយុត្តនេះអាចរួមមានទណ្ឌកម្មដែលអាចអនុវត្តចំពោះនីតិបុគ្គលសាធារណៈ និងឯកជនសម្រាប់ការមិនអនុលោមតាម។

**មាត្រា១៧៩ .** _ការអនុលោមតាមលិខិតបទដ្ឋានគតិយុត្តស្តីពីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់

គ្រប់ម្ចាស់គម្រោង និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ព័ត៌មានសម្រាប់បញ្ជី សារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ស្តីពីការប្រមូល ការផលិត និងការធានាបាននូវគុណភាព និងការប្រគល់ទិន្នន័យនៃបញ្ជីសារពើភណ្ឌ ដែលចេញដោយក្រុមប្រឹក្សា អភិវឌ្ឍន៍ដោយចីរភាព ។

## ផ្នែកទី២
## បញ្ជីគម្រោងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ថ្នាក់ជាតិ

**មាត្រា១៨០ .** _បញ្ជីគម្រោងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ថ្នាក់ជាតិ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបង្កើត និងគ្រប់គ្រងបញ្ជីគម្រោងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ថ្នាក់ជាតិ ដែលសាធារណជនអាចប្រើប្រាស់បាន ។ បញ្ជីនេះ ត្រូវដាក់បញ្ចូលនូវរាល់ការចុះបញ្ជីនានាដែលបានបង្កើតមុនរួចហើយក្រោមយន្តការហិរញ្ញប្បទានអាកាសធាតុដែលផ្អែកលើលទ្ធផលដែលពាក់ព័ន្ធ និងអាចបញ្ចូលនូវយន្តការឥណទានកាបូនដទៃទៀត ដែលប្រើប្រាស់

លក្ខខណ្ឌតម្រូវស្រដៀងគ្នាទៅនឹងយន្តការផ្អែកលើលទ្ធផល ដែលបានបង្កើតឡើងក្រោមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។ បញ្ជីនេះត្រូវបង្កើតឡើង ស្របតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ក្នុងគន្ថីទី១ មាតិកាទី២ និងទី៣ នៃក្រមនេះ ។

**មាត្រា១៨១ .** _ លិខិតបទដ្ឋានគតិយុត្ត ស្តីពីការប្រគល់ព័ត៌មានសម្រាប់បញ្ជីគម្រោងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ស្តីពីការប្រគល់ព័ត៌មានសម្រាប់បញ្ជីគម្រោងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ ស្របតាមវិធាន និងការណែនាំអន្តរជាតិពាក់ព័ន្ធ ។ លិខិតបទដ្ឋានគតិយុត្តនេះអាចរួមមានទណ្ឌកម្មដែលអាចអនុវត្តចំពោះនីតិបុគ្គលសាធារណៈ និងឯកជនសម្រាប់ការមិនអនុលោមតាមលិខិតបទដ្ឋានគតិយុត្តនោះ ។

**មាត្រា១៨២ .** _ ការអនុលោមតាមលិខិតបទដ្ឋានគតិយុត្តស្តីពីស្តីពីការប្រគល់ព័ត៌មានសម្រាប់បញ្ជីគម្រោងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ

គ្រប់ក្រសួង ស្ថាប័នទាំងអស់ ដែលរួមចំណែកនៅក្នុងយន្តការហិរញ្ញប្បទានអាកាសធាតុដែលផ្អែកលើលទ្ធផល រួមមានទាំងយន្តការទាំងឡាយដែលមិនត្រូវបានបង្កើតក្រោមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុជាអាទិ៍ ត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីការប្រគល់ព័ត៌មានសម្រាប់បញ្ជីគម្រោងកាត់បន្ថយការបំភាយ ឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ ។

## ជំពូកទី៦
## ការកសាងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យា និងចំណេះដឹង

**មាត្រា១៨៣ .**_ ការអភិវឌ្ឍសមត្ថភាពស្ថាប័ន

រាជរដ្ឋាភិបាលកម្ពុជា ត្រូវអភិវឌ្ឍសមត្ថភាពស្ថាប័ន វិនិយោគលើការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិជ្ជា កសាងសមត្ថភាព និងបង្កើតការយល់ដឹងនៅគ្រប់កម្រិត ដើម្បីឲ្យមានការយល់ដឹង និងដោះស្រាយអំពីការប្រែប្រួលអាកាសធាតុ និងដើម្បីឲ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៨៤ .**_ ការវាយតម្លៃសមត្ថភាពស្ថាប័នជាប្រចាំ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើ

ការវាយតម្លៃសមត្ថភាពស្ថាប័នជាប្រចាំ សម្រាប់អនុវត្តការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ បង្កើតកម្មវិធីផ្សេងៗ ដើម្បីបំពេញនូវភាពខ្វះចន្លោះផ្នែកសមត្ថភាពសំខាន់ៗ ធ្វើការកៀងគរធនធានសម្រាប់ការអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាព ។

**មាត្រា១៨៥ .**_ ការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបុគ្គល

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវពង្រឹងបរិយាកាសអំណោយផលរបស់ព្រះរាជាណាចក្រកម្ពុជា សមត្ថភាពស្ថាប័ន និងសមត្ថភាពបុគ្គលដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ។

**មាត្រា១៨៦ .**_ ការអប់រំ និងការបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ព្រមទាំងក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវលើកកម្ពស់កម្មវិធីអប់រំ និងកម្មវិធីបណ្តុះបណ្តាលស្តីពីពីការប្រែប្រួលអាកាសធាតុ ដោយអនុលោមតាមបទបញ្ញត្តផ្សេងៗស្តីពីការអប់រំ និងការយល់ដឹងផ្នែកបរិស្ថាន ស្របតាមគន្ថីទី៧ នៃក្រមនេះ ។

**មាត្រា១៨៧ .**_ ការចូលរួមក្នុងការអប់រំ និងការបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ

មន្ត្រីពាក់ព័ន្ធទាំងអស់ ត្រូវចូលរួមក្នុងកម្មវិធីអប់រំ និងកម្មវិធីបណ្តុះបណ្តាលនានា ដើម្បីធានាបាននូវការយល់ដឹងអំពីភាពស្មុគស្មាញផ្សេងៗ នៃការដោះស្រាយការប្រែប្រួលអាកាសធាតុ ។

**មាត្រា១៨៨ .**_ យន្តការកសាងចំណេះដឹង និងលើកកម្ពស់ការស្រាវជ្រាវ

ដោយសហការជាមួយនឹងអ្នកពាក់ព័ន្ធទាំងអស់ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ ដោយចីរភាព ត្រូវធ្វើការពង្រឹង និងបង្កើតយន្តការផ្សេងៗក្នុងការកសាងចំណេះដឹង និងលើកកម្ពស់ ការស្រាវជ្រាវស្តីពីការអនុវត្ត និងបច្ចេកវិជ្ជានៃការកាត់បន្ថយ និងការបន្សាំការប្រែប្រួលអាកាសធាតុ ។

## ជំពូកទី៧
## ក្របខ័ណ្ឌហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុ

**មាត្រា១៨៩ .**_ ការអភិវឌ្ឍក្របខ័ណ្ឌហិរញ្ញប្បទាន

ដោយសហការជាមួយនឹងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបង្កើត និងគ្រប់គ្រងក្របខ័ណ្ឌហិរញ្ញប្បទាន សម្រាប់ សកម្មភាពនានានៃការប្រែប្រួលអាកាសធាតុ ។ ក្របខ័ណ្ឌបែបនេះ ត្រូវរួមបញ្ចូលនូវការវិភាគ អំពីតម្រូវការហិរញ្ញប្បទានយុទ្ធសាស្ត្រក្នុងការបំពេញនូវសេចក្តីត្រូវការទាំងនេះតាមរយៈការប្រើប្រាស់ប្រភពហិរញ្ញវត្ថុក្នុង

ស្រុក និងក្រៅស្រុកដែលមានស្រាប់ ក៏ដូចជាវិធានការនៃការអភិវឌ្ឍសមត្ថភាពណាមួយ យន្តការហិរញ្ញវត្ថុ ឬកំណែទម្រង់ស្ថាប័ននានា ដើម្បីធ្វើការកៀងគរ និងគ្រប់គ្រងហិរញ្ញវត្ថុ ផ្នែកប្រែប្រួលអាកាសធាតុក្នុងលក្ខណៈដែលមានប្រសិទ្ធផលដ៏ខ្ពស់បំផុតមួយ ។ ក្របខ័ណ្ឌបែបនេះនឹងត្រូវបង្កើតឡើង ដោយអនុលោមទៅតាមបទបញ្ញត្តផ្សេងៗស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។

**មាត្រា១៩០ ._** ហិរញ្ញវត្ថុជាក់លាក់នៅតាមទីតាំង

តាមការស្នើសុំរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតគណនីមូលនិធិជាក់លាក់នៅតាមទីតាំងមួយចំនួនសម្រាប់អ្នកពាក់ព័ន្ធដែលចូលរួម ចំពោះយន្តការហិរញ្ញវត្ថុអាកាសធាតុដែលផ្អែកលើលទ្ធផល រួមមាន គម្រោងរេដបូកជាអាទិ៍ ដោយអនុលោមទៅតាមបទប្បញ្ញត្តិនានា ស្តីពីវិធានការសេដ្ឋកិច្ច គណនី ថ្លៃ ដែលត្រូវបង់ និងមូលនិធិផ្សេងៗក្នុងគន្ថីទី៨ មាតិកាទី២ នៃក្រមនេះ ។

## ផ្នែកទី១
## ការបែងចែកធនធាន សម្រាប់ការប្រែប្រួលអាកាសធាតុនៅក្នុងថវិកាជាតិ និងថវិកាថ្នាក់ក្រោមជាតិ

**មាត្រា១៩១ ._** ការប្រែប្រួលអាកាសធាតុនៅក្នុងថវិកាជាតិ

ដោយមានការគាំទ្របច្ចេកទេសពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិចារណាពីផលប៉ះពាល់ និងដំណោះស្រាយផ្សេងៗនៃការប្រែប្រួលអាកាសធាតុនៅក្នុងដំណើរការថវិកាជាតិ ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវផ្តល់ឲ្យក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវការវិភាគប្រចាំឆ្នាំអំពីហានិភ័យ និងអាទិភាពនៃការប្រែប្រួលអាកាសធាតុ ។ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងហិរញ្ញវត្ថុ ត្រូវពិចារណា និងបញ្ចូល នូវការវិភាគនេះនៅក្នុងសារាចរស្តីពីការរៀបចំថវិកាប្រចាំឆ្នាំ និងបញ្ចូលការណែនាំអំពីការដាក់បញ្ចូលផលប៉ះពាល់ និងដំណោះស្រាយផ្សេងៗនៃការប្រែប្រួលអាកាសធាតុ ទៅក្នុងលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធី សម្រាប់ថវិកាគម្រោង ។

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវតាមដាន និងដាក់ឲ្យសាធារណជនអាចស្វែងរកបាននូវព័ត៌មានស្តីពីការបែងចែក ការចំណាយ និងប្រសិទ្ធិភាពនៃហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុតាមរយៈថវិកាជាតិ ។

**មាត្រា១៩២ ._** ផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុនៅក្នុងការដាក់ស្នើថវិកា

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអជ្ញាធរថ្នាក់ក្រោមជាតិទាំងអស់ ត្រូវដាក់បញ្ចូល នូវផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុ នៅក្នុងការដាក់ស្នើថវិការបស់ខ្លួន ដោយអនុលោមទៅតាមលិខិតបទដ្ឋានគតិយុត្តដែលបានចេញដោយក្រសួង ស្ថាប័នទទួលបន្ទុក សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី២
## ការលើកកម្ពស់ ការវិនិយោគលើអាកាសធាតុដែលមានលក្ខណៈឆ្លាតវៃពីវិស័យឯកជន

**មាត្រា១៩៣ ._** ការលើកកម្ពស់ការវិនិយោគលើអាកាសធាតុដែលមានលក្ខណៈឆ្លាតវៃ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយនឹងក្រសួង ស្ថាប័នទទួលបន្ទុក សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធទាំងអស់ អំពីវិធានការសារពើពន្ធជាសក្តានុពល បទប្បញ្ញត្តិ ស្តង់ដារ និងយន្តការដែលផ្អែកលើទីផ្សារនានា ដើម្បីលើកកម្ពស់ការវិនិយោគលើអាកាសធាតុដែលមានលក្ខណៈឆ្លាតវៃ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមទៅតាមបទបញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។

## ផ្នែកទី៣
## ការកៀងគរហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុពីបរទេស

**មាត្រា១៩៤ ._** ការសម្របសម្រួលអំពីហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុពីបរទេស

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវសម្របសម្រួលលើការកៀងគរហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុពីបរទេសក្នុងលក្ខណៈមួយដែលមានប្រសិទ្ធផល និងប្រសិទ្ធភាពបំផុត នៅពេលដែលធ្វើការធានាឲ្យមានការបន្ស៊ីគ្នានៃធនធានពីបរទេសទាំងនេះ ទៅនឹងអាទិភាពផ្សេងៗនៃការប្រែប្រួលអាកាសធាតុរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៩៥ ._** ការអង្កេតតាមដានហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុពីបរទេស

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវសហប្រតិបត្តិការជាមួយនឹងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីធ្វើការអង្កេតតាមដានហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុពីបរទេស និងត្រូវធានាឲ្យមានការដាក់បញ្ចូលនូវការប្រែប្រួលអាកាសធាតុទៅក្នុងកិច្ចចរចានានាជាមួយនឹងដៃគូអភិវឌ្ឍ ស្តីពីយុទ្ធសាស្ត្រសម្រាប់ព្រះរាជាណាចក្រកម្ពុជារបស់ខ្លួន ។

## ផ្នែកទី៤
## ការលើកកម្ពស់យន្តការហិរញ្ញវត្ថុអាកាសធាតុដែលផ្អែកលើលទ្ធផល

**មាត្រា១៩៦ ._** អាជ្ញាធរជាតិដែលត្រូវបានចាត់តាំង

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវតែជាអាជ្ញាធរជាតិដែលត្រូវបានចាត់តាំង សម្រាប់ការងារហិរញ្ញវត្ថុអាកាសធាតុដែលផ្អែកលើលទ្ធផល ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវពិនិត្យមើល ធ្វើការឯកភាព និងផ្តល់សុពលភាពដល់គម្រោងទាំងអស់ ដែលស្នើសុំការយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីចូលរួមនៅក្នុងយន្តការហិរញ្ញប្បទានអាកាសធាតុដែលផ្អែកលើលទ្ធផល រួមមាន យន្តការទាំងឡាយយោងតាមយន្តការអភិវឌ្ឍស្អាត យន្តការនៃការផ្តល់ឥណទារួម វិធានការកាត់បន្ថយថ្នាក់ជាតិដ៏សមស្របមួយ ព្រមទាំងយន្តការរេដបូក ជាអាទិ៍ ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវធានាថា គម្រោងទាំងនេះ អនុលោមតាមផែនការ និងយុទ្ធសាស្ត្រជាតិ ស្តីពីការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធនានា ។

**មាត្រា១៩៧ ._** ការលើកកម្ពស់ការចូលរួមនៅក្នុងយន្តការហិរញ្ញវត្ថុដែលផ្អែកលើលទ្ធផល

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវលើកកម្ពស់ការចូលរួមនៅក្នុងយន្តការហិរញ្ញវត្ថុអាកាសធាតុដែលផ្អែកលើលទ្ធផល មានជាអាទិ៍តាមរយៈ ៖

ក- ការចេញការណែនាំ ស្តីពីការទទួលបានហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុតាមរយៈការចូលរួមនៅក្នុងយន្តការហិរញ្ញវត្ថុអាកាសធាតុដែលផ្អែកលើលទ្ធផល ។

ខ- ការរក្សា និងការផ្សព្វផ្សាយព័ត៌មានស្តីពីប្រភព ជម្រើសអាទិភាពផ្សេងៗ និងសក្តានុពលសម្រាប់ការកាត់បន្ថយការបំភាយឧស្ម័ននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

គ- ការរក្សា និងការផ្សព្វផ្សាយព័ត៌មានស្តីពីការកាត់បន្ថយការបំភាយឧស្ម័នពី គម្រោងដែលចូលរួមនានាតាមរយៈបញ្ជីថ្នាក់ជាតិសម្រាប់គម្រោងកាត់បន្ថយការបំភាយ ឧស្ម័នផ្ទះកញ្ចក់ រួមមានព័ត៌មានអំពីទំហំនៃការផ្តល់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដែលបានកៀងគរតាមរយៈការចូលរួមរបស់អង្គភាពរដ្ឋ និងអង្គភាពឯកជន នៅក្នុងយន្តការហិរញ្ញវត្ថុអាកាសធាតុដែលផ្អែកលើលទ្ធផល និងលទ្ធផលផ្សេងៗដែលសម្រេចបានជាអាទិ៍ ។

## មាតិកាទី៣
## ការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

## ផ្នែកទី១
## ការលើកកម្ពស់ការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព

**មាត្រា១៩៨** ._ ការប្រើប្រាស់ប្រកបដោយនិរន្តរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយមានការឯកភាពពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើតឯកសារនានាទាក់ទងនឹងគោលនយោបាយស្ដីពីការប្រើប្រាស់ប្រកបដោយនិរន្តរភាព ។ ឯកសារគោលនយោបាយទាំងនេះ ត្រូវរួមបញ្ចូលនូវ៖

ក- កម្មវិធីដើម្បីបង្កើននូវការអនុវត្តឲ្យបានពេញលេញនូវគំរូនៃការប្រើប្រាស់មួយដែលយកចិត្តទុកដាក់ដល់ បរិស្ថាន តាមរយៈនៃការបង្កើនការផ្គត់ផ្គង់ តម្រូវការសម្រាប់ផលិតផលសេវាកម្ម និងបច្ចេកវិជ្ជាទាំងឡាយដែលមិនបង្កគ្រោះថ្នាក់ដល់បរិស្ថាន ។

ខ- គោលនយោបាយនានា ដើម្បីឲ្យវិស័យឯកជន អង្គការសង្គមស៊ីវិល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋបានចូលរួម និងលើកកម្ពស់ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធផល និងការខូចខាតបរិស្ថានតិច រួមមានតំបន់នៃការប្រើប្រាស់ទឹក និងថាមពល ការបង្កើតសំណល់ប្រកបដោយគ្រោះថ្នាក់ ការគ្រប់គ្រងសំណល់ ទេសចរណ៍ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាអាទិ៍ ។

**មាត្រា១៩៩** ._ ផលិតកម្មប្រកបដោយនិរន្តរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយមានការឯកភាពពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រួមមានក្រសួង ស្ថាប័នទទួលបន្ទុកឧស្សាហកម្ម និងសិប្បកម្ម ដើម្បីបង្កើតឯកសារនានាទាក់ទងនឹងគោលនយោបាយស្ដីពីផលិកម្ម ប្រកបដោយនិរន្តរភាព ។ ឯកសារគោលនយោបាយទាំងនេះ ត្រូវរួមបញ្ចូលនូវ៖

ក. កម្មវិធីដើម្បីលើកកម្ពស់ការអនុវត្តគំរូផលិតផល និងទម្លាប់ល្អនៃការអនុវត្តដំណើរការផលិតកម្ម ដែលយកចិត្តទុកដាក់ដល់បរិស្ថាន ។

ខ. គោលនយោបាយនានា ដើម្បីឲ្យវិស័យឯកជន អង្គការសង្គមស៊ីវិល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋបានចូលរួម និងលើកកម្ពស់ផលិតកម្មដែលប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធផលខ្ពស់ និងការខូចខាតបរិស្ថានតិច ។

**មាត្រា២០០** ._ ការផ្ទៀងផ្ទាត់បច្ចេកវិជ្ជាបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកឧស្សាហកម្ម និងសិប្បកម្ម និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវបង្កើតកម្មវិធីមួយសម្រាប់ការផ្ទៀងផ្ទាត់ បច្ចេកវិជ្ជាបរិស្ថាន ដែលអាចអនុវត្តបានទៅលើគ្រឿងបច្ចេកវិជ្ជា ដែលត្រូវបានប្រើប្រាស់ដោយឧស្សាហកម្ម ឧស្សាហកម្មព្រៃឈើ កសិកម្ម រ៉ែ សេវាកម្ម និងលំនៅឋាន ។ កម្មវិធីនេះ ត្រូវផ្អែកលើការអនុវត្តល្អៗជាអន្តរជាតិ នៅក្នុងការការផ្ទៀងផ្ទាត់បច្ចេកវិជ្ជាបរិស្ថាន ។

**មាត្រា២០១** ._ បញ្ជីនៃបច្ចេកវិជ្ជាដែលបានផ្ទៀងផ្ទាត់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកឧស្សាហកម្ម និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវបង្កើតបញ្ជីនៃបច្ចេកវិជ្ជាដែលបានផ្ទៀងផ្ទាត់ និងដាក់បញ្ជីនេះឲ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទបញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

## ផ្នែកទី២
## លទ្ធកម្មប្រកបដោយនិរន្តរភាព

**មាត្រា២០២** ._ លិខិតបទដ្ឋានគតិយុត្តស្តីពីលទ្ធកម្មប្រកបដោយនិរន្តរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ស្តីពីលទ្ធកម្មប្រកបដោយនិរន្តរភាព ដែលផ្តោតទៅលើការបញ្ចូលនូវ លក្ខណៈវិនិច្ឆ័យបរិស្ថាន ក្នុងអំឡុងពេលនៃដំណើរការនៃការធ្វើលទ្ធកម្មលើទំនិញ សេវាកម្ម ការងារ និងសេវាផ្សេងខណៈពេលដែលទទួលបាននូវតំលៃជាសាច់ប្រាក់ដោយឈរលើមូលដ្ឋានវដ្តនៃជីវិតទាំងមូល ដើម្បីកាត់បន្ថយជាអប្បបរមានូវបន្ទុកផ្នែកបរិស្ថានពីការប្រើប្រាស់និងសម្របសម្រួលតម្រូវការផលិតកម្ម និងសេវាដែលមិនបង្កគ្រោះថ្នាក់ទៅដល់បរិស្ថាន ។

លិខិតបទដ្ឋានគតិយុត្តទាំងនេះ ត្រូវផ្អែកលើស្តង់ដាអន្តរជាតិពាក់ព័ន្ធ ។

**មាត្រា២០៣** ._ គោលបំណង

លិខិតបទដ្ឋានគតិយុត្តស្តីពីលទ្ធកម្មប្រកបដោយនិរន្តរភាព ត្រូវះ

ក- លើកទឹកចិត្តចំពោះប្រសិទ្ធផលនៃការផលិតធនធាន ។

ខ- កំណត់ប្រភេទ និងលំដាប់ថ្នាក់ជាអាទិភាពនៃផលិតផល និងសេវាកម្ម ដែលរួមមានបច្ចេកវិទ្យាដែលមាន សុវត្ថិភាពចំពោះបរិស្ថាន និងហរិញ្ញវត្ថុបៃតង ។

គ- កំណត់នូវលក្ខណៈវិនិច្ឆ័យបរិស្ថានអប្បបរមា និងលក្ខខណ្ឌតម្រូវសម្រាប់ប្រតិបត្តិ រួមមានប្រសិទ្ធផលនៃការផលិតធនធាន ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការច្នៃសំណល់ ការគ្រប់គ្រងសំណល់រួមគ្នា ផលិតកម្មស្អាតជាងមុន សម្រាប់ប្រភេទនីមួយៗនៃផលិតផល និងសេវាកម្ម ដោយផ្អែកទៅលើផលប៉ះពាល់នៃផលិតកម្ម និងសេវាកម្មនោះទៅលើបរិស្ថាន ។

ឃ- កំណត់នូវលក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍សម្រាប់ប្រភេទនៃផលិតផល សេវាកម្ម និង ទំហំនៃលទ្ធកម្ម ។

ង- ផ្តល់ការណែនាំសម្រាប់ការជ្រើសរើសអ្នកផ្គត់ផ្គង់ដែលមានលក្ខណៈសមស្រប ។

ច- ផ្តល់ការណែនាំសម្រាប់ការធ្វើការសម្រេចចិត្ត ដោយយកចិត្តទុកដាក់ដល់បរិស្ថានមានជាអាទិ៍ ការថ្លឹងថ្លែងរវាងលក្ខណៈវិនិច្ឆ័យបរិស្ថានជាមួយនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការទិញផ្សេងទៀត រួមមានការគិតគូរដល់សេដ្ឋកិច្ច តម្លៃ ការបំពេញការងារ និងគុណភាព ជាអាទិ៍ ។

ឆ- កំណត់ឲ្យមានទណ្ឌកម្មសម្រាប់អ្នករំលោភបំពានទៅលើលក្ខខណ្ឌតម្រូវសម្រាប់ដំណើរការនៃផលិតកម្ម និងសេវាកម្មដែលត្រូវយកចិត្តទុកដាក់ដល់បរិស្ថាន ។

ជ- កំណត់ឲ្យបានច្បាស់នូវវិធានការសម្រាប់ក្រសួង ស្ថាប័ន ដែលទទួលខុសត្រូវក្នុងការងារលទ្ធកម្ម ដើម្បីលើកទឹកចិត្ត និងជួយដល់អ្នកពាក់ព័ន្ធក្នុងការទទួលខុសត្រូវចំពោះការអនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាព ។

**មាត្រា២០៤** ._ ការអនុវត្តលិខិតបទដ្ឋានគតិយុត្តស្តីពីទម្លាប់នៃការធ្វើលទ្ធកម្ម

ក្រសួង ស្ថាប័ន ដែលទទួលខុសត្រូវទៅលើការងារ លទ្ធកម្ម ត្រូវដាក់បញ្ចូល លិខិតបទដ្ឋានគតិយុត្តស្តីពីលទ្ធកម្មប្រកបដោយនិរន្តរភាព នៅក្នុងទម្លាប់នៃការអនុវត្តនៃការធ្វើលទ្ធកម្មចំពោះផលិតកម្ម និងសេវាកម្ម ទាំងអស់ដែលត្រូវធ្វើលទ្ធកម្មជាសាធារណៈ ដែលរួមមានផលិតកម្ម និងសេវាកម្ម ដែល៖

ក- ត្រូវធ្វើលទ្ធកម្មក្រោមថវិការបស់អង្គភាព អជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ខ- ត្រូវធ្វើលទ្ធកម្មដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលស្ថិតនៅក្រោមលិខិតបទដ្ឋានស្តីពីលទ្ធកម្ម ។

គ- ត្រូវធ្វើលទ្ធកម្មក្រោមគម្រោងដែលទទួលបានមូលនិធិពីម្ចាស់ជំនួយ ។

**មាត្រា២០៥** ._ ការបញ្ចូលទម្លាប់នៃការអនុវត្តនៃការធ្វើលទ្ធកម្មប្រកបដោយនិរន្តរភាព

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានការសម្របសម្រួលជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធានាបានថា គ្រប់ក្រសួង ស្ថាប័ន ដែលទទួលខុសត្រូវទៅលើ

ការងារលទ្ធកម្ម បានបញ្ចូល និងអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីការធ្វើលទ្ធកម្មប្រកបដោយនិរន្តរភាព ។

**មាត្រា២០៦** ._ ការបណ្តុះបណ្តាល

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្តល់ការបណ្តុះបណ្តាលស្តីពីការអនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាពទៅដល់គ្រប់ក្រសួង ស្ថាប័ន ដែលទទួលខុសត្រូវចំពោះការងារលទ្ធកម្ម ។

**មាត្រា២០៧** ._ របាយការណ៍ប្រចាំឆ្នាំ

ក្រសួង ស្ថាប័ន ដែលទទួលខុសត្រូវទៅលើការងារ លទ្ធកម្ម ត្រូវធ្វើ របាយការណ៍ប្រចាំឆ្នាំមួយស្តីពីការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការធ្វើ លទ្ធកម្មប្រកបដោយនិរន្តរភាព ។ របាយការណ៍ប្រចាំឆ្នាំនេះ ត្រូវបញ្ចូលចំណុចដូចតទៅ៖

ក- បញ្ជីនៃផលិតផល និងសេវាកម្មដែលមិនបង្កគ្រោះថ្នាក់ទៅដល់បរិស្ថាន ដែលត្រូវបានទិញ ក្នុងអំឡុងពេល នៃឆ្នាំសារពើពន្ធ ។

ខ- ការវិភាគទាក់ទងទៅនឹងការដាក់បញ្ចូល និងការអនុវត្តលក្ខខណៈវិនិច្ឆ័យបរិស្ថាននៅក្នុងការធ្វើលទ្ធកម្ម ។

គ- ផែនការប្រចាំឆ្នាំទាំងឡាយសម្រាប់ការធ្វើបញ្ជីលទ្ធកម្មនៃផលិតផល និងសេវាកម្មជាអាទិភាព ដែលមិនបង្កគ្រោះថ្នាក់ដល់ បរិស្ថាន ។

ក្រសួង ស្ថាប័ន ដែលទទួលខុសត្រូវទៅលើការងារ លទ្ធកម្ម ត្រូវផ្តល់ជូន របាយការណ៍នេះទៅឲ្យក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា២០៨** ._ សិទ្ធិទទួលបានព័ត៌មានបរិស្ថាន

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវធានាថាគ្រប់របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តលទ្ធកម្មប្រកប ដោយនិរន្តរភាព ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ស្របតាមបទបញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ក្នុងគន្ថីទី ១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា២០៩** ._ ការវាយតម្លៃនៃការអនុវត្ត

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវប្រើប្រាស់ព័ត៌មានពី របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តលទ្ធកម្ម ប្រកបដោយនិរន្តរ

ភាព ដើម្បីកំណត់នូវបញ្ហា និងភាពគ្មានប្រសិទ្ធផល នៃអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាស្តីពីការធ្វើលទ្ធកម្មប្រកបដោយនិរន្តរភាព និងត្រូវពិគ្រោះយោបល់ជាមួយនឹងអ្នក ពាក់ព័ន្ធ ដើម្បីធ្វើការកែប្រែលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ តាមការចាំបាច់ ។

**មាត្រា២១០** ._ ផលិតផលដែលមិនបង្កគ្រោះថ្នាក់ទៅដល់បរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុក ត្រូវលុបបំបាត់នូវឧបសគ្គនានាក្នុងការផ្សព្វផ្សាយ ការទិញ ការប្រើប្រាស់ ការនាំចូល ការនាំចេញផលិតផលដែលមិនបង្កគ្រោះថ្នាក់ទៅដល់បរិស្ថាន ដើម្បីលើកទឹកចិត្តឲ្យអ្នកផ្គត់ផ្គង់ អនុលោមទៅតាមក្រម និងបទប្បញ្ញត្តិនានា។

## ផ្នែកទី៣
## ការដាក់ស្លាកសញ្ញាបរិស្ថានដោយស្ម័គ្រចិត្ត

**មាត្រា២១១** ._ ស្លាកសញ្ញាអេកូ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យឧស្សាហកម្ម និងសិប្បកម្ម ត្រូវបង្កើតប្រព័ន្ធដែលមានកម្រិតស្តង់ដារដោយស្ម័គ្រចិត្តមួយក្នុងការដាក់ស្លាកសញ្ញាលើផលិតផល និង សេវាកម្មដោយដាក់ឈ្មោះ ស្លាកសញ្ញាអេកូ ដោយភ្ជាប់ជាមួយព័ត៌មានស្តីពីបន្ទុកផ្នែកបរិស្ថាន ដែលរួមមានសារធាតុផ្សំ ធាតុចូល និងធាតុចេញនានានៃថាមពល ។

**មាត្រា២១២** ._ ប្រភេទផលិតផល និងសេវាកម្ម

ក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថាន ត្រូវកំណត់ប្រភេទផលិតផល និងសេវាកម្ម លក្ខណៈវិនិច្ឆ័យ និងស្តង់ដារ ការចេញវិញ្ញាបនបត្របញ្ជាក់ និងការធ្វើសវនកម្ម និងវិធាននៃការប្រើប្រាស់នៅក្នុងរយៈពេល១២ (ដប់ពីរ) ខែ បន្ទាប់ពីការអនុម័តក្រមនេះ ។

ការកំណត់ អំពីការដាក់ស្លាកសញ្ញាអេកូ និងព័ត៌មានស្តីពីបន្ទុកបរិស្ថាននៅលើផលិតផល និងសេវាកម្មតាមប្រភេទនានា ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា២១៣** ._ បញ្ជីសារពើភណ្ឌផលិតផល និងសេវាកម្ម

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវថែរក្សា និងផ្សព្វផ្សាយបញ្ជីសារពើភណ្ឌផលិតផល និងសេវាកម្មជាមួយនឹងការបញ្ជាក់ ដោយដាក់ស្លាកសញ្ញាអេកូ ជាសាធារណៈ ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា២១៤**._ លទ្ធកម្មដែលពេញចិត្ត

ក្រសួង ស្ថាប័នរដ្ឋាភិបាលដែលមានសមត្ថកិច្ចពាក់ព័ន្ធត្រូវធានាថាផលិតផល និងសេវាដែលពាក់ព័ន្ធការចេញវិញ្ញាបនបត្រស្លាកសញ្ញាអេកូត្រូវបានប្រើប្រាស់ការសម្រេចចិត្តផ្នែកលទ្ធកម្ម ។

## ផ្នែកទី៤
## ការវាយតម្លៃប្រសិទ្ធផលនៃធនធាន

**មាត្រា២១៥**._ វិសាលភាពនៃការអនុវត្ត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធ្វើការវាយតម្លៃពីប្រសិទ្ធផលនៃធនធានរៀងរាល់ ៣ (បី) ឆ្នាំម្ដង ចំពោះនីតិបុគ្គលតាមវិស័យជាក់លាក់ណាមួយដែលបានប្រើប្រាស់ធនធាន ហើយបង្កឲ្យមានផលប៉ះពាល់ដល់បរិស្ថាន និងលើសកម្រិតស្តង់ដារកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរៀបចំបង្កើតលិខិតបទដ្ឋានគិតយុត្ត ដើម្បីកំណត់វិស័យពាក់ព័ន្ធ ស្តង់ដារ ទម្រង់ និងខ្លឹមសារនៃការវាយតម្លៃ លក្ខខណ្ឌតម្រូវ និងនីតិវិធីសម្រាប់ការវាយតម្លៃប្រសិទ្ធផលធនធាន ។

រាល់ការឯកភាព លិខិតអនុញ្ញាត ឬអជ្ញាប័ណ្ណសម្រាប់គ្រប់វិស័យទាំងអស់ដែលបញ្ជាក់តាមរយៈលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ តម្រូវឲ្យបញ្ចប់ការវាយតម្លៃប្រសិទ្ធិផលធនធាន ។

**មាត្រា២១៦**._ អ្នកវាយតម្លៃប្រសិទ្ធផលធនធាន

ការវាយតម្លៃប្រសិទ្ធផលធនធាន ត្រូវបានធ្វើឡើងដោយអ្នកវាយតម្លៃប្រសិទ្ធផលធនធានដែលត្រូវបានទទួលស្គាល់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ លក្ខណៈសម្បត្តិនៃអ្នកវាយតម្លៃ និងតម្លៃនៃការវាយតម្លៃ ត្រូវកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា២១៧**._ អ្នកវាយតម្លៃប្រសិទ្ធផលធនធានបណ្តុះបណ្តាល

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតប្រព័ន្ធមួយសម្រាប់ធ្វើការបណ្តុះបណ្តាលដល់អ្នកវាយតម្លៃប្រសិទ្ធផលធនធាន ។ បញ្ជីឈ្មោះអ្នកវាយតម្លៃប្រសិទ្ធផលធនធានត្រូវផ្សព្វផ្សាយជាសាធារណៈ និងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។

**មាត្រា២១៨**._ របាយការណ៍នៃការវាយតម្លៃ

បន្ទាប់ពីបានបញ្ចប់ការវាយតម្លៃប្រសិទ្ធផលធនធាន អ្នកវាយតម្លៃ ត្រូវដាក់ជូនរបាយការណ៍ស្ដីពីលទ្ធផល នៃការវាយតម្លៃ និងវិធានការកាត់បន្ថយនានាដែលបានកំណត់ ។ របាយការណ៍នេះ ត្រូវដាក់ជូនទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ស្របតាមនីតិវិធីជាធរមាន ។

**មាត្រា២១៩** ._ ការវាយតម្លៃរបាយការណ៍

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធ្វើការវាយតម្លៃ និងផ្ដល់ការឯកភាពទៅលើរបាយការណ៍នៃការវាយតម្លៃប្រសិទ្ធផលធនធាន ស្របតាមលក្ខខណ្ឌតម្រូវ និងស្តង់ដារដែលត្រូវបានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា២២០** ._ ការធ្វើការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានអាចធ្វើសវនកម្មបរិស្ថានរបស់នីតិបុគ្គលពាក់ព័ន្ធដើម្បីផ្ទៀងផ្ទាត់ការវាយតម្លៃប្រសិទ្ធផលធនធាន និងការអនុវត្តការវាយតម្លៃប្រសិទ្ធផលនៃធនធាននៃវិធានការណ៍កាត់បន្ថយដែលកំណត់អត្តសញ្ញាណរួច ស្របតាមបទបញ្ញត្តិស្ដីពីសវនកម្ម ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍ក្នុងគន្ថីទី២ មាតិកាទី៤ នៃក្រមនេះ ។

**មាត្រា២២១** ._ លិខិតបទដ្ឋានគតិយុត្ត ការបណ្តុះបណ្តាល និងការសម្របសម្រួល

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យឧស្សាហកម្ម និងសិប្បកម្ម ក្រសួង ស្ថាប័នពាក់ព័ន្ធ សមាគមន៍ឧស្សាហកម្ម និងអ្នកពាក់ព័ន្ធផ្សេងទៀតដើម្បី៖

ក. រៀបចំបង្កើតលិខិតបទដ្ឋានគតិយុត្ត ទាក់ទងទៅនឹងប្រសិទ្ធផលធនធាន ការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានពីការប្រើប្រាស់ផលិតផល និងផលិតកម្មស្អាតជាងមុន ។

ខ. បង្កើតគេហទំព័រព័ត៌មានមួយ ដែលផ្ទុកទៅដោយ ទម្លាប់នៃការអនុវត្ត និងបច្ចេកទេសរួម សម្រាប់ ផលិតកម្មស្អាតជាងមុន និង ប្រសិទ្ធផលធនធានសម្រាប់វិស័យផលិតកម្ម និងវិស័យពាក់ព័ន្ធផ្សេងទៀត ។

គ. ផ្តល់ការបណ្តុះបណ្តាលឲ្យបានទៀងទាត់ និងបង្កើតបណ្តាញឲ្យបានទៀងទាត់ផ្អែកទៅលើលទ្ធផល និងបទពិសោធន៍នៃការអនុវត្តជាក់ស្តែង ។

ឃ. សម្របសម្រួលការពិគ្រោះយោបល់តាមវិស័យជាមួយអ្នកបច្ចេកទេស អ្នកគ្រប់គ្រង និងអ្នកជំនាញការផ្សេងទៀត ។

## ផ្នែកទី៥
## ការទទួលខុសត្រូវបន្ថែមរបស់ផលិតករ

**មាត្រា២២២ .**_ កម្មវិធីការទទួលខុសត្រូវបន្ថែមរបស់ផលិតករ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយមានការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងធ្វើការពិគ្រោះយោបល់ជាមួយអ្នកដែលពាក់ព័ន្ធទាំងអស់ ត្រូវបង្កើតកម្មវិធីដែលតម្រូវឲ្យផលិតករទទួលខុសត្រូវបន្ថែម ចំពោះសំណល់ក្រោយអ្នកប្រើប្រាស់រួចដោយផលិតករ ។ កម្មវិធីនេះ ត្រូវបញ្ជាក់ចំណុចដូចខាងក្រោម៖

ក- ការចូលរួមដែលជាកាតព្វកិច្ច និងស្ម័គ្រចិត្ត ក្នុងកម្មវិធីទទួលខុសត្រូវរបស់ផលិតករបន្ថែមអាចអនុវត្តលើ ផលិតផល ក្រុមផលិតផល និងចរន្តសំណល់នានា ។

ខ- គោលដៅសម្រាប់ការប្រមូល ការកែច្នៃឡើងវិញ ការទាញយក ។

គ- កូតាសម្រាប់ការយកផលិតផលត្រលប់មកវិញ ។

ឃ- ការទទួលខុសត្រូវរបស់តួអង្គនីមួយៗក្នុងការខ្សែសង្វាក់នៃការផ្គត់ផ្គង់ ដែលរួមមានទាំងផលិតករក្នុងស្រុក និងអ្នកនាំចូលផលិតផល និងគ្រឿងបច្ចេកវិជ្ជាពីបរទេស ។

ង- ការអភិវឌ្ឍសមត្ថភាពសម្រាប់អ្នកពាក់ព័ន្ធ ។

ច- ការទទួលខុសត្រូវរបស់ផលិតករ និងក្រុមគោលដៅផ្សេងទៀតដែលជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ។

## មាតិកាទី៤
## ការរៀបចំផែនការប្រើប្រាស់បរិស្ថានដី និងនិរន្តរភាពទីក្រុង
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា២២៣ .**_ វិសាលភាពនៃការអនុវត្ត

វិសាលភាពនៃមាតិកានេះរួមមានរាល់ដី និងធនធានដីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២២៤ .**_ ការរៀបចំផែនការប្រើប្រាស់ដីបរិស្ថាន និងនិរន្តរភាពទីក្រុង

ក្រសួង ស្ថាប័នរដ្ឋាភិបាលដែលមានសមត្ថកិច្ចតហារូវដាក់បញ្ចូលចំនុចដូចមានចែងខាងក្រោមនេះទៅក្នុងនីតិវិធីរៀបចំផែនការប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងការបង្កើតនិរន្តរភាពទីក្រុង៖

ក- ការអភិរក្សបរិស្ថាន និងគោលបំណងអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

ខ- បទបញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន

គ- យន្តការសម្រាប់ការការពារ គ្រប់គ្រង និងកាត់បន្ថយហានិភ័យបរិស្ថាន និងផលវិបាកនៃការរៀបចំផែនការប្រើប្រាស់ដីដែលនៅមានភាពខ្វះខាត និងការអភិវឌ្ឍតំបន់ទីក្រុងឆាប់រហ័ស ។

**មាត្រា២២៥ .**_ ការប្រើប្រាស់ភស្តុតាងបែបវិទ្យាសាស្ត្រសម្រាប់ការរៀបចំផែនការ និងវិធានការគ្រប់គ្រង

ការរៀបចំផែនការប្រើប្រាស់ដីបរិស្ថាន និងវិធានការរៀបចំ និរន្តរភាពទីក្រុង ត្រូវផ្អែកលើភស្តុតាងវិទ្យាសាស្ត្រដ៏ល្អបំផុតដែលអាចប្រើប្រាស់បាន និងរួមបញ្ចូលទាំងការប្រើប្រាស់បច្ចេកវិជ្ជាសំខាន់ៗដែលមានក្នុងតំបន់ និងឧបករណ៍រៀបចំផែនការនានា ។

## ជំពូកទី២
## តួនាទី និងការទទួលខុសត្រូវ

**មាត្រា២២៦ .**_ សមត្ថកិច្ចនៃការគ្រប់គ្រងការប្រើប្រាស់ដី

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវមានសមត្ថកិច្ចគ្រប់គ្រងលើការប្រើប្រាស់ដី និងសំណង់ ដើម្បីធានាបាននូវការអភិវឌ្ឍ និងការប្រើប្រាស់ធនធានដី និងដីទាំងឡាយប្រកបដោយប្រសិទ្ធភាព និរន្តរភាព សមធម៌ ភាពចុះសម្រុង និងសមាហរណកម្ម ដោយមានការសម្របសម្រួលជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា២២៧ .**_ អាជ្ញាធរទទួលបន្ទុកលើការចេញអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងការឯកភាព

អាជ្ញាធរទទួលបន្ទុកលើការចេញអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងការឯកភាព ត្រូវពិនិត្យឡើងវិញនូវលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ និងការឯកភាពនៃការប្រើប្រាស់ និងការអភិវឌ្ឍដី ស្របតាមច្បាប់ជាក់លាក់ដោយឡែក និងលិខិតបទដ្ឋានគតិយុត្តដទៃទៀត ដើម្បីធានារាល់ការសាងសង់ និងការប្រើប្រាស់ដីទាំងនោះ ស្របតាមលិខិតអនុញ្ញាតសាងសង់ និងការឯកភាព និងគោរពតាមស្តង់ដាបរិស្ថានពាក់ព័ន្ធ ។

**មាត្រា២២៨ .**_ ការឯកភាពលើលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវពិនិត្យទៅលើលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់បរិស្ថានដី សម្រាប់គ្រប់ផែនការ

ប្រើប្រាស់ដីដែលបានដាក់ស្នើសុំការឯកភាពមកកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាបាននូវភាពត្រឹមត្រូវពេញលេញតាមលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព ។

**មាត្រា២២៩** ._ លក្ខខណ្ឌតម្រូវលិខិត និងវិញ្ញាបនបត្រឯកភាព

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនត្រូវចេញលិខិតអនុញ្ញាត ឬលិខិតឯកភាពលើការសាងសង់ ចំពោះគម្រោងអភិវឌ្ឍសកម្មភាព កម្មវិធី ឬផែនការទាំងឡាយណា ដែលពុំទាន់មានលិខិត និង/ឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានឡើយ ។

**មាត្រា២៣០** ._ ការណែនាំផ្នែកបច្ចេកទេស និងជំនួយនានា

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវផ្តល់ការណែនាំផ្នែកបច្ចេកទេស និងជំនួយនានាពាក់ព័ន្ធទៅនឹង៖

ក- ការធ្វើឲ្យមានសុខដុមរមនីយកម្មទៅលើគោលបំណងនៃកិច្ចការពារផ្នែកបរិស្ថាន ការអភិរក្ស និង ការអភិវឌ្ឍជាតិប្រកបដោយនិរន្តរភាព ។

ខ- ការធានាថា ធនធានទាំងឡាយមានការគ្រប់គ្រងប្រកបដោយនិរន្តរភាព តាមការលើកទឹកចិត្តឲ្យអ្នកគ្រប់គ្រងធនធាន និងអ្នកធ្វើសេចក្តីសម្រេចចិត្ត ធ្វើការពិនិត្យពីផលប៉ះពាល់ និងទំនាក់ទំនងអន្តរវិស័យ ។

គ- ការពង្រឹងកិច្ចសម្របសម្រួលរវាងអង្គភាពរាជរដ្ឋាភិបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដែលពាក់ព័ន្ធ និងភាគីដែលពាក់ព័ន្ធ ។

ឃ- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន វិស័យឯកជន អង្គការក្រៅ រដ្ឋាភិបាល សហគមន៍ និងអ្នកស្រាវជ្រាវការដើម្បីផ្លាស់ប្តូរដំណេះដឹង ព័ត៌មាន និងកង្វល់ពាក់ព័ន្ធ ពាក់ព័ន្ធនឹងការរៀបចំផែនការប្រើប្រាស់ដី និងនិរន្តរភាពទីក្រុង ។

ង- ការប្រមូលទិន្នន័យទាំងបរិមាណ និងគុណភាព និងការប្រើប្រាស់ប្រព័ន្ធជំនួយដែលគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្ត ដើម្បីធានាបាននូវការយល់ដឹងដ៏ទូលំទូលាយអំពីបញ្ហាសម្រាប់វិស័យនានា និងកម្រិតនៃការគ្រប់គ្រងរបស់រដ្ឋាភិបាល ។

**មាត្រា២៣១** ._ ការសហការជាមួយក្រសួងនានា

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវ សហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចដ៏ទៃទៀត អង្គការ

មិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធស្តីពីការអនុវត្ត និងការពង្រឹងការអនុវត្តលក្ខខណ្ឌតម្រូវការរៀបចំផែនការប្រើប្រាស់ដីបរិស្ថានស្របតាមមាតិកានេះ ។

## ជំពូកទី៣
## ការរៀបចំផែនការដីបរិស្ថាន

**មាត្រា២៣២ ._** វិសាលភាពនៃការអនុវត្ត

រាល់គម្រោង ការអភិវឌ្ឍ កម្មវិធី និងផែនការសកម្មភាពនានាដែលទាក់ទងនឹងការប្រើប្រាស់ដី និងសំណង់ ត្រូវមានលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ឬលិខិតឯកភាព ដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងលិខិត ឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា២៣៣ ._** លក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដីដោយគិតគូរពីបញ្ហាបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដែលមានសមត្ថកិច្ចលើការរៀបចំផែនការប្រើប្រាស់ដី នៅក្នុងតំបន់នៃគម្រោង ការអភិវឌ្ឍ កម្មវិធី ឬផែនការដែលបានស្នើសុំ ត្រូវធានាថាការរៀបចំផែនការប្រើប្រាស់ដីនោះ បានបំពេញតាមលក្ខខណ្ឌតម្រូវពេញលេញដូចខាងក្រោម៖

ក- មានកិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធលើផែនការប្រើប្រាស់ដីរបស់ម្ចាស់គម្រោង ។

ខ- ទទួលបាននូវការព្រមព្រៀងជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយពីជនជាតិដើមភាគតិច ដែលសិទ្ធិលើដីរបស់ពួកគេ អាចនឹងរងការប៉ះពាល់ពីគម្រោង សកម្មភាពកម្មវិធី ឬផែនការ ។

គ- មានការបញ្ជាក់អំពីភាពត្រឹមត្រូវរបស់គម្រោង សកម្មភាព កម្មវិធី និងផែនការដែលបានស្នើសុំ ជាមួយនឹងផែនការគ្រប់គ្រងការប្រើប្រាស់ដី ផែនការមេស្តីពីការប្រើប្រាស់ដី និងផែនការយុទ្ធសាស្ត្រទីក្រុងបៃតង និងអំពីភាពត្រឹមត្រូវគ្នាជាមួយនឹងផែនការមេស្តីពីការប្រើប្រាស់ដីក្នុងការអភិវឌ្ឍ ។

ឃ- មានការស្រាវជ្រាវ និងការទទួលបាននូវទិន្នន័យ លម្អិត ដែលមានស្រាប់ និងតាមទីតាំងជាក់លាក់អំពីលក្ខណៈពិសេសនៃតំបន់ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ដីនាបច្ចុប្បន្ន និងនាពេលអនាគត រួមមានបញ្ជីសារពើភ័ណ្ឌធនធានដី ការប្រើប្រាស់ដីបច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធ អត្រាប្រជាជនដែលនៅជុំវិញ សហគមន៍ និងការអនុវត្តតាមវប្បធម៌ និងប្រព័ន្ធផ្សេងៗនៃ

ការចិញ្ចឹមជីវិត សិទ្ធិកាន់កាប់ដី រួមទាំងសិទ្ធិជាលក្ខណៈប្រពៃណី រចនាសម្ព័ន្ធសង្គម រដ្ឋាភិបាល វុក្ខជាតិ ការធ្វើចលនាឆ្លងដែនរបស់សត្វព្រៃ ការរំខានដោយធម្មជាតិ មុខងារធារាសាស្ត្រ ចរន្តថាមពល និងរាល់ព័ត៌មានទាំងឡាយពាក់ព័ន្ធទៅនឹងការប្រើប្រាស់ដីបច្ចុប្បន្នជាអាទិ៍ ។

ង- មានការប្រើប្រាស់បច្ចេកវិជ្ជាប់ដែលល្អបំផុតក្នុងការកំណត់ផែនទី តំបន់ទេសភាព រួមមានការកំណត់ទីតាំង និង/ឬ ការវាយតម្លៃពីធនធានធម្មជាតិ និងទំនិញ និងសេវាកម្ម ពាក់ព័ន្ធទៅនឹងធនធានធម្មជាតិ ការបន្សុីទិន្នន័យនៃការប្រើប្រាស់ដី សិទ្ធិកាន់កាប់ដី និងតំបន់បេតិកភណ្ឌវប្បធម៌ដែលស្ថិតនៅក្នុង និងក្បែរតំបន់អភិវឌ្ឍដែលបានស្នើសុំជាអាទិ៍។

ច- មានការផ្តល់ដំណោះស្រាយបញ្ហានៃការទូទាត់កាបូន និងការបញ្ចេញសំណល់ឧស្ម័ន ហើយត្រូវដាក់បញ្ចូលនូវគោលដៅ និងផែនការនានា ក្នុងការកាត់បន្ថយ និងទូទាត់កាបូន ក៏ដូចជាលំហូរនៃសំណល់ដែលពាក់ព័ន្ធនៅក្នុងរាល់ប្រតិបត្តិការគម្រោងដែលបានធ្វើការស្នើសុំ ។

ឆ- មានការផ្តល់ដំណោះស្រាយទៅលើការបង្កគ្រោះទឹកជំនន់ និងមានភ្ជាប់ទៅដោយផែនការនានា សម្រាប់៖

១- ការបង្ហូរសំណល់ទឹកចេញចូលទាំងអស់ ទាំងនៅខាងក្នុង និងក្រៅតំបន់អភិវឌ្ឍ ឬតំបន់នៃផែនការប្រើប្រាស់ដី ។

២- ហានិភ័យនៃការបំពុលទឹកក្រោមដី និងទឹកលើដី ក៏ដូចជាបញ្ហាពាក់ព័ន្ធ និងការធ្វើប្រព្រឹត្តកម្ម និងការបោះបង់ចោលសំណល់ទឹក ។

៣- ការដាក់កម្រិត និងការគ្រប់គ្រងលំហូរសំណល់រឹង និងសំណល់រាវ រួមមានទីតាំងនានានៃការបោះបង់ចោលជាអាទិ៍ ។

ជ- បញ្ចូលនូវវិធានការនៃការលើកកម្ពស់ការគ្រប់គ្រងប្រកបដោយនិរន្តរភាពលើព្រៃឈើទាំងឡាយនៅក្នុងទីតាំងដែលនៅក្នុង និងក្បែរទីតាំងប្រតិបត្តិការគម្រោង សកម្មភាព កម្មវិធី និងផែនការដែលបានស្នើសុំ ។

ឈ- ដាក់បញ្ចូល និងប្រើប្រាស់ នូវប្រព័ន្ធចំណត និងចលនាផ្លូវថ្នល់ប្រកបដោយប្រសិទ្ធផល នៅក្នុងទីតាំងប្រតិបត្តិការ និងធានាថា ប្រព័ន្ធចំណត និងផ្លូវថ្នល់ទាំងនោះតភ្ជាប់យ៉ាងមានប្រសិទ្ធភាព និងសុវត្ថិភាពទៅកាន់ផ្លូវដែលស្ថិតនៅក្រៅទីតាំងប្រតិបត្តិការគម្រោង ។

ញ- ដាក់បញ្ចូលនូវគោលដៅ និងវិធានការកាត់បន្ថយផលប៉ះពាល់គ្រោះថ្នាក់នាពេលខាងមុខ ដែលគម្រោង សកម្មភាព កម្មវិធី ឬផែនការមានទៅលើ៖

១- ដីដែលរាជរដ្ឋាភិបាលកាន់កាប់ ដែលត្រូវបានកំណត់ជា តំបន់បេតិកភណ្ឌ ឬតំបន់ប្រវត្តិសាស្ត្រ តំបន់វប្បធម៌ជាតិ ។

២- របៀងអភិរក្សចម្រុះ ឬតំបន់ការពារធម្មជាតិ ដែលបានកំណត់ ឬបង្កើត ដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

៣- តំបន់ទាំងឡាយដែលបានកាន់កាប់ និងស្ថិតនៅក្រោមការប្រើប្រាស់ជាលក្ខណៈប្រពៃណី របស់ជនជាតិដើមភាគតិច ។

៤- តំបន់រ៉ាមសារ ។

៥- តំបន់ដែលត្រូវបានកំណត់ដោយ អង្គការសហប្រជាជាតិទទួលបន្ទុកអប់រំ សង្គម វិទ្យាសាស្ត្រ និងវប្បធម៌ ។

៦- តំបន់ទាំងឡាយដែលត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ថាជាតំបន់ដែលមានទឹកសាប និងទឹកសមុទ្រសំខាន់ៗ ឬប្រព័ន្ធអេកូឡូស៊ីនៃតំបន់សមុទ្រ ឬតំបន់អភិរក្សទេសភាព ប្រភេទសត្វ និងរុក្ខជាតិ និងជីវៈចម្រុះដែលមានតម្លៃខ្ពស់ ឬតំបន់ដែលមានតម្លៃអភិរក្សប្រព័ន្ធអេកូឡូស៊ី ។

៧- តំបន់ដទៃទៀតដែលត្រូវបានកំណត់សម្រាប់ការការពារ ឬជាតំបន់ពិសេស ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

ដ- លក្ខខណ្ឌតម្រូវក្នុងការដោះស្រាយគោលដៅ និងវិធានការសម្រាប់ការរក្សាទុក និង/ឬការធ្វើឲ្យប្រសើរឡើងនូវតម្លៃធនធានប្រវត្តិសាស្ត្រ វប្បធម៌ ឬធនធានធម្មជាតិ ដែលស្ថិតនៅក្នុងឬជាប់ទីតាំងប្រតិបត្តការដែលស្នើទាំងអស់

ឋ- លក្ខខណ្ឌតម្រូវក្នុងការដោះស្រាយ និងទទួលយកគ្រប់កាតព្វកិច្ច និងការទទួលខុសត្រូវចំបងក្នុងពេលអភិវឌ្ឍ និងប្រតិបត្តស្របតាមគោលការណ៍អ្នកបំពុលជាអ្នកបង់ថ្លៃចំណាយ

ឌ- លក្ខខណ្ឌតម្រូវដែលថាគម្រោងអភិវឌ្ឍដែលបានស្នើ បង្ហាញពីភាគរយនៃតំបន់សរុប នៃគម្រោងអភិវឌ្ឍដែលបានស្នើ ជាលំហរបៃតងដែលមានទំហំសមស្រប ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវកំណត់លក្ខខណ្ឌតម្រូវសម្រាប់លំហរបៃតងក្នុងលិខិតបទដ្ឋានគតិយុត្ត ។

ក្នុងករណីដែលគម្រោង សកម្មភាព កម្មវិធី ឬផែនការដែលបានស្នើសុំនោះ មិនតម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់ពេញលេញ ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចមិនតម្រូវឲ្យគម្រោង សកម្មភាព កម្មវិធី ឬផែនការដែលបានស្នើសុំមួយចំនួន បំពេញតាមលក្ខខណ្ឌតម្រូវខ្លះៗ ឬមួយចំនួន ដែលត្រូវបានកំណត់ដូចមានចែងក្នុងមាត្រា២៣៣ ។

**មាត្រា២៣៤**._ សិទ្ធិទទួលបានព័ត៌មានបរិស្ថាន

គ្រប់ផែនការប្រើប្រាស់ដី ផែនទីប្រើប្រាស់ដីគ្រប់វិស័យ និងឯកសាររៀបចំផែនការដទៃទៀត

ដែលបង្កើតឡើងសម្រាប់ជាផ្នែកមួយនៃដំណើរការរៀបចំផែនការប្រើប្រាស់ដី ត្រូវទុកនៅក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន សាលាក្រុងដែលពាក់ព័ន្ធ និងអជ្ញាធរថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ និងត្រូវដាក់ជូនដល់សាធារណជនអាចស្វែងរកបាន ។

**មាត្រា២៣៥** ._ ថ្លៃ និងបន្ទុកសេវា

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចធ្វើការយកថ្លៃគ្រប់គ្រាន់ដើម្បីផ្តល់បាននូវរដ្ឋបាលកិច្ចដែលពាក់ព័ន្ធទៅនឹងលក្ខខណ្ឌតម្រូវនៃការប្រើប្រាស់ដី ស្របតាមមាតិកានេះ ។

**មាត្រា២៣៦** ._ ការកែសម្រួលផែនការប្រើប្រាស់ដីដែលបានឯកភាព

ផែនការប្រើប្រាស់ដីអាចមាន សំណើការកែសម្រួលស្របតាម លក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់បរិស្ថានដីបន្ថែម ។

ម្ចាស់គម្រោង ឬអាជ្ញាធរពាក់ព័ន្ធ ដែលធ្វើការស្នើសុំឲ្យមានការកែសម្រួលទៅលើផែនការប្រើប្រាស់ដី ត្រូវរៀបចំឯកសារដែលមានបញ្ជាក់ពីពត៌មានដូចខាងក្រោម៖

ក- ត្រូវមានហេតុផលផ្នែកសេដ្ឋកិច្ចសង្គម និងវិទ្យាសាស្ត្រ ដែលនាំឲ្យមានការកែសម្រួលផែនការប្រើប្រាស់ដី ។

ខ- បង្ហាញពីការខិតខំដើម្បីរក្សានូវស្ថានភាពប្រើប្រាស់ដីបច្ចុប្បន្ន ។

គ- បង្ហាញពីផលប៉ះពាល់ទៅលើបររចិញ្ចឹមជីវិតរបស់សហគមន៍ និងធុរកិច្ចនានាដោយសារការកែសម្រួលលើចំណាត់ថ្នាក់នៃការប្រើប្រាស់ដីដែលទទួលបានការអនុញ្ញាត ។

ឃ- បង្ហាញព័ត៌មានដទៃៗទៀតដែលចាំបាច់ក្នុងការផ្តល់ភាពសមហេតុផលនៃសំណើដែលបានស្នើសុំ ។

រាល់ការស្នើសុំឲ្យធ្វើការកែសម្រួលផែនការប្រើប្រាស់ដីដែលបានទទួលការឯកភាពហើយ ត្រូវអនុលោមតាមបទបញ្ញតិនៃ  ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។

**មាត្រា២៣៧** ._ លក្ខខណ្ឌតម្រូវសម្រាប់លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ឬវិញ្ញាបនបត្រឯកភាព

អង្គភាពរដ្ឋាភិបាលពាក់ព័ន្ធត្រូវធានាថាគ្រប់លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ឬវិញ្ញាបនបត្រឯកភាពអនុលោមទៅតាមលក្ខខណ្ឌតម្រូវនៃផែនការប្រើប្រាស់ដីបរិស្ថាន និងផែនការគ្រប់គ្រងដីដែលបានឯកភាពឲ្យប្រើប្រាស់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ និងគោលនយោបាយគ្រប់គ្រងដីដទៃៗទៀត ។

គ្រប់រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវធ្វើសកម្មភាពដែលស្របទៅតាមផែនការប្រើប្រាស់ដីដែលបានឯកភាពរួចរាល់។

ករណីមិនទាន់មានផែនការគ្រប់គ្រងដីជាមគ្គុទេស ផែនការមេស្តីពីការប្រើប្រាស់ដី ឬផែនការប្រើប្រាស់ដីនៅឡើយ នោះការផ្តល់អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រឯកភាពសម្រាប់ការអភិវឌ្ឍ ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវនៃការប្រើប្រាស់បរិស្ថានដី ស្របតាមក្រមនេះ ។

## ជំពូកទី៤
## និរន្តរភាពទីក្រុង
### ផ្នែកទី១
### ស្ថាប័នទទួលខុសត្រូវ

**មាត្រា២៣៨** ._ ផែនការយុទ្ធសាស្ត្រនិរន្តរភាពទីក្រុង

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានដោយសហការក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រនិរន្តរភាពទីក្រុង ។

**មាត្រា២៣៩** ._ អាជ្ញាធរទទួលខុសត្រូវ

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលខុសត្រូវលើការធានាបាននូវការអនុលោមតាមភារកិច្ច និងការទទួលខុសត្រូវដូចមានចែងក្នុងមាត្រា២៣៨ ។

### ផ្នែកទី២
### គណៈកម្មការនិរន្តរភាពទីក្រុង

**មាត្រា២៤០** ._ គណៈកម្មការនិរន្តរភាពទីក្រុង

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំបង្កើតគណៈកម្មការនិរន្តរភាពទីក្រុង និងលេខាធិការដ្ឋាន តាមការចាំបាច់ ។

គណៈកម្មការនីមួយៗត្រូវមានក្រុមការងារបច្ចេកទេសចម្បងចំនួន៤(បួន)មានដូចខាងក្រោមៈ

១- សម្រាប់កិច្ចការរៀបចំផែនការទីក្រុង និងការដឹកជញ្ជូន ។

២- សម្រាប់កិច្ចការផ្នែកថាមពល និងផលិតកម្ម ។

៣- សម្រាប់ការគ្រប់គ្រងសំណល់ និងភាពងាយរងគ្រោះទីក្រុង ។

៤- សម្រាប់លំហសាធារណៈ បេតិកភណ្ឌវប្បធម៌ និងបរិស្ថានសំណង់ ។ សមាសភាព ភារកិច្ច ការទទួលខុសត្រូវ និងលក្ខខណ្ឌតម្រូវរបស់គណៈកម្មការនិរន្តរភាពទីក្រុង និងក្រុមការងារបច្ចេកទេសចម្បង ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា២៤១** ._ ការរៀបចំផែនការយុទ្ធសាស្ត្រនិរន្តរភាពទីក្រុង

រាជធានី ទីក្រុងតាមខេត្ត និងរាល់ទីក្រុងផ្សេងទៀត ត្រូវបង្កើតផែនការយុទ្ធសាស្ត្រលម្អិតសម្រាប់និរន្តរភាពទីក្រុងដោយឡែកៗរបស់ខ្លួន ស្របតាមតាមស្ថានភាពភូមិសាស្ត្រ អត្រាប្រជារាស្ត្រ និងស្ថានភាពជាក់ស្តែងនៃរាជធានី ឬទីក្រុងនីមួយៗ ។

ការបញ្ចប់ផែនការយុទ្ធសាស្ត្រនិរន្តរភាពទីក្រុងសម្រាប់ប្រភេទទីក្រុងនីមួយៗត្រូវអនុវត្តដំណើការនិងលក្ខខណ្ឌតម្រូវសម្រាប់ការបញ្ចប់ក្របខណ្ឌរៀបចំផែនការយុទ្ធសាស្ត្រនិរន្តរភាពទីក្រុង ដូចដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តដែលធ្វើឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវធ្វើព្រាងផែនការយុទ្ធសាស្ត្រនិរន្តរភាពទីក្រុង និងប្រមូលក្រុមការងារបច្ចេកទេសស្នូលនានាដើម្បីគាំទ្រផែនការយុទ្ធសាស្ត្រនិរន្តរភាពទីក្រុងដែលខកខានមិនបានបង្កើតផែនការយុទ្ធសាស្ត្រនិរន្តរភាពទីក្រុងឬក្រុមការងារបច្ចេកទេសស្នូលនានា។

**មាត្រា២៤២** ._ សិទ្ធិទទួលបានព័ត៌មានបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធានាឲ្យមានសិទ្ធិទទួលបានព័ត៌មានបរិស្ថាន និងការចូលរួមជាសាធារណៈក្នុងការរៀបចំផែនការនិរន្តរភាពទីក្រុង ដូចមានចែងស្របតាមគន្ថីទី១ មាតិកាទី២ និងទី៣នៃក្រមនេះ ។

**មាត្រា២៤៣** ._ ការពិនិត្យឡើងវិញ និងការកែសម្រួលផែនការយុទ្ធសាស្ត្រទីក្រុងប្រកបដោយនិរន្តរភាព

ផែនការយុទ្ធសាស្ត្រទីក្រុងប្រកបដោយនិរន្តរភាពមេ និងផែនការយុទ្ធសាស្ត្រនិរន្តរភាពទីក្រុងលម្អិត ត្រូវទទួលការពិនិត្យឡើងវិញ និងអាចធ្វើការកែសម្រួលយ៉ាងហោចណាស់រៀងរាល់ ៥ (ប្រាំ) ឆ្នាំម្តង អាស្រ័យតាមការប្រែប្រួលស្ថានភាពជាក់ស្តែង នៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ។

# មាតិកាទី៥
# និរន្តរភាពទេសចរណ៍
## ជំពូកទី១
## ការអភិវឌ្ឍនិរន្តរភាពទេសចរណ៍

**មាត្រា២៤៤** ._ វិសាលភាពនៃការអនុវត្ត

មាតិកានេះអនុវត្តទៅលើគម្រោងទេសចរណ៍ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា រួមមានគម្រោងដែលស្ថិតក្នុងរបៀងអភិរក្សជីវចម្រុះនិងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ និងបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**មាត្រា២៤៥** ._ ការពិនិត្យលើនិរន្តរភាព

រាល់គម្រោង ឬសកម្មភាពផ្នែកទេសចរណ៍ដែលកំពុងអនុវត្តបច្ចុប្បន្ន ត្រូវតម្រូវឲ្យធ្វើការពិនិត្យលើនិរន្តរភាព ។

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យទេសចរណ៍ ដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីការពិនិត្យលើនិរន្តរភាព រួមមានលក្ខណៈវិនិច្ឆ័យ និងនីតិវិធី សម្រាប់គម្រោងទេសចរណ៍។

លិខិតបទដ្ឋានគតិយុត្តស្តីពីការពិនិត្យលើនិរន្តរភាពត្រូវៈ

ក- ផ្អែកលើទម្លាប់ល្អបំផុតជាអន្តរជាតិ រួមមានទម្លាប់ដែលកាត់បន្ថយជាអប្បបរិមានូវតំហាយធនធានរូបិយ ឬអរូបិយ

ខ- រួមមានលក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យគម្រោងនានាក្នុងរបៀងអភិរក្សជីវចម្រុះនិងតំបន់ការពារធម្មជាតិដែលត្រូវកំណត់និងបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**មាត្រា២៤៦** ._ ការវាយតម្លៃពីប្រសិទ្ធផលនៃធនធាន

រាល់សកម្មភាព ឬគម្រោងទេសចរណ៍ ដែលបង្កផលប៉ះពាល់ដល់បរិស្ថាន ដែលលើសពីកម្រិតដែលបានអនុញ្ញាត ឬឯកភាព ឬដែលមិនបានអនុលោមស្តង់ដារនានា នៃការវាយតម្លៃទៅលើនិរន្តរភាព ត្រូវតម្រូវធ្វើការវាយតម្លៃពីប្រសិទ្ធផលធនធាន ស្របតាមបទបញ្ញត្តិ ក្នុងគន្លឹទី៣ មាតិកាទី៣ នៃក្រមនេះ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យទេសចរណ៍ ដោយសហកាជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃប្រសិទ្ធផលធនធានសម្រាប់គម្រោងទេសចរណ៍ ។

## ជំពូកទី២
## ទេសចរណ៍ធម្មជាតិដែលផ្អែកលើសហគមន៍គ្រប់គ្រងរួមគ្នា

**មាត្រា២៤៧** ._ សហគមន៍គ្រប់គ្រងរួមគ្នាដែលផ្អែកលើទេសចរណ៍ធម្មជាតិ

រាល់គម្រោងទេចរណ៍ដែលបានស្នើសុំសម្រាប់តំបន់របៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិអំពីការគ្រប់គ្រងរួមគ្នា ស្របតាមបទបញ្ញត្តិនៃគន្ថីទី៤ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា២៤៨** ._ តម្លៃចូលទស្សនា

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចយកថ្លៃចូលទស្សនាសម្រាប់គម្រោងទេសចរណ៍មួយចំនួនដែលស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យទេសចរណ៍ក្រសួង ដោយមានកិច្ចពិគ្រោះជាមួយស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន សហគមន៍ដែលរងផលប៉ះពាល់ និងគ្រប់ភាគីពាក់ព័ន្ធ ត្រូវកំណត់ពីកាលវិភាគសម្រាប់ការបង់ថ្លៃស្របតាមតំបន់ជាក់លាក់នានា ។

តម្លៃចូលទស្សនាទាំងនេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដែលត្រូវប្រើសម្រាប់តែការគ្រប់គ្រងនៅតំបន់របៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលត្រូវបង់ថ្លៃចូលទស្សនាតែប៉ុណ្ណោះ ។ យន្តការបែងចែកផលប្រយោជន៍ផ្សេងៗទៀតត្រូវកំណត់លើដោយផ្អែកលើគម្រោងមួយៗ ដោយមានកិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

**មាត្រា២៤៩** ._ ទេសចរណ៍ធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យទេសចរណ៍ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ស្តីពីការអភិវឌ្ឍ និងការគ្រប់គ្រងវិស័យទេសចរណ៍ធម្មជាតិដែលមានមូលដ្ឋានលើសហគមន៍ ការទទួលខុសត្រូវដោយការគ្រប់គ្រងរួមគ្នា និងដែលមាននិរន្តរភាព ។ លិខិតបទដ្ឋានគតិយុត្តនេះ ត្រូវបំពេញតាមស្តង់ដារទេសចរណ៍ដែលផ្អែកលើសហគមន៍ នៃសមាគមន៍ប្រទេសនៃតំបន់អាស៊ីអាគ្នេយ៍ ។

## មាតិកាទី៦
## និរន្តរភាពថាមពល
## ជំពូកទី១
## ថាមពលប្រកបដោយនិរន្តរភាព

**មាត្រា២៥០** ._ វិសាលភាពនៃការអនុវត្ត

មាតិកានេះអនុវត្តទៅលើការផលិត និងការចែកចាយអគ្គិសនីនិងការប្រើប្រាស់សេវាអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៥១** ._ គោលការណ៍ថាមពលប្រកបដោយនិរន្តរភាព

រាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តគោលការណ៍និរន្តភាពថាមពល និងផ្តល់អាទិភាពលើការអភិវឌ្ឍគម្រោងនិរន្តរភាពថាមពលដើម្បីសម្រេចបានការតម្រូវការនាពេលបច្ចុប្បន្ន និងអនាគតសម្រាប់ព្រះរាជាណាចក្រកម្ពុជា។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ក្រសួង ស្ថាប័នផ្សេងៗ និងនីតិបុគ្គលសាធារណៈត្រូវអនុវត្តគោលការណ៍និរន្តរភាពថាមពលក្នុងការសម្រេចចិត្ត និងកម្មវិធិរបស់ពួកគេ។ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវធានាថានីតិបុគ្គលឯកជនអនុវត្តគោលការណ៍និរន្តរភាពថាមពលក្នុងគម្រោងដែលអភិវឌ្ឍក្រោមសិទ្ធិអំណាចរបស់ពួកគេ។

**មាត្រា២៥២** ._ និរន្តរភាពថាមពល

ដើម្បីសម្រេចបាននូវគោលបំណងនៃនិរន្តរភាពថាមពល វិធីសាស្ត្រអនុវត្តមានដូចខាងក្រោម៖

ក- ការគាំទ្រ និងការលើកកម្ពស់គម្រោង និងថាមពលប្រកបដោយនិរន្តរភាព ។

ខ- ការពិចារណាលើការប្រែប្រួលអាកាសធាតុអន្តរជាតិរបស់ ព្រះរាជាណាចក្រកម្ពុជានៅក្នុងរាល់ការសម្រេចចិត្តទៅលើគម្រោងថាមពល ។

គ- ការអនុម័តយកនូវគម្រោងថាមពលណា ដែលមានលក្ខណៈប្រកបដោយនិរន្តរភាពច្បាស់លាស់មួយ ។

ឃ- ការផ្តល់អាទិភាពចំពោះការវិនិយោគក្នុងគម្រោងថាមពលប្រកបដោយនិរន្តរភាព ។

ង- ការលើកកម្ពស់បច្ចេកវិជ្ជាដែលមិនបង្កផលប៉ះពាល់បរិស្ថាន ។

ច- ការផ្តល់ការគាំទ្រប្រភពថាមពលវិមជ្ឈការនិងប្រព័ន្ធបណ្តាញអគ្គិសនីខ្នាតតូច និងតូចជាង ។

ឆ- ការលើកកម្ពស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលផ្ទះ និងប្រព័ន្ធផលិតនិងស្តុកអគ្គិសនីតាមផ្ទះ ។

## ជំពូកទី២
## ការរៀបចំផែនការនិរន្តរភាពថាមពល

**មាត្រា២៥៣ .**_ ផែនការថាមពលនិងអគ្គិសនីជាតិប្រកបដោយនិរន្តរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យថាមពល ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវបង្កើតនូវផែនការថាមពល និងអគ្គិសនីប្រកបដោយនិរន្តរភាពជាតិ ដោយធ្វើការសហការកិច្ចការរបស់ខ្លួន ជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ ក៏ដូចជាពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល និងសហគមន៍ដែលប៉ះពាល់ដោយការអភិវឌ្ឍគម្រោងថាមពលនិងអគ្គិសនី ។

ផែនការនិរន្តរភាពថាមពល និងអគ្គិសនីជាតិត្រូវរួមមានគោលដៅនិរន្តរភាពថាមពលសម្រាប់ព្រះរាជាណាចក្រកម្ពុជា។

ក្នុងការអភិវឌ្ឍផែនការនិរន្តរភាពថាមពល និងអគ្គិសនី ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យថាមពល ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវរៀបចំការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ស្របតាមបទបញ្ញត្តិក្នុងគន្ថីទី២ មាតិកាទី២នៃក្រមនេះ។

**មាត្រា២៥៤ .**_ ធាតុផ្សំនៃផែនការ

ផែនការថាមពលនិងអគ្គិសនីជាតិជាឧបករណ៍ដែលសម្រាប់ការបង្កើតគោលនយោបាយ និងជាមគ្គុទេសមួយសម្រាប់សកម្មភាពគ្រប់គ្រង ។ ផែនការត្រូវរួមមាន ៖

ក- ការស្រាវជ្រាវទៅលើការបង្កើតគោលនយោបាយស្តង់ដារ ដើម្បីបង្កើនចំនួន និង/ឬសមាមាត្រថាមពលដែលអាចកើតឡើងជាថ្មី ដែលទិញបានពីស្ថាប័នជាក់លាក់មួយ ។

ខ- ការវាយតម្លៃស្ថានភាពបច្ចុប្បន្ននៃថាមពល និងការផលិតអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធបែងចែកភ្លើង ។

គ- ការពិពណ៌នាអំពីគម្រោងដែលមានលទ្ធភាពអាចបង្កើត បង្កើតសម្រាប់ផ្គល់ប្រេងឥន្ធនៈ និងការផលិតអគ្គិសនី ក៏ដូចជាការចែកចាយអគ្គិសនី ។

ឃ- គោលដៅជាក់លាក់សម្រាប់បង្កើតថាមពលប្រកបដោយនិរន្តរភាព ។

ង- ការពិនិត្យសំណល់ដែលបន្សល់ទុក ដោយគម្រោងថាមពលដែលអាចកកើតថ្មី ។ ផែនការត្រូវបង្កើតសម្រាប់ការកែច្នៃឡើងវិញ ឬការគ្រប់គ្រងសំណល់ដែលបន្សល់ទុកដែលកើតឡើងដោយ ការអភិវឌ្ឍថាមពលកកើតឡើងវិញ ។

ច- ការវិភាគផលប៉ះពាល់បរិស្ថាននៃគម្រោងផលិតថាមពល និងអគ្គិសនីដែលបាន គ្រោងទុក ។

ឆ- ការរៀបចំផែនការប្រើប្រាស់ធនធានបញ្ចូលគ្នាដែលក្នុងនោះការប្រើប្រាស់ធនធានប្រកួតប្រជែងត្រូវវាយតម្លៃដោយផ្អែកលើ តម្លៃចំណាយនិងផលចំណេញនៃធនធាននីមួយៗដែលយកមកប្រើប្រាស់ ដោយគិតពីថ្លៃចំណាយនៃវដ្តនៃជីវិតធនធាននោះ និងផលប៉ះពាល់អវិជ្ជមានដល់សង្គម និងកត្តាបរិស្ថានខាងក្រៅ ។

**មាត្រា២៥៥** ._ ការអនុលោមទៅតាមផែនការ និងការរៀបចំផែនការ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យថាមពលត្រូវទទួលខុសត្រូវការអនុលោមតាមផែនការនិរន្តរភាពថាមពល និងអគ្គិសនីជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យថាមពលត្រូវផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីការអភិវឌ្ឍផែនការនិរន្តរភាពថាមពល និងអគ្គិសនីជាតិ ស្របតាមបទបញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាននៃគន្ថីទី១ មាតិកាទី៣នៃក្រមនេះ ។

**មាត្រា២៥៦** ._ តំបន់ហាមឃាត់មិនឲ្យឲ្យមានគម្រោងថាមពល

មិនត្រូវអនុញ្ញាតឲ្យមានគម្រោងថាមពលនៅក្នុង៖

១- ដីសាធារណៈរបស់រដ្ឋដែលត្រូវបានកំណត់ជាទីតាំងវប្បធម៌ប្រវត្តិសាស្ត្រ ឬបេតិកភណ្ឌជាតិ ។

២- របៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើកលែងការដំឡើងកម្រិតថាមពលក្រៅបណ្តាញ កម្រិតភូមិ និង គ្រួសារ ។

៣- តំបន់ដែលតាំងនៅដោយជនជាតិដើមភាគតិច ឬទាក់ទិននឹងការប្រើប្រាស់ជាប្រពៃណីរបស់ជនជាតិដើមភាគតិច លើកលែងតែក្នុងករណីដែលមានការផ្តល់ជូននូវការយល់ព្រមជាមុន ដោយសេរីបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយទៅកាន់ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ លើកលែងការដំឡើងកម្រិតថាមពលក្រៅបណ្តាញ កម្រិតភូមិ និងគ្រួសារ ។

៤- ទីតាំងដីសើម ។

៥- ទីតាំង អង្គការសហប្រជាជាតិទទួលបន្ទុកអប់រំ សង្គម វិទ្យាសាស្ត្រ និងវប្បធម៌ ។

៦- តំបន់ណាដែលមានក្នុងបញ្ជីឧបករណ៍គតិយុត្តិថាជាតំបន់ដែលមាន៖

ក-ប្រព័ន្ធអេកូឡូស៊ីទឹកសាប ទឹកសមុទ្រ ឬឆ្នេរសំខាន់ ។

ខ-តម្លៃអភិរក្សទេសភាពខ្ពស់ ជីវៈចម្រុះប្រភេទសត្វនិងរុក្ខជាតិ ឬតម្លៃអភិរក្ស ប្រព័ន្ធអេកូឡូស៊ី ។

## ជំពូកទី៣
## ការលើកកម្ពស់នូវ បច្ចេកវិជ្ជាមេត្រីបរិស្ថាន

**មាត្រា២៥៧ ._** បច្ចេកវិជ្ជាដែលប្រកបដោយប្រសិទ្ធផល បញ្ចេញការបំភាយទាប និងសំណល់ទាប

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវពិនិត្យគម្រោងថាមពលនីមួយៗ ដើម្បីធានាថា គម្រោងនេះអនុវត្តនូវបច្ចេកវិជ្ជា ថាមពលប្រកបដោយប្រសិទ្ធផល បញ្ចេញការបំភាយទាប និង សំណល់ទាប ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវពិនិត្យគម្រោងថាមពលនីមួយៗ ដោយប្រើប្រាស់ បច្ចេកវិជ្ជាដ៏ល្អបំផុតដែលអាចស្វែងរកបាន និងការអនុវត្តល្អៗជាអន្តរជាតិ នៅក្នុង វិស័យថាមពលពាក់ព័ន្ធ ។

**មាត្រា២៥៨ ._** បច្ចេកវិជ្ជាល្អបំផុតដែលអាចស្វែងរកបាន និងជម្រើសដែលមានផលប៉ះពាល់ទាប

ស្របតាមបទបញ្ញត្តិស្តីពីការវាយតម្លៃបរិស្ថាននៃគន្ថីទី២ មាតិកាទី៣ នៃក្រមនេះ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានមិនត្រូវឯកភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ សម្រាប់គម្រោងណាមួយដែលប្រើប្រាស់ បច្ចេកវិជ្ជា ដែលមិនមែនជា បច្ចេកវិជ្ជាដ៏ល្អបំផុតដែល អាចស្វែងរកបាន  ឬ ដែលអាចផ្តល់ផលប៉ះពាល់ដល់បរិស្ថានច្រើនជាងជម្រើសដែលអាចស្វែងរក បានណាមួយ ។ ម្ចាស់គម្រោងអាចត្រូវបានតម្រូវឲ្យដាក់បញ្ជូននូវការរចនាដែលជាជម្រើស ដែលមាន ប្រសិទ្ធផលជាង និងបង្កឲ្យមានសំណល់ និងការបំភាយតិច ខណៈពេលដែលសម្រេចបាននូវគោល បំណងនានាដែលបានចែងនៃគម្រោង ។

**មាត្រា២៥៩ ._** ការលើកកម្ពស់ការផ្គត់ផ្គង់អគ្គិសនី

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា រួមមានក្រសួង ស្ថាប័ន និងនីតិបុគ្គលសាធារណៈ ដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី ត្រូវ ជំរុញ និងលើកកម្ពស់ដល់ការផ្គត់ផ្គង់អគ្គីសនី ដែលចេញមកពីបណ្តាញតចូលជាតិ និងមកពីប្រភពអគ្គិសនីវិមជ្ឈការ ដែលត្រូវបានផលិតឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន ។ អ្នកប្រើប្រាស់   អគ្គីសនី ត្រូវបានលើកទឹកចិត្ត និងលើកកម្ពស់ឲ្យដំឡើងបច្ចេកវិជ្ជាវិមជ្ឈការសម្រាប់បំពេញតម្រូវការនៃ ការផ្គត់ផ្គង់ថាមពលអគ្គីសនីរបស់ខ្លួន។

អ្នកប្រើប្រាស់អគ្គិសនីមិនត្រូវបានបង្ខំឲ្យប្រើប្រាស់អគ្គិសនីដែលបានមកពីប្រភពនៃការផលិតថាមពលជាក់លាក់ណាមួយទេ ។

**មាត្រា២៦០** ._ ការលើកកម្ពស់ការផ្គត់ផ្គង់អគ្គិសនីខ្នាតតូច និងបណ្ដាញតចូលខ្នាតតូច

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវគាំទ្រការផ្ដល់ការផ្គត់ផ្គង់អគ្គសនីខ្នាតតូច និងការផ្គត់ផ្គង់អគ្គិសនីតាមបណ្ដាញតូច ។ ប្រតិបត្តិករបណ្ដាញអគ្គិសនីខ្នាតតូច ត្រូវមានជម្រើសដូចខាងក្រោម៖

ក- បន្តផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ និងមានអត្ថិភាពស្របគ្នាជាមួយបណ្ដាញតចូលជាតិ ។

ខ- បន្តផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ និងលក់អគ្គិសនីដែលលើស ឬ ដែលមិនទាន់បានលក់ ទៅកាន់បណ្ដាញតចូលជាតិ នៅចំណុចអន្តរបណ្ដាញ និងទាញយកថាមពលមកពីបណ្ដាញអគ្គសនីខ្នាតតូច ។

ក្នុងករណីដែលបណ្ដាញតចូលខ្នាតតូចភ្ជាប់ជាមួយបណ្ដាញតចូលជាតិ ដើម្បីលក់ភ្លើងដែលសល់ ប្រតិបត្តិករនៃបណ្ដាញអគ្គិសនីខ្នាតតូច ត្រូវចុះកិច្ចសន្យាទិញថាមពលជាមួយនីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី ។

**មាត្រា២៦១** ._ សិទ្ធិក្នុងការផ្ទេរកម្មសិទ្ធិ

ប្រតិបត្តិករនៃបណ្ដាញតចូលខ្នាតតូច ត្រូវមានសិទ្ធិជាឯកតោភាគីក្នុងការសម្រេចចិត្តក្នុងការផ្ទេរកម្មសិទ្ធិនៃការផ្គត់ផ្គង់ និងទ្រព្យសម្បត្តិនៃការផលិតទាំងអស់នៃបណ្ដាញតចូលខ្នាតតូច ទៅឲ្យនីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី ។ តម្លៃនៃប្រតិបត្តិការផ្ទេរកម្មសិទ្ធិត្រូវតាម តាមតម្លៃទីផ្សារសេរីបច្ចុប្បន្ននៃទ្រព្យសម្បត្តិដែលត្រូវផ្ទេរនោះតាមការព្រមព្រៀងរវាងគូភាគី ។

**មាត្រា២៦២** ._ ការផលិតថាមពលអគ្គិសនីកកើតឡើងវិញតាមផ្ទះ

ការផលិតថាមពលអគ្គិសនីកកើតឡើងវិញតាមផ្ទះ មិនតម្រូវឲ្យមានលិខិតអនុញ្ញាតណាមួយពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការដំឡើងឡើយ ដ៏រាបណាគ្រួសារនោះប្រើប្រាស់ឧបករណ៍ដែលមានការទទួលស្គាល់ ដោយអនុលោមតាមលក្ខខណ្ឌនានានៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដ៏ទៃទៀត ។

**មាត្រា២៦៣** ._ ថាមពលប្រកបដោយនិរន្តរភាពរបស់ធុរកិច្ច និងសហគមន៍

ធុរកិច្ច ឬ សហាគមន៍ដែលបង្កើតប្រព័ន្ធនិរន្តរភាពថាមពល សម្រាប់ការផ្គត់ផ្គង់ អគ្គិសនីផ្ទាល់ខ្លួន មានសិទ្ធិភ្ជាប់ទៅកាន់បណ្តាញតចូលដែលមានស្រាប់ទៅតាមការព្រមព្រៀងរបស់អ្នកពាក់ព័ន្ធ ។

**មាត្រា២៦៤** ._ លក្ខខណ្ឌសម្រាប់លិខិតអនុញ្ញាត

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវធានាថា លក្ខខណ្ឌតម្រូវក្នុងការទទួលលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ មិនបានទប់ស្កាត់

ក- ធុរកិច្ច និងសហាគមន៍ ឬអ្នកអភិវឌ្ឍដែលជាភាគីទី៣ដែលមានកិច្ចព្រមព្រៀងជាមួយធុរកិច្ច ឬសហាគមន៍ពីការអភិវឌ្ឍនិរន្តរភាពថាមពលតែមួយ សម្រាប់បទបញ្ញត្តិពាក់ព័ន្ធនឹងអគ្គិសនីទៅកាន់អ្នកប្រើប្រាស់ ដរាបណា៖

១- ធុរកិច្ច និងសហាគមន៍ ឬអ្នកអភិវឌ្ឍដែលជាភាគីទី៣ ប្រើប្រាសឧបករណ៍ដែលមានវិញ្ញាបនបត្រទទួលស្គាល់ស្របតាមបទបញ្ញត្តិនៃក្រមនេះ ។

២- ធុរកិច្ច និងសហាគមន៍ ឬអ្នកអភិវឌ្ឍដែលជាភាគីទី៣ប្រើប្រាស់បច្ចេកទេសជាក់លាក់ដើម្បីធានាថា អគ្គិសនីដែលដាក់បញ្ចូលទៅក្នុងបណ្តាញតចូលគឺមានកម្រិតអប្បបរមា ដើម្បីការពារហេដ្ឋារចនាសម្ព័នពីការខូចខាតដែលបន្តកើនឡើង ។

ខ- នីតិបុគ្គលឯកជនពីការអភិវឌ្ឍនិរន្តរភាពថាមពលក្នុងព្រះរាជាណាចក្រកម្ពុជា

នីតិបុគ្គលឯកជនមិនត្រូវបានដាក់កម្រិតនូវចំនួននៃលិខិតអនុញ្ញាត ឬ អាជ្ញាប័ណ្ណ ដែលពួកគេទទួលបានពីអជ្ញាធរទទួលបន្ទុកក្នុងការធ្វើនិយ័តកម្ម ការចែកចាយអគ្គិសនី និងការប្រើប្រាស់សេវាអគ្គិសនី សម្រាប់គម្រោងខ្នាតតូច ដោយមានសមត្ថភាពផលិតក្រោម៥(ប្រាំ)ម៉េហ្គាវ៉ាត់ ។

នីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនីត្រូវធ្វើនិយ័តកម្មការដាក់បញ្ចូលអគ្គិសនីទៅក្នុងបណ្តាញតចូលដើម្បីធានានូវភាពអាចទុកចិត្តបាន និងសុវត្ថិភាព។

**មាត្រា២៦៥** ._ ការហាមឃាត់លើឯកសិទ្ធិ

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវធានាថា មិនមាននីតិបុគ្គលឯកជនណាមានឯកសិទ្ធិលើសពីអ្នកដទៃទៀតឡើយ រួមបញ្ចូល នៅក្នុងការធានានូវលិខិតអនុញ្ញាត ឬ អាជ្ញាប័ណ្ណទាំងអស់ និងនៅក្នុងការចចារអំពីលក្ខខណ្ឌនានានៃកិច្ចសន្យា ដែលបានឯកភាពជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

សេចក្តីសម្រេចទាំងអស់ សម្រាប់ការផ្តល់លិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណ និងការធ្វើឲ្យទៅជាផ្លូវការនូវលក្ខខណ្ឌពាក់ព័ន្ធដទៃទៀតសម្រាប់កិច្ចសន្យា ត្រូវធ្វើឡើងដោយផ្អែកលើភស្តុតាងផ្នែកបច្ចេកទេស និងសេដ្ឋកិច្ច ដូចត្រូវបានទទួលយកនៅក្រោមការអនុវត្តល្អៗជាអន្តរជាតិ ។

នៅពេលជ្រើសរើសនីតិបុគ្គលឯកជនដើម្បីអភិវឌ្ឍថាមពល ឬ ផលិតអគ្គិសនី ឬ គម្រោងចែកចាយអគ្គិសនីដែលពាក់ព័ន្ធ នៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់បញ្ចូលជាចាំបាច់ នៅក្នុងដំណើរការនៃការដាក់ពាក្យសុំ នូវលទ្ធភាពសម្រាប់ការក្រកូតប្រដែងលក្ខណៈបើកចំហ និង  នីតិបុគ្គលឯកជនដទៃទៀត ក្នុងការដាក់បញ្ជូននូវសំណើ ដោយធានាថានីតិបុគ្គលឯកជនទាំងនោះ អាចមានលទ្ធភាព និងពេលវេលាសមរម្យ ក្នុងការរៀបចំសំណើរបស់ពួកគេ ។

## ជំពូកទី៤
## ការត្រួតពិនិត្យគុណភាពផលិតផលសម្រាប់ផលិតថាមពលប្រកបដោយនិរន្តរភាព

**មាត្រា២៦៦** ._ អង្គភាពឯករាជ្យ

អាជ្ញាធរទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង្កើតអង្គភាពឯករាជ្យ នៅក្នុងរយៈពេល១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃអនុម័តនៃក្រមនេះ ដើម្បីត្រួតពិនិត្យគុណភាពនៃឧបករណ៍ផលិតថាមពល ដែលត្រូវបានផ្គត់ផ្គង់ និងប្រើប្រាស់ សម្រាប់ទីផ្សារជាតិ ដើម្បីធានាថាឧបករណ៍ទាំងនេះអនុលោមតាមស្តង់ដារសុខភាព សុវត្ថិភាព និងស្តង់ដារបរិស្ថាន ។ អង្គភាពឯករាជ្យ ដែលត្រូវបានបង្កើតឡើង ត្រូវទទួលភារកិច្ចក្នុងការអនុវត្តសវនកម្ម ការធ្វើតេស្ត និងការបញ្ជាក់លើឧបករណ៍ទាំងនេះ ។

**មាត្រា២៦៧** ._ ការបញ្ជាក់អំពីគុណភាព

អង្គភាពឯករាជ្យ ត្រូវផ្ទៀងផ្ទាត់ថា គុណភាពនៃផលិតផលដែលត្រូវបានលក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ការផលិតថាមពល បានទទួលនូវការបញ្ជាក់អំពីគុណភាព មុនពេលដែលផលិតផលទាំងនោះត្រូវបានធ្វើពាណិជ្ជកម្ម ។ ការបញ្ជាក់នេះអាចត្រូវបានត្រួតពិនិត្យដោយអង្គការស្តង់ដារអន្តរជាតិ ។

ការផ្ទៀងផ្ទាត់ចំពោះឧបករណ៍ដែលនាំចូល ត្រូវធ្វើឡើងនៅផ្នែកគយ ។ ការផ្ទៀងផ្ទាត់សម្រាប់ផលិតផលថ្នាក់ជាតិ ត្រូវធ្វើឡើងមុនពេលធ្វើពាណិជ្ជកម្មទៅកាន់សាធារណជន ដោយអង្គភាពឯករាជ្យ ។

**មាត្រា២៦៨** ._ ការធានាស្តង់ដារ

អង្គភាពឯករាជ្យ ត្រូវត្រួតពិនិត្យ និងធានាថា ស្តង់ដារលើផលិតផលថាមពលកកើតឡើងវិញ ត្រូវបានបំពេញ និងអនុលោមតាមស្តង់ដារតម្រូវ ។ អ្នកធានាត្រូវទទួលខុសត្រូវជាអប្បរមាសងមកវិញ

នូវផលិតផលដល់អ្នកប្រើប្រាស់នោះក្នុងរយៈពេលសមស្រប ទៅតាមលក្ខខណ្ឌនៃកិច្ចសន្យាធានា នៅក្នុងករណីមានវិការៈ ដំណើរការមិនល្អ ឬ ខកខានមិនបានអនុលោមតាមស្តង់ដារ ។

## ជំពូកទី៩
## ក្របខ័ណ្ឌនៅតាមប្រភេទថាមពល ឬគម្រោងអគ្គិសនី
## ផ្នែកទី១
## ថាមពលពន្លឺព្រះអាទិត្យ

**មាត្រា២៦៩ .**_ ករណីលើកលែងផ្នែកពន្ធ

គ្រប់ផ្ទាំងកញ្ចក់ពន្លឺព្រះអាទិត្យ ឬថាមពលពន្លឺព្រះអាទិត្យ និងសម្ភារនានា ដែលប្រើសម្រាប់ការដំឡើងប្រព័ន្ធពន្លឺព្រះអាទិត្យនៅតាមផ្ទះ មិនត្រូវជាប់ពន្ធនាំចូលឡើយ គឺដើម្បីលើកទឹកចិត្តឲ្យមានការចែកចាយ និងការបង្កើនការផលិតថាមពលអគ្គិសនីនៅតាមផ្ទះនៃប្រជាជនក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រព័ន្ធពន្លឺព្រះអាទិត្យតាមផ្ទះ ត្រូវស្ថិតនៅក្រោមស្តង់ដារគុណភាពជាតិ និងអន្តរជាតិ និងអធិការកិច្ចផ្នែកគ្រប់គ្រងគុណភាព ដែលត្រូវធ្វើឡើងដោយស្ថាប័នឯករាជ្យដែលត្រូវបង្កើតឡើងតាមជំពូកទី៤ នៃមាតិកានេះ ។

អង្គភាពឯករាជ្យនេះ និងអជ្ញាធរទទួលបន្ទុកក្នុងការធ្វើនិយ័តកម្ម ការចែកចាយអគ្គិសនី និងការប្រើប្រាស់សេវាអគ្គិសនីត្រូវធ្វើការអង្កេតតាមដាន ធ្វើយ៉ាងណាបញ្ជាក់ថា ប្រព័ន្ធពន្លឺព្រះអាទិត្យតាមផ្ទះមានគុណភាពខ្ពស់ ត្រូវបានដំឡើងត្រឹមត្រូវ ហើយតម្លៃដែលបានបង់ទុកជាមុន ទាំងថ្លៃដំឡើងផងត្រូវបានទូទាត់ ។

**មាត្រា២៧០ .**_ ការគ្រប់គ្រងក្នុងការប្រើប្រាស់អគ្គិសនីបន្ថែមតាមបណ្តាញតចូល

ក្នុងករណីដែលមានផ្គត់ផ្គង់អគ្គិសនីបន្ថែម អគ្គិសនីតាមបណ្តាញតចូលដោយតភ្ជាប់ទៅនឹងប្រព័ន្ធដំឡើងថាមពលពន្លឺព្រះអាទិត្យ តាមដំបូលផ្ទះ ការផ្គត់ផ្គង់អគ្គិសនីបន្ថែម ត្រូវគ្រប់គ្រង នីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី ។ រូបវន្តបុគ្គល ឬនីតិបុគ្គលឯកជន ដែលជាម្ចាស់ដំឡើងប្រព័ន្ធពន្លឺព្រះអាទិត្យតាមដំបូលសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវមានសិទ្ធិតភ្ជាប់ទៅនឹងបណ្តាញតចូល ។

អជ្ញាធរទទួលបន្ទុកក្នុងការធ្វើនិយ័តកម្ម ការចែកចាយអគ្គិសនី និងការប្រើប្រាស់សេវាអគ្គិសនីត្រូវបង្កើតលិខិតបទដ្ឋានដើម្បីកំណត់ពីក្របខ័ណ្ឌ កំណត់ស្តង់ដារ និងផ្តល់ការអនុញ្ញាតឲ្យមានការ

លក់អគ្គិសនីដែលកកើតឡើងវិញទៅកាន់សហគ្រាស ឬសហគមន៍ក្រោយពីក្រមនេះត្រូវបានអនុម័ត ក្នុងរយៈពេលមួយឆ្នាំ ។

**មាត្រា២៧១** ._ វង្វាស់ថាមពល

អជ្ញាធរទទួលបន្ទុកក្នុងការធ្វើនិយ័តកម្ម ការចែកចាយអគ្គិសនី និងការប្រើប្រាស់សេវាអគ្គិសនី ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តដើម្បីអនុញ្ញាតឲ្យមានការវាស់កម្រិតថាមពលដោយអ្នកប្រើប្រាស់ថាមពលដែលភ្ជាប់ទៅ បណ្ដាញតចូល ។ អ្នកទទួលផលអាចបង់ថ្លៃប្រើប្រាស់អគ្គិសនីទៅតាមអ្វីដែលបង្ហាញលើវង្វាស់ថាមពលនោះ ។

លិខិតបទដ្ឋានគតិយុត្តស្ដីពីវង្វាស់ថាមពល ត្រូវបង្កើតអំពីអាត្រាតម្លៃអគ្គិសនីសម្រាប់លក់ទៅកាន់នីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី ។ អ្នកទទួលផលត្រូវបង់ថ្លៃប្រើប្រាស់អគ្គិសនីទៅតាមអ្វីដែលបង្ហាញលើវង្វាស់ថាមពលនោះ ។

នីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនីត្រូវទទួលខុសត្រូវលើការអនុវត្តលិខិតបទដ្ឋានគតិយុត្តស្ដីពីវង្វាស់ថាមពល។

កិច្ចព្រមព្រៀងស្ដីពីការដាក់វង្វាស់ថាមពល និងការចេញវិក្កយបត្រប្រចាំខែរវាងនីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី និងម្ចាស់អាគារ ឬកន្លែងផ្គត់ផ្គង់ថាមពលពន្លឺព្រះអាទិត្យត្រូវធ្វើឡើង ។

**មាត្រា២៧២** ._ សិទ្ធិក្នុងការតភ្ជាប់ទៅនឹងបណ្ដាញតចូល

កន្លែងផ្គត់ផ្គង់ ដែលត្រូវប្រតិបត្តិដោយសហគមន៍ ឬសហគ្រាសទាំងឡាយ ទាំងដែលប្រើពិលពន្លឺព្រះអាទិត្យ ឬប្រើកញ្ចក់ពន្លឺព្រះអាទិត្យក្តី ត្រូវទទួលបានការអនុញ្ញាតស្របច្បាប់ឲ្យតចូល និងផ្ទេរភ្លើងចូលទៅក្នុងបណ្ដាញតចូល ។

នីតិបុគ្គលសាធារណៈដែលទទួលបន្ទុកផលិតកម្ម ការចែកចាយអគ្គិសនី និងការគ្រប់គ្រងការប្រើប្រាស់សេវាអគ្គិសនី អាចធ្វើជាកម្មសិទ្ធិករ ប្រតិបត្តិករ និងអ្នកថែរក្សាកន្លែងផ្គត់ផ្គង់ថាមពលពន្លឺព្រះអាទិត្យ ត្រូវមានសិទ្ធិជួលបន្តនូវសិទ្ធិប្រតិបត្តិការ និងថែរក្សាកន្លែងទាំងនោះ ។

**មាត្រា២៧៣** ._ ប្រព័ន្ធអនុគ្រោះពន្ធលើថាមពលកកើតឡើងវិញ ជាការសាកល្បង

អជ្ញាធរទទួលបន្ទុកក្នុងការធ្វើនិយ័តកម្ម ការចែកចាយអគ្គិសនី និងការប្រើប្រាស់សេវាអគ្គិសនី ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ស្ដីពីប្រព័ន្ធអនុគ្រោះពន្ធលើថាមពលកកើតឡើងវិញ សាកល្បងក្នុងរយៈពេល១ (មួយ)ឆ្នាំ ដែលក្នុងនោះ រាជរដ្ឋាភិបាលត្រូវផ្តល់ជាអត្រាថេរមួយសម្រាប់ការជាវ

អគ្គិសនីដែលកកើតឡើងវិញពីកន្លែងផ្តល់ថាមពលពន្លឺព្រះអាទិត្យ ឬប្រព័ន្ធផលិតថាមពលដែលកកើតឡើងវិញ ។

ប្រព័ន្ធនេះ ត្រូវមានគោលបំណងធានាបាននូវតម្រឹតថ្លៃថាមពលសម្រាប់មួយរយៈពេលណាមួយក្នុងគោលបំណងកាត់បន្ថយថ្លៃដែលត្រូវបង់ដោយអ្នកប្រើប្រាស់ចុងក្រោយ និងសម្រួលដល់ស្តារឡើងវិញនូវចំណាយវិនិយោគរបស់ម្ចាស់គម្រោង និងចំណាយថែទាំ ។

លិខិតបទដ្ឋានគតិយុត្តនេះ ត្រូវបង្កើតជាតារាងពន្ធថេរមួយដែលត្រូវបង់ថ្លៃប្រើប្រាស់អគ្គិសនីដែលកកើតឡើងវិញក្នុងមួយរយៈពេលនៃការសាកល្បង ។

## ផ្នែកទី២
## ថាមពលនុយក្លេអ៊ែរ

**មាត្រា២៧៤** ._ ការគ្រប់គ្រងថាមពលនុយក្លេអ៊ែរ

ថាមពលនុយក្លេអ៊ែរ ត្រូវបង្កើតឡើងដោយស្ថិតនៅក្រោមការគ្រប់គ្រង និង កម្មសិទ្ធិរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាតែមួយប៉ុណ្ណោះ និងដោយមានការគ្រប់គ្រង និងប្រតិបត្តិការតាមស្តង់ដារអន្តរជាតិនៃការការពារផ្នែកសុខភាព សុវត្ថិភាព និងបរិស្ថាន ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពី ថាមពលនុយក្លេអ៊ែរ និងសុវត្ថិភាព ។ លិខិតបទដ្ឋានគតិយុត្តត្រូវរួមមាន លក្ខខណ្ឌតម្រូវសម្រាប់រចនាសម្ព័ន្ធ និងការរៀបចំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់ធ្វើការត្រួតពិនិត្យគម្រោងផលិតថាមពលនុយក្លេអ៊ែរនានា។

រាជរដ្ឋាភិបាល មិនត្រូវទទួលយកសំណល់ថាមពលនុយក្លេអ៊ែរពីប្រទេសដទៃជាដាច់ខាត ទោះបីតាមលក្ខខណ្ឌ ឬកាលៈទេសៈបែបណាក៏ដោយ ។

**មាត្រា២៧៥** ._ ការបណ្តុះបណ្តាល

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យថាមពល អាចរៀបចំកម្មវិធី មួយដើម្បីផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកខ្លួន ដោយសហការជាមួយនឹង អង្គភាពថាមពលអាតូមអន្តរជាតិ ។

## ផ្នែកទី៣
## ការភ្ជាប់ប្រព័ន្ធចែកចាយ និងបណ្តាញតចូល

**មាត្រា២៧៦** ._ លក្ខខណ្ឌតម្រូវនៃប្រសិទ្ធផលនៃប្រព័ន្ធចែកចាយ

គម្រោងបណ្តាញចរន្តនានា ត្រូវប្រើប្រាស់បច្ចេកវិជ្ជាប្រកបដោយប្រសិទ្ធផលនានា ដើម្បីកាត់បន្ថយការបាត់បង់អគ្គិសនី ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបដិសេធចោលលើការឯកភាពទាំងឡាយលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ករណីមិនមានការប្រើប្រាស់បច្ចេកវិជ្ជាប្រកបដោយប្រសិទ្ធផលខ្ពស់បំផុត ដែលមាននៅពេលដាក់ការស្នើសុំ ។ បច្ចេកវិជ្ជាដែលប្រើ ត្រូវតែជាបច្ចេកវិជ្ជាដែលមានលក្ខណៈប្រគួតប្រជែងផ្នែកបរិស្ថាន និងសេដ្ឋកិច្ចដោយធៀបទៅ ទៅនឹងការបាត់បង់ផលអគ្គិសនី ដែលបច្ចេកវិជ្ជានោះជួយបញ្ចៀស ។

**មាត្រា២៧៧** ._ បច្ចេកវិជ្ជាគមនាគមន៍ឌីជីថល

ដើម្បីបើកឲ្យផលិតថាមពលកើតជាថ្មី តភ្ជាប់ទៅកាន់បណ្តាញតចូល និងការប្រើប្រាស់អគ្គិសនីបានពីធនធានប្រកបដោយនិរន្តរភាព និងប្រសិទ្ធផល រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង្កើតបណ្តាញតចូល ដែលប្រើប្រាស់បច្ចេកវិជ្ជាគមនាគមន៍ឌីជីថលដើម្បីតាមដាន និងប្រតិកម្ម ពាក់ព័ន្ធទៅនឹងការ ប្រែប្រួលក្នុងការប្រើប្រាស់ និងការផលិតថាមពល ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង្កើតកម្មវិធីអនុវត្តបច្ចេកវិជ្ជានេះនៅតាមបណ្តាញអគ្គិសនីជាតិ ឲ្យបានឆាប់ទៅតាមតម្រូវការនៃបច្ចេកវិជ្ជា ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវរៀបចំកម្មវិធីសាកល្បងមួយឲ្យបានរួចជាស្រេចដើម្បីអនុវត្តនាពេល ៣ (បី) ឆ្នាំ ក្រោយពីក្រមនេះត្រូវបានអនុម័ត ។

ថ្លៃចំណាយដើម្បីអនុវត្តបច្ចេកវិជ្ជាបណ្តាញតចូល និងនីតិវិធីទាំងឡាយដែលត្រូវអនុវត្ត ត្រូវផ្សព្វផ្សាយដល់ អ្នកប្រើប្រាស់បណ្តាញតចូលទាំងអស់ដោយស្មើភាពគ្នា ។

**មាត្រា២៧៨** ._ ការពង្រីកបណ្តាញតចូល

យោងតាមការពិចារណាផ្នែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចបញ្ឈប់រាល់ការពង្រីកបណ្តាញតចូលទៅកាន់តំបន់ជាក់លាក់ណាមួយក្នុងប្រទេស ។ ក្នុងករណីនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវលើកម្ពស់ និងអនុវត្តកម្មវិធីនានា ដើម្បីផ្តល់បាននូវដំណោះស្រាយបែបវិមជ្ឈការ ដល់ក្រុមគ្រួសារទាំងឡាយ ផ្អែកតាម តាមតម្រូវការរបស់អ្នកប្រើប្រាស់ចុងក្រោយ ទាំងការផលិតថាមពល និងការផលិតអគ្គិសនី ។

**មាត្រា២៧៩** ._ សិទ្ធិទទួលបានព័ត៌មានបរិស្ថាន

អាជ្ញាធរពាក់ព័ន្ធត្រូវចែកចាយជាសាធារណៈនូវព័ត៌មានអំពីវ៉ុល និងគុណភាពអគ្គិសនីដែលបានផ្គត់ផ្គង់ ឬផ្តល់ទៅឲ្យបណ្តាញតចូល ស្របតាមបទបញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ក្នុង

គន្លឹះទី១ មាតិកាទី៣ នៃក្រមនេះ ។ អាជ្ញាធរដែលទទួលបន្ទុក ត្រូវធ្វើការចេញផ្សាយអំពី គុណភាពភ្លើង និងរ៉ុលភ្លើង ដើម្បីការពារការខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធចែកចាយ ឬការអាក់ខានក្នុងការផ្តល់សេវាកម្ម ។

## ជំពូកទី៦
## ប្រសិទ្ធផលថាមពល

**មាត្រា២៨០** ._ ប្រព័ន្ធគ្រប់គ្រងថាមពល និងអគ្គិសនី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យថាមពេល និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តសម្រាប់ប្រព័ន្ធគ្រប់គ្រងថាមពល និងអគ្គិសនី ដោយផ្អែកលើស្តង់ដារនៃគណៈកម្មការបច្ចេកទេសអេឡិចត្រូនិកអន្តរជាតិ និងស្តង់ដារ៥០០០១ នៃអង្គការស្តង់ដារអន្តរជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យថាមពលដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តសម្រាប់ក្រសួង ស្ថាប័នទាំងអស់ស្តីពីការអនុលោមតាមផែនការប្រសិទ្ធផល ព្រមទាំងការអនុវត្តតាមស្តង់ដារនៃគណៈកម្មការបច្ចេកទេសអេឡិចត្រូនិកអន្តរជាតិ និងផែនការ និងគោលនយោបាយប្រសិទ្ធផល និងសម្រាប់ការពង្រឹការអនុវត្តស្តង់ដាគណៈកម្មការបច្ចេកទេសអេឡិចត្រូនិក ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យថាមពល ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ ជាសាធារណៈអំពី វឌ្ឍនភាពនៃប្រសិទ្ធផលថាមពល ដើម្បីធានាឲ្យបាននូវការអនុលោមតាមស្តង់ដារប្រសិទ្ធផលថាមពល ស្របតាមបទបញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាននៃគន្លឹះទី១ មាតិកាទី៣ នៃក្រមនេះ ។

## មាតិកាទី៧
## ឧស្សាហកម្មនិស្សារណកម្មប្រកបដោយការទទួលខុសត្រូវ
## ជំពូកទី១
## វិសាលភាព និងការរៀបចំផែនការបរិស្ថានសម្រាប់ឧស្សាហកម្មនិស្សារណកម្ម

**មាត្រា២៨១** ._ វិសាលភាពនៃការអនុវត្ត

មាតិកានេះអនុវត្តលើធនធានឧស្សាហកម្មនិស្សារណកម្ម រួមមាន ប្រេង ហ្គាស រ៉ែ ដែក វត្ថុធាតុភូគព្ភវិទ្យាផ្សេងៗ ដែលយកចេញពីដី និងពីប្រភពផ្សេងៗទៀត ដែលបង្កើតឡើងដោយឧបករណ៍គតិយុត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

មាតិកានេះអនុវត្តការរុករក ការធ្វើអាជីវកម្ម ការបិទ និងការស្តារនីតិសម្បទា នៃគម្រោងឧស្សាហកម្មនិស្សារណកម្មនៃព្រះរាជាណាចក្រកម្ពុជាដែលមានក្នុងបទបញ្ញត្តិស្តីពីការវាយតម្លៃ និងអង្កេតតាមដានបរិស្ថាននៃគន្ថីទី២ លើកលែងតែមាត្រា២៨៥ និង២៨៦ នៃក្រមនេះ ដែលអនុវត្តនូវរាល់ឧស្សាហកម្មនិស្សារណកម្ម ។

**មាត្រា២៨២** ._ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យរ៉ែ និងថាមពលត្រូវបង្កើតការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រដែលផ្អែកលើវិស័យ សម្រាប់ការរុករក ឬការធ្វើអាជីវកម្មនៃធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់នីមួយៗ ក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមបទប្បញ្ញត្តិក្នុងគន្ថីទី២ មាតិកាទី២ នៃក្រមនេះ ។

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រដែលបង្កើតឡើងក្រោមជំពូកនេះ ត្រូវតម្រូវឲ្យកំណត់អត្តសញ្ញាណ និងផ្តល់នូវក្របខណ្ឌសម្រាប់ម្ចាស់គម្រោងដើម្បីដាក់បញ្ចូលទៅក្នុងដំណាក់កាលទាំងអស់នៃការអភិវឌ្ឍគម្រោង ដូចខាងក្រោម៖

ក- លក្ខខណ្ឌតម្រូវនៃការអភិរក្សជីវចម្រុះ និងទេសភាព

ខ- ការគម្រាមកំហែងចំពោះប្រភេទជិតផុតពូជ ជម្រក និងតម្លៃអភិរក្សប្រព័ន្ធអេកូឡូស៊ី

គ- ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

**មាត្រា២៨៣** ._ការរុករក និងធ្វើអាជីវកម្មដែលមានស្រាប់

សម្រាប់ធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់នីមួយៗដែលការរុករក ឬធ្វើអាជីវកម្មបានកើតឡើងមុនការអនុម័តនៃក្រមនេះ ក្រសួង ស្ថាប័នទទួលបន្ទុករ៉ែត្រូវបញ្ជាប់ និងដាក់ឲ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទបញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ  ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនីមួយ នៅក្នុងរយៈពេល២ (ពីរ) ខែក្រោយការអនុម័តក្រមនេះ ។

**មាត្រា២៨៤** ._ការរុករកនិងការធ្វើអាជីវកម្មថ្មី

សម្រាប់ធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់នីមួយៗដែលការរុករក ឬធ្វើអាជីវកម្មមិនបានកើតឡើងមុននឹងការអនុម័តនៃក្រមនេះ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យរ៉ែ និងថាមពលត្រូវ

បញ្ជាប់ និងដាក់ឲ្យសាធារណជនអាចរកបាននូវការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនីមួយៗស្របតាមបទបញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានក្នុង គន្ថីទី១ មាតិកាទី៣ នៃក្រមនេះ មុននឹង៖

ក- ការឯកភាពលើលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណសម្រាប់ការរុករក ឬការធ្វើអាជីវកម្មនានា ។

ខ- ការចាប់ផ្តើមការរុករក ឬការធ្វើអាជីវកម្ម ។

**មាត្រា២៨៥** ._ ការធ្វើអាជីវកម្មរ៉ែខ្នាតតូច និងធ្វើជាលក្ខណៈសិប្បកម្ម

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីការធ្វើអាជីវកម្មរ៉ែខ្នាតតូច និងធ្វើជាលក្ខណៈសិប្បកម្មដើម្បី៖

ក- ចែងពីសិទ្ធិនៃការធ្វើអាជីវកម្មរ៉ែខ្នាត និងធ្វើជាលក្ខណៈសិប្បកម្មទៅកាន់ប្រជាពលរដ្ឋ ។

ខ- ធានានូវសកម្មភាពនៃការធ្វើអាជីវកម្មរ៉ែខ្នាតតូច និងធ្វើជាលក្ខណៈសិប្បកម្មប្រកបដោយនិរន្តរភាពបរិស្ថាន សុវត្ថិភាព និងប្រសិទ្ធផល ។

គ- ជំរុញ និងអនុវត្តតាមស្តង់ដារ និងការអនុវត្តដ៏ល្អបំផុតជាអន្តរជាតិ ក្នុងការគ្រប់គ្រងការធ្វើអាជីវកម្មរ៉ែខ្នាតតូច និងធ្វើជាលក្ខណៈសិប្បកម្ម ។

ឃ- បង្កើតនូវដំណើរការសម្រាប់កំណត់ ដោយមានកិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន តំបន់សម្រាប់ការធ្វើអាជីវកម្មរ៉ែលក្ខណៈសិប្បកម្ម និង

ង- គម្រូវ និងផ្តល់ជំនួយសម្រាប់អ្នកធ្វើអាជីវកម្មរ៉ែលក្ខណៈសិប្បកម្មក្នុងការបង្កើតនិងអនុវត្ត ផែនការសុវត្ថិភាព និងសន្តិសុខ ។

**មាត្រា២៨៦** ._ តំបន់ហាមឃាត់ចំពោះគម្រោងឧស្សាហកម្មនិស្សារណកម្ម

មិនត្រូវអនុញ្ញាតឲ្យមានគម្រោងឧស្សាហកម្មនិស្សារណកម្មនៅក្នុង៖

១- ដីសាធារណៈរបស់រដ្ឋដែលត្រូវបានកំណត់ជា ទីតាំងវប្បធម៌ ប្រវត្តិសាស្ត្រ ឬបេតិកភណ្ឌជាតិ ។

២- តំបន់ស្នូលឬតំបន់អភិរក្សនៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

៣- តំបន់ដែលតាំងនៅដោយជនជាតិដើមភាគតិច ឬទាក់ទិននឹងការប្រើប្រាស់ជាប្រពៃណីរបស់ជនជាតិដើមភាគតិច លើកលែងតែក្នុងករណីដែលការយល់ព្រមជាមុនដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ត្រូវបានផ្តលជូន ។

៤- ទីតាំងដីសើម ។

៥- ទីតាំង អង្គការសហប្រជាជាតិទទួលបន្ទុកអប់រំ សង្គម វិទ្យាសាស្ត្រ និងវប្បធម៌ ។

៦- សម្រាប់គោលដៅក្នុងមាត្រានេះ តំបន់ណាដែលមានក្នុងបញ្ជីឧបករណ៍គតិយុត្តិថាជាកំណត់ដែលមាន៖

ក- ប្រព័ន្ធអេកូឡូស៊ីទឹកសាប ទឹកសមុទ្រ ឬឆ្នេរសំខាន់ ។

ខ- តម្លៃអភិរក្សទេសភាពខ្ពស់ ជីវៈចម្រុះប្រភេទសត្វនិងរុក្ខជាតិ ឬតម្លៃអភិរក្សប្រព័ន្ធ អេកូឡូស៊ី ។

## ជំពូកទី២
## បច្ចេកវិជ្ជាដ៏ល្អបំផុតដែលអាចស្វែងរកបានសម្រាប់ឧស្សាហកម្មនិស្សារណកម្ម

**មាត្រា២៨៧** ._ ភារកិច្ចក្នុងការបញ្ចៀសការខូចខាតបរិស្ថាន

ម្ចាស់គម្រោងត្រូវតម្រូវឲ្យប្រើប្រាស់បច្ចេកវិជ្ជាដ៏ល្អបំផុតដែលអាចស្វែងរកបាន និងការអនុវត្តល្អៗ ដើម្បីបញ្ចៀសការបង្កឲ្យមានការបំពុល ឬ ការខូចខាតដល់បរិស្ថានដទៃទៀត និងដើម្បីបង្កើនប្រសិទ្ធផលជាអតិបរមា នៅពេលអនុវត្តសកម្មភាពឧស្សាហកម្មនិស្សារណកម្ម ។

**មាត្រា២៨៨** ._ បញ្ជីនៃបច្ចេកវិជ្ជាដ៏ល្អបំផុតដែលអាចស្វែងរកបាន និងការអនុវត្តល្អៗ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យរ៉ែ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរក្សាបញ្ជីនៃបច្ចេកវិជ្ជាដ៏ល្អបំផុតដែលអាចស្វែងរកបាន និងការអនុវត្តល្អៗ សម្រាប់ធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់នីមួយៗ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យរ៉ែ និងថាមពល ត្រូវ៖

ក- ចាប់ផ្តើមចងក្រងនូវបញ្ជីបឋមនៃបច្ចេកវិជ្ជាដ៏ល្អបំផុតដែលអាចស្វែងរកបាន និងចាប់ផ្តើមការពិគ្រោះយោបល់ជាសាធារណៈអំពីបញ្ជីដែលបានស្នើសុំ នៅក្នុងរយៈពេល ១ (មួយ) ខែ ក្រោយអនុម័តនៃក្រមនេះ ។

ខ- បញ្ចប់ និងបោះពុម្ពផ្សាយនូវបញ្ជីនៃ បច្ចេកវិជ្ជាដ៏ល្អបំផុតដែលអាចស្វែងរកបាន និងដាក់ឲ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទបញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី៣ នៅក្នុងរយៈពេល ១៨ (ដប់ប្រាំបី) ខែ នៃការអនុម័តនៃក្រមនេះ ។

**មាត្រា២៨៩** ._ បញ្ជីនៃការធ្វើបច្ចុប្បន្នភាពនៃបញ្ជីបច្ចេកវិជ្ជាដែលល្អបំផុតដែលអាចស្វែងរកបាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យរ៉ែ និងថាមពល ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាពនូវបញ្ជីនៃបច្ចេកវិជ្ជាដ៏ល្អបំផុតដែលអាចស្វែងរកបាន សម្រាប់ធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់នីមួយៗ យ៉ាងហោចណាស់ ជារៀងរាល់២(ពីរ)ឆ្នាំម្តង ។

**មាត្រា២៩០** ._ លក្ខខណ្ឌតម្រូវដើម្បីចៀសវាងការខូចខាតបរិស្ថាន

ស្របតាម បច្ចេកវិជ្ជាដ៏ល្អបំផុតដែលមាននៅក្នុងបញ្ជី ម្ចាស់គម្រោងនៃគម្រោងឧស្សាហកម្មនិស្សារណកម្ម ត្រូវៈ

ក- គ្រប់គ្រងឲ្យបានសមរម្យនូវសំណល់ថ្ម និងសំណល់ផ្សេងទៀត ដើម្បីធានាឲ្យបាននូវស្ថេរភាពខាងផ្នែករចនាសម្ព័ន្ធ ត្រួតពិនិត្យការបញ្ចេញ និងការពារពីផលប៉ះពាល់ដែលអាចកើតឡើង នៃការហូរជាតិអាស៊ីតចេញពីរ៉ែ ការលេចចេញនូវសារធាតុលោហៈ និងការបាត់បង់ការគ្រប់គ្រងកុំឲ្យប៉ះពាល់ដល់បរិស្ថាន ។

ខ- ចៀសវាងពីការសាងសង់អាងស្តុកសំណល់រ៉ែ នៅជិតទន្លេ ឬ សមុទ្រ ដែលមានជម្រៅរាក់ពេក ។

គ- ពិចារណាអំពីការសាងសង់នូវអាងស្តុកសំណល់រ៉ែ ដែលមិនបញ្ចេញសំណល់ទឹករួមបញ្ចូល ការស្តុកទឹកជាអចិន្ត្រៃយ៍ ក្រោយពីការបញ្ចប់គម្រោង ។

## ជំពូកទី៣
## ការប្រើប្រាស់ ស្យានីត និងបារ៉ត នៅក្នុងការធ្វើអាជីវកម្មរ៉ែមាស និងប្រាក់

**មាត្រា២៩១** ._ ការចេញវិញ្ញាបនបត្រសុវត្ថិភាពស្យានីត និងបារ៉ត

ម្ចាស់គម្រោងនៃគម្រោងអាជីវកម្មរ៉ែមាស និងប្រាក់ ត្រូវតម្រូវផ្តល់ឯកសារ ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានដើម្បីបញ្ជាក់ថា ស្យានីត និងបារ៉ត ដែលត្រូវប្រើប្រាស់នៅក្នុងប្រតិបត្តិការនៃការធ្វើអាជីវកម្មរ៉ែមាស និងប្រាក់ ត្រូវបានជាវនៅក្នុងលក្ខណៈដែលមានសុវត្ថិភាព និងមិនប៉ះពាល់ដល់បរិស្ថាន ។

**មាត្រា២៩២** ._ ការទទួលខុសត្រូវ

កិច្ចព្រមព្រៀងទិញលក់ ឬ កិច្ចព្រមព្រៀងដទៃទៀត និងការរៀបចំរវាងអ្នកផលិត អ្នកចែកចាយ អ្នកដឹកជញ្ជូន ប្រតិបត្តិករ ឬ ម្ចាស់គម្រោង ត្រូវបង្កើតការទទួលខុសត្រូវ និងបែងចែកភាពទទួលខុសត្រូវ ដែលទាក់ទងនឹងសុវត្ថិភាព សន្តិសុខ ការទប់ស្កាត់ការបញ្ចេញ ការបណ្តុះបណ្តាល និងការ

ឆ្លើយតបចំពោះភាពអាសន្ន ទាក់ទងនឹងការប្រើប្រាស់ ស្យានីត និងបារ៉ត នៅក្នុងគម្រោងអាជីវកម្មរ៉ែមាស និងប្រាក់ ។

**មាត្រា២៩៣** ._ លក្ខខណ្ឌតម្រូវសម្រាប់ការប្រើប្រាស់ស្យានីត និងបារ៉ត

សម្រាប់ ស្យានីត និងបារ៉ត ដែលត្រូវប្រើប្រាស់នៅក្នុងគម្រោងអាជីវកម្មរ៉ែមាស និងប្រាក់ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធានាថា កន្លែងដែលរក្សាទុកសារធាតុទាំងនេះ គឺស្របតាមក្រមស្ដីពីការគ្រប់គ្រង ស្យានីត អន្តរជាតិ និងគោរពតាមលក្ខខណ្ឌតម្រូវ ដូចខាងក្រោម៖

ក- ការដាក់ចុះ ការធ្វើសន្និធិ និងឧបករណ៍សម្រាប់លាយ ត្រូវបានរចនា និងធ្វើប្រតិបត្តិការ ស្របតាមការអនុវត្តផ្នែកវិស្វកម្មដែលត្រឹមត្រូវ និងទទួលយកបាន ក៏ដូចជា ការត្រួតពិនិត្យគុណភាព និងនីតិវិធីនៃការធានាគុណភាព និងវិធានការការពារការបញ្ចេញ និង វិធានការទប់ទល់ ។

ខ- ការដាក់ចុះ ការធ្វើសន្និធិ និងឧបករណ៍សម្រាប់លាយ ត្រូវបានធ្វើប្រតិបត្តិការដោយប្រើប្រាស់ការធ្វើអធិការកិច្ច ការថែទាំដែលមានការការពារ និងផែនការបម្រុងទុកជាមុនដើម្បីការពារ និងទប់មិនឲ្យរាលដាលនូវការបញ្ចេញ និងត្រួតពិនិត្យ និងឆ្លើយតបចំពោះភាពងាយរងគ្រោះរបស់កម្មករ ។

គ- ឧបករណ៍ ស្យានីត និងបារ៉ត ត្រូវបានធ្វើប្រតិបត្តិការ និងអង្កេតតាមដាន ដើម្បីការពារសុខភាព និងសុវត្ថិភាពកម្មករ ហើយប្រសិទ្ធភាពនៃវិធានការសុខភាព និងសុវត្ថិភាពត្រូវបានវាយតម្លៃជាប្រចាំ ។

ឃ- ប្រព័ន្ធគ្រប់គ្រង និងប្រតិបត្តិការ ត្រូវបានរចនា និងអនុវត្ត ដើម្បីការពារសុខភាពមនុស្ស និងបរិស្ថាន រួមមាន ផែនការជាយថាភាព និងផែនការអធិការកិច្ច និងនីតិវិធីថែទាំតាមលក្ខណៈការពារ ។

ង- កម្មវិធីគ្រប់គ្រងទឹកលក្ខណៈគ្រប់ជ្រុងជ្រោយ ត្រូវអនុវត្តដើម្បីការពារពីការបញ្ចេញដោយគ្មានចេតនា ។

ច- វិធានការក្នុងការការពារប្រភេទសត្វ និងរុក្ខជាតិ ពីផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងនៃដំណើរការ ស្យានីត និងបារ៉ត ត្រូវបានអនុវត្ត ។

ឆ- វិធានការក្នុងការការពារប្រភេទសត្វ និងរុក្ខជាតិពីការបញ្ចេញចោលដោយផ្ទាល់ និងប្រយោល នៃដំណើរការ ស្យានីត និងបារ៉ត ត្រូវទៅក្នុងទឹកលើដី ត្រូវបានអនុវត្ត ។

ជ- កម្មវិធីអង្កេតតាមដាន ដើម្បីវាយតម្លៃផលប៉ះពាល់នៃការប្រើប្រាស់ ស្យានីត និងបារ៉ត លើប្រភេទសត្វ និងរុក្ខជាតិ និងគុណភាពទឹកលើដីនិងក្រោមដី ត្រូវបានអនុវត្ត ។

ឈ- ផែនការ និងនីតិវិធីឆ្លើយតបចំពោះគ្រោះបន្ទាន់ ដើម្បីឆ្លើយតបចំពោះភាពងាយរងគ្រោះរបស់កម្មករចំពោះ ស្យានីត និងបារ៉ែត ត្រូវបានបង្កើត និងអនុវត្ត ។

ញ- នីតិវិធីសម្រាប់ការជូនដំណឹងបន្ទាន់ផ្ទៃក្នុង និងខាងក្រៅ និងការរាយការណ៍ ត្រូវបានអនុវត្ត ។

ដ- ការចូលរួមពេញលេញរបស់អ្នកពាក់ព័ន្ធត្រូវបានអនុវត្ត សម្រាប់សហគមន៍ ដើម្បីធ្វើការប្រាស្រ័យទាក់ទងអំពីបញ្ហានានានៃការបារម្ភ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈក្នុងគន្ថីទី១ មាតិកាទី២ នៃក្រមនេះ ។

ឋ- ព័ត៌មានស្តីពីប្រតិបត្តិការ និងព័ត៌មានបរិស្ថានដែលសមរម្យ ទាក់ទងនឹងការគ្រប់គ្រង ស្យានីត និងបារ៉ែត ត្រូវដាក់ឲ្យអ្នកពាក់ព័ន្ធអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីការទទួលបានព័ត៌មានបរិស្ថាន ក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

## ជំពូកទី៤
## ការលាតត្រដាងព័ត៌មាន

**មាត្រា២៩៤** ._ ព័ត៌មានដែលអាចអនុវត្តបាន

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធានាថា ព័ត៌មានលម្អិតនៃគម្រោងឧស្សាហកម្មនិស្សារណកម្មនីមួយៗ រួមបញ្ចូល ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រដែលអាចអនុវត្តបានទាំងអស់ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ផែនការគ្រប់គ្រងបរិស្ថានសវនកម្មផ្នែកបរិស្ថាន របាយការណ៍អង្កេតតាមដានបរិស្ថាន និងកិច្ចព្រមព្រៀងដទៃទៀតរវាងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងម្ចាស់គម្រោង ត្រូវបានដាក់ឲ្យសាធារណជនអាចស្វែងរកបានស្របតាមបទបញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ និងត្រូវផ្តល់ព័ត៌មានជូនសហគមន៍ និងអ្នកមានលំនៅដ្ឋានអចិន្ត្រៃយ៍ នៅក្នុងលក្ខណៈមួយដែលងាយយល់ និងនៅក្នុងភាសា និងទម្រង់ដែលសមរម្យ ។

**មាត្រា២៩៥** ._ ការដាក់កំហិតលើភាពសម្ងាត់

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធានាថា គ្មានទិន្នន័យណាមួយទាក់ទងនឹងគម្រោងឧស្សាហកម្មនិស្សារណកម្ម ត្រូវចាត់ទុកថាសម្ងាត់ ប្រសិនបើវាទាក់ទងទៅនឹងសុខភាពមនុស្ស ឬ បរិស្ថាន ស្របតាមបទប្បញ្ញត្តិស្តីពីការទទួលបានព័ត៌មានបរិស្ថាន ក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

# គន្ថីទី៤
# ការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃធនធានធម្មជាតិ
## មាតិកាទី១
## របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ
### ជំពូកទី១
### នីតិវិធីនៃការបង្កើត និងការលុបចោលចំណាត់ថ្នាក់

**មាត្រា២៩៦** ._ គោលដៅនៃរបៀងអភិរក្សជីវៈចម្រុះ

របៀងអភិរក្សជីវៈចម្រុះ សំដៅដល់តំបន់ការពារទេសភាពទាំងឡាយដូចបានកំណត់ជាពិសេស ដែលក្នុងនោះ មានទៅដោយតំបន់ការពារធម្មជាតិ ដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងតំបន់ដទៃទៀត ដែលមានសារៈសំខាន់ផ្នែកអភិរក្សធនធានធម្មជាតិ សេវាកម្មប្រព័ន្ធអេកូឡូស៊ី ឬតម្លៃសហគមន៍មូលដ្ឋាន និងតម្លៃនៃជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច និងដីដទៃទៀត ដែលមានតួនាទីយ៉ាងសំខាន់នៅក្នុងការការពារគម្របព្រៃឈើ ឬដែលផ្តល់នូវទំនាក់ទំនងរវាងតំបន់ជីវៈចម្រុះសំខាន់ៗ ។

របៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបង្កើត និងគ្រប់គ្រង ដើម្បីធានាឲ្យបាននូវនិរន្តរភាពនៃជីវៈចម្រុះ សេវាកម្មប្រព័ន្ធអេកូឡូស៊ីធនធានធម្មជាតិនិងវប្បធម៌ និងជីវភាពមូលដ្ឋានប្រកបដោយនិរន្តរភាព នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២៩៧** ._ ការទទួលខុសត្រូវចំពោះរបៀងអភិរក្សជីវៈចម្រុះ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវទទួលបន្ទុកក្នុងការកំណត់តំបន់នានាដែលត្រូវគ្រប់គ្រងជារបៀងអភិរក្សជីវៈចម្រុះ ឬតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ដោយថ្នាក់ជាតិ ។ ការបង្កើតថ្មីនូវរបៀងអភិរក្សជីវៈចម្រុះ ឬតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬការពង្រីកនូវព្រំប្រទល់នៃរបៀងអភិរក្សជីវៈចម្រុះ ឬតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ដោយថ្នាក់ជាតិ ដែលមានស្រាប់ ត្រូវធ្វើឡើងដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

អាជ្ញាធរថ្នាក់ក្រោមជាតិពាក់ព័ន្ធទទួលខុសត្រូវក្នុងការកំណត់ ឬបង្កើតតំបន់ការពារធម្មជាតិដទៃទៀត នៅថ្នាក់ក្រោមជាតិ តាមការសមរម្យ ។ ការបង្កើតនូវតំបន់ការពារធម្មជាតិថ្មី នៅថ្នាក់ក្រោមជាតិ ឬការពង្រីកនូវព្រំប្រទល់នៃតំបន់ការពារធម្មជាតិដែលមានស្រាប់ ត្រូវធ្វើឡើងដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

សេចក្តីសម្រេចណាមួយក្នុងការបង្កើត ឬពង្រីករបៀងអភិរក្សជីវៈចម្រុះ ឬតំបន់ការពារធម្មជាតិ ដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុងគន្ថីទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា២៩៨ .**_ ការលុបចោលចំណាត់ថ្នាក់នៃរបៀងអភិរក្សជីវៈចម្រុះ

ការលុបចោលចំណាត់ថ្នាក់ ឬការកាត់បន្ថយ ទាំងអស់ ឬផ្នែកណាមួយ នៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានរក្សាទុកសម្រាប់តែកាលៈទេសៈណា ដែលការអភិរក្សជីវៈចម្រុះ និងតម្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីនៃតំបន់នោះត្រូវបានកាត់បន្ថយដល់កម្រិតដែលថាការស្តារឡើងវិញគឺមិនអាចធ្វើទៅបាន ។

ការលុបចេញពីចំណាត់ថ្នាក់នៃផ្នែកទាំងអស់ ឬផ្នែកណាមួយនៃ របៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ត្រូវធ្វើឡើងដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ បន្ទាប់ពីបានទទួលអនុសាសន៍ពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងគណៈកម្មការជាតិស្តីពីជីវៈចម្រុះ ដែលស្ថិតនៅក្រោមក្រុមក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាពក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព។

ការលុបចេញពីចំណាត់ថ្នាក់នៃផ្នែកទាំងអស់ ឬផ្នែកណាមួយនៃតំបន់ការពារធម្មជាតិដែលត្រូវបានបង្កើតឡើងដោយថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងដោយលិខិតបទដ្ឋានគតិយុត្ត បន្ទាប់ពីបានទទួលអនុសាសន៍ពីមន្ទីរបរិស្ថានខេត្ត និងគណៈកម្មការជាតិស្តីពីជីវៈចម្រុះ ដែលស្ថិតនៅក្រោមក្រុមក្រសួងស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព។

សេចក្តីសម្រេចណាមួយដែលលុបចោលចំណាត់ថ្នាក់ ឬកាត់បន្ថយរបៀងអភិរក្សជីវៈចម្រុះ ឬតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុងគន្ថីទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា២៩៩ .**_ ការកំណត់ជាពិសេសនៃទីតាំង ឬតំបន់

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអាចបង្កើត កែសម្រួល ឬចាត់វិធានការផ្សេងទៀតដែលចាំបាច់នៅក្នុងតំបន់ណាមួយ ដែលមានសារៈសំខាន់ថ្នាក់ជាតិ ឬអន្តរជាតិ ដើម្បីកំណត់ថាជាទីតាំងបេតិកភណ្ឌថ្នាក់តំបន់ ឬពិភពលោក តំបន់រ៉ាមសារ ឬបបនីយជីវមណ្ឌល នៅក្នុងករណីដែលតំបន់នោះឆ្លើយតបចំពោះលក្ខណៈវិនិច្ឆ័យ ដែលមានចែងនៅក្នុងអនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិទាំងនោះ។

តំបន់ណាមួយដែលត្រូវបានកំណត់រួចហើយជាតំបន់បេតិកភណ្ឌថ្នាក់តំបន់ ឬពិភពលោក តំបន់រ៉ាមសារ ឬបបនីយជីវមណ្ឌល ត្រូវតម្រូវឱ្យមានអន្តរាគមន៍ពីសំណាក់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាថា ការគ្រប់គ្រង និងអភិរក្សតំបន់ទាំងនេះ ស្របតាមនីតិវិធី និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ។

តំបន់ទាំងនេះ ដែលត្រូវបានទទួលស្គាល់ដោយសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

## ជំពូកទី២
## ការគ្រប់គ្រង ការប្រើប្រាស់ និងលក្ខខណ្ឌតម្រូវផ្សេងទៀត

**មាត្រា៣០០** ._ ការរៀបចំផែនការ ការកំណត់តំបន់គ្រប់គ្រង និងលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការគ្រប់គ្រង

របៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ ក្រោមជាតិទាំងអស់ ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដីធ្លី ការកំណត់តំបន់គ្រប់គ្រង និងផែនការគ្រប់គ្រង នៃមាតិកាទី២ ស្តីពីការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិនៃគន្ថីនេះ ។

ការរៀបចំផែនការប្រើប្រាស់ដីធ្លី ការកំណត់តំបន់គ្រប់គ្រង និងការរៀបចំផែនការគ្រប់គ្រង ដែលមានមុនពេលអនុម័តក្រមនេះ ត្រូវបានបញ្ចប់សម្រាប់របៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ដោយថ្នាក់ជាតិ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ត្រូវបន្តមានសុពលភាព និងត្រូវចាត់ទុកថាស្របតាមបទប្បញ្ញត្តិនានានៃក្រមនេះ ។

ការរៀបចំផែនការប្រើប្រាស់ដីធ្លី ការកំណត់តំបន់គ្រប់គ្រង និងការរៀបចំផែនការគ្រប់គ្រង ដែលមានមុនពេលអនុម័តក្រមនេះ កំពុងតែស្ថិតក្នុងដំណើរការ សម្រាប់របៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ត្រូវបន្តដាក់បញ្ចូលនូវលក្ខខណ្ឌតម្រូវនានានៃក្រមនេះ ។

តំបន់នានាដែលស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ដោយថ្នាក់ជាតិ ដែលត្រូវធ្វើការគ្រប់គ្រងរួមគ្នា ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីការរៀបចំផែនការប្រើប្រាស់ដីធ្លី ការកំណត់តំបន់គ្រប់គ្រង និងការរៀបចំផែនការគ្រប់គ្រង នៃមាតិកាទី៣ ស្តីពីការគ្រប់គ្រងរួមគ្នានៃធនធានធម្មជាតិនៃគន្ថីនេះ ។

**មាត្រា៣០១** ._ ការហាមឃាត់ចំពោះសកម្មភាពពាណិជ្ជកម្ម ឬអភិវឌ្ឍ

គ្មានសកម្មភាពពាណិជ្ជកម្ម ឬអភិវឌ្ឍណាមួយ អាចកើតមានឡើងក្នុងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ នោះឡើយ រហូតដល់ពេលដែលការរៀបចំផែនការប្រើប្រាស់ដីធ្លី ការកំណត់តំបន់គ្រប់គ្រង និងដំណើរការគ្រប់គ្រង ដែលមានចែងក្នុងមាតិកាទី២ស្តីពីការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ និងមាតិកាទី៣ ស្តីពីការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិនៃគន្ថីនេះ ត្រូវបានបំពេញ លើកលែងតែមានចែងច្បាស់លាស់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ។

ការចេញនូវលិខិតបទដ្ឋានគតិយុត្តដូចមានចែងក្នុងកថាខណ្ឌខាងលើនេះត្រូវធ្វើឡើងបន្ទាប់ពីមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់សកម្មភាពពាណិជ្ជកម្ម ឬសកម្មភាពអភិវឌ្ឍស្នើសុំ ហើយត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុងគន្ថីទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

## ជំពូកទី៣
## របៀងអភិរក្សជីវៈចម្រុះថ្មី និងឋានៈនៃតំបន់ការពារធម្មជាតិបច្ចុប្បន្ន

**មាត្រា៣០២** ._ ការបង្កើតរបៀងអភិរក្សជីវៈចម្រុះ

ត្រូវបង្កើតរបៀងអភិរក្សជីវៈចម្រុះ ។ ការបង្កើតរបៀងអភិរក្សជីវៈចម្រុះ ត្រូវបង្កើតដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា៣០៣** ._ ភាពបន្តនៃតំបន់ការពារធម្មជាតិ

តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ដែលត្រូវបានបង្កើតឡើងស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ត្រូវបន្តរក្សាឋានៈផ្លូវច្បាប់ពេញលេញជាតំបន់ការពារធម្មជាតិដូចក្នុងពេលបច្ចុប្បន្ន ពាក់ព័ន្ធទៅនឹងការការពារ ព្រំប្រទល់ និងការរៀបចំសម្រាប់ការគ្រប់គ្រង ។

ផែនការប្រើប្រាសដី  ការកំណត់តំបន់គ្រប់គ្រង និងការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ អាចត្រូវអនុវត្តដូចតទៅ៖

១- អាចធ្វើឡើងដាច់ដោយឡែកពីគ្នាទៅតាមតំបន់ ។

២- អាចធ្វើឡើងក្នុងដំណើរការរួមដែលអនុវត្តចំពោះរបៀងអភិរក្សជីវៈចម្រុះទាំងមូល។

៣- អនុវត្តទាំងពីរ ។

គ- អាចធ្វើឡើងតាមដំណើរនៃការគ្រប់គ្រងរួមគ្នាសម្រាប់តំបន់នោះ ។

## មាតិកាទី២
## ការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៣០៤**._ វិសាលភាព

មាតិកានេះកំណត់ពីក្របខ័ណ្ឌនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍគ្រប់របៀងអភិរក្សជីវៈចម្រុះ និងគ្រប់តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតឡើងដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការធ្វើចំណាត់ថ្នាក់បន្តបន្ទាប់ អនុតំបន់ និងគ្រប់តំបន់នានាទៀតដែលស្ថិតនៅក្រោមការធ្វើចំណាត់ថ្នាក់នៃការប្រើប្រាស់ដី និងប្រភេទតំបន់នានាដែលស្ថិតនៅក្នុងតំបន់ទាំងនេះ។ មាតិកានេះក៏អនុវត្តចំពោះតំបន់បំរុងទុកធម្មជាតិទាំងឡាយណាដែលបានកំណត់ជាពិសេស តំបន់អភិរក្សប្រភេទសត្វ និងរុក្ខជាតិ តំបន់អភិរក្សជីវមណ្ឌល និងតំបន់អភិរក្សទឹកសាប តំបន់អភិរក្សទឹកសមុទ្រ និងតំបន់អភិរក្សដីគោគដែលត្រូវបង្កើត ។

មាតិកានេះ អនុវត្តចំពោះការគ្រប់គ្រងរួមគ្នា សម្រាប់តំបន់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងរួមគ្នា ដែលមានចែងនៅក្នុងមាតិកាទី៣ គន្ថីទី៤ នៃក្រមនេះ ។

មាតិកានេះ អនុវត្តចំពោះការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព សម្រាប់តំបន់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព ដែលមានចែងនៅក្នុងមាតិកាទី៤ គន្ថីទី៤ នៃក្រមនេះ ។

**មាត្រា៣០៥**._ គោលបំណងនៃរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ

គ្រប់របៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងអស់ ត្រូវគ្រប់គ្រងស្របតាមគោលបំណងដូចខាងក្រោម៖

ក- អភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងសត្វព្រៃ ។

ខ- អភិរក្សតម្លៃប្រព័ន្ធអេកូឡូស៊ី ទំនិញ និងសេវាកម្ម ។

គ- អភិវឌ្ឍជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ។

**មាត្រា៣០៦**._ ផែនការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ

របៀងអភិរក្សជីវៈចម្រុះនីមួយៗត្រូវអនុលោមតាមផែនការមេស្តីពីការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ ។ ផែនការគ្រប់គ្រងតូចៗ ដែលមានលក្ខណៈជាក់លាក់តាមតំបន់ នៅក្នុងរបៀងអភិរក្សជីវៈ

ចម្រុះណាមួយ អាចត្រូវបានបង្កើត ឬធ្វើឲ្យប្រសើរឡើងនូវភាពអាចអនុវត្តបាន ដោយផ្អែកលើមូលដ្ឋាននៃទីតាំងជាក់លាក់ និងស្របតាមតំបន់ការពារធម្មជាតិ និងការកំណត់អំពីការគ្រប់គ្រងរួមគ្នា ។

តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិទាំងឡាយណាដែលស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ អាចត្រូវអនុលោមតាមផែនការគ្រប់គ្រងដាច់ដោយឡែកនីមួយៗ បន្ថែមលើផែនការមេស្តីពីការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ ។

ផែនការគ្រប់គ្រងដាច់ដោយឡែកនីមួយៗនេះ ត្រូវដាក់បញ្ចូលទៅក្នុងផែនការមេស្តីពីការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ ។ ផែនការគ្រប់គ្រងដាច់ដោយឡែកនីមួយៗដែលមានរួចទៅហើយនៅមុនពេលអនុម័តក្រមនេះ ត្រូវបន្តមានប្រសិទ្ធភាពអនុវត្ត និងមានលក្ខណៈសម្បត្តិសម្រាប់ការដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ ។

តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងឡាយណា ដែលមិនស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ ឬតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ត្រូវអនុលោមតាមផែនការគ្រប់គ្រងដាច់ដោយឡែកនីមួយៗ ។

**មាត្រា៣០៧** ._ ការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ

គ្រប់របៀងអភិរក្សជីវៈចម្រុះ ឬតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានសិទ្ធិទទួលបានការគ្រប់គ្រងរួមគ្នាស្របតាមមាតិកាទី៣ស្តីពីការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិនៃគន្ថីនេះ រហូតដល់ពេលដែលការគ្រប់គ្រងរួមគ្នាត្រូវបានបង្កើតនៅក្នុងផ្នែកណាមួយនៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវគ្រប់គ្រងស្របតាមមាតិកានេះ ។

តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិទាំងឡាយណា ដែលមិនមែនជាកម្មវត្ថុនៃការគ្រប់គ្រងរួមគ្នា ត្រូវបន្តគ្រប់គ្រងស្របតាមមាតិកានេះ ។

## ជំពូកទី២
## ក្រសួង ស្ថាប័នទទួលខុសត្រូវ

**មាត្រា៣០៨** ._ ការទទួលខុសត្រូវ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ

ការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាជ្ញាធរអាជ្ញាធរថ្នាក់ក្រោមជាតិ និងស្ថាប័នដទៃទៀតដូចមានចែងក្នុងបទប្បញ្ញត្តិនៅក្នុងមាតិកាទី៣ នៃគន្ថីនេះ ។

ការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវធានានូវសិទ្ធិរបស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងសាធារណជនក្នុងការៈ

ក- ទទួលបាននូវការពិគ្រោះយោបល់ និងការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រង និងការអភិវឌ្ឍផ្នែកជីវៈចម្រុះប្រកបដោយនិរន្តរភាព ។

ខ- ផ្តល់ការយល់ព្រម ស្របតាមគោលការណ៍យល់ព្រមជាមុន ដោយសេរី បន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ តាមលក្ខខណ្ឌតម្រូវនៃក្រមនេះ ។

គ- ចូលរួមពេញលេញក្នុងការរៀបចំផែនការ ការប្រើប្រាស់ និងការគ្រប់គ្រងប្រកបដោយនិរន្តរភាពលើតំបន់ទាំងនេះ ។

ឃ- ធានាបាននូវការទទួលបានប្រកបដោយយុត្តិធម៌ និងស្មើភាពគ្នា សម្រាប់អ្នកប្រើប្រាស់ធនធានមូលដ្ឋាន ឲ្យស្របតាមការធ្វើចំណាត់ថ្នាក់ និងការដាក់កម្រិតនៃការបែងចែកតំបន់គ្រប់គ្រង ។

នៅក្នុងករណីដែលជនជាតិដើមភាគតិចមានវត្តមាននៅក្នុងតំបន់នោះ ឬមានទំនាក់ទំនង ឬផលប្រយោជន៍សម្ភហភាពនៅក្នុងតំបន់នោះ នីតិវិធីពិសេស ដែលមានលក្ខណៈខុសគ្នានៃការពិគ្រោះយោបល់ ត្រូវអនុវត្ត ដើម្បីធានាថាសិទ្ធិ និងផលប្រយោជន៍របស់ពួកគាត់ រួមបញ្ចូលសិទ្ធិតាមបែបប្រពៃណី ទំនៀមទម្លាប់ ត្រូវបានដោះស្រាយ និងគោរពឲ្យបានត្រឹមត្រូវ ។ សកម្មភាពគ្រប់គ្រង និងអភិរក្សដែលធ្វើឡើងនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដទៃទៀតដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដូចខាងក្រោមៈ

១- បទប្បញ្ញត្តិនេះ ត្រូវអនុវត្តចំពោះរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំងអស់ រហូតដល់ពេលការគ្រប់គ្រងរួមគ្នាត្រូវបានបង្កើតនៅក្នុងផ្នែកណាមួយនៃតំបន់ទាំងនេះ និងត្រូវគ្រប់គ្រងស្របតាមមាតិកាទី៣ស្តីពីការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិនៃគន្ថីនេះ។ រាល់ការរៀបចំផែនការប្រើប្រាស់ដីធ្លី ការកំណត់តំបន់គ្រប់គ្រង និងការរៀបចំផែនការគ្រប់គ្រង ដែលបានធ្វើឡើងស្របតាមមាតិកានេះហើយ នោះត្រូវអនុវត្តតាមលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ដែលមានសម្រាប់តំបន់ទាំងនេះ។

២- របៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឬផ្នែកណាមួយនៃតំបន់ទាំងនេះ ដែលមិនមែនជាកម្មវត្ថុនៃការគ្រប់គ្រងរួមគ្នា ត្រូវបន្តគ្រប់គ្រងស្របតាមអាជ្ញាធរថ្នាក់ក្រោមជាតិមាតិកានេះ។

**មាត្រា៣០៩** ._ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន

នៅក្នុងការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវបំពេញការទទួលខុសត្រូវដូចខាងក្រោម៖

ក- ផ្តល់នូវក្របខ័ណ្ឌទូទៅ ត្រួតពិនិត្យ និងគ្រប់គ្រង និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសទៅដល់ដំណើរការទូទៅ សម្រាប់ការអភិវឌ្ឍ និងការអនុវត្ត ការរៀបចំផែនការប្រើប្រាស់ដី ការកំណត់តំបន់គ្រប់គ្រង ការធ្វើចំណាត់ថ្នាក់ និងការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ។

ខ- ធានាឲ្យបាននូវការអង្កេតតាមដាន និងការត្រួតពិនិត្យលើការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ។

គ- បង្កើតយន្តការហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពសម្រាប់របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ស្របតាមយន្តការហិរញ្ញប្បទានប្រកបដោយនិរន្តរភាព គន្ថីទី៨ នៃក្រមនេះ ។

ឃ- ត្រួតពិនិត្យ និងផ្តល់ការគាំទ្រដល់ដំណើរការនៃការបញ្ចូលសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍នេសាទ តំបន់មូលដ្ឋាន និងតំបន់ដែលមានការទទួលស្គាល់ជាលក្ខណៈប្រពៃណី ចូលទៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ជាទូទៅ ។

ង- ដឹកនាំ និងគាំទ្រដល់ការឃាមល្បាត ការអង្កេតតាមដាន ការស៊ើបអង្កេត និងការពង្រឹងការអនុវត្ត នៅក្នុងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ។

ច- អនុវត្តការងារផ្នែកបច្ចេកទេស ក្នុង ការសិក្សា ការស្រាវជ្រាវ ការរៀបចំរបាយការណ៍ និងការលើកកម្ពស់ការយល់ដឹងទៅតាមការតម្រូវ ដើម្បីលើកកម្ពស់ការគ្រប់គ្រងប្រកបដោយនិរន្តរភាព និងការអភិរក្សរយៈពេលវែងនៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ។

**មាត្រា៣១០** ._ សិទ្ធិរបស់មន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន

នៅក្នុងការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ មន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន មានសិទ្ធិ និងការទទួលខុសត្រូវដូចខាងក្រោម៖

ក- អនុវត្តជាប្រចាំនូវការឃាមល្បាត ការអង្កេតតាមដាន ការស៊ើបអង្កេត និងសកម្មភាពពង្រឹងការអនុវត្តគ្រប់ប្រភេទ ។

ខ- ធ្វើអធិការកិច្ច និងចេញអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងឯកសារពាក់ព័ន្ធដទៃទៀត ។

គ- ចាត់វិធានការក្នុងការទប់ស្កាត់ និងត្រួតពិនិត្យភ្លើងឆេះព្រៃ ។

ឃ- ត្រួតពិនិត្យការនាំចេញ នាំចូលនូវពពួកសត្វ រុក្ខជាតិ គ្រាប់ពូជ និងសំណាកនានា ចេញពី ឬចូលទៅក្នុងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ។

ង- លើកកម្ពស់ការអប់រំ និងការផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន និងសម្របសម្រួលជាមួយសហគមន៍ជនជាតិដើមភាគតិចមូលដ្ឋាន ។

ច- អនុវត្តតួនាទីក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

ឆ- អនុវត្តការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា ទាក់ទងនឹងការបង្កើត និងការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ។

ជ- អនុលោមតាមកាតព្វកិច្ចទាក់ទងនឹងការទទួលបានហិរញ្ញប្បទានរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ។

ឈ- សហការជាមួយសហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូបច្ចេកទេសពាក់ព័ន្ធ ដែលមានបទពិសោធផ្នែកស្រាវជ្រាវ ការការពារ និងការអភិរក្សធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអង្គការអភិរក្សពាក់ព័ន្ធនៅក្នុងការអភិរក្សនៃតំបន់នានា និងអ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ ដើម្បីបង្កើតការគ្រប់គ្រងរួមគ្នាលើតំបន់ទាំងនេះ ដូចមានចែងក្នុងមាតិកាទី៣ ស្តីពីការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិនៃគន្ថីនេះ ។

ញ- សិទ្ធិលម្អិតផ្សេងទៀត និងភារកិច្ច ដូចមានចែងក្នុងក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត ។

**មាត្រា៣១១** ._ ការទទួលខុសត្រូវរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ

អាជ្ញាធរថ្នាក់ក្រោមជាតិដទៃទៀត ត្រូវមានតួនាទី និងការទទួលខុសត្រូវ ដូចខាងក្រោម៖

ក- គាំទ្រដល់នាយករបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងភាគីពាក់ព័ន្ធដទៃទៀត នៅក្នុងការបង្កើតផែនការប្រើប្រាស់ដី ការធ្វើចំណាត់ថ្នាក់តំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងដាច់ដោយឡែក សម្រាប់របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ។

ខ- សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់សម្រាប់ការអនុវត្តនូវសកម្មភាពនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលរួមបញ្ចូលតំបន់ការពារធម្មជាតិសហគមន៍ សហគមន៍ព្រៃឈើ ការចេញប័ណ្ណកម្មសិទ្ធិដីធ្លី ការកំណត់តំបន់គ្រប់គ្រង ការអង្កេតតាមដាន និងការស្រាវជ្រាវជីវៈចម្រុះ ទេសចរណ៍ធម្មជាតិ និងការអប់រំ ព្រមទាំងការចាប់ខ្លួន និងការចោទប្រកាន់លើបុគ្គលដែលអនុវត្តសកម្មភាពខុសច្បាប់ ។

គ- ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ទាក់ទងនឹងការអភិរក្ស និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដោយសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធមូលដ្ឋាន ។

ឃ- ធ្វើអធិការកិច្ចលើអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងឯកសារពាក់ព័ន្ធដទៃទៀត ទាក់ទងនឹងរបៀងអភិរក្សជីវៈចម្រុះ ឬតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ដោយថ្នាក់ជាតិ និងចូលរួមនៅក្នុងសកម្មភាពនៃការពង្រឹងការអនុវត្តច្បាប់ទាំងអស់ ទាក់ទងនឹងបរិស្ថាន និងបញ្ហាអភិរក្សធនធានធម្មជាតិ ។

ង- ចេញអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬឯកសារពាក់ព័ន្ធដទៃទៀត ទាក់ទងនឹងតំបន់ការពារធម្មជាតិ ដែលត្រូវបានកំណត់ ឬបង្កើតឡើងដោយថ្នាក់ក្រោមជាតិ ។

ច- អនុវត្តជាប្រចាំនូវការយាមល្បាត ការអង្កេតតាមដាន ការស៊ើបអង្កេត និងសកម្មភាពគ្រប់ប្រភេទនៃការពង្រឹងការអនុវត្តច្បាប់ ។

ឆ- សហការជាមួយសហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច ស្ថាប័នថ្នាក់ជាតិ ដៃគូបច្ចេកទេសពាក់ព័ន្ធផ្នែកស្រាវជ្រាវ ការការពារ និងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងភាគីពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ ដើម្បីបង្កើតការគ្រប់គ្រងរួមគ្នាលើតំបន់ទាំងនេះ ដូចមានចែងក្នុងមាតិកាទី៣ ស្តីពីការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិនៃគន្លឹះនេះ ។

ជ- ធ្វើសកម្មភាពផ្សេងទៀត ដែលអាចត្រូវបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត ដែលពិពណ៌នាលម្អិតអំពីវិមជ្ឈការលើការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា៣១២** ._ បទពិសោធន៍ និងការបណ្តុះបណ្តាលដែលចាំបាច់

នាយករបៀងអភិរក្សជីវៈចម្រុះ នាយកតំបន់ការពារធម្មជាតិ របៀងអភិរក្សជីវៈចម្រុះតាមវិស័យដទៃទៀត និងបុគ្គលិកផ្នែកបច្ចេកទេស និងផ្នែកគ្រប់គ្រងនៃតំបន់ការពារដែលត្រូវបានកំណត់ដោយ

ថ្នាក់ជាតិ ប្រធានមន្ទីរបរិស្ថានខេត្ត ត្រូវបានតែងតាំង ដោយផ្អែកលើអ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចខាងក្រោម៖

១- ផ្នែកអប់រំ និងជំនាញវិជ្ជាជីវៈដែលចាំបាច់ ។

២- បទពិសោធន៍ក្នុងវិស័យព្រៃឈើ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការពង្រឹងការអនុវត្តច្បាប់ និងវិស័យពាក់ព័ន្ធដទៃៗទៀត ។

នាយករបៀងអភិរក្សជីវៈចម្រុះ នាយកតំបន់ការពារធម្មជាតិ និងបុគ្គលិកផ្នែករបៀងអភិរក្សចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ដោយថ្នាក់ជាតិ និងប្រធានមន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្តដែលពាក់ព័ន្ធ ត្រូវបំពេញវគ្គសិក្សា និងវគ្គបណ្តុះបណ្តាល នៅបណ្ឌិតសភាបណ្តុះបណ្តាលផ្នែកបរិស្ថានជាតិ និងធនធានធម្មជាតិក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

## ជំពូកទី៣
## ការរៀបចំផែនការប្រើប្រាស់ដី នៅក្នុងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ

**មាត្រា៣១៣** ._ លក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៃរបៀងអភិរក្សជីវៈចម្រុះ

របៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ត្រូវអនុលោមតាមការរៀបចំផែនការប្រើប្រាស់ដី ដែលត្រូវដើរតួនាទីជាសមាសភាគដ៏សំខាន់មួយ និងឧបករណ៍ជំនួយដល់ដំណើរការនៃការរៀបចំផែនការគ្រប់គ្រងសម្រាប់តំបន់បែបនេះទាំងអស់ ។

ដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីនីមួយៗ ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ ២០(ម្ភៃ)ឆ្នាំម្តង ឬមុនពេល២០(ម្ភៃ)ឆ្នាំនេះ ក្នុងករណីចាំបាច់ ។

**មាត្រា៣១៤** ._ លក្ខខណ្ឌតម្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានក្នុងការរៀបចំផែនការប្រើប្រាស់ដី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងអាជ្ញាធរក្រោមជាតិពាក់ព័ន្ធ ត្រូវរៀបចំផែនការប្រើប្រាស់ដីសម្រាប់របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាផ្នែកមួយនៃដំណើរការរៀបចំផែនការគ្រប់គ្រង ។

ការរៀបចំផែនការប្រើប្រាស់ដីត្រូវរៀបចំដោយពិគ្រោះយោបល់ជាមួយដៃគូបច្ចេកទេស ដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងភាគីពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ មានជាអាទិ៍គណៈកម្មការគ្រប់គ្រង

រួមគ្នា និងសមាជិកនៃ  សហគមន៍គ្រប់គ្រងរួមគ្នា នៅក្នុងតំបន់នានាដែលស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នា និងសហគមន៍ផ្សេងទៀតដែលមានទីតាំងនៅក្នុងតំបន់ដែលត្រូវរៀបចំផែនការប្រើប្រាស់ដី ។

នៅក្នុងតំបន់ទាំងឡាយណាដែលត្រូវអនុលោមតាម ការគ្រប់គ្រងរួមគ្នា ការរៀបចំផែនការប្រើប្រាស់ដីអាចត្រូវបានធ្វើឡើងផងដែរជាផ្នែកមួយនៃដំណើរការនៃការគ្រប់គ្រងរួមគ្នា ស្របតាម បទប្បញ្ញត្តិស្តីពីការគ្រប់គ្រងរួមគ្នា មាតិកាទី៣ នៃគន្លឺនេះ ។

ការរៀបចំផែនការប្រើប្រាស់ដីនៃការគ្រប់គ្រងរួមគ្នាអាចត្រូវបានធ្វើឡើង៖

ក- មុនពេលនិងដាច់ដោយឡែកពីការរៀបចំផែនការប្រើប្រាស់ដីដែលមានចែងនៅក្នុងជំពូកនេះ ។

ខ- ក្នុងពេលដំណាលគ្នា និងរួមគ្នាជាមួយផែនការប្រើប្រាស់ដីដែលមានចែងនៅក្នុងជំពូកនេះ ឬ

គ- បន្ទាប់ពី និងស្របជាមួយការរៀបចំផែនការប្រើប្រាស់ដី ដែលមានចែងនៅក្នុងជំពូកនេះ ។

ការរៀបចំផែនការប្រើប្រាស់ដី និងការកំណត់តំបន់គ្រប់គ្រង ការរៀបចំផែនការគ្រប់គ្រង ដែលធ្វើឡើងនៅក្រោមមាតិកានេះ ទៅតាមកម្រិតធំបំផុតដែលអាចធ្វើទៅបាន ត្រូវស៊ីចង្វាក់គ្នាជាមួយការរៀបចំផែនការប្រើប្រាស់ដី ការកំណត់តំបន់គ្រប់គ្រង ការរៀបចំផែនការគ្រប់គ្រង ពីមុន ឬបន្តបន្ទាប់ដែលត្រូវបានធ្វើឡើង ស្របតាម បទប្បញ្ញត្តិស្តីពីការគ្រប់គ្រងរួមគ្នា មាតិកាទី៣ នៃ គន្លឹនេះ ។

**មាត្រា៣១៥** ._ គោលបំណងនៃការរៀបចំផែនការប្រើប្រាស់ដី

ការរៀបចំផែនការប្រើប្រាស់ដីធ្លីសម្រាប់របៀងអភិរក្សជីវៈចម្រុះទាំងអស់ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវអនុវត្តដូច ខាងក្រោម៖

ក- អនុវត្តការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ។

ខ- ស្រាវជ្រាវ និងទទួលបានទិន្នន័យលម្អិតជាក់លាក់តាមតំបន់ស្តីពីរូបសាស្ត្រ ជីវសាស្ត្រ សង្គម និងកត្តាសេដ្ឋកិច្ច ក្នុងនោះ មានជាអាទិ៍ ទិន្នន័យមានស្រាប់ដែលល្អបំផុត ពាក់ព័ន្ធទៅនឹងសន្និធិនៃធនធានដី ការប្រើប្រាស់ដីបច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធ អត្រាប្រជាជន ជីវៈចម្រុះ និងធនធានធម្មជាតិ សិទ្ធិដីធ្លី សិទ្ធិប្រពៃណី រចនាសម្ព័ន្ធសង្គម កត្តានានាពាក់ព័ន្ធទៅនឹងជីវភាពរស់នៅតាមវប្បធម៌ ការគ្រប់គ្រង រុក្ខជាតិ ការរំខានជាលក្ខណៈធម្មជាតិ មុខងារធារាសាស្ត្រ លំហូរថាមពល ចលនាសត្វព្រៃឆ្លងដែន និងចលនាសត្វព្រៃតាមធម្មតា និងរាល់ព័ត៌មានដទៃទៀតដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ដីបច្ចុប្បន្ន។

គ- រៀបចំផែនទីប្រើប្រាស់ដីគ្រប់វិស័យ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ នៃតំបន់ទេសភាព រូបសណ្ឋាននៃការប្រើប្រាស់ដី កម្មសិទ្ធិដីធ្លី ទីតាំងបេតិកភណ្ឌវប្បធម៌ និងរបៀងជីវ

សាស្ត្រសំខាន់ៗដែលស្ថិតនៅក្នុង និងនៅក្បែររបៀងអភិរក្សជីវៈចម្រុះទាំងអស់ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ឃ- ទទួលបានទិន្នន័យដ៏ល្អបំផុតដែលអាចស្វែងរកបានអំពីសក្ដានុពលនៃការប្រើប្រាស់ដី និងហេតុប៉ះពាល់បរិស្ថានដែលអាចព្យាករណ៍បានភ្លាមៗ នៃសក្ដានុពលនៃការប្រើប្រាស់ដីធ្លីនៅក្នុង ឬនៅក្បែររបៀងអភិរក្សជីវៈចម្រុះទាំងអស់ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ង- ទទួលបាននូវទិន្នន័យដ៏ល្អបំផុតដែលអាចស្វែងរកបានអំពីតម្លៃសេដ្ឋកិច្ចនៃដើមទុនធម្មជាតិ ដែលស្ថិតនៅក្នុង ឬនៅក្បែររបៀងអភិរក្សជីវៈចម្រុះទាំងអស់ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ទាំងអស់ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលផ្គត់ផ្គង់ដោយដើមទុនធម្មជាតិ ។

ច- កំណត់អត្តសញ្ញាណបញ្ហាបរិស្ថាន និងបញ្ហាគ្រប់គ្រងធនធានធម្មជាតិ ដែលទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការគ្រប់គ្រងបរិស្ថានប្រកបដោយនិរន្តរភាព ។

ឆ- ពិគ្រោះយោបល់ជាមួយអ្នកជំនាញការលើការអភិរក្សដី និងធនធាន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅទីណាដែលជនជាតិដើមភាគតិចរស់នៅមានវត្តមាន ត្រូវពិគ្រោះយោបល់ជាមួយអ្នកមានជំនាញឯកទេសខាងផ្នែកសង្គមដែលមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ដែលមានជំនាញទាក់ទងនឹងសហគមន៍ នៅក្នុងដំណើរការទាំងមូលនៃការរៀបចំផែនការប្រើប្រាស់ដីដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ។

**មាត្រា៣១៦** ._ លទ្ធផលនៃការរៀបចំផែនការប្រើប្រាស់ដី

បន្ទាប់ពីដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដី ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន ត្រូវកំណត់យកផែនទីប្រើប្រាស់ដីគ្រប់វិស័យជាផ្លូវការ និងត្រូវប្រគល់ផែនទីទាំងនោះទៅកាន់នាយកដ្ឋានទទួលបន្ទុកលើប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ក្រោមចំណុះរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និង/ឬមជ្ឈមណ្ឌលផែនទីបរិស្ថានកម្ពុជា ស្របតាមបទប្បញ្ញត្តិស្ដីពីសិទ្ធិទទួលបានព័ត៌មាន នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ។

**មាត្រា៣១៧** ._ ដំណើរការ និងលក្ខណៈវិនិច្ឆ័យ នៃការរៀបចំផែនការប្រើប្រាស់ដី

ដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងជំពូកនេះ កំណត់ពីការគ្រប់គ្រង និងការធ្វើចំណាត់ថ្នាក់តំបន់គ្រប់គ្រង និងត្រូវអនុវត្តចំពោះរបៀបអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងអាជ្ញាធរថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ដោយមានការពិចារណាទៅលើធនធាន និងពេលវេលា និងការសហការជាមួយដៃគូរបច្ចេកទេស អាចកំណត់ពីទំហំនៃការរៀបចំផែនការប្រើប្រាស់ដីស្របទៅតាមករណី និងភាពអាចព្យាករណ៍បាន នៅក្នុងរបៀងអភិរក្សជីវចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

លក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងជំពូកនេះ មិនត្រូវធ្វើឲ្យយឺតយាវដល់ការកំណត់តំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងទាំងមូលសម្រាប់របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឡើយ។

**មាត្រា៣១៨** ._ សំណើក្នុងការកែសម្រួលផែនការប្រើប្រាស់ដី

ការកែសម្រួលផែនការប្រើប្រាស់ដីដែលបានដាក់ស្នើ សម្រាប់របៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឬផ្នែកណាមួយនៃតំបន់ទាំងនេះ នីតិបុគ្គល ឬរូបវ័នបុគ្គល ដែលស្នើសុំឲ្យមានការកែសម្រួលនេះ ត្រូវរៀបចំឯកសារដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

ក- មូលហេតុផ្នែកវិទ្យាសាស្ត្រ និងសេដ្ឋកិច្ចសង្គម សម្រាប់សំណើកែសម្រួលផែនការមេប្រើប្រាស់ដីថ្មី ។

ខ- កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងដើម្បីរក្សាស្ថានភាពនៃការប្រើប្រាស់ដីថ្មីបច្ចុប្បន្ន ។

គ- លក្ខណៈដែលការកែសម្រួលចំពោះការចាត់ចំណាត់ថ្នាក់ នៃការប្រើប្រាស់ដីដែលមានការអនុញ្ញាត នឹងលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ធានាឲ្យបាននិរន្តរភាពនៃលំនាំនៃការប្រើប្រាស់ដីតាមទំនៀមទម្លាប់ និងធានាថានឹងមិនមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ណាមួយនៅក្នុងតំបន់ដែលមានតម្លៃអភិរក្សខ្ពស់នោះឡើយ ។

ឃ- មធ្យោបាយ ដែលតាមរយៈមធ្យោបាយនេះការបាត់បង់តម្លៃនៃការអភិរក្ស និងប្រព័ន្ធអេកូឡូស៊ី នឹងត្រូវកាត់បន្ថយ និង

ង- ព័ត៌មានដទៃទៀតដែលចាំបាច់ក្នុងការធ្វើឲ្យសំណើនេះមានហេតុផលសមរម្យ។

សំណើក្នុងការធ្វើការកែសម្រួលផែនការប្រើប្រាស់ដី នៃរបៀងអភិរក្សជីវៈចម្រុះ ឬតំបន់ការពារដទៃទៀត ត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ ក្នុងគន្ថីទី១ មាតិកាទី២ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាននៃក្រមនេះ គន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

បន្ទាប់មក ការឯកភាពលើការកែសម្រួលបែបនេះ ត្រូវទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន នៅក្នុងសេចក្តីសម្រេចដែលបញ្ជាក់ពីការពិចារណាដោយយកចិត្តទុកដាក់លើឯកសារ ដែលបានផ្តល់ឲ្យ ។

## ជំពូកទី៤
## តំបន់គ្រប់គ្រងនៃរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ

**មាត្រា៣១៩** ._ ការកំណត់តំបន់គ្រប់គ្រង

ស្របតាមលទ្ធផលនៃដំណើរការរៀបចំផែនការប្រើប្រាស់ដី ដែលអាចនឹងត្រូវបានធ្វើឡើងស្របតាមមាតិកានេះ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងអាជ្ញាធរថ្នាក់ក្រោមជាតិពាក់ព័ន្ធត្រូវកំណត់តំបន់គ្រប់គ្រងសម្រាប់របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្របតាមផែនការប្រើប្រាស់ដី។ ការកំណត់តំបន់គ្រប់គ្រង ត្រូវលើកកម្ពស់ដល់ការគ្រប់គ្រងតំបន់ទាំងនេះ ស្របតាមគោលបំណងដូចបានកំណត់ក្នុងមាតិកានេះ។

តំបន់គ្រប់គ្រងទាំងនេះត្រូវកំណត់ដោយផ្អែកលើទីតាំងជាក់លាក់នីមួយៗ ដែលត្រូវពិចារណាប្រភេទតំបន់គ្រប់គ្រងនីមួយៗ ក៏ដូចជាកម្រិតនៃប្រភេទតំបន់គ្រប់គ្រងនីមួយៗដែលត្រូវដាក់បញ្ចូលនៅក្នុងតំបន់នីមួយៗ និងក្រុមអនុតំបន់គ្រប់គ្រង ដែលអាចមានភាពសមរម្យដោយផ្អែកលើមូលដ្ឋាននៃទីតាំងជាក់លាក់ ។

ការកំណត់តំបន់គ្រប់គ្រងទៅតាមទីតាំងជាក់លាក់ ត្រូវធ្វើឡើងដោយពិគ្រោះយោបល់ជាមួយដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ រួមមានគណៈកម្មការគ្រប់គ្រងរួមគ្នា និងសមាជិកនៃសហគមន៍គ្រប់គ្រងរួមគ្នា នៅក្នុងតំបន់នានាដែលជាកម្មវត្ថុនៃការគ្រប់គ្រងរួមគ្នា និងសហគមន៍ដទៃទៀត ដែលមានទីតាំងនៅក្នុងតំបន់នោះ និងត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុងគន្ថីទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងអាជ្ញាធរថ្នាក់ក្រោមជាតិត្រូវផ្តល់ឱកាសដល់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ អង្គភាព និងនាយកដ្ឋានពាក់ព័ន្ធ ក្នុងការចូលរួមនៅក្នុងដំណើរការនៃការកំណត់តំបន់គ្រប់គ្រង និងត្រូវជូនដំណឹងពួកគាត់អំពីលទ្ធផលនៃដំណើរការនៃការកំណត់តំបន់គ្រប់គ្រង ដែលត្រូវមានចំណងកាតព្វកិច្ចផ្លូវច្បាប់ទៅលើក្រសួង ស្ថាប័នទាំងអស់ ។

ការកំណត់តំបន់គ្រប់គ្រងទាំងអស់ត្រូវប្រើប្រាស់ ក្របខ័ណ្ឌនៃការកំណត់តំបន់គ្រប់គ្រងខាងក្រោម បន្ថែមលើការកំណត់អនុតំបន់គ្រប់គ្រងទៅតាមទីតាំងជាក់លាក់៖

ក- **តំបន់ស្នូល៖** តំបន់គ្រប់គ្រងដែលមានតម្លៃនៃការអភិរក្សខ្ពស់ ដែលមានប្រភេទសត្វ រុក្ខជាតិដែលកម្រ ជិតវិនាសផុតពូជ ទទួលរងគ្រោះថ្នាក់ ការគំរាមកំហែង និងមានប្រព័ន្ធអេកូឡូស៊ីផុយស្រួយ ។

ការចេញចូលតំបន់ស្នូលត្រូវហាមឃាត់ លើកលែងតែ ១-មន្ត្រីដែលទទួលបានការអនុញ្ញាតត្រឹមត្រូវ ២-អ្នកសិក្សាស្រាវជ្រាវ ផ្នែកវិទ្យាសាស្ត្រធម្មជាតិ ក្នុងគោលបំណងការពារ និងអភិរក្សធនធានជីវសាស្ត្រ និងបរិស្ថានធម្មជាតិ ដែលត្រូវមានការអនុញ្ញាតជាមុនពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និង៣-អ្នកអនុវត្តការគ្រប់គ្រងរួមគ្នា ដែលមានកិច្ចព្រមព្រៀងដែលចុះហត្ថលេខារួច ក្នុងការគ្រប់គ្រងរួមគ្នាលើតំបន់ដែលពាក់ព័ន្ធ ដែលការចេញចូលនេះ ត្រូវមានលក្ខខណ្ឌច្បាស់លាស់នៃកិច្ចព្រមព្រៀងដោយមានកម្រិតចំពោះ ការអង្កេតតាមដាន ការពង្រឹងការអនុវត្តច្បាប់ និងទេសចរណ៍ធម្មជាតិដែលមានផលប៉ះពាល់ទាប ។ នៅក្នុងករណីដែលទាក់ទងនឹងផលប្រយោជន៍នៃសន្តិសុខជាតិ និងដោយមានការអនុញ្ញាតជាមុនពីនាយករដ្ឋមន្ត្រី វិស័យសន្តិសុខ និងការពារជាតិអាចចេញចូលតំបន់ស្នូលបាន ។ នៅពេលចេញចូលតំបន់ស្នូល វិស័យសន្តិសុខ និងការពារជាតិត្រូវជូនដំណឹងដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ប្រធាននាយកដ្ឋានបរិស្ថាននិងតំបន់ការពារធម្មជាតិ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត នៅពេលដែលការចេញចូលនេះមានការចាំបាច់ និងត្រូវសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត និងអ្នកពាក់ព័ន្ធនានា ដើម្បីកាត់បន្ថយជាអប្បបរមានូវការរំខានចំពោះតំបន់ស្នូល ឲ្យដល់កម្រិតដែលអាចធ្វើទៅបាន ។

ខ- **តំបន់អភិរក្ស៖** តំបន់គ្រប់គ្រងដែលមានតម្លៃអភិរក្សខ្ពស់ ដែលមានធនធានធម្មជាតិដែលមានប្រភេទសត្វ រុក្ខជាតិ ដែលកម្រ ជិតវិនាសផុតពូជ ទទួលរងគ្រោះថ្នាក់ ការគំរាមកំហែង និងមានប្រព័ន្ធអេកូឡូស៊ីផុយស្រួយ ធនធានធម្មជាតិ តំបន់ទីជម្រាល និងតំបន់ទេសភាពធម្មជាតិ ដែលជាទូទៅស្ថិតនៅក្បែរតំបន់ស្នូល ។

ការចេញចូលតំបន់អភិរក្ស ត្រូវមានការអនុញ្ញាតជាមុនពីអង្គភាពរដ្ឋាភិបាលពាក់ព័ន្ធ រួមបញ្ចូលអ្នកអនុវត្តការគ្រប់គ្រងរួមគ្នា ដែលមានកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខារួច ក្នុងការគ្រប់គ្រងរួមគ្នាលើតំបន់ពាក់ព័ន្ធនានា ។ នៅក្នុងករណីនៃផលប្រយោជន៍នៃសន្តិសុខជាតិ និងដោយមានការអនុញ្ញាតជាមុនពីនាយករដ្ឋមន្ត្រី វិស័យសន្តិសុខ និងការពារជាតិ អាចចេញចូលតំបន់ស្នូលបាន ។ នៅពេលចេញចូលតំបន់ស្នូល វិស័យសន្តិសុខ និងការពារជាតិត្រូវជូនដំណឹងដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ប្រធាននាយកដ្ឋានបរិស្ថាន និងតំបន់ការពារធម្មជាតិ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត នៅពេលដែលការចេញចូលនេះមានការ

ចាំបាច់ និងត្រូវសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត និងអ្នកពាក់ព័ន្ធនានា ដើម្បីកាត់បន្ថយជាអប្បបរមានូវការរំខានចំពោះតំបន់ស្នូលឲ្យដល់កម្រិតដែលអាចធ្វើទៅបាន ។

ប្រតិបត្តិការទេសចរណ៍ដែលមានផលប៉ះពាល់ទាប ការប្រើប្រាស់ទ្រង់ទ្រាយតូចដើម្បីចិញ្ចឹមជីវិតនូវឈើ អុសដុត និងការប្រើប្រាស់ទ្រង់ទ្រាយតូចនូវអនុផលព្រៃឈើ ដើម្បីគាំទ្រសហគមន៍មូលដ្ឋាន និងជីវភាពរស់នៅរបស់ជាតិភាគតិចមូលដ្ឋាន អាចអនុញ្ញាតនៅក្រោមលក្ខខណ្ឌដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬអាជ្ញាធរពាក់ព័ន្ធដទៃទៀត រួមទាំងអ្នកអនុវត្តតាមការគ្រប់គ្រងរួមគ្នា ដែលជាភាគីនៃកិច្ចព្រមព្រៀងលើការគ្រប់គ្រងរួមគ្នាលើតំបន់ដែលពាក់ព័ន្ធ ដរាបណាមិនផ្តល់នូវផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់តម្លៃនៃការអភិរក្សជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់គ្រប់គ្រង ។

គ- **តំបន់ប្រើប្រាស់ដោយចីរភាព៖** តំបន់គ្រប់គ្រង ដែលមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ និងតម្លៃនៃការអភិរក្ស និងប្រព័ន្ធអេកូឡូស៊ីគួរឲ្យកត់សម្គាល់ ដែលមានសក្តានុពលខ្ពស់ក្នុងការចូលរួមចំណែកចំពោះជីវភាពរស់នៅប្រកបដោយនិរន្តរភាពរបស់សហគមន៍មូលដ្ឋាន រួមបញ្ចូល សហគមន៍ជនជាតិដើមភាគតិច ។

បន្ថែមលើការប្រើប្រាស់ទ្រង់ទ្រាយតូចលក្ខណៈ ដែលអនុញ្ញាតនៅក្នុងតំបន់អភិរក្ស ការប្រមូលផល និងសកម្មភាពផលិតកម្មទ្រង់ទ្រាយតូចដែលមានដែនកម្រិត ត្រូវបានអនុញ្ញាតនៅក្នុងតំបន់នេះ ។ ការប្រើប្រាស់បែបនេះត្រូវមានភាពស៊ីចង្វាក់គ្នាជាមួយការរៀបចំផែនការប្រើប្រាស់ និងគ្រប់គ្រងដីធ្លី ដែលត្រូវបានបង្កើតឡើងសម្រាប់តំបន់នេះ និងត្រូវមានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត រួមទាំងអ្នកអនុវត្តតាមការគ្រប់គ្រងរួមគ្នា ដែលជាភាគីនៃកិច្ចព្រមព្រៀងលើការគ្រប់គ្រងរួមគ្នានៃតំបន់ដែលពាក់ព័ន្ធ។ សកម្មភាពទាំងនេះអាចរួមបញ្ចូល សកម្មភាពពាណិជ្ជកម្មដែលផ្អែកលើសហគមន៍ ដូចជា ការដាំដើមឈើថ្មី រុក្ខវប្បកម្មខ្នាតតូច ការធ្វើចំការ និងការធ្វើអាជីវកម្មលើផលិតកម្មអនុផលព្រៃឈើ ដរាបណាសកម្មភាពទាំងនេះមិនបង្កឲ្យមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ចំពោះតម្លៃនៃការអភិរក្សជីវៈចម្រុះដែលមានស្រាប់ និងតម្លៃប្រព័ន្ធអេកូឡូស៊ី ។ ការឆ្ការព្រៃឈើ និងសកម្មភាពពាណិជ្ជកម្មព្រៃឈើខ្នាតធំមិនត្រូវអនុញ្ញាតឡើយ ។

ឃ- **តំបន់សហគមន៍៖** តំបន់គ្រប់គ្រង សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៃសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ហើយបន្ថែមទៅលើការប្រើប្រាស់ ដែលអនុញ្ញាតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពអាចរួមមាននូវដីលំនៅដ្ឋានដែលមានស្រាប់ វាលស្រែ និងវាលស្មូនដំណាំ ឬចំការពនេចរ ។

រាល់ការលក់ដូរលក្ខណៈពាណិជ្ជកម្មនូវផលឈើ និងអុសដុត ពីតំបន់ប្រើប្រាស់ដោយចីរភាព ឬតំបន់សហគមន៍ ត្រូវអនុលោមទៅតាមផែនការគ្រប់គ្រងដែលទទួលបានការឯកភាពរបស់តំបន់ និងលិខិតអនុញ្ញាតពីអាជ្ញាធរពាក់ព័ន្ធ រួមទាំងអ្នកអនុវត្តតាមការគ្រប់គ្រងរួមគ្នាដែលជាភាគីនៃកិច្ចព្រមព្រៀងលើការគ្រប់គ្រងរួមគ្នានៃតំបន់ដែលពាក់ព័ន្ធ ។

**មាត្រា៣២០** ._ ការកំណត់តំបន់ដែលសមរម្យសម្រាប់សកម្មភាពពាណិជ្ជកម្ម

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាជ្ញាធរថ្នាក់ក្រោមជាតិ គណៈកម្មការគ្រប់គ្រងរួមគ្នា និងអង្គភាពពាក់ព័ន្ធដទៃទៀត ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រង នៅក្នុងផ្នែកណាមួយនៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាចកំណត់ផ្នែកជាក់លាក់នៃតំបន់ប្រើប្រាស់ដោយចីរភាព ឬតំបន់សហគមន៍នោះ ដែលមានទាំង សក្តានុពលសេដ្ឋកិច្ចខ្ពស់ និងតម្លៃអភិរក្សនិងប្រព័ន្ធអេកូឡូស៊ីទាប ដែលសមរម្យបំផុតសម្រាប់សកម្មភាពពាណិជ្ជកម្មនោះ ។

បន្ទាប់ពីធ្វើការកំណត់នេះរួចហើយ និងមុនពេលអនុវត្តសកម្មភាពពាណិជ្ជកម្មនោះ អង្គភាពពាក់ព័ន្ធត្រូវ៖

ក-អនុវត្តការពិគ្រោះយោបល់សមរម្យជាមួយដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ និងសហគមន៍មូលដ្ឋានដែលទទួលរងផលប៉ះពាល់ និងទទួលនូវការយល់ព្រមរបស់សហគមន៍ចំពោះសកម្មភាពពាណិជ្ជកម្មដែលស្នើសុំនោះ។

ខ-បង្ហាញការចាត់ចែងផ្នែកហិរញ្ញវត្ថុ និងការគណនាប្រាក់ចំណូលដែលនឹងទទួលបានមកពីសកម្មភាពពាណិជ្ជកម្មបែបនេះ ដល់អ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ទាំងអស់ ។

នៅពេលបំពេញតាមលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងកថាខណ្ឌខាងលើនេះ អង្គភាពពាក់ព័ន្ធត្រូវបង្កើតអនុតំបន់គ្រប់គ្រងថ្មីមួយ ដើម្បីគ្របដណ្តប់ឲ្យបានពេញលេញលើសកម្មភាពពាណិជ្ជកម្មដែលបានស្នើសុំ ។ អនុតំបន់គ្រប់គ្រងបែបនេះត្រូវធ្វើចំណាត់ថ្នាក់ជាតំបន់ទេសចរណ៍ តំបន់អភិវឌ្ឍកសិកម្មសហគមន៍ ឬតំបន់គ្រប់គ្រងដទៃទៀតតាមការចាំបាច់ ។

បន្ទាប់ពីបង្កើតអនុតំបន់គ្រប់គ្រងនេះមក អាជ្ញាធរពាក់ព័ន្ធអាចរៀបចំសកម្មភាពពាណិជ្ជកម្មបែបនេះបាន ។ ប្រាក់ចំណូលទាំងអស់ដែលបានមកពីសកម្មភាពបែបនេះ ត្រូវដាក់ចូលទៅក្នុងគណនីតាមទីតាំងជាក់លាក់ដែលសមរម្យ ដែលត្រូវបានបង្កើតឡើងស្របតាមបទប្បញ្ញត្តិនៅក្នុង គន្ថីទី៨ មាតិកាទី២ នៃក្រមនេះ និងត្រូវប្រើប្រាស់ផ្តាច់មុខសម្រាប់តែផលប្រយោជន៍នៃសហគមន៍មូលដ្ឋាននៅក្នុងតំបន់នោះ និងការអភិរក្សរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលសកម្មភាពពាណិជ្ជកម្មនោះស្ថិតនៅ ។

ដំណើរការនៃការកំណត់អនុតំបន់គ្រប់គ្រង និងការរៀបចំនានាសម្រាប់សកម្មភាពពាណិជ្ជកម្ម និង សេចក្តីលម្អិតទាំងអស់នៃការរៀបចំអនុតំបន់ ត្រូវលាតត្រដាង និងអាចឲ្យសាធារណជនទទួលបាន ព័ត៌មាន និងឱកាសផ្តល់មតិយោបល់ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុងគន្ថី ទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មាន ដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃ ក្រមនេះ ។

**មាត្រា៣២១ .**_ ផែនទីនៃរបៀងអភិរក្សជីវៈចម្រុះនីមួយៗ

នៅពេលបញ្ចប់ដំណើរការនៃការកំណត់តំបន់គ្រប់គ្រង អាជ្ញាធរពាក់ព័ន្ធត្រូវរៀបចំឲ្យទៅជា ផ្លូវការនូវផែនទីសម្រាប់របៀងអភិរក្សជីវៈចម្រុះនីមួយៗ ឬតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ព្រំប្រទល់ និងតំបន់គ្រប់គ្រង ត្រូវដាក់ឲ្យសាធារណជន អាចស្វែងរកបាន និងផ្សព្វផ្សាយទៅកាន់អ្នកពាក់ព័ន្ធទាំងអស់ដែលមានការចាប់អារម្មណ៍ ស្របតាម បទប្បញ្ញត្តិស្តីពី សិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៣២២ .**_ ការធ្វើបច្ចុប្បន្នភាពលើការកំណត់តំបន់គ្រប់គ្រង និងការធ្វើផែនទី

ការធ្វើផែនទី និងការកំណត់តំបន់គ្រប់គ្រងនីមួយៗទៅតាមទីតាំងជាក់លាក់ ត្រូវធ្វើបច្ចុប្បន្ន ភាពរៀងរាល់២០(ម្ភៃ)ឆ្នាំម្តង ឬឆាប់ជាងនេះ នៅក្នុងករណីចាំបាច់ ។

**មាត្រា៣២៣ .**_ សំណើក្នុងការកែសម្រួលការកំណត់តំបន់គ្រប់គ្រង

សំណើក្នុងការកែសម្រួលការកំណត់តំបន់គ្រប់គ្រងនៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្ម ជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឬផ្នែកណាមួយនៃតំបន់ទាំង នេះ ពីតំបន់ដែលមានឋានៈឬស្ថានភាពការពារខ្ពស់ ទៅជាតំបន់ដែលមានឋានៈឬស្ថានភាពការពារ ទាប ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

ក- មូលហេតុផ្នែកវិទ្យាសាស្ត្រ និងសេដ្ឋកិច្ចសង្គម សម្រាប់ការកែប្រែដែលបានស្នើ ឡើងចំពោះការធ្វើចំណាត់ថ្នាក់តំបន់គ្រប់គ្រង ។

ខ- កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងដើម្បីរក្សាស្ថានភាព/ឋានៈបច្ចុប្បន្ននៃតំបន់ គ្រប់គ្រង ។

គ- លក្ខណៈដែលការកែសម្រួលចំពោះការចាត់ចំណាត់ថ្នាក់នៃតំបន់គ្រប់គ្រង នឹង លើកកម្ពស់ជីវភាពរស់នៅ និងសិទ្ធិជាលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋាន ។

ឃ- មធ្យោបាយ ដែលតាមរយៈមធ្យោបាយនេះការបាត់បង់តម្លៃនៃការអភិរក្ស និង ប្រព័ន្ធអេកូឡូស៊ី នឹងត្រូវកាត់បន្ថយ និង

ង- ការពិគ្រោះយោបល់សមរម្យជាមួយអ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ និងសហគមន៍មូលដ្ឋានដែលទទួលរងផលប៉ះពាល់ រួមមានការយល់ព្រមជាមុនរបស់សហគមន៍ទាំងនេះ ចំពោះសំណើសុំកែសម្រួលនោះ ។

ច- ព័ត៌មានដទៃទៀតដែលចាំបាច់ក្នុងការធ្វើឲ្យសំណើនេះមានហេតុផលសមរម្យ ។

សំណើក្នុងការធ្វើការកែសម្រួលការធ្វើចំណាត់ថ្នាក់តំបន់គ្រប់គ្រង នៃរបៀងអភិរក្សជីវៈចម្រុះ ឬតំបន់ការពារដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ត្រូវស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុងគន្ថីទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

បន្ទាប់ពីនោះ រាល់ការឯកភាពលើការកែប្រែ ត្រូវផ្តល់ជូនជាលាយល័ក្ខអក្សរដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន បន្ទាប់ពីបានសម្រេច ដោយបង្ហាញពីការពិចារណាដោយប្រុងប្រយ័ត្នពីឯកសារដូចបានផ្តល់ជូន ។

## **ជំពូកទី៥**
## **ផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រសម្រាប់របៀងអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ**

**មាត្រា៣២៤**._ ការរៀបចំផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រនៃរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានត្រូវបង្កើតក្របខ័ណ្ឌនៃផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រជាតិស្តីពីរបៀងអភិរក្សជីវៈចម្រុះ និងផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រនៃតំបន់ការពារធម្មជាតិ ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវធានាថាផែនការនេះមានលក្ខណៈស្របគ្នា និងស៊ីចង្វាក់គ្នាជាមួយផែនការ និងយុទ្ធសាស្ត្រជាតិដទៃទៀត និងធានាថាផែនការនោះរួមបញ្ចូលនូវការពិចារណាអំពីគម្រោងថវិកា ។

**មាត្រា៣២៥**._ សំណើសុំពិនិត្យ និងកែសម្រួលផែនការ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវរៀបចំការស្នើសុំពិនិត្យ និងកែសម្រួលឡើងវិញនូវផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រជាតិស្តីពីរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ជារៀងរាល់ដប់ឆ្នាំម្តង ឬមុនរយៈពេលប្រាំឆ្នាំ ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ដើម្បីសម្រេចបាននូវគោល

ដៅ ទស្សន វិស័យ គោលដៅ ឬគោលបំណង របស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន នៅក្នុងការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ។

ផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រជាតិស្តីពីរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ដែលត្រូវបង្កើតឡើង និងកែសម្រួលឡើងវិញ អារម្មណ៍ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុងគន្ថីទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៣២៦** ._ ការបង្កើតផែនការគ្រប់គ្រង

សម្រាប់របៀងអភិរក្សជីវៈចម្រុះទាំងអស់ តំបន់ការពារធម្មជាតិដទៃទៀតដែលត្រូវបានបង្កើតឡើងនៅថ្នាក់ក្រោមជាតិ ដែលមិនត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងរួមគ្នា តាមមាតិកាទី២ នៃគន្ថីនេះ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬអាជ្ញាធរថ្នាក់ក្រោមជាតិត្រូវបង្កើតផែនការគ្រប់គ្រងតាមទីតាំងជាក់លាក់ ដោយអនុលោមតាមផែនការគ្រប់គ្រងជាយុទ្ធសាស្ត្រជាតិស្តីពីរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ។

ផែនការគ្រប់គ្រងតាមទីតាំងជាក់លាក់ ជាអប្បបរមា ត្រូវដាក់បញ្ចូលនូវការពិពណ៌នាអំពីតម្លៃខាងផ្នែកវប្បធម៌ និងធម្មជាតិនៃទីតាំង ការវិភាគអំពីការគំរាមកំហែង និងបញ្ហានានាដែលមានផលប៉ះពាល់លើតម្លៃទាំងនេះ និងដាក់បញ្ចូលនូវបណ្តុំនៃគោលបំណងជាយុទ្ធសាស្ត្រ និងសកម្មភាពគ្រប់គ្រងដែលនឹងដោះស្រាយការគំរាមកំហែងទាំងនេះ ។

កិច្ចដំណើរការនៃការបង្កើតផែនការគ្រប់គ្រងតាមទីតាំងជាក់លាក់ ត្រូវមានការសម្របសម្រួល និងពិគ្រោះយោបល់ជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច ដែលរស់នៅក្នុង និងក្បែរច្រករបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដទៃទៀតដែលត្រូវបានបង្កើតឡើងនៅថ្នាក់ក្រោមជាតិ ដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា អភាគីព័ន្ធដែលមានការចាប់អារម្មណ៍ និងរួមបញ្ចូលនូវនីតិបុគ្គលឯកជន និង ម្ចាស់សម្បទានដីសេដ្ឋកិច្ច ។

ផែនការគ្រប់គ្រងតាមទីតាំងជាក់លាក់នីមួយៗ ត្រូវកែសម្រួលជារៀងរាល់ដប់ឆ្នាំម្តង គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការឯកភាព ឬមុនរយៈពេល១០(ដប់)ឆ្នាំនេះ ប្រសិនបើមានការចាំបាច់ក្នុងការផ្លាស់ប្តូរ ដើម្បីសម្រេចបាននូវគោលបំណងនានានៃការគ្រប់គ្រង ដូចមានចែងនៅក្នុងផែនការគ្រប់គ្រង ។ ផែនការគ្រប់គ្រងតាមទីតាំងជាក់លាក់នីមួយៗ ត្រូវកែសម្រួលស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុងគន្ថីទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៣២៧ ._** ភាពបន្តនៃសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងតំបន់ដទៃទៀត

សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍តំបន់នេសាទ តំបន់មូលដ្ឋាន និងតំបន់ដែលត្រូវបានទទួលស្គាល់តាមប្រពៃណី ដែលមានស្រាប់រួចទៅហើយ នៅពេលអនុម័តក្រមនេះ ត្រូវបន្តមានសុពលភាព ហើយសិទ្ធិ ការទទួលខុសត្រូវ និងកាតព្វកិច្ចទាំងអស់ ទាក់ទងនឹងតំបន់ទាំងនេះ ត្រូវបន្តមានសុពលភាពស្របច្បាប់ លើកលែងតែ និងរហូតដល់ពេលដែល សហគមន៍តំបន់នីមួយៗ អាចត្រូវបានបញ្ចូលទៅក្នុង ឬប្រែក្លាយទៅជា តំបន់គ្រប់គ្រងរួមគ្នា ដូចមានចែងនៅក្នុងមាតិកាទី២ នៃគន្ថីនេះ ។

## ជំពូកទី៦
## លិខិតអនុញ្ញាត និងការឯកភាព

**មាត្រា៣២៨ ._** សិទ្ធិអំណាចក្នុងការចេញលិខិតអនុញ្ញាត កិច្ចព្រមព្រៀង និងកិច្ចសន្យា

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬអាជ្ញាធរថ្នាក់ក្រោមជាតិដទៃទៀតដែលពាក់ព័ន្ធ មានសិទ្ធិអំណាចក្នុងការចេញលិខិតអនុញ្ញាត កិច្ចព្រមព្រៀង ឬកិច្ចសន្យា សម្រាប់ការអភិរក្ស នៅក្នុងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោម ជាតិ ។ រាល់ការចេញលិខិតអនុញ្ញាត កិច្ចព្រមព្រៀង ឬកិច្ចសន្យា សម្រាប់ការអភិរក្សបែបនោះ ត្រូវអនុលោមស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ នៅក្នុងគន្ថីទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៣២៩ ._** ការអភិវឌ្ឍដែលត្រូវបានអនុញ្ញាតនៅក្នុងតំបន់គ្រប់គ្រង

ការអភិវឌ្ឍអគារ ឬហេដ្ឋារចនាសម្ព័ន្ធអចិន្ត្រៃយ៍ សកម្មភាពពាណិជ្ជកម្មគ្រប់ប្រភេទ ការឈូសឆាយដី ឬការឈូសឆាយដោយប្រើគ្រឿងចក្រ ត្រូវហាមឃាត់យ៉ាងតឹងរ៉ឹងនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។

ហេដ្ឋារចនាសម្ព័ន្ធដែលមិនមានលក្ខណៈអចិន្ត្រៃយ៍ ដែលមានផលប៉ះពាល់ទាប ដែលស៊ីចង្វាក់គ្នាជាមួយនឹងផែនការគ្រប់គ្រងតំបន់ អាចត្រូវបានអនុញ្ញាតនៅក្នុងតំបន់ស្នូលនិងតំបន់អភិរក្ស ។

សកម្មភាពពាណិជ្ជកម្ម នៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព ឬតំបន់សហគមន៍ ត្រូវតែមានភាពស៊ីចង្វាក់គ្នាជាមួយផែនការគ្រប់គ្រងសម្រាប់តំបន់ទាំងនេះ ។ ការឆ្ការ/ឈូសឆាយព្រៃឈើ និងសកម្មភាពអាជីវកម្មព្រៃឈើទ្រង់ទ្រាយធំ មិនត្រូវអនុញ្ញាតឡើយនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ប៉ុន្តែសកម្មភាពពាណិជ្ជកម្មអាចត្រូវបានអនុញ្ញាតនៅក្នុងអនុតំបន់គ្រប់គ្រង ដែល

ត្រូវបានបង្កើតឡើងជាពិសេស ស្របតាមមាត្រា៣២២ នៃក្រមនេះ ។ ប្រាក់ចំណូលដែលបានមកពីសកម្មភាពពាណិជ្ជកម្មបែបនេះ ត្រូវប្រើប្រាស់សម្រាប់ជាផលប្រយោជន៍ដោយផ្ទាល់នៃសហគមន៍មូលដ្ឋាននៅក្នុងតំបន់នោះ និងសម្រាប់ការអភិរក្សតំបន់ដែលសកម្មភាពពាណិជ្ជកម្មនោះស្ថិតនៅ ។

សកម្មភាពពាណិជ្ជកម្មទាំងនេះក៏ត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុងគន្ថីទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ និងត្រូវមានការឯកភាពពីក្រសួង ស្ថាប័នពាក់ព័ន្ធ ឬអង្គភាពដែលមានសមត្ថកិច្ចគ្រប់នៅក្នុងតំបន់ ។

**មាត្រា៣៣០** ._ សំណើដែលត្រូវការនូវការឯកភាពជាមុន

រាល់សំណើសុំយកចេញ ឬយកចូល ទៅក្នុងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នូវរុក្ខជាតិ គ្រាប់ពូជ សត្វព្រៃ ឬត្រី និងការបង្កាត់ពូជប្រភេទសត្វព្រៃ និងពូជមច្ឆាជាតិគ្រប់ប្រភេទ ត្រូវធ្វើការសិក្សាស្រាវជ្រាវ វិភាគ និងមានការឯកភាពជាមុន ពីក្រសួងបរិស្ថាន និងក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។

**មាត្រា៣៣១** ._ លក្ខខណ្ឌតម្រូវសម្រាប់ការស្រាវជ្រាវ ការវិភាគ និងការវាយតម្លៃ

រាល់ការនាំចេញ ការនាំចូល ឬការដោះដូរ សត្វព្រៃ ដែលពុំមានលក្ខណៈពាណិជ្ជកម្ម រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសដទៃទៀត ត្រូវធ្វើការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃឲ្យបានគ្រប់ជ្រុងជ្រោយដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយពិគ្រោះយោបល់ជាមួយដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មានតែក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានទេ ដែលអាចផ្តល់ការអនុញ្ញាតទៅលើសកម្មភាពបែបនេះ នៅក្នុងករណីដែលសកម្មភាពស្នើសុំនេះ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី ។

**មាត្រា៣៣២** ._ ការហាមឃាត់ចំពោះសកម្មភាពដែលបង្កឲ្យមានភ្លើងឆេះព្រៃ

ត្រូវហាមឃាត់ចំពោះសកម្មភាពដែល អាចបង្ក ឲ្យមានភ្លើងឆេះព្រៃនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដោយគ្មានការអនុញ្ញាត ។

ការប្រើប្រាស់ភ្លើងក្នុងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានបានហាមឃាត់ លើកលែងតែមានការអនុវត្តពីស្ថាប័នមានសមត្ថកិច្ចទទួលខុសត្រូវ ។

**មាត្រា៣៣៣ .**_ ការហាមឃាត់ចំពោះសកម្មភាពនេសាទ

ការនេសាទនៅក្នុងតំបន់ស្នូលនៃរបៀងអភិរក្សជីវៈចម្រុះទាំងអស់ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវហាមឃាត់ជាដាច់ខាត ។

ការនេសាទដោយប្រើឧបករណ៍ខុសច្បាប់នៅក្នុងរបៀងអភិរក្សជីវៈចម្រុះទាំងអស់ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ ត្រូវហាមឃាត់ជាដាច់ខាត ដែលរួមមាន សារធាតុពុល និងសារធាតុគីមី ការឆក់ ការប្រើបាស់មុង គ្រឿងផ្ទុះ ស្នរួមផ្សំជាមួយ គ្រឿងផ្ទុះ មង ឬអួន ដែលមានក្រឡាតូចជាង ១សង់ទីម៉ែត្រកន្លះ សំណាញ់ដែលមានភ្លើងព័ទ្ធជុំវិញ ។

ការដាក់រនាំង ឬឧបសគ្គរាំងនៅក្នុងប្រព័ន្ធវារីជាតិ នៅក្នុងរបៀងអភិរក្សជីវៈចម្រុះទាំងអស់ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលរាំងផ្លូវធ្វើដំណើររបស់មច្ឆាជាតិ ត្រូវហាមឃាត់ជាដាច់ខាត ដោយគ្មានលិខិតអនុញ្ញាត ។

ការបង្ហូរ ឬការប៉ុនប៉ងបង្ហូរ ឬបូមឲ្យរីងនូវប្រព័ន្ធវារីជាតិ នៅក្នុងរបៀងអភិរក្សជីវៈចម្រុះទាំងអស់ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលបំណងចាប់ ឬសម្លាប់មច្ឆាជាតិទោះបីជានៅក្នុងលក្ខណៈណាក៏ដោយ ត្រូវហាមឃាត់ជាដាច់ខាត ។

ការធ្វើឲ្យខូចខាតកន្លែងត្រីពង ច្រាំង ឬពងរបស់មច្ឆាជាតិ ត្រូវហាមឃាត់ជាដាច់ខាត នៅក្នុងរបៀងអភិរក្សជីវៈចម្រុះទាំងអស់ តំបន់ការពារដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ការបង្កើត ឬការធ្វើប្រតិបត្តិការលើដំណើរការនៃវារីវប្បកម្ម ត្រូវហាមឃាត់ជាដាច់ខាតនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។ ដំណើរការវារីវប្បកម្មនៅក្នុងតំបន់ស្នូល និងតំបន់ប្រើប្រាស់ដោយចីរភាព ត្រូវតម្រូវឲ្យមានលិខិតអនុញ្ញាត និងត្រូវអនុលោមតាមការអង្កេតតាមដាន ដើម្បីធានាថាមិនមានផលប៉ះពាល់អវិជ្ជមានណាមួយនៅជុំវិញតំបន់នោះ ។

**មាត្រា៣៣៤ .**_ ការការពារប្រឆាំងនឹងការអនុវត្តដែលមានលក្ខណៈបំផ្លិចបំផ្លាញ

រាល់ការអនុវត្តសកម្មភាព ដែលបង្កការខូចខាត ឬគ្រោះថ្នាក់ ដែលបណ្តាលមកពី ការទន្ទ្រានយកដីដោយខុសច្បាប់ ការប្រមូល ការឈូសឆាយ ការធ្វើអាជីវកម្ម ការបំពុលនៅក្នុងតំបន់ដែលមានធនធានជីវៈចម្រុះដ៏មានតម្លៃ ភ្លើងឆេះព្រៃ ការធ្វើកសិកម្មពនេចរ និងកសិកម្មបែបពាណិជ្ជកម្ម ការចម្លងជំងឺ និងសត្វល្អិតចង្រៃ ដែលរួមមាន ប្រភេទរុក្ខជាតិ ឬសត្វ ដែលរាតត្បាត ត្រូវហាមឃាត់ ក្នុង

របៀងអភិរក្សជីវៈចម្រុះទាំងអស់ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ការអនុវត្តសកម្មភាពដែលបង្កការខូចខាត ឬគ្រោះថ្នាក់ដែលត្រូវហាមឃាត់ រួមមាន ៖

ក- ការដកចេញ ឬបំផ្លិចបំផ្លាញគំនូសសម្គាល់ព្រំប្រទល់ ឬបង្គោលសម្គាល់ព្រំប្រទល់ផ្លូវការ ឬការដាក់ជំនួសនូវគំនូសសម្គាល់ព្រំប្រទល់ ឬបង្គោលសម្គាល់ព្រំប្រទល់ឯកជន ។

ខ- ការប្រមូល ផល និងអនុផលព្រៃឈើ ផលិតផលជលផល និងធនធានធម្មជាតិ នៅក្នុងលក្ខណៈមួយ ដែលរំលោភបំពានលើសិទ្ធិដែលមានការទទួលស្គាល់ ឬបានអនុញ្ញាតដោយច្បាប់ និងផែនការគ្រប់គ្រង ឬដោយបុគ្គលដែលគ្មានលិខិតអនុញ្ញាតដែលមានសុពលភាព ។

គ- ការកាប់ឆ្ការរំលំ គ្រៀវ កាប់បំផ្លាញ ឬបំពុល រុក្ខជាតិ ឬដើមឈើ ឬគាស់រំលើងគល់ឈើដោយគ្មានលិខិតអនុញ្ញាតដែលមានសុពលភាព ។

ឃ- ការចាប់ ប្រមាញ់ ប្រមូល និងយាយីរំខានស៊ុតសត្វព្រៃ កូនសត្វ និងសត្វស្លាបតាមគ្រប់មធ្យោបាយ ។

ង- ការបំផ្លាញគុណភាពទឹកគ្រប់រូបភាព ការដាក់ថ្នាំបំពុល ការប្រើសារធាតុគីមី ការបោះបង់ចោលសំណល់រឹង និងរាវចូលក្នុងទឹក ឬលើដី និងការប្រើប្រាស់ឧបករណ៍ឆក់ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីការការពារ ការអភិរក្ស និងការគ្រប់គ្រងសត្វព្រៃ នៃមាតិកាទី៥នៃគន្ថីនេះ ។

ច- ការយកអន្ទាក់ ឬសម្ភារៈផលិតអន្ទាក់ អង្គប់ កាំភ្លើងបាញ់សត្វ និងសម្ភារៈផ្សេងទៀត ដែលប្រើប្រាស់ក្នុងការបំផ្លាញ ឬសម្លាប់សត្វព្រៃ នៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស

ឆ- ការប្រមាញ់សត្វព្រៃនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។

ជ- ការស្តុកទុក ការទិញ និងការលក់ ការកាន់កាប់ ការធ្វើពាណិជ្ជកម្ម ការបង្កាត់ពូជ ការរក្សាទុក ការថែរក្សាឲ្យស្ថិតស្ថេរ ការដឹកជញ្ជូន ការប្រើប្រាស់ ការស្តុក និងការប្រើប្រាស់ដទៃទៀតនៃសត្វព្រៃ មានចែងក្នុងបទប្បញ្ញត្តិស្តីពីការការពារ ការអភិរក្ស និងការគ្រប់គ្រងសត្វព្រៃ នៃមាតិកាទី៥នៃគន្ថីនេះ ។ ឈ- ការបំផ្លាញព្រៃធម្មជាតិ វាលស្មៅធម្មជាតិ ដីសើម រុក្ខជាតិនានា និងទីជម្រកសត្វព្រៃ ។

ញ- ការនាំយកចូល ឬការលែងឲ្យពពួកសត្វ ឬរុក្ខជាតិ រួមមាន គោក្របី បសុសត្វ និងឆ្កែចូលទៅក្នុងតំបន់ស្នូល ឬតំបន់អភិរក្ស ។

ដ- ការបង្កាត់ពូជនៃប្រភេទសត្វព្រៃ ឬមច្ឆាជាតិ ។

ឋ- ការអនុវត្តនូវការនេសាទខុសច្បាប់ ការធ្វើឲ្យខូចខាតដល់ធនធានធម្មជាតិ ទាំងក្នុងដែនទឹកសាប និងទឹកប្រៃ ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ ទន្លេ និងដីសើម ។

ឌ- ការបង្កើតមូលដ្ឋានសម្រាប់ការកែច្នៃខ្លឹមច័ន្ទន៍ ដើមម្រះព្រៅ វល្លិរមៀត ឬអនុផលព្រៃឈើផ្សេងទៀត និងការធ្វើវារីវប្បកម្មទឹកសាប ទឹកប្រៃ ដែលអាចបង្កការបំពុល ឬផលប៉ះពាល់បែបបំផ្លិចបំផ្លាញ ចំពោះជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ។

ឍ- សកម្មភាពរុករករ៉ែ រួមមាន ការស្ទាបស្ទង់ ការធ្វើតេស្ត ការរុករក និងការទាញយករ៉ែ នៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។

ណ- ការបូម ឬការទាញយកខ្សាច់ និងរ៉ែ ឬធនធានផ្សេងទៀត ពីទន្លេ និងច្រាំងទន្លេ ឬតំបន់ឆ្នេរ នៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។

ត- ការអភិវឌ្ឍទំនប់ទឹក ឬធារាសាស្ត្រខ្នាតតូច នៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។

**មាត្រា៣៣៥** ._ ការហាមឃាត់ចំពោះការកែច្នៃ និងប្រតិបត្តិការ

ការកែច្នៃផលនិងអនុផលធនធានធម្មជាតិ ការបង្កើតនិងដំណើរការមូលដ្ឋានរោងអារជ្រៀកឈើ រោងចក្រកែច្នៃឈើ សិប្បកម្មកែច្នៃឈើ សិប្បកម្មកែច្នៃផល អនុផលធនធានធម្មជាតិ និងឡគ្រប់ប្រភេទ នៅក្នុងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវហាមឃាត់យ៉ាងតឹងរ៉ឹង លើកលែងតែរោងចក្រកែច្នៃអនុផលព្រៃឈើដែលគ្រប់គ្រង និងរក្សាដោយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលអាចអនុញ្ញាតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ។ ប៉ុន្តែ ការកែច្នៃវល្លិរមៀត និងម្រះព្រៅ ត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹង នៅក្នុងគ្រប់កន្លែងទាំងអស់នៃរបៀងអភិរក្សជីវៈចម្រុះទាំងអស់ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ការបង្កើតប្រតិបត្តិការនៃការចាប់ចង ការចិញ្ចឹម ការស្តុក ការបង្កាត់ពូជ ការថែរក្សា ឬការចិញ្ចឹមសត្វព្រៃក្នុងគោលបំណងធ្វើពាណិជ្ជកម្ម ឬសម្រាប់គោលបំណងក្រៅពីការអភិរក្សដទៃៗទៀត ដែលស្ថិតនៅក្នុង ឬនៅក្នុងចម្ងាយ៥គីឡូម៉ែត្រ នៃរបៀងអភិរក្សជីវៈចម្រុះ និងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវហាមឃាត់យ៉ាងតឹងរ៉ឹង ។

ការដឹកជញ្ជូនធនធានធម្មជាតិដែលប្រមូលបានដោយខុសច្បាប់ នៅក្នុងតំបន់គ្រប់គ្រងទាំងអស់នៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវហាមឃាត់ ។ ការដឹកជញ្ជូនធនធានធម្មជាតិនៅក្នុងតំបន់គ្រប់គ្រងទាំងអស់នៃតំបន់ទាំងនេះ ត្រូវហាមឃាត់ ។

**មាត្រា៣៣៦** ._ ការប្រមូលជ័រឈើ

ការប្រមូលផលផលជ័រឈើ នៅក្នុងតំបន់អភិរក្ស ឬតំបន់ប្រើប្រាស់ដោយចីរភាពនៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវហាមឃាត់ដោយគ្មានលិខិតអនុញ្ញាតដែលមានសុពលភាព ។

លិខិតអនុញ្ញាតក្នុងការប្រមូលផលផលជ័រឈើអាចអនុវត្តបានចំពោះបុគ្គលគ្រប់រូបគ្រប់ ប៉ុន្តែចំពោះការចូលទៅកាន់តំបន់អភិរក្សនិងតំបន់ប្រើប្រាស់ដោយចីរភាព គឺតម្រូវមានការត្រួតពិនិត្យពីអាជ្ញាធរមានសមត្ថកិច្ច ។

លិខិតអនុញ្ញាតក្នុងការប្រមូលផលផលជ័រឈើ អនុញ្ញាតដល់អ្នកប្រើប្រាស់ដែលកំណត់អត្តសញ្ញាណច្បាស់លាស់ ក្នុងការប្រមូលផលផលជ័រឈើនៅក្នុងតំបន់ជាក់លាក់នៅក្នុងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្របតាមសិទ្ធិអ្នកប្រើប្រាស់តាមបែបប្រពៃណីរបស់សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច ។

រូបវន្តបុគ្គលដែលមានបំណងរក្សាទុកនូវលិខិតអនុញ្ញាតក្នុងការប្រមូលផលផលជ័រឈើត្រូវដាក់បញ្ជូនពាក្យសុំជាលាយលក្ខណ៍អក្សរទៅកាន់មន្ទីរបរិស្ថានខេត្ត ។

ការដាក់ពាក្យសុំលិខិតអនុញ្ញាតអាចផ្តល់ជូនដោយអ្នកដាក់ពាក្យណាម្នាក់ទៅកាន់ការិយាល័យឃុំ ដែលត្រូវផ្ទេរពាក្យសុំបែបនេះ ទៅកាន់ប្រធានមន្ទីរបរិស្ថានខេត្ត និងនាយករបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

នៅក្នុងរយៈពេល ១ (មួយ) ខែនៃការទទួលបានពាក្យសុំ ពាក្យសុំប្រមូលជ័រឈើសម្រាប់តំបន់អភិរក្សនៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ  នឹងត្រូវបានពិនិត្យ និងទទួលបានការឯកភាព នៅក្នុងករណីសមស្រប និងត្រូវចេញលិខិតអនុញ្ញាតដោយប្រធានមន្ទីរបរិស្ថានខេត្ត និងនាយករបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលពាក់ព័ន្ធ ។

លិខិតអនុញ្ញាតត្រូវផ្តល់ជូន ដោយយោគយល់ ចំពោះសមាជិកនៃសហគមន៍មូលដ្ឋានទាំងឡាយណា ដែលបានប្រមូលជ័រឈើជាផ្នែកមួយនៃជីវភាពរស់នៅរបស់ខ្លួនរួចទៅហើយ នៅពេលអនុម័តក្រមនេះ ។

គ្មានលិខិតអនុញ្ញាតក្នុងការប្រមូលផលផលជ័រឈើដែលត្រូវចេញទៅឲ្យបុគ្គលណាមួយ ដែលធ្លាប់បានធ្វើសកម្មភាពខុសច្បាប់នៅក្នុងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសោះឡើយ ។

គ្មានលិខិតអនុញ្ញាតក្នុងការប្រមូលផលផលជ័រឈើ ដែលត្រូវចេញទៅឲ្យបុគ្គលណាមួយដែលប្រធានមន្ទីរបរិស្ថានខេត្ត និងនាយករបៀងអភិរក្សជីវៈចម្រុះ ឬនាយកតំបន់ការពារធម្មជាតិ មានហេតុ

ផលសមរម្យក្នុងការជឿជាក់ ឬមានភស្តុតាងដើម្បីបញ្ជាក់ថា បុគ្គលនោះបានចូលរួមនៅក្នុង ឬមានការពាក់ព័ន្ធជាមួយនឹងការប្រមាញ់លក្ខណៈអាជីវកម្ម និងការធ្វើពាណិជ្ជកម្មសត្វព្រៃនោះឡើយ ។

ការផ្ទេរលិខិតអនុញ្ញាត ក្នុងការប្រមូលផលជ័រឈើពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ត្រូវហាមឃាត់ ។

ការផ្ទេរលិខិតអនុញ្ញាតក្នុងការប្រមូលផលជ័រឈើគឺមានសុពលភាពរយៈពេល១ (មួយ)ឆ្នាំ បន្ទាប់មកលិខិតអនុញ្ញាតនេះ ត្រូវធ្វើការពិនិត្យឡើងវិញ និងបន្តសារជាថ្មីជារៀងរាល់ឆ្នាំ ។

នៅក្នុងករណីលិខិតអនុញ្ញាតក្នុងការប្រមូលផលជ័រឈើមានការបាត់បង់ អ្នកកាន់កាប់លិខិតនោះត្រូវជូនដំណឹងដល់មន្ទីរបរិស្ថានខេត្ត និងនាយករបៀងអភិរក្សជីវៈចម្រុះ ឬនាយកតំបន់ការពារធម្មជាតិ ប្រសិនបើសមរម្យ និងបញ្ឈប់រាល់សកម្មភាពប្រមូលផលជ័រឈើ រហូតដល់លិខិតអនុញ្ញាតថ្មីត្រូវបានផ្តល់ជូន ។

នាយករបៀងអភិរក្សជីវៈចម្រុះ នាយកតំបន់ការពារធម្មជាតិ ឬនាយកមន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត អាចផ្អាក ឬលុបចោលនូវរាល់លិខិតអនុញ្ញាតក្នុងការប្រមូលផលជ័រឈើ ដែលត្រូវបានផ្តល់ជូនដោយអនុលោមតាមមាតិកានេះ ដែលត្រូវកត់ត្រាទុកជាលាយលក្ខណ៍អក្សរ ដោយមានមូលហេតុសមរម្យ ។

**មាត្រា៣៣៧ ._** ទេសចរណ៍ធម្មជាតិលក្ខណៈពាណិជ្ជកម្ម

រូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍ ដែលអនុវត្តទេសចរណ៍ធម្មជាតិលក្ខណៈពាណិជ្ជកម្ម នៅក្នុងព្រៃនៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវមានកិច្ចព្រមព្រៀងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ឬគណៈកម្មការគ្រប់គ្រងរួមគ្នា សម្រាប់សកម្មភាព និងការរៀបចំទេសចរណ៍ធម្មជាតិដែលបានស្នើសុំ ។

នៅពេលពិចារណាអំពីសំណើសុំប្រតិបត្តិការទេសចរណ៍ធម្មជាតិបន្ថែម ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាជ្ញាធរថ្នាក់ក្រោមជាតិ គណៈកម្មការគ្រប់គ្រងរួមគ្នា ត្រូវពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងសហគមន៍ទាំងឡាយណាដែលកំពុងធ្វើប្រតិបត្តិការទេសចរណ៍ធម្មជាតិរួចទៅហើយ នៅក្នុងតំបន់ជុំវិញនៃសកម្មភាពស្នើសុំ ។

## ជំពូកទី៧
## ការអង្កេតតាមដាន និងការវាយតម្លៃការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ

**មាត្រា៣៣៨ ._** ការអង្កេតតាមដានផែនការគ្រប់គ្រង

ផែនការគ្រប់គ្រងសម្រាប់គ្រប់របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវមានសូចនាករដែលបញ្ជាក់ពីការសម្រេចបាននូវគោលបំណងអភិរក្ស តម្លៃប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅ។ របាយការណ៍ស្តីពីការវឌ្ឍនភាពនៃការសម្រេចបាននូវសូចនករទាំងនេះ ត្រូវធ្វើការរាយការជូនដល់សាធារណៈជននៅរាងរាល់ ២ (ពីរ) ឆ្នាំម្តង ។

**មាត្រា៣៣៩** ._ ការគ្រប់គ្រង និងការអង្កេតតាមដានការពង្រឹងការអនុវត្តច្បាប់

គ្រប់របៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងអស់ ត្រូវដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធ និងប្រព័ន្ធប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់គ្រប់គ្រង និងអង្កេតតាមដានលើកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងការអនុវត្តច្បាប់ និងការយាមល្បាត ។ របាយការណ៍នៃសកម្មភាពបែបនេះត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបានជារៀងរាល់ឆ្នាំ ។

## មាតិកាទី៣
## ការគ្រប់គ្រងរួមគ្នា លើធនធានធម្មជាតិ
## ជំពូកទី១
## ការបង្កើតក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា

**មាត្រា៣៤០** ._ វិសាលភាពនៃការអនុវត្ត

មាតិកានេះអនុវត្តចំពោះដំបន់ទាំងឡាយ ដែលអាចទទួលបានការអនុវត្តតាមការគ្រប់គ្រងរួមគ្នា។ គ្រប់របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហគមន៍តំបន់ការពារធម្មជាតិ  សមាគមន៍ព្រៃឈើ សហគមន៍នានាដែលបានដាក់ពាក្យស្នើសុំការកំណត់ជាសហគមន៍ព្រៃឈើពីមុនរួចហើយ ឬដែលបានត្រៀមឯកសារបំណងនឹងដាក់ពាក្យស្នើសុំការកំណត់ជាសហគមន៍ព្រៃឈើ  ដីសាធារណៈរបស់រដ្ឋដទៃទៀតដែលមានតម្លៃអភិរក្ស និងតម្លៃប្រព័ន្ធអេកូឡូស៊ី ដីបម្រុងទុក របស់ជនជាតិដើមភាគតិច ឬដីជាលក្ខណៈប្រពៃណីដទៃទៀត ត្រូវមានសិទ្ធិទទួលបានការគ្រប់គ្រងស្របតាមគោលការណ៍នៃការគ្រប់គ្រងរួមគ្នាដូចមានចែងក្នុងមាតិកានេះ។

**មាត្រា៣៤១** ._ គោលការណ៍

ការគ្រប់គ្រងរួមគ្នាគឺជាវិធានការគ្រប់គ្រងធនធានធម្មជាតិ និងធនធានដី ក៏ដូចជាការអភិវឌ្ឍ

ជីវភាពរស់នៅ ដែលក្នុងនោះអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋានត្រូវបែងចែកតួនាទី និងការទទួលខុសត្រូវលើការប្រើប្រាស់ប្រកបដោយនិរន្តរភាព ការគ្រប់គ្រង និងកិច្ចការពារធនធានធម្មជាតិ និងជីវៈចម្រុះ ប្រកបដោយភាពច្បាស់លាស់ ។

**មាត្រា៣៤២** ._ ការបន្តយន្តការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍

តំបន់គ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ មានជាអាទិ៍ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍នេសាទដែលមានស្រាប់ និងដែលកំពុងស្ថិតក្នុងដំណើរការទទួលការឯកភាព បន្ទាប់ពីមានការអនុម័តលើក្រមនេះ ត្រូវមានសភាពផ្លូវច្បាប់ដូចដើម រហូតដល់ពេលមានការដាក់បញ្ចូល ឬកែប្រែទៅតាមក្របខ័ណ្ឌ តំបន់គ្រប់គ្រង និងការពាររួមគ្នា ជាពេលដែលយន្តការទាំងនេះត្រូវបានទទួលស្គាល់ដោយស្វ័យប្រវត្តិថា ជាគុផ្សំនៃតំបន់គ្រប់គ្រង និងការពាររួមគ្នា នឹងត្រូវស្ថិតនៅក្រមវិធាន និងលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងរួមគ្នា ។

## ជំពូកទី២
## ការអនុវត្តក្របខ័ណ្ឌនៃការគ្រប់គ្រងរួមគ្នា

**មាត្រា៣៤៣** ._ សិទ្ធិក្នុងការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា

សហគមន៍មូលដ្ឋាន ក្រុមនានានៃសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច រួមទាំងសមាគមន៍ និងអង្គភាពរបស់ពួកគេផងដែរ ដោយរួមសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ត្រូវមានសិទ្ធិរៀបចំ និងអនុវត្តការគ្រប់គ្រងរួមគ្នា នៅតាមរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ដីសាធារណៈរបស់រដ្ឋដទៃទៀត ឬដីដែលមានតម្លៃអភិរក្ស តម្លៃប្រព័ន្ធអេកូឡូស៊ី និងដីដែលបានធ្វើចំណាត់ថ្នាក់ បទប្បញ្ញត្តិស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ស្របតាមមាតិកាទី៩ នៃគន្ថីនេះ ។

**មាត្រា៣៤៤** ._ ការរៀបចំការគ្រប់គ្រងរួមគ្នា

ក្នុងដំណើរការរៀបចំការគ្រប់គ្រងរួមគ្នា តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងអាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវធ្វើការកំណត់នានាក្នុងការរៀបចំការគ្រប់គ្រងរួមគ្នា ដែលក្នុងនោះរួមមានការរៀបចំផែនការប្រើប្រាស់ដីទៅតាមតំបន់ និងការកំណត់តំបន់គ្រប់គ្រងសម្រាប់តំបន់គ្រប់គ្រង និងការពាររួមគ្នា លក្ខខណ្ឌតម្រូវនៃភាពស្របច្បាប់របស់សហគមន៍មូលដ្ឋានក្រោមក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា និងលក្ខខណ្ឌតម្រូវដទៃទៀតស្តីពីការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣៤៥** ._ ការឧបត្ថម្ភទៅលើការគ្រប់គ្រងរួមគ្នា

ក្នុងដំណើរការរៀបចំការគ្រប់គ្រងរួមគ្នា តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងអាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវចូលរួមសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន បុគ្គលិកពាក់ព័ន្ធពីតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ និងស្ថាប័នពាក់ព័ន្ធដទៃៗទៀត ដែលត្រូវផ្តល់ជំនួយដល់អ្នកស្នើសុំ ក្នុងការត្រៀមលក្ខណៈសម្រាប់ការរៀបចំនានា ។

ក្នុងដំណើរការរៀបចំការគ្រប់គ្រងរួមគ្នា តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងអាជ្ញាធរមូលដ្ឋាន ត្រូវប្រើប្រាស់គំនិតផ្នែកបច្ចេកទេសពីដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលជាបណ្តាអង្គការអភិរក្សនានាដែលពាក់ព័ន្ធទៅនឹងការអភិរក្សតំបន់ទាំងនេះ និងអ្នកពាក់ព័ន្ធដទៃៗទៀត ។ តួនាទីជាក់លាក់សម្រាប់ភាគីដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ការអនុវត្តតាមក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា អាចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីការរៀបចំការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣៤៦** ._ ខ្លឹមសារនៃការរៀបចំការគ្រប់គ្រងរួមគ្នា

ការរៀបចំការគ្រប់គ្រងរួមគ្នា ត្រូវចែងអំពី៖

១- រចនាសម្ព័ន្ធនៃគណៈកម្មការគ្រប់គ្រងរួមគ្នា ។

២- សមាជិកភាព និងសិទ្ធិក្នុងការបោះឆ្នោតរបស់គ្រប់សមាជិកសហគមន៍គ្រប់គ្រងរួមគ្នា ដោយយកចិត្តទុកដាក់ដល់ទំនាក់ទំនង និងការចំណុះគ្នារវាងជនជាតិដើមភាគតិចទៅលើធនធាន និងដីប្រពៃណី ។

៣- ការរៀបចំផែនការប្រើប្រាស់ដី និងការកំណត់តំបន់គ្រប់គ្រងសម្រាប់តំបន់គ្រប់គ្រងរួមគ្នា និងផែនការគ្រប់គ្រងរួមគ្នាដែលបានស្នើសុំ ។ រាល់ការរៀបចំផែនការប្រើប្រាស់ដី ការកំណត់តំបន់គ្រប់គ្រង និងការរៀបចំផែនការគ្រប់គ្រង ដែលត្រូវធ្វើឡើងតាមមាតិកានេះ ត្រូវធ្វើឡើងដោយមានលក្ខណៈស្របគ្នាទៅនឹងការរៀបចំផែនការប្រើប្រាស់ដី ការកំណត់តំបន់គ្របគ្រង និងការរៀបចំផែនការគ្រប់គ្រង ដែលមានកាលពីមុន ដែលមានជាបន្តបន្ទាប់ និងដែលត្រូវធ្វើឡើងតាមមាតិកាទី២ ការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ នៃគន្ថីនេះ ។

៤- ការរៀបចំផែនការគ្រប់គ្រងដែលបានដាក់ស្នើ ត្រូវមានលក្ខណៈគ្រប់គ្រាន់ដើម្បីតាក់តែងជាស្តង់ដារមួយ ស្របតាមធនធាន និងសមត្ថភាពរបស់មូលដ្ឋាន ដែលឆ្លុះបញ្ចាំងពី

ចំណេះដឹង និងទស្សនវិស័យរបស់តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងរដ្ឋបាលថ្នាក់ក្រោមជាក់ ដែលជាអ្នកទទួលខុសត្រូវបឋមសម្រាប់ការអនុវត្តការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣៤៧ ._** ការពិនិត្យឡើងវិញទៅលើការរៀបចំពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវផ្តល់ការពិនិត្យឡើងវិញទៅលើការរៀបចំទាំងអស់ស្របតាមលក្ខខណ្ឌជ្រើសរើស និងនីតិវិធីជាក់លាក់ និងត្រូវធ្វើការឆ្លើយតបជាមតិទៅកាន់អ្នកស្នើសុំក្នុងរយៈពេល៣ (បី) ខែ បន្ទាប់ពីបានទទួលសំណើ ។ មាតិកាដែលត្រូវផ្តល់សម្រាប់ការឆ្លើយតបមានដូចតទៅ៖

ក- សេចក្តីសម្រេចចាប់ផ្តើមអនុវត្តការគ្រប់គ្រងរួមគ្នានៅក្នុងតំបន់ដែលបានស្នើសុំ ។

ខ- សេចក្តីសម្រេចចាប់ផ្តើមអនុវត្តការគ្រប់គ្រងរួមគ្នាក្នុងតំបន់ដែលបានស្នើសុំ បន្ទាប់ពីបានបញ្ចូលមតិរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានចូលទៅក្នុងការរៀបចំនានា។

គ- សេចក្តីណែនាំដល់អ្នកស្នើសុំឲ្យធ្វើការកែប្រែសម្រាប់ការលើកសំណើជាថ្មី ។

ករណីត្រូវលើកសំណើជាថ្មី ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវផ្តល់ការពិនិត្យឡើងវិញទៅលើការរៀបចំដែលបានកែប្រែទាំងឡាយក្នុងរយៈពេល ៣ (បី)ខែ បន្ទាប់ពីបានទទួល ។

រាល់ឯកសារអំពីការរៀបចំ ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរួមគ្នា រួមទាំងការពិនិត្យឡើងវិញដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវធ្វើផងដែរនោះ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៣៤៨ ._** កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា

បន្ទាប់ពីមានការឯកភាពទៅលើការរៀបចំនានាពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរួមគ្នា គណៈកម្មការគ្រប់គ្រងរួមគ្នា ត្រូវចុះកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នាជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និង/ឬអាជ្ញាធរថ្នាក់ក្រោមជាតិ ។ កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ត្រូវមានចែងអំពីតួនាទី និងការទទួលខុសត្រូវច្បាស់លាស់របស់គ្រប់អ្នកពាក់ព័ន្ធទៅនឹងតំបន់គ្រប់គ្រង និងការពាររួមគ្នាដែលបានទទួលការឯកភាពនោះ ។

កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ត្រូវមានរយៈពេលមិនកំណត់ ដែលត្រូវអនុវត្តទៅតាមលក្ខណ្ឌដូចបានកំណត់ក្នុងមាតិកានេះតែប៉ុណ្ណោះ ។

រាល់ឯកសារពាក់ព័ន្ធទៅនឹងការឯកភាពទៅលើការរៀបចំនានាពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា និងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ត្រូវធ្វើការដាក់ជូនដល់សាធារណជនស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣នៃក្រមនេះ។

**មាត្រា៣៤៩** ._ ការទទួលស្គាល់ស្របច្បាប់ទៅលើកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា

ការឯកភាពលើកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា បង្កើតបានជាការទទួលស្គាល់តាមផ្លូវច្បាប់សម្រាប់តំបន់គ្រប់គ្រង និងការពាររួមគ្នាដែលពាក់ព័ន្ធជាអង្គភាពរដ្ឋបាល ។ ទ្រព្យសម្បត្តិដែលបង្កើតឡើងនៅក្នុងតំបន់គ្រប់គ្រង និងការពាររួមគ្នា រក្សាបាននូវឋានៈស្របច្បាប់ ក្នុងរយៈពេលមួយដែលមិនកំណត់ ដែលអាស្រ័យទៅតាមការអនុវត្តតួនាទីគ្រប់គ្រងរួមគ្នាបានពេញលេញ ។

ការឯកភាពលើកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ត្រូវស្ថិតនៅក្រោមគណៈកម្មការគ្រប់គ្រងរួមគ្នា ដែលមានឋានៈជានីតិបុគ្គល ដែលនីតិបុគ្គលមានសិទ្ធិ និងកាតព្វកិច្ច មានជាអាទិ៍ សិទ្ធិក្នុងការគ្រប់គ្រងថវិកា សិទ្ធិចុះកិច្ចព្រមព្រៀង មានប្រតិបត្តិការ និងសិទ្ធិបង្កើតចំណូល ។

**មាត្រា៣៥០** ._ មូលនិធិសម្រាប់ការគ្រប់គ្រងរួមគ្នា

មូលនិធិពិសេសសម្រាប់ការគ្រប់គ្រងរួមគ្នាមួយ ត្រូវបង្កើតឡើងដើម្បីឧបត្ថម្ភដល់សកម្មភាពនៃការគ្រប់គ្រងរួមគ្នានានា ដែលស្ថិតនៅក្នុងតំបន់គ្រប់គ្រង និងការពាររួមគ្នានីមួយៗ ។ មូលនិធិនេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការគ្រប់គ្រងរួមគ្នា នៃតំបន់គ្រប់គ្រង និងការពាររួមគ្នា និងត្រូវទទួលការបង្កើត និងគ្រប់គ្រងប្រកបដោយតម្លាភាព ស្របតាមបទប្បញ្ញត្តិនៃគន្ថីទី៨ មាតិកាទី២ នៃក្រមនេះ ។

គណៈកម្មការគ្រប់គ្រងរួមគ្នា អាចទទួល និងប្រមូលចំណូលថវិកាពីប្រភពដែលមានជាអាទិ៍៖

១- មូលនិធិសង្គម និងបរិស្ថាន ។

២- ប្រភពឯកជន និងសាធារណៈជាច្រើន ។

៣- ពន្ធនានា ការយកថ្លៃជួល ថ្លៃប្រើប្រាស់ ថ្លៃកំសាន្ត ឬការយកថ្លៃចូលទស្សនាជាដើម ។

៤- មូលនិធិ ទាយជ្ជទាន ឬការឧបត្ថម្ភនានា ។

៥- ហិរញ្ញប្បទានដោយនិរន្តរភាព និងការបង់ថ្លៃសម្រាប់ធនធានធម្មជាតិ

៥-ហិរញ្ញប្បទានដែលមាននិរន្តរភាព និងការបង់ថ្លៃសេវាប្រព័ន្ធសេវាអេកូឡូស៊ី និងសេវាធនធានធម្មជាតិ។

**មាត្រា៣៥១** ._ ការប្រើប្រាស់ចំណូល បន្ទុកចំណាយ ឬវិភាគទាននានា

ការប្រើប្រាស់ចំណូល បន្ទុកចំណាយ ឬវិភាគទាននានា ដែលទទួលបានតាមរយៈការអនុវត្តការគ្រប់គ្រងរួមគ្នា ត្រូវប្រើសម្រាប់តែផលប្រយោជន៍របស់សហគមន៍មូលដ្ឋាននានា ដែលស្ថិតនៅតំបន់គ្រប់គ្រង និងការពាររួមគ្នា សម្រាប់ការជ្រោមជ្រែងបន្តដល់ការអនុវត្តទៅលើការគ្រប់គ្រងរួមគ្នា

និងសម្រាប់ការអភិរក្សទាំងឡាយនៃតំបន់គ្រប់គ្រង និងការពាររួមគ្នា និងតំបន់ដែលនៅជាប់ទាំងឡាយ ដែលត្រូវទទួលការអភិរក្ស ។ វិធីសាស្ត្រច្បាស់លាស់ក្នុងការបែងចែកចំណូល បន្ទុក ចំណាយ ឬវិភាគទាននានា ត្រូវមានកំណត់នៅក្នុងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ។

ចំណូល ថ្លៃ ឬវិភាគទាននានា ដែលទទួលបានដោយការគ្រប់គ្រងទៅលើតំបន់ការពារធម្មជាតិ និងគ្រប់គ្រងរួមគ្នា ត្រូវទទួលបានការលើកលែងពន្ធ អាករ បន្ទុក និងថ្លៃផ្សេងៗ ដូចបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា៣៥២** ._ ការគ្រប់គ្រងទៅលើការអនុវត្តការគ្រប់គ្រងរួមគ្នា

ការអនុវត្តទៅលើការគ្រប់គ្រងរួមគ្នា ត្រូវស្ថិតនៅក្រោមការពិនិត្យតាមដាន និងការមើលការខុសត្រូវ ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ គណៈកម្មការគ្រប់គ្រងរួមគ្នា ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដែលពណ៌នាអំពីសកម្មភាព និងលទ្ធផលទាំងឡាយ និងបង្ហាញពីសមិទ្ធិផលនៃគោលដៅ និងសូចនករណ៍នានា ។

**មាត្រា៣៥៣** ._ ការបញ្ចប់កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវមានសិទ្ធិក្នុងការបញ្ចប់កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ឬលុបចោលតំបន់ការពារធម្មជាតិ និងគ្រប់គ្រងរួមគ្នា បន្ទាប់ពីបានកំណត់ថា ការគ្រប់គ្រងរួមគ្នា មិនត្រូវបានអនុវត្តស្របតាមផែនការនៃការគ្រប់គ្រងដែលបានទទួលការឯកភាព ហើយការមិនអនុលោមតាមបែបនោះ នាំឲ្យមានការបំពានលក្ខខណ្ឌនៃផែនការគ្រប់គ្រងរួមគ្នា ឬមានការបំពានច្បាប់ធ្ងន់ធ្ងរបានកើតឡើងក្នុងពេលអនុវត្តការគ្រប់គ្រងរួមគ្នា ។

នៅមុនពេលបញ្ចប់សិទ្ធិក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា ភាគីត្រូវជួបគ្នាដោះស្រាយបញ្ហាដោយស្មារតីស្មោះត្រង់ និងសុចរិត ។ គណៈកម្មការគ្រប់គ្រងរួមគ្នាដែលទទួលបន្ទុក ត្រូវមានសិទ្ធិប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចបញ្ចប់កិច្ចព្រមព្រៀង ស្របតាមបទប្បញ្ញត្តិនៃគន្ថីទី៩ នៃក្រមនេះ ។

**មាត្រា៣៥៤** ._ លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងរួមគ្នា

អាជ្ញាធរថ្នាក់ក្រោមជាតិក្រសួង ស្ថាប័នទទួលបន្ទុកលើវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីសេចក្តីលម្អិតនៃការគ្រប់គ្រងរួមគ្នា មានជាអាទិ៍ តួនាទីជាលម្អិត សិទ្ធិ និងការទទួលខុសត្រូវ លក្ខខណ្ឌជ្រើសរើស និងនីតិវិធីនៃការពិនិត្យឡើងវិញទៅលើការរៀបចំនានានៃការគ្រប់គ្រងរួមគ្នា នីតិវិធី និងលក្ខណ្ឌជ្រើសរើសនៃការកំណត់តំបន់គ្រប់គ្រង នៃតំបន់ការពារធម្មជាតិ និងគ្រប់គ្រងរួមគ្នា ការរៀបចំផែនការ និងការគ្រប់គ្រង យន្តការនៃការផ្តល់មូលនិធិ សមាជិកភាព ការបែងចែងប្រយោជន៍

ការដោះស្រាយវិវាទ ការរាយការណ៍ និងជំហានអនុវត្តផ្សេងៗទៀតនៅក្នុងរយៈពេល ២ (ពីរ) ឆ្នាំ បន្ទាប់ពីក្រមនេះចូលជាធរមាន ។

**មាត្រា៣៥៥** ._ ការលើកកម្ពស់ និងការឧបត្ថម្ភដល់ការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ត្រូវចាត់វិធានការចាំបាច់ក្នុងការលើកកម្ពស់ និងការឧបត្ថម្ភដល់ការអនុវត្តការគ្រប់គ្រងរួមគ្នា នៅក្នុងតំបន់ទាំងឡាយដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ឬនៅក្នុងតំបន់ដែលខ្លួនមានសមត្ថកិច្ចរួមជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និង/ឬ អាជ្ញាធរថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ។

**មាត្រា៣៥៦** ._ សកម្មភាពដែលបានហាមឃាត់

ហាមដាច់ខាតមិនឲ្យនីតិបុគ្គល ឬរូបវន្តបុគ្គលណាមួយប្រព្រឹត្តល្មើសនឹងកិច្ចព្រមព្រៀងស្ដីពីការគ្រប់គ្រងរួមគ្នា ដែលបានឯកភាព ឬសិទ្ធិ និងការទទួលខុសត្រូវទាំងឡាយដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនោះឡើយ ។

## ជំពូកទី៣
## រយៈពេលនៃការគ្រប់គ្រងរួមគ្នា និងសិទ្ធិដីធ្លី

**មាត្រា៣៥៧** ._ ប័ណ្ណសម្គាល់សិទ្ធិសម្ភូហភាពនៃដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា

បន្ទាប់ពីមានការកំណត់ជា តំបន់គ្រប់គ្រង និងការពាររួមគ្នា ស្របតាមមាតិកានេះ សហគមន៍ទាំងឡាយដែលមានទីតាំងនៅក្នុងតំបន់គ្រប់គ្រង និងការពាររួមគ្នា ត្រូវមានសិទ្ធិទទួលបានប័ណ្ណសម្គាល់សិទ្ធិសម្ភូហភាពនៃដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា ហើយប័ណ្ណនេះ ត្រូវមានសុពលភាពទៅតាមរយៈពេលដែលបានកំណត់សម្រាប់តំបន់គ្រប់គ្រង និងការពាររួមគ្នា ។

មិនថាមានលក្ខខណ្ឌតម្រូវ ឬការចុះបញ្ជីបន្ថែមណាមួយត្រូវធ្វើឡើងក្ដី សិទ្ធិនៃប័ណ្ណសម្គាល់សិទ្ធិសម្ភូហភាពនៃដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា មិនអាចត្រូវបានបំពានដោយស្ថាប័នឯកជន ឬស្ថាប័នសាធារណៈណាមួយដោយគ្មានការយល់ព្រមជាមុនពីសហគមន៍នោះឡើយ ។

**មាត្រា៣៥៨** ._ ខ្លឹមសារនៃសិទ្ធិក្រោមប័ណ្ណសម្គាល់សិទ្ធិសម្ភូហភាពនៃដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា

សិទ្ធិនានាក្រោមប័ណ្ណសម្គាល់សិទ្ធិសម្ភូហភាពនៃដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា មានជាអាទិ៍ សិទ្ធិស្នាក់នៅ សិទ្ធិអភិរក្ស សិទ្ធិគ្រប់គ្រង របស់សហគមន៍នៅក្នុងតំបន់គ្រប់គ្រង និងការពាររួមគ្នា និងសិទ្ធិក្នុងការទទួលប្រយោជន៍ពីការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ស្របតាមសិទ្ធិដី

ធ្លីជាលក្ខណៈប្រពៃណី និងទំនៀមទម្លាប់នៃការប្រកបរបរចិញ្ចឹមជីវិតតាមបែបប្រពៃណី នៅក្នុងតំបន់គ្រប់គ្រង និងការពាររួមគ្នា និងសិទ្ធិក្នុងការហាមឃាត់ ឬដាក់កំហិតលើសិទ្ធិប្រើប្រាស់តំបន់ របស់មនុស្សពីក្រៅតំបន់ ស្របតាមផែនការគ្រប់គ្រងរួមគ្នាដែលបានទទួលការអនុម័ត ។

សិទ្ធិនានាក្រោមប័ណ្ណសម្គាល់សិទ្ធិសម្ងហាភាពនៃដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា មិនមែនជាសិទ្ធិក្នុងការលក់ ឬផ្ទេរកម្មសិទ្ធិទៅលើដីទាំងឡាយ ដែលត្រូវបានកំណត់ចូលទៅក្នុងតំបន់គ្រប់គ្រង និងការពាររួមគ្នានោះទេ ។

**មាត្រា៣៥៩** ._ អាជ្ញាយុកាលនៃសិទ្ធិក្រោមប័ណ្ណសម្គាល់សិទ្ធិសម្ងហាភាពនៃដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា

រយៈពេលនៃសិទ្ធិនានាក្រោមប័ណ្ណសម្គាល់សិទ្ធិសម្ងហាភាពនៃដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា ត្រូវកំណត់ទៅតាមរយៈពេលនៃតំបន់គ្រប់គ្រង និងការពាររួមគ្នាដែលមានរយៈពេលមិនកំណត់ និងការកំណត់លក្ខខណ្ឌតាមការបំពេញតាមការទទួលខុសត្រូវនៃការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣៦០** ._ ការដកហូតនូវសិទ្ធិក្រោមប័ណ្ណសម្គាល់សិទ្ធិសម្ងហាភាពនៃដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា

ត្រូវដកហូតសិទ្ធិក្រោមប័ណ្ណសម្គាល់សិទ្ធិសម្ងហាភាពនៃដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា ពីសហគមន៍ទាំងឡាយដែលមិនបានបំពេញតាមផែនការគ្រប់គ្រងរួមគ្នា វិធាន និងបទប្បញ្ញត្តិដទៃទៀតនៃការគ្រប់គ្រងរួមគ្នា ប៉ុន្តែ ការមិនបានអនុលោមតាមផែនការគ្រប់គ្រងរួមគ្នា វិធាន និងបទប្បញ្ញត្តិដទៃទៀតនៃការគ្រប់គ្រងរួមគ្នា របស់ភាគីណាមួយ ក្រៅពីសហគមន៍ ដូចជាការមិនបានអនុលោមតាមដែលនាំឲ្យមានការបញ្ចប់កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា តាមមាត្រា៣៥៣ នៃក្រមនេះ ជាដើម មិនត្រូវនាំឲ្យមានការដកហូតនូវសិទ្ធិក្រោមប័ណ្ណសម្គាល់សិទ្ធិសម្ងហាភាពនៃដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា របស់សហគមន៍នោះទេ ។

មិនអាចមានការផ្ទេរសិទ្ធិនានាក្រោមប័ណ្ណសម្គាល់សិទ្ធិសម្ងហាភាពនៃដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា ទៅឲ្យបុគ្គលណាមួយ ឬសហគមន៍ណាផ្សេង ក្រៅពីបុគ្គល និងសហគមន៍ក្នុងតំបន់គ្រប់គ្រង និងការពាររួមគ្នាឡើយ ។

**មាត្រា៣៦១** ._ សិទ្ធិបន្ថែម

សិទ្ធិក្រោមប័ណ្ណសម្គាល់សិទ្ធិសម្ងហាភាពនៃដីក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា គឺជាសិទ្ធិបន្ថែមទៅនឹងសិទ្ធិដទៃៗទៀត របស់សហគមន៍ជនជាតិដើមភាគតិចដែលអាចទទួលបាន ដូចជា សិទ្ធិនានាក្រោមបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ។

**មាត្រា៣៦២ ._** ផលប៉ះពាល់ទៅលើការកំណត់តំបន់ការពារធម្មជាតិដទៃទៀត

រាល់ការបង្កើតរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដទៃទៀតនាពេលបច្ចុប្បន្ន ឬអនាគត នៅតំបន់ទាំងឡាយដែលមានជនជាតិដើមភាគតិចរស់នៅ ឬមានការពាក់ព័ន្ធបែបសម្ងហភាព ឬប្រយោជន៍សម្ងហភាព មិនត្រូវប៉ះពាល់ដល់សិទ្ធិដីធ្លីនាបច្ចុប្បន្ន ឬអនាគតរបស់ជនជាតិដើមភាគតិចដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានកំណត់ ។

## មាតិកាទី៤
## ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៣៦៣ ._** វិសាលភាព

មាតិកានេះអនុវត្តចំពោះព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ដែលជាតំបន់ដែលត្រូវបានកំណត់នៅក្នុងតំបន់ព្រៃឈើ ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ។ ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាពជាដែនព្រៃដែលមានទីតាំងនៅក្រៅរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ។ ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាពមិនសំដៅដល់ដីសាធារណៈរបស់រដ្ឋទាំងឡាយណាដែលមានតម្លៃអភិរក្ស និងតម្លៃប្រព័ន្ធអេកូឡូស៊ី ដីរបស់ជនជាតិដើមភាគតិច និងដីបម្រុងទុកជាលក្ខណៈប្រពៃណីដទៃទៀត។

**មាត្រា៣៦៤ ._** គោលដៅ

គោលដៅនៃមាតិកានេះគឺដើម្បីកំណត់ន័យនៃក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព រួមមានការគ្រប់គ្រង ការប្រមូលផល ការអភិវឌ្ឍទ្រង់ទ្រាយតូច ការប្រើប្រាស់លក្ខណៈពាណិជ្ជកម្ម និងការអភិរក្សតំបន់ព្រៃឈើដើម្បីថែរក្សានិងជំរុញសមត្ថភាពរស់រាននៃសេដ្ឋកិច្ចរយៈពេលយូរអង្វែង និងផលប្រយោជន៍សង្គម ដែលរួមមានសុខុមាលភាពរបស់ប្រជាជន គុណភាពបរិស្ថាន និងទីផ្សារ និងទិន្នផលប្រកបដោយនិរន្តរភាព ។

**មាត្រា៣៦៥ ._** គោលបំណង

ព្រៃឈើដែលគ្រប់គ្រងប្រកបដោយនិរន្តរភាពត្រូវបានគ្រប់គ្រងស្របតាមគោលបំណង និងគោលការណ៍ដែលមានចែងក្នុងគន្ថីទី១ មាតិកាទី១ និងគោលបំណងជាក់លាក់ដូចខាងក្រោម៖

ក- បម្រុងទុកនូវផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន ។

ខ- អភិរក្ស លើកស្ទួយ និងស្តារតម្លៃជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ។

គ- ធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅក្នុងតំបន់ និងបេតិកភណ្ឌវប្បធម៌ និង

ឃ- លើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

## ជំពូកទី២
## អង្គភាពដែលមានការទទួលខុសត្រូវ

**មាត្រា៣៦៦**._ តួនាទី និងការទទួលខុសត្រូវ

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចទាក់ទងនឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងអាជ្ញាធរថ្នាក់ក្រោមជាតិពាក់ព័ន្ធត្រូវ៖

ក- គ្រប់គ្រងការអនុវត្តការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដែលរួមមានការរៀបចំផែនការ ការផ្តល់លិខិតអនុញ្ញាត ការគ្រប់គ្រង និងការត្រួតពិនិត្យទំលាប់ល្អៗទាក់ទងនឹងព្រៃឈើប្រកបដោយនិរន្តរភាព ។

ខ- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីសម្រាប់ការពង្រឹងការអនុវត្តប្រកបដោយប្រសិទ្ធភាព ។

គ- សិក្សា និងប្រមូលទិន្នន័យព្រៃឈើទាក់ទងនឹងគោលដៅវិទ្យាសាស្ត្រ និងកត្តាសេដ្ឋកិច្ច សង្គម និងបរិស្ថាន ដើម្បីបង្កើតម៉ាទ្រីក និងស្តង់ដារ និងបង្កើតផែនការគ្រប់គ្រងសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

ឃ- ធានានូវការវាយតម្លៃពេញលេញ និងទាន់ពេលវេលាសម្រាប់ព្រៃឈើទាំងអស់ និងការអភិវឌ្ឍផ្សេងៗទាក់ទងទៅនឹងសកម្មភាពដែលអាចមានផលប៉ះពាល់សង្គម និងបរិស្ថានគួរឲ្យកត់សម្គាល់ មុននឹងការឯកភាពទៅលើសកម្មភាពទាំងនោះ ។

ង- រៀបចំសំណើសម្រាប់ការបង្កើត និងការកែប្រែ ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ដូចដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាតម្រូវ ឬស្របទៅនឹង អនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិ និងតំបន់ ។

ច- លើកកម្ពស់ការអប់រំ និងការផ្សព្វផ្សាយព័ត៌មានទៅកាន់សាធារណជនដើម្បីបង្ហាញពីសារសំខាន់នៃការគ្រប់គ្រង ការថែរក្សា និងការការពារធនធានព្រៃឈើ ក៏ដូចជាដើម្បីលើក

ទឹកចិត្តឲ្យមានការចូលរួមក្នុងការអភិរក្ស និងការការពារធនធានធម្មជាតិក្នុងព្រៃឈើ ដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព ។

ឆ- ស្តារឡើងវិញនូវសេវាអេកូឡូស៊ី ស្តីពីដីព្រៃរិចរិល និងដាំព្រៃឈើឡើងវិញនូវព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ដើម្បីលើកកម្ពស់ និងសម្រេចបាននូវ រេដបូក និងទិសដៅអភិរក្សដទៃៗទៀត ដោយពិចារណាអំពីលក្ខណៈវិន្និច្ឆ័យ ដូចជា គម្របព្រៃឈើ និងកម្ពស់អប្បបរិមានៃដើមឈើក្នុងពេលវាធំ ក៏ដូចជាការបែងចែកថ្នាក់ព្រៃឈើ ។

ជ- កំណត់ន័យច្បាស់លាស់នៃស្ថានភាពស្របច្បាប់នៃដីទាំងអស់ដែលត្រូវបានចាត់ជាព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ដែលរួមមានសិទ្ធិកាន់កាប់ដីជាប្រពៃណីនិងសិទ្ធិប្រើប្រាស់ដែលមានស្រាប់ដែលរួមមានព្រំដី ។

ឈ- បង្កើតនិងអនុវត្តវិធានការ ដែលរួមមានការសហការជាមួយក្រសួង ស្ថាប័នដទៃទៀត ដើម្បីការពារព្រៃឈើជាលក្ខណៈប្រព័ន្ធពីការប្រើប្រាស់ធនធាន ដែលគ្មានការអនុញ្ញាត ឬមិនស្របច្បាប់ ការតាំងទីលំនៅ និងសកម្មភាពមិនស្របច្បាប់ដទៃទៀត ។

ញ- ផ្សព្វផ្សាយជាសាធារណៈ និងអនុវត្តតម្លាភាពពេញលេញនៅគ្រប់ទិដ្ឋភាពទាំងអស់នៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

ដ- ធ្វើឲ្យប្រសើរឡើងនូវការពង្រឹងការអនុវត្តតាមរយៈការសហការជាមួយក្រសួង ស្ថាប័នអាជ្ញាធរថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

ឋ- ធ្វើការអង្កេតតាមដាន និងការរៀបចំរបាយការណ៍បទល្មើស ។

ឌ- ពង្រាយនូវសមត្ថភាពរហ័ស ទាក់ទងនឹងព័ត៌មានបទល្មើសព្រៃឈើ និង

ឍ-ទាក់ទងជាមួយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចនៅគ្រប់ទិដ្ឋភាពទាំងអស់នៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

**មាត្រា៣៦៧ ._** ភារកិច្ចក្នុងការអភិរក្ស និងស្តារឡើងវិញ

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងអាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវថែរក្សា អភិរក្ស និង/ឬស្តារឡើងវិញនូវតម្លៃបរិស្ថាន និងសេវាប្រព័ន្ធអេកូឡូស៊ី ដែលស្ថិតក្នុងព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព និងត្រូវចៀសវាង ជួសជុល ឬកាត់បន្ថយផលប៉ះពាល់បរិស្ថានជាអវិជ្ជមានចំពោះ៖

ក- ព្រៃឈើដែលមានការប៉ះពាល់ និងផ្លូវទឹក ។

ខ- គុណភាពបរិស្ថាននៃដី ទឹក ខ្យល់ ។

គ- គុណភាពអេកូឡូស៊ីនៃដី និងប្រព័ន្ធអេកូឡូស៊ី ។

ឃ- សមត្ថភាពរស់រាន នៃប្រភេទសត្វ និងរុក្ខជាតិ ជាពិសេសប្រភេទសត្វ និងរុក្ខជាតិកម្រ ឬដែលមានតាមតំបន់ ។

**មាត្រា៣៦៨** ._ ភារកិច្ចផ្សេងទៀត

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនិងអាជ្ញាធរថ្នាក់ក្រោមជាតិត្រូវធានា៖

ក- ផលិតផលត្រូវបានប្រមូលនៅកម្រិត ឬក្រោមកម្រិតដែលអាចមាននិរន្តរភាពជាអចិន្ត្រៃយ៍ ។

ខ- ការកែច្នៃក្នុងមូលដ្ឋាន សេវា និងតម្លៃបន្ថែមត្រូវបានប្រើ នៅពេលដែលវាមាន ។

គ- ការចូលរួមក្នុងកម្មវិធីផ្តល់វិញ្ញាបនបត្រផលិតផល និងការគ្រប់គ្រងព្រៃឈើអន្តរជាតិ ដោយមានជំនួយពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ឃ- ការអនុវត្តនូវទំលាប់ នៃនីតិវិធីរក្សាភស្តុតាងត្រូវបានអនុវត្តសម្រាប់ផលិតផលដែលមិនត្រូវបានប្រើសម្រាប់ការប្រើប្រាស់ក្នុងស្រុក ។

## ជំពូកទី៣
## ការធ្វើចំណាត់ថ្នាក់ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព

**មាត្រា៣៦៩** ._ ការធ្វើចំណាត់ថ្នាក់

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពដែលរួមមានអាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវកំណត់អត្តសញ្ញាណ ធ្វើចំណាត់ថ្នាក់និងធ្វើផែនទីព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ។ ការធ្វើចំណាត់ថ្នាក់ត្រូវផ្អែកលើផែនទី ទិន្នន័យវិទ្យាសាស្ត្រ ការវាយតម្លៃ និងការរៀបចំផែនការ និងត្រូវពិចារណា៖

ក- មុខងារអេកូឡូស៊ី សេដ្ឋកិច្ច សង្គមនៃព្រៃឈើ ។

ខ- ភាពសម្បូរបែបនៃព្រៃឈើ ដែលកំណត់ដោយរចនាសម្ព័ន្ធសារពើរុក្ខជាតិ និងចរិតលក្ខណៈបែបជលវិទ្យា និងដីស្រទាប់ក្រោម ។

គ- ទិសដៅកាត់បន្ថយការបំភាយពីការកាប់ព្រៃឈើ និងការរិចរិលព្រៃឈើ និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ការអភិរក្ស និងការលើកស្ទួយ សន្និធិកាបូនព្រៃឈើតាមរយៈរេដបូក ។

ឃ- លក្ខខណ្ឌពាក់ព័ន្ធទាំងអស់ដែលស្របទៅតាមកិច្ចព្រមព្រៀងអន្តរជាតិ និងទិសដៅនិងគោលនយោបាយអភិវឌ្ឍន៍ជាតិ ។

ការកំណត់អត្តសញ្ញាណ ការធ្វើផែនទី និងដំណើការនៃការធ្វើចំណាត់ថ្នាក់ត្រូវធ្វើឡើងតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុងគន្លឹទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្លឹទី១ មាតិកាទី៣ នៃក្រមនេះ។

ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ត្រូវធ្វើចំណាត់ថ្នាក់ជា ព្រៃឯកជន ព្រៃផ្តល់ផលដោយនិរន្តរភាព ព្រៃស្តារឡើងវិញ ព្រៃសន្និធិ និង ដីព្រៃសម្បទានសេដ្ឋកិច្ច ៖

១- ព្រៃឯកជន៖ ជាប្រភេទដីព្រៃទាំងឡាយ ដែលស្ថិតក្រោមប័ណ្ណកាន់កាប់ដីឯកជន។

២- ព្រៃផ្តល់ផលដោយនិរន្តរភាព៖ ជាដីសាធារណៈរបស់រដ្ឋ មានជាអាទិ៍ដីព្រៃវិចរិល ចម្ការព្រៃឈើ និងដីដាំព្រៃឡើងវិញ និងដីព្រៃទាំងឡាយដែលអាចធ្វើការដាំដុះព្រៃបាន។ សកម្មភាពពាណិជ្ជកម្មទាំងឡាយដែលមានទីតាំងស្ថិតនៅក្នុងដីព្រៃផ្តល់ផលដោយនិរន្តរភាព ត្រូវមានលិខិតអនុញ្ញាតជាមុន។

៣- ព្រៃស្តារឡើងវិញ៖ ជាដីសាធារណៈរបស់រដ្ឋ និងជាដីព្រៃវិចរិល ដែលអាចថែទាំឡើងវិញ ធ្វើការស្តារ និងអភិរក្សបាន។

៤- ព្រៃសន្និធិ៖ ជាដីសាធារណៈរបស់រដ្ឋទាំងឡាយណា ដែលដីព្រៃបម្រុងទុកសម្រាប់ផលិតកម្ម និងការអភិរក្សនាពេលអនាគត។

៥- ដីព្រៃសម្បទានសេដ្ឋកិច្ច

ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព មិនមែនជា៖

ក- ដីដែលស្ថិតនៅក្នុងរបៀងអភិរក្សជវៈចម្រុះ ឬតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ខ- រាល់ដីសាធារណៈរបស់រដ្ឋ ដែលមានតម្លៃអភិរក្ស ឬតម្លៃប្រព័ន្ធអេកូឡូស៊ីរួចហើយ។

គ- ដីបម្រុងទុករបស់ជនជាតិដើមភាគតិចជាលក្ខណៈប្រពៃណីដទៃទៀត ឬដីរបស់ជនជាតិដើមភាគតិច ។

ប្រភេទដីខាងលើនេះ មិនត្រូវបានធ្វើចំណាត់ថ្នាក់ស្របតាមមាតិកានេះ ឬត្រូវបានរាប់បញ្ចូលទៅក្នុងផែនការប្រើប្រាស់ដីធ្លី នៃព្រៃដែលត្រូវបានគ្រប់គ្រងដោយនិរន្តរភាពឡើយ ស្របតាមមាតិកានេះ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចលើការគ្រប់គ្រងនិរន្តរភាពព្រៃឈើ អាចបង្កើតចំណាត់ថ្នាក់ព្រៃឈើបន្ថែម សម្រាប់ព្រៃដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព មានជាអាទិ៍ ព្រៃកំសាន្ត ព្រៃសហគមន៍ផ្តល់ផល ព្រៃពិសោធន៍ និងព្រៃស្តារឡើងវិញ។ ចំណាត់ថ្នាក់ព្រៃឈើបន្ថែម ត្រូវទទួលការវាយតម្លៃស្របតាមគោលការណ៍ និរន្តរភាព និងគោលដៅនៃផែនការគ្រប់គ្រង។

**មាត្រា៣៧០** ._ ផែនទីប្រើប្រាស់ដីសម្រាប់ព្រៃដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព

ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងដោយមានកិច្ចពិគ្រោះយោបល់ជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ និងសហគមន៍ពាក់ព័ន្ធ និងជនជាតិដើមភាគតិច ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវវាយតម្លៃព្រំប្រទល់ និងវាស់ព្រំប្រទល់ព្រៃឈើដែលគ្រប់គ្រងប្រកបដោយនិរន្តរភាព ដោយយោងតាមការបែងចែកថ្នាក់និងការបង្កើតផែនទីប្រើប្រាស់ដីព្រៃឈើ ដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព ។

ផែនទីប្រើប្រាស់ដីនេះត្រូវបញ្ចប់មុនការផ្តល់ជូនលិខិតអនុញ្ញាត ផលិតកម្ម ឬការប្រើប្រាស់ដទៃទៀតក្នុងព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព និងត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុងគន្ថីទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៣៧១** ._ ការផ្លាស់ប្តូរក្នុងការបែងចែកថ្នាក់ព្រៃឈើដែលត្រូវគ្រប់គ្រងប្រកបដោយនិរន្តរភាព

រាល់សំណើដើម្បីធ្វើការកែប្រែការបែងចែកថ្នាក់ក្នុងព្រៃឈើដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព ឬផ្នែកណាមួយ ត្រូវរៀបចំឯកសារដែលចែងលម្អិតដូចខាងក្រោម៖

ក- ហេតុផលវិទ្យាសាស្ត្រ និងសេដ្ឋកិច្ចសង្គម សម្រាប់ការកែប្រែការបែងចែកថ្នាក់ដែលស្នើ ។

ខ- កិច្ចប្រឹងប្រែងដែលធ្វើឡើងដើម្បីរក្សាស្ថានភាពនៃការបែងចែកថ្នាក់នាពេលថ្មីៗ ។

គ- លក្ខណៈដែលការកែប្រែការបែងចែកថ្នាក់នឹងលើកស្ទួយជីវភាពរស់នៅ និងសិទ្ធិជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន ។

ឃ- លក្ខណៈនៃការកើនឡើងដែលរំពឹងទុកក្នុងតម្លៃអភិរក្សនិងប្រព័ន្ធអេកូឡូស៊ី ឬមធ្យោបាយដែលការបាត់បង់តម្លៃអភិរក្សនិងប្រព័ន្ធអេកូឡូស៊ីនឹងត្រូវបានកាត់បន្ថយ ។

ង- ការពិគ្រោះយោបល់សមស្របជាមួយអ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ និងសហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ ដែលរួមមានការយល់ព្រមជាមុនពីសហគមន៍នោះទៅលើការកែប្រែដែលបានស្នើឡើង ។

ច- ព័ត៌មានផ្សេងៗដូចខាងលើ ក្នុងគោលបំណងដើម្បីធ្វើឲ្យសំណើមានលក្ខណៈត្រឹមត្រូវ ។

រាល់សំណើដើម្បីកែប្រែការបែងចែកថ្នាក់ព្រៃឈើ ដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព ឬផ្នែកណា ត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុងគន្លឺទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្លឺទី១ មាតិកាទី៣ នៃក្រមនេះ ។

បន្ទាប់មក ការឯកភាពលើការកែសម្រួលបែបនេះ ត្រូវទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ជាទម្រង់នៃសេចក្តីសម្រេចដែលបញ្ជាក់ពីការពិចារណាដោយយកចិត្តទុកដាក់លើឯកសារ ដែលបានផ្តល់ឲ្យ ។

## ជំពូកទី៤
## ការរៀបចំផែនការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាព

**មាត្រា៣៧២** ._ ការបង្កើតផែនការប្រើប្រាស់ប្រកបដោយនិរន្តរភាព

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចសម្រាប់ការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាពត្រូវបង្កើត និងអនុវត្តផែនការប្រើប្រាស់ប្រកបដោយនិរន្តរភាពរយៈពេល៥(ប្រាំ) ឆ្នាំ និងផែនការគ្រប់គ្រងរយៈពេល៥(ប្រាំ)ឆ្នាំ សម្រាប់ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ។ គ្រប់ផែនការទាំងអស់ត្រូវស្របទៅនឹងមាតិកានេះ ។

**មាត្រា៣៧៣** ._ ការពិចារណាសម្រាប់ផែនការប្រើប្រាស់ប្រកបដោយនិរន្តរភាព

ផែនការប្រើប្រាស់ប្រកបដោយនិរន្តរភាពត្រូវពិចារណាទៅលើកត្តាដូចខាងក្រោមៈ

ក- ប្រភេទ និងគុណភាពព្រៃឈើ ដោយផ្អែកលើទិន្នន័យសារពើភណ្ឌ ។

ខ- តម្លៃអេកូឡូស៊ីនៃព្រៃឈើ ។

គ- ទីតាំងរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន និងតម្រូវការសម្រាប់ជីវភាពរស់នៅរបស់ពួកគេ ។

ឃ- ផ្នែកខាងក្រៅនៃប្រតិបត្តិការ វិជ្ជមាន និងអវិជ្ជមាន ។

**មាត្រា៣៧៤ ._** ខ្លឹមសារនៃផែនការប្រើប្រាស់ប្រកបដោយនិរន្តរភាព

ផែនការប្រើប្រាស់ប្រកបដោយនិរន្តរភាពត្រូវរួមមានកត្តាដូចខាងក្រោមៈ

ក- ការគ្រប់គ្រងតំបន់ដីសម្បទានសេដ្ឋកិច្ចសកម្ម ។

ខ- ការប្រើប្រាស់ទម្លាប់រុក្ខវប្បកម្ម ដែលរួមមានការប្រមូលផលប្រចាំឆ្នាំដែលអនុញ្ញាតឲ្យ នៅក្នុងតំបន់គ្រប់គ្រងផ្សេងៗគ្នា ។

គ- ការដាំដើមឈើ ការដាំព្រៃឈើឡើងវិញ និងចំការក្នុងតំបន់រិចរិល ។

ឃ- ការអង្កេតតាមដានព្រៃឈើ និងការពង្រឹងការអនុវត្តច្បាប់ ។

ង- ទំនាក់ទំនងជាមួយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចក្នុងការគ្រប់គ្រងព្រៃឈើ ។

**មាត្រា៣៧៥ ._** សម្បទានដីសេដ្ឋកិច្ច

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ត្រូវធានាថារាល់សម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ត្រូវបានគ្រប់គ្រងស្របតាមគោលបំណងនិងក្របខ័ណ្ឌនៃមាតិកានេះ ។

បន្ថែមទៅលើការគ្រប់គ្រងតាមរយៈក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព រាល់សម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ដែលជាប់គ្នា ស្ថិតនៅក្នុងផ្នែកមួយក្នុងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវស្របទៅនឹងការចាត់ចែងទៅលើការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធដែលទទួលខុសត្រូវទៅលើតំបន់ទាំងនោះ ឬតំបន់នានា និងចាត់ចែងក្នុងលក្ខណៈស្របគ្នាជាមួយគោលបំណងគ្រប់គ្រងការអភិរក្សទូលំទូលាយនៃតំបន់ទាំងនោះ ឲ្យបានកាន់តែទូលំទូលាយបំផុតតាមដែលអាចធ្វើទៅបាន ។

## ជំពូកទី៥
## លិខិតអនុញ្ញាត និងការឯកភាព

**មាត្រា៣៧៦ ._** សកម្មភាពដែលពាក់ព័ន្ធ

រាល់រូបវន្តបុគ្គល ឬនីតុបុគ្គលដែលស្នើឲ្យធ្វើសកម្មភាពណាមួយខាងក្រោមក្នុងផ្នែកណាមួយនៃព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ត្រូវដាក់ពាក្យដើម្បីទទួលបាននូវលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នពាក់ព័ន្ធៈ

ក- ផលិត ផល និងអនុផលឈើពីការប្រើប្រាស់ផ្នែកពាណិជ្ជកម្ម ។

ខ- គ្រប់គ្រងផល និងអនុផលឈើពីការប្រើប្រាស់ផ្នែកពាណិជ្ជកម្ម ។

គ- ប្រមូលផល និងការលក់ផល និងអនុផលឈើពីការប្រើប្រាស់សម្រាប់គោលដៅពាណិជ្ជកម្ម ស្របតាមកូតាប្រមូលផលប្រចាំឆ្នាំ ដែលត្រូវរួមមានប្រាក់កក់ដើម្បីធានានូវការបង់ថ្លៃប្រាក់កម្រៃ និងបុព្វលាភ ដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ឃ- ដឹកជញ្ជូនផល និងអនុផលឈើ ស្របតាម កូតាដឹកជញ្ជូនប្រចាំឆ្នាំ ដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ង- នាំចេញផល និងអនុផលឈើ ស្របតាម កូតានាំចេញប្រចាំឆ្នាំ ដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ច- ប្រើប្រាស់ព្រៃឈើដើម្បីការស្រាវជ្រាវវិទ្យាសាស្ត្រ ឬបច្ចេកទេស ដែលរួមមានការទាញយកសម្រាប់គោលបំណងស្រាវជ្រាវរុក្ខវប្បកម្ម ឬការរីកចម្រើនព្រៃឈើ ការអប់រំ ឬការបណ្តុះបណ្តាលកសិកម្ម គោលបំណងធារាសាស្ត្រ និងកសិកម្ម ដោយផ្អែកលើកិច្ចព្រមព្រៀងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក និងឧត្តុនិយម ការបង្កើតសួនរុក្ខជាតិថ្នាលសម្រាប់ដំណុះពូជ ឬស្ថានីយ៍ពិសោធន៍ ឬដើម្បីបង្កើតការកំសាន្ត ទេសចរណ៍ធម្មជាតិ ឬភាពយន្ត ឬភាពយន្ត     ឯកសារ ។

ឆ- បង្កើតកន្លែងស្តុកដើម្បីលក់ និងចែកចាយផល និងអនុផលឈើ ។

ជ- បង្កើត កន្លែងកែច្នៃសម្រាប់ឧស្សាហកម្មព្រៃឈើ រោងអារឈើ ឬផល និងអនុផលឈើ ។

ឈ- បង្កើតឡដុតផ្សេងៗដែលប្រើប្រាស់ផល និងអនុផលឈើ ។

ញ- ផលិតធ្យូង និងឈើអុស ។

ដ- ធ្វើសកម្មភាពផ្នែកពាណិជ្ជកម្មផ្សេងៗស្របទៅនឹងក្រមនេះ ។

គ្រប់ពាក្យសុំលិខិតអនុញ្ញាតស្របទៅនឹងមាត្រានេះ ត្រូវដាក់ឲ្យសាធារណជនអាចរកបានស្របតាមសិទ្ធិទទួលបានព័ត៌មានបរិស្ថាននៃក្រមនេះ ។

ពាក្យសុំលិខិតអនុញ្ញាតណាដែលដាក់បញ្ជូនមកស្របតាមមាត្រានេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពី បទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៣៧៧** ._ កាពិចារណាទៅលើពាក្យសុំលិខិតអនុញ្ញាត

ក្រសួង ស្ថាបន័ពាក់ព័ន្ធ ដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពទាក់ទងនឹងការពិនិត្យទៅលើពាក្យសុំលិខិតអនុញ្ញាត ត្រូវពិចារណាទៅលើចំណុចដូចខាង  ក្រោមៈ

ក- ភាពសមស្របនៃគម្រោងស្នើសុំជាមួយនឹងគោលបំណងអភិរក្សទេសភាពនៅជុំវិញទីនោះ ។

ខ- កម្រិតដែលគម្រោងស្នើសុំគាំទ្រ និងបង្កើន ជីវភាពរស់នៅក្នុងតំបន់ ។

គ- កម្រិតដែលគម្រោងស្នើសុំបម្រុងទុកនូវតម្លៃជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ។

ឃ- ភាពស៊ីគ្នានៃគម្រោងស្នើសុំ និងផែនការប្រើប្រាស់ដីថ្នាក់ជាតិនិងតំបន់ ។

ង- ភាពស៊ីគ្នានៃគម្រោងស្នើសុំ និងផែនការប្រើប្រាស់ប្រកបដោយនិរន្តរភាព សម្រាប់ព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ដែលសកម្មភាពស្នើសុំតាំងនៅ ។

ច- កម្រិតដែលគម្រោងស្នើសុំប្រើប្រាស់ទម្លាប់ដ៏ល្អប្រសើរបំផុត នៅក្នុងរាល់ទិដ្ឋភាពទាំងអស់នៃការរៀបចំ ប្រតិបត្តិការ និងការស្តារឡើងវិញដែលបានស្នើឡើង ។

**មាត្រា៣៧៨** ._ ការពិគ្រោះយោបល់

មុននឹងធ្វើការសម្រេចលើពាក្យសុំលិខិតអនុញ្ញាត ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវធ្វើការពិគ្រោះយោបល់សមស្របមួយជាមួយដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ភាគីពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ និងសហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ និងបង្ហាញការរៀបចំហិរញ្ញវត្ថុ និងប្រាក់ចំណូលដែលប៉ាន់ប្រមាណទុកពីសកម្មភាពពាណិជ្ជកម្មទាំងនោះទៅកាន់អ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ទាំងអស់ ។

ដំណើរការនៃពាក្យសុំលិខិតអនុញ្ញាត និងការឯកភាពពេញលេញ និងសេចក្តីលម្អិតនៃសកម្មភាពពាណិជ្ជកម្មដែលស្នើសុំនិងបានឯកភាពរួច ក្នុងព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ត្រូវផ្សព្វផ្សាយឲ្យបានពេញលេញ និងស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនៅក្នុង គន្ថីទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១មាតិកាទី៣នៃក្រមនេះ ។

សេចក្តីលម្អិតនៃដំណើរការនៃពាក្យសុំលិខិតអនុញ្ញាត និងការឯកភាពពេញលេញសម្រាប់គ្រប់សកម្មភាពទាំងអស់ក្នុងព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ត្រូវមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី៦
## សិទ្ធិអ្នកប្រើប្រាស់ជាប្រពៃណី

**មាត្រា៣៧៩ ._** គោលដៅ

សម្រាប់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលរស់នៅក្នុង ឬក្បែរព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព រដ្ឋត្រូវស្គាល់ និងធានានូវសិទ្ធិអ្នកប្រើប្រាស់ជាប្រពៃណីក្នុងព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព សម្រាប់គោលដៅ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា និងការរស់នៅដូចដែលកំណត់ក្នុងជំពូកនេះ ។

**មាត្រា៣៨០ ._** សិទ្ធិអ្នកប្រើប្រាស់ជាប្រពៃណី

សិទ្ធិអ្នកប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចសម្រាប់ផល និងអនុផលព្រៃឈើមិនតម្រូវឲ្យមានលិខិតអនុញ្ញាតនោះទេ ។ សិទ្ធិអ្នកប្រើប្រាស់ជាប្រពៃណីផ្សំទៅដោយ៖

ក- ការប្រមូលឈើងាប់ ការបេះផ្លែឈើព្រៃ ការប្រមូលទឹកឃ្មុំ ការយកជ័រទឹក និងការប្រមូលអនុផលព្រៃឈើដទៃៗទៀត ។

ខ- ការប្រើប្រាស់ឈើដើម្បីសាងសង់ផ្ទះ រោងសត្វ របង និងធ្វើឧបករណ៍កសិកម្ម ។

គ- ការកាត់ស្មៅ និងការព្រលែងបសុសត្វឲ្យស៊ីអាហារក្នុងព្រៃ ។

ឃ- ការប្រើប្រាស់ផល និងអនុផលព្រៃឈើឲ្យស្របតាមការប្រើប្រាស់ជាលក្ខណៈគ្រួសារជាប្រពៃណី ។

ង- សិទ្ធិក្នុងកាដោះដូរ ឬលក់អនុផលព្រៃឈើមិនតម្រូវឲ្យមានលិខិតអនុញ្ញាតនោះទេ ប្រសិនបើសកម្មភាពទាំងនោះមិនបង្កការគំរាមកំហែងគួរឲ្យកត់សម្គាល់ចំពោះ និរន្តរភាពព្រៃ ។ អតិថិជន ឬតតិយជន ដែលទទួលបានអនុផលព្រៃឈើពីសហគមន៍មូលដ្ឋានសម្រាប់គោលដៅពាណិជ្ជកម្មត្រូវទទួលបានលិខិតអនុញ្ញាតស្របតាមមាតិកានេះ ។

## ជំពូកទី៧
## ផែនការ និងរបាយការណ៍គ្រប់គ្រងសកម្មភាពពាណិជ្ជកម្ម

**មាត្រា៣៨១ ._** វិសាលភាពនៃផែនការគ្រប់គ្រង

ផែនការគ្រប់គ្រងត្រូវបង្កើតឡើងសម្រាប់រាល់សកម្មភាពពាណិជ្ជកម្មទាំងអស់ដែលធ្វើឡើងចំពោះព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាពនីមួយៗ និងត្រូវសមាមាត្រទៅនឹងទំហំ អាំងតង់ស៊ីតេ និងហានិភ័យសកម្មភាពពាណិជ្ជកម្មទាំងនោះ ។ ផែនការគ្រប់គ្រងត្រូវអនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ដោយផ្អែកលើព័ត៌មានអង្កេតតាមដានដើម្បីលើកកម្ពស់ការគ្រប់គ្រងដែលអាចសម្រេចបាន ។

**មាត្រា៣៨២ ._** ខ្លឹមសារ នៃផែនការគ្រប់គ្រង

ផែនការគ្រប់គ្រងត្រូវៈ

ក- កំណត់ន័យនៃតំបន់ជាក់លាក់ ដែលអនុលោមទៅតាមសកម្មភាពពាណិជ្ជកម្ម ដែលរួមមានការពិពណ៌នា និងទីតាំងនៃសកម្មភាពជាក់លាក់ដែលគ្រោងទុក ។

ខ- កំណត់នូវ ទិសដៅ គោលបំណង និងធាតុចេញដែលត្រូវការ នៃសកម្មភាពពាណិជ្ជកម្ម ទាក់ទងនឹងធនធានដែលត្រូវបានប្រើប្រាស់ និងលក្ខណៈវិន្និច្ឆ័យសង្គម និងចំណូល ។

គ- កំណត់ទូនាទី និងការទទួលខុសត្រូវសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ។

ឃ- កំណត់កូតា សម្រាប់ការប្រមូលផលឈើ និងអនុផលឈើ ។

ង- កំណត់កម្មវិធី និងបន្ទាត់ពេលវាលាសម្រាប់ការអនុវត្ត ។

ច- កំណត់ថវិកា ។

ឆ- កំណត់ ការអនុវត្តការគ្រប់គ្រងដ៏ល្អបំផុត សម្រាប់ប្រើប្រាស់ និងសកម្មភាពដែលត្រូវចៀសវាង ដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ជ- កំណត់ការប្រើប្រាស់ដែលបានរៀបចំទុកនៃទម្លាប់អនុវត្តរុក្ខវប្បកម្ម ។

ឈ-កំណត់នីតិវិធីសម្រាប់វិញ្ញាបនបត្រ័ផលិតផលព្រៃឈើ ប្រសិនបើអាចអនុវត្តបាន។

ញ- កំណត់ការកែច្នៃនិង ការដឹកជញ្ជូន ផលិតផលព្រៃឈើ ។

ដ- កំណត់នីតិវិធីសម្រាប់ការអង្កេតតាមដានការវាយតម្លៃ និងការរៀបចំរបាយការណ៍ ។

**មាត្រា៣៨៣ ._** របាយការណ៍គ្រប់គ្រងព្រៃឈើ

ក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពជាប្រចាំឆ្នាំ ត្រូវរៀបចំរបាយការណ៍គ្រប់គ្រងព្រៃឈើស្តីពីការអនុវត្ត ផែនការគ្រប់គ្រងក្នុងព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ។

គ្រប់ផែនការប្រើប្រាស់ប្រកបដោយនិរន្តរភាព ផែនការគ្រប់គ្រង និងរបាយការណ៍គ្រប់គ្រងព្រៃឈើត្រូវដាក់ឲ្យសាធារណជនអាចរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៃគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

## ជំពូកទី៨
## ប្រាក់កម្រៃ និងបុព្វលាភស្តីពីផលព្រៃឈើ

**មាត្រា៣៨៤**._ ប្រាក់កម្រៃ និងបុព្វលាភ

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រមូលផល និងអនុផលឈើក្នុងគោលបំណងពាណិជ្ជកម្មក្នុងព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ត្រូវបង់ថ្លៃប្រាក់កម្រៃ និងបុព្វលាភ ទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចទាក់ទងនឹងព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាពព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាព ។

វិធានសម្រាប់ការវាយតម្លៃគុណភាព និងបរិមាណ ដែលរួមមានការតម្រូវការវាយតម្លៃមុននឹងធ្វើការដឹកជញ្ជូន វិធីសាស្ត្រក្នុងការបង់ថ្លៃ និងវិក័យប័ត្រប្រាក់ចំនូល ពីប្រាក់កម្រៃ និងបុព្វលាភ ទៅលើផល និងអនុផលឈើត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៣៨៥**._ ការចែកចាយឡើងវិញទៅកាន់សហគមន៍មូលដ្ឋាន

ផ្នែកមួយ នៃប្រាក់កម្រៃ និងបុព្វលាភ ដែលប្រមូលបានត្រូវបែងចែកឡើងវិញឲ្យសហគមន៍មូលដ្ឋានទៅតាម ចំនួនដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត នៃក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។ ចំណែកសេសសល់ពីប្រាក់កម្រៃ និងបុព្វលាភទាំងអស់ត្រូវដាក់ចូលក្នុងថវិកាជាតិ ។

**មាត្រា៣៨៦**._ សកម្មភាពដែលអាចអនុវត្តបាន

ការបង់ថ្លៃប្រាក់កម្រៃ និងបុព្វលាភ មិនតម្រូវសម្រាប់៖

ក- ការប្រមូលផល និងអនុផលឈើពីព្រៃឯកជន ។

ខ- ការប្រមូលផល និងអនុផលឈើដោយសហគមន៍មូលដ្ឋាន ដែលកំពុងប្រើប្រាស់សិទ្ធិអ្នកប្រើប្រាស់ជាប្រពៃណី ឬក្នុងសហគមន៍ព្រៃឈើដែលស្ថិតក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ ។

**មាត្រា៣៨៧**._ គោលដៅវិទ្យាសាស្ត្រ

ផល និងអនុផលឈើ ដែលប្រមូលបានមកពីព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាពសម្រាប់គោលដៅវិទ្យាសាស្ត្រ មិនតម្រូវថ្លៃប្រាក់កម្រៃ និងបុព្វលាភទេ ។

**មាត្រា៣៨៨**._ ពេលកំណត់ក្នុងការបង់ថ្លៃ

គ្រប់ប្រាក់កម្រៃ និងបុព្វលាភដែលអាចអនុវត្តបាន ត្រូវបង់មុននឹងការផ្ទេរ ឬលក់ផលព្រៃឈើឬសិទ្ធិទៅកាន់ភាគីទីបី ។

**មាត្រា៣៨៩**._ ការពន្យាពេលក្នុងការបង់ថ្លៃ

ប្រសិនបើអ្នកកាន់លិខិតអនុញ្ញាតមិនបង់ថ្លៃប្រាក់កម្រៃ និងបុព្វលាភ ទៅតាមកាលបរិច្ឆេទកំណត់ដែលព្រមព្រៀងគ្នា ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវមានអំណាចក្នុងការរឹបអូស ផល និងអនុផលឈើ និងឃាត់ផលទាំងនោះដាក់ជាទ្រព្យសម្បត្តិសាធារណៈរហូតដល់មានដំណោះស្រាយផ្នែកច្បាប់ទៅលើជម្លោះនោះ ។ ការពន្យាពេលក្នុងការបង់ថ្លៃប្រាក់កម្រៃ ឬបុព្វលាភ អាចត្រូវឯកភាពស្របតាមលក្ខណៈវិនិច្ឆ័យដូចបានរៀបរាប់ក្នុងលិខិតបទដ្ឋានគតិយុត្ត ដោយក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

**មាត្រា៣៩០**._ នីតិវិធីនៃការបង់ប្រាក់កម្រៃ

នីតិវិធីសម្រាប់ការបង់ប្រាក់កម្រៃត្រូវបង្កើតដោយលិខិតបទដ្ឋានគតិយុត្តមានសមត្ថកិច្ច ។

## ជំពូកទី៩
## យន្តការផ្សេងៗសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

**មាត្រា៣៩១**._ ការស្តារឡើងវិញ និងការលើកស្ទួយ

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវរក្សា និងលើកស្ទួយតម្លៃប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះនៃតំបន់ដែលមានទីតាំងស្ថិតក្នុងព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាពទាំងមូល ។

រាល់គម្រោងដែលត្រូវបានឯកភាពក្នុងព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាពមួយស្របតាមមាតិកានេះ ត្រូវរួមមានជាផ្នែកនៃប្រតិបត្តិការ ការស្តារឡើងវិញ ឬការដាំដើមឈើនៃតំបន់ដីព្រៃរិចរិលដែលមានទំហំស្មើ ជាសកម្មភាពពាណិជ្ជកម្មដែលត្រូវបានធ្វើឡើង ។

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវបង្កើតរចនាសម្ព័ន្ធប្រតិបត្តិការសំខាន់ដើម្បីលើកកម្ពស់ការស្តារឡើងវិញ និងការដាំដើមឈើព្រៃរិចរិល និងត្រូវបង្កើតយន្តការសមស្របក្នុងរយៈពេល០១ (មួយ) ឆ្នាំនៃការអនុម័តក្រមនេះ ។

**មាត្រា៣៩២**._ ការដាំដុះដើមឈើ

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវចេញ លិខិតបទដ្ឋានគតិយុត្ត ក៏ដូចជាកម្មវិធី និងការណែនាំផ្នែកបច្ចេកទេសដើម្បីកំណត់វិធានពិសេសស្តីពីការដាំដុះដើមឈើ ដើម្បីលើកទឹកចិត្តឯកបុគ្គលនិងអ្នកអភិវឌ្ឍគម្រោងក្នុងការដាំ និងរក្សាការដាំ

ដុះដើមឈើដែលអនុវត្តតាមគោលការណ៍ និងស្តង់ដារ សម្រាប់ការគ្រប់គ្រងព្រៃឈើប្រកប ដោយនិរន្តរភាព និងដែលសមស្របនឹងទិសដៅបរិស្ថានទេសភាព សង្គម សេដ្ឋកិច្ច និងធនធាន ។

**មាត្រា៣៩៣** ._ និរន្តរភាពផ្សិត និងឈើអុស

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវលើកកម្ពស់ផលិតកម្ម និងការប្រើប្រាស់ធ្យូង និងឈើអុសប្រកបដោយនិរន្តរភាពតាមរយៈការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងសារពើពន្ធសម្រាប់ផលិតករប្រកបដោយនិរន្តរភាពដែលទទួលលិខិតអនុញ្ញាត ។ ការលើកទឹកចិត្តទាំងនេះត្រូវបង្កើតឡើងក្នុងលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៣៩៤** ._ ការទប់ស្កាត់ និងការត្រួតពិនិត្យភ្លើងឆេះព្រៃ

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់តំបន់សម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ ការទប់ស្កាត់ភ្លើងឆេះព្រៃ និងការបង្កើតគណៈកម្មាធិការប្រឆាំងនឹងភ្លើងឆេះព្រៃ នៅពេលដែលវិធាន សម្រាប់ការអនុវត្តក្នុងតំបន់ព្រៃឈើទាំងអស់ត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តសមស្រប នៃក្រសួង ស្ថាប័នដែលទទួលខុសត្រូវលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។ ប្រជាពលរដ្ឋ កងកំលាំងប្រដាប់អាវុធ និងអាជ្ញាធរគ្រប់ជាន់ថ្នាក់ ត្រូវមានកាតព្វកិច្ចសម្រាប់ការការពារនិងការថែរក្សាព្រៃឈើ ការទប់ស្កាត់ភ្លើងឆេះ និងការប្រយុទ្ធប្រឆាំងនឹងភ្លើងឆេះព្រៃ ។

**មាត្រា៣៩៥** ._ ការផ្តល់វិញ្ញាបនបត្រផលព្រៃឈើ និងការគ្រប់គ្រងអន្តរជាតិ

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តដែលធ្វើឲ្យនីតិវិធីអាចដំណើការ និងពិពណ៌នាអំពីនីតិវិធី ដែលព្រះរាជាណាចក្រកម្ពុជាត្រូវចូលរួមក្នុងកម្មវិធីវិញ្ញាបនបត្រផលព្រៃឈើនិងការគ្រប់គ្រងអន្តរជាតិ និងការអនុវត្តនីតិវិធីរឹបអូស ឬឃាត់ទុក ផលដែលមិនត្រូវបានប្រើសម្រាប់ការប្រើប្រាស់ក្នុងស្រុក ។

**មាត្រា៣៩៦** ._ កម្មវិធីពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងអភិបាលកិច្ច និងពាណិជ្ជកម្ម

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវបង្កើត និងអនុវត្តកម្មវិធីពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងអភិបាលកិច្ច និងពាណិជ្ជកម្ម ដើម្បីពង្រឹងការគ្រប់គ្រង ការការពារ និងការអភិវឌ្ឍព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាពក្នុងលក្ខណៈតម្លាភាព យុត្តិធម៌ និងប្រកបដោយប្រសិទ្ធផល ។ គោលបំណងជាក់លាក់នៃកម្មវិធីពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងអភិបាលកិច្ច និងពាណិជ្ជកម្ម ត្រូវ៖

ក- ពង្រឹងច្បាប់ព្រៃឈើជាមួយនឹង ការត្រួតពិនិត្យ ការទប់ស្កាត់ បង្ក្រាប និងការលុបបំបាត់ចោលសកម្មភាពព្រៃឈើខុសច្បាប់ទាំងអស់ ។

ខ- ធានាថាច្បាប់ និងគោលនយោបាយសមរម្យត្រូវបានបង្កើត និងដាក់ឲ្យដំណើរការ ។

គ- លើកកម្ពស់អភិបាលកិច្ចល្អតាមរយៈសមត្ថភាពគ្រប់គ្រងជម្លោះដែលបានកែលម្អ ។

ឃ- បញ្ច្រាបការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាព សិទ្ធិសាធារណៈ និងកាតព្វកិច្ច ។

ង- កែលម្អការកសាងសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ នៃក្រសួង ស្ថាប័នមានសមត្ថកិច្ច ទទួលបន្ទុកលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

ច- អនុវត្តតាមវិធីសាស្ត្រប្រកបដោយប្រសិទ្ធផលដើម្បីរកឲ្យឃើញ អង្កេតតាមដាន និងបង្ក្រាបសកម្មភាពព្រៃឈើខុសច្បាប់ និង

ឆ- លើកកម្ពស់ការយល់ដឹងទៅកាន់សាធារណជនស្តីពីច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនៃការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ ។

**មាត្រា៣៩៧** ._ ប្រព័ន្ធផ្តល់លិខិតអនុញ្ញាត និងការអង្កេតតាមដានទូទាំងប្រទេស

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវបង្កើតប្រព័ន្ធផ្តល់លិខិតអនុញ្ញាត និងការអង្កេតតាមដានទូទាំងប្រទេសដើម្បីតាមដានផលិតកម្ម និងការប្រើប្រាស់នូវរាល់ផលឈើដែលកើតចេញពីព្រៃដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព ។ ការអនុលោមតាមប្រព័ន្ធតាមដានត្រូវតែជាលក្ខខណ្ឌតម្រូវរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការស្របតាមលិខិតអនុញ្ញាតក្រោមមាតិកានេះ ។

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវបង្កើតសេចក្តីលម្អិតនៃប្រព័ន្ធផ្តល់លិខិតអនុញ្ញាត និងការអង្កេតតាមដានទូទាំងប្រទេសនេះក្នុងរយៈពេល១(មួយ)ឆ្នាំ នៃការអនុម័តក្រមនេះ ។

**មាត្រា៣៩៨** ._យន្តការផ្តល់មូលនិធិ

ក្រសួង ស្ថាប័នមានសត្ថកិច្ចលើការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព អាចរក្សាយន្តការផ្តល់មូលនិធិពាក់ព័ន្ធដែលមានស្រាប់ ឬបង្កើតយន្តការផ្តល់មូលនិធិថ្មី ទៅតាមការតម្រូវ ដើម្បីអនុវត្តតាមមាតិកានេះ ។

## មាតិកាទី៥
## កិច្ចការពារ អភិរក្ស និងគ្រប់គ្រងសត្វព្រៃ

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៣៩៩** ._ វិសាលភាពនៃការអនុវត្ត

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រងសត្វព្រៃនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤០០** ._ សត្វព្រៃជាសម្បត្តិរដ្ឋ និងជាសមាសភាគនៃធនធានធម្មជាតិ

សត្វព្រៃគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺជាសម្បត្តិរដ្ឋ និងជាសមាសភាគនៃធនធានធម្មជាតិ ។

**មាត្រា៤០១** ._ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន មានតួនាទី និងសមត្ថកិច្ចជារួម ក្នុងការកំណត់គ្រប់គ្រង និងការពារសត្វព្រៃនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយមានការសហការពីក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត និងអាជ្ញាធរថ្នាក់ក្រោមជាតិ មានតួនាទី និងភារកិច្ចដូចតទៅ៖

ក-រៀបចំលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនានា សម្រាប់ការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រង និងការការពារសត្វព្រៃ និងការទប់ស្កាត់បទល្មើសសត្វព្រៃប្រកបដោយប្រសិទ្ធភាព ។

ខ-បង្កើត និងអនុវត្តយុទ្ធសាស្ត្រ ផែនការគ្រប់គ្រង និងផែនការសកម្មភាពនានា ក្នុងការអភិរក្សប្រភេទសត្វដែលរងការគំរាមកំហែង ស្របតាមអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

គ- ធ្វើការវាយតម្លៃពីស្ថានភាពនៃប្រភេទសត្វព្រៃ ដូចបានកំណត់ក្នុងក្រុមទី១ ក្រុមទី២ និងត្រូវកំណត់ពីកម្មវិធីស្តារ និងដាក់បញ្ចូលទៅវិញនូវប្រភេទសត្វទាំងនោះ ដែលជាមូលដ្ឋានត្រូវបានកំណត់ថា ផុតពូជ និងសម្រាប់ប្រភេទសត្វដែលអាចទទួលប្រយោជន៍ពីសកម្មភាពទាំងនោះ។

ឃ- បង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីការអនុវត្តដែលប្រសើបំផុត សម្រាប់គម្រោងនៃការស្តារ និងការដាក់បញ្ចូលទៅវិញនូវប្រភេទសត្វទាំងនោះ និងគម្រោងសម្រាប់ការស្តារចម្រកសត្វព្រៃឡើងវិញ ស្របតាមទម្លាប់នៃការអនុវត្តប្រសើបំផុត និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ ។

ង- ទប់ស្កាត់បទល្មើសសត្វព្រៃទាំងឡាយទាំងនៅក្នុង និងក្រៅរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលថ្នាក់ជាតិបានកំណត់ រួមទាំង ច្រកនាំចេញ និងនាំចូលអន្តរជាតិ និងកន្លែងដែលអាចមានការប្រមូលផលសត្វព្រៃ ការស្តុកទុកសត្វព្រៃ ការរក្សាទុកសត្វព្រៃ ការចរាចរសត្វព្រៃ អាជីវកម្មសត្វព្រៃ និង / ឬកន្លែងដែលមានការបរិភោគសត្វព្រៃ។

ច- អនុវត្តតាមមាតិកានេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត និងអង្កេតតាមដានគ្រប់បទល្មើសសត្វព្រៃ និងធ្វើពាក្យបណ្តឹងទៅកាន់តុលាការមានសមត្ថកិច្ច ។

ឆ- បង្កើត គ្រប់គ្រង និងរក្សារបាយការណ៍ និងទិន្នន័យអំពីជនល្មើស និងបទល្មើសសត្វព្រៃ។

ជ- ប្រើប្រាស់បណ្តាញដែលមានស្រាប់ ដើម្បីបំពេញតួនាទីប្រឆាំងនឹងការជួញដូរសត្វព្រៃ និងបទល្មើសសត្វព្រៃដទៃទៀត និងបង្កើតយុត្តិសាស្ត្របន្ថែមទៅតាមចាំបាច់ ក្នុងគោលបំណងបង្ក្រាបសកម្មភាពបទល្មើសសត្វព្រៃឆ្លងដែន ដែលអាចនឹងកំពុងប្រើប្រាស់ព្រះរាជាណាចក្រកម្ពុជាជាប្រភព ជាទិសដៅ ឬជាចំណុចប្រសព្វនៃការធ្វើចលនាសត្វព្រៃខុសច្បាប់រវាងប្រទេសក្រៅចំនួនពីរ។

ឈ- ធ្វើបច្ចុប្បន្នភាពអំពីចំណាត់ថ្នាក់ប្រភេទសត្វព្រៃគ្រប់ប្រភេទទាំងអស់ ដូចបានកំណត់ក្នុងជំពូកទី២ នៃមាតិកានេះ ។

ញ- បង្កើត និងអនុវត្តតាមកម្មវិធីអភិរក្ស ការពារ ពិនិត្យតាមដាន និងស្រាវជ្រាវអំពីសត្វព្រៃ និងប្រភេទសត្វដទៃផ្សេងទៀតដែលបានទទួលការគំរាមកំហែង និងបានធ្វើចំណាត់ថ្នាក់រួចហើយ ។

ដ- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងការគ្រប់គ្រង និងការចេញវិញ្ញាបនបត្រឯកភាពលើការប្រម៉ាញ់ សម្រាប់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលរស់នៅក្នុង និងក្រៅរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ឋ- ផ្តល់ការពិនិត្យឡើងវិញ ការបដិសេធ ឬការឯកភាពតាមលក្ខខណ្ឌនានា លើកលែងសម្រាប់ការប្រម៉ាញ់សត្វព្រៃ ដូចបានកំណត់នៅក្នុងជំពូកទី៤ នៃមាតិកានេះ ។

ឌ-ផ្តល់ការគ្រប់គ្រង ការពអង្កេតតាមដាន និងការចេញបទបញ្ជានានា សម្រាប់ប្រតិបត្តិការឧទ្យានសត្វព្រៃ មជ្ឈមណ្ឌលបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះ និងផ្តល់នីតិសម្បទាដល់សត្វព្រៃ និងកន្លែងប្រមូលផលសត្វព្រៃដើម្បីធ្វើអាជីវកម្ម ។

ឍ-ផ្តល់ការពិនិត្យ ការបដិសេធ ឬការឯកភាពទៅលើសំណើចាប់សត្វព្រៃទាំងរស់សម្រាប់គោលបំណងបង្កាត់ពូជអភិរក្ស ។

ណ-ផ្តល់ការធានាថា រាល់ដំណើរការផ្តល់ការឯកភាព និងការអនុញ្ញាត មានតម្លាភាព ហើយតម្លៃនៃលិខិតឯកភាព ឬអនុញ្ញាតទាំងនោះ មានការកំណត់ច្បាស់លាស់ ហើយមានការផ្សព្វផ្សាយជូនដល់សាធារណជន ។

ត-បង្កើត និងបន្តអនុវត្ត វិធីសាស្ត្រតាមដានសុខភាពសត្វព្រៃ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងសម្របសម្រួលឲ្យមានការឆ្លើយតបបានភ្លាមៗចំពោះករណីជំងឺសត្វព្រៃ ឬការរាតត្បាតជំងឺរបស់សត្វព្រៃ និងបញ្ហាសុខភាពសត្វព្រៃដទៃៗទៀត ។

ថ-ធ្វើសវនកម្មសម្រាប់ការអង្កេតតាមដានទីតាំងប្រមូលផលសត្វព្រៃ និងទីតាំងបង្កាត់ពូជអភិរក្សសត្វព្រៃ ដើម្បីផ្តល់ជាអនុសាសន៍ធ្វើការកែលម្អ និងពិនិត្យឡើងវិញនូវពាក្យសុំលិខិតអនុញ្ញាតថ្មីៗ មុនផ្តល់ការបដិសេធ ឬការអនុញ្ញាត ។

ទ-ពិនិត្យឡើងវិញ វាយតម្លៃ និងផ្តល់អនុសាសន៍ដើម្បីធ្វើការផ្លាស់ប្តូរដែលចាំបាច់ លើរាល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដែលបានកំណត់ពីផលប៉ះពាល់ជាអវិជ្ជមានទៅលើប្រភេទនៃក្រុម១ ក្រុម២ និងក្រុម៣ ដោយផ្អែកលើរបាយការណ៍ និងទិន្នន័យវិទ្យាសាស្ត្រ ។

ធ-ផ្តល់ការសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល និងនីតិបុគ្គលដែលពាក់ព័ន្ធក្នុងការបំពេញកាតព្វកិច្ចទាំងនេះ ។

ន-សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងចូលរួមនៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិនានា ។

ប-លើកកម្ពស់ការអប់រំជាសាធារណៈ និងកម្មវិធីផ្សព្វផ្សាយនានា ដែលបង្ហាញពីសារៈសំខាន់នៃកិច្ចការពារ ការអភិរក្ស និងការគ្រប់គ្រងសត្វព្រៃប្រកបដោយនិរន្តរភាព ។

**មាត្រា៤០២** ._ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួន ក្នុងការចាត់វិធានការគ្រប់មធ្យោបាយដើម្បីការពារ និងអភិរក្សសត្វព្រៃ ។

ក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានតួនាទី និងការទទួលខុសត្រូវក្នុងការជ្រោមជ្រែងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងសម្របសម្រួលដល់ដល់ការសម្រេចចិត្តជាអន្តរក្រសួងពាក់ព័ន្ធទៅនឹងការគ្រប់គ្រង និងការអភិរក្សជីវៈចម្រុះ។

អាជ្ញាធរគ្រប់គ្រង និងផ្នែកបច្ចេកវិជ្ជារបស់ព្រះរាជាណាចក្រកម្ពុជា នៃអនុសញ្ញាស្តីពីការជួញដូរសត្វ និងរុក្ខជាតិជិតផុតពូជ អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ត្រូវរក្សាប្រតិបត្តិការរបស់ខ្លួនឲ្យបានពេញលេញ ទៅតាមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នដែលទទួលបន្ទុក ។

ក្រុមការងារសង្គ្រោះសត្វព្រៃបន្ទាន់ ត្រូវរក្សាប្រតិបត្តិការរបស់ខ្លួនឲ្យបានពេញលេញ ទៅតាមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នដែលទទួលបន្ទុក ។

**មាត្រា៤០៣** ._ ការសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវសហការទប់ស្កាត់បទល្មើសសត្វព្រៃ និងត្រូវចែកចាយព័ត៌មានពាក់ព័ន្ធ ជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន។ ការសហការ និងការចែកចាយព័ត៌មាននេះ រួមមាន ជាអាទិ៍៖

ក- ការស៊ើបអង្កេតជាតិ និងអន្តរជាតិពាក់ព័ន្ធទៅនឹងជនល្មើស និងបទល្មើសសត្វព្រៃដែលប្រព្រឹត្តដោយរូបវន្តបុគ្គល និងនីតិបុគ្គល និងក្រុមចាត់តាំង។

ខ- ការរឹបអូសសត្វព្រៃ និងបំណែកសត្វព្រៃ បំណែកសត្វព្រៃ ដែលកំណត់ដោយក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ។

គ- ការធ្វើបណ្តឹងទៅកាន់តុលាការពាក់ព័ន្ធនឹងសត្វព្រៃ និងបំណែកនៃសត្វព្រៃ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចចេញលិខិតបទដ្ឋានគតិយុត្តស្តីពីមធ្យោបាយក្នុងកាសហការ និងការផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងបទល្មើសសត្វព្រៃរវាងក្រសួង ស្ថាប័ន ប៉ុន្តែកាតព្វកិច្ចផ្តល់ការសម្របសម្រួល សហការ និងផ្តល់ព័ត៌មាន ត្រូវមានអនុភាពចំពោះគ្រប់ក្រសួង ស្ថាប័ន បន្ទាប់ពីក្រមនេះត្រូវបានអនុម័ត ដោយមិនពាក់ព័ន្ធទៅនឹងការចេញលិខិតបទដ្ឋានគតិយុត្តបែបនេះនោះឡើយ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានអាចបង្កើត និងដឹកនាំកងកម្លាំងប្រឆាំងបទល្មើសសត្វព្រៃចម្រុះ សម្រាប់គោលបំណងកាត់បន្ថយ និងទប់ស្កាត់បទល្មើសសត្វព្រៃ និងសម្របសម្រួលដល់ការខិតខំព្រមគ្នារវាងក្រសួង ស្ថាប័ន និងអង្គភាពពង្រឹងការអនុវត្តច្បាប់ រួមទាំងសហប្រតិបត្តិការអន្តរជាតិផងដែរ ។

**មាត្រា៤០៤** ._ សមាសភាពនៃក្រុមការងារបច្ចេកទេសជីវៈចម្រុះ

ក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាពត្រូវមានសមាសភាពមន្ត្រីជំនាញផ្នែកជីវសាស្ត្រ និងអេកូឡូស៊ី ពីបណ្តាក្រសួង ស្ថាប័នដូចតទៅ៖

ក- ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ខ- ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យកសិកម្ម វិស័យព្រៃឈើ និងវិស័យជលផល និងក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត។

គ- ស្ថាប័ន និងអង្គភាពផ្នែកអប់រំ និងវិទ្យាសាស្ត្រ និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀតដែលរួមមាន ដៃគូផ្នែកបច្ចេកទេសដែលកំពុងរួមចំណែកក្នុងកិច្ចការពាររបៀងអភិរក្សជីវៈចម្រុះ

តំបន់ការពារធម្មជាតិដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងក្នុងការអភិរក្សសត្វព្រៃនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំកិច្ចប្រជុំយ៉ាងហោចណាស់១(មួយ)ឆ្នាំម្តង ដើម្បីៈ

ក-ធ្វើការពិនិត្យឡើងវិញទៅលើបញ្ជីជាតិស្តីពីប្រភេទសត្វព្រៃដែលរងការគំរាមកំហែង ហើយផ្តល់អនុសាសន៍ជូនដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានពាក់ព័ន្ធទៅនឹងបច្ចុប្បន្នភាពចាំបាច់ៗអំពីបញ្ជីប្រភេទសត្វ និងការធ្វើចំណាត់ថ្នាក់សត្វព្រៃ ។

ខ-ធ្វើការពិនិត្យឡើងវិញ ផ្តល់អនុសាសន៍ធ្វើការកែប្រែ និងផ្តល់ការឯកភាពលើការគ្រប់គ្រងប្រភេទសត្វនានា និងលើផែនការស្តារឡើងវិញ ផ្អែកលើរបាយការណ៍ និងទិន្នន័យបច្ចេកវិជ្ជា ។

គ-ជួយដោះស្រាយវិវាទ និងបណ្តឹងនានាពាក់ព័ន្ធទៅនឹងចំណាត់ថ្នាក់សត្វព្រៃ ក៏ដូចជាសកម្មភាពនានាដែលនាំឲ្យមានការផុតពូជនៃសត្វ ។

ឃ-ដោយយោងតាមការយល់ដឹងផ្នែកវិទ្យាសាស្ត្រ ត្រូវចេញអនុសាសន៍ស្តីពីកូតា នៃការប្រមាញ់ របស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច សម្រាប់ការប្រើជាលក្ខណៈប្រពៃណី និងចិញ្ចឹមជីវិត ។

## ជំពូកទី២
## ការធ្វើចំណាត់ថ្នាក់ប្រភេទសត្វព្រៃ

**មាត្រា៤០៥** ._ បញ្ជីថ្នាក់ជាតិនៃប្រភេទសត្វព្រៃដែលរងគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរៀបចំ រក្សាកំណត់ត្រា ឬធ្វើបច្ចុប្បន្នភាពនៃបញ្ជីថ្នាក់ជាតិស្តីពីប្រភេទសត្វព្រៃដែលរងគ្រោះថ្នាក់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្រោយពេលក្រមនេះចូលជាធរមាន ។ ចំពោះបញ្ជីថ្នាក់ជាតិនេះត្រូវៈ ។

ក- កំណត់ចូលប្រភេទសត្វព្រៃ ដែលដឹងថា មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានចុះទៅក្នុងបញ្ជីក្រហមរបស់សភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ។

ខ- បន្តកំណត់ចូលជាបន្តបន្ទាប់នូវប្រភេទសត្វព្រៃថ្មីៗ ដែលត្រូវបានដាក់ចូលរួចហើយចូលទៅក្នុងបញ្ជីក្រហមរបស់អង្គការសភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ និងដែលជាប្រភេទដែលបានព្រទះឃើញថា មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បញ្ជីនេះ ត្រូវដាក់ឲ្យសាធារណៈជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីការទទួលបានព័ត៌មានបរិស្ថាន គន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៤០៦ ._** ការធ្វើចំណាត់ថ្នាក់ប្រភេទសត្វព្រៃ

ប្រភេទសត្វព្រៃដែលត្រូវកំណត់ចូលទៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រភេទសត្វព្រៃដែលរងគ្រោះថ្នាក់ មានដូចតទៅ៖

ក-ក្រុមទី១ ៖ ប្រភេទទាំងអស់ ដែលរួមទាំង ប្រភេទដែលពុំមានដើមកំណើតនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលបានកំណត់ជាប្រភេទផុតពូជពីក្នុងធម្មជាតិ ជិតផុតពូជ ឬរងគ្រោះថ្នាក់ នៅក្នុងបញ្ជីក្រហមនៃអង្គការ សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ អំពីប្រភេទដែលរងការគំរាមកំហែង និងប្រភេទនានាដែលជាបេតិកភណ្ឌជាតិ និងវប្បធម៌ ឬដែលមានសារៈសំខាន់ខាងសេដ្ឋកិច្ចចំពោះកម្ពុជា ឧបសម្ព័ន្ធទី១ នៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ក្រុមទី១ ។

ខ-ក្រុមទី២ ៖ ប្រភេទទាំងអស់ដែលរួមទាំងប្រភេទដែលមានដើមកំណើតក្រៅព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានចាត់ថ្នាក់ជា ប្រភេទងាយរងគ្រោះ និងអាចទទួលរងការគំរាមកំហែង ពុំមានទិន្នន័យគ្រប់គ្រាន់ ឬគ្មានការវាយតម្លៃ នៅលើបញ្ជីក្រហមនៃសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ ប្រភេទរងការគំរាមកំហែង និងប្រភេទទាំងអស់ដែលពុំមានដើមកំណើតនៅកម្ពុជា ដែលមានចែងក្នុងតារាងប្រភេទសត្វព្រៃនៃឧបសម្ព័ន្ធទី២ នៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ។

គ-ក្រុមទី ៣ ៖ ប្រភេទទាំងអស់ ដែលរួមទាំងប្រភេទដែលមានដើមកំណើតក្រៅព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានចាត់ជា កង្វល់តិចតួច នៅក្នុងបញ្ជីក្រហមនៃសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ ស្តីពីប្រភេទរងការគំរាមកំហែង លើកលែងតែមានចែងក្នុងក្រុម ៤ និងគ្រប់ប្រភេទដែលមានមិនដើមកំណើតនៅក្រៅព្រះរាជាណាចក្រកម្ពុជា និងដែលមានចែងក្នុងតារាងប្រភេទសត្វព្រៃនៃឧបសម្ព័ន្ធ៣ នៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ។

គ-ក្រុមទី ៤ ៖ ប្រភេទទាំងអស់ ដែលបានចាត់ទុកថាមានទូទៅនៅកម្ពុជា ដូចដែលបានអនុម័តដោយ ក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព ។

ក្នុងករណីដែលប្រភេទមួយ អាចស្ថិតនៅក្នុងថ្នាក់ច្រើនខុសៗគ្នា ស្របតាមបញ្ជីក្រហមនៃសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ ស្តីពីប្រភេទរងការគំរាមកំហែង និងឧបសម្ព័ន្ធនានានៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ នោះត្រូវអនុវត្តតាម ឬចាត់ចូលទៅក្នុងថ្នាក់ខ្ពស់ជាង ។ ប្រភេទណាមួយដែលទើបមានការអធិប្បាយថ្មីៗដោយគ្មានការធ្វើ

ចំណាត់ថ្នាក់ពីប្រភេទ ដោយសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ នឹងត្រូវចាត់បញ្ចូលក្នុង ក្រុមទី១ លើកលែងតែមានការចាត់ចំណាត់ថ្នាក់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ប្រភេទទាំងឡាយ ដែលមាននៅក្នុងថ្នាក់ទាំងបួន ត្រូវមានការកំណត់ដោយលិខិតបទដ្ឋាន ដែលត្រូវចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រោមការពិគ្រោះជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូបច្ចេកទេសនានា ។ រាល់ការបង្កើត និងការអនុវត្ត តាមថ្នាក់ទាំងបួន ត្រូវមានប្រសិទ្ធភាពភ្លាមៗបន្ទាប់ពីមានការអនុម័តទៅលើក្រមនេះ ដោយឈរលើបញ្ជីក្រហម នៃសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ និងធនធានធម្មជាតិ និងឧបសម្ព័ន្ធនៃអនុសញ្ញាស្ដីពីពណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ដោយមិនអាស្រ័យលើការបង្កើតលិខិតបទដ្ឋានណាមួយនោះឡើយ ។

**មាត្រា៤០៧** ._ ការធ្វើបច្ចុប្បន្នភាពលើបញ្ជីជាតិស្ដីពីប្រភេទសត្វព្រៃដែលរងការគំរាមកំហែង

ក្រុមការងារបច្ចេកទេសជីវៈចម្រុះនៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំកិច្ចប្រជុំ១(មួយ)ដង យ៉ាងតិចក្នុងមួយឆ្នាំ ដើម្បីធ្វើការពិនិត្យឡើងវិញ និងផ្ដល់អនុសាសន៍ជូនដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានដើម្បីធ្វើបច្ចុប្បន្នភាពទៅលើបញ្ជីជាតិស្ដីពីប្រភេទសត្វព្រៃដែលរងការគំរាមកំហែង និងសម្រាប់ការចាត់ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ ដែលមានដើមកំណើត និងមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ការធ្វើបច្ចុប្បន្នភាពទៅលើប្រភេទសត្វព្រៃ ត្រូវយកមូលដ្ឋានទៅលើការចាត់ចំណាត់ថ្នាក់ប្រភេទសត្វ ដូចបានកំណត់នៅក្នុងបញ្ជីក្រហម នៃសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ និងធនធានធម្មជាតិ និងឧបសម្ព័ន្ធនៃអនុសញ្ញាស្ដីពីពណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ។

ក្រៅពីនោះ ប្រភេទទាំងឡាយដែលអាចដំឡើងចំណាត់ថ្នាក់ ត្រូវយកមូលដ្ឋានទៅលើកត្តានានា រួមមាន៖

ក-កម្រិតគ្រោះថ្នាក់ខ្ពស់យោងតាមអត្រានៅប្រភេទសត្វប្រភេទនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ-អត្រានៃប្រភេទសត្វនោះ ត្រូវតាមលក្ខខណ្ឌជ្រើសរើសនៃសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ និងធនធានធម្មជាតិ សម្រាប់ប្រភេទសត្វដែលជិតផុតពូជ ឬរងគ្រោះ ។

គ-សារៈសំខាន់នៃតម្លៃបេតិកភណ្ឌធម្មជាតិ ឬវប្បធម៌ ចំពោះប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ។

បច្ចុប្បន្នភាពទាំងនេះ ត្រូវមានការអនុញ្ញាតដោយលិខិតបទដ្ឋានគតិយុត្ត និងត្រូវធ្វើការចែកចាយដល់ក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ អង្គភាពពង្រឹងការអនុវត្តច្បាប់ គណៈកម្មការគ្រប់គ្រងរួមគ្នា និងតុលាការរាជធានី ខេត្ត ។

មិនត្រូវមានការបញ្ចុះថ្នាក់សម្រាប់ប្រភេទដែលនៅក្នុង ក្រុមទី១ ទី២ ឬទី៣ ដែលមិនស្របតាមការផ្លាស់ប្តូរដូចបានកំណត់ក្នុងបញ្ជីក្រហមនៃប្រភេទជិតផុតពូជ របស់អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ និងធនធានធម្មជាតិ នោះឡើយ ។

**មាត្រា៤០៨** ._ ការស្នើសុំធ្វើបច្ចុប្បន្នភាព

បុគ្គល និងអង្គភាពនានា អាចដាក់ពាក្យស្នើសុំទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានឲ្យធ្វើបច្ចុប្បន្នភាព ពីការចាត់ចំណាត់ថ្នាក់ប្រភេទសត្វព្រៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ពាក្យសុំបែបនេះ ត្រូវផ្តល់ទិន្នន័យ និងព័ត៌មានដើម្បីយោងពីការចាត់ចំណាត់ថ្នាក់ដែលត្រូវធ្វើបច្ចុប្បន្នភាព ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវផ្តល់ការឆ្លើយតបចំពោះពាក្យសុំបែបនោះដោយបញ្ជាក់អំពីហេតុផលក្នុងករណីផ្តល់ការឯកភាព ឬបដិសេធ ក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃបន្ទាប់ពីបានទទួលពាក្យសុំ ។

រាល់ឯកសារ ទិន្នន័យ និងព័ត៌មាន ដែលត្រូវប្រើសម្រាប់ការធ្វើចំណាត់ថ្នាក់ជាថ្មីទៅលើប្រភេទសត្វព្រៃទាំងឡាយ ទាំងដែលត្រូវធ្វើឡើងតាមការស្នើសុំ ត្រូវជម្រាបជូនដល់សាធារណជន ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬក្រសួង ស្ថាប័នពាក់ព័ន្ធដទៃៗទៀត ដែលកាន់កាប់ឯកសារ ឬទិន្នន័យបែបនោះ ឬព័ត៌មានដទៃទៀត ស្របតាមគន្ថីទី១ មាតិកាទី៣ សិទ្ធិទទួលបានព័ត៌មានផ្នែកបរិស្ថាននៃក្រមនេះ ។

## ជំពូកទី៣
## ការហាមឃាត់ចំពោះការបបាញ់

**មាត្រា៤០៩** ._ ការហាមឃាត់ទូទៅ

ការហាមឃាត់បរបាញ់តទៅនេះ ត្រូវអនុវត្តចំពោះរាល់ការបបាញ់ដែលកើតឡើងលើដីឯកជន និងដីរដ្ឋ ក៏ដូចជា ដីរដ្ឋទាំងឡាយ នៅក្រៅរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ៖

ក-ហាមបបាញ់ប្រភេទសត្វដូចបានរៀបរាប់ក្នុងក្រុមទី១ និងក្រុមទី២ លើកលែងតែករណីដូចបានកំណត់នៅក្នុងជំពូកទី៥ នៃមាតិកានេះ ។

ខ-ហាមបបាញ់ប្រភេទសត្វដូចបានកំណត់ក្នុងក្រុមទី១ ទី២ ទី៣ និងទី៤ ដោយប្រើមធ្យោបាយដែលត្រូវបានហាមឃាត់ ។

គ-ហាមផលិត កាន់កាប់ កែច្នៃ ទិញ ដឹកជញ្ជូន និងប្រើប្រាស់ វិធីសាស្ត្របបាញ់ដែលមិនកំណត់ទៅលើប្រភេទសត្វ ដែលនាំឲ្យប៉ះពាល់ដល់ប្រភេទសត្វច្រើន ឬចំនួនច្រើន ឬអាវុធ ឬឧបករណ៍ដែលបានហាមឃាត់ រួមមាន អន្ទាក់ អង្គុប កាំភ្លើងអាវុធកែច្នៃ ខ្សែលួស ខ្សែប្រាំងកង់ ឬម៉ូតូ ជាតិផ្ទុះ រំសេវ ជាតិពុល និងសារធាតុគីមី ដែលមានទាំង ថ្នាំសម្លាប់សត្វល្អិតនៅក្នុង និងក្រៅតំបន់កសិកម្ម សំណាញ់ដែលប្រើនៅលើដី នុយ ខ្សែអាត់សម្លេងសត្វ ឬប្រដាប់ទាក់ទាញផ្សេងៗទៀត ការបិទ ជ័រស្អិត ឧបករណ៍ឆក់ ការប្រមាញ់ដោយប្រើសត្វឆ្កែស្រុក និងមធ្យោបាយផ្សេងទៀតដែលបានហាមឃាត់មិនឲ្យចាប់ បបាញ់ដាក់អន្ទាក់ ប្រមូលផល ធ្វើឲ្យរបួស ឬការសម្លាប់សត្វព្រៃដែលបានហាមឃាត់មិនឲ្យធ្វើការបបាញ់គ្រប់ពេលវេលា និងគ្រប់ទីកន្លែង។

ង-ការបបាញ់ប្រភេទសត្វដូចបានកំណត់នៅក្នុងក្រុមទី៣ និងទី៤ ដែលស្ថិតនៅក្រៅរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ត្រូវបានអនុញ្ញាតចំពោះសហគមន៍មូលដ្ឋានសម្រាប់ការប្រើប្រាស់ជាលក្ខណៈប្រពៃណី និងចិញ្ចឹមជីវិត ដោយប័ណ្ណដែលមានសុពលភាព ស្របតាមជំពូកទី៥ នៃមាតិកានេះ ។

ច-ហាមបបាញ់ប្រភេទសត្វនៅក្នុងក្រុមទី១ ទី២ និងទី៣ ក្នុងគោលដៅអាជីវកម្ម ។

**មាត្រា៤១០ .**_ ការហាមឃាត់សម្រាប់របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ

ការហាមឃាត់ខាងក្រោម ត្រូវអនុវត្តចំពោះរាល់ការបបាញ់ទាំងអស់ នៅក្នុងតំបន់អភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ៖

ក-ហាមឃាត់រាល់ការបបាញ់ប្រភេទនានាក្នុងក្រុមទី១ ទី២ ទី៣ និងទី៤ នៅក្នុងតំបន់ស្នូល និងតំបន់អភិរក្សនៃរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ។ តំបន់ទាំងនេះត្រូវតែហាមឃាត់ពីការបបាញ់ ដើម្បីការពារក្រុមសត្វនៃប្រភេទនានា និងកាត់បន្ថយការរំខានចំពោះសត្វព្រៃ ។ តំបន់ទាំងនេះ ត្រូវមានតួនាទីជាអាង ឬប្រភពសត្វ ដែលអាចបំបែកហ្វូងទៅក្នុងតំបន់នានាផ្សេងទៀត ។

ខ-ការបបាញ់ប្រភេទនានានៅក្នុងក្រុមទី៣ និង៤ សម្រាប់ការប្រើប្រាស់ជាលក្ខណៈប្រពៃណី ឬការបរិភោគ សម្រាប់គ្រួសាររបស់សហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច ដែលរស់នៅក្នុង ឬនៅជាប់នឹងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវ

បានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ត្រូវអនុញ្ញាតឲ្យធ្វើឡើងតែនៅក្នុងតំបន់ប្រើប្រាស់ដោយនិរន្តរភាព និងតំបន់សហគមន៍មូលដ្ឋានប៉ុណ្ណោះ ដោយធ្វើឡើងត្រឹមមធ្យោបាយដែលបានអនុញ្ញាត និងដែលមានលិខិតអនុញ្ញាតឲ្យបបាញ់តែប៉ុណ្ណោះ ។

គ-កូតាបបាញ់សម្រាប់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ត្រូវកំណត់ដោយមន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត នាយករបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ឬគណៈកម្មការគ្រប់គ្រងរួមគ្នាក្រោមចំណុះរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងកិច្ចសម្របសម្រួលជាមួយដៃគូបច្ចេកទេស និងអាជ្ញាធរអាជ្ញាធរថ្នាក់ក្រោមជាតិ ។ កូតានេះ នឹងត្រូវបានកំណត់ទៅតាមលិខិតអនុញ្ញាតបបាញ់សម្រាប់បុគ្គលម្នាក់ៗ ។

ឃ-ការបបាញ់ប្រភេទក្នុងក្រុមទី៣ និងទី៤ ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយក្រៅពីសហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិចដែលមានលិខិតអនុញ្ញាតបបាញ់ដែលនៅមានសុពលភាព ត្រូវបានហាមឃាត់មិនឲ្យធ្វើឡើងនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

គ-ការបបាញ់សត្វព្រៃសម្រាប់គោលដៅអាជីវកម្ម ត្រូវហាមឃាត់ទាំងស្រុង និងគ្រប់ពេលទាំងអស់នៅក្នុងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ។

ង-ការបបាញ់ប្រភេទក្នុងក្រុម ៣ និង៤ សម្រាប់គោលដៅការពារដំណាំ ក្នុងចម្ងាយ ២០ (ម្ភៃ) មែត្រ ពីដីដាំដំណាំ ត្រូវបានអនុញ្ញាតតែនៅក្នុងតំបន់សហគមន៍ប៉ុណ្ណោះ តាមរយៈមធ្យោបាយដែលបានអនុញ្ញាតដែលចេញដោយមន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត ក្រោមចំណុះរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងសហការណ៍ជាមួយអង្គភាពផ្លូវច្បាប់ដែលពាក់ព័ន្ធ ។ ការបបាញ់ប្រភេទក្នុងក្រុមទី១ និងទី២ សម្រាប់គោលដៅការពារដំណាំនៅក្នុងតំបន់សហគមន៍ ត្រូវហាមឃាត់ ។

ច-ហាមឃាត់ចំពោះការផលិត ការកាន់កាប់ ការកែឆ្នៃ ការទិញ ដឹកជញ្ជូន  និងប្រើប្រាស់វិធីសាស្ត្របបាញ់ដែលមិនកំណត់ទៅលើប្រភេទសត្វ ដែលនាំឲ្យប៉ះពាល់ដល់ប្រភេទសត្វច្រើន ឬចំនួនច្រើន  ការប្រើប្រាស់អាវុធ ឬឧបករណ៍ដែលបានហាមឃាត់ រួមមាន អន្ទាក់ អង្គុប កាំភ្លើង អាវុធកែច្នៃ ខ្សែលួស ខ្សែប្រាំងកង់ ឬម៉ូតូ ជាតិផ្ទុះ រំសេវ ជាតិពុល និងសារធាតុគីមី ដែលមានទាំង ថ្នាំសម្លាប់សត្វល្អិតនៅក្នុង និងក្រៅតំបន់កសិកម្ម សំណាញ់ដែលប្រើនៅលើដី នុយ ខ្សែអាត់សម្លេងសត្វ ឬប្រដាប់ទាក់ទាញផ្សេងៗទៀត  ការបិទ ជ័រស្អិត ឧបករណ៍ឆក់ ការប្រម៉ាញ់ដោយប្រើសត្វឆ្កែស្រុក និងមធ្យោបាយផ្សេងទៀតដែលបានហាមឃាត់មិន

ឲ្យចាប់ បបាញ់ ដាក់អន្ទាក់ ប្រមូលផល ធ្វើឲ្យរបួស ឬការសម្លាប់សត្វព្រៃដែលបានហាមឃាត់ មិនឲ្យធ្វើការបបាញ់គ្រប់ពេលវេលា និងគ្រប់ទីកន្លែង។

ឆ-ជនណាដឹកជញ្ជូន ឬកាន់កាប់ប្រភេទណាមួយក្នុងក្រុមទី៣ ឬទី៤ នៅក្នុងតំបន់ការពារធម្មជាតិធម្មជាតិណាមួយ ដែលត្រូវបានកំណត់ និងបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវមានលិខិតអនុញ្ញាតបបាញ់ដែលនៅមានសុពលភាព ។

ជ-ការចាប់សត្វព្រៃពីរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ និងតំបន់គ្រប់គ្រង និងការពាររួមគ្នា សម្រាប់គោលដៅបង្កើត និងរក្សាទុកក្នុងកសិដ្ឋានសត្វព្រៃណាមួយ គ្រឹះស្ថានសត្វព្រៃ ការប្រមូលមករក្សាទុកជាឯកជន ត្រូវហាមឃាត់ទាំងស្រុង ។

ឈ-ការចាប់សត្វព្រៃសម្រាប់គោលដៅបង្កើត ឬរក្សាទុកក្នុងកន្លែងបង្កាត់ពូជអភិរក្ស ដែលត្រូវបានអនុញ្ញាតក្នុងមាត្រា៤០២ នៃក្រមនេះ ត្រូវមានការអនុញ្ញាតជាមុនដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ញ-រាល់ឆ្កែស្រុក ឆ្កែប្រមាញ់ និងសត្វចិញ្ចឹមនានា ត្រូវហាមឃាត់មិនឲ្យនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ និងតំបន់គ្រប់គ្រង និងការពាររួមគ្នានោះឡើយ ។

## ជំពូកទី៤
## ករណីលើកលែងសម្រាប់ការបបាញ់សត្វព្រៃ
### ផ្នែកទី១
### ការត្រួតពិនិត្យការបង្កគ្រោះថ្នាក់ដល់ជីវិតសត្វព្រៃ

**មាត្រា៤១១ ._** ការកំណត់ទៅលើការគ្រប់គ្រងការសម្លាប់

ក្នុងករណីមានការឯកភាពថា សត្វព្រៃណាមួយ បង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស នាយកតំបន់ការពារធម្មជាតិ ឬមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកការពារ និងអភិរក្សធម្មជាតិ អាចចេញបញ្ជាជាលាយលក្ខណ៍អក្សរ និងប្រកបដោយហេតុផល អនុញ្ញាតឲ្យមន្ត្រីក្រោមក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬមន្ទីរទទួលបន្ទុកវិស័យបរិស្ថាន សម្លាប់សត្វបែបនោះ ។

**មាត្រា៤១២ ._** សេចក្តីសម្រេច

សេចក្តីសម្រេចពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យការបង្កគ្រោះថ្នាក់ដល់ជីវិតសត្វព្រៃ ត្រូវធ្វើតាម

លិខិតបទដ្ឋានគតិយុត្តសម្រាប់ការពិចារណាទៅលើសុវត្ថិភាព សុខុមាលភាពសត្វព្រៃ និងតម្លៃនៃសត្វអភិរក្ស ដែលត្រូវបង្កើតដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៤១៣** ._ វិធីសាស្ត្រ

វិធីសាស្ត្រនៃការសម្លាប់សត្វព្រៃ ត្រូវធ្វើតាមលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ សម្រាប់ការធានាបាននូវសុខុមាលភាពរបស់សត្វព្រៃ និងការកាត់បន្ថយហានិភ័យទៅលើសត្វដទៃ ក៏ដូចជាជីវិតរបស់មនុស្ស ដែលត្រូវបង្កើតដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៤១៤** ._ កាតព្វកិច្ចក្នុងការបំផ្លាញ

សត្វព្រៃណាមួយដែលត្រូវបានសម្លាប់ ឬធ្វើឲ្យរបួស ដោយបាននាំគ្រោះថ្នាក់ដល់ជីវិតមនុស្ស ដែលមិនអាចជាសះស្បើយវិញបាន ដូចបានកំណត់តាមជំពូកនេះ ត្រូវក្លាយជាទ្រព្យសម្បត្តិរបស់រដ្ឋ និងត្រូវបំផ្លាញ ឬសម្លាប់ដោយអនុលោមតាមវិធីសាស្ត្រដូចបានរៀបរាប់ក្នុងជំពូកទី១១ នៃមាតិកានេះ ។

**មាត្រា៤១៥** ._ ក្រុមទី១ និងក្រុមទី២

ការសម្លាប់សត្វដែលមាននៅក្នុងប្រភេទក្រោមក្រុមទី១ និងទី២ ត្រូវទទួលការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬមន្ទីរទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៤១៦** ._ ក្រុមទី៣ និងក្រុមទី៤

សម្រាប់ការសម្លាប់សត្វដែលមាននៅក្នុងប្រភេទក្រោមក្រុមទី៣ និងទី៤ ត្រូវទទួលការអនុញ្ញាតពីនាយករបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ។

**មាត្រា៤១៧** ._ ប្រភេទសត្វដែលមិនមានដើមកំណើតនៅព្រះរាជាណាចក្រកម្ពុជា

ប្រភេទសត្វទាំងឡាយដែលមិនមានដើមកំណើតនៅព្រះរាជាណាចក្រកម្ពុជា ដូចត្រូវបានកំណត់ក្រោមក្រុមទី១និងទី២ ដែលបង្កគ្រោះថ្នាក់ជីវៈចម្រុះដើមនៃព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើការគ្រប់គ្រងទាំងនៅក្នុងព្រៃឬដីឯកជន ក្នុងករណីមានសកម្មភាពឬ គ្រោះថ្នាក់ នៅក្រោមផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វ តម្រូវឲ្យមានការ អនុញ្ញាត ជាលាយលក្ខណ៍អក្សរ ពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៤១៨ ._** ការចាប់ទាំងរស់សម្រាប់គោលដៅអភិរក្ស

វិធីសាស្ត្រចាប់សត្វព្រៃទាំងរស់ទៅតាមប្រភេទដូចបានកំណត់ក្នុងថ្នាក់ណាមួយនៃមាតិកានេះ សម្រាប់គោលដៅបង្កាត់ពូជអភិរក្ស ឬការគ្រប់គ្រងការអភិរក្ស ត្រូវមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយការចេញលិខិតអនុញ្ញាតជាក់លាក់ ។ ពាក្យសុំការអនុញ្ញាតបែបនេះ ត្រូវបង្ហាញពីសារៈប្រយោជន៍ក្នុងការចាប់ប្រភេទសត្វ ការអនុលោមពាក់ព័ន្ធទៅនឹងនីតិវិធី ពាក់ព័ន្ធទៅនឹងពិធីសារស្តីពីសុខុមាលភាព ការចាប់ ការដឹកជញ្ជូន និងការចិញ្ចឹមសត្វព្រៃ ។ ការចាប់បែបនេះ ត្រូវមានការ គាំទ្រពីក្រុមការងារបច្ចេកទេសជីវៈចម្រុះ និងក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព និងប្រធានក្រុមឯកទេសបេសកកម្មសង្គ្រោះសត្វព្រៃ នៃអង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ ។

**មាត្រា៤១៩ ._** ការផ្លាស់ទីកន្លែង

ការផ្លាស់ទីកន្លែង និងការចាប់សត្វព្រៃសម្រាប់ការបង្កាត់ដើម្បីអភិរក្ស ឬគ្រប់គ្រងដើម្បីអភិរក្ស នៃប្រភេទក្នុងក្រុមទី១ និងទី២ អាចអនុញ្ញាតបានតែដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ប៉ុណ្ណោះ ប្រសិនបើសកម្មភាពទាំងនោះស្របជាមួយផែនការគ្រប់គ្រង និងស្តារប្រភេទដែលបានអនុម័ត ឬជាមួយអនុសាសន៍ពីក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព ។

**មាត្រា៤២០ ._** ការអង្កេតតាមដានពីសុខភាព និងនីតិវិធីនៃការញែកសម្រាប់ការផ្លាស់ទីកន្លែង

ការអង្កេតតាមដានពីសុខភាព និងនីតិវិធីនៃការញែកសម្រាប់ការផ្លាស់ទីកន្លែងសត្វព្រៃ ឬការធ្វើការផ្ទេររវាងទីបង្ខាំង និងទីព្រៃតាមធម្មជាតិ ត្រូវអនុលោមតាមនីតិវិធីពាក់ព័ន្ធដែលបានអនុញ្ញាត ។

## ផ្នែកទី២
## គ្រឹះស្ថានឧទ្យានសត្វព្រៃ

**មាត្រា៤២១ ._** លក្ខខណ្ឌតម្រូវ

គ្រឹះស្ថានឧទ្យានសត្វព្រៃ ត្រូវមានលិខិតអនុញ្ញាតដែលមានសុពលភាពសម្រាប់ទាំងកន្លែង និងគ្រប់សត្វទាំងអស់ ដែលប្រមូលបានដោយគ្រឹះស្ថាន ។ តារាងស្តីពីតម្លៃនៃការអនុញ្ញាត ត្រូវបង្កើត និងកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រោមការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ។ ចំណូលដែលប្រមូលបានពីលិខិតអនុញ្ញាតទាំងនោះ ត្រូវប្រើប្រាស់ដើម្បីឧបត្ថម្ភដល់ការអភិរក្សសត្វព្រៃ និងជីវៈចម្រុះ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា រួមទាំងការអនុវត្ត

ផែនការ  ស្តារ និងគ្រប់គ្រងប្រភេទព្រៃ ឬការប្រើប្រាស់ដទៃទៀតដោយក្រុមការងារបច្ចេកទេសជីវៈចម្រុះនៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៤២២ .**_ ការហាមឃាត់

ត្រូវហាមឃាត់ចំពោះការបបាញ់ ការចាប់ ឬការប្រមូលសត្វពីព្រៃ គ្រប់ប្រភេទដូចបានកំណត់ក្នុងក្រុមទី១ និងទី២ សម្រាប់បំរើឲ្យគ្រឹះស្ថានឧទ្យានសត្វព្រៃ ។

**មាត្រា៤២៣ .**_ ការអនុវត្ត

ការអនុវត្តតាមការចាប់សត្វព្រៃ តាមប្រភេទដូចបានកំណត់ក្នុងក្រុមទី៣ និងទី៤ សម្រាប់គោលដៅរបស់គ្រឹះស្ថានឧទ្យានសត្វព្រៃ ត្រូវទទួលការពិនិត្យឡើងវិញ ហើយទទួលការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានទៅតាមភាពសមរម្យ ។

**មាត្រា៤២៤ .**_ ការចេញ និងការបញ្ឈប់សុពលភាពនៃលិខិតអនុញ្ញាតបណ្តោះអាសន្ន

មិនត្រូវមានការចេញលិខិតអនុញ្ញាតសម្រាប់គ្រឹះស្ថាន ដែលមានជាប់ពាក់ព័ន្ធទៅនឹងការបបាញ់ និងអាជីវកម្មសត្វព្រៃខុសច្បាប់នោះឡើយ ឬដែលមិនមានលិខិតអនុញ្ញាតដែលមានសុពលភាព ឬឯកសារផ្លូវច្បាប់សម្រាប់សត្វនៅក្នុងគ្រឹះស្ថានឡើយ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ទទួលសិទ្ធិក្នុងការបញ្ឈប់សុពលភាពបណ្តោះអាសន្ន បិទទីតាំង និងរឹបអូសសត្វនានា ករណីម្ចាស់គ្រឹះស្ថានមិនអនុវត្តតាមបទប្បញ្ញត្តិនានាដូចមានចែងក្នុងមាតិកានេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

## ជំពូកទី៥
## លិខិតអនុញ្ញាតបបាញ់

**មាត្រា៤២៥ .**_ លិខិតអនុញ្ញាតបបាញ់

ការបបាញ់សត្វព្រៃដូចបានកំណត់នៅក្នុងក្រុមទី៣ និងទី៤ ត្រូវហាមឃាត់ ប្រសិនបើគ្មានលិខិតអនុញ្ញាតដែលមានសុពលភាព ។

លិខិតអនុញ្ញាតបបាញ់ អនុញ្ញាតឲ្យរូបវ័នបុគ្គលដែលបានកំណត់មានសិទ្ធិបបាញ់ នៅតាមតំបន់ជាក់លាក់ណាមួយ ។

**មាត្រា៤២៦ .**_ កាតព្វកិច្ចអ្នកបបាញ់

រូបវន្តបុគ្គលដែលបបាញ់ ត្រូវយកលិខិតអនុញ្ញាតតាមខ្លួនជានិច្ច ក្នុងពេលបបាញ់ ក្នុងករណីមានការសាកសួរ ដោយអាជ្ញាធរមានសមត្ថកិច្ច តាមការចាំបាច់ ។

បុគ្គលកាន់កាប់លិខិតអនុញ្ញាតបបាញ់ អាចតម្រូវឲ្យផ្តល់គំរូតាង ឬផ្នែកណាមួយនៃសត្វដែលបានបបាញ់ ទៅឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធមានសមត្ថកិច្ច សម្រាប់ជាផ្នែកមួយនៃសកម្មភាពអង្កេតតាមដានសុខភាពសត្វព្រៃ ។ គ្មានការបង់សំណងជាហិរញ្ញវត្ថុសម្រាប់ការដោះដូរគំរូតាង ឬផ្នែកនៃសត្វព្រៃនោះទេ ។

**មាត្រា៤២៧ .**_ ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតបបាញ់

បុគ្គលទាំងឡាយដែលមានបំណងទទួលលិខិតអនុញ្ញាតបបាញ់ ត្រូវធ្វើការដាក់ពាក្យជាលាយលក្ខណ៍អក្សរទៅកាន់មន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត គណៈកម្មការគ្រប់គ្រងរួមគ្នា ឬនាយកនៃរបៀងអភិរក្សជីវៈចម្រុះដែលពាក់ព័ន្ធ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ។

ពាក្យសុំលិខិតអនុញ្ញាតបបាញ់នៅក្នុងតំបន់សហគមន៍មូលដ្ឋាន និងតំបន់ប្រើប្រាស់ដោយចីរភាព នៃរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ និងតំបន់គ្រប់គ្រង និងការពាររួមគ្នា ត្រូវធ្វើការពិនិត្យឡើងវិញ ហើយក្នុងករណីដែលឃើញថាមានភាពត្រឹមត្រូវ នោះត្រូវទទួលបានការឯកភាព ។

លិខិតអនុញ្ញាត ត្រូវចេញដោយគណៈកម្មការគ្រប់គ្រងរួមគ្នា ឬនាយកនៃរបៀងអភិរក្សជីវៈចម្រុះដែលពាក់ព័ន្ធ ឬតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ក្រោមកិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដែលមានការចាប់អារម្មណ៍ទៅនឹងកិច្ចការពារតំបន់នានានៃរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ។

ពាក្យសុំលិខិតអនុញ្ញាតបបាញ់សម្រាប់តំបន់ក្រៅពីរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ត្រូវទទួលការពិនិត្យឡើងវិញ ហើយបើសមរម្យ នោះត្រូវទទួលបានការអនុញ្ញាត ដែលចេញដោយនាយកមន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត ។

**មាត្រា៤២៨ .**_ ការចេញលិខិតអនុញ្ញាតបបាញ់

រាល់ទម្រង់បែបបទនៃការស្នើសុំ វិញ្ញាបនបត្រឯកភាព និងលិខិតអនុញ្ញាតបបាញ់ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ការអនុញ្ញាត ការដកហូតលិខិតអនុញ្ញាត ឬបដិសេធចំពោះលិខិតអនុញ្ញាត ឬលក្ខខណ្ឌ ដែលកំណត់ ត្រូវធ្វើឡើងស្របតាមការយល់ឃើញថាសមរម្យរបស់នាយកមន្ទីទទួលបន្ទុកវិស័យបរិស្ថានខេត្ត គណៈកម្មការគ្រប់គ្រងរួមគ្នា ឬនាយករបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយផ្អែកលើលក្ខខណ្ឌតម្រូវដូចតទៅ៖

ក-រាល់លិខិតអនុញ្ញាត ត្រូវចេញដោយមានតម្លាភាព ។

ខ-មួយគ្រួសារអាចទទួលបានលិខិតអនុញ្ញាតតែមួយប៉ុណ្ណោះ ។

គ-មិនត្រូវមានការចេញលិខិតអនុញ្ញាតសម្រាប់ជនទាំងឡាយណាដែលមានពាក់ព័ន្ធនឹងការបបាញ់ខុសច្បាប់ដែលមានរយៈពេល ៥ (ឆ្នាំ) ជាអតិបរិមា ឬមានការដកហូតលិខិតអនុញ្ញាត ៣ (បី) ដង ដូចបានកំណត់ក្នុងមាត្រា ៤៣០ នៃក្រមនេះ ។

ឃ-មិនត្រូវមានការចេញលិខិតអនុញ្ញាតសម្រាប់ជនទាំងឡាយណាដែលនាយកមន្ទីទទួលបន្ទុកវិស័យបរិស្ថានខេត្ត គណៈកម្មការគ្រប់គ្រងរួមគ្នា ឬនាយករបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានហេតុផលបង្ហាញ ឬជឿថា ធ្លាប់មានពាក់ព័ន្ធទៅនឹងការបបាញ់ក្នុងគោលដៅអាជីវកម្ម និងអាជីវកម្មសត្វព្រៃមិនស្របច្បាប់ឡើយ ។

ង-ហាមមិនឲ្យមានការផ្ទេរលិខិតអនុញ្ញាតបបាញ់ពីបុគ្គលម្នាក់ទៅបុគ្គលឯទៀតនោះឡើយ ។

ច-លិខិតអនុញ្ញាតបបាញ់មួយត្រូវមានសុពលភាពត្រឹម (១)ឆ្នាំប៉ុណ្ណោះ បន្ទាប់ពីនោះលិខិតនេះត្រូវទទួលការពិនិត្យឡើងវិញ និងអាចធ្វើជាថ្មីវិញបាន ។

ករណីបាត់លិខិតអនុញ្ញាត ម្ចាស់កាន់កាប់លិខិតអនុញ្ញាតត្រូវជូនដំណឹងភ្លាមៗដល់មន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត គណៈកម្មការគ្រប់គ្រងរួមគ្នា ឬនាយករបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយត្រូវបញ្ឈប់សមកម្មភាពបបាញ់របស់ខ្លួន រហូតមានលិខិតអនុញ្ញាតថ្មីជំនួសវិញ ។

**មាត្រា៤២៩** ._ ទិន្នន័យអំពីលិខិតអនុញ្ញាត និងអ្នកបបាញ់

គ្រប់នាយកមន្ទីទទួលបន្ទុកវិស័យបរិស្ថានខេត្ត គណៈកម្មការគ្រប់គ្រងរួមគ្នា និងនាយករបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ត្រូវរៀបចំទិន្នន័យ អំពីលិខិតអនុញ្ញាតបបាញ់ និងអ្នកបបាញ់នានា ក្នុងគោលបំណងអង្កេតតាមដាន និងកំណត់ក្របខ័ណ្ឌទៅលើសកម្មភាពបបាញ់ ។

ឯកសារប្រព័ន្ធទិន្នន័យដេតាបេស ត្រូវផ្ញើរជូនជាប្រចាំឆ្នាំទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងដៃគូបច្ចេកទេសពាក់ព័ន្ធទៅនឹងកិច្ចការពាររបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារ

ធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ និងការអភិរក្សប្រភេទសត្វព្រៃនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ព័ត៌មានទិន្នន័យដេតាបេស ត្រូវធ្វើការចែកចាយដល់សាធារណជនស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានផ្នែកបរិស្ថាន គន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៤៣០ .**_ ការដកហូត និងការផ្អាកលិខិតអនុញ្ញាតបបាញ់

នាយកមន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត គណៈកម្មការគ្រប់គ្រងរួមគ្នា ឬនាយករបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាចធ្វើការផ្អាក ឬដកហូតលិខិតអនុញ្ញាតបបាញ់ ដូចមានចែងក្នុងមាតិកានេះ ហើយត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ស្របតាមលក្ខខណ្ឌដូចតទៅ៖

ក- បទល្មើសបបាញ់ពាក់ព័ន្ធទៅនឹងប្រភេទក្នុងក្រុមទី១ ត្រូវស្ថិតនៅក្រោមការដកហូតលិខិតអនុញ្ញាតសម្រាប់ពេលនៃសុពលភាពដែលនៅសល់ក្នុងលិខិតអនុញ្ញាត និងការបដិសេធនូវរាល់ការស្នើសុំលិខិតអនុញ្ញាតបបាញ់ថ្មីសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីកាលបរិច្ចេទនៃការព្យួរលិខិតអនុញ្ញាត ជាទោសបន្ថែមទៅនឹងទោសដូចបានកំណត់ស្របតាមបទប្បញ្ញត្តិស្តីពីបទល្មើស និងទោសផ្នែកបរិស្ថាន គន្ថីទី៩ មាតិកាទី១ ដូចមានចែងក្នុងក្រមនេះ។

ខ-បទល្មើសបបាញ់ពាក់ព័ន្ធទៅនឹងប្រភេទក្នុងក្រុមទី២ ត្រូវស្ថិតនៅក្រោមការដកហូតលិខិតអនុញ្ញាត សម្រាប់រយៈពេលនៃសុពលភាពដែលនៅសល់ក្នុងលិខិតអនុញ្ញាត និងការច្រានចោលនូវរាល់សំណើរសុំលិខិតបបាញ់ថ្មីសម្រាប់រយៈពេល ២ (ប្រាំ) ឆ្នាំ គិតចាប់ពីកាលបរិច្ចេទនៃការព្យួរលិខិតអនុញ្ញាត ជាទោសបន្ថែមទៅនឹងទោសដូចបានកំណត់ស្របតាមបទប្បញ្ញត្តិស្តីពីបទល្មើស និងទោសផ្នែកបរិស្ថាន នៅក្នុងគន្ថីទី៩ មាតិកាទី១ ដូចមានចែងក្នុងក្រមនេះ ។

គ-បទល្មើសបបាញ់ពាក់ព័ន្ធទៅនឹងប្រភេទក្នុងក្រុមទី៣ ត្រូវស្ថិតនៅក្រោមការដកហូតលិខិតអនុញ្ញាតសម្រាប់រយៈពេល ៦ (ប្រាំមួយ)ខែ ឬសម្រាប់រយៈពេលនៃសុពលភាពដែលនៅសល់ក្នុងលិខិតអនុញ្ញាត ក្នុងករណីរយៈពេលនៃសុពលភាពក្នុងលិខិតអនុញ្ញាត មានរយៈពេលតិចជាង ៦ (ប្រាំមួយ) ខែ និងការបដិសេធរាល់ការស្នើសុំលិខិតអនុញ្ញាតបបាញ់ថ្មីសម្រាប់រយៈពេលដែលនៅសល់ក្នុងលិខិតអនុញ្ញាត ដែលជាទោសបន្ថែមទៅនឹងទោសដូចបានកំណត់ស្របតាមបទប្បញ្ញត្តិស្តីពីបទល្មើស និងទោសផ្នែកបរិស្ថាន នៅក្នុងគន្ថីទី៩ ដូចមានចែងក្នុងក្រមនេះ។

ឃ-បុគ្គលទាំងឡាយ ដែលត្រូវបានដកហូតលិខិតអនុញ្ញាតក្នុងករណីបបាញ់ខុសច្បាប់ ឬអាជីវកម្មសត្វព្រៃខុសច្បាប់ ត្រូវស្ថិតនៅក្រោមការបដិសេធមិនចេញលិខិតអនុញ្ញាតបបាញ់ឲ្យជារៀងរហូត។

ង- បុគ្គលទាំងឡាយ ដែលត្រូវបានដកហូតលិខិតអនុញ្ញាត ៣ (បី) ដង ក្នុងករណីបបាញ់ខុសច្បាប់ ឬអាជីវកម្មសត្វព្រៃខុសច្បាប់ មិនអាចធ្វើការស្នើសុំលិខិតអនុញ្ញាតបបាញ់បន្ថែមជារៀងរហូត។

រាល់ការដកហូតលិខិតអនុញ្ញាតបបាញ់ ត្រូវស្ថិតនៅក្រោមចំណុះរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយមានការសហការពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

## ជំពូកទី៦
## ការហាមឃាត់ចំពោះការធ្វើអាជីវកម្ម ការជួញដូរ ឬការធ្វើពាណិជ្ជកម្មសត្វព្រៃ សត្វដែលប្រម៉ាញ់បាន បំណែកសត្វ និងផលិតផលពីសត្វព្រៃគ្រប់ប្រភេទ

**មាត្រា៤៣១** ._ សកម្មភាពដែលត្រូវហាមឃាត់

ហាមឃាត់រាល់ការជួញដូរ ការដឹកជញ្ជូន ការបញ្ជូន ការនាំចូល នាំចេញ ការនាំចេញបន្ត កាន់កាប់ លក់ ទិញ ផ្ទេរ ស្តុកទុក ផ្តល់ជាអំណោយ បរិភោគ ចិញ្ចឹម និងការប្រើប្រាស់តាមរូបភាពពាណិជ្ជកម្មនូវបំណែកសត្វ និងផលិតផលពីសត្វដទៃទៀត ដែលជាប្រភេទក្នុងក្រុមទី១ ទី២ និងទី៣ ។

ហាមឃាត់រាល់ការផ្តល់ ឬការផ្សព្វផ្សាយ សម្រាប់លក់សត្វព្រៃ វត្ថុតាំងលំអ បំណែកសត្វ សាច់ ឬផលិតផលសត្វព្រៃដែលមានប្រភេទដូចក្នុងក្រុមទី១ ទី២ និងទី៣ ។

ការដាក់លក់ ឬការផ្សព្វផ្សាយលក់ផលិតផលក្លែងក្លាយ ដែលមានផ្សព្វផ្សាយថាជាផលិតផលពីសត្វព្រៃ និងបំណែកសត្វ ត្រូវចាត់ទុកជាបទល្មើស ដូចគ្នានឹងបទល្មើសដែលពាក់ព័ន្ធនឹងសត្វព្រៃ និងបំណែកសត្វព្រៃពិតប្រាកដផងដែរ ។

**មាត្រា៤៣២** ._ ការហាមឃាត់ចំពោះសកម្មភាពរូបវន្តបុគ្គល និងនីតិបុគ្គល

គ្មានបុគ្គល អង្គការ ក្រុមហ៊ុន ឬអង្គភាពដទៃណា ត្រូវបានអនុញ្ញាតឲ្យទិញ ទទួល ឬធ្វើលទ្ធកម្មសត្វព្រៃរស់ ឬសត្វព្រៃ ដែលមានប្រភេទក្នុងក្រុមទី១ ទី២ ឬទី៣ ឬបំណែកសត្វព្រៃ ឬសាច់សត្វឡើយ ។ រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវដាក់បញ្ចូលនៅក្នុងអាជីវកម្មរបស់ខ្លួននូវបុគ្គល ដូចខាងក្រោម៖

ក-អ្នកផលិត ឬអ្នកជួញដូរ សត្វព្រៃ ឬវត្ថុតាំងលម្អដែលធ្វើពីសត្វ បំណែកសត្វព្រៃដែលមានចែងក្នុងក្រុមទី១ ទី២ ឬទី៣ ។

ខ-អ្នកកែច្នៃស្បែកសត្វព្រៃ បំណែកសត្វដែលងាប់ ឬបំណែកសត្វព្រៃណាមួយ ដូចមានចែងក្នុងក្រុមទី១ ទី២ ឬទី៣ ។

ង-អ្នកជួញដូរ អ្នកចម្អិន ឬអ្នកផ្គត់ផ្គង់សាច់ ដែលបានពីសត្វព្រៃ ដូចមានចែងក្នុងក្រុមទី១ ទី២ ឬទី៣ ។

ច-អ្នកនាំចូល អ្នកនាំចេញ ឬអ្នកនាំចេញបន្តសត្វព្រៃ សាច់សត្វព្រៃ ឬវត្ថុតាំងលម្អដូចមានចែងក្នុងក្រុមទី១ ទី២ ឬទី៣ ។

## ជំពូកទី៧
## អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិនៃប្រភេទសត្វព្រៃ និងរុក្ខជាតិ ដែលជិតផុតពូជ

**មាត្រា៤៣៣** ._ ប្រភេទដែលដែលពាក់ព័ន្ធ

យោងតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីអនុសញ្ញាស្តីពីពណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ជំពូកនេះអនុវត្តចំពោះប្រភេទសត្វ និងរុក្ខជាតិ នៅក្នុង៖

១. ឧបសម្ព័ន្ធ ១ នៃអនុសញ្ញាស្តីពីពណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ សមមូលនឹងប្រភេទក្នុងក្រុមទី១ ។

២. ឧបសម្ព័ន្ធ ២ នៃអនុសញ្ញាស្តីពីពណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ សមមូលនឹងប្រភេទក្នុងក្រុមទី២ ។

៣. ឧបសម្ព័ន្ធ ៣ នៃអនុសញ្ញាស្តីពីពណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ សមមូលនឹងប្រភេទក្នុងក្រុមទី៣ ។

**មាត្រា៤៣៤** ._ ការហាមឃាត់ទៅលើសកម្មភាពនានា

ហាមមិនឲ្យបុគ្គលទាំងឡាយណា ប្រព្រឹត្តនូវសកម្មភាព ដូចខាងក្រោមដោយមិនបានអនុលោមតាមអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិនៃប្រភេទសត្វព្រៃ និងរុក្ខជាតិ ដែលជិតផុតពូជ៖

ក-ការនាំចូល ឬយកចូលពីបរទេស មកក្នុងប្រទេសនូវប្រភេទសត្វ និងរុក្ខជាតិ ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃអនុសញ្ញាស្តីពីពណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ដែលជំពូកនេះបានចែងនោះឡើយ ។

ខ-ការនាំចេញ ឬយកចេញពីប្រទេស ទៅបរទេស នូវប្រភេទសត្វ និងរុក្ខជាតិ ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃអនុសញ្ញាស្តីពីពណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ដែលជំពូកនេះបានចែងនោះឡើយ ។

គ-ការនាំចេញបន្ត ផ្ទេរ ឬដឹកជញ្ជូនឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ឆ្ពោះទៅកាន់បរទេសនូវប្រភេទសត្វ និងរុក្ខជាតិ ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ដែលជំពូកនេះបានចែងនោះឡើយ ។

## ជំពូកទី៨
## សហប្រតិបត្តិការអន្តរជាតិ

**មាត្រា៤៣៥** ._ ការទប់ស្កាត់ ការកំណត់អត្តសញ្ញាណ និងការបង្ក្រាបបទល្មើស

ក្រៅពីច្បាប់ដទៃបានកំណត់ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត និងអាជ្ញាធរអាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវសហការ និងផ្តល់បុគ្គលិក ក៏ដូចជាព័ត៌មានដទៃទៀត ទៅកាន់អាជ្ញាធរអនុវត្តច្បាប់បរទេស នៃប្រទេសក្រៅមួយទៀត និងទៅកាន់កន្លែងរបស់អង្គភាពអន្តរជាតិដែលពាក់ព័ន្ធក្នុងតំបន់ ក្នុងគោលដៅទប់ស្កាត់ កំណត់អត្តសញ្ញាណ និងបង្ក្រាបបទល្មើស ដូចមានចែងក្នុងមាតិកានេះ ទៅតាមសមត្ថកិច្ចរៀងៗខ្លួន ។

**មាត្រា៤៣៦** ._ ការស៊ើបអង្កេត និងនីតិវិធី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិត្រូវសហការជាមួយអាជ្ញាធរពង្រឹងការអនុវត្តច្បាប់អន្តរជាតិ និងអង្គការអន្តរជាតិថ្នាក់តំបន់ សម្រាប់កិច្ចការដែលមានដូចតទៅ៖

ក-ការផ្តល់វត្ថុ សារធាតុ ឯកសារ និងរបាយការណ៍នានាសម្រាប់ការវិភាគ ឬការស៊ើបអង្កេតនានា ។

ខ-ការផ្តល់ការឯកភាព ឬការដោះដូរបុគ្គលិក រួមទាំងមន្ត្រីជំនាញ និងមន្ត្រីមុខងារផ្សេងៗ ។

គ-ការស៊ើបអង្កេតរួមគ្នា ។

ឃ-ការចាត់នីតិវិធីតុលាការ និង

ង-ជំនួយផ្នែករដ្ឋបាល ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចធ្វើការចចារ និងធ្វើការសន្ទត់ទៅលើកិច្ចព្រមព្រៀងនានា ជាមួយអាជ្ញាធរពង្រឹងច្បាប់បរទេស និងអង្គការអន្តរជាតិថ្នាក់តំបន់ ក្នុងគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់ដើម្បីទប់ស្កាត់ កំណត់អត្តសញ្ញាណ និងបង្ក្រាបបទល្មើសដែលពាក់ព័ន្ធទៅនឹងបទប្បញ្ញត្តិនៃច្បាប់ត្រូវអនុវត្ត ។

## ជំពូកទី៩
## ផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ និងរុក្ខជាតិ

**មាត្រា៤៣៧** ._ ផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ និងរុក្ខជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរៀបចំផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ និងរុក្ខជាតិសម្រាប់ប្រភេទនៃក្រុមទី១ និងទី២ ដែលមានដើមកំណើតនៅព្រះរាជាណាចក្រកម្ពុជាទាំងអស់ ។ ផែនការទាំងនេះត្រូវមានរយៈពេល ១០ (ដប់) ឆ្នាំ ហើយផែនការមួយអាចកំណត់បាននូវច្រើនប្រភេទ ខុសៗគ្នា ក៏រួមទាំងប្រភេទរុក្ខជាតិផងដែរ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវធ្វើការសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ក្នុងការបង្កើតផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ និងរុក្ខជាតិ និងរុក្ខជាតិ ។ ក្រៅពីនេះ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបើកឲ្យមានកិច្ចពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងពេលរៀបចំផែនការនេះ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ គន្ថីទី១ បមាតិកាទី២ នៃក្រមនេះ ។

រាល់ផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ និងរុក្ខជាតិ និងរុក្ខជាតិ ត្រូវទទួលការពិនិត្យឡើងវិញ និងការឯកភាពពីក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព នៅមុនពេលមានការប្រតិបត្តិការ ។

មន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត ត្រូវធ្វើជាអង្គភាពអនុវត្តជាមូលដ្ឋាន ក្រោមចំណុះរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រុមការងារបច្ចេកទេសជីវៈចម្រុះ និងដោយមានការសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងដៃគូបច្ចេកទេសដែលពាក់ព័ន្ធដែលរួមចំណែកក្នុងការអភិរក្សប្រភេទសត្វព្រៃ និងរុក្ខជាតិនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៤៣៨** ._ មាតិកានៃផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវកំណត់ចូលនៅក្នុងផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ នូវចំណុចដូចខាងក្រោម៖

ក- សកម្មភាពអភិរក្ស និងការពារដែលចាំបាច់នានា ជាលក្ខខណ្ឌតម្រូវ ដើម្បីធានាបាននូវចម្រុះអត្រា នៃប្រភេទដូចបានចុះបញ្ជីដែលបន្តមាននៅក្នុងប្រទេសកម្ពុជា ។

ខ- ជម្រកសំខាន់ៗសម្រាប់ការអភិរក្សប្រភេទសត្វ ។

គ- សកម្មភាពសម្រាប់ការគ្រប់គ្រងទៅតាមជម្រក និងតំបន់ ដែលចាំបាច់ក្នុងការសម្រេចបានតាមគោលដៅផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ។

ក- គោលបំណង និងលក្ខខណ្ឌជ្រើសរើសដែលអាចវាស់វែងបានថា នៅពេលសម្រេច នោះនឹងមានការតម្លើងឋានៈនៃការអភិរក្សប្រភេទក្នុងគោលដៅ។

ខ- ការប៉ាន់ប្រមាណទៅលើពេលវេលា និងធនធានហិរញ្ញវត្ថុដែលត្រូវបានកំណត់ ដើម្បីអនុវត្តវិធានការណ៍ និងសកម្មភាពដែលចាំបាច់។ នោះ ។

ផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ និងរុក្ខជាតិ អាចត្រូវបានដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ ឬផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ។

សកម្មភាពនៅក្រោមផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ អាចរួមបញ្ចូល ការផ្លាស់ប្តូរទីតាំង ការអភិរក្សនៅក្រៅកន្លែងដើម និងការបង្កាត់ដើម្បីអភិរក្ស និងការនាំមកបញ្ចូលឡើងវិញក្នុងគោលដៅអភិរក្ស។ ផែនការនានាគួរតែកំណត់ទីតាំងសមស្របសម្រាប់ការដោះលែងសត្វដែលបានពីការរឹបអូស ដែលស្ថិតក្រោមកម្មវិធីនៃការនាំមកបញ្ចូលឡើងវិញ និងការស្តារប្រភេទសត្វ ។

ក្នុងករណីមានការនាំមកបញ្ចូលឡើងវិញនូវប្រភេទតាមផែនការ នោះផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃ និងរុក្ខជាតិ ត្រូវមានទៅដោយការសិក្សាពីបុរេវិនិច្ឆ័យ ដែលកំណត់អំពីកត្តាសង្គម ការគ្រប់គ្រង និងអេកូឡូស៊ី សម្រាប់ការនាំមកបញ្ចូលឡើងវិញតាមផែនការ។

កម្មវិធីនៃការនាំមកបញ្ចូលឡើងវិញ និងការស្តារប្រភេទសត្វ និងរុក្ខជាតិ ត្រូវអនុវត្តតាមគោលការណ៍ណែនាំជាតិ និងអន្តរជាតិស្តីពីទម្លាប់នៃការអនុវត្តល្អៗបំផុត និងមានទៅដោយមតិយោបល់ទេសពីក្រុមការងារបច្ចេកទេសជីវៈចម្រុះនៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព និងអ្នកជំនាញការពាក់ព័ន្ធ ។

**មាត្រា៤៣៩**._ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គ្រប់គម្រោង ផែនការ ឬសកម្មភាពនានាដែលអាចប៉ះពាល់ដល់ជម្រក នៃប្រភេទក្នុងក្រុមទី១ និង/ឬ ក្រុមទី២ ដែលបានស្គាល់ ស្របតាមបទប្បញ្ញត្តិស្តីពីការអង្កេតតាមដាន និងការវាយតម្លៃបរិស្ថាន គន្ថីទី២ មាតិកាទី៣ នៃក្រមនេះ ត្រូវមានការពិចារណា និងការបង្ហាញថា ផែនការ ឬសកម្មភាពទាំងនោះ មិនបានបំផ្លាញចំនួនតាមធម្មជាតិរបស់ប្រភេទសត្វ និងរុក្ខជាតិនៃថ្នាក់ទាំងនោះឡើយ ក្នុងករណីត្រូវអនុវត្តតាមផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វ និងរុក្ខជាតិ ។

ករណីមានប្រភេទដែលបានកំណត់ទៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រភេទសត្វព្រៃ ដែលរងការគំរាមកំហែង ប៉ុន្តែមិនទាន់មានការរៀបចំផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃទាំងនោះនៅឡើយ នោះការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោង ផែនការ ឬសកម្មភាពនានា ដែលអាចមាន

ផលប៉ះពាល់ដល់ប្រភេទសត្វទាំងនោះ ត្រូវបង្ហាញថា គម្រោង ផែនការ ឬសកម្មភាពដែលត្រូវធ្វើ នឹងមិនបំផ្លាញដល់អត្រាតាមធម្មជាតិនៃប្រភេទសត្វទាំងនោះ នោះឡើយ ។

**មាត្រា៤៤០** ._ ការរៀបចំរបាយការណ៍ និងការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយមានកិច្ចសហការជាមួយអ្នកពាក់ព័ន្ធនានា ត្រូវទទួលខុសត្រូវលើការអនុវត្តតាមប្រព័ន្ធអង្កេតតាមដានឲ្យមានប្រសិទ្ធភាព សម្រាប់ស្ថានភាពប្រភេទទាំងឡាយ ដែលបានកំណត់ក្នុងក្រុមទី១ និងទី២ ដែលបានស្តារឡើងទៅដល់កម្រិតស្របតាមបទប្បញ្ញត្តិនៃមាតិកានេះ និងដែលត្រូវបានដកចេញពីក្រុមទី១ និងទី២ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវចេញសេចក្តីរាយការណ៍ជាសាធារណៈអំពីប្រភេទក្នុងក្រុមទី១ និងទី២ ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានផ្នែកបរិស្ថានទូទៅ គន្ថីទី ១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៤៤១** ._ ការផ្តល់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នមានសមត្ថកិច្ចដែលទទួលខុសត្រូវចេញលិខិតអនុញ្ញាតសម្រាប់គម្រោង ឬសកម្មភាពនានា ដែលពាក់ព័ន្ធនឹងការកំណត់នានារបស់ប្រភេទនៃក្រុមទី១ និងទី២ ត្រូវពិនិត្យទៅលើផែនការ ស្តារ និងគ្រប់គ្រងប្រភេទសត្វ និងរុក្ខជាតិ និងផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្ស ជីវៈចម្រុះ មុននឹងផ្តល់អាជ្ញាប័ណ្ណ ឬធ្វើការឯកភាព ។

**មាត្រា៤៤២** ._ ប្រភេទដែលស្ថិតក្រោមការអង្កេតតាមដានទៅលើឋានៈ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រោមកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ ត្រូវផ្តល់ការអង្កេតតាមដានប្រកបដោយប្រសិទ្ធភាពទៅលើស្ថានភាពនៃប្រភេទក្នុងស្រុកទាំងអស់ទៅតាមក្រុមទី១ និងទី២ រហូតដល់រយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីឋានៈនៃប្រភេទទាំងនោះបានប្តូរទៅក្រុមទី៣ ឬទី៤ ស្របតាមនីតិវិធី ដូចមានចែងក្នុងជំពូកទី ៣ នៃមាតិកានេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវចេញសេចក្តីរាយការណ៍ជាសាធារណៈអំពីឋានៈនៃប្រភេទក្នុងក្រុមទី១ និងទី២ ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានផ្នែកបរិស្ថានទូទៅ គន្ថីទី ១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៤៤៣** ._ ការបង់ថ្លៃសំណង

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិ

យុត្តដើម្បីកំណត់ចំពោះការបង់ថ្លៃសំណង ដែលបង្កដោយបុគ្គល ឬនីតិបុគ្គលណាមួយដែលបបង្កការខូចខាតដល់សត្វព្រៃ ។ ថវិកាដែលប្រមូលបាន ត្រូវប្រើសម្រាប់ការអនុវត្តតាមផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វ និងរុក្ខជាតិ ។

## ជំពូកទី១០
## ការគ្រប់គ្រងលើកន្លែងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃ

**មាត្រា៤៤៤** ._ ការចុះបញ្ជី

រាល់ទីតាំងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃ ត្រូវធ្វើការចុះបញ្ជីជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងកាន់កាប់លិខិតអនុញ្ញាតដែលមានសុពលភាព ។

**មាត្រា៤៤៥** ._ ការហាមឃាត់

ត្រូវហាមចំពោះរាល់ការបង្ខាំង ការយកមកធ្វើជាសត្វចិញ្ចឹម ជាសត្វសម្រាប់ដាក់តាំង ឬជាសត្វបម្រើការងារ នូវរាល់ប្រភេទនានាដូចបានកំណត់ក្នុងក្រុមទី១ ទី២ និងទី៣ ដែលមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅក្រៅកន្លែងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬគ្រឹះស្ថានឧទ្យានសត្វព្រៃដែលមានអាជ្ញាប័ណ្ណ លើកលែងតែសម្រាប់ប្រភេទដែលស្ថិតក្នុងករណីលើកលែងដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៤៤៦** ._ លិខិតអនុញ្ញាត

រាល់ទីតាំងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃ ដែលមានបំណងរក្សាទុកសត្វព្រៃច្រើនប្រភេទ ត្រូវមានការអនុញ្ញាតដែលចាំបាច់សម្រាប់ប្រភេទទាំងនោះ ។

**មាត្រា៤៤៧** ._ ប្រភេទសត្វព្រៃដែលមានការហាមឃាត់ទាំងស្រុង

ក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព អាចផ្តល់ជាអនុសាសន៍ ជូនដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ពីប្រភេទសត្វព្រៃដែលហាមដាច់ខាតមិនឲ្យមានការបង្ខាំង។

**មាត្រា៤៤៨** ._ ការធ្វើអធិការកិច្ច

រាល់ទីតាំងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃ ត្រូវស្ថិតនៅក្រោមក្របខ័ណ្ឌនៃអធិការកិច្ចដែលត្រូវធ្វើដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន

**មាត្រា៤៤៩** ._ ការដកហូត និងបញ្ឈប់បណ្ដោះអាសន្ន

ករណីមិនបានបំពេញតាមលក្ខខណ្ឌនានាសម្រាប់ការបង្ខាំង ឬរក្សាទុកសត្វព្រៃ នោះក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអង្គភាពពង្រឹងការអនុវត្តច្បាប់ទាំងឡាយ មានសិទ្ធិក្នុងការដកហូត ឬបញ្ឈប់ប្រតិបត្តិការនៃលិខិតអនុញ្ញាតជាបណ្ដោះអាសន្ន ហើយធ្វើការរឹបអូសរាល់សត្វទាំងឡាយដែលត្រូវបានបង្ខាំង ។

**មាត្រា៤៥០** ._ ការអង្កេតតាមដាន និងធ្វើកំណត់ហេតុ

រាល់ទីតាំងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃ មានភារកិច្ចធ្វើកំណត់ហេតុពីកំណើត ការស្លាប់ និងការផ្ទេរនានា ពាក់ព័ន្ធទៅនឹងសត្វព្រៃដូចបានកំណត់ក្នុងក្រុមទី១ ទី២ និងទី៣ ។ ព័ត៌មានទាំងនេះ ត្រូវធ្វើការចែកចាយដល់អាជ្ញាធរសម្រាប់ការធ្វើអធិការកិច្ចប្រចាំឆ្នាំ ហើយរាល់សត្វទាំងឡាយដែលមិនបានចុះក្នុងកំណត់ត្រា នោះត្រូវរាប់ថា ជាសត្វដែលបានពីការបបាញ់ខុសច្បាប់ ។

**មាត្រា៤៥១** ._ ការផ្ទេរ និងការប្ដូរទីតាំង

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងដៃគូបច្ចេកទេស ត្រូវជូនដំណឹងជាមុន អំពីរាល់ការផ្ទេរ និងការប្ដូរទីតាំងនៃប្រភេទសត្វព្រៃដែលបានកំណត់ក្នុងក្រុមទី១ និងទី២ ហើយលិខិតអនុញ្ញាតដឹកជញ្ជូន ត្រូវយកតាមខ្លួនជានិច្ច ។ ការប្ដូរទីកន្លែងនានារវាងមជ្ឈមណ្ឌលបង្កាត់ពូជមួយ ទៅមណ្ឌលមួយទៀត ត្រូវមានកំណត់ត្រាច្បាស់លាស់ អាចតាមដានបាន និងធ្វើការជូនដំណឹងប្រកបដោយតម្លាភាព និងត្រូវត្រៀមឯកសារទាំងនោះ សម្រាប់ក្រុមអធិការកិច្ចនៃទីភ្នាក់ងារដែលទទួលបន្ទុក ។

**មាត្រា៤៥២** ._ ការបោះបង់ចោលបំណែក សាច់ ឬវត្ថុតាំងលម្អ នៃសត្វព្រៃ

ការបោះបង់ចោលបំណែក សាច់ ឬវត្ថុតាំងលម្អ នៃសត្វព្រៃ ដែលបានងាប់ក្នុងការបង្ខាំង ត្រូវធ្វើឡើងស្របតាមលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងជំពូកទី១១ នៃមាតិកានេះ ។ ការរក្សាទុកសរីរាង្គទាំងមូល ឬជាផ្នែកនៃសត្វដែលស្លាប់នៅក្នុងទីតាំងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬគ្រឹះស្ថានឧទ្យានសត្វព្រៃ ត្រូវហាមឃាត់ ។

**មាត្រា៤៥៣** ._ លក្ខខណ្ឌតម្រូវនៃការព្យាបាល និងទីកន្លែង

រាល់សត្វព្រៃដែលត្រូវបានបង្ខាំង នៅតាមទីតាំងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃគ្រឹះស្ថានឧទ្យានសត្វព្រៃ និងកន្លែងផ្ទុកឯកជន ត្រូវទទួលការថែទាំប្រកបដោយមនុស្សធម៌ និងរបៀបសមរម្យ ដើម្បីធានាថា មានការអនុលោមតាមពិធីសារនៃសុខុមាលភាពរបស់សត្វ ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវបង្កើតការថែទាំ ការការពារ និងការស្រាវជ្រាវសម្រាប់ប្រភេទសត្វទាំងនេះ ក្រោមកិច្ចសហការជាមួយដៃគូបច្ចេកទេស និងអ្នកពាក់ព័ន្ធផ្សេងទៀត ហើយត្រូវចេញនូវលិខិតបទដ្ឋានគតិយុត្តស្ដីពីពិធីការនៃការចិញ្ចឹម និងសុខុមាលភាពសត្វព្រៃ ។

**មាត្រា៤៥៤** ._ ការរឹបអូស

នៅពេលដែលរបបអាហារ ទ្រុង ទីបង្ខាំង ការចិញ្ចឹម សុខភាព ឬលក្ខខណ្ឌតម្រូវផ្សេងទៀតសម្រាប់សត្វព្រៃ មិនត្រូវបានអនុវត្តបានគ្រប់គ្រាន់ ទៅតាមស្តង់ដារអន្តរជាតិនានាដែលបានឯកភាព នោះក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអង្គភាពពង្រឹងការអនុវត្តច្បាប់ អាចរឹបអូសសត្វទាំងឡាយ និងឧបករណ៍ដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា៤៥៥** ._ លក្ខណៈធម្មជាតិរបស់សត្វ

ទីតាំងនានាដែលអនុវត្តការបង្កាត់ពូជសត្វអភិរក្ស ដូចបានកំណត់ក្រោមក្រុមទី១ និងទី២ ត្រូវធានាបាននូវលក្ខណៈធម្មជាតិតាមពូជរបស់សត្វ និងទម្លាប់ពីធម្មជាតិ តាមវិធីដូចខាងក្រោម៖

ក- រៀបចំបញ្ជីកំណត់ត្រាអំពីប្រភេទពាក់ព័ន្ធ ដែលកំណត់អំពីគ្រប់ប្រភេទនីមួយៗ នៅក្នុងកម្មវិធីបង្កាត់ពូជ ។

ខ- កាផ្តល់នូវការថែទាំ និងការបង្ខាំងបានសមរម្យ ។

គ- ការបន្តបំពេញតាមស្តង់ដារសុខមាលភាពនៃសត្វស្របតាមលិខិតបទដ្ឋានគតិយុត្ត ។

ឃ- រាល់សកម្មភាពផ្សេងទៀត ដែលពង្រីកលក្ខណៈធម្មជាតិតាមពូជរបស់សត្វ និងទម្លាប់ពីធម្មជាតិរបស់សត្វ។

គ្រប់ព្រឹត្តិការណ៍ និងពពួកពូជតែមួយ ត្រូវធ្វើការកត់ត្រាឲ្យបានត្រឹមត្រូវនូវសត្វដើម និងកូន ដែលកើតពីពួកវាដែលអាចសម្គាល់បាន ។ គ្រប់ប្រភេទសត្វទាំងនេះ ត្រូវដាក់សញ្ញាសម្គាល់ជាអចិន្ត្រៃយ៍ ដើម្បីសម្រួលដល់ការកត់ត្រាពីភាគរយ និងដើមកំណើតរបស់ពួកវា ។

**មាត្រា៤៥៦** ._ បញ្ជីទិន្នន័យថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើត និងគ្រប់គ្រងទិន្នន័យដេតាបេស មួយ សម្រាប់ការពិនិត្យតាមដាន និងការគ្រប់គ្រងដែលមានលក្ខណៈតឹងរឹង និងដែលនៅជិត ទៅលើសត្វដែលត្រូវបង្ខាំង និងទីតាំងបង្ខាំង ។

**មាត្រា៤៥៧** ._ ការដោះលែង

នៅទីដែលមានសត្វរស់នៅដោយការបង្ខាំង ឬបានកើតក្នុងទីបង្ខាំង ហើយមានការកំណត់ឲ្យដោះលែងជាបន្តបន្ទាប់ ត្រូវអនុលោមតាមពិធីសាររបស់អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ ។ នៅមុនការដោះលែង ត្រូវពិនិត្យសុខភាពរបស់សត្វទាំងនោះ កំណត់អត្តសញ្ញាណ និងរៀបចំកន្លែងដោះលែង ការសម្របតាមអាកាសធាតុនៃសត្វដែលត្រូវដោះលែង និងការអង្កេតតាមដានក្រោយការដោះលែង ក្នុងករណីចាំបាច់ ។

## ជំពូកទី១១
## ការគ្រប់គ្រងទៅលើសត្វព្រៃ និងផ្នែកនៃសត្វព្រៃដែលបានរឹបអូស

**មាត្រា៤៥៨** ._ នីតិវិធីនៃការគ្រប់គ្រងសត្វព្រៃ

គ្រប់សត្វព្រៃ និងផ្នែកនៃសត្វព្រៃដែលរឹបអូសបានស្របតាមមាតិកានេះ ត្រូវអនុវត្តតាមកត្តាដូចមានចែងខាងក្រោម៖

ក-ក្នុងករណីជាសត្វរស់ ហើយមានដើមកំណើតក្នុងស្រុក ត្រូវធ្វើការវាយតម្លៃសុខភាព និងភាពសមស្របនានា មុនការដោះលែងចូលទៅក្នុងជម្រកសត្វព្រៃ ករណីសមរម្យ ឬត្រូវបញ្ជូនទៅមជ្ឈមណ្ឌលដែលបានឯកភាព ។

ខ-ក្នុងករណីជាសត្វព្រៃ ឬជាផ្នែកដែលងាប់ ត្រូវបំផ្លាញចោល រក្សាទុក ឬស្តុកទុក ស្របតាមនីតិវិធី ដែលត្រូវអនុវត្ត ។

គ-ក្នុងករណីជាសត្វរស់ និងមិនមានដើមកំណើតក្នុងស្រុក នោះត្រូវបញ្ជូនទៅមជ្ឈមណ្ឌលសង្គ្រោះដែលបានទទួលការឯកភាព រង់ចាំការបញ្ជូនទៅកន្លែងដើម ទៅតាមដែលអាចអនុវត្តបាន ។

**មាត្រា៤៥៩**._ នីតិវិធីនៃជីវៈសុវត្ថិភាព

បុគ្គលទាំងឡាយដែលជាប់ពាក់ព័ន្ធទៅនឹងការរឹបអូសសត្វព្រៃទាំងរស់ និងផ្នែកសត្វទាំងនោះ ត្រូវអនុវត្តតាមនីតិវិធីជីវៈសុវត្ថិភាពដើម្បីជៀសវាងការបំពុលសត្វដទៃទៀត ឬជំងឺដែលអាចឆ្លង ឬមិនឆ្លងដល់មនុស្ស ។

ការដឹកជញ្ជូនសត្វព្រៃដែលបានរឹបអូស ត្រូវអនុលោមតាមការថែទាំសង្គ្រោះបន្ទាន់ និងជំនួយបឋម និងនីតិវិធីនៃការដឹកជញ្ជូនប្រកបដោយមនុស្សធម៌ ។

វត្ថុតាងនៃការរឹបអូសនានា អាចអនុលោមតាមក្របខ័ណ្ឌនៃការយកសំណាក ក្នុងគោលបំណងអង្កេតតាមដានពីសុខភាពរបស់សត្វព្រៃ ទៅតាមយុទ្ធសាស្ត្រ និងពិធីសារនៃការពិនិត្យតាមដានសុខភាព ដែលត្រូវបង្កើតដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រោមការសម្របសម្រួលជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងដៃគូបច្ចេកទេសនានា ។

**មាត្រា៤៦០**._ ភស្តុតាង

ករណីត្រូវរក្សាទុកវត្ថុដែលរឹបអូសបានទុកជាភស្តុតាងសម្រាប់នីតិវិធីតុលាការ នោះរាល់សត្វព្រៃដែលងាប់ និងបំណែករបស់សត្វទាំងនោះ ដូចបានកំណត់ក្នុងក្រុមទី២ ទី៣ និងទី៤ ត្រូវរក្សាទុកប្រកបដោយសុវត្ថិភាព នៅតាមស្ថាប័នដែលមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យ បរិស្ថាន ទៅតាមពិធីសារស្តីពីការគ្រប់គ្រង និងសន្តិសុខដែលសមរម្យ រហូតដល់ពេលបញ្ចប់នីតិវិធីតុលាការ ។

មិនត្រូវមានការរក្សាទុកជាភស្តុតាងសម្រាប់នីតិវិធីតុលាការនូវសត្វព្រៃ ឬបំណែកសត្វព្រៃដែលរស់ ក្រៅពីភស្តុតាងជារូបភាព និងឯកសារផ្លូវច្បាប់ដែលពាក់ព័ន្ធនោះឡើយ ។ រាល់សត្វព្រៃរស់ដែលបានរឹបអូសត្រូវទទួលការថែទាំសង្គ្រោះបន្ទាន់ និងជំនួយបឋមភ្លាមៗ ហើយត្រូវធ្វើការប្រគល់ទៅឲ្យអង្គភាពឯកទេសប្រឆាំងអំពើជួញដូរសត្វព្រៃ ដើម្បីធ្វើការបែងចែកទៅឲ្យមជ្ឈមណ្ឌលសង្គ្រោះដែលបានទទួលការឯកភាព ។

នៅពេលនីតិវិធីតុលាការបានបញ្ចប់ ឬមានការអនុញ្ញាតពីតុលាការ រាល់វត្ថុតាងនៃសត្វព្រៃងាប់ និងបំណែកសត្វដូចបានកំណត់ក្នុងក្រុមទី២ ទី៣ និងទី៤ ទាំងនោះ ត្រូវធ្វើការប្រគល់ជូនទៅក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងធ្វើការបំផ្លាញចោលស្របតាមនីតិវិធីដែលបានឯកភាព ។

រាល់ការរឹបអូសសត្វព្រៃ និងបំណែកសត្វនានា ដូចបានកំណត់ក្រោមក្រុមទី១ ត្រូវធ្វើការផ្ទេរទៅក្រោមការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដើម្បីអនុវត្តទៅតាមនីវិធីស្តីពីការបំផ្លាញ និងសន្តិសុខ ដែលសមរម្យ និងដែលបំពេញតាមលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ

និងដើម្បីធ្វើបច្ចុប្បន្នភាពថ្នាក់ជាតិឲ្យបានទៀតទាត់អំពីសន្និធិនៃផលិតផលទាំងនេះដើម្បីជួយទប់ស្កាត់បទល្មើសជួញដូរសត្វព្រៃ ។

**មាត្រា៤៦១ ._** ការរៀបចំរបាយការណ៍តាមអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់

គ្រប់អង្គភាពពង្រឹងការអនុវត្តច្បាប់ ដែលបានធ្វើការរឹបអូសប្រភេទសត្វ និងរុក្ខជាតិជិតផុតពូជដូចបានកំណត់ក្នុងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ជាសត្វទាំងមូល ឬជាបំណែកនៃសត្វនានា ពីប្រទេសផ្សេង បន្ទាប់ពីបានរឹបអូស ៤៨ (សែសិបប្រាំបី) ម៉ោង នោះត្រូវរៀបចំសេចក្តីរាយការណ៍ជូនដល់អាជ្ញាធរគ្រប់គ្រងដែលទទួលបន្ទុកលើអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ។

អាជ្ញាធរគ្រប់គ្រងដែលទទួលបន្ទុកលើអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ត្រូវធ្វើសេចក្តីរាយការណ៍ជូនដល់លេខាធិការដ្ឋានសម្រាប់អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ស្របតាមកាតព្វកិច្ចស្តីពីការរាយការណ៍ដូចបានកំណត់នៅក្នុងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ។

ករណីមានប្រភេទដូចបានកំណត់នៅក្នុងអនុញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ត្រូវបានរឹបអូសក្នុងពេលកំពុងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ឬកំពុងចែកចាយទៅឲ្យព្រះរាជាណាចក្រកម្ពុជាជាប្រទេសគោលដៅ នោះក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ត្រូវចាត់វិធានការបំផ្លាញវត្ថុតាងដែលរឹបអូសបានស្របតាមវិធាននានាដូចបានកំណត់នៅក្នុងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ និងដោយរួមសហការជាមួយអាជ្ញាធរគ្រប់គ្រប់ដែលទទួលបន្ទុកលើអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ក៏ដូចជាអង្គភាពពង្រឹងការអនុវត្តច្បាប់ប្រឆាំងការជួញដូរសត្វព្រៃ ។

**មាត្រា៤៦២ ._** សហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់អន្តរជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានអាចធ្វើការចចារ និងកំណត់ពីកិច្ចព្រមព្រៀងនានាជាមួយអាជ្ញាពរពង្រឹងការអនុវត្តច្បាប់អន្តរជាតិ ឬអង្គការអន្តរជាតិថ្នាក់តំបន់ក្នុងគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់អន្តរជាតិដើម្បីទប់ស្កាត់ កំណត់អត្តសញ្ញាណ និងបង្ក្រាបបទល្មើសដែលពាក់ព័ន្ធទៅនឹងបទប្បញ្ញត្តិទាំងនេះ ។

## ជំពូកទី១២
## ការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វព្រៃ

**មាត្រា៤៦៣** ._ ការហាមឃាត់

ហាមឃាត់មិនឲ្យមានការបង្កើតកសិដ្ឋានចិញ្ចឹមសត្វព្រៃ ឬទីតាំងបង្កាត់ពូជសត្វព្រៃដទៃទៀត ដោយគ្មានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានឡើយ ។

ហាមមិនឲ្យមានការចិញ្ចឹម រក្សាទុក បង្កាត់ពូជ ស្តុកទុក ឬថែទាំ សត្វព្រៃណាមួយ ក្នុងកសិដ្ឋានសត្វព្រៃ ឬទីតាំងបង្ខាំងសត្វព្រៃដទៃក្នុងចម្ងាយ ២០ (ម្ភៃ) គីឡូម៉ែត្រ ពីរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិ ដែលកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នោះឡើយ ។

ហាមមិនឲ្យដាក់បញ្ចូលសត្វព្រៃដែលចាប់បានពីព្រៃចូលទៅក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃនោះឡើយ ។ កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវទទួល និងទិញសត្វព្រៃពីកសិដ្ឋានដទៃទៀតដែលមានវិញ្ញាបនបត្រឯកភាពដែលមានសុពលភាពតែប៉ុណ្ណោះ ។

**មាត្រា៤៦៤** ._ ការដាក់កំហិតទៅលើប្រភេទសត្វ

ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃដែលមានការអនុញ្ញាត ត្រូវរក្សាទុកតែប្រភេទសត្វទាំងឡាយណាដែលទទួលបានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានតែប៉ុណ្ណោះ ។

**មាត្រា៤៦៥** ._ លិខិតបទដ្ឋានគតិយុត្ត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានទទួលភារកិច្ចក្នុងការបង្កើត ចេញ និងពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តសម្រាប់ការបង្កើត ប្រតិបត្តិការ ការថែទាំ អធិការកិច្ច ការអង្កេតតាមដាន និងការកំណត់ក្របខ័ណ្ឌនានាសម្រាប់កន្លែងដែលចិញ្ចឹម រក្សាទុក ស្តុកទុក ឬថែទាំសត្វព្រៃនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានមានភារកិច្ចធ្វើអធិការកិច្ច អង្កេតតាមដាន កំណត់ក្របខ័ណ្ឌ ដកហូតលិខិតអនុញ្ញាត បិទ និងរៀបចំបណ្តឹងទៅតុលាការ ពាក់ព័ន្ធទៅនឹងកសិដ្ឋានសត្វព្រៃដែលមានស្រាប់ និងដែលអាចពាក់ព័ន្ធទៅនឹងការបបាញ់ ឬសកម្មភាពនៃអាជីវកម្មសត្វព្រៃដែលបានហាមឃាត់ ដូចបានកំណត់នៅក្នុងមាតិកានេះ ឬដែលមិនអនុលោមតាមគោលការណ៍ដែលជាក្របខ័ណ្ឌចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ។

**មាត្រា៤៦៦ ._** កំណត់ត្រា និងសារពើភ័ណ្ឌ

គ្រប់សត្វព្រៃនៅក្នុងកសិដ្ឋានសត្វព្រៃ ត្រូវធ្វើអត្តសញ្ញាណកម្មដោយឡែកៗនៅគ្រប់ពេលវេលា ។ ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវធ្វើកំណត់ត្រារបាយការណ៍អំពីសារពើភ័ណ្ឌត្រឹមត្រូវមួយទៅតាមទម្រង់បែបបទដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងដែលបញ្ជាក់ពីទិដ្ឋភាព ដែលមានដូចតទៅៈ

ក-ប្រភេទសត្វ ។

ខ-អត្តសញ្ញាណពិសេសរបស់សត្វ មានទាំងការប្រួលប្រែទាំងឡាយដែលទៅលើអត្តសញ្ញាណ និងកាលបរិច្ឆេទនៃការប្រួលប្រែទាំងនោះ ។

គ-ភេទសត្វ ។

ឃ-ថ្ងៃខែឆ្នាំកំណើត ។

ង-ករណីសត្វដែលមិនកើតនៅក្នុងកសិដ្ឋានសត្វព្រៃរបស់ប្រតិបត្តិករ នោះត្រូវមានៈ

១-កាលបរិច្ឆេទដែលប្រតិបត្តិករទទួលសត្វព្រៃមកដាក់ក្នុងកសិដ្ឋាន ។

២-ឈ្មោះ និងអាស័យដ្ឋានរបស់អ្នកដែលបានប្រគល់សត្វមកឲ្យកសិដ្ឋាន ។

៣-ទីតាំងនៃកសិដ្ឋានដែលបានប្រគល់សត្វព្រៃ ។

ច-កាលបរិច្ឆេទនៃការស្លាប់ មូលហេតុនៃការស្លាប់ ករណីដឹង និងលទ្ធផលនៃការពិសោធន៍នានា ។

ឆ-ការប្តូរទីតាំងរបស់សត្វចេញពីកសិដ្ឋានរបស់ប្រតិបត្តិករ ត្រូវមានៈ

១-កាលបរិច្ឆេទនៃការប្តូរទីតាំង ។

២-ទីតាំងដាក់សត្វដែលបានប្តូរទីតាំង ។

៣-ឈ្មោះ និងអាស័យដ្ឋានរបស់អ្នកដែលទទួលសត្វ ។

**មាត្រា៤៦៧ ._** ការលក់ដូរសត្វព្រៃចិញ្ចឹម និងផលិតផលសត្វព្រៃ

ការហាមឃាត់ចំពោះ ការលក់ដូរសត្វព្រៃដែលបានចិញ្ចឹម និងផលិតផលសត្វព្រៃ មានដូចតទៅៈ

ក-ហាមមិនឲ្យកសិដ្ឋានសត្វព្រៃលក់ដូរ ឬធ្វើអាជីវកម្មសត្វព្រៃរស់ ឬដែលបានសម្លាប់ ដល់បុគ្គលណាឡើយ ក្រៅពីកសិដ្ឋានដែលមានការអនុញ្ញាត ។

ខ-ហាមមិនឲ្យកសិដ្ឋានសត្វព្រៃទិញពី ឬធ្វើអាជីវកម្មសត្វព្រៃរស់ ឬស្លាប់ ដល់បុគ្គលណាឡើយ ក្រៅពីកសិដ្ឋានដែលមានការអនុញ្ញាត ។

គ-រាល់ប្រតិបត្តិការនៃពាណិជ្ជកម្មពាក់ព័ន្ធនឹងសត្វព្រៃដែលបានពីកសិដ្ឋាន ត្រូវមានកំណត់ត្រា និងការរៀបចំសម្រាប់អធិការកិច្ចតាមតម្រូវការ ។

**មាត្រា៤៦៨ ._** ការញែកសត្វដោយឡែក និងការអង្កេតតាមដានពីសុខភាព

ត្រូវមានការញែកសត្វដោយឡែក និងការអង្កេតតាមដានពីសុខភាព នៅមុនការដាក់បញ្ចូលសត្វព្រៃថ្មីចូលទៅក្នុងកសិដ្ឋាន ។

ក្នុងករណីរកឃើញថា មានសត្វព្រៃស្លាប់នៅក្នុងកសិដ្ឋាន នោះប្រតិបត្តិករ ត្រូវរាយការណ៍ភ្លាមៗពីការស្លាប់នេះ ទៅកាន់មន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត ។ សត្វព្រៃដែលស្លាប់ ត្រូវមានអធិការកិច្ច ទទួលសំណាក និងបោះបង់ចោលស្របតាមលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច និងនីតិបុគ្គលដែលពាក់ព័ន្ធ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចស្នើឲ្យបំពេញតាមក្របខ័ណ្ឌតាមដាននៅនឹងកន្លែងទៅលើជំងឺទាំងឡាយណាស្ថិតក្នុងកង្វល់ជាពិសេស ស្របតាមលក្ខខណ្ឌដូចតទៅ៖

ក-ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធ្វើបញ្ជី និងចេញផ្សាយនូវប្រភេទជំងឺដែលស្ថិតក្នុងកង្វល់ជាពិសេស សម្រាប់បំពេញតាមក្របខ័ណ្ឌតាមដាននៅនឹងកន្លែងនៃកសិដ្ឋានសត្វព្រៃ ហើយបង្កើតជាពិធីសារនៃការការឆ្លើយឆ្លង ក្រោមកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ ។

ខ-ប្រតិបត្តិករ ត្រូវរាយការណ៍ភ្លាមៗទៅកាន់មន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត ក្នុងករណីមានការសង្ស័យ ឬដឹងថា មានសត្វព្រៃណាមួយមានផ្ទុកនូវជំងឺស្ថិតក្នុងការព្រួយបារម្ភជាពិសេស ឬនៅពេលដឹង ឬសង្ស័យថា មានសត្វណាមួយមានជាប់ពាក់ព័ន្ធទៅនឹងសត្វដែលមានជំងឺ ។

គ-ហាមមិនឲ្យបុគ្គលណាមួយរក្សា លាក់ទុក ដឹកជញ្ជូន លក់ ធ្វើប្រទានកម្ម ឬប្រើប្រាស់សត្វព្រៃទាំងឡាយណាដែលបានដឹង ឬសង្ស័យថា មានផ្ទុកជំងឺស្ថិតក្នុងការព្រួយបារម្ភជាពិសេស ឬដែលបានដឹងថា បានស្លាប់ដោយមូលហេតុមិនច្បាស់លាស់ក្នុងកសិដ្ឋានឡើយ ។

ឃ-ប្រតិបត្តិករនៃកសិដ្ឋានសត្វព្រៃ ត្រូវបំពេញតាមពិធីសារ ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និង

ង-រាល់ការខកខានមិនបានមិនអនុលោមតាមពិធីសារស្ដីពីការតាមដានជំងឺ អាចនាំឲ្យមានការបិទកសិដ្ឋានជាបណ្ដោះអាសន្ន ឬអចិន្ត្រៃយ៍ ។

**មាត្រា៤៦៩ ._** លក្ខខណ្ឌតម្រូវជាអប្បបរមា

ដោយមានការពិគ្រោះជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងដៃគូបច្ចេកទេស ក្រសួង ស្ថាប័

នទទួលបន្ទុកវិស័យបរិស្ថានត្រូវបង្កើតលក្ខខណ្ឌតម្រូវជាអប្បប្រមាសម្រាប់ទីតាំងកសិដ្ឋាន និងកន្លែងបង្ខាំងសត្វព្រៃ ដែលត្រូវបំពេញតាមពិធីសារស្តីពីការចិញ្ចឹម និងសុខុមាលភាពសត្វព្រៃ ។

នៅពេលណាក៏បាន ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចធ្វើអធិការកិច្ចទៅលើការអនុលោមតាមរបស់កសិដ្ឋានសត្វព្រៃទាំងឡាយ ទៅតាមលក្ខខណ្ឌតម្រូវទាំងនេះ និងត្រូវសហការជាមួយដៃគូបច្ចេកទេសចិញ្ចឹមសត្វព្រៃ និងស្ថាប័នប្រឆាំងបទល្មើសជួញដូរសត្វព្រៃដើម្បីធ្វើអធិការកិច្ចប្រចាំឆ្នាំ ។

ប្រតិបត្តិករទាំងឡាយ ដែលមិនអនុលោមតាមលក្ខខណ្ឌតម្រូវដែលបានកំណត់ អាចនាំឲ្យមានការដកហូត ឬលុបចោលលិខិតអនុញ្ញាត និងទទួលទណ្ឌកម្មបន្ថែម ដូចបានកំណត់ក្នុងបទប្បញ្ញត្តិស្តីពីបទល្មើសបរិស្ថាន និងធនធានធម្មជាតិ នៅក្នុងគន្ថីទី៩ មាតិកាទី៤ នៃក្រមនេះ ។

**មាត្រា៤៧០** ._ លក្ខខណ្ឌតម្រូវទូទៅ

ប្រតិបត្តិករនៃកសិដ្ឋានដែលអនុញ្ញាត គ្រប់ពេលត្រូវផ្តល់ការថែទាំសមរម្យ ដល់រាល់សត្វព្រៃចិញ្ចឹមទាំងឡាយ ដែលមានដូចតទៅ៖

ក-ការដឹកជញ្ជូនសត្វព្រៃទៅកាន់ និងពីកសិដ្ឋាន ត្រូវអនុលោមតាមពិធីសារស្តីពីការដឹកជញ្ជូនដោយមនុស្សធម៌ ។

ខ-គ្រប់ប្រតិបត្តិករនៃកសិដ្ឋានសត្វព្រៃ ត្រូវធានាបាននូវទីជម្រក អាហារ ទឹកសាប ម្លប់ និងទីធ្លាសមរម្យ ហើយទីបង្ខាំងមិនត្រូវមានលក្ខណៈចង្អៀតខ្លាំង និងមានការសម្អាតជាប្រចាំថ្ងៃ ។

គ-ការកាន់ ឬប៉ះពាល់សត្វ ត្រូវអនុវត្តតាមបទពិសោធន៍ដែលអាចទទួលយកបានជាទូទៅនៃការចិញ្ចឹមសត្វ ការគ្រប់គ្រង ការសម្លាប់ និងសុខភាពរបស់សត្វ ។

ឃ-ករណីប្រតិបត្តិករ មិនអនុវត្តការថែទាំងជិតដល់ និងប៉ះពាល់សត្វមិនបានត្រឹមត្រូវ នោះមន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចលុប ឬដកហូតលិខិតអនុញ្ញាតនៃកសិដ្ឋាន និងបិទកសិដ្ឋានជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ។

**មាត្រា៤៧១** ._ ការទប់ស្កាត់ការរត់គេច

ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃទាំងឡាយ មិនត្រូវបណ្តោយឲ្យសត្វរបស់ខ្លួនរួច ឬគេចពីការបង្ខាំង ឬព្រលែងចូលទៅក្នុងព្រៃឡើយ ។ ករណីមានការរួចពីការបង្ខាំង នោះប្រតិបត្តិករនៃកសិដ្ឋានទទួលបន្ទុកត្រូវ៖

ក-ជូនដំណឹងដល់មន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្តក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង ។

ខ-ត្រូវខិតខំតាមដែលអាចធ្វើបាន ក្នុងការចាប់យកមកបង្ខាំងវិញ ។

**មាត្រា៤៧២** ._ ការសម្លាប់ដោយមនុស្សធម៌

រាល់ការសម្លាប់សត្វចិញ្ចឹម ត្រូវអនុវត្តដោយមនុស្សធម៌ ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវចេញនូវលិខិតបទដ្ឋានគតិយុត្តសម្រាប់ការសម្លាប់សត្វចិញ្ចឹម ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នសុខភាព និងផលិតកម្មសត្វ ។

**មាត្រា៤៧៣** ._ ការដឹកជញ្ជូន

រាល់ប្រតិបត្តិករនៃកសិដ្ឋានសត្វព្រៃ ត្រូវផ្តល់ការដឹកជញ្ជូន រាល់សត្វព្រៃដែលត្រូវបង្ខាំង ស្របតាមនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តផ្លូវច្បាប់ ដែលបង្កើតដោយនាយកដ្ឋានសុខភាព និងផលិតកម្មសត្វ ។

**មាត្រា៤៧៤** ._ ការមិនទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន មិនត្រូវទទួលខុសត្រូវទោះបីក្នុងករណីណាមួយដូចខាងក្រោម៖

ក-រាល់ការខូចខាតទៅលើទ្រព្យសម្បត្តិ ឬការប៉ះពាល់ទាំងឡាយណា ដែលបង្កដោយសត្វព្រៃចិញ្ចឹម ឬដោយការរួចពីការបង្ខាំងរបស់សត្វព្រៃចិញ្ចឹមនោះទេ ។

ខ- រាល់ការបាត់បង់ ឬការស្លាប់របស់សត្វព្រៃចិញ្ចឹមណាមួយឡើយ មិនថាដោយការរួច ឬការស្លាប់ដោយសារជំងឺឡើយ បើទោះជាក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានអាចតម្រូវឲ្យមានការសម្លាប់សត្វព្រៃចិញ្ចឹមណាមួយដែលរួច ឬដោយសារស្ថានភាពនៃជំងឺក៏ដោយ ។

**មាត្រា៤៧៥** ._ កាតព្វកិច្ចរបស់ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ

ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ដែលកំពុងមានប្រតិបត្តិការ បន្ទាប់ពីក្រមនេះចូលជាធរមាន៖

ក-ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតថ្មីក្នុងរយៈពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ

ខ-ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិទាំងនេះ ដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការនៃកសិដ្ឋានសត្វព្រៃនានា ។

## ជំពូកទី១៣

## ការតាមដានសុខភាពសត្វព្រៃ

**មាត្រា៤៧៦** ._ វិធីសាស្ត្រតាមដានជំងឺសត្វព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវបង្កើតវិធីសាស្ត្រតាមដានជំងឺសត្វព្រៃ និងការអង្កេតតាមដានសុខភាពសត្វព្រៃ ដោយមានការសម្របសម្រួលជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច អង្គភាពមិនមែនរដ្ឋាភិបាល និងដៃគូបច្ចេកទេស ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធ្វើការស៊ើបអង្កេត ធ្វើកំណត់ត្រា និងឆ្លើយតបចំពោះរាល់ការតាមដានសុខភាពសត្វព្រៃ និងការស៊ើបអង្កេតពីការលេចឡើងនៃជំងឺសត្វព្រៃ ដោយមានការសម្របសម្រួលជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច អង្គភាពមិនមែនរដ្ឋាភិបាល និងដៃគូបច្ចេកទេស ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវផ្តល់ព័ត៌មានអំពីសមិទ្ធិផល និងការរកឃើញនានា ពាក់ព័ន្ធទៅនឹងការតាមដានសុខភាពសត្វព្រៃ និងការស៊ើបអង្កេតដល់ការលេចឡើងនូវជំងឺសត្វព្រៃ ដល់ភាគីដែលពាក់ព័ន្ធនឹងសត្វ ឬសុខភាពសាធារណៈ ឲ្យបានទាន់ពេលវេលា និងអង្គការសុខភាពអន្តរជាតិដែលពាក់ព័ន្ធ ជាពិសេសក្នុងករណីមានជំងឺដែលឆ្លងពីសត្វទៅមនុស្ស ។

**មាត្រា៤៧៧** ._ ការញែកដោយឡែក

នៅមុនការប្តូរទីតាំងសត្វ ការនាំមកបញ្ចូល ឬការផ្ទេរសត្វរវាងទីបង្ខាំង និងព្រៃ នោះសត្វព្រៃត្រូវមានការញែកទុកដោយឡែក និងមានការអង្កេតតាមដាន ដោយអ្នកដែលមានសិទ្ធិ ហើយដែលត្រូវផ្តល់ការបញ្ជាក់ដូច តទៅ៖

ក-សត្វព្រៃត្រូវបានញែកទុកដោយឡែកមិនឲ្យលើសពី ១៤ថ្ងៃ ហើយមានអធិការកិច្ចនៅមុនពេលដោះលែង ។

ខ-សត្វព្រៃទាំងឡាយមិនបានបង្ហាញសញ្ញាសម្គាល់ណាមួយថាមានរបួស ឬជំងឺនោះទេ ។

គ-សត្វព្រៃទាំងនោះត្រូវបានធ្វើអត្តសញ្ញាណដោយឡែកៗ ហើយមានភាពវិជ្ជមាន ។

ឃ-សត្វព្រៃទាំងនោះត្រូវបានពិសោធន៍ ហើយរួចពីជំងឺក្រោមកង្វល់ជាពិសេសសម្រាប់ប្រភេទសត្វបែបទាំងនោះ ។

**មាត្រា៤៧៨** ._ ការរៀបចំរបាយការណ៍

មន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវជូនដំណឹងភ្លាមៗ ករណីមានសត្វព្រៃចិញ្ចឹមណាមួយកើតជំងឺ ឬស្លាប់ក្នុងពេលញែកដោយឡែកនោះ ។

# ជំពូកទី១៤
# លិខិតបទដ្ឋានគតិយុត្តស្តីពី
# ការការពារ ការអភិរក្ស និងការគ្រប់គ្រងសត្វព្រៃ

**មាត្រា៤៧៩ ._** លិខិតបទដ្ឋានគតិយុត្តស្តីពីការការពារ ការអភិរក្ស និងការគ្រប់គ្រងសត្វព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចចេញលិខិតបទដ្ឋានពាក់ព័ន្ធនានាទៅតាមចាំបាច់ និងអំណាចរបស់ខ្លួន ក្នុងការអនុវត្តបទប្បញ្ញត្តិនានាតាមមាតិកានេះ ឬក្នុងការផ្តល់ឱវាទនានា ឬការតម្រូវ ទៅតាមមាតិកានេះ ។

**មាត្រា៤៨០ ._** កម្មវត្ថុនៃលិខិតបទដ្ឋានគតិយុត្តស្តីពីការការពារ ការអភិរក្ស និងការគ្រប់គ្រងសត្វព្រៃ

លិខិតបទដ្ឋានគតិយុត្ត អាចធ្វើឡើងដោយមានកម្មវត្ថុដូចតទៅ៖

ក-ការរៀបចំចាត់ចែង និងការគ្រប់គ្រងសត្វព្រៃនៅក្នុង និងក្រៅរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិជាតិដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ខ-ការគ្រប់គ្រងលើការស្នើសុំការបបាញ់ និងលិខិតអនុញ្ញាតបបាញ់ និងការកំណត់ កូតា ។

គ-លក្ខខណ្ឌនានាក្នុងការបង្ខាំងសត្វព្រៃ រួមមានទីតាំងឧទ្យានសត្វព្រៃ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ កសិដ្ឋានសត្វព្រៃ និងមជ្ឈមណ្ឌលបង្កាត់ពូជអភិរក្ស ។

ឃ-ការបង្កើត ប្រតិបត្តិការ ការថែរក្សា អធិការកិច្ច ការអង្កេតតាមដាន និងការចេញលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធទៅនឹងកសិដ្ឋានសត្វព្រៃទីតាំងឧទ្យានសត្វព្រៃ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ កសិដ្ឋានសត្វព្រៃ និងមជ្ឈមណ្ឌលបង្កាត់ពូជអភិរក្ស និងទីតាំងដទៃទៀតដែលរក្សាសត្វព្រៃ ។

ង-នីតិវិធីនានាសម្រាប់ការអនុវត្តមាតិកានេះប្រកបដោយប្រសិទ្ធភាព ។

ច-ការគ្រប់គ្រងលើភស្តុតាងនានាដែលបានរឹបអូសក្រោមមាតិកានេះ រួមមានសន្តិសុខ និងសុខុមាលភាពសមរម្យរបស់សត្វព្រៃដែលរស់ តាមប្រភេទនៃក្រុមទី១ ទី២ ទី៣ និងទី៤ និងពិធីសារស្តីពីសន្តិសុខសម្រាប់ផលិតផលនៃប្រភេទក្នុងក្រុមទី១ ។

ឆ-ថ្លៃដែលត្រូវប្រមូលនានាស្របតាមមាតិកានេះ ។

ជ-នីតិវិធីសម្រាប់ការប្តូរទីតាំង ការដឹកជញ្ជូន ការចាប់ ការប៉ះពាល់ ឬកាន់សត្វព្រៃ និងការធ្វើសំណាកសត្វព្រៃ ។

ឈ-នីតិវិធីនានាសម្រាប់ការធានាបាននូវសុខភាពសត្វព្រៃ ។

ញ-ការបង្កើត ប្រតិបត្តិការ និងការទទួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព ។

ដ-នីតិវិធីនានាសម្រាប់ការធ្វើកំណត់ត្រាបទល្មើសសត្វព្រៃ ។

ឋ-វិធីសាស្ត្រប្រកបដោយមនុស្សធម៌ក្នុងការសម្លាប់សត្វព្រៃក្នុងកសិដ្ឋានសត្វព្រៃ ។

ឌ-ការបង់ថ្លៃសំណងការខូចខាតដែលបានកើតឡើងចំពោះសត្វព្រៃ ដែលបង្កដោយរូបវន្តបុគ្គល និងនីតិបុគ្គលណាមួយ ។

ឍ-ការផ្ដល់ការអង្កេតតាមដានជនល្មើស ។

## មាតិកាទី៦
## ការការពាររុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងគ្រោះថ្នាក់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៤៨១ .**_វិសាលភាពនៃការអនុវត្ត

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះរុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ី ដែលកំពុងរងគ្រោះថ្នាក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៤៨២ .**_ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ចទាំងអស់ ត្រូវចាត់វិធានការការការពារ និងអភិរក្សរុក្ខជាតិ និងប្រព័ន្ធអេកូឡូដែលកំពុងរងគ្រោះថ្នាក់ និងត្រូវប្រើសមត្ថកិច្ចដែលមានដើម្បីលើកកម្ពស់មាតិកានេះ។

ក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព ទទួលមុខងារគ្រប់គ្រងលើឋានៈរុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលកំពុងគ្រោះថ្នាក់ និងសម្របសម្រួលដល់សេចក្ដីសម្រេចអន្តរក្រសួងពាក់ព័ន្ធទៅនឹងការអភិរក្ស និងការគ្រប់គ្រងជីវៈចម្រុះ។

អាជ្ញាធរវិទ្យាសាស្ត្រ និងគ្រប់គ្រង អនុសញ្ញាស្ដីពីការគ្រប់គ្រងការធ្វើជំនួញជាអន្តរជាតិនូវប្រភេទសត្វព្រៃ និងរុក្ខជាតិព្រៃកំពុងផុតពូជ ត្រូវមានប្រតិបត្តិការពេញលេញក្រោមសមត្ថកិច្ច របស់ក្រសួង ស្ថាប័នទទួលបន្ទុក។

**មាត្រា៤៨៣ .**_ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ទទួលសមត្ថកិច្ច និងការទទួលខុសត្រូវធ្វើការកំណត់ គ្រប់គ្រង និងការពាររុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលកំពុងគ្រោះថ្នាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវមានសមត្ថកិច្ចដូចខាងក្រោមៈ

ក- ធ្វើចំណាត់ថ្នាក់ គ្រប់គ្រង និងការពាររុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ី

ខ- ត្រួតពិនិត្យ រៀបចំ និងពង្រឹងការអនុវត្តច្បាប់ ដែលពាក់ព័ន្ធ ទៅនឹងការធ្វើចំណាត់ថ្នាក់ និងការគ្រប់គ្រងរុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងគ្រោះ ។

គ- គ្រប់គ្រង កំណត់ក្របខណ្ឌ និងអនុវត្តច្បាប់ពាក់ព័ន្ធទៅនឹងការកំណត់ និងការគ្រប់គ្រងរុក្ខជាតិ និងប្រព័ន្ធដែលកំពុងរងគ្រោះថ្នាក់។

ឃ- គ្រប់គ្រង ប្រភេទរុក្ខជាតិដែលរាតត្បាត ប្រភេទរុក្ខជាតិដែលមិនមានដើមកំណើតក្នុងស្រុក ឬដែលមិនកើតឡើងដោយធម្មជាតិ ។

ង- ចាត់វិធានការនានានៅក្នុងការអភិរក្ស និងការគ្រប់គ្រងដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រដែលមានស្រាប់ និងប្រសើបំផុត។

ទប់ស្កាត់ការបាត់បង់នូវរុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងគ្រោះថ្នាក់។ ដែលកំពុងរងគ្រោះថ្នាក់

**មាត្រា៤៨៤** ._ កិច្ចសហការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវសហការ និងចែករំលែកព័ត៌មានអំពីបទល្មើសដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធអេកូឡូស៊ី និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន។ ការសហការ និងការចែករំលែកព័ត៌មាននេះ រួមមាន ជាអាទ៍ៈ

ក. ការស៊ើបអង្កេតថ្នាក់ជាតិ និងថ្នាក់អន្តរជាតិនៃការកាន់កាប់ ការធ្វើជំនួញ ឬការដឹកជញ្ជូនរុក្ខជាតិ និងឈើខុសច្បាប់ ។

ខ. ការរឹបអូសរុក្ខជាតិដែលកំពុងរងគ្រោះ និងឈើដែលបានកាន់កាប់ខុសច្បាប់ ដែលត្រូវបានធ្វើឡើង នៅក្រោមក្រមនេះ និងច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធដទៃ ទៀត ។

គ. គ្រប់បណ្ដឹងរបស់តុលាការ ពាក់ព័ន្ធនឹងរុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងគ្រោះ ។

**មាត្រា៤៨៥** ._ សមាសភាពក្រុមការងារបច្ចេកទេសជីវៈចម្រុះ

ក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព ត្រូវមានសមាសភាពអ្នកជំនាញផ្នែកជីវសាស្ត្រ និងអេកូឡូស៊ី មកបណ្តាក្រសួង ស្ថាប័នដូចខាងក្រោម៖

ក- ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន

ខ-ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត។

គ-អង្គភាព និងស្ថាប័នអប់រំ និងវិទ្យាសាស្ត្រ និងអង្គភាព និងស្ថាប័នដទៃទៀត រួមមានដៃគូបច្ចេកទេសដែលរួមចំណែកក្នុងការការពាររបៀងជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ និងការអភិរក្សប្រភេទរុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ី នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព ត្រូវជួបប្រជុំគ្នារៀងរាល់១ (មួយ) ឆ្នាំម្តងយ៉ាងតិចដើម្បី៖

ក. ពិនិត្យទៅលើបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលកំពុងរងគ្រោះ បញ្ជីថ្នាក់ជាតិស្តីពី ប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងគ្រោះ បញ្ជីថ្នាក់ជាតិស្តីពីប្រភេទសត្វ និងរុក្ខជាតិដែលទទួលរងការរាតត្បាត និងផ្តល់អនុសាសន៍ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដែលទាក់ទងទៅនឹងការធ្វើបច្ចុប្បន្នភាព ដែលចាំបាច់ទៅលើបញ្ជី និងការធ្វើ ចំណាត់ថ្នាក់ និង

ខ. ពិនិត្យ ផ្តល់អនុសាសន៍សម្រាប់ការផ្លាស់ប្តូរជាចាំបាច់ និងឯកភាពទៅលើផែនការគ្រប់គ្រង និងស្តារ ឡើងវិញនូវប្រភេទសត្វ និងរុក្ខជាតិសម្រាប់ការអនុវត្ត ផ្អែកលើមូលដ្ឋានរបាយការណ៍វិទ្យាសាស្ត្រ និងទិន្នន័យ ។

## ជំពូកទី២
## ការធ្វើចំណាត់ថ្នាក់នៃប្រភេទរុក្ខជាតិ

**មាត្រា៤៨៦** ._ បញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតនិងរក្សាបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ដែលកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុវត្តតាមការអនុម័តនៃក្រមនេះ។ បញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ត្រូវទទួលយកគ្រប់ប្រភេទរុក្ខជាតិ ដែលត្រូវបានគេស្គាល់ថាមាននៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដែលបានរាយឈ្មោះនៅក្នុងបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ ។ បញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ នឹងទទួលយកប្រភេទរុក្ខជាតិថ្មីៗជាបន្តបន្ទាប់ ដែលត្រូវបានបន្ថែមទៅក្នុងបញ្ជីក្រហម

របស់សហភាពអន្តរជាតិ អភិរក្សធម្មជាតិ ដែលត្រូវបានគេស្គាល់ថាមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានប្រសិទ្ធភាពភ្លាមៗ បន្ទាប់ពី ការវាយឈ្មោះប្រភេទរុក្ខជាតិទាំងនោះនៅក្នុងបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ ។បញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ត្រូវដាក់ឲ្យសាធារណៈជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មាន មាតិកាទី៣ នៃក្រមនេះ។

**មាត្រា៤៨៧** ._ ក្រុមនៃប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់

ប្រភេទទាំងឡាយដែលមានចែងនៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ត្រូវបែងចែកទៅតាមក្រុម ដូចតទៅ៖

ក. ក្រុមទី ១៖ គ្រប់ប្រភេទ ដែលរួមមានប្រភេទដែលមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានវាយឈ្មោះជាប្រភេទផុតពូជនៅក្នុងព្រៃ ជិតផុតពូជ ឬកំពុងផុតពូជ នៅក្នុងបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ ស្តីពីប្រភេទដែលទទួលរងគ្រោះថ្នាក់ ឬប្រភេទទាំងនោះ ដែលត្រូវបាន បន្ថែមទៅក្នុងប្រភេទដែលបានរៀបរាប់ខាងលើ នៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ។ គ្រប់ប្រភេទដែលមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានវាយឈ្មោះ នៅក្នុង ឧបសម្ព័ន្ធទី១ នៃអនុសញ្ញាស្តីពីការគ្រប់គ្រងការធ្វើជំនួញជាអន្តរជាតិនូវប្រភេទសត្វព្រៃ និងរុក្ខជាតិព្រៃកំពុងផុតពូជ ក៏ត្រូវបានបញ្ចូលនៅក្នុងក្រុមទី ១ផងដែរ ។

ខ.ក្រុមទី ២៖ គ្រប់ប្រភេទ ដែលរួមមានប្រភេទដែលមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានវាយឈ្មោះជាប្រភេទដែលងាយរងគ្រោះ ដែលជិតទទួលរងការគំរាមកំហែង ដែលមិនមានទិន្នន័យគ្រប់គ្រាន់ ឬដែលមិនទាន់បានសិក្សា នៅក្នុងបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ ស្តីពីប្រភេទដែល ទទួលរងការគំរាមកំហែង ប្រភេទទាំងនោះ ដែលត្រូវបានបន្ថែមទៅក្នុងប្រភេទដែលបានរៀបរាប់ខាងលើ នៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ និងគ្រប់ប្រភេទដែលមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលបានវាយឈ្មោះនៅក្នុងឧបសម្ព័ន្ធទី ២ នៃអនុសញ្ញាស្តីពីការគ្រប់គ្រងការធ្វើជំនួញជាអន្តរជាតិនូវប្រភេទសត្វព្រៃ និងរុក្ខជាតិព្រៃកំពុងផុតពូជ ។

គ. ក្រុមទី ៣៖ គ្រប់ប្រភេទ ដែលរួមមានប្រភេទដែលមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានវាយឈ្មោះជាប្រភេទដែលមិនទាន់មានក្នុងប្រភេទណាមួយ នៅក្នុងបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ ស្តីពីប្រភេទដែលទទួលរងគ្រោះថ្នាក់ និងគ្រប់ប្រភេទ ដែលមិនមានដើមកំណើត នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលបាន

វាយឈ្មោះនៅក្នុងឧបសម្ព័ន្ធទី២ នៃអនុសញ្ញាស្តីពីការគ្រប់គ្រងការធ្វើជំនួញជាអន្តរជាតិនូវប្រភេទសត្វព្រៃ និងរុក្ខជាតិព្រៃកំពុងផុតពូជ ។

នៅក្នុងករណីដែលប្រភេទមួយប្រភេទ អាចចាត់ថ្នាក់ក្រោមក្រុមផ្សេងៗទៀត អនុលោមទៅតាមបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ និងឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីការគ្រប់គ្រងការធ្វើជំនួញជាអន្តរជាតិនូវប្រភេទសត្វព្រៃ និងរុក្ខជាតិព្រៃកំពុងផុតពូជ ក្រុមដែលខ្ពស់ជាង ត្រូវបានយកមកអនុវត្ត ។ រាល់ប្រភេទដែលពិពណ៌នាថ្មីៗដោយគ្មានការចាត់ថ្នាក់នៃសហភាពអន្តរជាតិអភិរក្សធម្មជាតិត្រូវចាត់ចូលក្នុងក្រុមទី១លើកលែងតែវាត្រូវបានចាត់ថ្នាក់ផ្ទុយពីនេះ ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន។

ប្រភេទទាំងឡាយដែលបានបញ្ចូលនៅក្នុងក្រុមទាំងបី ត្រូវបានវាយឈ្មោះនៅក្នុងលិខិតបទដ្ឋានគតិយុត្តមួយ ដែលត្រូវបានបង្កើតឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងដៃគូបច្ចេកទេស ។ ការបង្កើតក្រុមទាំងបីនេះ ត្រូវមានប្រសិទ្ធភាពជាប្រញាប់ បន្ទាប់ពីការអនុម័តក្រមនេះ ដែលផ្អែកលើបញ្ជីក្រហម របស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ និងអនុសញ្ញាស្តីពីការគ្រប់គ្រងការធ្វើជំនួញជាអន្តរជាតិនូវប្រភេទសត្វព្រៃ និងរុក្ខជាតិព្រៃកំពុងផុតពូជ ។

**មាត្រា៤៩៨** ._ ការធ្វើបច្ចុប្បន្នភាពនៃបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់

ក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព ត្រូវជួបប្រជុំគ្នារៀងរាល់១ (មួយ) ឆ្នាំម្តងយ៉ាងតិច ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ទៅដល់ក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថាន ដើម្បីធ្វើបច្ចុប្បន្នភាព ទៅលើបញ្ជី ថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ និងការធ្វើចំណាត់ថ្នាក់នៃប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ។

នៅពេលដែលប្រភេទរុក្ខជាតិណាមួយដែលបានវាយឈ្មោះនៅក្នុងបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ ដែលពីមុនមិនត្រូវបានគេស្គាល់ថាមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានរកឃើញថាមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ពពួករុក្ខជាតិនេះ ត្រូវបានបញ្ចូលទៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ។

ប្រភេទរុក្ខជាតិដែលមិនមាននៅក្នុងបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ អាចត្រូវបានបន្ថែមទៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ។ ការបន្ថែមនេះ ត្រូវធ្វើឡើងជាមួយនឹងឯកសារយោងទៅលើលក្ខណៈវិនិច្ឆ័យ ដែលបានចែងនៅក្នុងប្រភេទ និង លក្ខណៈវិនិច្ឆ័យនៃបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ ។

ការធ្វើចំណាត់ថ្នាក់ប្រភេទរុក្ខជាតិដែលបានធ្វើបច្ចុប្បន្នភាព នឹងត្រូវផ្អែកទៅលើការបែងចែងជាប្រភេទ នៃប្រភេទនៅក្នុងបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ និងឧបសម្ព័ន្ធនៃអនុសញ្ញា ស្តីពីការគ្រប់គ្រងការធ្វើជំនួញជាអន្តរជាតិនូវប្រភេទសត្វព្រៃ និងរុក្ខជាតិព្រៃកំពុងផុតពូជ ។

បន្ថែមជាងនេះទៅទៀត ប្រភេទណាមួយអាចធ្វើបច្ចុប្បន្នភាពទៅជាប្រភេទក្រុមដែលខ្ពស់ជាងមុន ដោយផ្អែកលើកត្តាមួយចំនួន ដែលរួមមាន៖

ក. កម្រិតខ្ពស់នៃការគំរាមកំហែងទៅកាន់ចំនួនប្រភេទដែលមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ. ស្ថានការណ៍នៃចំនួនប្រភេទដែលមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវនឹងលក្ខណៈវិនិច្ឆ័យនៃបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ ដែលជិតផុតពូជ ឬកំពុងផុតពូជ ។

គ. តម្លៃបេតិកភណ្ឌវប្បធម៌ និងធម្មជាតិដ៏មានសារៈសំខាន់ សម្រាប់ប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ។

ការធ្វើបច្ចុប្បន្នភាពទាំងនេះ ត្រូវបានអនុម័តដោយលិខិតបទដ្ឋានគតិយុត្ត និងត្រូវបានចែកចាយទៅកាន់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ភ្នាក់ងារពង្រឹងការអនុវត្តច្បាប់ គណៈកម្មាធិការសហគ្រប់គ្រង និងតុលាការខេត្ត ។

គ្មានប្រភេទណាមួយ អាចត្រូវវាយឈ្មោះនៅក្នុងក្រុមទី ១ ឬទី ២ ដោយគ្មានការផ្លាស់ប្តូរស្របគ្នានឹង ការវាយឈ្មោះថ្មីៗ នៅក្នុងបញ្ជីក្រហមនៃប្រភេទដែលទទួលរងគ្រោះថ្នាក់ របស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ និងធនធានធម្មជាតិបានឡើយ ។

**មាត្រា៤៨៩** ._ សំណើធ្វើបច្ចុប្បន្នភាព

ជន ឬអង្គការណាមួយដែលចាប់អារម្មណ៍ អាចប្តឹងមកកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដើម្បីបន្ថែមប្រភេទរុក្ខជាតិ ណាមួយទៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ។ ការប្តឹងនេះ ត្រូវផ្តល់ទិន្នន័យ និងព័ត៌មានដើម្បីគាំទ្រការបញ្ចូលប្រភេទនេះទៅក្នុងបញ្ជីថ្នាក់ជាតិ ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវឆ្លើយតបទៅនឹងបណ្តឹងនេះ ជាមួយនឹងហេតុផលដែលបណ្តឹងនេះត្រូវបានទទួលយកទុក ឬបដិសេធ នៅក្នុងរយៈពេល ៦០(ហុកសិប) ថ្ងៃ បន្ទាប់ពីការទទួលយកបណ្តឹងនោះ ។

ឯកសារ ទិន្នន័យ ឬព័ត៌មានផ្សេងទៀតណាមួយ ដែលត្រូវបានប្រើប្រាស់សម្រាប់ការវាយឈ្មោះនៃប្រភេទ មួយប្រភេទ តាមការស្នើសុំ ឬក្រៅពីនេះ ត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបានដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត នៅក្នុងការ

កាន់កាប់ឯកសារ ទិន្នន័យ ឬព័ត៌មានផ្សេងទៀតនេះ ស្របតាមគន្លឹះទី១ បទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន មាតិកាទី៣ នៃក្រមនេះ ។

## ជំពូកទី៣
## ការហាមឃាត់ទៅលើសកម្មភាពដែលប៉ះពាល់ចំពោះទីជម្រក និងប្រភេទរុក្ខជាតិ ដែលទទួលរងគ្រោះថ្នាក់ និងការប្រមូលយករុក្ខជាតិ

**មាត្រា៤៩០ .**_ សកម្មភាពដែលត្រូវហាមឃាត់ចំពោះទីជម្រក និងប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ និងការប្រមូលយករុក្ខជាតិ

ការបំផ្លិចបំផ្លាញ និងការផ្លាស់ប្តូរជម្រកធម្មជាតិនៃប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ដែលបានកំណត់ដោយអាជ្ញាធរត្រឹមត្រូវ ថាបង្កឡើង ដោយផ្ទាល់ ឬប្រយោលនូវការបំផ្លិចបំផ្លាញរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់នៅក្នុងជម្រកធម្មជាតិរបស់វា ត្រូវបានហាមឃាត់ លើកលែងតែមានចែងនៅក្នុងជំពូកទី៤ នៃមាតិកានេះ ។

**មាត្រា៤៩១ .**_ សកម្មភាពដែលត្រូវហាមឃាត់ចំពោះរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់

ការប្រមូល ការបំផ្លិចបំផ្លាញ ការប្រើប្រាស់ ការលក់ ការធ្វើជំនួញ ឬការដឹកជញ្ជូនរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ណាមួយ ឬនិស្សន្ទវត្ថុ ដែលត្រូវបានរាយឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ត្រូវបានហាមឃាត់ លើកលែងតែមានចែងនៅក្នុងជំពូកទី៤ នៃមាតិកានេះ ។

**មាត្រា៤៩២ .**_ សកម្មភាពដែលត្រូវហាមឃាត់នៅក្នុងច្រករបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ

ការប្រមូល ឬការបំផ្លិចបំផ្លាញនៃរុក្ខជាតិណាមួយនៅក្នុងច្រករបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ត្រូវបានហាមឃាត់ លើកលែងតែមានចែងនៅក្នុងជំពូកទី ៤ នៃមាតិកានេះ ឬស្របតាមផែនការគ្រប់គ្រងច្រករបៀងអភិរក្សជីវៈចម្រុះ ឬតំបន់ការពារធម្មជាតិ ។

## ជំពូកទី៤
## ការផ្តល់លិខិតអនុញ្ញាតសម្រាប់គោលបំណងពិសេស

**មាត្រា៤៩៣**._ ការប្រើប្រាស់ជាលក្ខណៈគ្រួសារ និងការប្រើប្រាស់ជាឱសថ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចផ្តល់ការអនុញ្ញាតពិសេសនៅក្នុងការប្រមូល ការលក់ ជំនួញ ឬការដឹកជញ្ជូនរុក្ខជាតិ ដែលទទួលរងគ្រោះថ្នាក់ ឬនិស្សន្ទវត្ថុ សម្រាប់ការប្រើប្រាស់ជាលក្ខណៈគ្រួសារ និងការប្រើប្រាស់ជាឱសថបាន ។ ការអនុញ្ញាតពិសេសណាមួយនៅក្រោមជំពូកនេះ ត្រូវមានចែងអំពីការដាក់កំហិតសមរម្យទៅលើកម្រិត និងក្របខ័ណ្ឌពេលវេលា ដែលសកម្មភាពទាំងនោះដែលត្រូវបានអនុវត្តនៅក្រោមការអនុញ្ញាតនេះ នឹងមិនធ្វើឲ្យថយចុះនូវចំនួន ធម្មជាតិ ឬធ្វើអន្តរាគមន៍ជាមួយការស្តារឡើងវិញនូវចំនួនធម្មជាតិនៃរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ដូចបានកំណត់ដោយវិទ្យាសាស្ត្រដែលអាចស្វែងរកបាន និងល្អបំផុត នៅពេលដែលផ្តល់ការអនុញ្ញាតពិសេសនេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតនីតិវិធីក្នុងការផ្តល់លិខិតអនុញ្ញាតលក្ខណៈវិនិច្ឆ័យ និងបទប្បញ្ញត្តិនានានៅក្នុងលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៤៩៤**._ គោលបំណងវិទ្យាសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចផ្តល់ការអនុញ្ញាតពិសេសនៅក្នុងការប្រមូលរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ សម្រាប់គោលបំណងវិទ្យាសាស្ត្របាន លុះត្រាតែការប្រមូលនេះ ត្រូវបានកំណត់ថាមិនមានសក្តានុពលក្នុងការបង្ក ឲ្យមានការផុតពូជនៃរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ឬបង្កការខូចខាតដែលមិនអាចជំនួសបាន ទៅដល់ចំនួនធម្មជាតិ នៃរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ដូចបានកំណត់ដោយវិទ្យាសាស្ត្រដែលអាចស្វែងរកបាន និងល្អបំផុត នៅពេលដែលផ្តល់ការអនុញ្ញាតពិសេសនេះ ។លិខិតអនុញ្ញាតដែលត្រូវបានផ្តល់សម្រាប់គោលបំណង វិទ្យាសាស្ត្រ អាចផ្តល់ឲ្យបានតែ ស្ថាប័នណាដែលតំណាងឲ្យស្ថាប័នសិក្សា ស្ថាប័នស្រាវជ្រាវ អង្គការអភិរក្ស អគារសន្និធិរុក្ខជាតិ សួតសម្រាប់ការសិក្សាស្រាវជ្រាវ ឬសួនរុក្ខសាស្ត្រ ។ មិនមានកាលៈទេសៈណាមួយដែលលិខិតអនុញ្ញាតនៅក្នុងការប្រមូលរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់សម្រាប់គោលបំណងវិទ្យាសាស្ត្រ ត្រូវបានផ្តល់ទៅ ឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រមូលរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ជាមួយនឹងផលប្រយោជន៍ពាណិជ្ជកម្មនោះឡើយ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតនីតិវិធីក្នុងការផ្តល់លិខិតអនុញ្ញាតលក្ខណៈវិនិច្ឆ័យ និងបទប្បញ្ញត្តិនានានៅក្នុង លិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៤៩៥**._ អវត្តមាននៃព័ត៌មានខាងផ្នែកវិទ្យាសាស្ត្រគ្រប់គ្រាន់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចបដិសេធក្នុងការផ្តល់លិខិតអនុញ្ញាតពិសេសនៅក្រោមជំពូកនេះ ក្នុងករណីដែលមិនមានព័ត៌មានគ្រប់គ្រាន់ខាងផ្នែកវិទ្យាសាស្ត្រដើម្បីធ្វើការកំណត់

អំពីផលប៉ះពាល់នៃសកម្មភាពទៅលើប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ និងជម្រករបស់វា ជាមួយនឹងការលើកលែងក្នុងការផ្តល់លិខិតអនុញ្ញាតពិសេសនានា ដែលត្រូវផ្តល់ជាកំហិតសម្រាប់គោលបំណងវិទ្យាសាស្ត្រ ។ ក្នុងករណីដែលលិខិតអនុញ្ញាត ត្រូវបានផ្តល់ សម្រាប់គោលបំណងវិទ្យាសាស្ត្រ ថ្វីត្បិតតែមិនមានព័ត៌មានខាងផ្នែកវិទ្យាសាស្ត្រគ្រប់គ្រាន់ ដើម្បីធ្វើការកំណត់ច្បាស់លាស់ក៏ដោយ ក៏ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចប្រើប្រាស់ការវិនិច្ឆ័យដែលល្អបំផុតរបស់ខ្លួន ដើម្បីបន្ទាប កម្រិតនៃការប្រមូល ដែលនឹងកាត់បន្ថយលទ្ធភាពដែលសកម្មភាពទាំងនេះ នឹងបង្កឲ្យមានការផុតពូជនៃរុក្ខជាតិ ដែលទទួលរងគ្រោះថ្នាក់ ឬបង្កការខូចខាតដែលមិនអាចជំនួសបាន ទៅដល់ចំនួនធម្មជាតិនៃរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ។

**មាត្រា៤៩៦** ._ ការព្យួរ ឬការលុបចោលនូវលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរក្សាសិទ្ធិអំណាចនៅក្នុងការព្យួរជាបណ្តោះអាសន្ន ឬមិនមានការកំណត់ ឬលុបចោល នូវលិខិតអនុញ្ញាតដែលបានផ្តល់នៅក្រោមជំពូកនេះ ដែលផ្អែកទៅលើទិន្នន័យថ្មីៗ ព័ត៌មានខាងផ្នែកវិទ្យាសាស្ត្រ ឬការគំរាមកំហែងដែលបានរកឃើញថ្មីៗទៅលើប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ និងជម្រករបស់វា ។

## ជំពូកទី៥
## ផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទរុក្ខជាតិ

**មាត្រា៤៩៧** ._ ផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទ សម្រាប់ប្រភេទរុក្ខជាតិដែលទទួលរង ការគំរាមកំហែងមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានរាយឈ្មោះនៅក្នុងក្រុមទី ១ នៃបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ។ ផែនការទាំងនេះ ត្រូវមានវិសាលភាពក្នុងរយៈពេល ១០ (ដប់) ឆ្នាំ ហើយផែនការនីមួយៗ អាចគ្របដណ្តប់ទៅលើប្រភេទរុក្ខជាតិច្រើនប្រភេទ ដែលរួមបញ្ចូលទាំងប្រភេទ សត្វព្រៃផងដែរ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត និងអ្នកជំនាញការបច្ចេកទេស ដើម្បីបង្កើតផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទ ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវផ្តល់ការពិគ្រោះយោបល់ជាសាធារណៈ ក្នុងអំឡុងពេលនៃការបង្កើតផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទនេះ ស្របទៅតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ ក្នុងគន្ថីទី ១ មាតិកាទី២ នៃក្រមនេះ ។

គ្រប់ផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទដែលបានស្នើសុំ ត្រូវពិនិត្យ និងឯកភាព ដោយក្រុមការងារ បច្ចេកទេសអភិរក្សជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព មុនពេលផែនការនេះត្រូវបានអនុវត្ត ។

មន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត ត្រូវធ្វើជាស្ថាប័នអនុវត្តបឋម ក្រោមការត្រួតពិនិត្យពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រុមការងារបច្ចេកទេសអភិរក្សជីវៈចម្រុះ នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយ ចីរភាព និងក្នុងកិច្ចសហការជាមួយអង្គភាព រដ្ឋាភិបាលពាក់ព័ន្ធផ្សេងទៀត និងដៃគូបច្ចេកទេសនានា ។

**មាត្រា៤៩៨** ._ ផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទរុក្ខជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរួមមាន ផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទរុក្ខជាតិៈ

ក- សកម្មភាពអភិរក្ស និងគ្រប់គ្រងចាំបាច់ ដើម្បីធានាបានថា ចំនួននៃប្រភេទមានមុខងារអេកូឡូស៊ីដែលបានរាយឈ្មោះ កំពុងមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅឡើយ ។

ខ- ការទទួលរងគ្រោះថ្នាក់ទាំងផ្ទាល់ និងប្រយោល និងវិធានការដែលតម្រូវក្នុងការកាត់បន្ថយគ្រោះថ្នាក់នេះ និងធានាសុវត្ថិភាពទៅដល់ចំនួនប្រភេទ ។

គ- ជម្រកសំខាន់សម្រាប់ការអភិរក្សប្រភេទ

ឃ-ការគ្រប់គ្រងជម្រក និងទាសភាពជាក់លាក់ដែលចាំបាច់ដើម្បីសម្រេចឲ្យបាននូវគោលដៅរបស់ផែនការគ្រប់គ្រង និងស្តារឡើងវិញ។

ង- គោលបំណង និងលក្ខណៈជ្រើសរើស ដែលបញ្ជាក់ថា ឋានៈនៃការអភិរក្សបានប្រសើជាងមុន សម្រាប់ប្រភេទគោលដៅ និងទីជម្រកដែលពាក់ព័ន្ធ នៅពេលសម្រេចបាន ។

ច- ការព្យាករណ៍ពេលវេលា និងធនធានហិរញ្ញវត្ថុ ដែលតម្រូវក្នុងការអនុវត្តតាមសកម្មភាព និងវិធានការដែលចាំបាច់ ។

ផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទរុក្ខជាតិ អាចត្រូវបញ្ចូលទៅក្នុងផែនការគ្រប់គ្រងសម្រាប់របៀងអភិរក្សជីវៈចម្រុះ ឬផែនការសម្រាប់តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ។

**មាត្រា៤៩៩** ._ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

រាល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោង ផែនការ ឬសកម្មភាពទាំងឡាយណាដែលអាចមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ទៅលើជម្រកនៃប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ដែលបានស្គាល់ ត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គន្ថីទី២

មាតិការទី៣ នៃក្រមនេះ និងត្រូវពិចារណា ហើយដាក់បញ្ចូលនូវផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទរុក្ខជាតិជាឯកសារយោង និងត្រូវចង្អុលបង្ហាញថាគម្រោង ផែនការ ឬសកម្មភាពនេះ នឹងមិនធ្វើឲ្យថយចុះនូវចំនួនធម្មជាតិនៃរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ឬធ្វើអន្តរាគមន៍ជាមួយការស្តារឡើងវិញនូវចំនួនធម្មជាតិនៃរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ តាមរយៈការអនុវត្តផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទ ស្របតាមគន្លឹះទី២ ការវាយតម្លៃ និងការអង្កេតតាមដានបរិស្ថាន មាតិកាទី៣ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃក្រមនេះ ។

នៅក្នុងករណីដែលប្រភេទរុក្ខជាតិមួយប្រភេទ ត្រូវបានបន្ថែមនៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ប៉ុន្តែផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទនេះ មិនទាន់បានបំពេញ ដូច្នេះគ្រប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោង ផែនការ ឬសកម្មភាពទាំងឡាយណាដែលអាចមាន ផលប៉ះពាល់គួរឲ្យកត់សម្គាល់ទៅលើប្រភេទរុក្ខជាតិ ត្រូវចង្អុលបង្ហាញថាគម្រោង ផែនការ ឬសកម្មភាពនេះ នឹងមិនធ្វើឲ្យថយចុះនូវចំនួនធម្មជាតិនៃប្រភេទណាមួយឡើយ។

## ជំពូកទី៦
## ការធ្វើចំណាត់ថ្នាក់នៃប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់

**មាត្រា៥០០ ._** បញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើត និងចុះជាបញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ ដែលកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីក្រមនេះចូលជាធរមាន។ បញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ ត្រូវផ្តល់ទិន្នន័យ អំពីប្រព័ន្ធអេកូឡូស៊ីដែលត្រូវបានគំរាមកំហែង ដែលពុំគិតដល់វត្តមាន ឬអវត្តមាននៃរុក្ខជាតិ ឬសត្វព្រៃដែលមាននៅក្នុងប្រព័ន្ធអេកូឡូស៊ីនោះឡើយ ។ បញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ីដែល ទទួលរងការគំរាមកំហែង ត្រូវទទួលយកប្រព័ន្ធអេកូឡូស៊ីទាំងអស់ដែលកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានវាយឈ្មោះនៅក្នុងបញ្ជីក្រហមនៃប្រព័ន្ធអេកូឡូស៊ីរបស់សហភាពអភិរក្សធម្មជាតិ ។ បញ្ជីថ្នាក់ជាតិ ស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ នឹងទទួលយកប្រព័ន្ធអេកូឡូស៊ីថ្មីជាបន្តបន្ទាប់ដែលត្រូវបានបន្ថែមទៅក្នុងបញ្ជីក្រហមនៃប្រព័ន្ធអេកូឡូស៊ីរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិដែលកើតមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានប្រសិទ្ធភាពភ្លាមៗ បន្ទាប់ពីការវាយឈ្មោះប្រព័ន្ធអេកូឡូស៊ីទាំងនោះ នៅក្នុងបញ្ជីក្រហមនៃប្រព័ន្ធអេកូឡូស៊ីរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ ។ បញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ ត្រូវដាក់ឲ្យសាធារណៈជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មាន គន្លឹះទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៥០១ .**_ ចំណាត់ថ្នាក់នៃប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់

ប្រព័ន្ធអេកូឡូស៊ីដែលបានរាយឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ ត្រូវបានធ្វើចំណាតថ្នាក់ទៅតាមក្រុមដូចខាងក្រោម៖

ក-ក្រុមទី ១៖ គ្រប់ប្រព័ន្ធអេកូឡូស៊ី ដែលបានរាយឈ្មោះជាប្រព័ន្ធអេកូឡូស៊ីដែលផុតពូជនៅក្នុងព្រៃ ដែលជិតផុតពូជ ឬកំពុងផុតពូជ នៅក្នុងបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ ស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ ឬប្រព័ន្ធអេកូឡូស៊ីទាំងនោះដែលត្រូវបានបន្ថែមទៅក្នុងប្រភេទដែលបានរៀបរាប់ខាងលើ នៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ ។

ខ- ក្រុមទី ២៖ គ្រប់ប្រព័ន្ធអេកូឡូស៊ី ដែលបានរាយឈ្មោះជាប្រព័ន្ធអេកូឡូស៊ី ដែលងាយរងគ្រោះ ដែលជិតទទួលរងការគំរាមកំហែង ដែលមិនមានទិន្នន័យគ្រប់គ្រាន់ ឬដែលមិនទាន់បានសិក្សា នៅក្នុងបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ ស្តីពីប្រព័ន្ធអេកូឡូស៊ី ដែលទទួលរងគ្រោះថ្នាក់ និងប្រព័ន្ធអេកូឡូស៊ី ទាំងនោះ ដែលត្រូវបានបន្ថែមទៅក្នុងប្រភេទដែលបានរៀបរាប់ខាងលើ នៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ី ដែលទទួលរងគ្រោះថ្នាក់ និង

គ- ក្រុមទី ៣៖ គ្រប់ប្រព័ន្ធអេកូឡូស៊ី ដែលបានរាយឈ្មោះជាប្រព័ន្ធ អេកូឡូស៊ី ដែលមិនទាន់មានក្នុងប្រភេទណាមួយ នៅក្នុងបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិ ស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ ។

**មាត្រា៥០២ .**_ ការធ្វើបច្ចុប្បន្នភាពនៃបញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់

ក្រុមការងារបច្ចេកទេសជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព ត្រូវជួបប្រជុំគ្នារៀងរាល់ ១ (មួយ) ឆ្នាំ ម្តងយ៉ាងតិច ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ទៅដល់ក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថាន ដើម្បីធ្វើបច្ចុប្បន្នភាព ទៅលើបញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ និងការធ្វើចំណាត់ថ្នាក់ក្រុមនៃប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ ។

ប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមិនមាននៅក្នុងបញ្ជីក្រហមរបស់សហភាពអន្តរជាតិអភិរក្សធម្មជាតិស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ អាចត្រូវបានបន្ថែមនៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់បាន ។ ការបន្ថែមនេះ ត្រូវធ្វើឡើងជាមួយនឹងឯកសារយោងទៅលើលក្ខណៈវិនិច្ឆ័យ ដែលបានចែងនៅក្នុងប្រភេទ និងលក្ខណៈវិនិច្ឆ័យនៃបញ្ជីក្រហមនៃប្រព័ន្ធអេកូឡូស៊ីរបស់សហភាពអន្តរជាតិ អភិរក្សធម្មជាតិ ។

**មាត្រា៥០៣ .**_ សំណើធ្វើបច្ចុប្បន្នភាព

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលចាប់អារម្មណ៍ អាចធ្វើសំណើមកកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដើម្បីបន្ថែមប្រព័ន្ធអេកូឡូស៊ីណាមួយទៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ី ដែលទទួលរងគ្រោះថ្នាក់ ។ សំណើនេះ ត្រូវផ្តល់ទិន្នន័យ និងព័ត៌មាន ដើម្បីគាំទ្រការបញ្ចូលប្រព័ន្ធ អេកូឡូស៊ីនេះទៅក្នុងបញ្ជីថ្នាក់ជាតិ ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវឆ្លើយតបទៅនឹងបណ្តឹងនេះ ជាមួយនឹងហេតុផលដែលសំណើនេះត្រូវបានទទួលយកទុក ឬបដិសេធ នៅក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ បន្ទាប់ពីការទទួលយកសំណើនោះ ។

ឯកសារ ទិន្នន័យ ឬព័ត៌មានផ្សេងទៀតណាមួយ ដែលត្រូវបានប្រើប្រាស់សម្រាប់ការវាយឈ្មោះនៃប្រព័ន្ធអេកូឡូស៊ីតាមការស្នើសុំ ឬវិធីផ្សេង ត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត នៅក្នុងការកាន់កាប់ឯកសារ ទិន្នន័យ ឬព័ត៌មានផ្សេងទៀតនេះ ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន គន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

## ជំពូកទី៧
## ផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី ដែលទទួលរងគ្រោះថ្នាក់

**មាត្រា៥០៤** ._ ផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី សម្រាប់ប្រព័ន្ធអេកូឡូស៊ី ដែលទទួលរងគ្រោះថ្នាក់ ដែលបានវាយឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ ។ ផែនការទាំងនេះ ត្រូវមានវិសាលភាពក្នុងរយៈពេល ១០ (ដប់) ឆ្នាំ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត និងអ្នកជំនាញការបច្ចេកទេស ដើម្បីបង្កើតផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រព័ន្ធអេកូ ឡូស៊ី ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវផ្តល់ការពិគ្រោះយោបល់ជាសាធារណៈក្នុងអំឡុងពេលនៃការបង្កើតផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីនេះ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ គន្ថីទី១ មាតិកាទី២ នៃក្រមនេះ ។

គ្រប់ផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីដែលបានស្នើសុំ ត្រូវពិនិត្យ និងឯកភាពដោយ ក្រុមការងារបច្ចេកទេសអភិរក្សជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព មុនពេលផែនការនេះត្រូវបានអនុវត្ត ។

មន្ទីរបរិស្ថានទទួលបន្ទុកវិស័យបរិស្ថាន ទទួលភារៈកិច្ចជាស្ថាប័នអនុវត្តចម្បង ក្រោមចំណុះរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រុមការងារបច្ចេកទេសជីវៈចម្រុះ ដោយសហការ

ជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត និងដីគូបច្ចេកទេសដែលរួមចំណែកក្នុងការអភិរក្សប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥០៥** ._ខ្លឹមសារនៃផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវកំណត់ឲ្យបានច្បាស់នៅក្នុងផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីដូចខាងក្រោម៖

ក- វិធានការអភិរក្ស និងគ្រប់គ្រងចាំបាច់ ដែលតម្រូវដើម្បីធានាបាននូវភាពស្ថិតស្ថេរ និងបូរណភាពអេកូឡូស៊ី នៃប្រព័ន្ធអេកូឡូស៊ីដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ- មុខងារ និងតម្លៃអេកូឡូស៊ី ។

គ-ទំហំទីតាំងភូមិសាស្ត្រ ។

ឃ-ធនធានអេកូឡូស៊ីសំខាន់ៗ ។

ង- ការគំរាមកំហែងទៅលើប្រព័ន្ធអេកូឡូស៊ីទាំងដោយផ្ទាល់ និងប្រយោល ។

ច- សូចនករអេកូឡូស៊ីដែលអាចត្រូវបានតាមដានយ៉ាងសកម្ម ។

ឆ-លំដាប់នៃតម្លៃ ដែលអាចទទួលយកបាន និងមិនអាចទទួលយកបានចំពោះអេកូឡូស៊ីសម្រាប់សូចនករអេកូឡូស៊ីនីមួយៗ ។

ចំពោះសូចនករអេកូឡូស៊ីណាមួយ ដែលមានតម្លៃដែលចាត់ទុកថាមិនអាចទទួលយកបាន ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវចាត់វិធានការកាត់បន្ថយដែលកំណត់ដោយវិទ្យាសាស្ត្រដែលអាចស្វែងរកបាន និងល្អបំផុត នៅពេលដែលមានបំណងចង់សម្រេចបាននូវតម្លៃមួយដែលទទួលយកបានសម្រាប់សូចនករអេកូឡូស៊ីនោះ ។

**មាត្រា៥០៦** ._ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោង ផែនការ ឬសកម្មភាពទាំងឡាយណាដែលអាច មានផលប៉ះពាល់គួរឲ្យកត់សម្គាល់ទៅលើជម្រកនៃប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ដែលបានវាយឈ្មោះ ត្រូវពិចារណា និងដាក់បញ្ចូលនូវផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីជាឯកសារយោង និងត្រូវចង្អុលបង្ហាញថាគម្រោងនេះនឹងមិនធ្វើឲ្យថយចុះនូវបូរណភាពអេកូឡូស៊ីនៃប្រព័ន្ធអេកូឡូស៊ី ឬធ្វើអន្តរាគមន៍ជាមួយការស្តារឡើងវិញ និង/ឬការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ តាមរយៈការអនុវត្តផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីតាមបទប្បញ្ញត្តិស្តីពីការវាយតម្លៃបរិស្ថាន គន្ថីទី២ មាតិកាទី៣ នៃក្រមនេះ ។

នៅក្នុងករណីដែលប្រព័ន្ធអេកូឡូស៊ីមួយ ត្រូវបានបន្ថែមនៅក្នុងបញ្ជីថ្នាក់ជាតិស្តីពីប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ ប៉ុន្តែផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីនេះ មិនទាន់បានបំពេញ ដូច្នេះគ្រប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោង ផែនការ ឬសកម្មភាពទាំងឡាយណាដែលអាចមាន ផលប៉ះពាល់គួរឲ្យកត់សម្គាល់ទៅលើប្រភេទរុក្ខជាតិ ត្រូវចង្អុលបង្ហាញថាគម្រោងផែនការ ឬសកម្មភាពនេះ នឹងមិនធ្វើឲ្យថយចុះនូវបូរណភាពអេកូឡូស៊ីនៃប្រព័ន្ធអេកូឡូស៊ី។

## ជំពូកទី៨
## ការគ្រប់គ្រងប្រភេទរុក្ខជាតិរាតត្បាត

**មាត្រា៥០៧** ._ បញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិរាតត្បាត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើត និងដាក់ឲ្យសាធារណជនអាចស្វែងរកបាននូវបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិរាតត្បាត មួយណាក៏បានដែលកើតមានឡើងថ្មីៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលបង្កជាការគំរាមកំហែង ប្រសិនបើប្រភេទនេះបាននាំមកចូលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ការនាំប្រភេទរាតត្បាតមកចូលទៅក្នុងបរិស្ថានធម្មជាតិ ឬទាសភាពកសិកម្ម ត្រូវបានហាមឃាត់ ប្រសិនបើមិនមានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៥០៨** ._ ផែនការគ្រប់គ្រងប្រភេទរាតត្បាត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតផែនការរគ្រប់គ្រងប្រភេទរាតត្បាត ដើម្បីកំណត់ឲ្យបានច្បាស់ពីប្រភេទរាតត្បាតទាំងអស់ដែលកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ផែនការរគ្រប់គ្រងប្រភេទរាតត្បាត ត្រូវស្វះស្វែងក្នុង ការលុបបំបាត់ និង/ឬកាត់បន្ថយផលប៉ះពាល់នៃប្រភេទរាតត្បាតទៅលើបរិស្ថាន សេដ្ឋកិច្ច និងសុខភាពមនុស្ស ។ ផែនការគ្រប់គ្រងប្រភេទរាតត្បាតអាចកំណត់ឲ្យបានច្បាស់ពីការគ្រប់គ្រងប្រភេទមួយ ដាច់ដោយឡែកតែឯង ឬក្រុមប្រភេទច្រើន និងត្រូវមានសុពលភាពក្នុងរយៈពេល ១០ (ដប់) ឆ្នាំ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត និងអ្នកបច្ចេកទេស ដើម្បីបង្កើតផែនការគ្រប់គ្រងប្រភេទរាតត្បាត ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវផ្តល់ការពិគ្រោះយោបល់ជាសាធារណៈ ក្នុងអំឡុងពេលនៃការបង្កើត ផែនការគ្រប់គ្រងប្រភេទរាតត្បាតនេះ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ គន្លឹះទី១ មាតិកាទី២ នៃក្រមនេះ ។

គ្រប់ផែនការគ្រប់គ្រងប្រភេទរាតត្បាតដែលបានស្នើសុំត្រូវពិនិត្យ និងប្រសិនបើសមរម្យ ឯកភាពដោយក្រុមការងារបច្ចេកទេសអភិរក្សជីវៈចម្រុះ នៃក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព មុនពេលផែនការនេះត្រូវបានអនុវត្ត ។

## ជំពូកទី៩
## ការគ្រប់គ្រងរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ដែលរឹបអូសបាន ឬផលដែលកើតចេញពីរុក្ខជាតិដែលបានរឹបអូស

**មាត្រា៥០៩ .**_ ការគ្រប់គ្រងរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ហើយទទួលរងការរឹបអូស ឬផលដែលបានកើតចេញពីរុក្ខជាតិដែលបានរឹបអូស

គ្រប់រុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ឬផលដែលបានកើតចេញពីរុក្ខជាតិដែលបានរឹបអូសក្រោមច្បាប់នេះត្រូវ ៖

ក- នៅក្នុងករណីដែលរុក្ខជាតិមានជីវិត នៅពេលណាមួយក៏បានដែលអាចធ្វើទៅបាន ត្រូវនាំទៅកាន់ ជម្រកដើមសារជាថ្មី ឬត្រូវប្រគល់ឲ្យទៅស្ថាប័នសមរម្យដើម្បីគោលបំណងនៃការផ្សាំ ឬការស្រាវជ្រាវ ។ ស្ថាប័នមានសមត្ថកិច្ច រួមមានស្ថាប័នសិក្សា ស្ថាប័នស្រាវជ្រាវ អង្គការអភិរក្ស អគារសន្និធិរុក្ខជាតិស្ងួតសម្រាប់ការសិក្សាស្រាវជ្រាវ ឬសួនរុក្ខសាស្ត្រ ជាអាទ៏។

ខ- នៅក្នុងករណីដែលរុក្ខជាតិនោះស្លាប់ ឬនិស្សន្ទវត្ថុរបស់វាដែលមិនអាចផ្សាំបាន ត្រូវរក្សាទុក ស្តុកទុក ឬបំផ្លាញចោលស្របតាមនីតិវិធីដែលបានឯកភាពដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៥១០ .**_ ការគ្រប់គ្រងភស្តុតាងមុនពេលបញ្ចប់បណ្តឹងនៅតុលាការ

ក្នុងករណីដែលវត្ថុតាងដែលបានរឹបអូស ត្រូវរក្សាទុកជាភស្តុតាងសម្រាប់បណ្តឹងនៅតុលាការគ្រប់សំភារៈ ឬនិស្សន្ទវត្ថុដែលជារុក្ខជាតិមានតម្លៃខ្ពស់ ត្រូវរក្សាទុកប្រកបដោយសុវត្ថិភាពដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬមន្ទីរទទួលបន្ទុកវិស័យបរិស្ថាន ដោយគោរពទៅតាមពិធីការគ្រប់គ្រង និងសុវត្ថិភាពសមរម្យ រហូតដល់ពេលមួយដែលរឿងក្តីនៅតុលាការ ត្រូវបានចប់រួចរាល់ ឬខណៈដែលរឿងក្តីកំពុងស្ថិតក្នុងដំណើរការ នៅក្នុងករណីដែលតុលាកាអនុញ្ញាតឱ្យយកភស្តុតាងនោះចេញ ។

**មាត្រា៥១១ .**_ ការគ្រប់គ្រងភស្តុតាងបន្ទាប់ពីបញ្ចប់បណ្តឹងនៅតុលាការ

នៅពេលដែលបណ្ដឹងនៅតុលាការត្រូវបានបញ្ចប់ គ្រប់សំភារៈ ឬនិស្សន្ទវត្ថុដែលជារុក្ខជាតិ ដែលរក្សាទុកជា ភស្តុតាង ត្រូវបញ្ជូនត្រលប់ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានវិញ សម្រាប់ជាផលប្រយោជន៍សាធារណៈ នៅក្នុងករណីឈើមានតម្លៃខ្ពស់ ឬប្រណិត ឬបំផ្លាញចោល ។ ផលរុក្ខជាតិ និងឈើ មិនត្រូវបានលក់ដូរ ក្នុងការលក់ដេញថ្លៃជាសាធារណៈឡើយ ។

## ជំពូកទី១០
## លិខិតបទដ្ឋានគតិយុត្តសម្រាប់ការការពាររុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់

**មាត្រា៥១២ .**_ លិខិតបទដ្ឋានគតិយុត្តសម្រាប់ការការពាររុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចបង្កើតលិខិតបទដ្ឋានគតិយុត្តបែបនោះ ដែលអាចជួយសម្រួល ឬ អាចជាការចាំបាច់  ដើម្បីអនុវត្តបទបញ្ញត្តិនៃមាតិកានេះអោយកាន់តែប្រសើឡើង និងដើម្បីចែងអំពីអ្វីមួយ ដែលអាច ឬ តម្រូវឱ្យមានចែងនៅក្នុងមាតិកានេះ ។

**មាត្រា៥១៣ .**_ ការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការការពាររុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់

លិខិតបទដ្ឋានគតិយុត្តស្ដីពីការការពារ ការអភិរក្ស និងការគ្រប់គ្រងសត្វព្រៃអាចធ្វើឡើងដោយពាក់ព័ន្ធនឹងចំណុចមួយចំនួនដូចខាងក្រោម ៖

ក. រដ្ឋបាល និងការគ្រប់គ្រងរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ។

ខ. ការថែរក្សា និងការពារប្រព័ន្ធអេកូឡូស៊ីដែលទទួលរងគ្រោះថ្នាក់ ។

គ. ការនាំចូល និងការប្រើប្រាស់ប្រភេទសត្វ និងរុក្ខជាតិរាតត្បាត ។

ឃ. មធ្យោបាយនានាក្នុងការបោះបង់ចោលនូវផលរុក្ខជាតិដែលបានរឹបអូសដែលមានតម្លៃខ្ពស់ រួមមាន ឈើជាអាទិ៍ និង

ង. សោហ៊ុយឬ ថ្លៃដែលអាចបង់បាន នៅក្រោមក្រមនេះ ។

## មាតិកាទី៧
## ការគ្រប់គ្រងតំបន់ឆ្នេរ

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៥១៤ .**_ វិសាលភាពនៃការអនុវត្ត

មាតិកានេះ អនុវត្តចំពោះតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥១៥ .**_ តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ

គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ត្រូវមានតួនាទី និងការទទួលខុសត្រូវលើការគ្រប់គ្រងតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា និងភារកិច្ចត្រួតពិនិត្យ និងបង្កើតក្របខ័ណ្ឌនានាសម្រាប់ការអភិវឌ្ឍ និងសកម្មភាពទាំងឡាយដែលពាក់ព័ន្ធទៅនឹងតំបន់ឆ្នេរ រួមមាន៖

ក-ការដាក់បញ្ចូលគោលបំណងអភិរក្សបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពចូលទៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ ។

ខ-ការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មានបរិស្ថានពាក់ព័ន្ធទៅនឹងការសម្រេចចិត្តទាំងអស់អំពីការគ្រប់គ្រងតំបន់ឆ្នេរ ស្របតាមបទប្បញ្ញត្តិ ស្ដីពីការចូលរួមជាសាធារណៈ គន្ថីទី១ មាតិកាទី២ និងបទបញ្ញត្តិស្ដីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន គន្ថីទី១ មាតិកាទី៣នៃក្រមនេះ ។

គ-ការដាក់បញ្ចូលវិធីសាស្ត្រនៃការបង្កឲ្យមានភាពធន់ស៊ាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ចូលទៅក្នុងគម្រោង និងសកម្មភាពនានានៅក្នុងតំបន់ឆ្នេរ ។

ឃ-ការចាត់វិធានការ និងកាត់បន្ថយផលប៉ះពាល់ដែលអាចកើតឡើងទៅលើទឹកនៃតំបន់ឆ្នេរ ដោយការគ្រប់គ្រងធនធានធម្មជាតិ និងសកម្មភាពរបស់មនុស្សទាំងឡាយនៅតាមទីជម្រាលទឹកនៃតំបន់ឆ្នេរ ។

ង-ការគ្រប់គ្រងធនធានធម្មជាតិ និងសកម្មភាពរបស់មនុស្សនៅក្នុងតំបន់ឆ្នេរ ទៅតាមវិធីសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីជាសវាង និងកាត់បន្ថយផលប៉ះពាល់ដែលមិនអាចព្យាករណ៍បានពាក់ព័ន្ធទៅនឹងទឹកនៃតំបន់ឆ្នេរ ។

ច-ការគ្រប់គ្រងប្រកបដោយភាពសកម្ម និងទូលំទូលាយ លើប្រភពសារជាតិបំពុលបរិស្ថាន និងសារធាតុបំពុលខ្យល់ រឹង រាវទាំងឡាយ នៅតាមច្រាំងសមុទ្រ និងប្រភពសារជាតិពុលដែលកើតពីដី ។

ឆ-ការគ្រប់គ្រង ក្ដាប់ស្ថានភាព និងការពារសន្តិសុខតាមតំបន់ឆ្នេរក្នុងករណីបាក់ស្រុតការបោកបក់នៃព្យុះ និងផលប៉ះពាល់ដែលពាក់ព័ន្ធផ្សេងទៀត ។

ជ-ការការពារឆ្នេរនានាតាមរយៈការកំណត់តំបន់គ្រប់គ្រងដែលសមរម្យ និងលិខិតបទដ្ឋានគតិយុត្តអំពីការអភិវឌ្ឍ ។

ឈ-ការអនុវត្តតាមវិធានការណ៍ផ្សេងៗដើម្បីធានានូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃតំបន់ឆ្នេ ។

## ជំពូកទី២
## អនុតំបន់ឆ្នេរ

**មាត្រា៥១៦ .**_ អនុតំបន់ឆ្នេរ

តំបន់ឆ្នេរ រួមផ្សំទៅដោយអនុតំបន់ឆ្នេរចំនួនបី មានដូចតទៅៈ

ក-ដែនទឹកតំបន់ឆ្នេរៈ ដែនទឹកដែលលាតសន្ធឹងចូលក្នុងសមុទ្រចម្ងាយ ៥ (ប្រាំ) គីឡូម៉ែត្រ ពីខ្សែឆ្នេរ រួមបញ្ចូលដីដែលលិចទឹកដែលជាប់ពាក់ព័ន្ធនានា ។

ខ-ដីតំបន់ឆ្នេរៈ ដីដែលលេចឡើងទាំងឡាយ ដែលលាតសន្ធឹងដីគោកចេញពីខ្សែឆ្នេរក្នុងរយៈចម្ងាយ ៥ (ប្រាំ) គីឡូម៉ែត្ររួមបញ្ចូល តំបន់ដែលទទួលរបបទឹកជោរ-នាចនៃសមុទ្រ ។

គ-ទីជម្រាលតំបន់ឆ្នេរៈ វិសាលភាពទាំងមូលនៃទីជម្រាលបង្ហូររួមបញ្ចូលគ្នា ទៅកាន់ដែនទឹកសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥១៧ .**_ ផលប៉ះពាល់នៃការអភិវឌ្ឍនាពេលខាងមុខ

គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ដោយរួមសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវបង្កើតលិខិតបទដ្ឋាន ដើម្បីគ្រប់គ្រងប្រកបដោយនិរន្តរភាព ទៅលើផលប៉ះពាល់ដោយការអភិវឌ្ឍនាពេលខាងមុខ និងផលប៉ះពាល់ផ្នែកបរិស្ថានដែលពាក់ព័ន្ធ ។

## ជំពូកទី៣
## ការរៀបចំផែនការសម្រាប់ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពទៅលើតំបន់ឆ្នេរ

**មាត្រា៥១៨ .**_ ការផ្តល់ជំនួយបច្ចេកទេសរបស់ក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព ត្រូវផ្តល់ជំនួយផ្នែកបច្ចេកទេស ដល់គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ដើម្បីធានាដល់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុ

វត្តតាមគោលនយោបាយការពារ និងលើកកម្ពស់ធនធានធម្មជាតិ និងបរិស្ថាន និងការអភិវឌ្ឍតំបន់ឆ្នេរប្រកបដោយនិរន្តរភាព ។

**មាត្រា៥១៩** ._ កត្តាដែលត្រូវពិចារណា

គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ត្រូវផ្តល់ការពិចារណាពេញលេញទៅលើបញ្ហានានាពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុនៅមុនពេលកំណត់ទៅលើប្រភេទនៃលិខិតអនុញ្ញាត ឬ វិញ្ញាបនបត្រឯកភាពទៅលើគម្រោង និងសកម្មភាពនានាក្នុងតំបន់ឆ្នេរ មានជាអាទិ៍៖

ក-ផលប៉ះពាល់ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ ដូចជា ការបាក់ស្រុតឆ្នេរ និងការជន់លិច ជាដើម ។

ខ-នីតិវិធីនៃការវាយតម្លៃ ។

គ-ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ។

ឃ-យុទ្ធសាស្ត្រ ផែនការ គោលនយោបាយ និងរបាយការណ៍នានា ពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុ ដែលរៀបចំឡើងដោយ ក្រសួង ស្ថាប័នទទួលបន្ទុកលើការអភិវឌ្ឍន៍ដោយចីរភាព ក្រសួង ស្ថាប័នពាក់ព័ន្ធ និងនីតិបុគ្គលពាក់ព័ន្ធដ៏ទៃទៀត ។

**មាត្រា៥២០** ._ ការហាមឃាត់ចំពោះការឯកភាពលើសកម្មភាពដែលមិនដាក់បញ្ចូលនូវការពិចារណាអំពីផលប៉ះពាល់ដែលអាចកើតមានឡើង

មិនត្រូវមានការឯកភាពដាច់ខាតទៅលើសកម្មភាព និងការអភិវឌ្ឍទាំងឡាយណានៅក្នុងតំបន់ឆ្នេរ លុះត្រាតែមានភស្តុតាងច្បាស់លាស់ដែលថាសំណើការអភិវឌ្ឍ រឺសកម្មភាពរួមមាន ពិចារណាពេញលេញអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរ ទៅលើគម្រោងស្នើសុំ ។ កត្តាដែលត្រូវពិចារណា មានជាអាទិ៍ ផលប៉ះពាល់ដែលកើតមានដល់គម្រោង ឬបង្កឡើងដោយគម្រោង ឬការអភិវឌ្ឍដែលបានស្នើសុំ រួមមាន ព្រឹត្តិការណ៍ខ្យល់ព្យុះ ការជន់លិច ការបាក់ស្រុតឆ្នេរ និងកត្តាដទៃទៀត ។

**មាត្រា៥២១** ._ លក្ខខណ្ឌតម្រូវ

នៅមុនពេលចេញលិខិតអនុញ្ញាត ឬ វិញ្ញាបនបត្រ សម្រាប់ការអភិវឌ្ឍនៅក្នុងតំបន់ឆ្នេរណាមួយ គណៈកម្មការជាតិគ្រប់គ្រង និងការអភិវឌ្ឍតំបន់ឆ្នេរ ត្រូវផ្តល់ការធានាដែលមានដូចតទៅ៖

ក-គម្រោងដែលបានស្នើសុំ ត្រូវស្របទៅនឹងគោលបំណងនៃការគ្រប់គ្រង និងផែនការរបស់តំបន់ ឬ អនុតំបន់នៃគម្រោង ។

ខ-ម្ចាស់គម្រោង ឬ អ្នកស្នើសុំ ត្រូវបង្ហាញថា ខ្លួនបានគោរពតាមដំណាក់កាលដែលសមហេតុផលនានា សម្រាប់ការកាត់បន្ថយផលប៉ះពាល់ដល់ទឹកតាមដងអូរ ទឹកតាមទីជម្រាល និងទឹកសមុទ្រនៃតំបន់ឆ្នេរ ។

គ-លក្ខខណ្ឌនៃការឯកភាព ឬ ការអនុញ្ញាត ស្របទៅតាមបទប្បញ្ញត្តិស្តីពីការវាយតម្លៃបរិស្ថាន គន្ថីទី២ មាតិកាទី៣ នៃក្រមនេះ ។

ឃ-ផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុដែលអាចកើតមានឡើង រួមទាំងតំបន់គ្រោះថ្នាក់ដោយទឹកជំនន់នៃតំបន់ឆ្នេរ ជាដើម ត្រូវបានពិចារណា ហើយមានការការពារទៅលើហេដ្ឋារចនាសម្ព័ន្ធពីការប្រែប្រួលអាកាសធាតុ ។

ង-មានការបញ្ចៀស និងកាត់បន្ថយផលប៉ះពាល់ពីកករ ឬ សារជាតិពុល ដែលហៀរចូលទៅក្នុងតំបន់ឆ្នេរ ដោយប្រើការគ្រប់គ្រងប្រសិទ្ធផលនៃសំណល់ ។

ច-ការចាក់លុបដី ត្រូវបានកាត់បន្ថយយ៉ាងពេញលេញ ។

**មាត្រា៥២២ .**_ សកម្មភាពដែលត្រូវហាមឃាត់

ហាមដាច់ខាតចំពោះ រាល់សកម្មភាព ការសាងសង់ និងគម្រោងទាំងឡាយ ពាក់ព័ន្ធទៅនឹងអាជីវកម្មរ៉ែខ្សាច់ គម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលបង្កឲ្យមានការបាត់បង់ ឬ ការបំផ្លាញដល់វត្ថុធាតុ នៃតំបន់ឆ្នេរ ដែលមានដូចតទៅ ៖

ក-ផ្កាថ្ម ។

ខ-ស្មៅសមុទ្រ ឬ តំបន់ស្មៅសមុទ្រ ។

គ-ទីតាំងបង្កាត់ពូជជលផលទឹកសាប និងសមុទ្រ និងធនធានជលផល ។

ឃ-ព្រៃកោងកាង ។

## ជំពូកទី៤
## ការចូលរួមជាសាធារណៈនៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ

**មាត្រា៥២៣ .**_ ការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មានបរិស្ថាន

គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ត្រូវអនុលោមតាមរាល់លក្ខខណ្ឌតម្រូវនានាសម្រាប់ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ស្របតាមបទបញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ ក្នុងគន្ថីទី១ មាតិកាទី២ និងបទបញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៥២៤** ._ ការលើកកម្ពស់ដល់ការចូលរួមជាសាធារណៈ

គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ អាចចេញនូវលិខិតបទដ្ឋានគតិយុត្តបន្ថែម ក្នុងបំណងលើកកម្ពស់ដល់ការចូលរួមជាសាធារណៈ នៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរទាំងឡាយ ។

## មាតិកាទី៨
## ការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាព
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ
## ផ្នែកទី១
## គោលដៅ និងគោលការណ៍

**មាត្រា៥២៥** ._ វិសាលភាពនៃការអនុវត្ត

មាតិកានេះអនុវត្តចំពោះធនធានទឹកនានាក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥២៦** ._ គោលការណ៍នៃការគ្រប់គ្រងធនធានទឹករួមគ្នា

ទឹក និង ធនធានទឹក ត្រូវស្ថិតក្រោមការគ្រប់គ្រង និង អភិវឌ្ឍន៍ ដោយផ្អែកលើគោលការណ៍ ដូចតទៅ ៖

ក- សមធម៌សង្គម៖ ការធានាបាននូវសមភាពនៃការទទួលបានទឹកសម្រាប់អ្នកប្រើប្រាស់ទាំងអស់ ជាពិសេស ក្រុមមនុស្សដែលមិនសូវបានទទួលការយកចិត្តទុកដាក់ និងដែលមិនមានតំណាងគ្រប់គ្រាន់ ឲ្យទទួលបានទឹកក្នុងបរិមាណ និងគុណភាពគ្រប់គ្រាន់ ដើម្បីទ្រទ្រង់សុខុមាលភាពរបស់ពួកគេ ។

ខ- ប្រសិទ្ធផលសេដ្ឋកិច្ច៖ ការផ្តល់ផលប្រយោជន៍ខ្ពស់បំផុតឲ្យទៅអ្នកប្រើប្រាស់ជាអតិបរិមា សម្រាប់ធនធានហិរញ្ញវត្ថុ និងធនធានទឹកដែលបានប្រើប្រាស់ ។

គ- និរន្តរភាពអេកូឡូស៊ី៖ ការតម្រូវឲ្យធ្វើការបែងចែងទឹកគ្រប់គ្រាន់ ដើម្បីធានានិរន្តរភាពនៃមុខងារតាមធម្មជាតិនៃពពួកសត្វ និង រុក្ខជាតិដែលទទួលការគំរាមកំហែង និងប្រព័ន្ធអេកូឡូស៊ី ។

**មាត្រា៥២៧** ._ កត្តាដែលត្រូវពិចារណាសម្រាប់ការអនុវត្ត

នៅពេលអនុវត្តការគ្រប់គ្រងធនធានទឹកជាលក្ខណៈអន្តរវិស័យ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក និងឧត្តុនិយម ត្រូវពិចារណា៖

ក-គ្រប់ទិដ្ឋភាពនៃធនធានទឹក ។

ខ-ចំណងទាក់ទងរវាងធនធានទឹក និងសមាសភាគដទៃទៀតនៃបរិស្ថានធម្មជាតិរួមមាន ដីធ្លី ជលផល រុក្ខជាតិ សត្វ ជាអាទិ៍។

គ-លក្ខខណ្ឌតម្រូវសម្រាប់ការប្រើប្រាស់ទឹករបស់ប្រជាជន និង បរិស្ថានធម្មជាតិឲ្យមានប្រសិទ្ធភាព និង និរន្តរភាព ។

**មាត្រា៥២៨** ._ ការសហការរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ច

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទាំងអស់ ដែលទទួលខុសត្រូវលើការប្រើប្រាស់ទឹក ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានវារីជាតិប្រកបដោយនិរន្តរភាពទៅលើធនធានទឹកដែលមានជីវិត និងប្រព័ន្ធអេកូឡូស៊ីដែលពាក់ព័ន្ធ ត្រូវសហការអនុវត្តការគ្រប់គ្រងធនធានទឹកជាលក្ខណៈរួមគ្នា ។

**មាត្រា៥២៩** ._ ការរួមចំណែករបស់ភាគីដែលពាក់ព័ន្ធ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរួមសហការជាមួយគ្នា ក៏ដូចជានីតិបុគ្គលសាធារណៈ និងឯកជនសម្រាប់ការគ្រប់គ្រង ការបណ្តាក់ទុន ការធ្វើអាជីវកម្ម ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក ។

## ផ្នែកទី២
## ម្ចាស់កម្មសិទ្ធិលើទឹក និងធនធានទឹក

**មាត្រា៥៣០** ._ កម្មសិទ្ធិលើធនធានទឹក

ទឹក និងធនធានទឹកទាំងអស់ ជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

**មាត្រា៥៣១** ._ ការបែងចែកទឹក

ការបង្វែរទឹកចេញឆ្លងដែនពីក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាត និងការឯកភាពដោយរាជរដ្ឋាភិបាលកម្ពុជា និងមានការអនុម័តផ្តល់សច្ចានុមត្តិដោយស្ថាប័ននីតិបញ្ញត្តិ ។

## ជំពូកទី២
## ការទទួលខុសត្រូវផ្នែកធនធានទឹក
## ផ្នែកទី១
## ការទទួលខុសត្រូវរបស់សាមីក្រសួង

**មាត្រា៥៣២** ._ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវ ៖

១- គ្រប់គ្រង ដឹកនាំ និងត្រួតពិនិត្យការអនុវត្តមាតិកានេះ ។

២- ធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការបំពេញតាមតួនាទី ។

**មាត្រា៥៣៣** ._ សារពើភ័ណ្ឌកណ្តាលនៃធនធានទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវរក្សាទុកនូវរាល់សារពើភណ្ឌថ្នាក់កណ្តាលមួយអំពីធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា រួមមានទីកន្លែង បរិមាណ និងគុណភាពនៃធនធានក្នុងឆ្នាំនីមួយៗ ។

**មាត្រា៥៣៤** ._ ទិន្នន័យអំពីធនធានទឹក

ទិន្នន័យអំពីចំនួនទឹក គុណភាពទឹក និងព័ត៌មានពាក់ព័ន្ធនឹងទឹកដទៃទៀត ដែលប្រមូលបានដោយក្រសួង ស្ថាប័នមានសម្ថកិច្ច នៅពេលដែលត្រូវបានស្នើដោយក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវធ្វើការដាក់ជូនទៅក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ស្របតាមទម្រង់បែបបទដែលកំណត់ដោយ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ។ ទិន្នន័យពាក់ព័ន្ធនឹងទឹកដោយរៀបចំឡើងដោយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រុវធ្វើការផ្តល់ជូនដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ១ (មួយ) ដងក្នុង១(មួយ)ឆ្នាំ។

**មាត្រា៥៣៥** ._ ការអាចស្វែងរកបានទិន្នន័យ

ទិន្នន័យ និងព័ត៌មានដែលត្រូវដាក់ជូនដូចមានចែងក្នុងមាត្រា៥៣៤ ខាងលើ លើកលែងតែករណីពិត៌មាននោះជាព័ត៌មានសម្ងាត់ ត្រូវធ្វើការផ្តល់ជូនដោយឥតគិតថ្លៃដល់គ្រប់ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធដទៃទៀត សម្រាប់ជាប្រយោជន៍សាធារណៈ ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលព័ត៌មានបិរស្ថាន គន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក អាចតម្រូវឲ្យបង់ថ្លៃសម្រាប់ទិន្នន័យដែលស្នើសុំក្នុងគោលដៅពាណិជ្ជកម្ម ។

**មាត្រា៥៣៦** ._ ការចេញលិខិតបទដ្ឋានគតិយុត្ត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក អាចចេញលិខិតបទដ្ឋានគតិយុត្ត មានជាអាទិ៍ ៖

ក-កន្លែងដែលមានការហាមឃាត់ចំពោះការយក ឬ ការរំខានដល់ទឹក ឬការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ។

ខ-ការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការទាញយកទឹក ឬ រំខានដល់ធនធានទឹក ។

គ-ការបង្កើត និងការគ្រប់គ្រងអាជ្ញាធរអាងទន្លេនានា ។

ឃ-កិច្ចការអាទិភាពសម្រាប់ដាក់បញ្ចូលក្នុងផែនការធនធានទឹកនៃអាងទន្លេ ។

ង-ការលើកទឹកចិត្តឲ្យមានការស្រាវជ្រាវ ឬ ការអភិវឌ្ឍ បច្ចេកវិជ្ជាថ្មីៗ ដែលនឹងរួមចំណែកក្នុងការកាត់បន្ថយសំណល់ និងការកែលម្អគុណភាពទឹក និងបង្កើនប្រសិទ្ធផលនៃការប្រើប្រាស់ទឹក ។

ច- ការលើកទឹកចិត្ត និងការរារាំង ដែលរួមទាំង យន្តការហិរញ្ញវត្ថុ រួមមាន ការប្រើប្រាស់កម្រៃ និង តារាងថ្លៃតាមអត្រាថយចុះ ដើម្បីលើកទឹកចិត្តឲ្យមានការប្រើប្រាស់ទឹកដោយប្រសិទ្ធផល ជាអាទិ៍ ។

ឆ- ការបង្កើត និង គ្រប់គ្រងសហគមន៍អ្នកប្រើប្រាស់ទឹក ដែលរួមទាំង សហគមន៍កសិករប្រើប្រាស់ទឹក ។

ជ- ការប្រកាសតំបន់ការពារធម្មជាតិដែនទឹក ។

ឈ- ការកំណត់ និង គ្រប់គ្រងតំបន់តំកល់ទឹកជំនន់ ។

ញ-ការចាក់បំពេញ ឬការប្តូរទិសដៅនៃទីជម្រាល និងលំហូរទឹក ។

ដ-ការរៀបចំបទប្បបញ្ញត្តិស្តីពីការអភិវឌ្ឍទឹកក្រោមដី និងឧស្សាហកម្មអភិវឌ្ឍទឹកក្រោមដី រួមមានៈ

១-លក្ខខណ្ឌតម្រូវសម្រាប់អ្នកម៉ៅការខួងអណ្តូង និងការដំឡើងអណ្តូងស្នប់ ។

២-ការទាមទារឲ្យមានភស្តុតាងរបស់អ្នកកាន់វិញ្ញាបនបត្រ សម្រាប់ការប្រតិបត្តិការម៉ាស៊ីនខួង ។

៣-ការទទួលយកសំណាក ការធ្វើតេស្ត ការវិភាគ ការស្ទង់មតិ និងទិន្នន័យពីអណ្តូងខួង និង ការប្រគល់អ្វីៗទាំងនេះទៅឲ្យក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ។

៤-ការលុបអណ្តូងខួង និងវិធីសាស្ត្រ ក៏ដូចជាលក្ខខណ្ឌតម្រូវនានា ការដែលត្រូវបំពេញនៅក្នុងប្រតិបត្តិការលុបអណ្តូងខួង ។

៥-សកម្មភាពនានាក្នុងការដោះស្រាយបញ្ហាអណ្តូងខួងដែលពាក់ព័ន្ធ ។

៦-ការត្រួត្យពិនិត្យអណ្តូង ។

៧-វិធីសាស្ត្រនៃការជីកខួង និងការជីកអណ្តូង និង ការកំណត់ពីប្រភពនៃទឹកក្រោមដី ។

៨-ការប្រុងប្រយ័ត្ន និង វិធានការដើម្បីត្រូវអនុវត្តមុនពេល និងអំឡុងពេលនៃការខួង នៃការជីក និងការអភិវឌ្ឍលើអណ្តូង ។

៩-គោរពតាមការថែរក្សានានាសម្រាប់អណ្តូងដែលមិនដំណើរការ ។

១០-បានគោរពការថែរក្សា និង ការប្រតិបត្តិការដែលត្រូវមានជាបន្ត សម្រាប់អណ្តូង ។

ថ-ការកំណត់បន្ទុក និង ថ្លៃនានា ដែលត្រូវបង់សម្រាប់ការគ្រប់គ្រងធនធានទឹកស្របតាមមាតិកានេះ ។

## ផ្នែកទី២
## ការសម្របសម្រួលរបស់រាជរដ្ឋាភិបាល

**មាត្រា៥៣៧** ._ គណៈកម្មការជាតិរៀបចំផែនការ និងគ្រប់គ្រងអាងទន្លេ

ត្រូវចេញលិខិតបទដ្ឋានគតយុត្តដើម្បីបង្កើតគណៈកម្មាធិការជាតិរៀបចំផែនការ និងគ្រប់គ្រងអាងទន្លេ នៅក្រោមក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ដោយមានការចូលរួម ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងគណៈកម្មាធិការជាតិទន្លេមេគង្គ ។

**មាត្រា៥៣៨** ._ តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិរៀបចំផែនការ និងគ្រប់គ្រងអាងទន្លេ

គណៈកម្មាធិការជាតិរៀបចំផែនការ និងគ្រប់គ្រងអាងទន្លេ មានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

ក- សម្របសម្រួល និងគ្រប់គ្រងលើការរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីទឹកសម្រាប់គោលដៅគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍន៍អាងទន្លេ ។

ខ- តាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីទឹក សម្រាប់គ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍអាងទន្លេ ។

គ- សម្រុះសម្រួល និងដោះស្រាយទំនាស់នានាលើការគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍអាងទន្លេ ។

ឃ- អនុវត្តកិច្ចការដទៃទៀតតាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា៥៣៩** ._ សិទ្ធិ និងកាតព្វកិច្ចក្នុងការចូលរួមប្រើប្រាស់ អភិវឌ្ឍ និងគ្រប់គ្រងអាងទន្លេអន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិ និងករណីយកិច្ច ចូលរួមនៅក្នុងការប្រើប្រាស់ អភិវឌ្ឍ និងគ្រប់គ្រងភាគតាមសមធម៌ និងហេតុផលនៃ អាងទន្លេអន្តរជាតិ នៅក្នុងដែនទន្លេរបស់ប្រទេស ។

**មាត្រា៥៤០** ._ ការប្រើប្រាស់ដែលសមស្របបំផុត និងមានប្រសិទ្ធភាព

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវយកចិត្តទុកដាក់ជាពិសេស ចំពោះកម្រិតសមស្របបំផុត និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវអាងទន្លេមេគង្គ ស្របជាមួយគោលការណ៍ដឹកនាំនៃគណៈកម្មាធិការជាតិទន្លេមេគង្គ ។

## ជំពូកទី៣
## ការរៀបចំផែនការធនធានទឹក
### ផ្នែកទី១
### សមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក

**មាត្រា៥៤១** ._ ផែនការធនធានទឹកជាយុទ្ធសាស្ត្រថ្នាក់ជាតិ និងផែនការធនធានទឹកអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវគ្រោងសម្រាប់ការបែងចែក និងការគ្រប់គ្រងទឹកដោយនិរន្តរភាព ដើម្បីបំពេញបានតាមតម្រូវការរបស់កម្ពុជាទៅអនាគត តាមរយៈផែនការធនធានទឹកជាយុទ្ធសាស្ត្រថ្នាក់ជាតិ និងដោយរៀបចំផែនការធនធានទឹកអាងទន្លេ ។

**មាត្រា ៥៤២** ._ ការចូលរួមរបស់ភាគីពាក់ព័ន្ធ

នៅក្នុងការរៀបចំផែនការធនធានទឹកជាយុទ្ធសាស្ត្រថ្នាក់ជាតិ និងផែនការធនធានទឹកនៃអាងទន្លេរ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវសហការជាមួយគ្រប់ភាគីដែលពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍ មានជាអាទិ៍ អាជ្ញាធរថ្នាក់ក្រោមជាតិ វិស័យឯកជន ក្រុមអ្នកទទួលប្រយោជន៍ និងនីតិបុគ្គលផ្សេងៗទៀត ។

ការរៀបចំផែនការធនធានទឹកជាយុទ្ធសាស្ត្រ និងផែនការធនធានអាងទន្លេ ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនៃការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ស្របតាមគន្ថីទី១ មាតិកាទី២ និងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៥៤៣** ._ ប្រតិភូកម្មអំណាច

ការរៀបចំ និងការអនុវត្តផែនការធនធានទឹកនៃអាងទន្លេ អាចធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកទៅអាជ្ញាធរអាងទន្លេដែលត្រូវបង្កើតឡើងដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៥៤៤** ._ ភារកិច្ចអនុលោមតាម

អាជ្ញាធរអាងទន្លេ ដែលរៀបចំ ឬដែលអនុវត្តផែនការធនធានទឹកអាងទន្លេ ស្របតាមមាត្រា ៥៤៦ នៃមាតិកានេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃមាតិកានេះ ។

**មាត្រា៥៤៥** ._ ព័ត៌មានសម្រាប់រៀបចំផែនការ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវប្រមូលយក រក្សាទុក និងប្រើប្រាស់ព័ត៌មានសម្រាប់គោលបំណងនៃការរៀបចំផែនការដោយ ៖

ក- វាស់វែងជាទៀងទាត់ និងចុះកំណត់ត្រា អំពីបរិមាណ និងគុណភាពទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ- ប្រមូលព័ត៌មានអំពីតម្រូវការទឹក និងផលប៉ះពាល់នៃការគ្រប់គ្រងទឹកដល់ប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ជម្រកជលផល អត្រាជលផល និងប្រភេទសត្វដែលរងការគំរាមកំហែងពីក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងនីតិបុគ្គលនានា ។

គ- ប្រមូលព័ត៌មានអំពីតម្រូវការទឹកទៅអនាគត ។

ឃ- ធ្វើការកែលម្អជាបន្តបន្ទាប់នូវបណ្តាញជាតិសម្រាប់ការពិនិត្យតាមដាន ដើម្បីឲ្យមានការប្រមូលព័ត៌មានស្របតាមមាតិកានេះ ។

ព័ត៌មាន ដែលប្រមូលសម្រាប់គោលបំណងរៀបចំផែនការ ត្រូវដាក់ឲ្យសាធារណៈជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន គន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៥៤៦** ._ ក្រុមប្រឹក្សាយោបល់បច្ចេកទេស

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក អាចបង្កើតក្រុមប្រឹក្សាយោបល់បច្ចេកទេស ដែលមានសមាសភាពនៃមន្ត្រីជំនាញបច្ចេកទេស ដែលបំពេញបានតាមលក្ខខណ្ឌតម្រូវ ដែលត្រូវបង្កើតដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ដើម្បីណែនាំអំពី៖

ក- សំណើរ ឬសេចក្តីព្រាងនៃផែនការធនធានទឹកជាយុទ្ធសាស្ត្រថ្នាក់ជាតិ និងផែនការធនធានទឹក ។

ខ- សំណើរធ្វើវិសាធនកម្មលើផែនការធនធានទឹកជាយុទ្ធសាស្រ្ត និងផែនការធនធានទឹក។

គ- ការផ្តល់សិទ្ធិនៅក្រោមជំពូកទី៤ នៃមាតិកានេះ ។

## ផ្នែកទី២
## ផែនការធនធានទឹកជាយុទ្ធសាស្រ្ត ថ្នាក់ជាតិ

**មាត្រា៥៤៧** ._ គោលដៅនៃផែនការយុទ្ធសាស្រ្តធនធានទឹកថ្នាក់ជាតិ

ត្រូវរៀបចំផែនការយុទ្ធសាស្រ្តធនធានទឹកថ្នាក់ជាតិ ដើម្បីផ្តល់ជាមគ្គុទេស សម្រាប់ការសម្រេចបាននូវ ៖

ក- សន្តិសុខនៃការផ្គត់ផ្គង់ទឹកសម្រាប់រយៈពេលវែង នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ- និរន្តរភាពនៃធនធានទឹកក្នុងព្រះរាជាណាចក្រកម្ពុជា ។

គ-កិច្ចការពារទឹក និងប្រព័ន្ធអេកូឡូស៊ីដែលពឹងផ្អែកលើលំហូរទឹក ។

ឃ-ការបែងចែក និងប្រើប្រាស់ទឹកឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពដើម្បីទប់ស្កាត់គ្រោះមហន្តរាយ និង ទំនាស់នានា ។

**មាត្រា៥៤៨** ._ លក្ខខណ្ឌតម្រូវនៃផែនការធនធានទឹកជាយុទ្ធសាស្រ្ត ថ្នាក់ជាតិ

ផែនការធនធានទឹកជាយុទ្ធសាស្រ្ត ថ្នាក់ជាតិ ត្រូវរាប់បញ្ចូលនូវចំណុចដូចមានចែងដូចខាងក្រោម៖

ក- ការកំណត់អត្តសញ្ញាណនៃប្រព័ន្ធអេកូឡូស៊ី និងប្រភេទសត្វ និងរុក្ខជាតិ ដែលកំពុងស្ថិតក្នុងឋានៈដែលស្ថិតក្នុងក្តីបារម្ភណ៍ និងគ្រោះថ្នាក់ ដែលពាក់ព័ន្ធនឹងទឹក និងលំហូរផ្អែកបរិស្ថាន ។

ខ- ការព្យាករណ៍អំពីតម្រូវការទឹកដែលមានរយៈពេលវែង ។

គ- ការកំណត់អត្តសញ្ញាណអំពីនិន្នាការអាកាសធាតុ និងធាតុអាកាសរយៈពេលវែង

គ-ការព្យាករណ៍ពីការប្រែប្រួល និងបរិមាណទឹកនាពេលអនាគត ។

ឃ- ជម្រើសនានា ក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវនៃទឹកនាពេលអនាគត ។

ង- ជម្រើសនានា សម្រាប់ការគ្រប់គ្រងតម្រូវការទឹកនាពេលអនាគត ។

ច- ការផ្តល់អាទិភាពលើការប្រើប្រាស់ទឹក ។

ឆ- ការធានាបានថា ហេដ្ឋារចនាសម្ព័ន្ធនានា មិនបង្អាក់ដល់លំហូរទឹក និងមានលំហូរគ្រប់គ្រាន់សម្រាប់ផ្លូវទឹកដែលអាចកំណត់ទិសដៅបាន ។

១- យុទ្ធសាស្ត្រគ្រប់គ្រងគ្រោះរាំងស្ងួត ។

២- យុទ្ធសាស្ត្រគ្រប់គ្រងទឹកជំនុន ។

៣- គោលបំណងស្ដីលទ្ធភាពនៃគុណភាពទឹក ។

## ផ្នែកទី៣
## ផែនការធនធានទឹកអាងទន្លេ

**មាត្រា៥៤៩ .**_ គោលដៅនៃផែនការធនធានទឹកអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវរៀបចំផែនការធនធានទឹកអាងទន្លេដើម្បីះ

ក- កំណត់ពីវត្តមាននៃទឹកសម្រាប់គោលបំណងនីមួយ ។

ខ- ផ្ដល់ក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រងទឹកឲ្យមាននិរន្តរភាព និងការទាញយកទឹក ។

គ- កំណត់អាទិភាព និងយន្តការនានាសម្រាប់ដោះស្រាយតម្រូវការទឹកទៅអនាគត ។

ឃ- ផ្ដល់ក្របខ័ណ្ឌសម្រាប់បង្កើតការបែងចែកទឹក ។

ង- ផ្ដល់ក្របខ័ណ្ឌសម្រាប់កែប្រែស្ថានភាពនៃការរេចរឹល ដែលកើតឡើងដល់ប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ដូចជា ទន្លេដែលមានសភាពរីងស្ងួត ឬ តានតឹងជាដើម ។

**មាត្រា៥៥០ .**_ ទឹកក្រោមដី

ផែនការធនធានទឹកអាងទន្លេ ត្រូវផ្ដល់ក្របខ័ណ្ឌក្នុងការការទាញយកទឹកពីក្រោមដី ប្រសិនបើក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក យល់ថាមានហានិភ័យធ្ងន់ធ្ងរ ដោយការទាញយក ឬ ការរំខានដល់ទឹកក្រោមដី នៅក្នុងកន្លែងណាមួយ អាចប៉ះពាល់ជាខ្លាំងដល់ ៖

ក- វត្តមានទឹកសម្រាប់អ្នកប្រើប្រាស់បច្ចុប្បន្ន ។

ខ- តម្រូវការទឹកសម្រាប់ប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ។

គ- គុណភាពទឹក ។

ឃ- សមិទ្ធផលនៃគោលដៅណាមួយ ឬ លទ្ធផលផ្សេងទៀត នៅក្នុងផែនការ ។

**មាត្រា៥៥១ .**_ ការប្រកាសផ្អាកការអភិវឌ្ឍជាបណ្ដោះអាសន្ន

នៅពេលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ចេញសេចក្ដីជូនដំណឹងអំពីបំណងក្នុងការរៀបចំផែនការធនធានទឹកអាងទន្លេ ត្រូវចេញប្រកាសផ្អាកការអភិវឌ្ឍនានា នៅក្នុងតំបន់ជម្រាលទឹកនៃអាងទន្លេ ដែលត្រូវមានសុពលភាពរហូតដល់ពេលដែលះ

ក- ផែនការធនធានទឹក ត្រូវបានអនុម័ត ដោយលិខិតបទដ្ឋានគតិយុត្តណាមួយ ឬ

ខ- ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ចេញសេចក្តីជូនដំណឹងពីការលុបចោលបំណងរៀបចំផែនការធនធានទឹក និងចែងពីមូលហេតុនៃការលុបចោលនោះ ។

**មាត្រា៥៥២** ._ វិធាននៃការផ្អាកជាបណ្តោះអាសន្នស្តីពីការអភិវឌ្ឍ

នៅពេលដែលមានការផ្អាកការអភិវឌ្ឍជាបណ្តោះអាសន្ន ដូចមានចែងក្នុងមាត្រា៥៥១ នៃក្រមនេះចូលជាធរមាន នោះ ៖

ក-មិនមានពាក្យសុំក្រោមក្រមនេះត្រូវបានទទួលយក ឬ ដំណើការ ទោះបីជាត្រូវបានដាក់បញ្ជូនមុនការផ្អាកជាបណ្តោះអាសន្នចូលជាធរមាន ប្រសិនបើការផ្តល់ពាក្យសុំអាចមានឥទ្ធិពលមួយ ឬ ច្រើន ដូចរៀបរាប់ខាងក្រោម ៖

១-ការកើនឡើងចំនួនទឹកដែលអាចត្រូវបានយក ។

២-ការផ្លាស់ប្តូរទីតាំងពីកន្លែងដែលទឹកត្រូវបានយក ។

៣-ការកើនឡើងអត្រាដែលទឹកអាចត្រូវបានយក ។

៤-ការផ្លាស់ប្តូរលក្ខខណ្ឌចរន្តដែលទឹកអាចត្រូវបានយកក្រោមនោះ ។

៥-ការផ្លាស់ប្តូរគោលដៅដែលទឹកអាចត្រូវបានយក ។

ខ-ការងារថ្មីមិនត្រូវចាប់ផ្តើមជារូបរាងក្នុងតំបន់ដែលគ្រប់គ្រងដោយអនុស្សាវរណៈ ។

គ-ការងារដែលចាប់ផ្តើមហើយអាចត្រូវបានបញ្ចប់បាន ទាល់តែមានការឯកភាពជាលាយលក្ខណ៍អក្សរពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក និងផ្អែកលើលក្ខខណ្ឌដែលរួមមាន កាលបរិច្ឆេទបញ្ចប់ ដែលកម្រិតដោយក្រសួង ស្ថាប័នទទួលបន្ទុក វិស័យធនធានទឹក និង

ឃ-កិច្ចការបញ្ចប់ដែលមានមិនត្រូវលើកឡើង ពង្រីក ធ្វើឲ្យជ្រៅ ឬ ផ្លាស់ប្តូរ ។

**មាត្រា៥៥៣** ._ ការចូលជាធរមាននៃផែនការមួយចំនួន

មានតែផែនការធនធានទឹកអាងទន្លេ១ (មួយ)ប៉ុណ្ណោះ ដែលត្រូវចូលជាធរមាននៅពេលវេលាមួយកំណត់ លើកលែងតែនៅពេលមានផែនការដាច់ដោយឡែក ត្រូវបានរៀបចំសម្រាប់ ធនធានទឹកដីលើ និងទឹកក្រោមដី ។

**មាត្រា៥៥៤** ._ លក្ខខណ្ឌតម្រូវនៃផែនការធនធានទឹកអាងទន្លេ

សេចក្តីព្រាងផែនការធនធានទឹកអាងទន្លេត្រូវ ៖

ក-លើកឡើងពីគោលដៅនៃសេចក្តីព្រាងផែនការ ។

ខ-មានផែនទីនៃតំបន់ផែនការដែលស្នើរួច ។

គ-លើកឡើងពីទឹកដែលសេចក្តីព្រាងផែនការមានបំណងក្នុងការអនុវត្តលើ ។

ឃ- លើកឡើងពីអាទិភាពនៃទឹក និងអ្នកប្រើប្រាស់ធនធានទឹកដែលមនុស្សត្រូវការ និង សេវាកម្មប្រព័ន្ធអេកូឡូស៊ីទទួលបានទឹក និងធនធានទឹកគ្រប់គ្រាន់ មុននឹងបែងចែកទឹក និងធនធានទឹកដែលលើសទៅកាន់អ្នកប្រើប្រាស់ដទៃទៀត ។

ង-លើកឡើងពីលទ្ធផល ដែលរួមមាន លទ្ធផលអេកូឡូស៊ី ទាក់ទងនឹងប្រព័ន្ធអេកូឡូស៊ីក្នុងផ្នែកផ្សំរបស់វា ដែលរួមមានល្អាងទឹកក្រោមដី អាងបង្ហូរទឹក អាងប្រមូលទឹក អនុអាងប្រមូលទឹក និងគ្រប់ផ្លូវទឹកអចិន្ត្រៃយ៍ សម្រាប់ការគ្រប់គ្រងទឹកប្រកបដោយនិរន្តរភាព ។

ច-នៅក្នុងកម្រិតដែលអាចធ្វើទៅបានដោយប្រើប្រាស់ព័ត៌មានវិទ្យាសាស្ត្រល្អបំផុតដែលអាចស្វែងរកបាន ត្រូវលើកឡើងពីយុទ្ធសាស្ត្រដែលបានស្នើឡើង ដើម្បីសម្រេចបាននូវលទ្ធផល ដែលត្រូវបានកំណត់ក្នុងអនុផ្នែកមាត្រានេះ ដែលរួមមាន ការកម្រិតទៅលើការយកជាសរុបពីអាង ។

ឆ-លើកឡើងពីយុទ្ធសាស្ត្រដែលបានស្នើឡើងសម្រាប់បង្កើតការបែងចែកទឹកទៅកាន់តំបន់ផែនការដែលបានស្នើ ។

ជ-លើកឡើងពីវិធានគ្រប់គ្រងបរិស្ថាន និងវិធានបែងចែកទឹកសម្រាប់ទឹកដែលសេចក្តីព្រាងផែនការមានបំណងក្នុងការអនុវត្ត ។

ឈ-កំណត់ហេដ្ឋារចនាសម្ព័ន្ធទឹក និងដែលរួមមាន ប្រតិបត្តិការនៃរចនាសម្ព័ន្ធទឹកដែលសេចក្តីព្រាងផែនការមានបំណងនឹងអនុវត្ត ។

ញ-កំណត់កម្រិតផ្គត់ផ្គង់ពេញលេញ សម្រាប់ទំនប់ទាំងឡាយណា ដែលត្រូវបានរួមបញ្ចូលក្នុងហេដ្ឋារចនាសម្ព័ន្ធដែលមានកំណត់ក្នុងអនុផ្នែកនៃចំណុច ង. នៃមាត្រានេះ ។

ដ-លើកឡើងពីលក្ខខណ្ឌតម្រូវនៃការអង្កេតតាមដាន និងការរៀបចំរបាយការណ៍ទឹក និងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ដែលអាចរួមមានសូចនាករសុខភាពអាងទន្លេ ដើម្បីជួយក្នុងការវាយតម្លៃប្រសិទ្ធភាពនៃយុទ្ធសាស្ត្រគ្រប់គ្រងដែលស្នើក្នុងការសម្រេចបាននូវលទ្ធផលដែលលើកឡើងក្នុងអនុផ្នែកនៃមាត្រានេះ ។

ឋ-លើកឡើងពីលក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍ជាប្រចាំ សម្រាប់ការអនុវត្តសេចក្តីព្រាងផែនការ ។

ឌ-រួមមានតារាងនៃការរៀបចំចាត់ចែងដែលស្នើឡើង សម្រាប់ការអនុវត្តសេចក្តីព្រាងផែនការ ។

ឍ-រួមមានព័ត៌មានអំពីទឹកដែលមាន ដែលមិនទាន់បានបែងចែកសម្រាប់គោលដៅប្រើប្រាស់នាពេលអនាគត និងអាទិភាព និងដំណើការសម្រាប់ការបែងចែក ឬ បម្រុងទឹកទុក ។

ណ-បង្កើតដំណើរការក្នុងការផ្តល់ បម្រុងទុក ឬ ផ្ទុយពីនោះ ដោះស្រាយទៅលើទឹក ដែលមិនទាន់បែងចែក ដែលសេចក្តីព្រាងផែនការមានបំណងក្នុងការអនុវត្ត ។

ត-លើកឡើងពីលក្ខណៈវិនិច្ឆ័យសម្រាប់កែប្រែសិទ្ធិទទួលបានព័ត៌មានទឹកដែលមាន ស្រាប់ ក្នុងករណីចាំបាច់ ដើម្បីសម្រេចបាននូវលទ្ធផលផែនការ ។

ថ-លើកឡើងពីលក្ខណៈវិនិច្ឆ័យសម្រាប់ដោះស្រាយលើភាពរេចរិលដែលបានកើត ឡើងក្នុងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ។

**មាត្រា៥៥៥** ._ ផែនការទន្លេមេគង្គ

ផែនការធនធានទឹកអាងទន្លេ ដែលអនុវត្តចំពោះធនធានទឹកទន្លេមេគង្គ ត្រូវពិចារណាអំពីៈ

ក-ចរន្តហូរទឹកឆ្លងដែនចូលមកកាន់ព្រះរាជាណាចក្រកម្ពុជា ។

ខ-លក្ខខណ្ឌតម្រូវស្របច្បាប់ ឬ មិនលម្អៀង សម្រាប់ចរន្តហូរទឹកផ្នែកខាងក្រោមឆ្លង ដែននៃព្រះរាជាណាចក្រកម្ពុជា ស្របតាមបទប្បញ្ញត្តិ នៃសន្ធិសញ្ញាអង្គការសហប្រជាជាតិស្តី ពីច្បាប់នៃការប្រើប្រាស់ផ្លូវទឹកអន្តរជាតិដែលមិនពាក់ព័ន្ធនឹងការធ្វើនាវាចរ ។

គ-បញ្ហាបរិស្ថានឆ្លងដែនដទៃៗទៀត ។

ឃ-ការកើតមានប្រតិបត្តិការ និងលក្ខខណ្ឌតម្រូវ នៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល ដែលទាក់ទងនឹងទន្លេមេគង្គ ។

**មាត្រា៥៥៦** ._ សេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ

សេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ ត្រូវផ្តល់នូវក្របខ័ណ្ឌសម្រាប់ការបង្កើតសិទ្ធិទទួល បានទឹកដោយលើកឡើងនូវចំណុចដូចខាងក្រោមៈ

ក- គោលដៅលំហូរបរិស្ថាន ។

ខ- គោលបំណងសន្តិសុខសិទ្ធិទទួលបានទឹក ។

គ- សូចនករការងារ សម្រាប់គោលបំណងលំហូរបរិស្ថាន និងគោលបំណង សន្តិ សុខនៃសិទ្ធិទទួលបានទឹក ។

ឃ- អាទិភាពសម្រាប់ការផ្តល់សិទ្ធិទទួលបានព័ត៌មាន ។

**មាត្រា៥៥៧** ._ ការពិចារណា សម្រាប់សេចក្តីព្រាងផែនការ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវពិចារណាទៅលើចំណុចខាងក្រោមនៅពេល រៀបចំសេចក្តីព្រាងផែនការធនធានទឹកអាងទន្លេៈ

ក-កម្រិតនិងគុណភាពទឹកក្នុងតំបន់ផែនការ ។

ខ-គោលបំណង និងអាទិភាព ជាតិ និងក្រោមជាតិ សម្រាប់លើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

គ-ផែនការតំបន់ផ្សេងៗសម្រាប់តំបន់ ។

ឃ-រយៈពេល ភាពញឹកញាប់ ទំហំ និងការកំណត់ពេលនៃលំហូរទឹក ដែលវាមានសារសំខាន់ក្នុងការគាំទ្រប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងប្រភេទសត្វ រុក្ខជាតិ ស្ថិតក្នុងក្តីកង្វល់ពាក់ព័ន្ធទៅនឹងឋានៈ និងការទទួលរងគ្រោះថ្នាក់ ដូចបានវាយតម្លៃដោយប្រើព័ត៌មានវិទ្យាសាស្ត្រល្អបំផុតដែលមាន ។

ង-ការជន់លេច និងការសម្ងួតដើម្បីគាំទ្រប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងប្រភេតសត្វ រុក្ខជាតិដែលស្ថិតក្នុងក្តីកង្វល់ពាក់ព័ន្ធទៅនឹងឋានៈ និងការទទួលរងគ្រោះថ្នាក់

ច-កម្រិតទឹកក្រោមដី និងដំណើរការហូរទឹកពីលើដីទៅក្រោមដី ដែលមានសារសំខាន់ក្នុងការគាំទ្រប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងប្រភេទសត្វ រុក្ខជាតិដែលស្ថិតក្នុងក្តីកង្វល់ពាក់ព័ន្ធទៅនឹងឋានៈ និងការទទួលរងគ្រោះថ្នាក់។

ឆ-ការចូលរួមគ្រប់គ្រងទឹកនៃទីជម្រក ឬ ប្រព័ន្ធពាក់ព័ន្ធ ដែលរួមមានព្រៃឈើ និងដីសើម ដែលគាំទ្រនូវគោលបំណងនៃផែនការធនធានទឹកអាងទន្លេ ។

ជ-សិទ្ធិដែលមានស្រាប់ក្នុងការទទួលបាន ប្រើប្រាស់ ឬគ្រប់គ្រងទឹក ។

ឈ-លក្ខខណ្ឌតម្រូវរបស់ទឹកនាពេលអនាគតរបស់ព្រះរាជាណាចក្រកម្ពុជា ដែលរួមមានលក្ខខណ្ឌតម្រូវវប្បធម៌ សេដ្ឋកិច្ច បរិស្ថាន និងសង្គម ។

ញ-តម្លៃវប្បធម៌ សេដ្ឋកិច្ច បរិស្ថាន និងសង្គម ។

ដ-ការវាយតម្លៃផ្នែកបច្ចេកទេសសម្រាប់សេចក្តីព្រាងផែនការ ។

ឋ-ឥទ្ធិពលដែលសេចក្តីព្រាងផែនការនឹងមានទៅលើទឹកដែលមិនមានលើកឡើងក្នុងសេចក្តីព្រាងផែនការ ។

ឌ-ឥទ្ធិពលដែលការយក ឬ ធ្វើអន្តរាគមន៍ជាមួយទឹកដែលមិនមានលើកឡើងក្នុងសេចក្តីព្រាងផែនការ និងមានលើទឹកដែលលើកឡើងក្នុងសេចក្តីព្រាងផែនការ ។

ឍ-យុទ្ធសាស្ត្រគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាពសម្រាប់អាងទន្លេ ឬ អាងទឹកក្រោមដី ដែលរួមមានតំបន់ឆ្នេរពាក់ព័ន្ធផ្សេងៗ ។

ណ-គ្រប់ការដាក់បញ្ជូន ទាក់ទងនឹងសេចក្តីព្រាងផែនការដែលស្នើឡើង ។

ត-ផលប្រយោជន៍សាធារណៈ ។

**មាត្រា៥៥៨** ._ ការជូនដំណឹងនៃសេចក្តីព្រាងផែនការ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវផ្សព្វផ្សាយការជូនដំណឹងទៅក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាធារណជននៅពេលដែលសេចក្តីព្រាងផែនការធនធានទឹកអាងទន្លេត្រូវបានរៀបចំ ដោយលើកឡើងអំពី៖

ក- ទីកន្លែងដែលត្រូវទទួលសេចក្តីព្រាងផែនការ ។

ខ- លិខិតប្រគល់ ដែលធ្វើឡើងរវាងរូបវន្តបុគ្គល ឬនីតិបុគ្គល ពាក់ព័ន្ធទៅនឹងសេចក្តីព្រាងផែនការ ។

គ- លិខិតប្រគល់ត្រូវធ្វើឡើងតាមកាលបរិច្ឆេទ យ៉ាងតិច ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីបានចេញសេចក្តីជូនដំណឹងអំពីសេចក្តីព្រាងផែនការ ដោយមានបញ្ជាក់ពីទីកន្លែង និងមនុស្សដែលត្រូវទទួល ។

**មាត្រា៥៥៩** ._ ការចូលរួមជាសាធារណៈ

រូបវន្តបុគ្គល ឬ នីតិបុគ្គល អាចដាក់បញ្ជូនឯកសារទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក អំពីទិដ្ឋភាពណាមួយនៃសេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ ដែលរួមមានបញ្ហានានាដែលមិនបានដាក់បញ្ចូលក្នុងសេចក្តីព្រាងផែនការ តាមរយៈកាលបរិច្ឆេទដែលលើកឡើងក្នុងការជូនដំណឹងដែលចេញផ្សាយ ដូចមានចែងក្នុងមាត្រា៥៥៨ នៃក្រមនេះ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ នៃគន្ថីទី១ មាតិកាទី២ នៃក្រមនេះ ។

**មាត្រា៥៦០** ._ ការពិចារណាទៅលើមតិយោបល់សាធារណជន

មុននឹងបញ្ចប់ផែនការធនធានទឹកអាងទន្លេ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវពិចារណារាល់ការដាក់បញ្ជូនដែលបានធ្វើឡើងស្របតាមមាត្រា៥៥៩ នៃក្រមនេះ ទាក់ទងនឹងសេចក្តីព្រាងផែនការ ។

**មាត្រា៥៦១** ._ ផែនការចុងក្រោយ

ផែនការធនធានទឹកអាងទន្លេចុងក្រោយ មិនមានអនុភាពនោះទេ ទាល់តែវាត្រូវបានឯកភាពដោយគណៈរដ្ឋមន្ត្រី ។

**មាត្រា៥៦២** ._ ផែនការដែលទទួលបានការឯកភាព

ផែនការធនធានទឹកអាងទន្លេដែលទទួលបានការឯកភាព ត្រូវផុតកំណត់បន្ទាប់ពី១០(ដប់)ឆ្នាំ លើកលែងតែមុនរយៈពេលនេះ ផែនការនោះត្រូវបាន៖

ក-និរាករណ៍ ឬ

ខ-ជំនួសដោយផែនការធនធានទឹកផ្សេងទៀតដែលបានចាប់ផ្តើម និងដែលលើកឡើងថាវាជាផែនការជំនួស ។

**មាត្រា៥៦៣** ._ វិសោធនកម្ម និងផែនការថ្មី

ដោយការសម្រេចដោយខ្លួនឯង ឬ ដោយឆ្លើយតបចំពោះបណ្តឹងដែលប្តឹងមកកាន់ខ្លួនដោយរូបវន្តបុគ្គល ឬ នីតិបុគ្គល ក្រសួង ស្ថាប័ន ទទួលបន្ទុកវិស័យធនធានទឹក អាច ៖

ក- ធ្វើវិសោធនកម្មទៅលើផែនការធនធានទឹកអាងទន្លេ ឬ

ខ- រៀបចំផែនការធនធានទឹកអាងទន្លេថ្មីមួយ ដើម្បីជំនួសផែនការដែលមានស្រាប់ ។

**មាត្រា៥៦៤** ._ ការធ្វើយុត្តិកម្មសម្រាប់ការធ្វើវិសោធនកម្ម ឬ ផែនការថ្មី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក អាចធ្វើវិសោធនកម្ម ឬរៀបចំផែនការធនធានទឹកអាងទន្លេថ្មី ស្របតាមមាត្រា៥៦៣នៃក្រមនេះ នៅក្នុងករណីដែល៖

ក-លទ្ធផលនៃផែនការធនធានទឹកអាងទន្លេមិនអាចសម្រេចបាន ឬ

ខ-គោលបំណងនៃផែនការធនធានទឹកអាងទន្លេ ឬយុទ្ធសាស្ត្រសម្រាប់សម្រេចបាននូវលទ្ធផលរបស់ផែនការ លែងមានលក្ខណៈសមស្របសម្រាប់តំបន់ផែនការទៀតហើយ ។

**មាត្រា៥៦៥** ._ ការចូលរួមជាសាធារណៈ

នៅពេលធ្វើវិសោធនកម្មទៅលើផែនការធនធានទឹកអាងទន្លេដែលមានស្រាប់ ដូចមានចែងនៅក្នុងមាត្រា៥៦៣ នៃក្រមនេះ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវអនុលោមតាមជំពូកនេះ និងស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ នៃគន្ថីទី១ មាតិកាទី៣ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៃគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

## ជំពូកទី៤
## ការផ្តល់ការអនុញ្ញាត
### ផ្នែកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៥៦៦** ._ សិទ្ធិក្នុងការប្រើប្រាស់ធនធានទឹក

រាល់រូបវន្តបុគ្គលមានសិទ្ធិក្នុងការយក និងប្រើប្រាស់ធនធានទឹកដោយមិនត្រូវការមានការផ្តល់ការអនុញ្ញាតក្រោមជំពូកនេះ សម្រាប់៖

ក-តម្រូវការរបស់មនុស្សជាសំខាន់ ដែលរួមមាន ការផឹក ការសម្អាត ការងូត អនាម័យ ការស្រោចស្រពសួននៅតាមផ្ទះ និងចំការផលព្រឹក្ស និងគោលដៅក្នុងផ្ទះផ្សេងៗទៀត ។

ខ-គោលដៅសង្គ្រោះបន្ទាន់ ដែលរួមមានការពន្លត់អគ្គិភ័យ ។

**មាត្រា៥៦៧** ._ ការការពារសិទ្ធិស្របច្បាប់របស់អ្នកដទៃ

ការយក និងការប្រើប្រាស់ធនធានទឹក ដូចមានចែងក្នុងមាត្រា៥៦៦ នៃក្រមនេះ ត្រូវធ្វើឡើងក្នុងលក្ខណៈដែលមិនប៉ះពាល់សិទ្ធិស្របច្បាប់របស់រូបវន្តបុគ្គលផ្សេងៗទៀត ។

**មាត្រា៥៦៨** ._ សិទ្ធិរបស់ម្ចាស់ និងអ្នកកាន់កាប់ដី

ម្ចាស់ និងអ្នកកាន់កាប់ដីមានសិទ្ធិប្រមូល និងប្រើប្រាស់ទឹកភ្លៀង និងទឹកដែលហូរជាធម្មជាតិលើដីរបស់ពួកគេដោយគ្មានការផ្តល់ការអនុញ្ញាតក្រោមជំពូកនេះ នៅក្នុងករណីដែលធ្វើឡើងស្របតាម និមាត្រា៥៦៦ នៃក្រមនេះ នៅក្នុងករណីដែលលំហូរទឹកធម្មជាតិនេះ មិនត្រូវបានរាំង ឬទប់ស្កាត់ ដោយការធ្វើសំណង់ផ្លូវ របង ទំនប់ការពារ អាងទឹកបង្កើតឡើងដោយទំនប់ ឬ ត្រពាំង ។

**មាត្រា៥៦៩** ._ សកម្មភាពដែលតម្រូវឲ្យមានការផ្តល់ការអនុញ្ញាត

សកម្មភាពខាងក្រោមត្រូវបានហាមឃាត់ប្រសិនបើមិនមានការអនុញ្ញាតដោយការផ្តល់សិទ្ធិអំណាចដែលចេញ ស្របតាមជំពូកនេះ និង បើមិនបានធ្វើស្របតាមលក្ខខណ្ឌទាំងអស់របស់ការផ្តល់ការអនុញ្ញាត ៖

ក-ការរារាំង ទប់ស្កាត់ ការបង្វែរ ការយក ឬការប្រើប្រាស់ធនធានទឹក ក្រៅពីអ្វីដែលមានចែងក្នុងមាត្រា៥៦៦ និងមាត្រា៥៦៧ និងមាត្រា៥៦៨

ខ-ការសាងសង់ ឬប្រតិបត្តិការនៃការសាងសង់ដើម្បីរាំង ទប់ស្កាត់ បង្វែរ ឬយកធនធានទឹក ក្រៅពីអ្វីដែលមានចែងក្នុងមាត្រា៥៦៧ និងមាត្រា៥៦៨ នៃក្រមនេះ។

គ-ការទាញយក ដីខ្សាច់ ដី ថ្ម គ្រួស រ៉ែ សាំង ហ្គាសពីបាត និងច្រាំង ផ្លូវទឹក បឹង ដីសើម តំបន់ទំនាប ទឹកផុសពីក្នុងដី ឬ អាងទឹក ។

ឃ-ការបំពេញ ការបង្កើតខ្សែទឹក ការជីកប្រឡាយ ឬ ការកែប្រែនៃផ្លូវទឹក បឹង ដីសើម តំបន់ទំនាប ទឹកផុសពីក្នុងដី ឬ អាងទឹក ។

**មាត្រា៥៧០** ._ កម្រិតសម្រាប់ការរារាំង ទប់ស្កាត់ ការបង្វែរ ការយក ឬ ប្រើប្រាស់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក អាចបង្កើតដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនូវកម្រិតសម្រាប់ការធ្វើអន្តរាគមន៍ជាមួយ ការបង្វែរ ការយក ឬប្រើប្រាស់ធនធានទឹកសម្រាប់គោលដៅជាក់លាក់ដែលមិនតម្រូវឲ្យមានការផ្តល់សិទ្ធិអំណាច ដូចមានចែងក្នុងមាត្រា៥៦៩ នៃក្រមនេះ ។

**មាត្រា៥៧១** ._ ពាក្យសុំសម្រាប់ការផ្តល់ការអនុញ្ញាត

ពាក្យសុំសម្រាប់ការផ្តល់ការអនុញ្ញាតក្រោមជំពូកនេះត្រូវអមដោយការឯកភាពផ្សេងៗទៅតាមលក្ខខណ្ឌតម្រូវដែលតម្រូវដោយក្រមនេះ ។

## ផ្នែកទី២
## អាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធ

**មាត្រា៥៧២** ._ អាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវផ្តល់អាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធទៅគ្រប់ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបានកំណត់ក្នុងផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៥៧៣** ._ គោលដៅនៃលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ

អាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធផ្តល់ការអនុញ្ញាតដល់អ្នកកាន់កាប់នោះប្រើប្រាស់ ចរន្តទឹកហូរក្នុងកម្រិតមួយចាំបាច់ដើម្បី សង់ហេដ្ឋារចនាសម្ព័ន្ធដូចដែលអាជ្ញាប័ណ្ណបានផ្តល់ឲ្យ ។

**មាត្រា៥៧៤** ._ លក្ខខណ្ឌសម្រាប់អាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវកំណត់លក្ខខណ្ឌតម្រូវសម្រាប់អាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធក្នុងលិខិតបទដ្ឋានគតិយុត្ត ។

## ផ្នែកទី៣
## សិទ្ធិទទួលបានទឹក

**មាត្រា៥៧៥** ._ ការចុះបញ្ជីសិទ្ធិទទួលបានទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវរក្សានូវការចុះបញ្ជីនៃគ្រប់សិទ្ធិទទួលបានទឹក ។ ព័ត៌មានដែលត្រូវដាក់បញ្ចូលទៅក្នុងសិទ្ធិទទួលបានទឹក ត្រូវកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា៥៧៦** ._ លក្ខខណ្ឌសម្រាប់សិទ្ធិទទួលបានទឹក

ការយក ឬ ការបង្វែរធនធានទឹក អាចត្រឹមតែធ្វើទៅបានស្របតាមសិទ្ធិទទួលបានទឹកដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ។

**មាត្រា៥៧៧** ._ សិទ្ធិស្របច្បាប់ចំពោះសិទ្ធិទទួលបានទឹក

រូបវន្តបុគ្គលដែលមានសិទ្ធិស្របច្បាប់ចំពោះក្បាលដី អាចដាក់ពាក្យសុំទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក សម្រាប់សិទ្ធិទទួលបានទឹក ដើម្បីយកប្រើប្រាស់ជាមួយទឹកដែលមានប្រភពមកពី ៖

ក-ផ្លូវទឹក បឹង ទឹកផុសពីក្រោមដី លើ ឬ ជាប់ដី ។

ខ-ល្អាងទឹកក្រោមដី នៅក្រោមដីណាមួយ ។

គ-ទឹកហូរកាត់ដីផ្សេងៗ ។

ឃ-ហេដ្ឋារចនាសម្ព័ន្ធដែលប្រតិបត្តិការក្រោមលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធដែលអាចផ្គត់ផ្គង់ទឹកទៅកាន់ដី ។

**មាត្រា៥៧៨** ._ នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ពាក្យសុំ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តនូវនីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ពាក្យសុំសិទ្ធិទទួលបានទឹក ។

**មាត្រា៥៧៩** ._ ការជូនដំណឹងជាសាធារណៈ

នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក យល់ថាមានព័ត៌មានគ្រប់គ្រាន់ដើម្បីធ្វើការសម្រេចចិត្តលើពាក្យសុំហើយនោះ ក្រសួងអាចចេញការជូនដំណឹងជាសាធារណៈអំពីពាក្យសុំដែលលើកឡើងពី៖

ក-សេចក្ដីលម្អិតនៃពាក្យសុំ ។

ខ-ទីកន្លែងដែលពាក្យសុំអាចត្រូវបានពិនិត្យ ។

គ-កាលបរិច្ឆេទ យ៉ាងហោចណាស់ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីការជូនដំណឹងជាសាធារណៈត្រូវបានចេញ ដែលការដាក់បញ្ជូនពាក្យសុំជាលាយលក្ខណ៍អក្សរ អាចធ្វើឡើងទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ។

**មាត្រា៥៨០** ._ នីតិវិធីនិងលក្ខខណ្ឌតម្រូវសម្រាប់ការកំណត់

នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់កំណត់នូវ ការឯកភាព ឬ ការបដិសេធទៅលើសិទ្ធិទទួលបានទឹកត្រូវបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា៥៨១** ._ ករណីលើកលែងស្តីពីលំហូរបរិស្ថាន

លំហូរបរិស្ថាន មិនត្រូវស្ថិតនៅក្រោមការកំណត់ពីចំនួនទឹកជាអតិបរិមាទៅលើការបែងចែកទឹកនោះទេ ។

**មាត្រា៥៨២** ._ ការប្រកាសផ្សាយអំពីការទទួលបានទឹកប្រើប្រាស់

មុនពេលចាប់ផ្តើមឆ្នាំការិយបរិច្ឆេទនៃទឹកនីមួយៗក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវប្រកាសនូវសិទ្ធិទទួលបានទឹកប្រើប្រាស់ដែលត្រូវសម្រេចសម្រាប់ឆ្នាំការិយបរិច្ឆេទនោះ ស្របតាមវិធានចែករំលែកទឹក និងក្រុមអាទិភាព ដែលត្រូវបានបង្កើតឡើងដោយផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៥៨៣** ._ សិទ្ធិប្រើប្រាស់ទឹកដែលប្រកាសទទួលស្គាល់រួចរាល់

សិទ្ធិដែលប្រកាសរួចរាល់ ៖

ក-គឺជាភាគរយនៃតម្លៃកំណត់ទុកមុន នៃសិទ្ធិទទួលបានទឹកដែលអាចយកក្នុងឆ្នាំការិយបរិច្ឆេទនៃទឹក ។

ខ-ត្រូវបានសម្រេចចិត្តមុនការចាប់ផ្តើមនៃឆ្នាំនៃទឹកដែលសិទ្ធិដែលប្រកាសរួចរាល់ពាក់ព័ន្ធ ។

គ-ត្រូវបានកំណត់ដោយផ្អែកលើភាពអាចរកបានទឹកតាមរដូវកាលជាក់ស្តែងដែលសិទ្ធិត្រូវទទួលបាន ។

ឃ-អាចត្រូវបានធ្វើឲ្យកើនអំឡុងឆ្នាំនៃទឹក ។

ង-អាចខុសគ្នាទៅតាមអនុតំបន់ផ្សេងគ្នានៃអាង ។

ច-អាចត្រូវបានប្រកាសផ្សេងគ្នាសម្រាប់សិទ្ធិទទួលបានទឹកក្នុងក្រុមអាទិភាព ។

ឆ-ដាក់ពាក្យសុំការផ្តល់សិទ្ធិអំណាចជាមួយនឹងគោលដៅនៃការផ្គត់ផ្គង់ទឹកក្រុង និងទីក្រុង ។

**មាត្រា៥៨៤** ._ សិទ្ធិដែលត្រូវបានគ្រប់គ្រងក្រោមផែនការធនធានទឹកអាងទន្លេ

សម្រាប់សិទ្ធិការទទួលបានទឹកដែលត្រូវបានគ្រប់គ្រងក្រោមផែនការធនធានទឹកអាងទន្លេះ

ក-អាចយកទឹកបានក្នុងករណីតែវាស្របនឹងផែនការនោះ ។

ខ-ប្រសិនបើមានជម្លោះរវាងផែនការ និងសិទ្ធិទទួលបានទឹក ផែនការមានអនុភាពជាង ។

គ-សិទ្ធិទទួលបានទឹកមិនអាចត្រូវបានផ្លាស់ប្តូរ ក្នុងវិធីណាមួយដែលអាចកាត់បន្ថយចំនួននៃ ឬ ប៉ះពាល់ជាអវិជ្ជមានទៅលើលក្ខខណ្ឌ ដែលទឹកអាចយកបាន សម្រាប់រយៈពេលនៃផែនការ ប្រសិនបើក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក មិនផ្តល់ជូនអ្នកកាន់កាប់សិទ្ធិនូវសំណងដែលបានព្រមព្រៀងរួច ។

**មាត្រា៥៨៥** ._ ការកែសម្រួលទៅលើចំនួនកំណត់ធម្មតា

ចំនួនកំណត់ធម្មតា នៅចុងបញ្ចប់នៃជីវិតរបស់ផែនការធនធានទឹកអាងទន្លេ ដែលវាត្រូវបានគ្រប់គ្រងក្រោមផែនការនោះ ដោយគ្មានសំណងណាដែលអាចបង់ថ្លៃជូនបានឡើយ ។

**មាត្រា៥៨៦** ._ កិច្ចព្រមព្រៀងផ្គត់ផ្គង់សម្រាប់អាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធ

ប្រសិនបើសិទ្ធិទទួលបានទឹកទាក់ទងនឹងធនធានទឹកដែលត្រូវបានផ្តល់ជូនដោយហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបានគ្រប់គ្រងក្រោមអាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធ កិច្ចព្រមព្រៀងផ្គត់ផ្គង់ត្រូវមានរវាងអ្នកកាន់កាប់សិទ្ធិទទួលបានទឹក និងអ្នកកាន់កាប់អាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធ ប្រសិនបើពួកគេមិនមែនជានីតិបុគ្គលដូចគ្នានោះទេ ។

**មាត្រា៥៨៧** ._ កិច្ចព្រមព្រៀងផ្គត់ផ្គង់ស្តង់ដារ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវរៀបចំកិច្ចព្រមព្រៀងផ្គត់ផ្គង់ជាស្តង់ដារមួយសម្រាប់ការស្តុកទុក និង ឬការចែកចាយដោយអ្នកកាន់កាប់អាជ្ញាប័ណ្ណហេដ្ឋារចនា សម្ព័ន្ធទឹក ក្រោមសិទ្ធិទទួលបានទឹក ដែល៖

ក-ត្រូវដាក់ឲ្យសាធារណជនអាចរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន គន្ថីទី១ មាតិកាទី៣ នៃក្រមនេះ និង

ខ-អាចខុសគ្នាសម្រាប់ទីតាំងផ្សេងគ្នា ។

**មាត្រា៥៨៨** ._ ពាក្យសុំកិច្ចព្រមព្រៀងផ្គត់ផ្គង់ស្តង់ដារ

កិច្ចព្រមព្រៀងផ្គត់ផ្គង់ជាស្តង់ដារ ដូចមានចែងក្នុងមាត្រា៥៨៧ នៃក្រមនេះសម្រាប់ទីតាំងដែលសិទ្ធិទទួលបានទឹកពាក់ព័ន្ធ អនុវត្តចំពោះសិទ្ធិទទួលបានទឹក ប្រសិនបើកិច្ចព្រមព្រៀងផ្គត់ផ្គង់ដោយឡែកពីគ្នាមិនត្រូវបាន៖

ក-យល់ស្របរវាងអ្នកកាន់កាប់សិទ្ធិទទួលបានទឹក និង អ្នកកាន់កាប់អាជ្ញាប័ណ្ណហេដ្ឋារចនាសម្ព័ន្ធ ។

ខ-ដាក់បញ្ជូនទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ។

## ផ្នែកទី៤
## កិច្ចការពារទាក់ទងនឹងទន្លេ និងស្ទឹង

**មាត្រា៥៨៩ .**_ សកម្មភាពដែលទទួលបានការអនុញ្ញាត

រូបវន្តបុគ្គលអាចដាក់ពាក្យទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ដើម្បីទទួលបានលិខិតអនុញ្ញាតធ្វើសកម្មភាពដូចខាងក្រោម៖

ក-ការធ្វើកំណាយក្នុង ផ្លូវទឹក បឹង ដីសើម តំបន់ទំនាប ទឹកផុសក្រោមដី ឬអាងទឹក ។

ខ-ដាក់បំពេញក្នុង ផ្លូវទឹក បឹងធម្មជាតិ ដីសើម តំបន់ទំនាប ទឹកផុសក្រោមដី ឬ អាងទឹក ។

**មាត្រា៥៩០ .**_ នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ពាក្យសុំ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តនូវនីតិវិធី និងលក្ខខណ្ឌតម្រូវ សម្រាប់ការដាក់ពាក្យសុំលិខិតអនុញ្ញាតក្រោមផ្នែកនេះ ។

**មាត្រា៥៩១ .**_ ការជូនដំណឹងជាសាធារណ:

នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក យល់ថាមានព័ត៌មានគ្រប់គ្រាន់ដើម្បីសម្រេចចិត្តលើពាក្យសុំហើយនោះ ក្រសួងអាចចេញនូវការជូនដំណឹងជា សាធារណ: អំពីពាក្យសុំដែលលើកឡើងពី៖

ក-សេចក្តីលម្អិតនៃពាក្យសុំ ។

ខ-ទីកន្លែងដែលពាក្យសុំអាចត្រូវបានពិនិត្យ ។

គ-កាលបរិច្ឆេទ យ៉ាងហោចណាស់ ៣០(សាមសិប)ថ្ងៃបន្ទាប់ពីចេញនូវការជូនដំណឹងជាសាធារណ: ដែលការដាក់បញ្ជូនពាក្យសុំជាលាយលក្ខណ៍អក្សរ អាចធ្វើឡើងទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ។

**មាត្រា៥៩២ .**_ នីតិវិធី និងការពិចារណាសម្រាប់ការឯកភាព ឬបដិសេធ

នីតិវិធី និងការពិចារណាសម្រាប់កំណត់នូវការឯកភាព ឬការបដិសេធ ការដាក់ពាក្យសុំលិខិតអនុញ្ញាតក្រោមផ្នែកនេះ និងលក្ខខណ្ឌនៃលិខិតអនុញ្ញាតប្រសិនបើការដាក់ពាក្យត្រូវបានឯកភាព ត្រូវបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

## ផ្នែកទី៥
## អ្នកអភិវឌ្ឍទឹកក្រោមដី

**មាត្រា៥៩៣** ._ ការដាក់ពាក្យសុំវិញ្ញាបនបត្រ

រូបវន្តបុគ្គលអាចដាក់ពាក្យទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ដើម្បីទទួលបានវិញ្ញាបនបត្រ ៖

ក-អ្នកខួងអណ្តូងទឹក ។

ខ-អ្នកជីកអណ្តូងទឹក ។

គ-អ្នកតំឡើងម៉ាស៊ីនបូមទឹកក្រោមដី ។

**មាត្រា៥៩៤** ._ នីតិវិធីសម្រាប់ការដាក់ពាក្យសុំ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តនូវនីតិវិធីសម្រាប់ការដាក់ពាក្យសុំវិញ្ញាបនបត្រ ។

**មាត្រា៥៩៥** ._ នីតិវិធីសម្រាប់ការឯកភាព ឬបដិសេធ

នីតិវិធីសម្រាប់កំណត់ការឯកភាព ឬការបដិសេធទៅលើពាក្យសុំវិញ្ញាបនបត្រត្រូវកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា៥៩៦** ._ លក្ខខណ្ឌនៃវិញ្ញាបនបត្រ

លក្ខខណ្ឌនៃវិញ្ញាបនបត្រត្រូវកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា៥៩៧** ._ នីតិវិធីក្នុងការលុបវិញ្ញាបនបត្រ

នីតិវិធីក្នុងការលុបវិញ្ញាបនបត្រត្រូវកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា៥៩៨** ._ ភស្តុតាងនៃវិញ្ញាបនបត្រ

មន្ត្រីដែលផ្តល់នូវសិទ្ធិអំណាចអាចតម្រូវឲ្យរូបវន្តបុគ្គលផ្តល់នូវភស្តុតាងជាវិញ្ញាបនបត្រសម្រាប់ការធ្វើអធិការកិច្ច ប្រសិនបើមន្ត្រីសង្ស័យបុគ្គលនោះដោយមានហេតុផលថា៖

ក-ការខួង ការជីក ការធ្វើឲ្យជ្រៅ ការពង្រីក ឬការរៀបអណ្តូងទឹក ។

ខ-ការដកចេញ ការដាក់ជំនួស ការប្តូរ ឬការជួសជុល ការដាក់ទ្រនាប់ពីក្នុង ការបាំងអណ្តូង ។

គ-បញ្ឈប់ដំណើរការនៃអណ្តូងទឹក ។

ឃ-ការរៀប ការដាក់ជំនួស ការប្តូរ ឬការបិទអណ្តូងស្នប់ ។

**មាត្រា៥៩៩** ._ សកម្មភាពដែលត្រូវបានហាមឃាត់

ត្រូវហាមឃាត់ចំពោះ រាល់សកម្មភាពទាំងឡាយណាដែលពុំមានវិញ្ញាបនបត្រសម្រាប់ការធ្វើអធិការកិច្ច ។

**មាត្រា៦០០** ._ លក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍

បុគ្គលណាមួយធ្វើការងារទាក់ទងនឹងអណ្តូងគ្រប់ប្រភេទ សម្រាប់គោលដៅវិជ្ជាជីវៈ និងពាណិជ្ជកម្ម ត្រូវផ្តល់ដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក នូវរបាយការណ៍ការងារលម្អិត ។ ព័ត៌មានតម្រូវឲ្យរួមមានក្នុងរបាយការណ៍ ត្រូវកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា៦០១** ._ កំណត់ត្រាសកម្មភាព

អ្នកកាន់វិញ្ញាបនបត្រត្រូវរក្សាព័ត៌មានដែលមានបញ្ញត្តិក្រោមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធពីសកម្មភាពដែលអ្នកកាន់កាប់អនុវត្តក្រោមក្រមនេះ និងផ្តល់ព័ត៌មានទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ប្រសិនបើមានការស្នើសុំ ។

## ផ្នែកទី៦
## ការដកហូតការអនុញ្ញាត

**មាត្រា៦០២** ._ លក្ខខណ្ឌសម្រាប់ការដកហូតការអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនូវលក្ខខណ្ឌសម្រាប់ចាប់ផ្តើមនីតិវិធីដកហូតការអនុញ្ញាត ។

**មាត្រា៦០៣** ._ នីតិវិធីនៃការដកហូតការអនុញ្ញាត

នីតិវិធីដកហូតការអនុញ្ញាត ត្រូវកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

## ជំពូកទី៥
## ការតម្រូវឲ្យមានការអនុញ្ញាត

**មាត្រា៦០៤** ._ ការអនុញ្ញាតចំពោះការផ្គត់ផ្គង់ និងប្រើប្រាស់ទឹក

បុគ្គលម្នាក់មិនអាចយក ផ្គត់ផ្គង់ ឬប្រើប្រាស់ទឹក បានឡើយ ប្រសិនបើគ្មានការអនុញ្ញាតឲ្យធ្វើដូច្នេះទេ និងលើកលែងតែការអាចយក ការផ្គត់ផ្គង់ ឬការប្រើប្រាស់ទឹកនេះ ស្របតាមមាតិកានេះ ។

**មាត្រា៦០៥** ._ ការរំលោភបំពានទៅលើសិទ្ធិដែលបានអនុញ្ញាត

អ្នកកាន់កាប់នូវការអនុញ្ញាតក្រោមមាតិកានេះមិនត្រូវរំលោភបំពានលើលក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាតនោះទេ ។

**មាត្រា៦០៦** ._ ការចេញចូលបរិវេណដីឯកជន របស់មន្ត្រីមានសមត្ថកិច្ច

ម្ចាស់ ឬអ្នកគ្រប់គ្រងដីកម្មសិទ្ធិឯកជន មិនត្រូវបដិសេធនូវការចូលទៅកាន់ដីនោះពីសំណាក់មន្ត្រីដែលមានសមត្ថកិច្ចមកពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក និងដែលមានភារកិច្ចក្នុងការធ្វើការស្ទាបស្ទង់ផ្នែកបច្ចេកទេស ការវាយតម្លៃ ឬការអង្កេតតាមដានបញ្ហាទាក់ទងនឹងមាតិកានេះនោះទេ លើកលែងដូចករណីដូចខាងក្រោមនេះ ម្ចាស់ ឬអ្នកគ្រប់គ្រងដីឯកជនមានសិទ្ធិបដិសេធះ

ក-ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក មិនបានផ្តល់ជូនម្ចាស់ ឬអ្នកកាន់កាប់ដីនូវការជូនដំណឹងជាលាយលក្ខអក្សរជាមុន ។

ខ-មន្ត្រីមានសមត្ថកិច្ចមិនបានផ្តល់ភស្តុតាងពីអត្តសញ្ញាណ និងមិនមានលិខិតនៃការផ្តល់សិទ្ធិអំណាចពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ។

## ជំពូកទី៦
## ការរៀបចំអន្តរកាល

**មាត្រា៦០៧** ._ បញ្ជីសកម្មភាពអាទិភាពសម្រាប់រៀបចំផែនការធនធានទឹកអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវបង្កើតតារាងអនុវត្ត ដែលរួមមានបញ្ជីសកម្មភាពអាទិភាព សម្រាប់ការរៀបចំផែនការធនធានទឹកអាងទន្លេ ស្របតាមជំពូកទី៣ នៃមាតិកានេះ ក្នុងរយៈពេល០១ (មួយ)ឆ្នាំក្រោយការអនុម័តក្រមនេះ ។

**មាត្រា៦០៨ ._** ករណីលើកលែងចំពោះសិទ្ធិទទួលបានទឹក

មិនតម្រូវឲ្យមានសិទ្ធិទទួលបានទឹកសម្រាប់គោលដៅដូចខាងក្រោមៈក- ការស្រោចស្រពដីនៃតំបន់ទាំងមូលដែលតិចជាង១០(ដប់)ហិកតា ។

ខ- ការផ្គត់ផ្គង់ទឹកស្អាត ដែលទឹកត្រូវបានប្រើតិចជាង៤០(សែសិប)ម៉ែត្រគីប ក្នុងមួយថ្ងៃ ។

គ- ថាមពលវារីអគ្គិសនីដើរដោយលំហូរទឹកទន្លេ ឬ បច្ចេកទេសថាមពលវារីអគ្គិសនីដែលមិនតម្រូវឲ្យមានការបង្ខាំង ការបង្វែរ ឬការទាញយកទឹក ។

**មាត្រា៦០៩ ._** ការអនុលោមតាមរបស់នីតិបុគ្គល

នីតិបុគ្គលដែលកំពុងធ្វើសកម្មភាពក្រោមជំពូកទី៤ នៃមាតិកានេះដោយគ្មានការផ្តល់សិទ្ធិអំណាចជាមុនពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ឬមន្ទីរទទួលបន្ទុកវិស័យធនធានទឹក ត្រូវធ្វើសកម្មភាពឲ្យអនុលោមតាមជំពូកទី៤ នៃមាតិកានេះ ក្នុងរយៈពេល ៦(ប្រាំមួយ)ខែ នៃការអនុម័តក្រមនេះ ។

**មាត្រា៦១០ ._** ការកំណត់អំពីច្រាំងទន្លេ ឬឆ្នេរសមុទ្រ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីរង្វាស់ដែលត្រូវប្រើដើម្បីកំណត់អំពីច្រាំងទន្លេ និងឆ្នេរសមុទ្រ នៃទ្រង់ទ្រាយ និងសមាសធាតុនៃអាងទន្លេ ។

## មាតិកាទី៩
## និរន្តរភាពជលផល
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៦១១ ._** វិសាលភាពនៃការអនុវត្ត

មាតិកានេះមានវិសាលភាពអនុវត្តចំពោះ ក្របខ័ណ្ឌស្តីពីនិរន្តរភាពនៃការគ្រប់គ្រងធនធានជលផលទឹកសាប និងសមុទ្រ និងធនធានជលផលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៦១២ ._** ក្របខ័ណ្ឌនៃការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព

ការគ្រប់គ្រងធនធានជលផលក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវៈ

ក- ដាក់បញ្ចូលនូវគោលបំណងនិងគោលការណ៍ស្តីពីការការអភិរក្សបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

ខ- ដាក់បញ្ចូលនូវលក្ខខណ្ឌតម្រូវស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ នៅក្នុង គន្ថីទី១ មាតិកាទី២ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

គ- គ្រប់គ្រង និងកាត់បន្ថយហានិភ័យ និងផលវិបាកផ្នែកបរិស្ថាន នៃការអភិវឌ្ឍវារីវប្បកម្ម ។

**មាត្រា៦១៣**._ ធនធានដែលពាក់ព័ន្ធ

មាតិកានេះមានវិសាលភាពអនុវត្តចំពោះ រដ្ឋបាលកិច្ចលើជលផល និងធនធានជលផលទឹកសាប និងសមុទ្រនិងការគ្រប់គ្រងធនធានជលផលក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានជាអាទិ៍៖

ក-ការអនុវត្ត និងការបកស្រាយ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងជលផល និងធនធានជលផល ឲ្យស្របទៅនឹងច្បាប់ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ ។

ខ-ការអនុវត្តនូវ និងការកែសម្រួលទៅលើ ក្របខ័ណ្ឌនៃការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ជលផល និងធនធានជលផល ដោយយោងទៅលើក្រមប្រតិបត្តិសម្រាប់ការទទួលខុសត្រូវជលផលរបស់ព្រះរាជាណាចក្រកម្ពុជា

គ-រដ្ឋបាលជលផល និងសកម្មភាពគ្រប់គ្រងធនធានជលផល ដែលធ្វើឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យជលផល ក្រសួង ស្ថាប័ន មានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធដទៃទៀត ។

នៅក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យ មានសមត្ថកិច្ច កាតព្វកិច្ច និងតួនាទី និងការទទួលខុសត្រូវរួមគ្នា ទាក់ទងនឹងធនធានមួយចំនួន ឬតំបន់គ្រប់គ្រងភូមិសាស្ត្រ និងរដ្ឋបាល ដែលមានធនធានជលផល នោះក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នទទួលពន្ទុកវិស័យជលផលត្រូវសហការគ្នាដើម្បី គ្រប់គ្រងធនធានជលផល និងតំបន់គ្រប់គ្រងភូមិសាស្ត្រ និងរដ្ឋបាលទាំងនោះ ក្នុងលក្ខណៈប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ។

**មាត្រា៦១៤**._ ការអភិរក្ស និងវិធានការគ្រប់គ្រងធនធានជលផល

ក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវបង្កើត និងអនុវត្ត វិធានការអភិរក្ស និងគ្រប់គ្រង ដើម្បីទប់ស្កាត់ការនេសាទលើសកម្រិត និងការនេសាទក្នុងលក្ខណៈបំផ្លាញសម្រាប់សន្និធិជលផល ឬ សន្និធិ

ចម្រុះ និងដើម្បីធានានូវសន្តិសុខស្បៀង ចំណូល និងការងារ ។ វិធានការគ្រប់គ្រងធនធានជលផល នោះត្រូវ៖

ក-ផ្អែកលើភស្តុតាងបែបវិទ្យាសាស្ត្រល្អបំផុតដែលមាន ។

ខ-គាំទ្រដោយការស្រាវជ្រាវបែបវិទ្យាសាស្ត្រដែលកំពុងបន្ត និងការប្រមូលទិន្នន័យ ។

## ជំពូកទី២
## និរន្តរភាពនៃការគ្រប់គ្រងជលផលទឹកសាប និងសមុទ្រ

**មាត្រា៦១៥**._ លិខិតបទដ្ឋានគតិយុត្តស្ដីពីជលផលទឹកសាប

ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីគាំទ្រទៅដល់ការអភិរក្ស និងការគ្រប់គ្រងជលផលទឹកសាបប្រកបដោយនិរន្តរភាព ដែលរួមមាន ៖

ក-សហគមន៍ជលផល ជលផលស្រែ ត្រពាំងវាលភក់ល្បាប់ត្រីសហគមន៍ ការគ្រប់គ្រងសហគមន៍ជលផល និងការចែករំលែកផលប្រយោជន៍សហគមន៍ ដែលរួមមាន ការធ្វើសមាហរណកម្មទៅតាមបទប្បញ្ញត្តិស្ដីពីការគ្រប់គ្រងរួមគ្នា នៅក្នុងគន្ថីទី៤ មាតិកាទី៣ នៃក្រមនេះ ។

ខ-ដាក់បញ្ចូលនូវទិន្នន័យស្ដីពីធនធានទឹក គុណភាពនិងលំហូរទឹក ការបោះបង់ចោលស្តុក ជីវៈចម្រុះ និងកត្តាពាក់ព័ន្ធបរិស្ថានដទៃទៀត ទៅក្នុងរដ្ឋបាលកិច្ច និងការគ្រប់គ្រងធនធានជលផល ។

គ-យុទ្ធសាស្ត្រ និងឧបករណ៍គ្រប់គ្រង ដើម្បីអភិរក្សជីវៈចម្រុះ ដែលរួមមាន ប្រភេទសត្វ រុក្ខជាតិ ដែលមិនមែនជាគោលដៅ ទីជម្រកមច្ឆា ដែលរួមមានជាអាទិ៍ វាលទំនាបដែលលិចទឹកនៅរដូវជំនឿង បឹង អន្លង់ ថ្មខ្សាច់នៅបាតផ្លូវទឹកហូរ ព្រៃលិចទឹក សារពើរុក្ខជាតិ ផ្នែកនៅតាមមាត់ទន្លេ និងប្រព័ន្ធអេកូឡូស៊ី ។

ឃ-ការធ្វើផែនទី និងការអង្កេតតាមដានធនធានជលផល ដែលរួមមាន ទីជម្រកចាំបាច់ ផលិតកម្មជលផល លក្ខខណ្ឌតម្រូវនៃលំហូរជលវិទ្យា និងតំបន់ផ្នែកនៅតាមមាត់ស្ទឹង បឹងសំខាន់ ជាអាទិ៍ ។

ង-ការផ្ដល់ជូននូវព័ត៌មានជលផល ដែលរួមមាន ដូចបានកំណត់នៅក្នុងអនុផ្នែក ឃ. នៃមាត្រានេះទៅឱ្យក្រសួង ស្ថាប័នដែលទទួលបន្ទុកលើការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សបរិស្ថាន ជាអាទិ៍ ។

ច-សកម្មភាពដែលត្រូវបានហាមឃាត់ក្នុងជលផលទឹកសាប ដែលរួមមាន ការហាមឃាត់ការប្រមូលផល និងការដាក់ចុះនូវប្រភេទសត្វ រុក្ខជាតិ ដែលត្រូវបានចុះក្នុងបញ្ជីជាតិ និងអន្តរជាតិ ថាកំពុងរងគ្រោះថ្នាក់ និងទទួលរងគ្រោះថ្នាក់ ។

ឆ-ប្រភេទឧបករណ៍នេសាទ ដែលត្រូវបានហាមឃាត់ក្នុងការលក់ កាន់កាប់ ឬប្រើប្រាស់ក្នុងជលផលទឹកសាប ។

ជ-ទាក់ទិននឹងផលស្តុកធនធានជលផលបំលាស់ទី កិច្ចសហការជាមួយ រដ្ឋដែលជាប់ច្រាំងទន្លេ ជាពិសេសរដ្ឋទាំងឡាយណានៅតាមបណ្តោយទន្លេមេគង្គ ដោយផ្ទាល់ក្តី ឬប្រយោលក្តី ឬ តាមរយៈស្ថាប័នថ្នាក់តំបន់ ឬ អន្តរជាតិ ដោយមានទស្សនៈក្នុងការធានានូវការអភិរក្ស និងការលើកកម្ពស់សមិទ្ធិផលទិន្នផលប្រកបដោយនិរន្តរភាព នៃប្រភេទសត្វ រុក្ខជាតិទាំងនោះពាសពេញតំបន់របស់ពួកគេ ។

ឈ-លក្ខណៈវិនិច្ឆ័យសម្រាប់ការអភិរក្ស និងការស្តារឡើងវិញនៃជម្រកជលផលទឹកដែលរួមមានការគ្រប់គ្រងការបំពុល និងការថែរក្សាតំណភ្ជាប់រវាងទីជម្រកមច្ឆា ជាអាទិ៍។

ញ-ការអង្កេតតាមដានទៅលើផលប៉ះពាល់មកពីហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក ដែលរួមមាន ចរាចរមច្ឆាជាតិ ដំណើរចាក់គរកករ និងសីតុណ្ហភាពទឹក ។

ដ-អង្កេតតាមដានពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ទៅលើធនធានជលផល ។

ឋ-វិធីសាស្ត្រសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃឧបករណ៍នេសាទថ្មី និងវិធីសាស្ត្រ មុននឹងអនុញ្ញាត ឬហាមឃាត់ការប្រើប្រាស់ទាំងនោះ ។

**មាត្រា៦១៦** ._ លិខិតបទដ្ឋានគតិយុត្តស្តីពីជលផលសមុទ្រ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបង្កើត លិខិតបទដ្ឋានគតិយុត្ត ដើម្បីគាំទ្រនូវការអភិរក្ស និងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃជលផលសមុទ្រ ដែលរួមមាន ដូចខាងក្រោម៖

ក-និយ័តកម្ម និងកម្រិតទៅលើការទទួលបានធនធានជលផលសមុទ្រក្នុងទឹក ក្រោមសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ដោយកប៉ាល់ ដែលមានសញ្ជាតិខ្មែរ និងបរទេស តាមរយៈការធ្វើកំណត់ត្រា និងការផ្តល់អាជ្ញាប័ណ្ណជលយាន និងការបង្កើតកិច្ចព្រមព្រៀងការទទួលបានការនេសាទ និងការពង្រឹងការអនុវត្ត ។

ខ-ការប្រមូលទិន្នន័យស្តីពីកិច្ចខិតខំប្រឹងប្រែងផ្នែកជលផលសមុទ្រ ការចាប់ និងការដាក់ចុះ ដែលធ្វើឡើងដោយរូបវន្តបុគ្គល និងនីតិបុគ្គល ដែលប្រមូលផលធនធានធម្មជាតិ ឬទិញធនធានជលផល ដែលប្រមូលបានពីជលផលសមុទ្ររបស់ព្រះរាជាណាចក្រកម្ពុជា ។

គ-ការការពារពីសកម្មភាពនេសាទដែលប៉ះពាល់ជាអវិជ្ជមានទៅលើតំណភ្ជាប់នៃជម្រកបាតសមុទ្រសំខាន់ៗ ដែលរួមមានព្រៃកោងកាង ស្មៅសមុទ្រ និងផ្កាថ្ម ជាអាទិ៍។

ឃ-ការការពារពីសកម្មភាពនេសាទ និងមិនមែននេសាទ ដូចជា ការចាក់បំពេញដី ដំណើរចាក់គរកករ ការបោះចោលសំណល់ និងការប្រើអួន ។

ង-ការបង្កើត និងការគ្រប់គ្រង តំបន់គ្រប់គ្រងជលផលសមុទ្រ ដើម្បីធ្វើនិយ័តកម្មទៅលើសកម្មភាពនេសាទ និងការពារទីជម្រក ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ ។

ច-ការគ្រប់គ្រងសហគមន៍ជលផល និងតំបន់សហគមន៍នេសាទ និងការចែករំលែកផលប្រយោជន៍សហគមន៍ ។

ឆ-ទាក់ទិននឹងផលស្តុកធនធានជលផលបំលាស់ទី កិច្ចសហប្រតិបត្តិការផ្ទាល់ ឬតាមរយៈស្ថាប័នកម្រិតតំបន់ ឬអន្តរជាតិពាក់ព័ន្ធ ជាមួយនឹងរដ្ឋពាក់ព័ន្ធដែលមានទស្សនៈក្នុងការធានានូវការអភិរក្ស និងការលើកកម្ពស់សមិទ្ធផលនៃទិន្នផលប្រកបដោយនិរន្តរភាពនៃប្រភេទសត្វ រុក្ខជាតិទាំងនោះពាសពេញប្រភេទរបស់ពួកគេ ។

ជ-សកម្មភាពដែលត្រូវបានហាមឃាត់ក្នុងជលផលសមុទ្រ ដែលរួមមាន ការហាមឃាត់ការប្រមូលផល ការទិញ ការធ្វើជាកម្មសិទ្ធិ ផៃ និងការផ្តល់ជូន ដើម្បីលក់ប្រភេទសត្វ រុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ និងត្រូវទទួលរងគ្រោះថ្នាក់ស្របតាមច្បាប់ជាតិ និងអន្តរជាតិ ឬតារាង ប្រភេទសត្វ រុក្ខជាតិទាំងនោះ ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ។

ឈ-ប្រភេទឧបករណ៍នេសាទ ដែលត្រូវបានហាមឃាត់ក្នុងការលក់ ធ្វើជាកម្មសិទ្ធិ ឬប្រើប្រាស់ក្នុងជលផលសមុទ្រ ។

ញ-ការនាំចូលមកព្រះរាជាណាចក្រកម្ពុជានូវធនធានជលផលសមុទ្រ ដែលរួមមានការតម្រូវឲ្យអ្នកនាំចូលបញ្ជាក់ថាធនធានបែបនោះត្រូវបានប្រមូលផល ស្របតាមច្បាប់ជលផលនៃប្រទេសដែលជាអ្នកប្រមូលផលផ្ទាល់ ។

ដ-ការគ្រប់គ្រង សមត្ថភាពនេសាទ តាមរយៈការត្រួតពិនិត្យ ការអង្កេតតាមដាន និងការឃ្លាំមើល ។

ឋ-ទប់ស្កាត់ការនេសាទខុសច្បាប់ មិនបានរាយការណ៍ និងមិនបានធ្វើនិយ័តកម្ម ។

ឍ-ការកម្រិតអនុផលជលផលនៃប្រភេទសត្វ រុក្ខជាតិដែលមិនមែនជាគោលដៅ ដែលរួមមាន សត្វស្លាបសមុទ្រ ថនិកសត្វសមុទ្រ អណ្តើកសមុទ្រ ដែលរួមមាន តាមរយៈការប្រើប្រាស់ឧបករណ៍ញែកចេញនូវអនុផលនេសាទ និងកម្មវិធីអ្នកសង្កេតការណ៍ ។

ធ-ការស្រាវជ្រាវជលផលសមុទ្រ ។

**មាត្រា៦១៧** ._ ផែនការគ្រប់គ្រងជលផលសមុទ្រ

ដោយសហការជាមួយ អាជ្ញាធរថ្នាក់ក្រោមជាតិ ពាក់ព័ន្ធ សហគមន៍ សហគមន៍ជលផល ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតផែនការគ្រប់គ្រងជលផលសមុទ្រ ដោយផ្តោតលើប្រភេទសត្វ រុក្ខជាតិជាក់លាក់ ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រដ៏ប្រសើរបំផុត ដែលមានស្រាប់ និងចំណេះដឹងមូលដ្ឋាន ។ ផែនការគ្រប់គ្រងជលផលសមុទ្រ ត្រូវរួមមានដាក់បញ្ចូលនូវបញ្ហា ដូចខាងក្រោម៖

ក-រដូវ និងតំបន់បិទការធ្វើសកម្មភាព ។

ខ-សេចក្តីលម្អិតនៃជលផលពាក់ព័ន្ធ ដែលរួមមានចំនួននៃកប៉ាល់ដែលពាក់ព័ន្ធ ប្រភេទ និងបរិមាណ នៃឧបករណ៍នេសាទដែលត្រូវប្រើប្រាស់ ប្រភេទសត្វ រុក្ខជាតិក្នុងសមុទ្រ ដែលត្រូវប្រមូលផល តំបន់ហាមឃាត់ និងចម្ងាយភូមិសាស្ត្រនៃជលផល ។

គ-ការប្រមាណនៃផលប្រកបដោយនិរន្តរភាពពីជលផល និងលក្ខខណ្ឌដែលអាចកើតមានរបស់វា ដែលរួមមាន សេចក្តីសង្ខេបព័ត៌មានដែលត្រូវបានប្រើប្រាស់ក្នុងការបង្កើតការកំណត់នេះ ជាអាទិ៍។

ឃ-ការពិពណ៌នាអំពីវិធានការអភិរក្ស និងគ្រប់គ្រង ដែលត្រូវបានអនុវត្តចំពោះជលផល ដើម្បីកាត់បន្ថយការនេសាទហួសកំណត់ និងការនេសាទបំផ្លាញ មានជាអាទិ៍អួន ។

ង-ដំណើការសម្រាប់អង្កេតតាមដាន និងការពិនិត្យជាថ្មីទៅលើផែនការគ្រប់គ្រងជលផលសមុទ្រមួយៗ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិពាក់ព័ន្ធ សហគមន៍ និងសហគមន៍ជលផល ។

**មាត្រា៦១៨** ._ វិធានការអភិរក្ស និងការគ្រប់គ្រងជលផលសមុទ្រ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាចបង្កើត ក្នុងលិខិតបទដ្ឋានគតិយុត្តនូវវិធានការអភិរក្ស និងគ្រប់គ្រង ដើម្បីធានានូវនិរន្តរភាព នៃធនធានជលផលសមុទ្រ៖

ក-កម្រិត និងកូតាមួយៗប្រចាំថ្ងៃ ក្នុងរយៈពេលយូរ សម្រាប់ប្រភេទសត្វ រុក្ខជាតិសមុទ្រជាក់លាក់ ។

ខ-កម្រិតទំហំ និងទម្ងន់អប្បបរមា និងអតិបរមាសម្រាប់ប្រភេទសត្វ រុក្ខជាតិសមុទ្រក្រោម ឬលើ ក្នុងករណីដែលមិនត្រូវបានអនុញ្ញាតឲ្យមានការប្រមូលផល ។

គ-ប្រព័ន្ធចូលដែលកម្រិតរួច ទាក់ទងនឹងការប្រមូលផលធនធានជលផលសមុទ្រជាក់លាក់  សន្និធិ ឬសន្និធិចម្រុះ ឬ ទាក់ទងនឹងតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ។

ឃ-ការបិទតាមរដូវកាលនូវធនធានជលផលជាក់លាក់ណាមួយ សន្និធិ សន្និធិចម្រុះ ឬ ទាក់ទងនឹងតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ។

ង-ការបិទតំបន់ជាអចិន្ត្រៃយ៍ ឬបណ្ដោះអាសន្នសម្រាប់ការប្រមូលផលធនធានជលផលសមុទ្រជាក់លាក់ សន្និធិ ឬសន្និធិស្មុគស្មាញ ឬ ទាក់ទងនឹងតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ។

ច-ការកម្រិតទៅលើប្រភេទ ទំហំ និងចំនួនឧបករណ៍ ដែលត្រូវបានប្រើប្រាស់សម្រាប់ការប្រមូលផលធនធានជលផលសមុទ្រជាក់លាក់ ឬ ការប្រើប្រាស់របស់ពួកគេទាក់ទងនឹងតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ។

**មាត្រា៦១៩ ._** របាយការណ៍ប្រចាំឆ្នាំស្ដីពីជលផលសមុទ្រ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំស្ដីពីសភាពនៃធនធានជលផល សមុទ្រ ដោយយោងលើ ផ្កាថ្ម ថ្មាលស្មៅសមុទ្រ ព្រៃកោងកាង និងវិភាគលើតំណភ្ជាប់ទៅកាន់ការប្រែប្រួលអាកាសធាតុ ស្របតាមបទប្បញ្ញត្តិស្ដីពីសិទ្ធិទទួលបានព័ត៌មាននៃក្រមនេះ ។

## ជំពូកទី៣
## វារីវប្បកម្ម

**មាត្រា៦២០ ._** យុទ្ធសាស្ត្រវារីវប្បកម្មជាតិ

ការបង្កើតនូវ និងការកែសម្រួលទៅលើ យុទ្ធសាស្ត្រវារីវប្បកម្មថ្នាក់ជាតិ នៅក្នុងផែនការ និងគោលនយោបាយរបស់ ដែលបង្កើតឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យជលផល ត្រូវពិចារណាទៅលើបញ្ហាដូចខាងក្រោម៖

ក-ភាពជិតបំផុតនៃ និងអន្តរសកម្មភាពជាមួយតំបន់ ដែលមានប្រព័ន្ធអេកូឡូស៊ីសំខាន់ ឬតម្លៃអភិរក្សខ្ពស់ ។

ខ-គុណភាពទឹកនៅជុំវិញ គោលបំណងគុណភាពទឹក និងការរៀបចំការគ្រប់គ្រង និងការរៀបចំការគ្រប់គ្រងធនធានទឹក ។

គ-ការប្រើប្រាស់ទឹកផ្សេងទៀតដែលអាចត្រូវប៉ះពាល់ដោយវារីវប្បកម្ម និងសហគមន៍មូលដ្ឋាន ។

**មាត្រា៦២១ ._** វិធានការចៀសវាង និងកាត់បន្ថយ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាចបង្កើតវិធានការដើម្បីចៀសវាង ឬកាត់បន្ថយ ហេតុប៉ះពាល់បរិស្ថាន នៃវារីវប្បកម្ម ដែលរួមមាន ដូចខាងក្រោម៖

ក-ធានានូវការអនុវត្ត ទម្លាប់វារីវប្បកម្មល្អ និងវិធានការជីវៈសន្តិសុខ ។

ខ-ប្រភេទ វិធីសាស្ត្រ និងតំបន់វារីវប្បកម្មដែលអនុញ្ញាតរួច ។

គ-លក្ខខណ្ឌតម្រូវនៃការអង្កេតតាមដាន និងការរៀបចំរបាយការណ៍បរិស្ថាន ។

ឃ-ការប្រើប្រាស់សន្និធិកែច្នៃហៃ្សន ប្រភេទសត្វ រុក្ខជាតិក្រៅប្រទេស ប្រភេទសត្វ រុក្ខជាតិក្នុងស្រុក មច្ឆាជាតិតូចៗ និងចំណីអាហារកែច្នៃហៃ្សន ។

ង-នីតិវិធីសម្រាប់ការជ្រើសរើសកន្លែងសម្រាប់ត្រីមេពូជជ្រក និងផលិតកម្ម ពង កូនញាស់ និងកូនត្រី ដើម្បីចៀសវាង និងកាត់បន្ថយហានិភ័យចំពោះ ប្រព័ន្ធអេកូឡូស៊ីជលផល ។

ច-ការប្រើប្រាស់ការព្យាបាលរោគ អរម៉ូន ថ្នាំផ្សះ និងគីមី ឬវិធីសាស្ត្រត្រួតពិនិត្យជំងឺ ។

ឆ-ស្តង់ដារនៃការផ្តល់វិញ្ញាបណ្ណបត្រសម្រាប់ប្រតិបត្តិការវារីវប្បកម្ម ត្រី ផលិតផលត្រីដែលរួមមាន ប្រភព និងគុណភាពចំណី ។

ជ-លិខិតបទដ្ឋានគតិយុត្តនៃភាពអាចណែនាំបាន ដើម្បីធ្វើឲ្យប្រសើរឡើងនូវកាកំណត់អត្តសញ្ញាណត្រី និងប្រភពដើមនៃផលិតផលជលផល ។

## គន្ថីទី៥
## ការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌
## មាតិកាទោល
## ការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៦២២** ._វិសាលភាពអនុវត្តសម្រាប់បេតិកភណ្ឌវប្បធម៌

មាតិកានេះអនុវត្តចំពោះបេតិកភណ្ឌវប្បធម៌រូបិយ និងអរូបិយ នៃព្រះរាជាណាចក្រកម្ពុជា រួមមាន បេតិកភណ្ឌបុរេប្រវត្តិសាស្ត្រ មុនសម័យអង្គរ សម័យអង្គរ ក្រោយសម័យអង្គរ សម័យអាណានិគមនិយម និងសម័យទំនើប ជាអាទិ៍ ។ បេតិកភណ្ឌវប្បធម៌នៃព្រះរាជាណាចក្រកម្ពុជា រួមមានចំណុចដូចខាងក្រោមនេះ ៖

ក- បូជនីយដ្ឋាន៖ ស្នាដៃស្ថាបត្យកម្ម ស្នាដៃគំនូរនិងចម្លាក់ ធាតុ ឬ រចនាសម្ព័ន្ធដែលមានលក្ខណៈបុរាណសាស្ត្រ ចម្លាក់អក្សរ លំនៅដ្ឋានរូងថ្ម និងបន្សំនៃទ្រង់ទ្រាយនានា ដែលមានតម្លៃកម្រិតមូលដ្ឋាន កម្រិតខេត្ត ឬ កម្រិតជាតិ ទៅតាមទស្សនៈនៃប្រវត្តិសាស្ត្រ សិល្បៈ ឬ វិទ្យាសាស្ត

ខ- បណ្តុំនៃសំណង់៖ ជាបណ្តុំនៃសំណង់តភ្ជាប់ ឬ ដាច់ដោយឡែកពីគ្នា ដែលមានតម្លៃកម្រិតមូលដ្ឋាន កម្រិតខេត្ត ឬ កម្រិតជាតិ ទៅតាមទស្សនៈនៃប្រវត្តិសាស្ត្រ សិល្បៈ ឬ វិទ្យា

សាស្ត្រ ដោយសារស្នាដៃស្ថាបត្យកម្ម ឯកសណ្ឋានភាព ឬ ទីកន្លែងរបស់វានៅក្នុងតំបន់ទេសភាព

គ- ទីស្ថាន ឬទីតាំង ៖ ជាស្នាដៃរបស់មនុស្ស ស្នាដៃរួមគ្នារបស់មនុស្ស និងធម្មជាតិ និងតំបន់នានា រួមមាន បុរាណស្ថាន ដែលមានតម្លៃកម្រិតមូលដ្ឋាន កម្រិតខេត្ត ឬ កម្រិតជាតិ ទៅតាមទស្សនៈប្រវត្តិសាស្ត្រ សោភ័ណ្ឌភាព ជាតិពន្ធុវិទ្យា និងទស្សនៈនរវិទ្យា និង

ឃ- វត្ថុដទៃទៀត ដែលមានចរិតរូបិយ ឬ អរូបិយ ដែលមានតម្លៃមូលដ្ឋាន កម្រិតខេត្ត ឬ កម្រិតជាតិ ទៅតាមទស្សនៈប្រវត្តិសាស្ត្រ សោភ័ណ្ឌភាព ជាតិពន្ធុវិទ្យា និងទស្សនៈនរវិទ្យា ។

**មាត្រា៦២៣**._ តម្លៃបេតិកភណ្ឌវប្បធម៌

តម្លៃបេតិកភណ្ឌវប្បធម៌ អាចវាស់វែងបានតាមរយៈចំណុចដូចខាងក្រោម ៖

ក- ការកំណត់ចំនួនឆ្នាំ អាយុកាលនៃសម្បត្តិវប្បធម៌នោះ ឬ ដោយផ្អែកតាមសម័យកាល ។

ខ- ការបង្កើតថ្មីដែលមានតម្លៃចំពោះសង្គម ។

គ- សម្បត្តិវប្បធម៌ដែលមានតម្លៃយ៉ាងពិសេសសម្រាប់ជាតិ ដែលរួមមាន សម្បត្តិវប្បធម៌ដែលមានតម្លៃពិសេសចំពោះខេត្ត សហគមន៍មូលដ្ឋាន ឬ ជនជាតិដើមភាគតិច ជាអាទិ៍ ។

ឃ- ចលនានៃស្ថាបត្យកម្ម ដែលឆ្លុះបញ្ចាំងអំពីអត្តសញ្ញាណជាតិ និង

ង- ស្នាដៃស្ថាបត្យកម្ម ដែលមានឥទ្ធិពលដល់មនុស្សជំនាន់ក្រោយ ។

**មាត្រា៦២៤**._ ការហាមឃាត់នូវបង្កផលប៉ះពាល់ដល់បេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នមានសមត្ថកិច្ច មិនត្រូវធ្វើសកម្មភាព ឬ ផ្តល់លិខិតអនុញ្ញាត ឬ ការឯកភាពណាមួយ ដែលបង្ក ឬទំនងជានឹងបង្កឱ្យមានផលប៉ះពាល់ដល់តម្លៃបេតិកភណ្ឌវប្បធម៌ ឬ វត្ថុ ឬ ទីកន្លែងណាមួយដូចមាន ចែងនៅក្នុងគន្ថីនេះឡើយ លើកលែងតែធ្វើឡើងស្របតាមលិខិតអនុញ្ញាត ឬការឯកភាព ដែលត្រូវបានផ្តល់ឲ្យដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ។

## ជំពូកទី២
## ការទទួលខុសត្រូវសម្រាប់កិច្ចការពារបេតិកភណ្ឌវប្បធម៌
## ផ្នែកទី១
## ក្រសួង ស្ថាប័នមានសមត្ថកិច្ចដែលមានស្រាប់

**មាត្រា៦២៥ ._** ការទទួលខុសត្រូវរបស់ស្ថាប័នមានសមត្ថកិច្ចដែលមានស្រាប់

ស្ថាប័ន ឬ អាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវបានបង្កើតឡើងសម្រាប់គោលបំណងនៃការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ត្រូវអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនដែលមានស្រាប់ ស្របតាមលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ លើកលែងតែមានបទប្បញ្ញត្តិពិសេសដែលមានចែងក្នុងក្រមនេះ ។

**មាត្រា៦២៦ ._** ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយ និងចាត់វិធានការ ក្នុងការការពារបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦២៧ ._** កិច្ចសហការរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្ដីពីតួនាទី និងការទទួលខុសត្រូវ សម្រាប់កិច្ចសហការរវាងក្រសួង ស្ថាប័ន ពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ និងនីតិបុគ្គលនានា ក្នុងការគ្រប់គ្រងសម្បត្តិបេតិកភណ្ឌវប្បធម៌ ។

## ផ្នែកទី២
## ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

**មាត្រា៦២៨ ._** ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវមានដំណើរការឡើងវិញ និងត្រូវមានការទទួលខុសត្រូវ ដូចខាងក្រោម៖

ក- កំណត់អត្តសញ្ញាណ ការពារ ថែរក្សា ធ្វើកំណត់ត្រា និងលើកកម្ពស់កិច្ចការពារបេតិកភណ្ឌវប្បធម៌ សម្រាប់ជំនាន់បច្ចុប្បន្ន និងអនាគត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ- បង្កើតគោលនយោបាយស្ដីពីកិច្ចការពារ និងលើកស្ទួយបេតិកភណ្ឌវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា ។

គ- បង្កើត និងរៀបចំផែនការយុទ្ធសាស្ត្រ និង ផែនការសកម្មភាព ដើម្បីការពារ លើកស្ទួយ និងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ។

ឃ- ការពារទ្រព្យសម្បត្តិវប្បធម៌ បុរេប្រវត្តិសាស្ត្រ និងប្រវត្តិសាស្ត្រ និងវត្ថុបុរាណនៃធម្មជាតិរូបសាស្ត្រ ។

ង- គ្រប់គ្រង និងត្រួតពិនិត្យតំបន់នានា នៅទីកន្លែងណាដែលវិមាន/បូជនីយដ្ឋាន ដែលបានចុះបញ្ជីរួចស្ថិតនៅ រួមជាមួយការប្រមូលផ្តុំនៃវត្ថុសិល្បៈនានា ដែលមានការទាក់ទងទៅនឹងវិមាន ឬបូជនីយដ្ឋានទាំងនេះ ។

ច - ផ្តល់ការអនុញ្ញាតសម្រាប់ការស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យាទាំងអស់ ការងារអភិរក្ស និងសកម្មភាពដទៃទៀត ដែលទាក់ទងទៅនឹងទីតាំងបូជនីយដ្ឋាន និងទ្រព្យសម្បត្តិវប្បធម៌របស់ជាតិ ។

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវជួបប្រជុំជាទៀងរាល់៦(ប្រាំមួយ)ខែម្តង ដើម្បីតាមដានការអនុវត្ត មានប្រសិទ្ធភាពដើម្បីឆ្លើយតបទៅនឹងការពារបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦២៩** ._ សមាជិកនៃក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវមានសមាជិកដូចខាងក្រោម៖

ក- តំណាងនាយករដ្ឋមន្ត្រី ជាប្រធាន ។

ខ- តំណាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ជាអនុប្រធាន ។

គ- តំណាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ជាសមាជិក ។

ឃ- តំណាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យឧស្សាហកម្ម និងសិប្បកម្ម ជាសមាជិក ។

ង- តំណាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិក ។

ច- តំណាងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកផ្នែកបេតិកភណ្ឌពិភពលោក ជាសមាជិក ។

ឆ- តំណាងអភិបាលរាជធានីភ្នំពេញ ជាសមាជិក ។

ជ- តំណាង២(ពីរ)រូប នៃអង្គការមិនមែនរដ្ឋាភិបាល ដែលមានការពាក់ព័ន្ធនឹងការការពារ និងការអភិរក្សបេតិកភណ្ឌ ជាសមាជិក ។

ឈ- អ្នកមានជំនាញផ្នែកបច្ចេកទេសចំនួន២(ពីរ) រូប ដែលមានគុណសម្បត្តិ និងជំនាញផ្នែកបេតិកភណ្ឌ ជាសមាជិក ។

ង- តំណាងក្រសួង ស្ថាប័ន ឬ នីតិបុគ្គលដទៃទៀត ដែលមានការងារពាក់ព័ន្ធនឹងវិស័យបេតិកភណ្ឌវប្បធម៌ ដែលក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌អាចជ្រើសរើសតាមការចាំបាច់ ។

**មាត្រា៦៣០** ._ នីតិវិធីនៃការប្រជុំរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវកំណត់នីតិវិធីនៃការប្រជុំរបស់ខ្លួន ដោយមានការឯកភាពពីក្រសួង ឬ ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ និងស្របតាមទម្លាប់អនុវត្តល្អបំផុតជាអន្តរជាតិ ។

**មាត្រា៦៣១** ._ កិច្ចសហការរវាងក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ និងនីតិបុគ្គលដទៃទៀត ក្នុងការៈ

ក- បង្កើតគោលនយោបាយក្នុងការលើកស្ទួយបេតិកភណ្ឌវប្បធម៌ ។

ខ- រៀបចំមធ្យោបាយ ដើម្បីអនុញ្ញាតឲ្យសាធារណជនអាចចូលទៅកាន់បេតិកភណ្ឌវប្បធម៌ ។

គ- តែងតាំងបុគ្គលិកត្រួតពិនិត្យ និងបុគ្គលិកដទៃទៀត ដើម្បីអនុវត្តការងារនេះ ។

ឃ- រៀបចំបណ្តាញអ្នកទេសចរណ៍ ។

ង- លើកកម្ពស់តម្លៃវប្បធម៌ ដោយកៀងគរមូលនិធិដែលចាំបាច់ អប់រំដល់សាធារណជនបុគ្គលិកបណ្តុះបណ្តាល និងអនុវត្តការស្រាវជ្រាវអំពីបេតិកភណ្ឌរូបសាស្ត្រ វប្បធម៌ និងប្រវត្តិសាស្ត្រ ។

ច- ផ្តល់ការធានាទាក់ទងនឹងការទទួលខុសត្រូវ និងកាតព្វកិច្ចផ្នែកគ្រប់គ្រង ដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីវប្បធម៌ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

ឆ- ចាត់វិធានការចាំបាច់ ដើម្បីអនុវត្តគម្រោង និងសកម្មភាពដទៃទៀត ដែលទាក់ទងនឹងការការពារ ការថែរក្សា ការស្តារឡើងវិញ និងការលើកស្ទួយបេតិកភណ្ឌជាតិ ។

ជ- បង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុវត្តកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាចំពោះការការពារបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៣២** ._ការទទួលបានព័ត៌មានបរិស្ថាន

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធានាថា រាល់ឯកសារពាក់ព័ន្ធទៅនឹងកិច្ចប្រជុំរបស់ខ្លួន ត្រូវបានផ្តល់ជូនដល់សាធារណជនស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

## ជំពូកទី៤
## ការបង្កើតបញ្ជីបេតិកភណ្ឌជាតិ

**មាត្រា៦៣៣**._បញ្ជីបេតិកភណ្ឌជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវបង្កើតបញ្ជីបេតិកភណ្ឌជាតិសម្រាប់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៦៣៤**._សម្បត្តិ និងប្រភេទនៅក្នុងបញ្ជីបេតិកភណ្ឌជាតិ

រដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចបន្ថែមចំនួនបេតិកភណ្ឌ ចូលទៅក្នុងបញ្ជីបេតិកភណ្ឌជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៦៣៥**._ ការចុះបញ្ជីបេតិកភណ្ឌវប្បធម៌ ឬតំបន់បេតិកភណ្ឌ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ និងអាជ្ញាធរ ឬ ស្ថាប័នមានសមត្ថកិច្ចដែលត្រូវបានបង្កើតឡើងសម្រាប់គោលបំណងនៃការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ត្រូវកត់ត្រាចំនួនបេតិកភណ្ឌ និងតំបន់បេតិកភណ្ឌទាំងអស់ ទៅក្នុង បញ្ជីបណ្ដោះអាសន្ន នៃបេតិកភណ្ឌវប្បធម៌ជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ អាជ្ញាធរ ឬ ស្ថាប័នមានសមត្ថកិច្ចដែលត្រូវបានបង្កើតឡើងសម្រាប់គោលបំណងនៃការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ត្រូវកត់ត្រាផងដែរនូវសម្បត្តិបេតិកភណ្ឌ ឬតំបន់បេតិកភណ្ឌទាំងឡាយណា ដែលស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ នៃការបំផ្លិចបំផ្លាញ ដែលស្ថិតនៅក្នុងបញ្ជីគ្រោះអាសន្ននៃបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ ដើម្បីធ្វើការសង្គ្រោះជាបន្ទាន់ចំពោះបេតិកភណ្ឌ ឬតំបន់បេតិកភណ្ឌទាំងនោះ ។

**មាត្រា៦៣៦**._ ការការពារស្របច្បាប់ចំពោះវត្ថុបេតិកភណ្ឌ

វត្ថុបេតិកភណ្ឌ ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌជាតិ ត្រូវទទួលបាននូវការការពារ ស្របតាមក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា៦៣៧**._ ការធ្វើបច្ចុប្បន្នភាពទៅលើបញ្ជីបេតិកភណ្ឌជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្ដីពីការធ្វើបច្ចុប្បន្នភាពទៅលើបញ្ជីបេតិកភណ្ឌជាតិ ដោយពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា៦៣៨**._ កិច្ចការពារ និងការធ្វើចំណាត់ថ្នាក់

វត្ថុបេតិកភណ្ឌវប្បធម៌ត្រូវស្ថិតនៅក្នុងបញ្ជីបេតិកភណ្ឌជាតិ និងទទួលបានការពារពីការខូចខាត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ រហូតដល់ពេលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ បានធ្វើចំណាត់ថ្នាក់វត្ថុទាំងនោះ ដោយអនុលោមតាមបទប្បញ្ញត្តិនៃលិខិតបទដ្ឋានគតិយុត្តស្តីពី បេតិកភណ្ឌវប្បធម៌។

**មាត្រា៦៣៩** ._បញ្ជីវត្ថុបេតិកភណ្ឌវប្បធម៌ដែលបានធ្វើចំណាត់ថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំបញ្ជីសម្បត្តិបេតិកភណ្ឌវប្បធម៌ ដូចបានធ្វើចំណាត់ថ្នាក់ប្រចាំឆ្នាំ ។ បញ្ជីនេះ ត្រូវដាក់បញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌជាតិ ។

## ជំពូកទី៥
## ការរៀបចំតំបន់ការពារបេតិកភណ្ឌជាតិ

**មាត្រា៦៤០** ._ ការបង្កើតតំបន់ការពារបេតិកភណ្ឌជាតិ

ត្រូវបង្កើតឲ្យមានតំបន់ការពារបេតិកភណ្ឌជាតិ ដែលរួមមាននូវបេបនីយភណ្ឌផ្នែកបុរាណវត្ថុវិទ្យា ឬ តំបន់ដទៃទៀត ដែលមានតម្លៃខាងផ្នែកវត្ថុបុរាណវិទ្យា នរវិទ្យា វប្បធម៌ ឬ ប្រវត្តិសាស្ត្រ ។

**មាត្រា៦៤១** ._ ការបង្កើតព្រំប្រទល់ និងការរៀបចំដែនទី

ព្រំប្រទល់នៃតំបន់ការពារបេតិកភណ្ឌជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៤២** ._ តំបន់ការពារបេតិកភណ្ឌជាតិ

តំបន់នានាដែលរួមមាននូវទីតាំងបេតិកភណ្ឌ ត្រូវហៅថា តំបន់ការពារបេតិកភណ្ឌជាតិ ។ របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារ ដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាចរួមបញ្ចូលទីតាំង និងសម្បត្តិបេតិកភណ្ឌវប្បធម៌ នៃតំបន់ទាំងនេះ ។

**មាត្រា៦៤៣** ._ កិច្ចការពារទៅលើរាល់វត្ថុបេតិកភណ្ឌវប្បធម៌

វត្ថុបេតិកភណ្ឌវប្បធម៌ ត្រូវទទួលបាននូវការការពារ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ដទៃទៀត ទោះបីជាវត្ថុទាំងនោះមានក្តី ឬ មិនមានក្តី នៅក្នុងតំបន់ការពារបេតិកភណ្ឌជាតិ ។

## ជំពូកទី៦
## ការបង្កើតតំបន់ការពារបេតិកភណ្ឌទីក្រុង

**មាត្រា៦៤៤ ._** ការបង្កើតតំបន់បេតិកភណ្ឌទីក្រុង

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ អាចលើកសំណើស្នើសុំទៅកាន់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ សម្រាប់តំបន់ទីក្រុង ដើម្បីកំណត់ជាតំបន់បេតិកភណ្ឌទីក្រុង ។

**មាត្រា៦៤៥ ._** ផែនការតំបន់បេតិកភណ្ឌទីក្រុង

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំផែនការសម្រាប់តំបន់បេតិកភណ្ឌទីក្រុង និងចំណាត់ថ្នាក់នៃទីតាំងនោះ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៦៤៦ ._** ការជូនដំណឹង

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវជូនដំណឹងដល់ ក្រសួង ស្ថាប័នមានសមត្ថកិច្ចអំពីសំណើសុំបង្កើតតំបន់បេតិកភណ្ឌទីក្រុង ។

**មាត្រា៦៤៧ ._** ការវាយតម្លៃបេតិកភណ្ឌ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវធ្វើការពិចារណា និងវាយតម្លៃលើតម្លៃបេតិកភណ្ឌជាមុនសិន មុនសម្រេចឯកភាពឲ្យមានការសាងសង់ ឬការកំទេចចោល ឬការអភិវឌ្ឍឡើងវិញនៅក្នុងតំបន់បេតិកភណ្ឌទីក្រុង ។

## ជំពូកទី៧
## កិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ
## ផ្នែកទី១
## ការប្រទះឃើញដោយចៃដន្យ ក្នុងអំឡុងពេលនៃការកំទេចចោល ការសាងសង់ ឬសកម្មភាពដទៃទៀត

**មាត្រា៦៤៨ ._** កាតព្វកិច្ចទូទៅចំពោះការជូនដំណឹងអំពីការរកឃើញដោយចៃដន្យ

បុគ្គលគ្រប់រូប ដែលបានដឹង ឬ ប្រទះឃើញដោយចៃដន្យនូវ វត្ថុ ឬ តំបន់បេតិកភណ្ឌវប្បធម៌ ត្រូវមានកាតព្វកិច្ចរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរ និង ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

**មាត្រា៦៤៩ ._** កាតព្វកិច្ចក្នុងការបញ្ឈប់ការងារ និងជូនដំណឹងនៃអាជ្ញាធរថ្នាក់ក្រោមជាតិ

រូបវន្តបុគ្គល ម្ចាស់គម្រោង ម្ចាស់ទីតាំង ឬអ្នកជួលនៃទីតាំង ដែលរកឃើញដោយចៃដន្យ នៅក្នុងអំឡុងពេលនៃការងារសាងសង់ នូវសម្បត្តិ ឬ តំបន់បេតិកភណ្ឌ ត្រូវបញ្ឈប់ការងារសាងសង់ជាបណ្តោះអាសន្ន និងត្រូវរាយការណ៍ទៅកាន់អាជ្ញាធរថ្នាក់ក្រោមជាតិ និងត្រូវបញ្ជូនសម្បត្តិបេតិកភណ្ឌនេះទៅកាន់អាជ្ញាធរថ្នាក់ក្រោមជាតិ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដោយគ្មានការពន្យាពេល ។ សម្បត្តិបេតិកភណ្ឌ ឬតំបន់បេតិកភណ្ឌ មានជាអាទិ៍ វិមាន សម្បត្តិបាក់បែក វត្ថុបុរាណ សំណល់នៃទីតាំងដែលមនុស្សធ្លាប់រស់នៅ ទីតាំងផ្នូរបុរាណ ចម្លាក់ ឬ សម្បត្តិទាំងឡាយណា ដែលទំនងជាមានការចាប់អារម្មណ៍នៅក្នុងការសិក្សាអំពីបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ បុរាណវត្ថុវិទ្យា ជាតិពន្ធវិទ្យា ការសិក្សាវិទ្យាសាស្ត្រហ្វូស៊ីលសត្វនិងរុក្ខជាតិ ឬ សាខាផ្សេងទៀតនៃវិទ្យាសាស្ត្រដែលទាក់ទងនឹងអតីតកាល ឬ វិទ្យាសាស្ត្រមនុស្សជាតិជាទូទៅ ។

**មាត្រា៦៥០ ._** ការជូនដំណឹងទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌

អាជ្ញាធរថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវរាយការណ៍ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ និងចាត់វិធានការដែលចាំបាច់ ក្នុងការធានានូវការការពារសម្បត្តិបេតិកភណ្ឌ និងទីតាំងនៃសម្បត្តិបេតិកភណ្ឌទាំងនោះ រហូតដល់ពេលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ធ្វើអធិការកិច្ចទីតាំងនោះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវជូនដំណឹងដល់ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដែលត្រូវបានបង្កើតឡើងសម្រាប់គោលបំណងនៃការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៥១ ._** ការកំណត់ ជាបឋមនៃបេតិកភណ្ឌ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវធ្វើការកំណត់ជាបឋមអំពីសារៈសំខាន់នៃវត្ថុបេតិកភណ្ឌ នៅក្នុងរយៈពេល១៤ (ដប់បួន) ថ្ងៃ ក្រោយពេលទទួលបានការជូនដំណឹង ឬរបាយការណ៍ ។ រយៈពេលនេះ អាចពន្យាបានតែម្តងប៉ុណ្ណោះ ដោយមានរយៈពេល១៤(ដប់បួន)ថ្ងៃបន្ថែម ។ ក្រសួង ស្ថប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ ម្ចាស់គម្រោង ឬម្ចាស់ ឬម្ចាស់ទ្រព្យសម្បត្តិ ឬអ្នកជួល អំពីការពន្យាពេលនេះ ។

**មាត្រា៦៥២ ._** សេចក្តីសម្រេចក្នុងការផ្អាកជាបណ្តោះអាសន្ន ឬ បន្តផ្អាកការងារ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវចេញសេចក្តីសម្រេច ក្នុងការផ្អាកជាបណ្តោះអាសន្ន ឬបន្តការព្យួរការងារនៅលើទីតាំងទាំងឡាយណាដែលមានការប្រទះឃើញវត្ថុ

បេតិកភណ្ឌ ។ សេចក្ដីសម្រេចផ្អាក បណ្ដោះអាសន្ន ឬបន្តព្យួរការងារនេះ មានសុពលភាពត្រឹមរយៈពេល៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីបានធ្វើការកំណត់ជាបឋម ដូចមានចែងក្នុងមាត្រា៥៥១ខាងលើនេះ ។

ក្នុងករណីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ពុំបានចេញសេចក្ដីសម្រេចថ្មីក្រោយរយៈពេល៣០(សាមសិប)ថ្ងៃខាងលើនេះបានកន្លងផុតនោះទេ ម្ចាស់គម្រោង ឬម្ចាស់ ឬម្ចាស់ទ្រព្យសម្បត្តិ ឬអ្នកជួល អាចបន្តសកម្មភាពការងាររបស់ខ្លួនបាន ។

**មាត្រា៦៥៣** ._ ការហាមឃាត់ចំពោះការយកចេញ ឬបំផ្លាញបេតិកភណ្ឌ

ត្រូវហាមឃាត់ចំពោះការយកចេញ ឬបំផ្លិចបំផ្លាញនូវវត្ថុបេតិកភណ្ឌណាមួយដែលមាននៅក្នុងទីតាំងដីកម្មសិទ្ធិឯកជន លើកលែងតែមានការអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា៦៥៤** ._ កាតព្វកិច្ចចុះកំណត់ត្រា

ម្ចាស់គម្រោង ឬម្ចាស់ ឬម្ចាស់ទ្រព្យសម្បត្តិ ឬអ្នកជួលមានកាតព្វកិច្ច ក្នុងការធ្វើកំណត់ត្រា និងថតរូបវត្ថុបេតិកភណ្ឌ ស្របតាមការណែនាំរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៥៥** ._ ការហាមឃាត់ពាក់ព័ន្ធទៅនឹងការមិនបានអនុលោមតាម

ការខកខានមិនបានរាយការណ៍អំពីការប្រទះឃើញដោយចៃដន្យ ឬការបំផ្លិចបំផ្លាញវត្ថុបេតិកភណ្ឌណាមួយ មុនពេលធ្វើការកំណត់អំពីតម្លៃបេតិកភណ្ឌនោះ ត្រូវទទួលរងនូវការលុបចោលលិខិតអនុញ្ញាត ឬ វិញ្ញាបនបត្រឯកភាព ។

## ផ្នែកទី២
## ការការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក និងក្នុងសមុទ្រ

**មាត្រា៦៥៦** ._ បេតិកភណ្ឌវប្បធម៌ក្រោមទឹក

បេតិកភណ្ឌវប្បធម៌ក្រោមទឹក មានជាអាទិ៍ រាល់ស្លាកស្នាមទាំងអស់នៃអត្ថិភាពរបស់មនុស្សដែលមានចរិតលក្ខណៈផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ ឬបុរាណវត្ថុវិទ្យា ដែលលិចចូលទៅក្នុងទឹកដោយផ្នែក ឬ ទាំងស្រុង មួយរយៈកាល ឬ ជានិរន្តរ អស់រយៈពេល យ៉ាងហោចណាស់១០០ (មួយរយ) ឆ្នាំមានជាអាទិ៍ ៖

១- ទីតាំង រចនាសម្ព័ន្ធ អគារ វត្ថុបុរាណ និងសំណល់អដ្ឋិធាតុរបស់មនុស្ស រួមជាមួយបរិបទខាងផ្នែកបុរាណវត្ថុវិទ្យា និងផ្នែកធម្មជាតិរបស់ពួកគេ ។

២- នាវា យន្តហោះ យានយន្តដទៃទៀត ឬ បំណែករបស់យានយន្តទាំងនេះ និងទំនិញ ឬបន្ទុកផ្សេងទៀតនៅក្នុងយានយន្តទាំងនោះ រួមជាមួយបរិបទខាងផ្នែកបុរាណវត្ថុវិទ្យារបស់យានយន្តទាំងនោះ ។

៣- វត្ថុនានាដែលមានចរិត/លក្ខណៈបុរេប្រវត្តិសាស្ត្រ ។

**មាត្រា៦៥៧** ._ សេចក្តីប្រកាសអំពីបញ្ជីបេតិកភណ្ឌជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវធ្វើសេចក្តីប្រកាសទាក់ទងនឹងវត្ថុបេតិកភណ្ឌវប្បធម៌ក្នុងទឹក ដើម្បីដាក់បញ្ចូលវត្ថុនោះទៅក្នុងបញ្ជីបេតិកភណ្ឌជាតិ ។

**មាត្រា៦៥៨** ._ កាតព្វកិច្ចរាយការណ៍

រូបវន្តបុគ្គល និងនីតិបុគ្គលទាំងអស់ ត្រូវមានកាតព្វកិច្ចរាយការណ៍ជូនក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ អំពីវត្ថុក្រោមទឹកណាមួយ ដែលកំណត់អត្តសញ្ញាណជាវត្ថុបេតិកភណ្ឌ ដែលត្រូវបានប្រទះឃើញដោយចៃដន្យ ដើម្បីធ្វើការកំណត់ដាក់បញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌជាតិ ។

**មាត្រា៦៥៩** ._ ការហាមឃាត់ក្នុងការធ្វើឲ្យខូចខាត ការបំផ្លិចបំផ្លាញ ការស្រង់ ឬ ការរំខាន

រាល់សកម្មភាពដែលបង្កការខូចខាត ការបំផ្លិចបំផ្លាញ ការស្រង់ ឬ ការរំខាន ចំពោះបេតិកភណ្ឌវប្បធម៌ក្នុងទឹក ត្រូវហាមឃាត់ ។

**មាត្រា៦៦០** ._ ការការពារ ការវាយតម្លៃផ្នែកវិទ្យាសាស្ត្រ និងការរុករក

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុញ្ញាតឲ្យមានការការពារ ការវាយតម្លៃផ្នែកវិទ្យាសាស្ត្រ និងការរុករកបេតិកភណ្ឌវប្បធម៌ក្រោមទឹក ។

**មាត្រា៦៦១** ._ លិខិតអនុញ្ញាត និងការឯកភាព

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកបេតិកភណ្ឌជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ អាចចេញលិខិតអនុញ្ញាត និងការឯកភាពសម្រាប់សកម្មភាពនានាដែលមានការប៉ះពាល់ចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ស្របតាមលិខិតបទដ្ឋានគតិយុត្តនានា ។

## ផ្នែកទី៣
## លិខិតអនុញ្ញាតសម្រាប់គម្រោងអភិវឌ្ឍដែលប៉ះពាល់ដល់បេតិកភណ្ឌវប្បធម៌

**មាត្រា៦៦២** ._ គម្រោង និងសកម្មភាពដែលតម្រូវឲ្យមានលិខិតអនុញ្ញាត

រាល់គម្រោង ឬសកម្មភាពទាំងឡាយណា ដែលអាចមានផលប៉ះពាល់ទៅលើវត្ថុបេតិកភណ្ឌ ឬវត្ថុណាមួយដូចមានចុះក្នុងបញ្ជីបេតិកភណ្ឌជាតិ ត្រូវមានលិខិតអនុញ្ញាតជាមុនសិន មុននឹងអនុវត្តការងារដែលអាចបង្កឲ្យមានការខូចខាតចំពោះវត្ថុបេតិកភណ្ឌ ។

**មាត្រា៦៦៣** ._ នីតិវិធីក្នុងការផ្តល់ការអនុញ្ញាត

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកបេតិកភណ្ឌជាតិ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីក្នុងការផ្តល់លិខិតអនុញ្ញាតចំពោះសកម្មភាពទាំងឡាយណាដែលអាចបង្កការខូចខាតដល់វត្ថុបេតិកភណ្ឌ ។

**មាត្រា៦៦៤** ._ ការហាមឃាត់ក្នុងការធ្វើឲ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឲ្យគ្រោះថ្នាក់

ត្រូវហាមឃាត់ចំពោះសកម្មភាពដែះបង្កឱ្យមានការខូចខាត ការបំផ្លិចបំផ្លាញ ឬធ្វើឲ្យគ្រោះថ្នាក់ដល់វត្ថុដែលមានចុះនៅក្នុងបញ្ជីបេតិកភណ្ឌជាតិ លើកលែងតែមានការផ្តល់លិខិតអនុញ្ញាត ស្របតាមមាតិកានេះ ។

**មាត្រា៦៦៥** ._ លិខិតអនុញ្ញាត និងការឯកភាពដែលតម្រូវឲ្យមាន

មិនត្រូវផ្តល់ការអនុញ្ញាត ឬការឯកភាពលើការសាងសង់ណាមួយឡើយ ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ លុះត្រាតែក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ បានផ្តល់នូវការអនុញ្ញាតនេះ ស្របតាមនីតិវិធីនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

**មាត្រា៦៦៦** ._ ការហាមឃាត់ចំពោះការចេញលិខិតអនុញ្ញាតដោយគ្មានការកំណត់ត្រឹមត្រូវ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ មិនត្រូវផ្តល់លិខិតអនុញ្ញាតចំពោះរាល់សកម្មភាពនានាដែលអាចបង្កផលប៉ះពាល់ចំពោះវត្ថុបេតិកភណ្ឌឡើយ ដរាបណាមិនទាន់បានវាយតម្លៃទៅលើតម្លៃនៃវត្ថុបេតិកភណ្ឌទាំងនោះ ស្របតាមនីតិវិធីដែលមានចែងនៅក្នុងក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

## ជំពូកទី៨
## អច្ចតាពបុរាណវត្ថុវិទ្យា

**មាត្រា៦៦៧** ._ តួនាទី និងការទទួលខុសត្រូវ

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់ពីតួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវចំពោះបុរាណវត្ថុ ស្របតាមក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ។

**មាត្រា៦៦៨** ._ តួនាទី និងភារកិច្ចរបស់អង្គភាពដែលមានស្រាប់

ស្ថាប័ន ឬ អាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវបានបង្កើតឡើងសម្រាប់គោលដៅនៃការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ត្រូវអនុវត្តតួនាទី និងការទទួលខុសត្រូវដែលមានស្រាប់ ស្របតាមលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ លើកលែងតែមានចែងផ្ទុយជាក់លាក់នៅក្នុងក្រមនេះ ។

## ជំពូកទី៩
## ការដោះស្រាយវិវាទ និងបទបញ្ជាបន្ទាន់

**មាត្រា៦៦៩** ._ នីតិវិធីដោះស្រាយវិវាទ

នៅក្នុងករណីមានវិវាទកើតឡើង គូភាគីត្រូវអនុវត្តតាមនីតិវិធីដែលកំណត់នៅក្នុងគន្ថីទី៩ នៃក្រមនេះ ។

**មាត្រា៦៧០** ._ តំណាង នៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតកភណ្ឌវប្បធម៌ នៅក្នុងវិវាទ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវធ្វើជាតំណាងនៅក្នុងនីតិវិធីដោះស្រាយវិវាទ ដែលមានផលប៉ះពាល់លើតម្លៃបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៧១** ._ បទបញ្ជាបន្ទាន់ក្នុងការផ្អាកសកម្មភាពគំរាមកំហែង ឬគ្រោះថ្នាក់វត្ថុបេតិកភណ្ឌ

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកបេតិកភណ្ឌ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ និងក្រសួង ស្ថាប័នមានសមត្ថកិច្ច អាចចេញបញ្ជាបន្ទាន់ដើម្បីផ្អាកការងារ ការសាងសង់ ឬ ការឈូសឆាយ ក្នុងករណីដែលទីតាំង ឬវត្ថុបេតិកភណ្ឌ កំពុងរងគ្រោះថ្នាក់ ឬជិតវិនាសហិនហោច ទោះបីជាបាន ឬ មិនបានចុះនៅក្នុងបញ្ជីបេតិកភណ្ឌជាតិក៏ដោយ ។

អំឡុងពេលនៃបទបញ្ជាផ្អាកសកម្មភាពការងារនេះ មានរយៈពេល១៤ (ដប់បួន) ថ្ងៃ ។ រយៈពេលនេះអាចពន្យារបានតែម្តងទៀតប៉ុណ្ណោះ សម្រាប់រយៈពេល១៤ (ដប់បួន) ថ្ងៃបន្ថែម ។

## ជំពូកទី១០
## ផែនការគ្រប់គ្រងបេតិកភណ្ឌ

**មាត្រា៦៧២** ._ ផែនការគ្រប់គ្រងបេតិកភណ្ឌ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ អាចតម្រូវឲ្យមានការរៀបចំផែនការគ្រប់គ្រងបេតិកភណ្ឌ សម្រាប់ទីតាំងបេតិកភណ្ឌវប្បធម៌ ដែលមានចុះនៅក្នុងបញ្ជីបេតិកភណ្ឌជាតិ ឬតំបន់បេតិកភណ្ឌទីក្រុង ។ ផែនការគ្រប់គ្រងបេតិកភណ្ឌត្រូវបង្កើតផងដែរនូវតំបន់ការពារ និងតំបន់ស្នូល ។

**មាត្រា៦៧៣** ._ ការចូលរួមរបស់អ្នកពាក់ព័ន្ធ

ការរៀបចំផែនការគ្រប់គ្រងបេតិកភណ្ឌ ត្រូវសហការជាមួយសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៦៧៤** ._ ការរៀបចំផែនការគ្រប់គ្រងបេតិកភណ្ឌ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីផែនការគ្រប់គ្រងបេតិកភណ្ឌ ស្របតាមគោលការណ៍ ដែលបានបង្កើតឡើង ដោយក្រុមប្រឹក្សាអន្តរជាតិស្តីពីបូជនីយដ្ឋាន និងទីតាំងបេតិកភណ្ឌ និងការអនុវត្តល្អបំផុតជាអន្តរជាតិដទៃទៀត ។

**មាត្រា៦៧៥** ._ ការពិចារណាទៅលើផលប៉ះពាល់ទៅលើសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច

នៅក្នុងការរៀបចំផែនការគ្រប់គ្រងទីតាំងបេតិកភណ្ឌ ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវគិតគូរពិចារណាអំពីផលប៉ះពាល់នៃទីតាំងបេតិកភណ្ឌ ចំពោះសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។

**មាត្រា៦៧៦** ._ ការចូលរួមជាសាធារណៈសម្រាប់ផែនការគ្រប់គ្រងបេតិកភណ្ឌ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធានាថាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ទទួលបានការពិគ្រោះយោបល់មុននឹងធ្វើការសម្រេចចិត្ត ទាក់ទងនឹងបេតិកភណ្ឌវប្បធម៌ដែលអាចប៉ះពាល់ដល់ពួកគេ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ នៅក្នុងគន្ថីទី១ មាតិកាទី២ នៃក្រមនេះ ។

## ជំពូកទី១១
## ការលើកកម្ពស់ និងការការពារបេតិកភណ្ឌអរូបិយ

**មាត្រា៦៧៧ ._** វិធានការក្នុងការលើកកម្ពស់និងការពារបេតិកភណ្ឌអរូបិយ

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកបេតិកភណ្ឌជាតិ ដោយសហការជាមួយ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីលើកកម្ពស់ និងការពារបេតិកភណ្ឌអរូបិយ ។

**មាត្រា៦៧៨ ._** ការចូលរួមជាសាធារណៈសម្រាប់បេតិកភណ្ឌអរូបិយ

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកបេតិកភណ្ឌជាតិ ត្រូវដាក់លិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងមាត្រា៦៧៧ខាងលើនេះ ឲ្យសាធារណជនអាចស្វែងរកបាន ដើម្បីផ្តល់យោបល់ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ មុនពេលមានការឯកភាពពីក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកបេតិកភណ្ឌជាតិ ។

## ជំពូកទី១២
## ការអប់រំ និងការយល់ដឹង

**មាត្រា៦៧៩ ._** ការអប់រំ និងការយល់ដឹងជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវរៀបចំកម្មវិធីអប់រំ និងការយល់ដឹងជាសាធារណៈសម្រាប់ការអភិរក្ស និងការការពារវត្ថុ និងទីតាំងបេតិកភណ្ឌ ។

**មាត្រា៦៨០ ._** ថ្លៃសេវា និងបន្ទុកផ្សេងៗ

ផែនការគ្រប់គ្រង សម្រាប់តំបន់បេតិកភណ្ឌ អាចដាក់បញ្ចូលនូវបទប្បញ្ញត្តិនៃថ្លៃសេវា និងបន្ទុកផ្សេងៗ ដែលត្រូវប្រើប្រាស់សម្រាប់ការលើកកម្ពស់ និងកិច្ចការពារ បេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៨១ ._** សារៈមន្ទីរ និងស្ថាប័នវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការផ្តល់អាជ្ញាប័ណ្ណ និងការគ្រប់គ្រងសារមន្ទីរ និងស្ថាប័នវប្បធម៌ ស្របតាមទម្លាប់អនុវត្តល្អបំផុតជាអន្តរជាតិ និងការតព្វកិច្ចជាអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី១៣
## បទប្បញ្ញត្តិប្រឆាំងនឹងការជួញដូរ

**មាត្រា៦៨២** ._ កងកម្លាំងប្រឆាំងការជួញដូរ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធ និងនីតិបុគ្គលនានា ដែលរួមមាន ក្រសួង ស្ថាប័នអន្តរជាតិ និងអង្គការមិនមែន រដ្ឋាភិបាល ត្រូវបង្កើតកងកម្លាំងក្នុងការបញ្ឈប់ការធ្វើពាណិជ្ជកម្ម និងការជួញដូរបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៨៣** ._ កិច្ចសហការអន្តរជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការប្រឆាំងការជួញដូរ ដើម្បីបញ្ឈប់ការធ្វើពាណិជ្ជកម្ម និងការជួញដូរបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៦៨៤** ._ វិធានសម្រាប់ការនាំយកមកវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវសហការជាមួយ បណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង្កើតលិខិតបទដ្ឋានគតិយុត្តស្ដីពីការនាំមកព្រះរាជាណាចក្រកម្ពុជាវិញនូវបេតិកភណ្ឌវប្បធម៌ ដែលត្រូវបានយកចេញពីព្រះរាជាណាចក្រកម្ពុជា ។

## គន្ថីទី៦
## ការគ្រប់គ្រងសំណល់ និងការបំពុល
## មាតិកាទី១
## កាតព្វកិច្ចទូទៅចំពោះការត្រួតពិនិត្យការបំពុល
## ជំពូកទី១
## ការហាមឃាត់ស្ដីពីការបំពុល

**មាត្រា៦៨៥** ._ កាតព្វកិច្ចទូទៅចំពោះការបំពុលខ្យល់ ទឹក និងដី

រូបវន្តបុគ្គល និងនីតិបុគ្គល មិនត្រូវធ្វើសកម្មភាពណាមួយដែលនាំឲ្យមានការបំពុលខ្យល់ ទឹក និងដី ឡើយ ។

**មាត្រា៦៨៦** ._ សំណល់

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវដឹកជញ្ជូន គ្រប់គ្រង ស្តុកទុក ធ្វើប្រព្រឹត្តកម្ម ឬបោះបង់ ចោលសំណល់ណាមួយ ទោះក្នុងរូបភាពជាសារធាតុរឹង ឬរាវ ឬឧស្ម័នឬសារធាតុ គ្រោះថ្នាក់ ឬសំណល់គ្រោះថ្នាក់ លើកលែងតែស្របតាមលក្ខខណ្ឌនៃលិខិតអនុញ្ញាត ដែលបានចេញស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

**មាត្រា៦៨៧** ._ សំឡេង និងរំញ័រ

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវបង្កសកម្មភាពណាមួយដែលនាំមានការបំពុលដោយ សំឡេង ឬរំញ័រដែលលើសពីស្តង់ដារដែលអនុញ្ញាត ស្របតាមបទប្បញ្ញត្តិនៃគន្ថីនេះ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធឡើយ ។

## ជំពូកទី ២
## លិខិតអនុញ្ញាត និងការឯកភាព

**មាត្រា៦៨៨** ._ កាតព្វកិច្ចអនុវត្តតាមលក្ខខណ្ឌនៃលិខិតអនុញ្ញាត ឬការឯកភាព

រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវគោរពតាមលក្ខខណ្ឌនានានៃលិខិតអនុញ្ញាត ឬការឯកភាព ដែលបានចេញ ។

**មាត្រា៦៨៩** ._ ស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវប្រើប្រាស់ស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ នៅពេលចេញលិខិតអនុញ្ញាត ឬការឯកភាព នានាស្របតាមបទប្បញ្ញត្តិក្រមនេះ ។

## មាតិកាទី ២
## ស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ
## ជំពូកទី ១
## ការបង្កើតស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ

**មាត្រា៦៩០ ._** ស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ ។

**មាត្រា៦៩១ ._** លក្ខខណ្ឌតម្រូវសម្រាប់ការបង្កើតស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន នៅពេលបង្កើតស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ ត្រូវពិចារណា ដូចខាងក្រោម៖

ក- គោលការណ៍នានានៅក្នុងមាតិកាទី១ គន្ថីទី១ នៃក្រមនេះ ។

ខ- សក្តានុពលភាពនៃការធ្វើឲ្យខូចខាតសុខភាពមនុស្ស ។

គ- សក្តានុពលនៃការធ្វើឲ្យខូចខាតសុខភាពជនងាយរងគ្រោះ រួមមានជាអាទ៍ កុមារ និងមនុស្សចាស់ ។

ឃ- សក្តានុពលនៃការខូចខាតទៅលើបរិស្ថាន ។

ង- ព័ត៌មានផ្នែកវិទ្យាសាស្ត្រដែលអាចស្វែងរកបាន និងប្រសើរបំផុត ។

ច- ស្តង់ដារអាស៊ានដែលពាក់ព័ន្ធ ។

ឆ -ស្តង់ដារអន្តរជាតិដែលពាក់ព័ន្ធ ។

ជ- បច្ចេកទេសប្រសើរបំផុតដែលអាចស្វែងរកបាន ដែលពាក់ព័ន្ធ ។

ឈ- ទម្លាប់នៃការអនុវត្តល្អៗផ្នែកឧស្សាហកម្ម ដែលពាក់ព័ន្ធ។

**មាត្រា៦៩២ ._** ប្រភេទក្រុមស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចបង្កើតស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ មានដូចខាងក្រោម៖

ក ការបំភាយខ្យល់ និងគុណភាពខ្យល់នៃបរិយាកាសជុំវិញ ។

ខ- គុណភាពទឹក រួមមានធនធានទឹកក្រោមដី និងទឹកក្រោមដី និង ធនធានក្នុងតំបន់ឆ្នេរ និងតំបន់ដៃទន្លេ ។

គ -សំឡេងរំខាន និងរំញ័រ ។

ឃ -សំណល់រាវ រួមមានសំណល់ទឹក ។

ង -សំណល់រឹង សំណល់រាវ និងសំណល់គ្រោះថ្នាក់ ។

ច -ផលិតកម្ម និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព ។

ឆ -ប្រសិទ្ធផលថាមពល ។

ជ -គោលដៅគុណភាពបរិស្ថានផ្សេងៗ ដូចដែលបានកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២
## ការអនុវត្តស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ

**មាត្រា៦៩៣** ._ ការអនុវត្តស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ

ស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ ត្រូវអនុវត្តចំពោះរាល់សកម្មភាពទាំងអស់ និងលិខិតអនុញ្ញាត ឬការឯកភាពទាំងឡាយណា ន ដែលចេញស្របតាមក្រមនេះ ឬ លិខិតបទដ្ឋានផ្សេងទៀត ។

**មាត្រា៦៩៤** ._ លិខិតអនុញ្ញាត និងការឯកភាព

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត មិនត្រូវចេញនូវលិខិតអនុញ្ញាត ឬការឯកភាព ដែលមិនស្របទៅនឹងស្តង់ដារគុណភាពបរិស្ថាន ឬ ស្តង់ដារសំណល់រាវបានឡើយ ។

**មាត្រា៦៩៥** ._ ការមិនអនុលោមតាមច្បាប់

រាល់លិខិតអនុញ្ញាត ឬការអនុញ្ញាតទាំងឡាយណា ដែលមិនអនុលោមតាមស្តង់ដារគុណភាពបរិស្ថានឬស្តង់ដារសំណល់រាវ ត្រូវចាត់ទុកជាមោឃៈ ។

## ជំពូកទី ៣
## ស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវអន្តរកាល

**មាត្រា៦៩៦** ._ ស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវដែលមានជាធរមាន និងស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវអន្តរកាល

ស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ ដែលមានជាធរមានទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តស្ថិតនៅជាធរមាន នៅពេលក្រមនេះ ត្រូវបានអនុម័ត រហូតដល់ពេលមានស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវថ្មី ត្រូវបានបង្កើតឡើង។

ក្នុងករណីដែលពុំទាន់មានស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវជាក់លាក់ណាមួយទេ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានអាច អនុវត្ត ស្តង់ដារអន្តរជាតិ ស្តង់ដារអាស៊ាន និងទម្លាប់អនុវត្តដ៏ល្អបំផុតផ្នែកឧស្សាហកម្មដែលពាក់ព័ន្ធ នៅក្នុងអំឡុងពេលអន្តរកាលបាន ។

**មាត្រា៦៩៧** ._ ការរៀបចំសេចក្តីព្រាងស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរៀបចំសេចក្តីព្រាងស្តង់ដារគុណភាព បរិស្ថាន និងស្តង់ដារសំណល់រាវ ។ នៅក្នុងការរៀបចំសេចក្តីព្រាងទាំងនេះ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ។

**មាត្រា៦៩៨** ._ ការចូលរួមជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាននូវសេចក្តីព្រាងស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ និងត្រូវទទួលមតិយោបល់នានា ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ ដែលមានចែងនៅក្នុងគន្ថីទី១ មាតិកាទី២ នៃក្រមនេះ ។

**មាត្រា៦៩៩** ._ ការកែសម្រួលសេចក្តីព្រាងស្តង់ដារបរិស្ថាន និងស្តង់ដារសំណល់រាវ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវពិចារណាអំពីមតិយោបល់ដែលទទួលបានលើសេចក្តីព្រាងស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ និងត្រូវកែសម្រួលសេចក្តីព្រាងស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវនេះ ដោយពិចារណាលើមតិយោបល់ទាំងនោះ និងពន្យល់មូលហេតុនៃការបដិសេធចំពោះមតិយោបល់ទាំងនេះ ។

**មាត្រា៧០០** ._ ការធ្វើវិសោធនកម្មស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ទៅលើស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវធ្វើវិសោធនកម្មទៅលើស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ ស្របតាមភាពរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ឬលក្ខខណ្ឌតម្រូវនៃការងារ ទៅតាម និង នៅពេលដែលចាំបាច់ សម្រាប់ផលប្រយោជន៍សាធារណៈ ។

**មាត្រា៧០១** ._ សិទ្ធិក្នុងការស្នើសុំការធ្វើវិសោធនកម្មស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ

រូបវន្តបុគ្គល ឬនីតិបុគ្គល អាចលើកជាសំណើទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដើម្បីធ្វើវិសោធនកម្មទៅលើស្តង់ដារគុណភាពបរិស្ថាន ឬ ស្តង់ដារសំណល់រាវ ដោយសម្អាងលើព័ត៌មានថ្មីៗ ។

**មាត្រា៧០២ .**_ នីតិវិធីនៃការបង្កើតស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតនូវលិខិតបទដ្ឋានគតិយុត្ត ស្តីពីនីតិវិធីសម្រាប់ការបង្កើតស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់ រាវ ។

**មាត្រា៧០៣ .**_ សិទ្ធិទទួលបានព័ត៌មានបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាននូវស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ដែលមានចែងនៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

## មាតិកាទី ៣
## ការគ្រប់គ្រងសារធាតុគ្រោះថ្នាក់
### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៧០៤ .**_ វិសាលភាពនៃការអនុវត្ត

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះផលិតផល និងសារធាតុ គ្រោះថ្នាក់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង រូបវន្តបុគ្គល និងនីតិបុគ្គលទាំងអស់ដែលផលិត ដឹកជញ្ជូន ទិញ លក់ ប្រើប្រាស់ រក្សាទុក បញ្ចេញ ឬបោះបង់ចោលសារធាតុទាំងនេះ ក៏ដូចជាវត្ថុធាតុដែលពាក់ព័ន្ធ ក្នុងវដ្តជីវិតរបស់ពួកវា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាតិកានេះ មិនមានវិសាលភាពអនុវត្តចំពោះសារធាតុវិទ្យុសកម្ម ឱសថ សម្ភារៈកែសម្ផស្សផលិតផលអាហារ ឬអាហារបន្ទាប់បន្សំ ដែលត្រូវស្ថិតនៅក្រោមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដោយឡែកឡើយ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងសារធាតុ និងផលិតផល និងគ្រោះថ្នាក់ ដោយមានការចូលរួមសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា ។

**មាត្រា៦០៥ .**_ យន្តការគ្រប់គ្រង និងត្រួតពិនិត្យ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយមានការចូលរួមសហាការពីក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ធ្វើការគ្រប់គ្រង និងត្រួតពិនិត្យសារធាតុ គ្រោះថ្នាក់នៅក្នុងវដ្តនៃជីវិតសារធាតុទាំងនោះ ។

**មាត្រា៧០៦** ._ លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់និយមន័យ និងកំណត់ប្រភេទ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់និយមន័យ និងកំណត់ប្រភេទសារធាតុគ្រោះថ្នាក់ ។ស្របតាមមូលដ្ឋាននៃកិច្ចព្រមព្រៀងអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ទម្លាប់ល្អបំផុត និងព័ត៌មានវិទ្យាសាស្ត្រល្អបំផុតដែលមានស្រាប់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ទៅលើលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ។

**មាត្រា៧០៧** ._ការទទួលខុសត្រូវលើការខូចខាត

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលផលិត ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់សម្រាប់ការផលិតសារធាតុ និងទំនិញ ត្រូវទទួលខុសត្រូវលើការខូចខាតទៅដល់សុខភាពមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថានដែលបង្កដោយសារធាតុទាំងនោះ ក្នុងអំឡុងពេលផលិត ឬប្រើប្រាស់ ។

## ជំពូកទី ២
## ការហាមឃាត់ស្តីពីសារធាតុគ្រោះថ្នាក់

**មាត្រា៧០៨** ._ ការហាមឃាត់អំពីការដាក់ម៉ាកដែលនាំឲ្យច្រឡំ

រូបវន្តបុគ្គល ឬនីតិបុគ្គលមិនត្រូវប្រព្រឹត្តសកម្មភាព ដូចខាងក្រោម ៖

ក-ការនាំចូល ឬការចែកចាយសារធាតុគ្រោះថ្នាក់ដែលបានដាក់ម៉ាកដែលនាំឲ្យច្រឡំ ឬសារធាតុគ្រោះថ្នាក់ដែលបានហាមឃាត់ ។

ខ-ការកែប្រែ ការកំទេចចោល ឬការដកចេញនូវស្លាកសម្គាល់ ឬផ្នែកណាមួយនៃស្លាកសម្គាល់សារធាតុគ្រោះថ្នាក់ណាមួយនៅពេលលក់ ជាលើកដំបូង ឬពេលណាមួយ ឬដឹកជញ្ជូន ។

គ-ការទទួលយកសារធាតុគ្រោះថ្នាក់ដែលមានម៉ាកដែលនាំឲ្យច្រឡំ ឬសារធាតុគ្រោះថ្នាក់ដែលបានហាមឃាត់ និងការចែកចាយ ឬប្រគល់សារធាតុទាំងនេះសម្រាប់គោលដៅស្វែងរកកម្រៃ ឬមិនស្វែងរកកម្រៃ ។

**មាត្រា៧០៩** ._ ការហាមឃាត់ចំពោះសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ

ហាមមិនឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ផលិត ប្រើប្រាស់ ឬចែកចាយសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដូចបានហាមឃាត់ទាំងស្រុងដោយអនុសញ្ញាស្តុកខូម ដែលព្រះរាជាណាចក្រកម្ពុជា គឺជាភាគីហត្ថលេខី នោះឡើយ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរៀបចំបញ្ជីស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដែលបានហាមឃាត់ ដែលក្នុងនោះត្រូវរាប់បញ្ចូលនូវសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុទាំងអស់ ដូចបានហាមឃាត់ទាំងស្រុងដោយអនុសញ្ញាស្តុកខូម ដែលព្រះរាជាណាចក្រកម្ពុជា ជាភាគីហត្ថលេខី ។

**មាត្រា៧១០** ._ ការហាមឃាត់អំពីសំណនៅក្នុងថ្នាំពណ៌ និងផលិតផលសម្រាប់កុមារ

ទឹកថ្នាំពណ៌ទាំងឡាយដែលមានសំណ ឬសមាសធាតុសំណ លើសពី ៩០ភាគនៃមួយលានឯកតា នៃបរិមាណដែលជាកំហាប់សំណ ឬថ្នាំពណ៌ ឬទម្ងន់នៃហ្វីលថ្នាំពណ៌ដែលស្ងួត ជាផលិតផលដែលត្រូវបានហាមឃាត់ ។

ផលិតផលសម្រាប់កុមារ ដែលមានថ្នាំពណ៌ដែលមានសមាសធាតុសំណ លើសពី ៩០ភាគនៃមួយលានឯកតា នៃបរិមាណដែលជាកំហាប់សំណ ឬថ្នាំពណ៌ ឬទម្ងន់នៃហ្វីលថ្នាំពណ៌ដែលស្ងួត ជាផលិតផលដែលត្រូវបានហាមឃាត់ ។

**មាត្រា៧១១** ._ កាលបរិច្ឆេទចូលជាធរមានសម្រាប់ការហាមឃាត់លើថ្នាំពណ៌ដែលមានសមាសធាតុសំណ

ការហាមឃាត់លើថ្នាំពណ៌ និងផលិតផលដែលមានសមាសធាតុសំណដូចមានចែងក្នុងមាត្រា ៧១០ នៃក្រមនេះ ត្រូវចូលជាធរមានដូចតទៅ៖

ក-ផលិតកម្ម ឬការផលិតដោយគ្រឿងចក្រ ការនាំចូល ឬការលក់ ផលិតផលសម្រាប់កុមារ ដែលមានថ្នាំពណ៌ដែលមានសមាសធាតុសំណលើសពី ៩០ ភាគនៃមួយលានឯកតា នៃបរិមាណដែលជាកំហាប់សំណ ឬថ្នាំពណ៌ ឬទម្ងន់នៃហ្វីលថ្នាំពណ៌ដែលស្ងួត ក្នុងរយៈពេល ៣ (បី) ឆ្នាំ បន្ទាប់ពីក្រមនេះត្រូវបានអនុម័ត ។

ខ-ផលិតកម្ម ការផលិតដោយគ្រឿងចក្រ ឬការនាំចូលថ្នាំពណ៌ ដែលជាជាតិពណ៌ វត្ថុធាតុដែលស្ងួត ឬលក្ខណៈណាមួយតាមការប្រើប្រាស់ ដែលមានសមាសធាតុសំណលើសពី ៩០ ភាគនៃមួយលានឯកតា នៃបរិមាណដែលជាកំហាប់សំណ ឬថ្នាំពណ៌ ឬនៃទម្ងន់នៃហ្វីល

ថ្នាំពណ៌ដែលស្ងួតសម្រាប់ការប្រើប្រាស់ក្នុងវិស័យស្ថាបត្យកម្ម ការតុបតែង និងតាមគេហដ្ឋាន ក្នុងរយៈពេល ៣ (បី) ឆ្នាំ បន្ទាប់ពីក្រមនេះត្រូវបានអនុម័ត ។

គ-ផលិតកម្ម ការផលិតដោយគ្រឿងចក្រ ឬការនាំចូលថ្នាំពណ៌ ដែលជាជាតិពណ៌ វត្ថុធាតុដែលស្ងួត ឬលក្ខណៈណាមួយតាមការប្រើប្រាស់ ដែលមានសមាសធាតុសំណលើសពី ៩០ ភាគនៃមួយលានឯកតា នៃបរិមាណដែលជាកំហាប់សំណ ឬថ្នាំពណ៌ ឬនៃទម្ងន់នៃហ្វីលថ្នាំពណ៌ដែលស្ងួត សម្រាប់ការប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម ក្នុងរយៈពេល ៦ (ប្រាំមួយ) ឆ្នាំ បន្ទាប់ពីក្រមនេះត្រូវបានអនុម័ត ។

**មាត្រា៧១២** ._ នីតិវិធីសម្រាប់ការអង្កេតតាមដាន និងការពង្រឹងការអនុវត្តការហាមឃាត់ទៅលើថ្នាំពណ៌ដែលមានសមាសធាតុសំណ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការអង្កេតតាមដាន និងការអនុវត្តការហាមឃាត់ទៅលើថ្នាំពណ៌ និងផលិតផលសម្រាប់កុមារដែលមានសមាសធាតុសំណ ។

**មាត្រា៧១៣** ._ ការឃាត់ទុក និងការរឹបអូសសារធាតុដែលមានម៉ាកដែលនាំឲ្យ ច្រឡំ

រាល់សារធាតុ ឬផលិតផលគ្រោះថ្នាក់ ដែលមានម៉ាកដែលនាំឲ្យច្រឡំ ឬដែលបានហាមឃាត់ ត្រូវធ្វើការរឹបអូស ឬឃាត់ទុក ។

**មាត្រា៧១៤** ._ ការហាមឃាត់ចំពោះសារធាតុដែលមិនបានចុះបញ្ជី

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវផលិត កាន់កាប់ ប៉ះពាល់ រក្សាទុក ដឹកជញ្ជូន នាំចូល នាំចេញ ចែកចាយ ឬប្រើប្រាស់ផលិតផល ឬសារធាតុគ្រោះថ្នាក់ ដែលមិនទាន់បានចុះបញ្ជីស្របតាមមាតិកានេះឡើយ ។

**មាត្រា៧១៥** ._ ការហាមឃាត់ចំពោះការវេចខ្ចប់ដែលមិនត្រឹមត្រូវ

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវរក្សាទុក នាំចេញ នាំចូល ឬធ្វើការចែកចាយនូវសារធាតុ ឬផលិតផលគ្រោះថ្នាក់ ដែលមិនបានវេចខ្ចប់ស្របតាមបទប្បញ្ញត្តិ និងលក្ខខណ្ឌនៃការចុះបញ្ជីនោះឡើយ ។

**មាត្រា៧១៦** ._ ការហាមឃាត់ចំពោះការវេចខ្ចប់ និងការផ្សព្វផ្សាយក្លែងក្លាយ ឬនាំឲ្យ ច្រឡំ

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវធ្វើការវេចខ្ចប់ ឬផ្សព្វផ្សាយអំពីសារធាតុ ឬផលិតផលគ្រោះថ្នាក់ ដែលក្លែងក្លាយ ធ្វើឲ្យច្រឡំ ឬបង្កឲ្យមានការឆ្លើយតបបែបយល់ច្រឡំពាក់ព័ន្ធទៅនឹងចរិតលក្ខណៈ តម្លៃ ចំនួន ធាតុផ្សំ សុវត្ថិភាព ឬការចុះបញ្ជីឡើយ ។

**មាត្រា៧១៧** ._ ស្តង់ដារនានាសម្រាប់សារធាតុដែលបង្កឲ្យមានច្រែះស៊ី ការរលាក ការធ្វើអុកស៊ីតកម្ម ឬរបួសស្នាមនានា

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់សារធាតុទាំងឡាយ មានជាអាទិ៍ អាស៊ីត ឧស្ម័ន ឬសារធាតុគីមីពុល ដែលអាចបង្កឲ្យមានច្រែះស៊ី ការរលាក ការធ្វើអុកស៊ីតកម្ម ឬរបួសស្នាមនានា ដែលមានផលប៉ះពាល់ដល់សុខភាព និងជីវិតរបស់មនុស្សឡើយ លើកលែងតែស្របតាមមាតិកានេះ ។

## ជំពូកទី ៣
## ការចុះបញ្ជី និងការលាតត្រដាងព័ត៌មាន
## អំពីសារធាតុគ្រោះថ្នាក់

**មាត្រា៧១៨** ._ លក្ខខណ្ឌតម្រូវ និងនីតិវិធីនៃការចុះបញ្ជី

រូបវន្តបុគ្គល និងនីតិបុគ្គល ត្រូវធ្វើការចុះបញ្ជី រាល់ផលិតផល និងសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលផលិត ចែកចាយ លក់ ឬប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធ ។

នីតិវិធីនៃការចុះបញ្ជី ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រា៧១៩** ._ លក្ខខណ្ឌតម្រូវនៃការដាក់ពាក្យស្នើសុំ

រាល់ការដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវដាក់ជូនទៅក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយមានភ្ជាប់ជាមួយនូវព័ត៌មានជាអប្បបរមាអំពីក្រុមហ៊ុនដែលផលិត ឈ្មោះ និងពាណិជ្ជនាមទូទៅនៃសារធាតុគីមី ចំណាត់ថ្នាក់ភាពបង្កគ្រោះថ្នាក់ បរិមាណ គោលបំណងនៃការនាំចូល ឬប្រើប្រាស់ ឯកសារព័ត៌មានអំពីសុវត្ថិភាព ព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់ ហានិភ័យដែលអាចកើតមានដល់សុខភាពរបស់មនុស្ស និងអាសយដ្ឋានសម្រាប់ធ្វើការចែកចាយ ។

**មាត្រា៧២០** ._ ការពិនិត្យឡើងវិញទៅលើពាក្យស្នើសុំ និងការឯកភាពលើការចុះបញ្ជី

ព័ត៌មានអំពីសារធាតុគ្រោះថ្នាក់ ត្រូវទទួលការពិនិត្យឡើងវិញ និងឯកភាពដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានជាមុនសិន មុននឹងផ្ញើការបញ្ជូនទៅឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធ ធ្វើការឯកភាព ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានអាចធ្វើការពិសោធន៍ និងផ្តល់ការពិគ្រោះយោបល់បន្ថែម លើព័ត៌មានដែលបានផ្តល់ឲ្យដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃព័ត៌មានទាំងនេះ ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវ ឯកភាពទៅលើការចុះបញ្ជីនោះ បើព័ត៌មានទាំងនោះបង្ហាញថា ការចុះបញ្ជីសម្រាប់សារធាតុ ឬផលិតផលដែលមិននាំឲ្យមានហានិភ័យ ដល់សុខភាពមនុស្ស ឬបរិស្ថាន ។

អ្នកស្នើសុំការចុះបញ្ជី ត្រូវទទួលបន្ទុកក្នុងការបង្ហាញភស្តុតាងនៃការបំពេញតាមស្តង់ដារ នៃការចុះបញ្ជី ។

**មាត្រា៧២១** ._ កាតព្វកិច្ចនៃការផ្តល់ព័ត៌មាន

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវផ្តល់រាល់ព័ត៌មានអំពីផលិតផល និងសារធាតុគ្រោះថ្នាក់ទៅឲ្យក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌ ការត្រួតពិនិត្យ ការវាយតម្លៃពីហានិភ័យ និងការធ្វើអធិការកិច្ច ។

ក្នុងករណីផលិតករ ឬអ្នកនាំចូលនូវសារធាតុ មានព័ត៌មានបន្ថែមពាក់ព័ន្ធទៅនឹងផលប៉ះពាល់អវិជ្ជមានគួរឲ្យកត់សម្គាល់នៃសារធាតុនោះ ផលិតករ ឬអ្នកនាំចូល ត្រូវផ្តល់ព័ត៌មាន មកកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយគ្មានការពន្យារពេលនោះឡើយ ។

**មាត្រា៧២២** ._ ផែនការសកម្មភាពសម្រាប់ការទប់ស្កាត់ ការឆ្លើយតបក្នុងករណីសង្គ្រោះបន្ទាន់ ការកាត់បន្ថយ ការអង្កេតតាមដាន និងការគ្រប់គ្រងហានិភ័យ

បន្ទាប់ពីមានការចុះបញ្ជីជាផ្លូវការរួចហើយ រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលបន្ទុក ត្រូវរៀបចំផែនការសកម្មភាពដែលសមរម្យសម្រាប់ការទប់ស្កាត់ ការឆ្លើយតបក្នុងករណីសង្គ្រោះបន្ទាន់ ការកាត់បន្ថយ ការអង្កេតតាមដាន និងការគ្រប់គ្រងហានិភ័យ នៃសារធាតុគ្រោះថ្នាក់ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលខុសត្រូវ ត្រូវផ្តល់ព័ត៌មានដែលត្រឹមត្រូវពាក់ព័ន្ធទៅនឹងសារធាតុគ្រោះថ្នាក់ទាំងនោះ ទៅឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងករណីមានការស្នើសុំ ។

**មាត្រា៧២៣** ._ ការលុបចោលការចុះបញ្ជី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវលុបចោលការចុះបញ្ជីសារធាតុគ្រោះថ្នាក់ ឬនៃការប្រើប្រាស់បែបណាមួយនៃសារធាតុគ្រោះថ្នាក់ ក្នុងករណីដែលបានកំណត់ថា សារធាតុគ្រោះថ្នាក់ ឬការប្រើប្រាស់សារធាតុគ្រោះថ្នាក់បែបនោះ បង្កឲ្យមានហានិភ័យគួរឲ្យកត់សម្គាល់ទៅដល់សុខភាព

មនុស្ស ឬបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវព្យួរការចុះបញ្ជីសារធាតុគ្រោះថ្នាក់ ឬសម្រាប់ការប្រើប្រាស់បែបណាមួយនៃសារធាតុគ្រោះថ្នាក់ ក្នុងករណីបានកំណត់ថា សារធាតុគ្រោះថ្នាក់ ឬការប្រើប្រាស់សារធាតុបែបនោះ អាចបង្កឲ្យកើតមានហានិភ័យគួរឲ្យកត់សម្គាល់ទៅដល់ សុខភាពមនុស្ស ឬបរិស្ថាន ។

## ជំពូកទី ៤
## ការដាក់ស្លាកសញ្ញាសារធាតុគ្រោះថ្នាក់

**មាត្រា៧២៤ ._** បទប្បញ្ញត្តិចំពោះការដាក់ស្លាកសញ្ញាសារធាតុគ្រោះថ្នាក់

រូបវន្តបុគ្គល ឬនិតីបុគ្គលដែលជាប់ពាក់ព័ន្ធទៅនឹងការផលិត ការវេចខ្ចប់ ការចែកចាយ ការដឹកជញ្ជូន ឬការលក់សារធាតុ ឬផលិតផលគ្រោះថ្នាក់ ត្រូវធ្វើការដាក់ស្លាកសញ្ញាឲ្យបានត្រឹមត្រូវ លើសារធាតុ ឬផលិតផលគ្រោះថ្នាក់ទាំងនោះ ស្របតាមបទប្បញ្ញត្តិដែលបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តនានា ។

**មាត្រា៧២៥ ._** លក្ខណៈវិនិច្ឆ័យនៃភាពអាចបង្កគ្រោះថ្នាក់

លក្ខណៈវិនិច្ឆ័យនៃភាពអាចបង្កគ្រោះថ្នាក់ដល់ផ្នែកសុខភាព និងបរិស្ថាន ត្រូវអនុលោមតាមឯកសារបទដ្ឋានបច្ចេកទេសស្តីពីប្រព័ន្ធស៊ីចង្វាក់ជាសាកលអំពីការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញា ។

**មាត្រា៧២៦ ._** កាតព្វកិច្ចនៃការផ្តល់ព័ត៌មាន

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលពាក់ព័ន្ធទៅនឹងផលិតកម្ម ការវេចខ្ចប់ ការចែកចាយ ការដឹកជញ្ជូន ឬការលក់សារធាតុ ឬផលិតផល គ្រោះថ្នាក់ ត្រូវដាក់ឲ្យសាធារណៈជនអាចស្វែងរកបាននូវឯកសារព័ត៌មានអំពីសុវត្ថិភាព ការទប់ស្កាត់ និងការកាត់បន្ថយភាពបង្កគ្រោះថ្នាក់ និងហានិភ័យដល់សុខភាព ដែលពាក់ព័ន្ធទៅនឹងគ្រប់សារធាតុគ្រោះថ្នាក់ ដែលមានបំណងធ្វើការចែកចាយ ឬលក់សារធាតុទាំងនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

## ជំពូកទី ៥
## ការដឹកជញ្ជូន ការប្រើប្រាស់ និងការបោះបង់ចោលសារធាតុគ្រោះថ្នាក់

**មាត្រា៧២៧ ._** ការដឹកជញ្ជូន

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលដឹកជញ្ជូនសារធាតុគ្រោះថ្នាក់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូនសារធាតុ ឬផលិតផលគ្រោះថ្នាក់ដូចបានកំណត់តាមមាតិកានេះ ។

ប្រតិបត្តិករ និងម្ចាស់នៃមធ្យោបាយដឹកជញ្ជូន ត្រូវរៀបចំផែនការសុខភាព និងសុវត្ថិភាពបុគ្គលិក និងផែនការឆ្លើយតបនានា សម្រាប់ករណីមានគ្រោះថ្នាក់ណាមួយដោយសារវត្ថុធាតុនៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដើម្បី៖

ក- កំណត់អត្តសញ្ញាណ និងចាត់វិធានការចាំបាច់ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដែលអាចកើតឡើង និងដំណោះស្រាយនានា មានជាអាទិ៍ ការបណ្តុះបណ្តាលបុគ្គលិកដែលពាក់ព័ន្ធទៅនឹងការដឹកជញ្ជូនអំពីវិធានការសុវត្ថិភាព និងផែនការឆ្លើយតបនានា ។

ខ-កំណត់អត្តសញ្ញាណ និងជូនដំណឹង ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងករណីមានគ្រោះថ្នាក់កើតឡើងក្នុងអំឡុងពេលការដឹកជញ្ជូន មានជាអាទិ៍ តាមផ្លូវគោក ផ្លូវដែក ផ្លូវអាកាស និងផ្លូវទឹក ។

ប្រតិបត្តិករ ឬម្ចាស់នៃមធ្យោបាយដឹកជញ្ជូន ត្រូវធានាថា រាល់យានយន្តដែលប្រើប្រាស់ក្នុងការដឹកជញ្ជូនសារធាតុ ឬផលិតផល គ្រោះថ្នាក់ សមស្របសម្រាប់ការដឹកជញ្ជូន សារធាតុ ឬផលិតផលបែបនោះ និងយានយន្តដឹកជញ្ជូនទាំងនោះ ត្រូវមានសញ្ញាសម្គាល់ ដែលមានរូបភាព ឬរូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់បានត្រឹមត្រូវ ។

**មាត្រា៧២៨ ._** បទប្បញ្ញត្តិសម្រាប់ការដឹកជញ្ជូន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធ្វើការសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យដឹកជញ្ជូន និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការដឹកជញ្ជូនសារធាតុ ឬផលិតផលគ្រោះថ្នាក់ ។

**មាត្រា៧២៩ ._** សិទ្ធិ និងកាតព្វកិច្ចនៃការប្រើប្រាស់

រូបវន្តបុគ្គល ឬនីតិបុគ្គល មានសិទ្ធិប្រើប្រាស់សារធាតុគ្រោះថ្នាក់ ស្របតាមលក្ខខណ្ឌ ដែលបានកំណត់ដោយក្រមនេះ និងសេចក្តីណែនាំអំពីសុវត្ថិភាពនៃសារធាតុគ្រោះថ្នាក់ ។

**មាត្រា៧៣០ ._** ការប្រើប្រាស់ដែលត្រូវបានហាមឃាត់

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវប្រើប្រាស់សារធាតុគ្រោះថ្នាក់ ដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព និងមនុស្ស នៅក្នុងផលិតផលអាហារ គ្រឿងកែសម្ផស្ស និងប្រដាប់ក្មេងលេងឡើយ ។

**មាត្រា៧៣១** ._ ការប្រើប្រាស់ក្នុងការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលប្រើប្រាស់សារធាតុគ្រោះថ្នាក់ ក្នុងគោលបំណងធ្វើការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ត្រូវបំពេញតាមភារកិច្ចមានដូចតទៅៈ

ក- ប្រើប្រាស់សារធាតុគ្រោះថ្នាក់ ឲ្យស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាតិកានេះ ។

ខ- ធានាថា មន្ទីរពិសោធន៍ មានឧបករណ៍គ្រប់គ្រាន់សម្រាប់ការរក្សាទុកដែលមានសុវត្ថិភាព និងការកាន់កាប់សារធាតុគ្រោះថ្នាក់ និងឧបករណ៍ការពារផ្ទាល់ខ្លួនសម្រាប់បុគ្គលិក ។

គ- ធានាថា រាល់សារធាតុគ្រោះថ្នាក់ ត្រូវមានការដាក់ស្លាកសញ្ញាត្រឹមត្រូវ ស្របតាមបទ ប្បញ្ញត្តិ ដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ។

ឃ- ធានាថា មន្ទីរពិសោធន៍ ត្រូវមានប្រព័ន្ធរៀបចំឯកសារត្រឹមត្រូវ និងមានរបាយការណ៍ អំពីសារធាតុគ្រោះថ្នាក់ទាំងឡាយដែលបានប្រើប្រាស់ ។

ង- បោះបង់ចោលសារធាតុ ឬសំណល់គ្រោះថ្នាក់ ស្របតាមបទប្បញ្ញត្តិស្តីពីការគ្រប់គ្រង សំណល់ ក្នុងមាតិកាទី៤ នៃគន្ថីនេះ ។

ច- បង្កើតយន្តការដែលមានប្រសិទ្ធភាព ដើម្បីកំណត់អត្តសញ្ញាណ និងកាត់បន្ថយគ្រោះថ្នាក់ ដែលអាចកើតមានឡើងដោយសារការប្រើប្រាស់ និងការបោះបង់ចោលសារធាតុ ឬសំណល់គ្រោះថ្នាក់ ។

**មាត្រា៧៣២** ._ ការបោះបង់ចោលសារធាតុគ្រោះថ្នាក់

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវដុតចោល ឬបោះបង់ចោលរាល់សារធាតុ ឬសំណល់គ្រោះថ្នាក់ ចូលទៅក្នុងបរិស្ថាន ដោយគ្មានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានឡើយ ។

រាល់ការបោះបង់ចោលសារធាតុគ្រោះថ្នាក់ ឬការវេចខ្ចប់នៃសារធាតុទាំងនេះ ត្រូវស្របតាមបទប្បញ្ញត្តិ ស្តីពីការគ្រប់គ្រងសំណល់ ក្នុងមាតិកាទី៤ នៃគន្ថីនេះ ។

## ជំពូកទី ៦
## សុវត្ថិភាពនៃសារធាតុគ្រោះថ្នាក់
## ការទប់ស្កាត់គ្រោះថ្នាក់ ការត្រៀមលក្ខណៈ និងការឆ្លើយតបនានា

**មាត្រា៧៣៣** ._ សមត្ថភាពផ្នែកបច្ចេកទេស

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានជាប់ពាក់ព័ន្ធទៅនឹងការផលិតសារធាតុ ឬផលិតផលគ្រោះថ្នាក់ ត្រូវមានសមត្ថភាពផ្នែកបច្ចេកទេសសម្រាប់ការប្រើប្រាស់ឧបករណ៍ និងនីតិវិធីក្នុងការការពារបរិស្ថាន និងសង្គម មានជាអាទិ៍៖

ក- រោងជាង ឃ្លាំង និងឧបករណ៍បច្ចេកទេស

ខ- ឧបករណ៍ និងសម្ភារៈទូទៅផ្នែកសុវត្ថិភាព ឧបករណ៍ និងសម្ភារៈជាក់លាក់ផ្នែកទប់ស្កាត់ និងពន្លត់អគ្គីភ័យ ការផ្ទុះ ការបែកផ្កាភ្លើង ការលេចសារធាតុគ្រោះថ្នាក់ ឬការរាលដាល និងគ្រោះថ្នាក់ដទៃទៀត ដោយសារសារធាតុគ្រោះថ្នាក់ ។

គ- ឧបករណ៍ និងសម្ភារៈការពារផ្នែកពលកម្ម ។

ឃ- ឧបករណ៍ និងសម្ភារៈផ្នែកការពារបរិស្ថាន ។

ង- ប្រព័ន្ធបោះបង់ចោល និងធ្វើប្រព្រឹត្តកម្មសំណល់ ។

ច- ការរៀបចំផែនការទប់ស្កាត់ និងឆ្លើយតប មានជាអាទិ៍ ព័ត៌មានអំពីគ្រោះថ្នាក់ ។

**មាត្រា៧៣៤** ._ លក្ខណៈសម្បត្តិនានា

រូបវន្តបុគ្គល និងនីតិបុគ្គល ដែលជាប់ពាក់ព័ន្ធក្នុងការផលិតសារធាតុ ឬផលិតផលគ្រោះថ្នាក់ ត្រូវមានបុគ្គលិកជំនាញការ ដែលមានលក្ខណៈសម្បត្តិពាក់ព័ន្ធទៅនឹងវិសាលភាព ប្រភេទ និងទំហំ នៃសកម្មភាពដែលពាក់ព័ន្ធទៅនឹងសារធាតុគ្រោះថ្នាក់ និងចំណេះដឹងអំពីបច្ចេកវិទ្យា ផែនការ និងវិធានការសុវត្ថិភាពនៃសារធាតុគ្រោះថ្នាក់ ។

**មាត្រា៧៣៥** ._ លក្ខខណ្ឌតម្រូវនៃការចុះបញ្ជី និងលិខិតអនុញ្ញាត

រូបវន្តបុគ្គល និងនីតិបុគ្គល ដែលជាប់ពាក់ព័ន្ធក្នុងការផលិតសារធាតុ ឬផលិតផលគ្រោះថ្នាក់ ត្រូវមានការចុះបញ្ជីត្រឹមត្រូវអំពីសារធាតុគ្រោះថ្នាក់ និងលិខិតអនុញ្ញាតផលិត ដែលត្រូវចេញដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា៧៣៦** ._ លក្ខខណ្ឌតម្រូវនៃការរៀបចំរបាយការណ៍

រូបវន្តបុគ្គល និងនីតិបុគ្គលដែលជាប់ពាក់ព័ន្ធក្នុងការផលិតសារធាតុ ឬផលិតផលគ្រោះថ្នាក់ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំជូនដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អំពីដំណើរការផលិតកម្ម ចំនួនធាតុផ្សំគ្រោះថ្នាក់ បំណងនៃការប្រើប្រាស់ ទីតាំងចែកចាយ ប្រព័ន្ធបោះបង់ចោល និងធ្វើប្រព្រឹត្តកម្មសំណល់ វិធានការ និងផែនការសុវត្ថិភាព ។

ក្រសួង ស្ថាប័នទទួលដែលពាក់ព័ន្ធ ត្រូវកំណត់ទម្រង់បែបបទនៃរបាយការណ៍ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៧៣៧**._ បទប្បញ្ញត្តិអំពីសុវត្ថិភាព

រូបវន្តបុគ្គល និងនីតិបុគ្គលដែលជាប់ពាក់ព័ន្ធក្នុងការផលិតសារធាតុ ឬផលិតផលគ្រោះថ្នាក់ត្រូវ៖

ក- បំពេញឲ្យបានតឹងរ៉ឹងតាមព័ត៌មានបច្ចេកទេស ការដាក់ស្លាកសញ្ញា និងការណែនាំអំពីសុវត្ថិភាព ដែលកំណត់ទៅតាមសារធាតុគ្រោះថ្នាក់ ។

ខ- មានវិធានការទប់ស្កាត់ និងការឆ្លើយតបក្នុងករណីសង្គ្រោះបន្ទាន់ មានជាអាទិ៍ ការសង្គ្រោះបឋម ផែនការជម្លៀស ឧបករណ៍ពន្លត់អគ្គីភ័យ និងឧបករណ៍ការពារផ្ទាល់ខ្លួនសម្រាប់បុគ្គលិក ។

គ- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ និងការកាន់កាប់ ឬប៉ះពាល់ដោយសុវត្ថិភាពនូវសារធាតុគ្រោះថ្នាក់ ដោយសុវត្ថិភាព ។

ឃ- បង្កើតផែនការឆ្លើយតបក្នុងករណីសង្គ្រោះបន្ទាន់ពាក់ព័ន្ធទៅនឹងសារធាតុ គ្រោះថ្នាក់ ។

**មាត្រា៧៣៨**._ ការជូនដំណឹងអំពីគ្រោះថ្នាក់

ក្នុងករណីមានគ្រោះថ្នាក់ដែលបង្កដោយសារធាតុគ្រោះថ្នាក់ រូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវបញ្ឈប់សកម្មភាពដែលពាក់ព័ន្ធទៅនឹងគ្រោះថ្នាក់ ហើយធ្វើការជូនដំណឹងភ្លាមៗដល់អាជ្ញាធពាក់ព័ន្ធ និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវចាត់វិធានការ ស្របតាមផែនការទប់ស្កាត់ និងឆ្លើយតបក្នុងករណីសង្គ្រោះបន្ទាន់ ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថាន ។

រូបវន្តបុគ្គល និងនីតិបុគ្គលដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងគ្រោះថ្នាក់ ត្រូវជូនដំណឹងជាបន្ទាន់ទៅដល់សាធារណជនក្នុងតំបន់ ដែលអាចទទួលរងនូវការប៉ះពាល់ដោយគ្រោះថ្នាក់នៃហានិភ័យទៅដល់សុខភាព ទ្រព្យសម្បត្តិ ឬបរិស្ថាន ហើយត្រូវធ្វើការណែនាំដល់សាធារណជនអំពីវិធានការកាត់បន្ថយហានិភ័យទាំងនោះ ។

## មាតិកាទី ៤
## ការគ្រប់គ្រងសំណល់
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៧៣៩** ._ វិសាលភាពនៃការអនុវត្ត

មាតិកានេះ មានវិសាលភាពទៅលើ សំណល់គ្រោះថ្នាក់ និងសំណល់រឹងទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា និងមានវិសាលភាពទៅលើរូបវន្តបុគ្គល នីតិបុគ្គល និងក្រសួង ស្ថាប័ន ដែលបង្កើត កាន់កាប់ ដឹកជញ្ជូន គ្រប់គ្រង ស្តុក ធ្វើប្រព្រឹត្តកម្ម បោះបង់ចោល ទាញយក ឬកែច្នៃសំណល់គ្រោះថ្នាក់ និងសំណល់រឹង ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៧៤០** ._ ប្រភពនៃសំណល់គ្រោះថ្នាក់ និងសំណល់រឹង

ប្រភពនៃសំណល់ មានជាអាទិ៍ លំនៅឋាន ទីផ្សារ ផ្សារទំនើប កន្លែងកំសាន្ត អគារសាធារណៈ គ្រឹះស្ថានអប់រំ សកម្មភាពអាជីវកម្មសាធារណៈនិងឯកជន សេវាកម្ម សិប្បកម្ម គ្រឿងបរិក្ខាររោងចក្រ និងផលិត សកម្មភាពកសិកម្ម និងសកម្មភាពអាជីវកម្មរ៉ែ ។

**មាត្រា៧៤១** ._ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងស្របតាមលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន មានតួនាទី និងការទទួលខុសត្រូវលើការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ដូចខាងក្រោម៖

ក- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធនានា ។

ខ- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលរួមមាន អាជ្ញាធរនៅថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវលើការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ។

គ- បញ្ជាក់ និងប្រគល់សិទ្ធិអំណាចដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលរួមមាន អាជ្ញាធរនៅថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវ លើការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង។

ឃ- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារៈ សម្រាប់គាំទ្រដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលរួមមាន អាជ្ញាធរនៅថ្នាក់ក្រោមជាតិលើការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ។

ង- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលរួមមានអាជ្ញាធរនៅថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុង និងក្រៅប្រព័ន្ធ និងការយល់ដឹងអំពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និង សំណល់រឹង ប្រកបដោយសុវត្ថិភាពបរិស្ថាន និងអំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំណល់ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំណល់ ។

ច- តាមដានត្រួតពិនិត្យ ធ្វើអធិការកិច្ច និងវាយតម្លៃក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលរួមមានអាជ្ញាធរនៅថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវលើការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ។

**មាត្រា៧៤២** ._ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ

រាជរដ្ឋាភិបាលកម្ពុជា ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីភារកិច្ច និងតួនាទី របស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និង អាជ្ញាធរនៅថ្នាក់ក្រោមជាតិ នៅក្នុងការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ និងសំណល់រឹង ។

**មាត្រា៧៤៣** ._ ការទទួលខុសត្រូវលើការខូចខាត

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កើតសំណល់គ្រោះថ្នាក់ និងសំណល់រឹង ត្រូវទទួលខុស ត្រូវលើការខូចខាតទៅដល់សុខភាពមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថាន ដែលបង្កសំណល់គ្រោះថ្នាក់ និងសំណល់រឹងនោះ ។

## ជំពូកទី ២
## ការធ្វើចំណាត់ថ្នាក់សំណល់

**មាត្រា៧៤៤** ._ ការធ្វើចំណាត់ថ្នាក់សំណល់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីធ្វើចំណាត់ថ្នាក់សំណល់ ក្នុងរយៈពេល ១៨ (ដប់ប្រាំបី) ខែ បន្ទាប់ពីការអនុម័តនៃក្រមនេះ ។

**មាត្រា៧៤៥** ._ ការពិនិត្យ និងការធ្វើបច្ចុប្បន្នភាពនៃការធ្វើចំណាត់ថ្នាក់សំណល់

លិខិតបទដ្ឋានគតិយុត្ត ដែលធ្វើចំណាត់ថ្នាក់សំណល់គ្រោះថ្នាក់ និងសំណល់រឹងនោះ ត្រូវពិនិត្យ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់៥ (ប្រាំ) ឆ្នាំម្តង ។

## ជំពូកទី៣
## ការគ្រប់គ្រងសំណល់គ្រោះថ្នាក់

**មាត្រា៧៤៦ ._** ការគ្រប់គ្រង និងការត្រួតពិនិត្យសំណល់គ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ចាប់តាំងពីដំណាក់កាលនៃការបង្កើតសំណល់រហូតដល់ដំណាក់កាលនៃការបោះបង់ចោល ឬការធ្វើប្រព្រឹត្តកម្ម ។

**មាត្រា៧៤៧ ._** កាតព្វកិច្ចក្នុងការការស្តុកទុក ការគ្រប់គ្រង និងការបោះបង់ចោលសំណល់ គ្រោះថ្នាក់

បុគ្គលទាំងឡាយណាដែលបង្កើតសំណល់គ្រោះថ្នាក់ ត្រូវទទួលខុសត្រូវ លើការស្តុកទុក ការគ្រប់គ្រង និងការបោះបង់ចោលសំណល់ គ្រោះថ្នាក់របស់ខ្លួន ស្របតាមនីតិវិធីដែលមានចែងនៅក្នុងមាតិកានេះ ។

បុគ្គលទាំងឡាយដែលបង្កើតសំណល់ ត្រូវទទួលខុសត្រូវក្នុងបង់ថ្លៃសម្រាប់ការប្រមូល និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ផងដែរ ។

## ជំពូកទី៤
## ការគ្រប់គ្រងសំណល់រឹង

**មាត្រា៧៤៨ ._** ផែនការជាតិជាយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងសំណល់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវបង្កើតផែនការជាតិជាយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងសំណល់ ដែលផ្តោតទៅលើការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំណល់ ស្របទៅតាមបទប្បញ្ញត្តិនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ នៅក្នុងគន្ថីទី២ មាតិកាទី២ នៃក្រមនេះ ។

**មាត្រា៧៤៩ ._** ការអនុវត្តផែនការជាតិជាយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងសំណល់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុវត្តផែនការជាតិជាយុទ្ធសាស្ត្រស្តីពីគ្រប់គ្រងសំណល់ ។

**មាត្រា៧៥០ ._** ផែនការទៅតាមវិស័យដាច់ដោយឡែក

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីរៀបចំបង្កើតផែនការគ្រប់គ្រងសំណល់តាមវិស័យដាច់ដោយឡែក សម្រាប់ប្រភេទសំណល់នីមួយៗ ស្របតាមផែនការជាតិជាយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងសំណល់ ។

ផែនការគ្រប់គ្រងសំណល់តាមវិស័យដាច់ដោយឡែក សម្រាប់ប្រភេទសំណល់នីមួយៗ ត្រូវបញ្ចូលគោលដៅសម្រាប់ការកាត់បន្ថយវឌ្ឍនភាពនៃទំហំសំណល់ និងវិធានការនៃការកាត់បន្ថយ ការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំណល់ ។

**មាត្រា៧៥១** ._ ការអនុវត្តផែនការទៅតាមវិស័យដាច់ដោយឡែក

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុវត្តផែនការគ្រប់គ្រងសំណល់តាមវិស័យដាច់ដោយឡែកនីមួយៗ ។

**មាត្រា៧៥២** ._ ការពិនិត្យ និងការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងសំណល់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវពិនិត្យ និងធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងសំណល់ទាំងអស់ ជារៀងរាល់១០ (ដប់) ឆ្នាំម្តង ។

## មាតិកាទី៥
## ការត្រួតពិនិត្យការបំពុលទឹក
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៧៥៣** ._ វិសាលភាពនៃការអនុវត្ត

មាតិកានេះ មានវិសាលភាពអនុវត្តទៅលើការបញ្ចេញសារធាតុបំពុលដោយប្រភពជាក់ លាក់ទៅក្នុងធនធានទឹកលើដី ឬធនធានទឹកក្រោមដី និងសកម្មភាពប្រើប្រាស់ដីធ្លីទាំងឡាយ ដែល បង្កើតឲ្យមានការបំពុលទឹកដោយប្រភពមិនជាក់លាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងការបំពុលទឹកដោយប្រភពជាក់លាក់ និងប្រភពមិនជាក់លាក់ ។

**មាត្រា៧៥៤** ._ ការទទួលខុសត្រូវលើការខូចខាត

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបញ្ចេញសារធាតុបំពុលដោយប្រភពជាក់លាក់ ទៅក្នុងធន ធានទឹកលើដី ឬធនធានទឹកក្រោមដី ឬធ្វើសកម្មភាពប្រើប្រាស់ដីធ្លីទាំងឡាយ ដែលបង្កើតឲ្យមាន ការ

បំពុលទឹកដោយប្រភពមិនជាក់លាក់ ត្រូវទទួលខុសត្រូវលើការខូចខាតទៅដល់សុខភាពមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថាន ដែលបង្កដោយការបំពុលដោយប្រភពជាក់ជាក់ ឬប្រភពមិនជាក់លាក់នោះ ។

## ជំពូកទី២
## ការត្រួតពិនិត្យប្រភពបំពុលទឹកជាក់លាក់

**មាត្រា៧៥៥** ._ ការហាមឃាត់ការបញ្ចេញសារធាតុបំពុលដោយប្រភពបំពុលជាក់លាក់

រាល់ការបញ្ចេញសារធាតុបំពុលដោយប្រភពជាក់លាក់ទៅក្នុងធនធានទឹកលើដី ឬធនធានទឹកក្រោមដី ត្រូវបានហាមឃាត់ លើកលែងតែស្របតាមមាតិកានេះ ។

**មាត្រា៧៥៦** ._ ការទទួលខុសត្រូវចំពោះការធ្វើប្រព្រឹត្តកម្ម និងការបញ្ចេញ

ម្ចាស់កម្មសិទ្ធិ និងប្រតិបត្តិករនៃប្រភពបំពុលជាក់លាក់ ត្រូវទទួលខុសត្រូវចំពោះការបញ្ចេញសារធាតុបំពុល និងកិច្ចប្រតិបត្តិការនៃការធ្វើប្រព្រឹត្តកម្មទាំងឡាយណា មុនពេលបញ្ចេញសារធាតុបំពុលទាំងនោះពីប្រភពជាក់លាក់នោះ ។

**មាត្រា៧៥៧** ._ លិខិតអនុញ្ញាតក្នុងការបញ្ចេញ

ប្រភពជាក់លាក់ អាចបញ្ចេញសារធាតុបំពុលទៅក្នុងធនធានទឹកលើដី ឬធនធានទឹកក្រោមដី ដោយអនុលោមទៅតាមលិខិតអនុញ្ញាត ដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន សម្រាប់ប្រភពជាក់លាក់នោះ ។

លិខិតអនុញ្ញាតដែលត្រូវចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ៖

ក- ត្រូវចែងពីដែនកំណត់ និង/ឬ លក្ខខណ្ឌតម្រូវក្នុងការត្រួតពិនិត្យ ស្របតាម មាតិកានេះ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធ ។

ខ- អាចចែងពីដែនកំណត់ និង/ឬ លក្ខខណ្ឌតម្រូវបន្ថែមទៀតក្នុងការត្រួតពិនិត្យបញ្ចេញសារធាតុបំពុលពីប្រភពជាក់លាក់ ដើម្បីការពារគុណភាពទឹកលើដី ឬក្រោមដី ដែលទទួលសារធាតុបំពុល និង/ឬ ប្រព័ន្ធអេកូឡូស៊ី និងទឹកនៅតាមខ្សែទឹកផ្សេងទៀត ដែលអាចរងផលប៉ះពាល់ដោយការបញ្ចេញ ដែលរួមមានទឹកសមុទ្រទាំងឡាយ ។

គ- ត្រូវចែងពីលក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន និងការរៀបចំរបាយការណ៍ ដែលរួមមាន៖

១- ការអង្កេតតាមដានបរិមាណ គុណភាព ពេលវេលា និងរយៈពេល នៃការបញ្ចេញ ។

២- ការអង្កេតតាមដានគុណភាពទឹកដែលទទួលសារធាតុបំពុល និងទឹកនៅតាមខ្សែទឹកផ្សេងទៀតដែលរងផលប៉ះពាល់ដោយការបញ្ចេញ ដែលរួមមានទឹកសមុទ្រ និង/ឬ ទឹកឆ្លងដែន ។

៣- ការរក្សាទុកកំណត់ត្រា និងការរៀបចំធ្វើរបាយការណ៍អំពីព័ត៌មាននៃការអង្កេតតាមដាន ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

៤- សូចនករទាំងឡាយសម្រាប់គោលដៅនៃការអង្កេតតាមដាន ។

ឃ- ត្រូវមានសុពលភាពក្នុងរយៈពេល១ (មួយ)ឆ្នាំ ប្រសិនបើមិនមានការកំណត់ ដទៃទៀតនៅក្នុងលិខិតអនុញ្ញាត ។

ង- អាចត្រូវបានកែសម្រួល ឬលុបចោលនៅពេលណាមួយក៏បាន តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដែលរួមមានហេតុផលសម្រាប់ការធ្វើការសម្រេចចិត្ត ទៅកាន់ម្ចាស់ និងប្រតិបត្តិករនៃប្រភពជាក់លាក់ដែលកាន់លិខិតអនុញ្ញាតដោយ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៧៥៨** ._ លក្ខខណ្ឌបន្ថែម

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាចបង្កើត៖

ក- នីតិវិធីក្នុងការដាក់ពាក្យសុំ និងការធ្វើសារជាថ្មីនៃលិខិតអនុញ្ញាត ។

ខ- សោហ៊ុយសម្រាប់លិខិតអនុញ្ញាតដែលបានស្នើសុំ ដែលបានចេញ និង/ឬ ដែលបានធ្វើសារជាថ្មី ។

គ- ក្រមិត ឬលក្ខខណ្ឌស្តង់ដារ ដើម្បីត្រួតពិនិត្យការបញ្ចេញ ដែលប្រើប្រាស់កម្រិតកំហាប់ និង/ឬ កម្រិតនៃផ្ទុកសារធាតុបំពុលចេញពីប្រភពជាក់លាក់ និងផ្អែកលើបច្ចេកវិទ្យាដ៏ប្រសើរបំផុត និងទម្លាប់នៃការគ្រប់គ្រប់បរិស្ថានដែលល្អបំផុត ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច ស្របតាមបទប្បញ្ញត្តិស្តីពីស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ នៅក្នុងមាតិកាទី២ នៃគន្ថីនេះ ។

## ជំពូកទី៣
## ការត្រួតពិនិត្យប្រភពបំពុលទឹកមិនជាក់លាក់

**មាត្រា៧៥៩** ._ ការទទួលខុសត្រូវចំពោះទម្លាប់នៃការគ្រប់គ្រងដ៏ប្រសើរបំផុត

សកម្មភាពនៃការប្រើប្រាស់ដីធ្លីទាំងឡាយណាដែលបង្កើតឲ្យមានការបំពុលពីប្រភពមិនជាក់លាក់ ត្រូវអនុវត្តទម្លាប់នៃការគ្រប់គ្រងដ៏ប្រសើរបំផុតដែលពាក់ព័ន្ធ ។

**មាត្រា៧៦០ .**_ ប្រភេទនៃប្រភពបំពុលមិនជាក់លាក់ និងទម្លាប់នៃការគ្រប់គ្រងដ៏ប្រសើរបំផុត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ស្តីពីប្រភេទនៃប្រភពបំពុលមិនជាក់លាក់ និងទម្លាប់នៃការគ្រប់គ្រងដ៏ប្រសើរបំផុត ដើម្បីកាត់បន្ថយការបំពុលទឹកសម្រាប់ប្រភេទនីមួយៗ ។

## ជំពូកទី ៤
## ការអង្កេតតាមដានប្រភពបំពុលទឹកជាក់លាក់

**មាត្រា៧៦១ .**_ ការទទួលខុសត្រូវក្នុងការអង្កេតតាមដានលិខិតអនុញ្ញាតក្នុងការបញ្ចេញរបស់ប្រភពជាក់លាក់

ការអង្កេតតាមដានលិខិតអនុញ្ញាតក្នុងការបញ្ចេញរបស់ប្រភពជាក់លាក់ត្រូវ និងការអនុលោមតាមកម្រិត លក្ខខណ្ឌតម្រូវក្នុងការត្រួតពិនិត្យ និងលក្ខខណ្ឌនៃលិខិតអនុញ្ញាតនោះ ជាការទទួលខុសត្រូវរបស់ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពជាក់លាក់ ដែលបានចេញលិខិតអនុញ្ញាតដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៧៦២ .**_ វិញ្ញាបនបត្របញ្ជាក់ពីការវិភាគលើសំណាក និងការអង្កេតតាមដាន

ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពជាក់លាក់ ដែលបានចេញលិខិតអនុញ្ញាតដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបញ្ជាក់ថាការជ្រើសរើសសំណាកយកមកវិភាគ និងការអង្កេតតាមដានត្រូវបានធ្វើឡើង ស្របតាមលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាត និងលក្ខខណ្ឌផ្សេងៗទៀត ដែលបានកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៧៦៣ .**_ លក្ខខណ្ឌតម្រូវក្នុងការជូនដំណឹង

ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពជាក់លាក់ ដែលបានចេញលិខិតអនុញ្ញាតដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្នុងករណីបានកើតឡើង ដូចខាងក្រោម៖

ក. ការរំលោភបំពានទៅលើដែនកំណត់នៃលិខិតអនុញ្ញាត ឬលក្ខខណ្ឌតម្រូវក្នុងការត្រួតពិនិត្យ ទោះដោយ ចេតនា ឬយ៉ាងណាក្តី ។

ខ. ភាពមិនប្រក្រតីចំពោះឧបករណ៍វិភាគលើសំណាក ឬលទ្ធផលនៃការវិភាគលើសំណាក ។

គ. ការខកខានរបស់ឧបករណ៍ត្រួតពិនិត្យការបំពុល ។

**មាត្រា៧៦៤** ._ បទបញ្ជាឲ្យមានការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចតាមដាន និង/ឬ បញ្ជាអង្គភាពណាមួយ ឲ្យធ្វើការអង្កេតតាមដានការបញ្ចេញរាល់សារធាតុបំពុលពីប្រភពជាក់លាក់ណាមួយ ទៅក្នុងធនធានទឹកលើដី ឬធនធានទឹកក្រោមដី តាមរយៈការជូនដំណឹងទៅកាន់ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពជាក់លាក់ ដែលបានចេញលិខិតអនុញ្ញាតដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននោះ ។

**មាត្រា៧៦៥** ._ ការអង្កេតតាមដានទឹកលើដី និងទឹកក្រោមដី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចអង្កេតតាមដានគុណភាពទឹកនៃទឹកលើដី ឬទឹកក្រោមដីណាមួយក៏បាន ។

**មាត្រា៧៦៦** ._ សំណាកសម្រាប់ការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចទទួល និងពិចារណាទៅលើសំណាកដែលយកចេញមកពីប្រភពទឹកក្រោមដី ឬប្រភពទឹករបស់បុគ្គលណាមួយ ។

**មាត្រា៧៦៧** ._ ការវិភាគនៃលើសំណាកសម្រាប់ការអង្កេតតាមដាន

រាល់សំណាកសម្រាប់ការអង្កេតតាមដានទាំងអស់ ត្រូវបានវិភាគដោយមន្ទីរពិសោធន៍របស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬមន្ទីរពិសោធន៍ផ្សេងទៀត ដែលមានការទទួលស្គាល់ពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

## ជំពូកទី៥
## ការធ្វើប្រព្រឹត្តកម្ម និងការប្រើប្រាស់ឡើងវិញនូវទឹកកខ្វក់ និងសំណល់

**មាត្រា៧៦៨** ._ សំណល់ភក់ និងជីវសំណល់រឹង

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតនូវ លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណល់ភក់ ឬជីវៈសំណល់រឹង មានជាអាទិ៍៖

ក- លិខិតបទដ្ឋានគតិយុត្តដើម្បីលើកទឹកចិត្តចំពោះការប្រើប្រាស់សំណល់ភក់ ឬជីវៈសំណល់រឹង ។

ខ- លិខិតបទដ្ឋានគតិយុត្តសម្រាប់ការប្រើប្រាស់សំណល់ភក់ ឬជីវៈសំណល់រឹងប្រកបដោយការទទួលខុសត្រូវ និងសុវត្ថិភាព ។

គ- ស្តង់ដារអប្បបរមាសម្រាប់កម្រិតនៃការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ និង/ឬ វិធីសាស្ត្រក្នុងការប្រើប្រាស់សំណល់ភក់ និងជីវសំណល់រឹង ។

ឃ- គ្រឿងលើកទឹកចិត្តចំពោះការប្រើប្រាស់សំណល់ភក់ និងជីវៈសំណល់រឹងក្នុងវិស័យកសិកម្ម ។

ង- គ្រឿងលើកទឹកចិត្តចំពោះការប្រើប្រាស់សំណល់ភក់ និងជីវៈសំណល់រឹងក្នុងការផលិតថាមពល ។

**មាត្រា៧៦៩ ._** ការប្រើប្រាស់ទឹកឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតនូវលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ទឹកឡើងវិញ មានជាអាទ៍៖

ក- លិខិតបទដ្ឋានគតិយុត្តដើម្បីលើកទឹកចិត្តចំពោះការប្រើប្រាស់ឡើងវិញនូវទឹកកខ្វក់ដែលបានធ្វើប្រព្រឹត្តកម្មរួច ។

ខ- លិខិតបទដ្ឋានគតិយុត្តសម្រាប់ការប្រើប្រាស់ឡើងវិញនូវទឹកកខ្វក់ដែលបានធ្វើប្រព្រឹត្តកម្មរួច ប្រកបដោយការទទួលខុសត្រូវ និងសុវត្ថិភាព ។

គ- កាតព្វកិច្ចរបស់ប្រតិបត្តិករនៃបរិក្ខារប្រព្រឹត្តកម្មទឹកកខ្វក់ ។

ឃ- កាតព្វកិច្ចរបស់ប្រតិបត្តិករនៃប្រព័ន្ធចែកចាយទឹក ។

ង- ការអនុវត្តចំពោះការប្រើប្រាស់ទឹកកខ្វក់ឡើងវិញ។

ច- ស្តង់ដារអប្បបរមាសម្រាប់កម្រិតនៃការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ វិធីសាស្ត្រ និងការចែកចាយសម្រាប់ការអនុវត្ត ការប្រើប្រាស់សារទឹកកខ្វក់ឡើងវិញ ស្របតាមបទប្បញ្ញត្តិស្តីពីស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ ក្នុងមាតិកាទី២ នៃគន្ថីនេះ ។

ជ- គ្រឿងលើកទឹកចិត្តចំពោះការប្រើប្រាស់ទឹកកខ្វក់ឡើងវិញ។

## ជំពូកទី៦
## ការផ្តល់វិញ្ញាបនបត្រនៃប្រតិបត្តិករ

**មាត្រា៧៧០ ._** លក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់ឲ្យនូវវិញ្ញាបនបត្រ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ស្តីពី លក្ខណៈវិនិច្ឆ័យ និង/ឬកម្រិតនៃការផ្តល់ឲ្យនូវវិញ្ញាបនបត្រ សម្រាប់ប្រតិបត្តិករនៃប្រភពជាក់លាក់ ។

## ជំពូកទី៧
## ការត្រួតពិនិត្យការបំពុលសមុទ្រ

**មាត្រា៧៧១** ._ វិសាលភាពនៃការអនុវត្ត

មាតិកានេះ មានវិសាលភាពអនុវត្តទៅលើប្រភពបំពុលទាំងឡាយណាដែលធ្វើសកម្មភាពលើទឹកសមុទ្រ ក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៧៧២** ._ ការត្រួតពិនិត្យការបំពុលសមុទ្រ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពី ការត្រួតពិនិត្យការបំពុលសមុទ្រ មានជាអាទិ៍ លក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន ការវាយតម្លៃ និងការរៀបចំរបាយការណ៍ ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលទាក់ទងនឹងការត្រួតពិនិត្យការបំពុលសមុទ្រ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

**មាត្រា៧៧៣** ._ ការបំពុលពីនាវា

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តបន្ថែមស្តីពី ការទប់ស្កាត់ និងការកាត់បន្ថយការបំពុលពីនាវា ដែលកើតចេញពីប្រតិបត្តិការដោយឧបទ្ទវហេតុ និង ប្រតិបត្តិការប្រចាំថ្ងៃក្តី។

## មាតិកាទី៦
## ការត្រួតពិនិត្យការបំពុលខ្យល់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៧៧៤** ._ វិសាលភាពនៃការអនុវត្ត

មាតិកានេះមានវិសាលភាពអនុវត្តចំពោះគ្រប់ប្រភពចល័ត និងអចល័ត នៃការបំពុលខ្យល់ទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែប្រភពតូចតាច ឬតិចតួច ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងការបំពុលខ្យល់។

**មាត្រា៧៧៥** ._ការទទួលខុសត្រូវលើការខូចខាត

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កឲ្យមានការបំពុលខ្យល់ពីប្រភពចល័ត ឬអចល័ត ត្រូវទទួលខុសត្រូវលើការខូចខាតទៅដល់សុខភាពមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថាន ដែលបង្ក មានការបំពុលខ្យល់ពីប្រភពចល័ត ឬអចល័តនោះ ។

**មាត្រា៧៧៦** ._ ស្តង់ដារគុណភាពខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន បង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពី ង់ដារគុណភាពខ្យល់ នៅក្នុងរយៈពេល១ (មួយ) ឆ្នាំ ក្រោយការអនុម័តនៃក្រមនេះ ។

លិខិតបទដ្ឋានគតិយុត្តស្តីពីការបង្កើតស្តង់ដារគុណភាពខ្យល់ ត្រូវរួមបញ្ចូល ៖

ក- ស្តង់ដារគុណភាពខ្យល់ជុំវិញ ដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន បានកំណត់ ផ្អែកលើព័ត៌មានផ្នែកវិទ្យាសាស្ត្រដែកអាចស្វែងរកបាន និងប្រសើរបំផុត និងមានលក្ខណៈគ្រប់គ្រាន់ ដើម្បីការពារបរិស្ថាន ។

ខ- ស្តង់ដារសម្រាប់ការបញ្ចេញ ឬការបំភាយនៃសារធាតុបំពុលខ្យល់ ដែលត្រូវបានរចនាឡើងដើម្បីសម្រេចបាននូវស្តង់ដារគុណភាពខ្យល់ជុំវិញ ។

គ- និយមន័យ និងបញ្ជីនៃប្រភពបំពុលតូចតាច ឬតិចតួច ដែលលើកលែង ។

ឃ- លិខិបទដ្ឋានគតិយុត្តសម្រាប់ការកាត់បន្ថយការបំពុលខ្យល់ក្នុងអគារផ្សេងៗ ។

**មាត្រា៧៧៧** ._ ការត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើស្តង់ដារគុណភាពខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវពិនិត្យ និងធ្វើបច្ចុប្បន្នភាពនូវលិខិតបទដ្ឋានគតិយុត្ត ស្តីពីស្តង់ដារគុណភាពខ្យល់ ជារៀងរាល់១០(ដប់)ឆ្នាំម្តង ស្របតាមបទប្បញ្ញត្តិ ស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន នៅក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៧៧៨** ._ ការអភិវឌ្ឍ បច្ចេកវិទ្យាដើម្បីកាត់បន្ថយ និងទប់ស្កាត់ការបំពុលខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវលើកកម្ពស់ និងគាំទ្រការស្រាវជ្រាវ ដើម្បីអភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាកាត់បន្ថយ និងទប់ស្កាត់ការបំពុលខ្យល់ពីប្រភពចល័ត និងអចល័ត ។

## ជំពូកទី២
## ការបំពុលខ្យល់ពីប្រភពចល័ត

**មាត្រា៧៧៩** ._ ការហាមឃាត់ចំពោះការបញ្ចេញសារធាតុបំពុលខ្យល់

ការបញ្ចេញនូវសារធាតុបំពុលខ្យល់ ដោយប្រភពចល័តណាមួយទៅក្នុងបរិយាកាស ត្រូវបានហាមឃាត់ លើកលែងតែស្របតាមមាតិកានេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវបង្កើតស្តង់ដារគុណភាពខ្យល់ចំពោះកម្រិតអប្បបរមានៃសារធាតុបំពុលខ្យល់ ដែលអនុញ្ញាតឲ្យបញ្ចេញដោយប្រភពចល័ត ។

**មាត្រា៧៨០** ._ ការហាមឃាត់ចំពោះការបញ្ចេញសារធាតុបំពុលដែលលើសពីស្តង់ដារ

ត្រូវហាមឃាត់ សម្រាប់ប្រភពចល័តណាមួយក្នុងការបញ្ចេញសារធាតុបំពុលខ្យល់ លើសពីស្តង់ដារដែលពាក់ព័ន្ធ ។

**មាត្រា៧៨១** ._ ការហាមឃាត់ចំពោះការនាំចូល ការប្រើប្រាស់ និងការផលិតនៃប្រភពអចល័ត ដែលលើសពីស្តង់ដារ

ត្រូវហាមឃាត់ ចំពោះការនាំចូល ការប្រើប្រាស់ និងការផលិតនូវ យានយន្ត និងគ្រឿងចក្រដែលបញ្ចេញសារធាតុបំពុលខ្យល់លើសពីស្តង់ដារអនុញ្ញាត ។

**មាត្រា៧៨២** ._ លិខិតបទដ្ឋានគតិយុត្តស្តីពីប្រេងឥន្ធនៈ និងសារធាតុបន្ថែមជាមួយប្រេងឥន្ធនៈ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីប្រេងឥន្ធនៈ ឬសារធាតុបន្ថែមជាមួយប្រេងឥន្ធនៈ ដើម្បីគ្រប់គ្រងទៅលើប្រេងឥន្ធនៈ ឬ សារធាតុបន្ថែមជាមួយឥន្ធនៈណាមួយ ដែលអ្នកផលិត ឬ អ្នកកែច្នៃប្រេងឥន្ធនៈ ឬសារធាតុបន្ថែមជាមួយប្រេងឥន្ធនៈ អាចលក់ ឬស្នើលក់ ឬ ណែនាំឲ្យប្រើប្រាស់នៅក្នុងពាណិជ្ជកម្ម ។ លិខិតបទដ្ឋានគតិយុត្ត ត្រូវរួមមានដូចខាងក្រោម៖

ក- លក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជីប្រេងឥន្ធនៈ ឬសារធាតុបន្ថែមជាមួយប្រេងឥន្ធនៈ ដើម្បីកំណត់ថា ប្រេងឥន្ធនៈ ឬសារធាតុបន្ថែមជាមួយឥន្ធនៈនោះ មិនបង្កើតឲ្យមានការបញ្ចេញ ឬការបំភាយ ដែលនឹងធ្វើឲ្យគ្រោះថ្នាក់ចំពោះបរិស្ថាន ។

ខ- ប្រេងឥន្ធនៈ ឬសារធាតុបន្ថែមជាមួយប្រេងឥន្ធនៈ ដែលបានប្រើប្រាស់នៅក្នុងប្រភពចល័តដែលក្រៅពីផ្លូវ ដែលត្រូវបានហាមឃាត់មិនឲ្យលក់ ធ្វើការស្នើលក់ ឬ ណែនាំឲ្យប្រើប្រាស់ក្នុងពាណិជ្ជកម្ម ដោយផ្អែកលើព័ត៌មានផ្នែកវិទ្យាសាស្ត្រ ដែលអាចស្វែងរកបាន និងប្រសើរបំផុត ។

គ- លក្ខខណ្ឌត្រូវក្នុងការលើកលែងការហាមឃាត់ជាបណ្តោះអាសន្នទាក់ទងនឹងការប្រើប្រាស់ប្រេងឥន្ធនៈ ឬសារធាតុបន្ថែមជាមួយឥន្ធនៈ ដែលអាចបណ្តាលមកពីករណីនៃគ្រោះ

មហន្ត រាយធម្មជាតិ ការខូចខាតនូវបំពង់ឧស្ម័ន ឬឧបករណ៍ចម្រាញ់ ឬព្រឹត្តិការណ៍ផ្សេងទៀត ដែលមិនអាចព្យាករណ៍ ឬទប់ស្កាត់បាន និងមិនមែនកើតឡើងដោយសារកង្វះខាតនូវ ការរៀបចំផែនការដោយប្រុងប្រយ័ត្នរបស់អ្នកផ្គត់ផ្គង់ប្រេងឥន្ធនៈ ឬសារធាតុបន្ថែមជាមួយ ឥន្ធនៈទៅខេត្ត ឬតំបន់ណាមួយនោះទេ ។

ឃ- កំហាប់អតិបរមា ដែលប្រេងឥន្ធនៈ ឬសារធាតុបន្ថែមជាមួយប្រេងឥន្ធនៈ ដែលបានប្រើប្រាស់នៅក្នុងប្រភពចល័ត ដែលក្រៅពីផ្លូវ ដែលត្រូវអនុញ្ញាតឲ្យលក់ ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ង- កំហាប់អតិបរមា ឬ អត្រានៃការបំភាយនីត្រូសែនអុកស៊ីត សមាសភាគសរីរាង្គ មិនស្ថិតស្ថេរ និងសារធាតុបំពុលខ្យល់ដទៃទៀត ដែលអាចបំភាយដោយប្រភពចល័ត ។

ច- លក្ខខណ្ឌតម្រូវចំពោះចំណុះស្តាន់ដ័រអតិបរមា សម្រាប់ឥន្ធនៈម៉ាស៊ូត ដែលរួមបញ្ចូលឥន្ធនៈម៉ាស៊ូត ដែលត្រូវបានប្រើប្រាស់សម្រាប់ប្រភពចល័តក្រៅពីផ្លូវផងដែរ ។

**មាត្រា៧៨៣** ._ កម្មវិធីទិញយកយានយន្តវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីកម្មវិធី ដើម្បីលើកកម្ពស់ខ្យល់ស្អាត តាមរយៈការទិញយានយន្តចាស់ៗពីប្រជាពលរដ្ឋ ។ កម្មវិធីនេះ ត្រូវផ្តល់នូវការលើកទឹកចិត្ត ជាសាច់ប្រាក់ ដើម្បីឲ្យឈប់ប្រើប្រាស់យានយន្តចាស់ៗដែលបំពុលខ្យល់ ។

ការលើកទឹកចិត្តជាសាច់ប្រាក់ មិនត្រូវផ្អែកលើតម្លៃទីផ្សារនៃយានយន្តឡើយ ប៉ុន្តែត្រូវផ្អែក លើយានយន្តដែលកំពុងដំណើរការ ឬអាចបើកបរបាន ចំនួនគីឡូម៉ែត្រដែលយានយន្តនោះបាន កត់ត្រា និងការខូចខាតជាចម្បងណាមួយចំពោះយានយន្តនោះ ។

## ជំពូកទី៣
## ការបំពុលខ្យល់ពីប្រភពអចល័ត

**មាត្រា៧៨៤** ._ ការហាមឃាត់ចំពោះការបញ្ចេញ ឬការបំភាយសារធាតុបំពុលខ្យល់

ការបញ្ចេញ ឬការបំភាយនូវសារធាតុបំពុលខ្យល់ណាមួយទៅក្នុងបរិយាកាស ដោយប្រភពអចល័ត ត្រូវបានហាមឃាត់ លើកលែងតែអនុលោមតាមលិខិតអនុញ្ញាត ដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ស្របតាមមាតិកានេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា៧៨៥** ._ ការទទួលខុសត្រូវរបស់ម្ចាស់ និងប្រតិបត្តិករ

ម្ចាស់ ឬ ប្រតិបត្តិករ ត្រូវទទួលខុសត្រូវចំពោះសារធាតុបំពុលខ្យល់ទាំងអស់ ដែលបញ្ចេញ ឬ បំភាយចូលទៅក្នុងបរិយាកាស ។

ម្ចាស់ ឬ ប្រតិបត្តិករ ត្រូវទទួលខុសត្រូវផងដែរ ចំពោះការអនុវត្តតាមតាមស្តង់ដារសម្រាប់ ការបញ្ចេញ ឬការបំភាយដែលកំណត់ដោយក្រសួងប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៧៨៦** ._ ស្តង់ដារសម្រាប់ការបញ្ចេញ ឬការបំភាយលក្ខណៈទូលាយតាមប្រភេទ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារ ស្តង់ដារសម្រាប់ការបញ្ចេញ ឬការបំភាយលក្ខណៈទូលាយតាមប្រភេទ ដោយផ្អែកលើបច្ចេកវិទ្យា ដែលអាចស្វែងរកបាន ប្រសើរបំផុត និងមានតម្លៃទាប ចំពោះប្រភេទប្រភពអចល័ត នៃ ការបំពុលខ្យល់ ។

**មាត្រា៧៨៧** ._ ស្តង់ដារសម្រាប់លិខិតអនុញ្ញាតចំពោះប្រភពថ្មី ឬដែលមានស្រាប់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវកំណត់នូវស្តង់ដារសម្រាប់ការបញ្ចេញ ឬ ការបំភាយសម្រាប់លិខិតអនុញ្ញាត ចំពោះការដាក់ពាក្យសុំពីម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពអចល័ត ថ្មី ឬ ដែលមានស្រាប់ នៃការបំពុលខ្យល់ ដូចតទៅ៖

ក- ចំពោះប្រភពអចល័តថ្មី ឬដែលមានស្រាប់ ដែលមានស្តង់ដារលក្ខណៈ ទូលាយតាមប្រភេទដែលពាក់ព័ន្ធរួចហើយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបញ្ចូលស្តង់ដារមួយនៅក្នុងលិខិតអនុញ្ញាត យ៉ាងហោចណាស់មានលក្ខណៈតឹងរ៉ឹងដូចស្តង់ដារលក្ខណៈទូលាយតាមប្រភេទនោះ លើកលែងតែមានចែងមាត្រា៧៨៨ ចំពោះប្រភពអចល័តដែលមានស្រាប់ ។

ខ- ចំពោះប្រភពអចល័តថ្មី ឬដែលមានស្រាប់ ដែលពុំមានស្តង់ដារលក្ខណៈទូលាយតាមប្រភេទដែលពាក់ព័ន្ធទេ ប៉ុន្តែក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន បានចេញ លិខិតអនុញ្ញាតរួចហើយសម្រាប់ប្រភពអចល័តថ្មីមួយក្នុងប្រភេទដូចគ្នា ដែលមានស្តង់ដារ មួយដោយផ្អែកលើបច្ចេកវិទ្យាដែលអាចស្វែងរកបាន ប្រសើរបំផុត និងមានតម្លៃទាប ក្រសួង ស្ថាប័ន ទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបញ្ចូលស្តង់ដារមួយ នៅក្នុងលិខិតអនុញ្ញាត យ៉ាងហោចណាស់មានលក្ខណៈតឹងរ៉ឹងដូចស្តង់ដារដែលមានក្នុង លិខិតអនុញ្ញាតលើកមុនដែរ ។

ក្នុងករណីណាក៏ដោយ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចប្រើប្រាស់ស្តង់ដារ មួយដែលតឹងរ៉ឹងជាងស្តង់ដារលក្ខណៈទូលាយតាមប្រភេទដែលពាក់ព័ន្ធណាមួយបាន នៅក្នុង លិខិតអនុញ្ញាត ប្រសិនបើក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន បានកំណត់ថា  ស្តង់ដារតឹងរ៉ឹងជាងមុននេះ មានភាពចាំបាច់ ដើម្បីសម្រេចបាននូវស្តង់ដារគុណភាពខ្យល់ជុំវិញ ដែលពាក់ព័ន្ធ ដោយផ្អែកលើព័ត៌មានផ្នែកវិទ្យាសាស្ត្រដែលអាចស្វែងរកបាន និងប្រសើរបំផុត។

**មាត្រា៧៨៨** ._ ការលើកលែងចំពោះប្រភពដែលមានស្រាប់

ម្ចាស់ ឬ ប្រតិបត្តិករ នៃប្រភពដែលមានស្រាប់ អាចដាក់ពាក្យសុំការលើកលែងពីស្តង់ដារលក្ខណៈទូលាយតាមប្រភេទដែលពាក់ព័ន្ធឬពីការកំណត់ពីមុននៅក្នុងលិខិតអនុញ្ញាតនៃ បច្ចេកវិទ្យា ដែលអាចស្វែងរកបាន ប្រសើរបំផុត និងមានតម្លៃទាប។ ម្ចាស់ ឬ ប្រតិបត្តិករ ត្រូវបង្ហាញថា ខ្លួនមានហេតុផលសមរម្យក្នុងការប្រើប្រាស់ស្តង់ដារដែលមានលក្ខណៈតឹងរ៉ឹងទាបជាងនេះ ពីព្រោះ បច្ចេកវិទ្យា ប្រសើរបំផុត និងមានតម្លៃទាប មិនអាចស្វែងរកបាន ឬមានតម្លៃខ្ពស់ពេក សម្រាប់ប្រភពបំពុលដែលមានស្រាប់ជាក់លាក់នោះ ។

ប្រសិនបើក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន កំណត់ថា មានហេតុផលសមរម្យក្នុង ការប្រើប្រាស់ស្តង់ដារដែលមានលក្ខណៈតឹងរ៉ឹងទាបជាងនេះ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យ បរិស្ថាន ត្រូវកំណត់ស្តង់ដារសម្រាប់ការលើកលែងមួយដែលទទួលបានការឯកភាព ដោយផ្អែកលើ បច្ចេកវិទ្យាដែលអាចស្វែងរកបាន ប្រសើរបំផុត និងមានតម្លៃ ទាប ដែលអាចធ្វើឡើងបាន សម្រាប់ប្រភពដែលមានស្រាប់ជាក់លាក់នោះ ។

## ជំពូកទី៤
## លិខិតអនុញ្ញាតក្នុងការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័ត

**មាត្រា៧៨៩** ._ ការដាក់ពាក្យសុំលិខិតអនុញ្ញាត

ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពអចល័តណាមួយក៏ដោយ ត្រូវដាក់ពាក្យទៅក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដើម្បីស្នើសុំការអនុញ្ញាតក្នុងការបញ្ចេញសារធាតុបំពុលខ្យល់ ទៅក្នុងបរិយាកាស ។ ក្រសួង ស្ថាប័ន ទទួលបន្ទុកវិស័យ បរិស្ថាន ត្រូវផ្ញើសំណៅថតចម្លងមួយច្បាប់នៃពាក្យសុំនេះ ទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

បន្ទាប់ពីទទួលបានពាក្យស្នើសុំ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវចេញលិខិតអនុញ្ញាត ស្របតាមមាត្រា៧៩៤ នៃក្រមនេះ ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យ បរិស្ថាន ត្រូវផ្ញើសំណៅមួយច្បាប់នៃលិខិតអនុញ្ញាតទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា៧៩០** ._ នីតិវិធីក្នុងការដាក់ពាក្យសុំលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីក្នុងការដាក់ពាក្យសុំ និងការដាក់ពាក្យសុំឡើង វិញ សម្រាប់លិខិតអនុញ្ញាតនៃប្រភពអចល័ត ស្របតាមបទ

ប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន នៅក្នុងគន្ថីទី១ មាតិកាទី២ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៧៩១** ._ លក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាត

លិខិតអនុញ្ញាតសម្រាប់ការបញ្ចេញសារធាតុបំពុលខ្យល់ដោយប្រភពអចល័ត ដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរួមមាន ដូចខាងក្រោម៖

ក- ស្តង់ដារសម្រាប់ការបញ្ចេញសារធាតុបំពុលខ្យល់ ដើម្បីសម្រេចបាននូវស្តង់ដារគុណភាពខ្យល់ជុំវិញដែលពាក់ព័ន្ធនិងត្រូវផ្អែកលើបច្ចេកវិទ្យាដែលអាចស្វែងរកបាន ប្រសើរបំផុត និងមានតម្លៃសេដ្ឋកិច្ចទាប ។

ខ- លក្ខខណ្ឌតម្រូវនានាសម្រាប់ការដំឡើង និងប្រតិបត្តិការនៃប្រព័ន្ធ ឬយន្តការ ក្នុងការអង្កេតតាមដាន ការបញ្ចេញសារធាតុបំពុលខ្យល់ ។

គ- លក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំរបាយការណ៍អំពីលទ្ធផលនៃការអង្កេត តាមដានទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន យ៉ាងហោចណាស់ ជារៀងរាល់៦ (ប្រាំមួយ) ខែ ម្តង ស្របតាមបទប្បញ្ញត្តិនានា នៅក្នុងគន្ថីទី៣ មាតិកាទី៤ នៃក្រមនេះ ។ របាយការណ៍ស្តីពីការអង្កេតតាមដាន ត្រូវកត់ត្រាករណី ណាមួយ ឬរាល់ករណីទាំងអស់ដែលការបញ្ចេញសារធាតុបំពុលខ្យល់ លើសពីស្តង់ដារ កំណត់ ដែលមានចែងយ៉ាងច្បាស់លាស់នៅក្នុងលិខិតអនុញ្ញាតដែលពាក់ព័ន្ធ ។ របាយការណ៍ស្តីពីការអង្កេតតាមដានទាំងអស់ ត្រូវចុះហត្ថលេខា និងបញ្ជាក់ដោយ មន្ត្រីទទួលខុសត្រូវនៃម្ចាស់ ឬប្រតិបត្តិករ ។

ឃ- លក្ខខណ្ឌតម្រូវសម្រាប់ការ រក្សាទុកនូវកំណត់ត្រានៃលទ្ធផលនៃការអង្កេតតាមដានការបញ្ចេញសារធាតុបំពុលខ្យល់ និងរបាយការណ៍ស្តីពីការអង្កេតតាមដានទាំងឡាយណាដែលត្រូវដាក់ជូន ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដែលរួមមានព័ត៌មានដែលប្រើប្រាស់ សម្រាប់រៀបចំរបាយការណ៍ទាំងនោះ សម្រាប់រយៈពេលជាអប្បបរមាចំនួន៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលបានទទួលលទ្ធផលនៃការអង្កេតតាមដាន និងថ្ងៃដែលរបាយការណ៍ស្តីពី ការអង្កេតតាមដានបានដាក់ជូនក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ កំណត់ត្រាទាំងអស់ ត្រូវរក្សាទុកនៅក្នុងបរិវេណនៃប្រភពអចល័ត ដែលទទួលបានការអនុញ្ញាត ។

**មាត្រា៧៩២** ._ ប្រភពថ្មី និងប្រភពដែលមានស្រាប់នៃការបំពុលខ្យល់

លក្ខខណ្ឌតម្រូវក្នុងការទទួលបាននូវលិខិតអនុញ្ញាត ក្នុងការបញ្ចេញសារធាតុបំពុលខ្យល់ ត្រូវអនុវត្តចំពោះទាំងប្រភពបំពុលខ្យល់អចល័តថ្មី និងដែលមានស្រាប់ ។

**មាត្រា៧៩៣** ._ រយៈពេលនៃការដាក់ពាក្យសុំលិខិតអនុញ្ញាត

ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័តថ្មី ឬដែលមានស្រាប់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាត ក្នុងការបញ្ចេញការបំពុលខ្យល់ ទៅក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន៖

ក- នៅក្នុងរាជធានីភ្នំពេញ រយៈពេល៩០ (កៅសិប) ថ្ងៃ មុនពេលចាប់ផ្តើមប្រតិបត្តិការគម្រោងដែលមានបញ្ចេញសារធាតុបំពុលខ្យល់ ឬ

ខ-នៅក្នុងខេត្តផ្សេងទៀត រយៈពេល១២០(មួយរយម្ភៃ)ថ្ងៃ មុនពេលចាប់ផ្តើមប្រតិបត្តិការគម្រោង ដែលមានបញ្ចេញសារធាតុបំពុលខ្យល់ ។

ក្នុងករណីដែលការដាក់ពាក្យសុំលិខិតអនុញ្ញាត ត្រូវបានធ្វើឡើងទាន់ពេលវេលា ហើយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានមិនចេញលិខិតអនុញ្ញាត ឬ បដិសេធការដាក់ពាក្យនោះ មុនពេលការចាប់ផ្តើមប្រតិបត្តិការគម្រោងអភិវឌ្ឍ ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័តនោះ អាចបន្តការអភិវឌ្ឍគម្រោងបាន ដោយធានាចំពោះហានិភ័យដោយខ្លួនឯង ។

ក្នុងករណីដែលម្ចាស់ ឬ ប្រតិបត្តិករនៅតែបន្តការអភិវឌ្ឍគម្រោងរបស់ខ្លួនរហូតដល់ពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ចេញនូវលិខិតអនុញ្ញាត ម្ចាស់ ឬ ប្រតិបត្តិករនោះ ត្រូវដំឡើង ឬអនុវត្តបច្ចេកវិទ្យា ឬវិធានការចាំបាច់នានា ដើម្បីបំពេញតាមស្តង់ដារនៃការបញ្ចេញសារធាតុបំពុលខ្យល់ ដែលមានមុនពេលចាប់ផ្តើមប្រតិបត្តិការគម្រោង ។

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន បដិសេធលិខិតអនុញ្ញាតនៅពេលក្រោយ ម្ចាស់ ឬ ប្រតិបត្តិករ មិនត្រូវបញ្ចប់ ឬ អនុវត្តប្រតិបត្តិការគម្រោងនោះឡើយ ។

**មាត្រា៧៩៤** ._ រយៈពេលនៃសុពលភាពនៃលិខិតអនុញ្ញាត

លិខិតអនុញ្ញាតណាដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ទៅឲ្យម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពអចល័ត ត្រូវផុតកំណត់ក្នុងរយៈពេល៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលចេញលិខិតអនុញ្ញាត ។

ម្ចាស់ ឬ ប្រតិបត្តិករ ត្រូវដាក់ពាក្យសុំបន្តសារជាថ្មី នូវលិខិតអនុញ្ញាតសម្រាប់ការបញ្ចេញសារធាតុបំពុលខ្យល់ មិនតិចជាង៦ (ប្រាំមួយ) ខែ មុនពេលផុតកំណត់នៃលិខិតអនុញ្ញាតចាស់ ។

**មាត្រា៧៩៥** ._ សិទ្ធិអំណាចក្នុងការកែសម្រួល និងលុបចោលលិខិតអនុញាត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចកែសម្រួល ឬ លុបចោលលិខិតអនុញ្ញាតសម្រាប់ប្រភពអចល័តណាមួយ បានគ្រប់ពេលវេលា ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវផ្តល់ហេតុផលជាលាយលក្ខណ៍អក្សរ ទៅកាន់ម្ចាស់ ឬ ប្រតិបត្តិករ ។

**មាត្រា៧៩៦ ._** ថ្លៃសេវាសម្រាប់លិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាច តម្រូវឲ្យម្ចាស់ ឬ ប្រតិបត្តិករ បង់ថ្លៃសេវាសម្រាប់លិខិតអនុញ្ញាត និង/ឬ ការបន្តសារជាថ្មីនូវលិខិតអនុញ្ញាតនីមួយៗ ។

## ជំពូកទី៥
## ការគ្រប់គ្រង និងការត្រួតពិនិត្យ គុណភាពបរិយាកាស

**មាត្រា៧៩៧ ._** ការអង្កេតតាមដានគុណភាពខ្យល់ជុំវិញ សម្រាប់ប្រភពអចល័ត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវទទួលខុសត្រូវធ្វើការអង្កេតតាមដាននូវ គុណភាពខ្យល់ជុំវិញ ដោយសហការជាមួយ ម្ចាស់ និង/ឬប្រតិបត្តិករ នៃប្រភពអចល័ត ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធី សម្រាប់ការអង្កេតតាមដានគុណភាពខ្យល់ជុំវិញ ។

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពអចល័ត ដែលកាន់លិខិតអនុញ្ញាតចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវទទួលខុសត្រូវលើលក្ខខណ្ឌតម្រូវការអនុលោមតាម និងការអង្កេតតាមដាន ។

**មាត្រា៧៩៨ ._** របាយការណ៍អង្កេតតាមដានប្រភពអចល័ត

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពអចល័ត ដែលកាន់អ្នកកាន់កាប់លិខិតអនុញ្ញាតចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបញ្ជាក់នៅក្នុងរបាយការណ៍នៃការអង្កេតតាមដានដែលតម្រូវថា ការធ្វើសំណាក និងការអង្កេតាមដាន ត្រូវបានអនុវត្ត ស្របតាមលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាត និងលក្ខខណ្ឌនានា ដែលបង្កើតឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៧៩៩ ._** កាតព្វកិច្ចក្នុងការរៀបចំរបាយការណ៍នៃប្រភពអចល័ត ចំពោះលក្ខខណ្ឌតម្រូវក្នុងលិខិតអនុញ្ញាត

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពអចល័ត ដែលកាន់លិខិតអនុញ្ញាតចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវកំណត់អត្តសញ្ញាណឲ្យបានច្បាស់លាស់ អំពីគ្រប់ករណីទាំងអស់នៃភាពលើសកម្រិតនៃការបញ្ចេញសារធាតុបំពុលខ្យល់ ដែលមានកំណត់នៅក្នុងលិខិតអនុញ្ញាត នៅក្នុងរបាយការណ៍នៃការអង្កេតតាមដាន ។

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពអចល័ត ដែលកាន់លិខិតអនុញ្ញាតចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវជូនដំណឹងភ្លាមដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្នុងករណីមានបញ្ហាជាមួយការធ្វើសំណាក ឬ ឧបករណ៍ត្រួតពិនិត្យការបំពុលមិនដំណើរការ ឬខូច នៅក្នុងរយៈពេល២៤ (ម្ភៃបួន) ម៉ោង គិតចាប់ពីពេលដែលបានដឹងអំពីបញ្ហាទាំងអស់នេះ ។

**មាត្រា៨០០** ._ កាតព្វកិច្ចក្នុងការរៀបចំរបាយការណ៍នៃប្រភពអចល័ត ចំពោះការគំរាមកំហែងទៅដល់បរិស្ថាន

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពអចល័ត ដែលកាន់លិខិតអនុញ្ញាតចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរាយការណ៍ដោយផ្ទាល់មាត់អំពីការបំពានលើលិខិតអនុញ្ញាត ដែលអាចធ្វើឲ្យគ្រោះថ្នាក់ដល់បរិស្ថាន ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្នុងរយៈពេលមិនយូរជាង២៤ (ម្ភៃបួន) ម៉ោង គិតចាប់ពីពេល បានដឹងអំពីការបំពាននោះ ។

ការរាយការណ៍នេះ ត្រូវមានជាអាទិ៍ លក្ខណៈ និងភាពធ្ងន់ធ្ងរនៃការបំពាន ការគំរាមកំហែងដែលអាចកើតមានចំពោះបរិស្ថាន និងវិធានការនានាដែលត្រូវបានចាត់ ដើម្បីកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ដែលបានបង្កឡើង ។

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពអចល័ត ដែលកាន់លិខិតអនុញ្ញាតចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវដាក់បញ្ជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលរួមមានព័ត៌មាននេះទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្នុងរយៈពេលមិនយូរជាង៣ (បី) ថ្ងៃ គិតចាប់ពីពេលដែលបានដឹងអំពីការបំពាននោះ ។

**មាត្រា៨០១** ._ ការអង្កេតតាមដានការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័ត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលខុសត្រូវការអង្កេតតាមដាននូវការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័ត ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ស្ដីពី នីតិវិធីនៃការអង្កេតតាមដាននូវការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័ត ។

**មាត្រា៨០២** ._ វិធីសាស្ត្រសម្រាប់ការអង្កេតតាមដាន ប្រភពបំពុលចល័ត និងអចល័តនៃការបំពុលខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្ដីពីវិធីសាស្ត្រសម្រាប់ការអង្កេតតាមដានប្រភពបំពុលចល័ត និងអចល័តនៃការបំពុលខ្យល់ ។

**មាត្រា៨០៣** ._ ការធ្វើសំណាកនៃការបញ្ចេញដោយប្រភពអចល័ត

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពអចល័ត ដែលកាន់លិខិតអនុញ្ញាតចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវអនុវត្តការធ្វើសំណាកនៃការបញ្ចេញពីចំណុចនៃការបញ្ចេញទាំងអស់ ដើម្បីផ្ទៀងផ្ទាត់នូវប្រតិបត្តិការត្រឹមត្រូវនៃយន្តការ ឬ បច្ចេកវិទ្យានៃការត្រួតពិនិត្យការបំពុលខ្យល់ នៅក្នុងរយៈពេល១ (មួយ) ខែ បន្ទាប់ពីការចាប់ផ្តើមនៃប្រតិបត្តិការនៃប្រភពអចល័តនៃការបំពុលខ្យល់ ។

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពអចល័ត ដែលកាន់លិខិតអនុញ្ញាតចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបញ្ជូនភ្លាមនូវលទ្ធផលនៃធ្វើសំណាកនេះទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៨០៤** ._ សំណាកនៃការអង្កេតតាមដានប្រភពអចល័ត

សំណាកនៃការអង្កេតតាមដានណាមួយ ដែលបានផ្តល់ឲ្យក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថាន មិនត្រូវចាត់ទុកថាមានសុពលភាព ឬ យកជាការបានឡើយ លើកលែងតែ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬ មន្ទីរពិសោធន៍ដទៃទៀត ដែលទទួលបានទទួលការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន បានធ្វើការវិភាគ និងបញ្ជាក់លើសំណាកទាំងនោះ ។

**មាត្រា៨០៥** ._ ថ្លៃចំណាយលើការវិភាគលើសំណាក

ម្ចាស់ ឬ ប្រតិបត្តិករ ត្រូវទទួលខុសត្រូវលើបន្ទុកចំណាយនៃការវិភាគលើសំណាករបស់ខ្លួន ដែលថ្លៃសេវានោះ ត្រូវបានកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងហិរញ្ញវត្ថុ ។

**មាត្រា៨០៦** ._ ការខកខានមិនបានបំពេញតាមស្តង់ដារ

ក្នុងករណី រកឃើញថា មានការបញ្ចេញនូវប្រភពនៃការបំពុលខ្យល់ណាមួយ មិនបានបំពេញតាមស្តង់ដារដូចមានចែងក្នុងលិខិតបទដ្ឋានគិតយុត្តស្តីពីស្តង់ដារគុណភាពខ្យល់ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវៈ

ក- ចេញបទបញ្ជាជាលាយលក្ខណ៍អក្សរ ដែលតម្រូវឲ្យម្ចាស់ ឬ ប្រតិបត្តិករ នៃប្រភពបំពុលបែបនេះ ធ្វើការកែតម្រូវសកម្មភាពដែលបំពាននោះភ្លាមៗ នៅក្នុងរយៈពេលមិនឲ្យលើសពី៣០(សាមសិប)ថ្ងៃ និង/ឬ

ខ- ចេញបទបញ្ជាជាលាយលក្ខណ៍អក្សរដែលតម្រូវឲ្យ ម្ចាស់ ឬប្រតិបត្តិករ នៃប្រភពបំពុលនេះ បញ្ឈប់សកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្ន រហូតដល់ពេលមានការកែតម្រូវ

ចំពោះការបំពាននោះក្នុងករណីដែលសកម្មភាពដែលបំពាននោះអាចបង្កឲ្យមានគ្រោះថ្នាក់ដល់បរិស្ថាន។

**មាត្រា៨០៧** ._ ការគ្រប់គ្រង និងភាពអាចស្វែងរកបាននូវទិន្នន័យគុណភាពខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរក្សាទុកទិន្នន័យទាំងឡាយដែលពាក់ព័ន្ធទៅនឹងលទ្ធផលនៃការពិសោធន៍គុណភាពខ្យល់ និងដើម្បីប្រើប្រាស់ក្នុងការវាយតម្លៃស្ថានភាពគុណភាពខ្យល់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានដាក់ព័ត៌មានអំពីស្ថានភាពនៃគុណភាពខ្យល់ ព្រមទាំងស្ថានភាពទាក់ទងទៅនឹងការបំពុលខ្យល់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យសាធារណៈជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិ ស្ដីពីព័ត៌មានបរិស្ថាន នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៨០៨** ._ ការជូនដំណឹងជាសាធារណៈអំពីការគំរាមកំហែងដល់បរិស្ថាន

ក្នុងករណី រកឃើញថា មានតំបន់ណាមួយទទួលរងការប៉ះពាល់ដោយការបំពុលខ្យល់ ដែលអាចគំរាមកំហែងដល់បរិស្ថាន នោះក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធ្វើការជូនដំណឹងដល់សាធារណជនអំពីគ្រោះថ្នាក់ទាំងនោះ  ធ្វើការស៊ើបអង្កេតពីប្រភពនៃការបំពុលខ្យល់នេះ និងចាត់វិធានការទប់ស្កាត់ការបំពុលខ្យល់ និងធ្វើការស្ដារគុណភាពខ្យល់ឡើងវិញ ។

## ជំពូកទី៦
## វិញ្ញាបនបត្ររបស់ប្រតិបត្តិករ

**មាត្រា៨០៩** ._ លក្ខណៈវិនិច្ឆ័យ និងការបញ្ជាក់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចបង្កើតលក្ខណៈវិនិច្ឆ័យ និង/ឬ កម្រិតនៃវិញ្ញាបនបត្រសម្រាប់ម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុល ។  លក្ខណៈវិនិច្ឆ័យ និងកម្រិតនៃវិញ្ញាបនបត្រអាចរួមបញ្ចូលជាអាទិ៍នូវលក្ខខណ្ឌតម្រូវនានាសម្រាប់ការអប់រំ ការបណ្ដុះបណ្ដាល បទពិសោធន៍ និង/ឬ ភាពស្ទាត់ជំនាញ ។

## ជំពូកទី៧
## ការបំពុលខ្យល់ឆ្លងដែន

**មាត្រា៨១០** ._ ការបំពុលខ្យល់ដែលមានប្រភពមកពីប្រទេសក្រៅ

បន្ទាប់ពីទទួលបានរបាយការណ៍ នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានធ្វើការស្ទាបស្ទង់ ឬសិក្សា ពីអង្គភាពអន្តរជាតិដែលបានបង្កើតឡើងដោយត្រឹមត្រូវ មានហេតុផលក្នុងការជឿជាក់ថា ការបំពុលខ្យល់ដែលបានបញ្ចេញនៅក្នុងប្រទេសក្រៅមួយ កំពុងតែធ្វើឲ្យមានគ្រោះថ្នាក់ដល់បរិស្ថាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវសហការជាមួយជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តដំណើរការការទូត ដើម្បីជូនដំណឹង និងពិគ្រោះយោបល់ជាមួយប្រទេសដែលជាប្រភពនៃការបំពុលខ្យល់នោះ ដើម្បីស្វែងរកមធ្យោបាយនានាក្នុងការកាត់បន្ថយផលប៉ះពាល់នៃការបំពុលនោះ ។

**មាត្រា៨១១ .**_ ការបំពុលខ្យល់ដែលមានប្រភពនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធ្វើការជាមួយប្រទេសក្រៅ ដែលផ្អែកលើរបាយការណ៍ ការស្ទាបស្ទង់ ឬ ការសិក្សា របស់អង្គភាពអន្តរជាតិដែលបានបង្កើតឡើងត្រឹមត្រូវ មានហេតុផលក្នុងការជឿជាក់ថា ការបំពុលខ្យល់ដែលមានប្រភពនៅក្នុងព្រះរាជាណាចក្រកម្ពុជា កំពុងបង្កគ្រោះថ្នាក់ដល់បរិស្ថាន នៅក្នុងប្រទេសមួយផ្សេងទៀត ។

**មាត្រា៨១២ .**_ សិទ្ធិស្មើភាពគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវផ្តល់សិទ្ធិស្មើគ្នាតែប៉ុណ្ណោះ ទាក់ទងនឹងការបំពុលខ្យល់ ដែលមានប្រភពនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានផ្តល់ផលប៉ះពាល់ដល់ប្រទេសមួយផ្សេងទៀត ដូចគ្នានឹងសិទ្ធិដែលប្រទេសទាំងនោះផ្តល់ឲ្យដល់ព្រះរាជាណាចក្រកម្ពុជាផងដែរ ។

## ជំពូកទី៨
## សារធាតុបំផ្លាញស្រទាប់អូហ្សូន

**មាត្រា៨១៣ .**_ លិខិតបទដ្ឋានគតិយុត្ត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ។

**មាត្រា៨១៤ .**_ ការត្រួតពិនិត្យ និងការធ្វើបច្ចុប្បន្នភាពលើលិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្ត ដែលកំណត់អំពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ត្រូវធ្វើបច្ចុប្បន្នភាពជាទៀងរាល់៥ (ប្រាំ) ឆ្នាំម្តង ។

## មាតិកាទី៧
## ការត្រួតពិនិត្យសំឡេង និងរំញ័រ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៨១៥** ._ វិសាលភាពនៃការអនុវត្ត

មាតិកានេះមានវិសាលភាពអនុវត្តទៅលើរាល់ការបញ្ចេញសំឡេង និងរំញ័រទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងការបញ្ចេញសំឡេង និងបង្កើតរំញ័រ ។

**មាត្រា៨១៦** ._ ការទទួលខុសត្រូវចំពោះការខូចខាត

រូបវន្តបុគ្គល ឬនីតិបុគ្គលណា ដែលបង្កើតសំឡេង ឬរំញ័រ ត្រូវទទួលខុសត្រូវ ចំពោះការខូចខាតទាំងណា ចំពោះសុខភាពមនុស្ស ទ្រព្យសម្បត្តិ និងបរិស្ថាន ដែលបង្កឡើងដោយការបញ្ចេញសំឡេង ឬរំញ័រនោះ ។

## ជំពូកទី២
## លិខិតបទដ្ឋានគតិយុត្តស្តីពីសំឡេង និងរំញ័រ

**មាត្រា៨១៧** ._ កម្រិតកំណត់ស្តង់ដារ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីកម្រិតកំណត់ស្តង់ដារសម្រាប់ការបញ្ចេញសំឡេង និងរំញ័រ ស្របតាមបទប្បញ្ញត្តិស្តីពីស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់រាវ នៅក្នុងមាតិកាទី២ នៃគន្ថីនេះ ។

ស្តង់ដារនេះ ត្រូវចាត់ថ្នាក់ការបញ្ចេញទៅតាមប្រភេទនៃប្រភព មានជាអាទិ៍រោងចក្រ គ្រឿងយន្ត ឧបករណ៍សម្រាប់ការសាងសង់ ម៉ាស៊ីន ឬយានយន្ត ឬនាវាធំៗផ្សេងទៀត ជាប្រភពចល័ត ឬអចល័ត និង ប្រភពមួយមានភាពស៊ីគ្នាជាមួយនឹងឧបករណ៍ត្រួតពិនិត្យសំឡេង និងរំញ័រ ។

ស្តង់ដារនេះ ត្រូវកំណត់ និងអាចបញ្ចូលស្តង់ដារតឹងរ៉ឹងជាង ចំពោះកន្លែងធ្វើការ ឬទីកន្លែងដែលមានជនងាយទទួលរងការរំខានដោយសំឡេង ឬរំញ័រ មានជាអាទិ៍ គេហដ្ឋាន សកលវិទ្យាល័យ មតេយ្យសាលា បណ្ណាល័យ មន្ទីរពេទ្យ សណ្ឋាគារ វត្តអារាម ឬទីកន្លែងសាសនាផ្សេងទៀត ។

**មាត្រា៨១៨ ._** ការគោរពតាមស្តង់ដារ

រូបវន្តបុគ្គល ឬនីតិបុគ្គលណា ដែលបង្កើតសំឡេង ឬរំញ័រ ត្រូវគោរពតាមស្តង់ដារសម្រាប់ការបញ្ចេញសំឡេង និងរំញ័រ ។

**មាត្រា៨១៩ ._** លក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពី លក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន ដើម្បីធានាបាននូវការគោរពតាមស្តង់ដារសម្រាប់ការបញ្ចេញសំឡេង និងរំញ័រ ។

លក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន ត្រូវអនុវត្តចំពោះ និង ដាក់បញ្ចូលទៅក្នុងលិខិតអនុញ្ញាត ឬការឯកភាពនានា ដែលមានជាអាទិ៍ លិខិតអនុញ្ញាត ឬការឯកភាពលើការសាងសង់ដែលចេញដោយក្រសួង ស្ថាប័នមានពាក់ព័ន្ធ សម្រាប់សកម្មភាព ឬគម្រោងណាមួយដែលបង្កឲ្យមានផលប៉ះពាល់ជាសំឡេង ឬរំញ័រ ។

## មាតិកាទី៨
## ការស្តារឡើងវិញនូវទីតាំងដែលទទួលរងការបំពុល
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៨២០ ._** វិសាលភាពនៃការអនុវត្ត

មាតិកានេះ មានវិសាលភាពអនុវត្តលើ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតបញ្ជីទូទៅ ឬប្រភេទនៃទីតាំងដែលរងការបំពុលសំខាន់ៗ ការស្តារឡើងវិញនូវផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពមនុស្ស ឬបរិស្ថាន ចំពោះរាល់ទីតាំងដែលរងការបំពុលទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពី ប្រភេទ នៃទីតាំងដែលរងការបំពុល ។

**មាត្រា៨២១ ._** នីតិវិធីនៃការស្តារឡើងវិញនូវទីតាំងដែលទទួលរងការបំពុល

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហកាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីនៃការស្តារឡើងវិញនូវទីតាំងដែលទទួលរងការបំពុល ដែលរួមមាន៖

ក. ការកំណត់អត្តសញ្ញាណនៃទីតាំងដែលទទួលរងការបំពុល ។

ខ. ដំណើរការវាយតម្លៃហានិភ័យដើម្បីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចំពោះការស្តារឡើងវិញណាមួយ ។

គ. ការជូនដំណឹង និងការរាយការណ៍អំពីផលប៉ះពាល់បរិស្ថានដែលកើតចេញពីទីតាំងដែលទទួលរងការបំពុល ។

ឃ. ការពិគ្រោះយោបល់ជាសាធារណៈ ។

ង. ការចាត់តាំងអ្នកជំនាញការ ។

ច. លិខិតបទដ្ឋានគតិយុត្តបច្ចេកទេសស្តីពីការស្តារឡើងវិញ មានជាអាទិ៍ការស៊ើបអង្កេត និងស្តង់ដារ ។

ឆ. ការរៀបចំការវាយតម្លៃទីតាំង ។

ជ. លក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន និងការរាយការណ៍ ។

ឈ. ការរៀបចំកិច្ចព្រមព្រៀងនានាក្នុងការស្តារឡើងវិញ ។

ញ. ការផ្តល់មូលនិធិ ការអនុវត្ត និងការបំពេញចប់សព្វគ្រប់នូវការងារស្តារឡើងវិញ ។

## ជំពូកទី២
## ការរាយការណ៍អំពីផលប៉ះពាល់បរិស្ថាន

**មាត្រា៨២២** ._ កាតព្វកិច្ចក្នុងការរាយការណ៍

រាល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលខុសត្រូវ ត្រូវរាយការណ៍ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬក្រសួង ស្ថាប័នមានពាក់ព័ន្ធក្នុងករណី បានដឹង ឬ រកឃើញថា មានទីតាំងដែលទទួលរងការបំពុល ឬមានផលប៉ះពាល់បរិស្ថាន ។

**មាត្រា៨២៣** ._ សេចក្តីជូនដំណឹង និងសេចក្តីសង្ខេបរបាយការណ៍

ក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថាន ត្រូវផ្តល់សេចក្តីជូនដំណឹង និងសេចក្តីសង្ខេបនៃរបាយការណ៍អំពីទីតាំងដែលទទួលរងការបំពុល ឬផលប៉ះពាល់បរិស្ថាននោះទៅកាន់ក្រសួង ស្ថាប័នមានពាក់ព័ន្ធ នៅក្នុងរយៈពេល៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីទទួលបានរបាយការណ៍ ។

## ជំពូកទី៣
## ការស៊ើបអង្កេត និងការស្តារឡើងវិញ

**មាត្រា៨២៤**._ ការស៊ើបអង្កេត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយមានការសហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ ត្រូវធ្វើការស៊ើបអង្កេតទៅលើតាំងដែលរងការបំពុលមួយ ដើម្បីការពារសុវត្ថិភាពទីតាំង កាត់បន្ថយហានិភ័យភ្លាមៗ កំណត់ទំហំនៃការបំពុល និងជ្រើសរើសជម្រើសក្នុងការស្តារឡើងវិញដែលសមស្រប ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការឆ្លើយតបទៅនឹង និងការស៊ើបអង្កេតទៅលើទីតាំងដែលទទួលរងការបំពុលនេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវដាក់របាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការឆ្លើយតបទៅនឹង និងការស៊ើបអង្កេតទៅលើ និងការស្តារទីតាំងដែលទទួលរងការបំពុលនេះ ស្របតាមបទប្បញ្ញត្តិ ស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៨២៥**._ កិច្ចព្រមព្រៀងក្នុងការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចតម្រូវឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយធ្វើកិច្ចព្រមព្រៀងស្តារឡើងវិញ ជាមួយនឹងលក្ខខណ្ឌតម្រូវជាក់លាក់ និង រយៈពេលសម្រាប់ការស្តារឡើងវិញនូវទីតាំងដែលទទួលរងការបំពុល ។

## ជំពូកទី៤
## ការអង្កេតតាមដានការស្តារឡើងវិញ

**មាត្រា៨២៦**._ ការអង្កេតតាមដានការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយមានការសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើការអង្កេតតាមដានការស្តារឡើងវិញនូវទីតាំងដែលរងការបំពុល ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការអង្កេតតាមដានការស្តារឡើងវិញនូវទីតាំងដែលរងការបំពុលនោះ ។

**មាត្រា៨២៧**._ របាយការណ៍នៃការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវដាក់របាយការណ៍ ជាលាយលក្ខណ៍អក្សរអំពីការអង្កេតតាមដានការស្តារឡើងវិញនូវទីតាំងដែលទទួលរងការបំពុល នេះ ស្របតាមបទប្បញ្ញត្តិ ស្តីពីព័ត៌មានបរិស្ថាន នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

# ជំពូកទី៥
# ការចេញវិញ្ញាបនបត្រនៃការបំពេញចប់ការស្តារឡើងវិញ

**មាត្រា៨២៨** ._ ការផ្តល់វិញ្ញាបនបត្រនៃការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានអាចចេញវិញ្ញាបនបញ្ជាក់ថា ការស្តារឡើងវិញនូវផលប៉ះពាល់បរិស្ថាននៅទីតាំងដែលរងការបំពុលមួយ ត្រូវបានបំពេញចប់ ដោយសម្រេចបាននូវៈ

ក. កាតព្វកិច្ចទូទៅចំពោះការត្រួតពិនិត្យការបំពុល ដូចមានចែងក្នុងមាតិកាទី១ នៃគន្ថីនេះ ។

ខ. ស្តង់ដារគុណភាពបរិស្ថាន និងស្តង់ដារសំណល់

រាវដែលពាក់ព័ន្ធ ។

គ. វិសាលភាពនៃហានិភ័យដែលបានបង្កើតឡើង ដែលកំណត់នៅក្នុងការវាយតម្លៃហានិភ័យដែលធ្វើឡើងក្រោយការស្តារឡើងវិញ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធី ស្តីពីការចេញវិញ្ញាបនបត្រនៃការបំពេញចប់ការស្តារឡើងវិញនូវទីតាំងដែលរងការបំពុល ។

**មាត្រា៨២៩** ._ សេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចចុងក្រោយ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវដាក់ឲ្យសាធារណៈជនអាចស្វែងរកបាននូវ ការចេញវិញ្ញាបនបត្រនៃការបំពេញចប់ការស្តារឡើងវិញនូវទីតាំងដែលរងការបំពុលនោះ ស្របតាមបទប្បញ្ញត្តិ ស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតបញ្ជីនៃរាល់ការសម្រេចចិត្តចុងក្រោយទាំងអស់ពាក់ព័ន្ធនឹងការស្តារឡើងវិញនូវទីតាំងដែលរងការបំពុល ស្រប តាមបទប្បញ្ញត្តិ ស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៨៣០** ._ បញ្ជីឯកសារយោង

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើត បញ្ជីឯកសារយោងអំពីព័តមានផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ ដែលអាចទាក់ទង និងត្រូវបានប្រើប្រាស់ ដើម្បីធ្វើការងារស្តារឡើងវិញនូវផលប៉ះពាល់បរិស្ថាននៅទីតាំងដែលរងការបំពុល ។

**មាត្រា៨៣១** ._ សិទ្ធិទទួលបានបញ្ជីឯកសារយោង

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវដាក់ឲ្យសាធារណៈជនអាចស្វែងរកបាននូវបញ្ជីឯកសារយោងនេះ ស្របតាមបទប្បញ្ញត្តិ ស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៅក្នុងមាតិកាទី៣ គន្ថីទី១ នៃក្រមនេះ ។

## មាតិកាទី៩
## ប្រព័ន្ធថ្នាក់ជាតិស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៨៣២** ._ វិសាលភាពនៃការអនុវត្ត

មាតិកានេះ មានវិសាលភាពអនុវត្តទៅលើរាល់សារធាតុគីមី និងសារធាតុបំពុល ដែលត្រូវ បានបញ្ចេញទៅក្នុងខ្យល់ ទឹក និងដី និងដែលត្រូវបានផ្លាស់ទីចេញពីទីតាំងណាមួយ នៅក្នុងព្រះ រាជាណាចក្រកម្ពុជា ។

**មាត្រា៨៣៣** ._ ការបង្កើតប្រព័ន្ធថ្នាក់ជាតិស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតប្រព័ន្ធថ្នាក់ជាតិស្តីពីសារធាតុបំពុល ដែលសាយភាយ និងផ្លាស់ទី  សម្រាប់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៨៣៤** ._ បញ្ជីនៃឧស្សាហាកម្ម

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីបញ្ជីនៃឧស្សាហាកម្ម ដែលត្រូវបានដាក់បញ្ចូលនៅក្នុងប្រព័ន្ធថ្នាក់ជាតិសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី ផ្អែកលើ ចំណាត់ថ្នាក់ឧស្សាហាកម្មស្តង់ដារអន្តរជាតិនៃសកម្មភាពសេដ្ឋកិច្ចទាំងអស់ និងអង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍសេដ្ឋកិច្ច ប្រព័ន្ធជាសកលស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី (សំណើសម្រាប់បញ្ជីស៊ីចង្វាក់គ្នានៃវិស័យដែលត្រូវរាយការណ៍)។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាពលើបញ្ជីនៃឧស្សាហាកម្មនេះ តាមការចាំបាច់ ។

**មាត្រា៨៣៥** ._ បញ្ជីនៃសារធាតុបំពុលបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីបញ្ជីនៃសារធាតុបំពុលបរិស្ថាន ដែលត្រូវបានដាក់បញ្ចូលនៅក្នុងប្រព័ន្ធថ្នាក់ជាតិស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី ដោយផ្អែកលើអង្គការសម្រាប់កិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍសេដ្ឋកិច្ច ប្រព័ន្ធ

ជាសកលស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី (សំណើសម្រាប់បញ្ជីស៊ីចង្វាក់គ្នានៃវិស័យដែលត្រូវរាយការណ៍) ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាពលើបញ្ជីនៃសារធាតុបំពុលបរិស្ថាននេះ តាមការចាំបាច់ ។

## ជំពូកទី២
## ការគ្រប់គ្រងប្រព័ន្ធថ្នាក់ជាតិស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី

**មាត្រា៨៣៦** ._ ទម្រង់បែបបទនៃការបញ្ចេញសារធាតុបំពុលបរិស្ថាន

ម្ចាស់ ឬប្រតិបត្តិករនៃបរិក្ខារ ដែលត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីនៃឧស្សាហកម្មនៅក្នុងប្រព័ន្ធថ្នាក់ជាតិសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី និងដែលផលិត កែច្នៃ ប្រើប្រាស់ ស្តុកទុក ឬដឹកជញ្ជូននូវសារធាតុបំពុលណាមួយ ដែលលើសពីបរិមាណកម្រិតដែលត្រូវបាន កំណត់ដោយលិខិតបទដ្ឋានគតិយុត្ត បញ្ជីនៃសារធាតុបំពុលបរិស្ថាននៅក្នុងប្រព័ន្ធថ្នាក់ជាតិស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី ត្រូវបំពេញទម្រង់បែបបទនៃការបញ្ចេញសារធាតុបំពុលបរិស្ថាន សម្រាប់សារធាតុបំពុលបរិស្ថាននិមួយៗ ដែលត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីនៃសារធាតុបំពុលបរិស្ថាននោះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីនៃទម្រង់បែបបទនៃការបញ្ចេញសារធាតុបំពុលបរិស្ថាន ។

**មាត្រា៨៣៧** ._ ប្រព័ន្ធថ្នាក់ជាតិស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរក្សានូវប្រព័ន្ធថ្នាក់ជាតិស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី ដោយផ្អែកលើព័ត៌មានដែលបានបញ្ជូនមកកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ស្របតាមមាត្រា៨៣៦ នៃមាតិកានេះ ។

**មាត្រា៨៣៨** ._ សិទ្ធិទទួលបានព័ត៌មានបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវដាក់ឲ្យសាធារណៈជនអាចស្វែងរកបាននូវប្រព័ន្ធថ្នាក់ជាតិស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

## គន្ថីទី៧
## ការអប់រំ និងការយល់ដឹងពីបរិស្ថាន

## មាតិកាទោល
## ការអប់រំ និងការយល់ដឹងពីបរិស្ថាន
## ជំពូកទី១
## ការបណ្តុះបណ្តាល ស្តីពីការការពារបរិស្ថាន ការអភិរក្សធនធានបរិស្ថាន និងការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព

**មាត្រា៨៣៩** ._ លក្ខណៈសម្បត្តិវិជ្ជាជីវៈ

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវបង្កើតគោលនយោបាយ និងផែនការសម្រាប់ការរួម បញ្ចូលនូវចំណេះដឹង និងជំនាញពាក់ព័ន្ធ សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ទៅក្នុង លក្ខខណ្ឌតម្រូវនៃការងារសម្រាប់លក្ខណៈសម្បត្តិវិជ្ជាជីវៈ និងវិញ្ញាបនបត្រ ។

**មាត្រា៨៤០** ._ ការបណ្តុះបណ្តាលទូទៅ

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតគោលនយោបាយ និងផែនការដើម្បីធានាថា ខ្លឹមសារ វិធីសាស្ត្រ និងសម្ភារៈដែលទាក់ទងនឹងចំណេះដឹង និងជំនាញសម្រាប់ការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព ត្រូវបានដាក់បញ្ចូលទៅក្នុងការបណ្តុះបណ្តាល និងដំណើរនៃការរៀនសូត្រ ផ្សេងទៀតរបស់ខ្លួន ។

**មាត្រា៨៤១** ._ ការបណ្តុះបណ្តាលបុគ្គលិក

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតគោលនយោបាយ និងផែនការសម្រាប់ ការផ្តល់នូវកម្មវិធីបណ្តុះបណ្តាលជាក់លាក់ស្តីពីការការពារបរិស្ថាន ការអភិរក្ស ធនធានធម្មជាតិ និង ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់បុគ្គលិករបស់ខ្លួន ។

**មាត្រា៨៤២** ._ ការបង្កើតសម្ភារៈបណ្តុះបណ្តាល

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធ្វើការសហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធក្នុងការបង្កើតសម្ភារៈបណ្តុះបណ្តាល និងកម្មវិធីសិក្សាសមស្រប ស្តីពីការការពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកដោយនិរន្តរភាព ។

**មាត្រា៨៤៣** ._ ការកំណត់អត្តសញ្ញាណនូវទំហំនៃតម្រូវការ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវធ្វើការសហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធដើម្បីកំណត់អត្តសញ្ញាណនូវទំហំនៃតម្រូវការ និងបង្កើតផែនការជាតិ ដើម្បីផ្តល់នូវ ឱកាសនៃការប

ណ្តុះបណ្តាល និងការរៀនសូត្រ ស្តីពីការការពារបរិស្ថាន ការអភិរក្សធនធាន ធម្មជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពចំពោះសហគមន៍មូលដ្ឋាន សង្គមស៊ីវិល និងវិស័យ ឯកជន ។

## ជំពូកទី២
## បណ្ឌិតសភាជាតិបណ្តុះបណ្តាលបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៨៤៤** ._ បណ្ឌិតសភាជាតិបណ្តុះបណ្តាលបរិស្ថាន និងធនធានធម្មជាតិ

ត្រូវបង្កើត បណ្ឌិតសភាជាតិបណ្តុះបណ្តាលបរិស្ថាន និងធនធានធម្មជាតិ ក្នុងរយៈពេល ១៨ (ដប់ប្រាំបី) ខែ នៃការអនុម័តនៃក្រមនេះ ។

**មាត្រា៨៤៥** ._ ការបណ្តុះបណ្តាលសម្រាប់បុគ្គលិកចុះវាល

បណ្ឌិតសភាជាតិបណ្តុះបណ្តាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តល់ការបណ្តុះបណ្តាល និងការផ្តល់ជូនវិញ្ញាបនបត្រវិជ្ជាជីវៈទៅកាន់នាយកប្រចាំតំបន់ បុគ្គលិកដទៃទៀត និងឆ្មាំក្នុងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារដែលកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

**មាត្រា៨៤៦** ._ ការកសាងសមត្ថភាពសម្រាប់បុគ្គលិកក្រសួង ស្ថាប័ន

បណ្ឌិតសភាជាតិបណ្តុះបណ្តាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តល់ការកសាង សមត្ថភាពវិជ្ជាជីវៈសម្រាប់បុគ្គលិកក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិស្តីពីជំនាញមុខវិជ្ជាពាក់ព័ន្ធនឹងការការពារបរិស្ថាន ការអភិរក្ស ជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

**មាត្រា៨៤៧** ._ កម្មវិធីផ្តល់វិញ្ញាបនបត្រ

បណ្ឌិតសភាជាតិបណ្តុះបណ្តាលបរិស្ថាន និងធនធានធម្មជាតិ ផ្តល់នូវកម្មវិធីបណ្តុះ បណ្តាល និង វិញ្ញាបនបត្រវិជ្ជាជីវៈក្នុងវិស័យពាក់ព័ន្ធ ជំនាញមុខវិជ្ជាពាក់ព័ន្ធនឹងការការពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយនិរន្តរភាព ជូនមន្ត្រីរាជរដ្ឋាភិបាល បុគ្គលិករបៀងអភិរក្ស ជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ គណៈកម្មការគ្រប់គ្រងរួមគ្នា និងសមាជិកសហគមន៍ និងសាធារណជន ។

**មាត្រា៨៤៨** ._ ការបណ្តុះបណ្តាលសម្រាប់ដោះស្រាយបណ្តឹងបរិស្ថាន

បណ្ឌិតសភាជាតិបណ្តុះបណ្តាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តល់នូវកម្មវិធីបណ្តុះបណ្តាល ទៅកាន់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានជ្រើសរើសសម្រាប់ដោះស្រាយ បណ្តឹងបរិស្ថានក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា៨៤៩** ._ កម្មវិធីដទៃៗទៀត

បណ្ឌិតសភាជាតិបណ្តុះបណ្តាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវបង្កើតកម្មវិធីដទៃទៀត ក្នុងការស្រាវជ្រាវ គោលនយោបាយ ការអប់រំ និងការយល់ដឹង ក្នុងករណីចាំបាច់ ។

## ជំពូកទី៣
## ការយល់ដឹង

**មាត្រា៨៥០** ._ ការយល់ដឹងរបស់អ្នកពាក់ព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តសម្រាប់ ធ្វើទំនាក់ទំនង និងជម្រាបជូនអ្នកពាក់ព័ន្ធ ដែលជាប់ទាក់ទិនក្នុងការបង្កើតគោលនយោបាយ និងគម្រោង និងដំណើការក្នុងការធ្វើការសម្រេចចិត្តពាក់ព័ន្ធផ្សេងៗទៀត ស្តីពីផលអវិជ្ជមាន ដែលអាចកើតមាននៃដំណើរការទាំងនេះចំពោះការការពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ស្របតាមគន្លឹះទី១ មាតិកាទី៣ នៃក្រមនេះ ។

**មាត្រា៨៥១** ._ ផែនការយុទ្ធសាស្ត្រជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើតផែនការយុទ្ធសាស្ត្រជាតិសម្រាប់យុទ្ធនាការយល់ដឹងជាសាធារណៈ ដើម្បីលើក កម្ពស់ការការពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

## ជំពូកទី៤
## ការអប់រំក្នុងប្រព័ន្ធ

**មាត្រា៨៥២** ._ លក្ខខណ្ឌតម្រូវបរិស្ថាន និងនិរន្តរភាព

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានានូវការដាក់បញ្ចូលលក្ខខណ្ឌតម្រូវ សម្រាប់ចំណេះ ដឹងបរិស្ថាននិងនិរន្តរភាពទៅក្នុងលក្ខណៈវិនិច្ឆ័យ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានជាអាទិ៍ ការចេញ

វិញ្ញាបនបត្រ និងនិងការចេញការផ្តល់វិញ្ញាបនបត្រឡើងវិញសម្រាប់អ្នកមានវិជ្ជាជីវៈ ក្នុងករណីចាំបាច់។

**មាត្រា៨៥៣** ._ ការការពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយ និរន្តរភាព

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តសម្រាប់សមាហរណកម្មនៃកិច្ចការពារបរិស្ថាន ការអភិរក្ស ធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ទៅក្នុងកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នក សិក្សានៅគ្រប់កម្រិត និងនៅក្នុងគ្រប់កម្រិត ដែលរួមមានជាអាទិ៍ ការអប់រំទូទៅ និងការអប់រំជាន់ ខ្ពស់ ការបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់មុខវិជ្ជា ចូលទៅក្នុងកម្មវិធី និងវគ្គសិក្សាជាក់លាក់ ។

**មាត្រា៨៥៤** ._ អាទិភាពក្នុងការអភិវឌ្ឍ និងការឈានមុខផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកទេស

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាថាកម្មវិធីបណ្តុះបណ្តាល និងកម្មវិធីអប់រំពាក់ព័ន្ធនឹង ការការពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ឆ្លុះបញ្ចាំង ពីអាទិភាពក្នុងការអភិវឌ្ឍ និងភាពរីកចម្រើនផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ។

**មាត្រា៨៥៥** ._ សម្ភារៈអប់រំ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើត និងរក្សាទុកសម្ភារៈអប់រំដែលបានធ្វើបច្ចុប្បន្នភាព មានជាអាទិ៍ ការបោះពុម្ពផ្សាយ និង សៀវភៅសិក្សាផ្នែកគរុកោសល្យ ផ្នែកអប់រំ និងវិធីសាស្ត្រ និងធនធានពាក់ព័ន្ធដទៃទៀត ដើម្បី គាំទ្រកិច្ចដំណើការក្នុងការបង្រៀន និងការរៀនសូត្រ ដែលទាក់ទងនឹងការការពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

**មាត្រា៨៥៦** ._ ប្រព័ន្ធគ្រប់គ្រងបរិស្ថាន

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានានូវការគាំទ្រដល់ការបង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថាននៅសាលារៀន គ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានសិក្សាដទៃទៀត ។

**មាត្រា៨៥៧** ._ លក្ខណៈវិនិច្ឆ័យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវបង្កើតលក្ខណៈវិនិច្ឆ័យដែលលក្ខណៈសម្បត្តិគ្រប់គ្រាន់លម្អិត ដែលទាក់ទងនឹងចំណេះដឹង និងការបណ្តុះបណ្តាលអំពីការការពារបរិស្ថាន ការអភិរក្សធនធាន ធម្មជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព សម្រាប់អ្នកសិក្សានៅគ្រប់កម្រិតនៃការអប់រំ ។

**មាត្រា៨៥៨** ._ សមត្ថកិច្ច វិធីសាស្ត្រ និងវិធាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យអប់រំ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និង ក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ត្រូវសហការគ្នាក្នុងការបង្កើត គាំទ្របណ្តាញជាតិ ស្តីពីសមត្ថកិច្ច វិធីសាស្ត្រ និងវិធាន នៃការការពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយ និរន្តរភាព ។

## ជំពូកទី៥
## ការស្រាវជ្រាវ និងនវានុវត្តន៍

**មាត្រា៨៥៩** ._ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនវិក្រឹតការ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនវិក្រឹតការ ដោយផ្អែក លើការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសនៃចំណេះដឹងដែលទាក់ទងនឹងការការពារ បរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

**មាត្រា៨៦០** ._ កម្មវិធីអប់រំ និងស្រាវជ្រាវ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវគាំទ្រនូវការបង្កើត និងការអនុវត្តកម្មវិធីអប់រំ និងស្រាវជ្រាវរួមគ្នា ដើម្បីបង្កើតដំណោះស្រាយចំពោះបញ្ហាប្រឈមទាក់ទងនឹងការការពារបរិស្ថាន ការអភិរក្សធនធាន ធម្មជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

**មាត្រា៨៦១** ._ ការធ្វើបច្ចុប្បន្នភាពទៅលើសម្ភារៈអប់រំ និងបណ្តុះបណ្តាល

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ នូវសម្ភារៈឧបទេសសម្រាប់ការអប់រំ និង បណ្តុះបណ្តាល ដោយផ្អែកទៅលើចំណេះដឹងផ្នែកវិទ្យាសាស្ត្រចុងក្រោយបំផុត ។

**មាត្រា៨៦២** ._ ធនធាន និងការគាំទ្រសម្រាប់ការស្រាវជ្រាវ ការសិក្សា និងការដោះដូរ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវគាំទ្រសម្រាប់ការស្រាវជ្រាវ និងការអប់រំ តាមរយៈការផ្តល់ ធនធាននានាសម្រាប់ការស្រាវជ្រាវ និងឱកាសសម្រាប់ការសិក្សា និងការដោះដូរ ។

**មាត្រា៨៦៣ .**_ ការអភិវឌ្ឍចំណេះដឹងអំពីគោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាព

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតគោលនយោបាយ និងផែនការ ដើម្បីធ្វើឲ្យចំណេះ ដឹងអំពីការការពារបរិស្ថាន និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព ស៊ីគ្នាជាមួយនឹង ការអភិវឌ្ឍផ្នែកចំណេះដឹង និងជំនាញតាមវិស័យដទៃទៀតដែលពាក់ព័ន្ធទៅនឹងទិសដៅអភិវឌ្ឍ ប្រកបដោយនិរន្តរភាពរបស់ព្រះរាជាណាចក្រកម្ពុជា តាមរយៈ ៖

ក- ការធានាបាននូវកិច្ចសហការរវាងអ្នកមានចំណេះដឹងជាលក្ខណៈប្រពៃណី

ខ- ការគាំទ្រចំពោះកិច្ចសហការជាអន្តរវិស័យ ការជំរុញឲ្យមានអន្តរកម្មរវាង វិទ្យាសាស្ត្រ ការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា និងធុរកិច្ច និងការគាំទ្រចំពោះការអភិវឌ្ឍវិស័យ បច្ចេកវិទ្យាដែលសមរម្យ ដែលមានផលប៉ះពាល់អវិជ្ជមានតិចតួចទៅលើបរិស្ថាន

គ- ការគាំទ្រចំពោះការអប់រំទៅវិញទៅមករវាងការស្រាវជ្រាវ និងនវានុវត្តន៍ និង

ឃ- ការបង្កើតជាកម្មវិធីស្រាវជ្រាវដែលមានគោលដៅក្នុងការកំណត់អត្តសញ្ញាណដំណោះស្រាយនវានុវត្តន៍ ចំពោះបញ្ហាប្រឈមដែលទាក់ទងនឹងការការពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

## ជំពូកទី៦
## លិខិតបទដ្ឋាន និងក្របខ័ណ្ឌប្រតិបត្តិការ

**មាត្រា៨៦៤ .**_ ការគាំទ្រផ្នែកលិខិតបទដ្ឋាន ផ្នែកហិរញ្ញវត្ថុ និងផ្នែកការរៀបចំ

រាជរដ្ឋាភិបាលកម្ពុជាត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តចាំបាច់ ដើម្បីគាំទ្រផ្នែកលិខិត បទដ្ឋាន ហិរញ្ញវត្ថុ ការរៀបចំសម្រាប់ការអប់រំ និងស្រាវជ្រាវផ្នែកបរិស្ថាន ។

លិខិតបទដ្ឋានគតិយុត្តទាំងនេះត្រូវដោះស្រាយទៅលើ៖

ក- ការកំណត់អាទិភាពដោយផ្អែកលើផ្នែកមួយៗជាក់លាក់ ដោយធ្វើការសហការជាមួយអ្នកពាក់ព័ន្ធ

ខ- ការបង្កើតយន្តការសម្រាប់កិច្ចសម្របសម្រួលការអប់រំ និងការបណ្តុះបណ្តាល ស្តីពីការការពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព រវាងក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានឧត្តមសិក្សា

គ- ការប្រើប្រាស់ឧបករណ៍ផ្នែកសេដ្ឋកិច្ច និងការរៀបចំ ដើម្បីលើកកម្ពស់ការដោះដូរផ្នែកវិទ្យាសាស្ត្រ និងអប់រំជាអន្តរជាតិ និងកម្មវិធីអន្តរជាតិ សម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា និង

ឃ- ការបង្កើតធនធានព័ត៌មានដើម្បីគាំទ្រទៅលើការអប់រំផ្នែកបរិស្ថាន ។

**មាត្រា៨៦៥**._ ផែនការសកម្មភាពអប់រំបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យអប់រំ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតផែនការសកម្មភាពអប់រំបរិស្ថាន ដើម្បីអនុវត្តមាតិកានេះ នៅក្នុង ក្នុងរយៈពេល ១៨ (ដប់ប្រាំបី) ខែ នៃការអនុម័តនៃក្រមនេះ ។

ផែនការសកម្មភាពអប់រំបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាព យ៉ាងហោចណាស់ ៥ (ប្រាំ) ឆ្នាំ ម្តង ។

## គន្ថីទី៨
## វិធានការសេដ្ឋកិច្ច គណនី ថ្លៃ និងមូលនិធិផ្នែកបរិស្ថាន
## មាតិកាទី១
## វិធានការសេដ្ឋកិច្ច និងគណនី
## ជំពូកទី១
## វិធានការសេដ្ឋកិច្ច

**មាត្រា៨៦៦**._ ការវាយតម្លៃជាប្រចាំទៅលើឱកាស និងយន្តការនៃការលើកទឹកចិត្តឲ្យមានការវិនិយោគទុនផ្នែកបរិស្ថាន និងធនធានធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ត្រូវវាយតម្លៃជាប្រចាំទៅលើឱកាស និងយន្តការក្នុងការលើកទឹកចិត្តឲ្យមានការវិនិយោគទុនក្នុងកិច្ចការពារបរិស្ថាន ការស្តារបរិស្ថានឡើងវិញ និងលើកស្ទួយបរិស្ថាន និងធនធានធម្មជាតិ ។

ការវាយតម្លៃដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវធ្វើការពិចារណាលើអាទិភាពសម្រាប់ការប្រមូល ការកំណត់ក្របខ័ណ្ឌគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងផែនការធុរកិច្ចពី៣ (បី) ទៅ៥ (ប្រាំ)ឆ្នាំ ដើម្បីលើកកម្ពស់ការធ្វើឲ្យមានភាពចម្រុះមុខ និងនិរន្តរភាពនៃហិរញ្ញប្បទាន ។

**មាត្រា៨៦៧**._ វិធានការបរិស្ថានដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ដោយការសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីវិធានការសេដ្ឋកិច្ចក្នុងគោលបំណងគាំទ្រដល់ការបង្កើតយុទ្ធសាស្ត្រផ្នែកជីវៈចម្រុះ ការអភិរក្ស ការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ការធ្វើឲ្យបរិស្ថានប្រសើរឡើង និងមានការស្តារឡើងវិញ ។

វិធានការសេដ្ឋកិច្ចនេះ ត្រូវស្របតាមស្តង់ដារដែលបានទទួលស្គាល់ជាអន្តរជាតិ និងត្រឹមត្រូវក្នុងកម្រិតអប្បបរិមាផ្នែកសេដ្ឋកិច្ច មានជាអាទ៍ ការយកពន្ធ ការឧបត្ថម្ភធនធាន និងវិធានការសារពើពន្ធដែលទាក់ទិននឹងៈ

ក- ការដាក់បញ្ចូលស្តង់ដារ ការអនុវត្តការងារបរិស្ថាន និងសង្គម និងការគ្រប់គ្រងហានិភ័យទៅក្នុងការធ្វើសេចក្តីសម្រេចផ្នែកពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ។

ខ- ការវិនិយោគលើវិស័យឯកជន ។

គ- ការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ និងការលើកកម្ពស់ជីវៈចម្រុះ និងការអភិរក្សធនធានធម្មជាតិ ។

ឃ- និរន្តរភាពព្រៃឈើ និងជលផល ។

ង- ការគ្រប់គ្រងធនធានធម្មជាតិនៅតាមសហគមន៍ ។

ច- ការអភិវឌ្ឍ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថាមពលកើតឡើងវិញ ។

ឆ- ការប្រើប្រាស់ប្រកបដោយប្រសិទ្ធផលនូវធនធានធម្មជាតិតាមរយៈឧស្សាហកម្មដែលប្រើប្រាស់ថាមពលស្អាត ប្រភេទនៃផលិតកម្មដែលប្រើប្រាស់កាបូនតិច និងប្រសិទ្ធផលនៃធនធាន និងការកាត់បន្ថយការបំពុលពីប្រភពឧស្សាហកម្ម និងកសិកម្ម ។

ជ- ការប្រើប្រាស់បច្ចេកវិជ្ជាដែលអាចរកបានល្អបំផុត និងដែលបានផ្ទៀងផ្ទាត់រួច ។

ឈ- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាក្នុងគោលបំណងសម្រាប់កិច្ចការពារបរិស្ថាន និងដឹកជញ្ជូន ។

ញ- ការបែងចែកស្មើភាពគ្នានៃប្រាក់ចំណូលពីយន្តការកាត់បន្ថយកាបូនក្នុងបញ្ជីដែលនឹងត្រូវកំណត់ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងទទួលការឯកភាពពីក្រសួងស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ បញ្ជីនេះត្រូវបានធ្វើបច្ចុប្បន្នភាព និងឯកភាពឡើងវិញរៀងរាល់ ៣ (បី) ឆ្នាំម្តង ដោយផ្អែកលើគុណភាពនៃការវាស់វែង ការរៀបចំរបាយការណ៍ និងការផ្ទៀងផ្ទាត់សម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័ន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។

ដ- ការបង់ថ្លៃសម្រាប់ការផលិត ឬការថែទាំទំនិញ និងសេវាធនធានធម្មជាតិទៅកាន់រូបវន្តបុគ្គល និងសហគមន៍ ដោយមានកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ ស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ ។

ឋ- ការលើកកម្ពស់ការនាំចូល និងការទិញយានយន្តដែលមានលក្ខណៈមិនបង្កផលប៉ះពាល់បរិស្ថាន និងការទប់ស្កាត់ការនាំចូលយានយន្តដែលមានផលប៉ះពាល់ខ្ពស់ដល់បរិស្ថាន ។

ឌ- ការអភិរក្ស និងកិច្ចការពារវត្ថុ និងទីតាំងបេតិកភណ្ឌ  និង

ធ- ការអភិរក្សថាមពល ក្នុងចំហោះតាមរយៈការធ្វើឲ្យប្រសើឡើង និងប្រសិទ្ធផលនៃការប្រើប្រាស់អគ្គិសនី ការទប់ស្កាត់ការបាត់បង់ថាមពល ការច្នៃសំណល់ថាមពលឡើងវិញ និងដាក់ជំនួសដោយថាមពលដែលអាចកកើតឡើងវិញ និងមធ្យោបាយផ្សេងៗនៃការអភិរក្សថាមពលដូចដែលបានកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា៨៦៨ ._** វិធាននៃការយកពន្ធ

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង្កើតវិធានពន្ធ ដើម្បីលើកកម្ពស់ការអនុវត្តតាមថាមពលប្រកបដោយនិរន្តរភាពដូចខាងក្រោម៖

១- ធុរកិច្ចនានា ដែលប្រើប្រាស់ប្រភពថាមពលប្រកបដោយនិរន្តរភាព ដែលត្រូវទទួលបានការកាត់បន្ថយអត្រាពន្ធប្រាក់ចំណូលចំនួន១០ (ដប់) ភាគរយ សម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីបានចាប់ផ្តើមរាយការណ៍ពីប្រាក់ចំណេញ ឬទទួលបានការកាត់បន្ថយ ២០ (ម្ភៃ) ភាគរយ នៃអត្រាពន្ធប្រាក់ចំណូល នៅពេលបានអនុលោមតាមសកម្មភាពដូចខាងក្រោម៖

ក- ផលិតច្រើនជាង ២០ (ម្ភៃ)ភាគរយ នៃថាមពលសម្រាប់សកម្មភាពឧស្សាហកម្ម ដោយប្រើប្រាស់ប្រភពថាមពលប្រកបដោយនិរន្តរភាព ។

ខ- ការផលិតដែលផ្អែកលើប្រភពថាមពលប្រកបដោយនិរន្តរភាព ជាផ្នែកខ្លះ និងតិចជាង ២០ (ម្ភៃ)ភាគរយ ក្រុមហ៊ុនអាចប្រើប្រាស់ការលើកលែងឲ្យមានលក្ខណៈសមមាត្រ ។

២- ធុរកិច្ច ដែលធ្វើពាណិជ្ជកម្ម តំឡើងឬផ្តល់ការគាំទ្រ ឬការថែទាំផ្នែកបច្ចេកទេសទៅលើឧបករណ៍ផលិតថាមពលប្រកបដោយនិរន្តរភាព ត្រូវលើកលែងការបង់ថ្លៃពន្ធលើប្រាក់ចំណូលជាតិ ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីពួកគេចាប់ផ្តើមរាយការណ៍ពីប្រាក់ចំណេញ ឬត្រូវកាត់បន្ថយ ២០ (ម្ភៃ) ភាគរយ នៃអត្រាពន្ធលើប្រាក់ចំណូល ដែលអាចជ្រើសជម្រើសមួយណាដែលអាចអនុវត្តបាន ។

៣- ធុរកិច្ចដែលនាំចូល ផលិត ចែកចាយ ឬលក់ឧបករណ៍ដែលផលិតថាមពលប្រកបដោយនិរន្តរភាព ឬបង្កើនប្រសិទ្ធផលថាមពល មានជាអាទិ៍ បន្ទះស្រូបពន្លឺព្រះអាទិត្យ ឧបករណ៍បង្កើតឧស្ម័នធម្មជាតិ ទុរបីនផលិតថាមពលដោយប្រើខ្យល់ អំពូលអិលអ៊ីឌី ឧបករណ៍ប្រើប្រាស់ថាមពលតិច និងសេវា បំពាក់ ថែទាំ និងជួសជុលឧបករណ៍ទាំងនោះ ដែលត្រូវលើកលែងពីការបង់ពន្ធលើតម្លៃបន្ថែម ។ ដើម្បីទទួលបាននូវការលើកលែងនេះ ធុរកិច្ចទាំងឡាយត្រូវលក់ឧបករណ៍ដែលមានលក្ខណៈសម្បត្តិត្រឹមត្រូវសមស្របទៅនឹងសុខភាព សុវត្ថិភាព និងលិខិតបទដ្ឋានផ្នែកបរិស្ថាន និងស្របទៅតាមក្រមនេះ ។ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតលិខិត

បទដ្ឋានគតិយុត្ត ដើម្បីផ្តល់នូវការលើកលែងនេះ ក្នុងរយៈពេល ១ (មួយ) ឆ្នាំបន្ទាប់ក្រមនេះចូលជាធរមាន ។

៤- ការនាំចូលឧបករណ៍សម្រាប់ផលិតថាមពលប្រកបដោយនិរន្តរភាព ឬឧបករណ៍សម្រាប់ការបង្កើនការប្រើប្រាស់ថាមពលតិចដែលមានប្រសិទ្ធផល ដែលមិនត្រូវមានតារាងពន្ធគយដែលត្រូវអនុវត្តចំពោះឧបករណ៍ទាំងនោះ នៅពេលចូលមកដល់ព្រះរាជាណាចក្រកម្ពុជាឡើយ លើកលែងតែបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេល១ (មួយ) ឆ្នាំ បន្ទាប់ពីក្រមនេះចូលជាធរមាន ។

**មាត្រា៨៦៩** ._ សំណើសម្រាប់ភាពជាដៃគូឯកជនសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយក្រសួងផ្ទាល់ផ្ទាល់ ឬដោយមានកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាចចេញនូវការស្នើសុំ សម្រាប់ភាពជាដៃគូឯកជនសាធារណៈសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រលើនិរន្តរភាព ឬគោលដៅបរិស្ថានស្របតាមច្បាប់ពិសេស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវអនុវត្តតាមដំណើរការនៃលទ្ធកម្ម ដូចដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តនៃគោលនយោបាយពាក់ព័ន្ធ ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចតម្រូវឲ្យរាល់សំណើ ត្រូវមានភស្តុតាងស្តីពីធនធានហិរញ្ញវត្ថុ និងសុខភាព ការសិក្សាទីផ្សារ ការប្រើប្រាស់ផែនការកំណត់រកប្រភពប្រកបដោយនិរន្តរភាព ការបង្ហាញពីការចូលរួមរបស់គម្រោងចំពោះការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃភាពធន់ស៊ាំចំពោះការប្រើប្រាស់កាបូនទាប និងសមត្ថភាពសម្រាប់ផ្តល់នូវកិច្ចគាំពារផ្នែកបច្ចេកទេសដែលកំពុងបន្តអនុវត្ត ។

គណៈកម្មការលទ្ធកម្មត្រូវដាក់បញ្ចូលនូវអ្នកតំណាងសហគមន៍ដែលរស់នៅក្នុងតំបន់ដែលរងផលប៉ះពាល់យ៉ាងខ្លាំងពីហេដ្ឋារចនាសម្ព័ន្ធ និងសេវាពាក់ព័ន្ធដែលនឹងត្រូវបង្កើតតាមរយៈភាពជាដៃគូឯកជនសាធារណៈ ។ កិច្ចដំណើរការក្នុងការចូលរួមត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និង សិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៅក្នុងគន្ថីទី១ មាតិកាទី២ នៃក្រមនេះ និងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

គ្រប់ឯកសារស្នើសុំ ត្រូវរៀបចំស្របតាមច្បាប់ពិសេស និងលិខិតបទដ្ឋានគតិយុត្តនៃគោលនយោបាយពាក់ព័ន្ធ ។

## ជំពូកទី២
## គណនី

**មាត្រា៨៧០ ._** ការបង់ថ្លៃសម្រាប់សេវាធនធានធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតយន្តការបង់ថ្លៃទៅកាន់រូបវន្តបុគ្គល សហគមន៍ នីតិបុគ្គល សម្រាប់សេវាធនធានធម្មជាតិដែលពួកគេបានចូលរួមវិភាគទានក្នុងការផ្តល់ជូន មានជាអាទិ៍ សេវាធនធានធម្មជាតិដែលមានដើមកំណើតចេញពីផ្នែកនានានៃប្រព័ន្ធអេកូឡូស៊ីក្រោមការត្រួតពិនិត្យ កិច្ចការពារ និងការគ្រប់គ្រងរបស់ក្រសួង ។ យន្តការ នេះត្រូវពិចារណាលើទិន្នន័យ និងស្ថិតិដែលអាចរកបានល្អបំផុត ដែលផ្តោតលើស្ថានភាព និងតម្លៃដែលបានវាយតម្លៃរួចរាល់នៃសេវាធនធានធម្មជាតិ ។

ការបង់ថ្លៃនានាសម្រាប់សេវាធនធានធម្មជាតិ ត្រូវធ្វើការបែងចែក និងចែកចាយទៅតាមមូលដ្ឋានសមធម៌ដោយពិចារណាទៅលើសិទ្ធិរបស់សហគមន៍មូលដ្ឋាន ។

**មាត្រា៨៧១ ._** កិច្ចសហប្រតិបត្តិការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវគាំទ្រ និងធ្វើសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថាន ដើម្បីបង្កើត អនុវត្ត និងគ្រប់គ្រងយន្តការដូចមានចែងក្នុងមាត្រា៨៧០ នៃក្រម នេះ ។

**មាត្រា៨៧២ ._** ការទទួលបានរបាយការណ៍ជាសាធារណៈ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយជាប្រចាំ និងដាក់របាយការណ៍ដែលលើកឡើងពីទិន្នន័យ និងស្ថិតិដែលបង្ហាញពីស្ថានភាព និងតម្លៃនៃធនធានបរិស្ថាន និងធនធានធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជាឲ្យសាធារណជនអាចស្វែងរកបាន ។

## មាតិកាទី២
## ថ្លៃ និងបន្ទុកសេវាបរិស្ថាន មូលនិធិ និងការគ្រប់គ្រងមូលនិធិ
## ជំពូកទី១
## ថ្លៃ និងបន្ទុកសេវាបរិស្ថាន

**មាត្រា៨៧៣ ._** ការបង់ថ្លៃចំណាយលើការរៀបចំ និងការអនុវត្តផែនការគ្រប់គ្រង អង្កេតតាមដាន បរិស្ថាន

ម្ចាស់គម្រោង ត្រូវបង់ថ្លៃចំណាយលើការរៀបចំ និងការអនុវត្តផែនការ គ្រប់គ្រងបរិស្ថានបរិស្ថាន និងថ្លៃចំណាយលើការអនុវត្ត និងការអង្កេតតាមដានវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គម ដូចមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថាន និងផែនការអភិវឌ្ឍសង្គម ។

ម្ចាស់គម្រោង ត្រូវមានថវិកាតម្កល់ ឬថវិកាធានារ៉ាប់រង សម្រាប់គ្រប់គ្រងគ្រោះហានិភ័យនានាផ្នែកបរិស្ថាន និងសង្គម ដែលត្រូវកំណត់ដោយ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៨៧៤** ._ ថ្លៃចំណាយលើវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន

ថវិកាលំអិតអំពីការប៉ាន់ស្មាននៃការចំណាយលើវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន ដែលត្រូវដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង ។

ថ្លៃចំណាយលើការផ្សព្វផ្សាយឯកសារជាសាធារណៈ ដូចមានចែងក្នុងមាត្រា១២៩ នៃក្រមនេះ ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង ។

ថ្លៃចំណាយទាំងអស់ក្នុងការកែតម្រូវ ឬកែលម្អវិធានការកាត់បន្ថយផលប៉ះពាល់ និងកម្មវិធីអង្កេតតាមដានគម្រោងដូចមានចែងក្នុងមាត្រា១៣២នៃក្រមនេះត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង ។

ថ្លៃចំណាយទាំងអស់ ក្នុងការដោះស្រាយវិវាទពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ទាំងតាមប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ ស្របតាមគន្ថីទី៩ មាតិកាទី១ នៃក្រមនេះ ជាបន្ទុករបស់ម្ចាស់គម្រោង ។

ថ្លៃសេវា និងបន្ទុកផ្សេងៗ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាង ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា៨៧៥** ._ ថ្លៃចំណាយលើការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ

នៅពេលម្ចាស់គម្រោងដាក់ពាក្យសុំពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវប្រមូលថ្លៃ និងបន្ទុកសេវា ស្របតាមលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាង ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង់ថ្លៃសេវាការងារសម្រាប់ការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

**មាត្រា៨៧៦** ._ ថ្លៃចំណាយលើការពិនិត្យលើរបាយការណ៍អង្កេតតាមដានបរិស្ថាន

ម្ចាស់គម្រោងត្រូវបង់សេវាពិនិត្យលើរបាយការណ៍អង្កេតតាមដានបរិស្ថានទៅឲ្យក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដើម្បី ត្រួតពិនិត្យរបាយការណ៍តាមដាន ត្រួតពិនិត្យ ក៏ដូចជាឆ្លើយតបចំពោះសំណើឲ្យមានការស៊ើបអង្កេតលើបណ្ដឹងបរិស្ថាន និងអនុវត្តការតាមដានត្រួតពិនិត្យ លើការអនុលោមតាមច្បាប់ជាប្រចាំ ទាំងនៅក្នុងអំឡុងពេលនៃដំណាក់សាងសង់ និងដំណាក់កាលប្រតិបត្តិការគម្រោងដែលពាក់ព័ន្ធ ។

**មាត្រា៨៧៧ ._** ការបង់មូលនិធិទាយជ្ជទានបរិស្ថាន

ម្ចាស់គម្រោង ត្រូវបង់មូលនិធិទាយជ្ជទានបរិស្ថាន តាមការព្រមព្រៀងគ្នារវាង ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងម្ចាស់គម្រោង ជារៀងរាល់ឆ្នាំរហូតដល់ អាជីវកម្មបានបញ្ចប់ដោយផ្អែកលើប្រភេទ និងទំហំនៃគម្រោងអភិវឌ្ឍ ។

**មាត្រា៨៧៨ ._** ថ្លៃ និងបន្ទុកសេវាការពារបរិស្ថាន

ម្ចាស់គម្រោងទាំងឡាយដែលតម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបង់ថ្លៃ និងបន្ទុកសេវាបរិស្ថានដែលមានចំនួន ១ (មួយ)ភាគរយ នៃតម្លៃគម្រោងសរុប លើកលែងតែមានការកំណត់ក្នុងច្បាប់ លិខិតបទដ្ឋានគតិយុត្ត ឬកិច្ចព្រមព្រៀងដោយឡែកផ្សេងទៀត ។ ថ្លៃ និងបន្ទុកសេវាការពារបរិស្ថាននឹងត្រូវបង់ចូលទៅក្នុងគណនីមូលនិធិបរិស្ថាន និងសង្គម ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីវិធីសាស្ត្រគណនាថ្លៃគម្រោងសរុបដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ។ ការបង់ថ្លៃ និងបន្ទុកទាំងនេះត្រូវជាកាតព្វកិច្ចសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលត្រូវបានចាប់ផ្ដើមឡើងបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃក្រមនេះ ។

**មាត្រា៨៧៩ ._** ការលើកលែងការបង់កម្រៃលើកិច្ចការពារបរិស្ថាន

នីតិបុគ្គលដែលបង្កើតបាននូវជម្រើសនៃធនធានថាមពលកកើតឡើងវិញដោយប្រើប្រាស់ខ្យល់ ពន្លឺព្រះអាទិត្យ និងជីវម៉ាសដែលប្រកបដោយនិរន្តរភាព អាចដាក់ពាក្យស្នើសុំឲ្យមានការលើកលែងការបង់កម្រៃលើកិច្ចការពារបរិស្ថាន ។

ម្ចាស់គម្រោងទាំងឡាយដែលអាចបង្ហាញថា ខ្លួនបានវិនិយោគទៅលើវិធានការទប់ស្កាត់ការប្រែប្រួលអាកាសធាតុ និង/ឬ ប្រសិទ្ធផលនៃធនធាន អាចដាក់ពាក្យស្នើសុំឲ្យមានការលើកលែងការបង់កម្រៃលើកិច្ចការពារបរិស្ថាន ។

**មាត្រា៨៨០ ._** គម្រោងការងារសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព

ក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថាន ត្រូវបង្កើត និងគាំទ្រគម្រោងការងារសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព មានជាអាទិ៍ ការធ្វើការស្រាវជ្រាវ និងការអភិវឌ្ឍ ការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ ការអភិវឌ្ឍវិធានការ និងការឧបត្ថម្ភធននានា ការតម្រូវតាមស្តង់ដារ និងការដាក់ស្លាកសម្គាល់ និងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចចាប់ផ្តើមធ្វើយុទ្ធនាការអប់រំ និងយល់ដឹង ដើម្បីលើកកម្ពស់ការយល់ដឹង និងការចូលរួមជាសាធារណៈក្នុងគម្រោងការងារសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាពក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៨៨១ ._** ការទទួលខុសត្រូវសម្រាប់ថ្លៃ និងបន្ទុកផ្សេងទៀត

ម្ចាស់គម្រោង ត្រូវបន្តទទួលខុសត្រូវទៅលើថ្លៃ និងបន្ទុកសេវា ស្របតាមច្បាប់ពិសេស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ក្រៅពីក្រមនេះ ។

## ជំពូកទី២

## មូលនិធិបរិស្ថាន និងការគ្រប់គ្រងមូលនិធិ

### ផ្នែកទី១

### មូលនិធិបរិស្ថាន និងសង្គម

**មាត្រា៨៨២ ._** ការបង្កើតមូលនិធិបរិស្ថាន និងសង្គម

មូលនិធិបរិស្ថាន និងសង្គម ត្រូវបង្កើតឡើងដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថាន ។

**មាត្រា៨៨៣ ._** ប្រភពចំណូលសម្រាប់មូលនិធិបរិស្ថាន និងសង្គម

ប្រភពចំណូលសម្រាប់មូលនិធិបរិស្ថាន និងសង្គម ត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថាន ។ ប្រភពចំណូលដទៃទៀត មានដូចខាងក្រោមៈ

១- ប្រាក់ដែលបានមកពីការដោះស្រាយបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងប្រយោជន៍សាធារណៈ ។

២- ប្រាក់ដែលទទួលបានពីការអនុវត្តការស្តារបរិស្ថានឡើងវិញ និង

៣- ប្រាក់ដែលទទួលបានពី សំណងលើការខូចខាតផ្សេងៗទៀត ។

**មាត្រា៨៨៤ ._** គណៈកម្មការគ្រប់គ្រងមូលនិធិបរិស្ថាន និងសង្គម

មូលនិធីបរិស្ថាន និងសង្គម ត្រូវគ្រប់គ្រងដោយគណៈកម្មការគ្រប់គ្រងមូលនិធិបរិស្ថាន និងសង្គម ដែលបង្កើតឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថាន ។

ភារកិច្ច និងតួនាទីរបស់គណៈកម្មការមូលនិធិបរិស្ថាន និងសង្គម ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៨៨៥** ._ ការចំណាយនៃមូលនិធិបរិស្ថាន និងសង្គម

ការចំណាយនានាសម្រាប់គណៈកម្មការគ្រប់គ្រងបរិស្ថាន និងសង្គមក្នុងការបំពេញភារកិច្ច និងតួនាទីរបស់ខ្លួន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គណៈកម្មការមូលនិធិបរិស្ថាន និងសង្គម ត្រូវបង្កើតយុទ្ធសាស្ត្រមួយ ដើម្បីធានានូវអត្ថិភាពមូលនិធិរយៈពេលយូរ ។ យុទ្ធសាស្ត្រនេះ ត្រូវធ្វើការពិចារណាលើការគ្រប់គ្រង និងវិធីសាស្ត្រលទ្ធកម្មសម្រាប់មូលនិធិ មានជាអាទិ៍ ការគ្រប់គ្រងមូលនិធិ ដែលរួមមាន ការប្រើប្រាស់មូលធន និងវិនិយោគទុន និងវិធានការផ្នែករដ្ឋបាល និងផ្លូវច្បាប់ ដើម្បីប្រមែប្រមូលនូវចំនួនដែលកំណត់ដោយផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងគោលនយោបាយពាក់ព័ន្ធដទៃទៀត ។

## ផ្នែកទី២
## មូលនិធិភារៈគ្រប់គ្រងបរិស្ថាន

**មាត្រា៨៨៦** ._ ការបង្កើត ការលុបចោល និងគោលដៅរបស់មូលនិធិភារៈគ្រប់គ្រងបរិស្ថាន

អាណត្តិទាយក អាចធ្វើដោយខ្លួនឯង ឬដោយសហការជាមួយសមាគមន៍ក្នុងស្រុក និងសមាគមន៍បរទេសក្នុងការបង្កើត ឬប្រតិបត្តិការមូលនិធិភារៈគ្រប់គ្រងបរិស្ថានស្របតាមលក្ខខណ្ឌដែលបានកំណត់ ។

មូលនិធិភារៈគ្រប់គ្រងបរិស្ថាននេះ ត្រូវប្រើប្រាស់សម្រាប់សកម្មភាពជាអាទិភាពដូចដែលត្រូវបានកំណត់កិច្ចការពារបរិស្ថានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការគ្រប់គ្រងរួមគ្នា ផែនការនិរន្តរភាព និងផែនការអភិរក្ស និងក្នុងគោលដៅនេះ

ក- ការអភិរក្ស កិច្ចការពារ ការស្តារបរិស្ថានឡើងវិញ ការលើកស្ទួយធនធានបរិស្ថាន និងធម្មជាតិ ។

ខ- កិច្ចការពារបេតិកភណ្ឌវប្បធម៌ ឬជីវៈចម្រុះ ។

គ- ការលើកកម្ពស់ការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃទំនិញ និងសេវាធនធានធម្មជាតិ និងធនធានធម្មជាតិ ។

ឃ- ការលើកកម្ពស់ការស្រាវជ្រាវ និងការអប់រំបរិស្ថាន ។

ង- ការអភិវឌ្ឍសមត្ថភាព ឬការពង្រឹងស្ថាប័ន ។

ច- ការគាំទ្រទៅលើសហគមន៍ដែលរងផលប៉ះពាល់ដោយផ្ទាល់ពីការអភិវឌ្ឍ ។

ឆ- គោលដៅណាមួយដើម្បីផលប្រយោជន៍សាធារណៈ និងសម្រាប់ផលប្រយោជន៍បរិស្ថានដែលរដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានបានកំណត់ ។

មូលនិធិភារៈគ្រប់គ្រងបរិស្ថាន ត្រូវបង្កើតឡើងស្របតាម នីតិវិធី និងទម្រង់ ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវចុះបញ្ជីទទួលស្គាល់ដោយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អាណត្តិទាយកដែលមានបំណងបង្កើត ឬប្រតិបត្តិការមូលនិធិភារៈគ្រប់គ្រងបរិស្ថាន ត្រូវរៀបចំសំណុំបែបបទស្តីពីភារៈគ្រប់គ្រង និងចុះបញ្ជី នៅក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធពាក់ព័ន្ធ ។

**មាត្រា៨៨៧** ._ ការគ្រប់គ្រងមូលនិធិភារៈគ្រប់គ្រងបរិស្ថាន

មូលនិធិភារៈគ្រប់គ្រងបរិស្ថាន ត្រូវបានផ្ទេរពីអាណត្តិទាយកទៅកាន់អ្នកទទួលភារៈគ្រប់គ្រងដើម្បីធ្វើការគ្រប់គ្រង សម្រាប់ជាផលប្រយោជន៍របស់អ្នកទទួលផលប្រយោជន៍ស្របតាមការកំណត់របស់អាណត្តិទាយក ។ មូលនិធិភារៈគ្រប់គ្រងបរិស្ថាន មានជាអាទិ៍ មូលនិធិភារៈគ្រប់គ្រងអភិរក្សភារៈគ្រប់គ្រងសត្វព្រៃ មូលនិធិអាកាសធាតុ និងព្រៃឈើ មូលនិធិស្តារនីតិសម្បទា និងមូលនិធិស្តារបរិស្ថានឡើងវិញ មូលនិធិគ្រប់គ្រងរួមគ្នា និងទម្រង់ដទៃទៀតដែលបានផ្តល់ឲ្យដើម្បីផលប្រយោជន៍បរិស្ថាន សង្គម និងសេដ្ឋកិច្ច ។

**មាត្រា៨៨៨** ._ លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យមូលនិធិភារៈគ្រប់គ្រងបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសម្របសម្រួលជាមួយ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើត លិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់វិធាន និងនីតិវិធីសម្រាប់ការគ្រប់គ្រង និងការត្រួតពិនិត្យមូលនិធិភារៈគ្រប់គ្រងបរិស្ថាន ។

**មាត្រា៨៨៩** ._ ការចុះបញ្ជីមូលនិធិភារៈគ្រប់គ្រងបរិស្ថាន

មូលនិធិភារៈគ្រប់គ្រងបរិស្ថាន មានសុពលភាព លុះត្រាតែបានចុះបញ្ជីទទួលស្គាល់ដោយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញ

វត្ថុ ត្រូវសម្រេចលើពាក្យស្នើសុំចុះបញ្ជីក្នុងរយៈពេល៩០(កៅសិប)ថ្ងៃបន្ទាប់ពីទទួលបានសំណើដែលស្របតាមលក្ខខណ្ឌតម្រូវសម្រាប់ការចុះបញ្ជីទាយជ្ជទានហិរញ្ញវត្ថុ ។

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បដិសេធចំពោះការស្នើសុំចុះបញ្ជីដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្តល់ជាការពន្យល់ជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើក្នុងរយៈពេល៣០(សាមសិប)ថ្ងៃបន្ទាប់ពីបានទទួលបានសំណើ ។

**មាត្រា៨៩០ ._** ទ្រព្យរបស់មូលនិធិភារៈគ្រប់គ្រងបរិស្ថាន

ទ្រព្យរបស់មូលនិធិភារៈគ្រប់គ្រងបរិស្ថានអាចមានប្រភពមកពី៖

១- ថវិការជាតិ ។

២- ជំនួយអភិវឌ្ឍជាផ្លូវការ ដែលបានផ្តល់ឲ្យដោយអង្គការជាតិ និងអន្តរជាតិ ។

៣- ការបង់ថ្លៃសម្រាប់ទំនិញ និងសេវាធនធានធម្មជាតិ ។

៤- សេវាគ្រប់គ្រងធនធានធម្មជាតិ និង

៥- ការបរិច្ចាកផ្ទាល់ពីវិស័យឯកជន។

ផលប្រយោជន៍ទាំងអស់ដែលកើតចេញពីមូលនិធិភារៈគ្រប់គ្រងបរិស្ថាន ត្រូវដាក់ចូល ឬបង្កើតជាផ្នែកៗក្នុងមូលនិធិភារៈគ្រប់គ្រងបរិស្ថាន ។

ការបង្កើត និងការប្រព្រឹត្តទៅនៃមូលនិធិភារៈគ្រប់គ្រងបរិស្ថាន និងគណនី ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៨៩១ ._** សិទ្ធិ និងកាតព្វកិច្ចរបស់អាណត្តិទាយក

អាណត្តិទាយកមានសិទ្ធិដូចខាងក្រោម៖

ក- ទទួលឯកសារពាក់ព័ន្ធនឹងការគ្រប់គ្រងភារៈគ្រប់គ្រងដែលរួមមានរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សវនកម្ម និងឯកសារពាក់ព័ន្ធដទៃៗទៀត ។

ខ- តែងតាំង និងបញ្ចប់ភារៈគ្រប់គ្រង ស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តភារៈគ្រប់គ្រង ។

អាណត្តិទាយកមានកាតព្វកិច្ចដូចខាងក្រោម៖

ក- ផ្ទេរមូលនិធិទៅកាន់អ្នកទទួលភារៈគ្រប់គ្រង ។

ខ- ផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ការកែប្រែភារៈគ្រប់គ្រង អ្នកទទួលភារៈគ្រប់គ្រង អ្នកផ្តល់វិភាគទានភារៈគ្រប់គ្រង ឬលក្ខខណ្ឌរបស់លក្ខន្តិកៈភារៈគ្រប់គ្រង និង

គ- អនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងលក្ខន្តិកៈភារៈគ្រប់គ្រង ។

នៅក្នុងករណីដែលអាណត្តិទាយក ពុំមានសមត្ថភាព ឬ លទ្ធភាព ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចដើរតួនាទីជាអាណត្តិទាយកជំនួសបាន ។

**មាត្រា៨៩២** ._ សិទ្ធិរបស់អ្នកទទួលផលប្រយោជន៍

អ្នកទទួលផលប្រយោជន៍មានសិទ្ធិដូចខាងក្រោម៖

ក- ទទួលបានអត្ថប្រយោជន៍ដូចមានចែងក្នុងលក្ខន្តិកៈភារៈគ្រប់គ្រង ។

ខ- តម្រូវឲ្យអ្នកទទួលភារៈគ្រប់គ្រងឲ្យបំពេញកាតព្វកិច្ចដូចកំណត់ក្នុងលក្ខន្តិកៈភារៈគ្រប់គ្រង ។

គ- ទទួលបានព័ត៌មានទាក់ទងនឹងការគ្រប់គ្រង និងការបែងចែកភារៈគ្រប់គ្រង ។

ឃ- សិទ្ធិដទៃទៀតដូចមានចែងក្នុងលក្ខន្តិកៈភារៈគ្រប់គ្រង ។

អ្នកទទួលផលប្រយោជន៍ទទួលបានផលប្រយោជន៍ស្មើគ្នា លើកលែងតែមានចែងពិសេសក្នុងលក្ខន្តិកៈភារៈគ្រប់គ្រង ។

**មាត្រា៨៩៣** ._ សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកទទួលភារៈគ្រប់គ្រង

អ្នកទទួលភារៈគ្រប់គ្រងមានសិទ្ធិដូចខាងក្រោម៖

ក- ទទួលប្រាក់ឈ្នួលសុទ្ធសាធស្មើគ្នា ស្របតាមបទពិសោធន៍ និងលក្ខណៈសម្បត្តិសម្រាប់ការគ្រប់គ្រងមូលនិធិភារៈគ្រប់គ្រង ។

ខ- ស្វែងរកមូលនិធិបន្ថែម និងឱកាសវិនិយោគសម្រាប់ផលប្រយោជន៍ភារៈគ្រប់គ្រង ។

គ- តំណាងអាណត្តិទាយក ឬអ្នកទទួលផលប្រយោជន៍ នៅចំពោះមុខច្បាប់ ឬអាជ្ញាធរមានសមត្ថកិច្ច ។

ឃ- អនុវត្តតាមលក្ខខណ្ឌដែលកំណត់ដោយលក្ខន្តិកៈភារៈគ្រប់គ្រង ឬបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

ង- គ្រប់គ្រង និងបែងចែកមូលនិធិភារៈគ្រប់គ្រង ស្របតាមគោលដៅ និងលក្ខខណ្ឌនៃលក្ខន្តិកៈភារៈគ្រប់គ្រង និងសម្រាប់ផលប្រយោជន៍របស់អ្នកទទួលផលប្រយោជន៍ ។ ច-

ចំណាយទៅលើសកម្មភាពដែលស៊ីគ្នាទៅនឹងគោលដៅនិងលក្ខខណ្ឌរបស់លក្ខន្តិកៈភារៈគ្រប់គ្រង ។

អ្នកទទួលផលប្រយោជន៍ មានកាតព្វកិច្ចដូចខាងក្រោម៖

ក- ដាក់បញ្ជូនសំណើសម្រាប់ការចុះបញ្ជីភារៈគ្រប់គ្រងស្របតាមលក្ខខណ្ឌតម្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ខ- រាយការណ៍ និងផ្តល់ព័ត៌មានអំពីភារៈគ្រប់គ្រង និងអ្នកទទួលភារៈគ្រប់គ្រង ទៅកាន់អាណត្តិទាយក អ្នកទទួលផលប្រយោជន៍ និងអ្នកគ្រប់គ្រងពាក់ព័ន្ធទាំងអស់ ។

គ- រក្សាទុកកំណត់ហេតុប្រជុំសម្រាប់ការគ្រប់គ្រងគណនីប្រចាំឆ្នាំ ។

ឃ- បង់ពន្ធដែលទាក់ទងនឹងទ្រព្យសម្បត្តិភារៈគ្រប់គ្រង ។

ង- ឆ្លើយតបទៅកាន់អ្នកគ្រប់គ្រង ។

ច- ផ្តល់ផលប្រយោជន៍ ដូចមានចែងដោយលក្ខន្តិកៈភារៈគ្រប់គ្រង ជូនអ្នកទទួលផលប្រយោជន៍ ។

ឆ- ចាត់វិធានការសមស្របក្នុងករណីរំលោភបំពានលើភារៈគ្រប់គ្រង ។

ជ- ចុះកិច្ចសន្យាធានាសម្រាប់ការទទួលខុសត្រូវរបស់អ្នកទទួលភារៈគ្រប់គ្រង ។

អ្នកទទួលភារៈគ្រប់គ្រងមិនត្រូវផ្ទេរមុខងារ ទៅកាន់មនុស្សផ្សេងទៀតឡើយ លើកលែងតែក្នុងកាលៈទេសៈទទួលមរណភាព វិសមត្ថភាព ឬក្នុងករណីដែលអ្នកទទួលភារៈគ្រប់គ្រងខកខានក្នុងការបំពេញមុខការរបស់ខ្លួនជាអ្នកទទួលភារៈគ្រប់គ្រងដូចមានចែងក្នុងលក្ខន្តិកៈភារៈគ្រប់គ្រង ។

**មាត្រា៨៩៤**._ ការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់អ្នកទទួលភារៈគ្រប់គ្រង

អ្នកទទួលភារៈគ្រប់គ្រងត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះ៖

ក- ការខូចខាត និងការថយចុះនៃភារៈគ្រប់គ្រងដោយគ្មានហេតុផលសមស្រប ។

ខ- ខកខានក្នុងការប្រមូលចំណូលក្នុងភារៈគ្រប់គ្រង ។

គ- ប្រើប្រាស់ទាយជ្ជទានមិនស្របតាមគោលដៅនៃភារៈគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ ។

ឃ- ការប្រព្រឹត្តកំហុសដោយចេតនា ឬដោយព្រងើយកន្តើយណាមួយក្នុងការអនុវត្តមុខការរបស់ខ្លួន ។

ង- ការចំណាយណាមួយដែលរំលោភទៅលើភារៈគ្រប់គ្រងហិរញ្ញវត្ថុ ។

ច- ធានាបាននូវភាពដាច់ដោយឡែកពីគ្នារវាងទ្រព្យសម្បត្តិភារៈគ្រប់គ្រង និងទ្រព្យឯកជនរបស់ខ្លួន ។

ឆ- ចាត់វិធានការសមស្របសម្រាប់កិច្ចការពារទ្រព្យសម្បត្តិភារៈគ្រប់គ្រង និងអ្នកទទួលផលប្រយោជន៍ដោយការផ្តល់ហេតុផលដែលផ្អែកលើចំណេះ ជំនាញ និងការប្រកបដោយវិជ្ជាជីវៈ ។

ជ- បំពេញតួនាទី ដោយយកចិត្តទុកដាក់ និងប្រុងប្រយ័ត្ន សុចរិតនិងស្មោះត្រង់ និងដោយការថែរក្សា និងការប្រុងប្រយ័ត្នដូចជាការបំពេញការងាររបស់ខ្លួនផ្ទាល់ ។

ឈ- ចៀសវាងទំនាស់ផលប្រយោជន៍ដោយផ្ទាល់ និងប្រយោល ដែលនាំឲ្យប៉ះពាល់ ឬខូចខាតដល់ផលប្រយោជន៍ភារៈគ្រប់គ្រង ។

ញ- បដិសេធផលប្រយោជន៍ផ្សេងៗពីតតិយជន ដែលជាទំនាស់ផលប្រយោជន៍ចំពោះភារៈគ្រប់គ្រង ។

**មាត្រា៨៩៥** ._ ទំនាស់ផលប្រយោជន៍ចំពោះមូលនិធិភារៈគ្រប់គ្រងបរិស្ថាន

ក្នុងអំឡុងពេលនៃការបំពេញភារកិច្ចរបស់ខ្លួន អ្នកទទួលភារៈគ្រប់គ្រង ត្រូវរាយការណ៍អំពីបញ្ហាទំនាស់ផលប្រយោជន៍ មកកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នៅក្នុងករណីដែលផ្អែកលើភស្តុតាង ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានហេតុផលក្នុងការជឿជាក់ថា អ្នកទទួលភារៈគ្រប់គ្រងកំពុងតែប្រព្រឹត្តអំពើដែលមានទំនាស់ផលប្រយោជន៍ចំពោះមូលនិធិភារៈគ្រប់គ្រងបរិស្ថាន ឬ កំពុងតែប្រព្រឹត្តផ្ទុយទៅនឹងផលប្រយោជន៍បរិស្ថាន ឬ សាធារណៈ នោះក្រសួង ស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចសម្របសម្រួលជាមួយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដើម្បីផ្តួចផ្តើមការស៊ើបអង្កេតទៅលើបញ្ហានេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចផ្អាកនូវការទទួលខុសត្រូវរបស់អ្នកទទួលភារៈគ្រប់គ្រង នៅក្នុងករណីដែលការស៊ើបអង្កេតរកឃើញថា អ្នកទទួលភារៈគ្រប់គ្រងមានទំនាស់ផលប្រយោជន៍ចំពោះភារៈគ្រប់គ្រង ។ ប៉ុន្តែ នៅក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានផ្អាកការទទួលខុសត្រូវរបស់អ្នកទទួលភារៈគ្រប់គ្រងមូលនិធិបរិស្ថាន នោះក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងអ្នកទទួលភារៈគ្រប់គ្រងស្តីទីដែលមានលក្ខណៈសម្បត្តិតាមលក្ខខណ្ឌតម្រូវនៃក្រមនេះ និងស្របតាមលក្ខន្តិកៈនៃភារៈគ្រប់គ្រង ។

**មាត្រា៨៩៦** ._ បញ្ជីរបាយការណ៍ប្រចាំឆ្នាំដែលអាចរកបានជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវរក្សានូវបញ្ជីរបាយការណ៍ប្រចាំឆ្នាំដែលអាចស្វែងរកបានជាសាធារណៈនៃមូលនិធិភារៈគ្រប់គ្រងបរិស្ថាន ។

**មាត្រា៨៩៧** ._ ការប្រើប្រាស់ទ្រព្យសម្បត្តិ(ទ្រព្យសកម្ម)នៃមូលនិធិភារៈគ្រប់គ្រងបរិស្ថាន

អ្នកទទួលភារៈគ្រប់គ្រងអាចប្រើប្រាស់ទ្រព្យសម្បត្តិនៃមូលនិធិភារៈគ្រប់គ្រងបរិស្ថានក្នុងការៈ

ក- ផ្តល់មូលនិធិដល់សកម្មភាព ឬ គម្រោងដែលបំពេញតាមគោលដៅមូលនិធិភារៈគ្រប់គ្រងបរិស្ថាន ស្របតាមក្រមនេះ ។

ខ- បង់ថ្លៃសម្រាប់តម្លៃប្រតិបត្តិការនៃមូលនិធិភារៈគ្រប់គ្រងបរិស្ថាន មានជាអាទិ៍ប្រាក់ឈ្នួលរបស់អ្នកទទួលភារៈគ្រប់គ្រង និងថ្លៃចំណាយក្នុងការគ្រប់គ្រងមូលនិធិ ។

គ- ចំណាយទៅលើសកម្មភាពសង្គមដែលស្របទៅនឹងគោលដៅ និងលក្ខន្តិកៈនៃភារៈគ្រប់គ្រង ។

ឃ- ធ្វើការវិនិយោគមូលប័ត្រ និងវិនិយោគនានាដែលមានការទទួលខុសត្រូវផ្នែកបរិស្ថាន និងសង្គម ។

**មាត្រា៨៩៨** ._ ការបញ្ចប់មូលនិធិភារៈគ្រប់គ្រងបរិស្ថាន

ការបញ្ចប់មូលនិធិភារៈគ្រប់គ្រងបរិស្ថានមុនកាលកំណត់ តម្រូវឱ្យមានការយល់ព្រមពីក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងករណីដូចខាងក្រោមៈ

ក- សេចក្តីសម្រេច ដោយឆន្ទានុសិទ្ធិ ឬសំឡេងឆ្នោតភាគច្រើនរបស់អាណត្តិទាយក ។

ខ- ដល់ពេលកំណត់ដែលមានចែងក្នុងលក្ខន្តិកៈភារៈគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ ។

គ- ការរំលោភបំពានធ្ងន់ធ្ងររបស់អ្នកទទួលភារៈគ្រប់គ្រងទៅលើភារៈគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបាននូវការជូនដំណឹងអំពីគ្រប់ដំណាក់កាលទាំងអស់ នៃដំណើរការបញ្ចប់មូលនិធិភារៈគ្រប់គ្រងនេះ ។

**មាត្រា៨៩៩** ._ ការគ្រប់គ្រងមូលនិធិភារៈគ្រប់គ្រងបរិស្ថានដែលត្រូវបានបញ្ឈប់

នៅក្នុងករណីដែលមូលនិធិភារៈគ្រប់គ្រងត្រូវបានបញ្ចប់ អាណត្តិទាយកត្រូវតែងតាំងអ្នករដ្ឋបាលភារៈគ្រប់គ្រងដែលមានវិជ្ជាជីវៈ ដើម្បីគ្រប់គ្រង និងវាយតម្លៃមូលនិធិភារៈគ្រប់គ្រងនោះ ។ អ្នករដ្ឋបាលគ្រប់គ្រងមូលនិធិភារៈគ្រប់គ្រងនោះ ត្រូវមានការទទួលខុសត្រូវដូចខាងក្រោមៈ

ក- បំពេញ និងបញ្ចប់កិច្ចការដែលនៅសេសសល់ របស់អ្នកទទួលភារៈគ្រប់គ្រង ។

ខ- ប្រមូល និងសងបំណុលដែលនៅសេសសល់ និង

គ- វាយតម្លៃមូលនិធិភារៈគ្រប់គ្រងដែលនៅសេសសល់ ។

នៅពេលបំពេញលក្ខខណ្ឌតម្រូវទាំងនេះរួចរាល់ អ្នកគ្រប់គ្រងមូលនិធិភារៈគ្រប់គ្រងត្រូវផ្តល់នូវគណនេយ្យចុងក្រោយ និងផ្តល់របាយការណ៍ជូនក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ ទ្រព្យសម្បត្តិនៃមូលនិធិភារៈគ្រប់គ្រងដែលនៅសេសសល់ត្រូវបែងចែកស្របតាមឯកសារនានាស្តីពីមូលនិធិភារៈគ្រប់គ្រងនោះ ។

ថ្លៃសេវា សម្រាប់អ្នកគ្រប់គ្រងភារៈគ្រប់គ្រង ត្រូវគិតគូរដោយឈរលើមូលដ្ឋាននៃអត្រាវិជ្ជាជីវៈជាស្តង់ដារ និងត្រូវបង់ថ្លៃជូនដោយយកពីទ្រព្យរបស់ភារៈគ្រប់គ្រង។

**មាត្រា៩០០ ._** លក្ខខណ្ឌតម្រូវនៅពេលបញ្ចប់មូលនិធិភារៈគ្រប់គ្រងបរិស្ថាន

មូលនិធិភារៈគ្រប់គ្រងបរិស្ថាន ត្រូវបញ្ចប់ ក្រោយពេលដែល៖

ក- បំណុលនៃមូលនិធិភារៈគ្រប់គ្រងបរិស្ថាននោះ ត្រូវបានទូទាត់ នៅក្នុងករណីដែលមានបំណុលណាមួយ

ខ- មូលនិធិដែលនៅសេសសល់ក្នុងគណនីនៃមូលនិធិភារៈគ្រប់គ្រងបរិស្ថាន និងរាល់ទ្រព្យសម្បត្តិទាំងអស់នៃមូលនិធិភារៈគ្រប់គ្រងបរិស្ថាន ត្រូវបានផ្ទេរស្របតាមក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃៗទៀត និង

គ- រាល់វិវាទទាំងអស់ដែលទាក់ទងនឹងការធ្វើគណនេយ្យចុងក្រោយត្រូវបានដោះស្រាយរួច ។ អ្នកទទួលភារៈគ្រប់គ្រង នៅតែទទួលខុសត្រូវ បន្ទាប់ពីការបញ្ចប់មូលនិធិភារៈគ្រប់គ្រងបរិស្ថាន ចំពោះការបាត់បង់ ឬខូចខាតដែលបានបង្កឡើង និងដែលបណ្តាលមកពីកំហុសដោយចេតនា សេចក្តីធ្វេសប្រហែស ការក្លែងបន្លំ ឬភាពមិនស្មោះត្រង់របស់អ្នកទទួលភារៈគ្រប់គ្រង។

**មាត្រា៩០១ ._** វិវាទទាក់ទងនឹងប្រតិបត្តិការមូលនិធិភារៈគ្រប់គ្រងបរិស្ថាន

រាល់វិវាទដែលទាក់ទងនឹងប្រតិបត្តិការនៃមូលនិធិភារៈគ្រប់គ្រងបរិស្ថាន ត្រូវដោះស្រាយតាមរយៈការផ្សះផ្សា ឬសន្ទានកម្ម ដែលធ្វើឡើងដោយនាយកដ្ឋាននីតិកម្មនៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

វិវាទដែលទាក់ទងនឹងប្រតិបត្តិការនៃមូលនិធិភារៈគ្រប់គ្រងដែលមិនទាន់ចុះបញ្ជីរួច នាយកដ្ឋាននីតិកម្មនៃក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវមានសិទ្ធិក្នុងការលុបចោលនូវភារៈគ្រប់គ្រងនោះ ។

ភាគីណាមួយមិនពេញចិត្តនឹងសេចក្តីសម្រេចដែលធ្វើឡើងដោយនាយកដ្ឋាននីតិកម្មនៃក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើបណ្តឹង ស្របតាមបទប្បញ្ញត្តិស្តីពីការស៊ើបអង្កេត ការពង្រឹងការអនុវត្តច្បាប់ និងដំណោះស្រាយ នៅក្នុងគន្ថីទី៩ នៃក្រមនេះ នៅក្នុងរយៈពេល១ (មួយ)ខែបន្ទាប់ពីបានទទួលសេចក្តីសម្រេច ។

លទ្ធផលនៃដំណើរការដោះស្រាយវិវាទទាំងអស់ ត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា៩០២** ._ ការគ្រប់គ្រងឬការប្រើប្រាស់មូលនិធិភារៈគ្រប់គ្រងបរិស្ថានមិនសមស្រប

អ្នកទទួលភារៈគ្រប់គ្រងណាដែលគ្រប់គ្រង ឬប្រើប្រាស់មូលនិធិភារៈគ្រប់គ្រងបរិស្ថានមិនសមស្រប ឬប្រឆាំងទៅនឹងគោលដៅនៃមូលនិធិភារៈគ្រប់គ្រងបរិស្ថាន ដែលបណ្តាលឲ្យមានការខូចខាតដល់បរិស្ថាន ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ស្របតាមក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ។

## ផ្នែកទី៣
## មូលនិធិដទៃទៀត

**មាត្រា៩០៣** ._ មូលនិធិសម្រាប់ដោះស្រាយទំនាស់បរិស្ថាន និងធនធានធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតមូលនិធិដើម្បីដោះស្រាយវិវាទបរិស្ថាននៅកម្រិតឃុំ សង្កាត់ ដែលស្ថិតនៅក្រោមគម្រោងថវិការបស់ក្រសួងមហាផ្ទៃ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតមូលនិធិមួយ ដើម្បីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ នៃគណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដែលស្ថិតនៅក្រោមគម្រោងថវិការបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៩០៤** ._ ប្រភពនៃមូលនិធិ

ប្រភពមូលនិធិដើម្បីដោះស្រាយ វិវាទបរិស្ថាន និងធនធានធម្មជាតិដូចមានចែងនៅក្នុងមាត្រា ៩០៣ ខាងលើបានមកពី៖

ក- ថវិការជាតិដែលផ្តល់ជូន ។
ខ- វិភាគទានពីរូបវន្តបុគ្គលជាតិ និងអន្តរជាតិ ។
គ- សប្បុរសធម៌ និង
ឃ- ប្រភពដទៃៗទៀត ។

**មាត្រា៩០៥** ._ ការប្រើប្រាស់មូលនិធិ

នីតិវិធីក្នុងការប្រើប្រាស់មូលនិធិដើម្បីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននិងក្រសួងមហាផ្ទៃ ។

## ជំពូកទី៣
## ហិរញ្ញប្បទានសម្រាប់ការបិទ ការស្ដារនីតិសម្បទា ការផ្ដល់ដំណោះស្រាយ និងការស្ដារឡើងវិញនៃសកម្មភាពដែលធ្វើឲ្យប៉ះពាល់បរិស្ថាន

**មាត្រា៩០៦ ._** នីតិវិធីសម្រាប់ការធានាផ្នែកហិរញ្ញវត្ថុ

រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលតម្រូវឲ្យផ្ដល់ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការបិទ ការជួសជុល ការដោះស្រាយ និងការស្ដារឡើងវិញ ត្រូវធ្វើតាមទម្រង់ និងការប្រើប្រាស់វិធីសាស្ត្រដែលកំណត់ដោយច្បាប់ពិសេស លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ឬ កិច្ចព្រមព្រៀង ។

នៅក្នុងករណីដែលមិនមានលក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់ប្រាក់ធានាហិរញ្ញវត្ថុទេ នីតិវិធីនានាដែលស្របទៅនឹងក្រមនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា៩០៧ ._** ថ្លៃចំណាយនៃការបិទគម្រោង

រាល់ម្ចាស់គម្រោង ដែលតម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងរៀបចំផែនការគ្រប់គ្រងបរិស្ថាន ត្រូវដាក់បញ្ចូលការកំណត់ថ្លៃនៃការបិទគម្រោង នៅក្នុងផែនការគ្រប់គ្រងបរិស្ថានដែលត្រូវទទួលការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ ថ្លៃដែលត្រូវបានប៉ាន់ប្រមាណសម្រាប់ការបិទនេះ ត្រូវផ្អែកលើចំនួនដែលបានតម្រូវនៅក្នុងការធានាផ្នែកហិរញ្ញវត្ថុ ។

ការធានាផ្នែកហិរញ្ញវត្ថុ ត្រូវបង្កើតចេញពីចំណូលដែលបំពេញនូវរាល់លក្ខខណ្ឌតម្រូវដូចខាងក្រោម៖

- ក- តម្លៃនៃការបញ្ចប់គម្រោង ។
- ខ- តម្លៃសម្រាប់ការសំអាត ។
- គ- តម្លៃសម្រាប់ផ្ដល់នីតិសម្បទា (ជួសជុលការខូចខាត?) ។
- ឃ- តម្លៃសម្រាប់ការថែទាំ ការអង្កេតតាមដាន និងការថែរក្សាជាអចិន្ត្រៃយ៍
- ង- តម្លៃសម្រាប់ការងាររដ្ឋបាល និង
- ច- តម្លៃសម្រាប់ការត្រៀមបម្រុងទុក១៥ (ដប់ប្រាំ)ភាគរយ នៃតម្លៃចំណាយសរុប ។

ចំនួនទាំងនេះ ត្រូវបូកសរុបដោយផ្អែកលើថ្លៃដែលកំណត់ដោយតតិយជនសម្រាប់ការស្តារតំបន់ដែលបានរងការប៉ះពាល់ ឲ្យស្របទៅតាមតម្លៃសេដ្ឋកិច្ច និងសង្គមដែលសមរម្យបំផុត ព្រមទាំងត្រូវគិតគូរអំពីកត្តាអតិផរណា ។

ចំនួនសរុបទាំងអស់ដែលតម្រូវដោយការធានាផ្នែកហិរញ្ញវត្ថុ ក្នុងទម្រង់ឯកភាពមួយ ដូចដែលមានចែងក្នុងមាត្រា៩០៨ ត្រូវបង់នៅមុនការចាប់ផ្តើមការងារនៃគម្រោង សម្រាប់គម្រោងទាំងឡាយណាដែលមានអាយុកាល៥(ប្រាំ)ឆ្នាំ ឬក្រោម៥(ប្រាំ)ឆ្នាំ ឬ ក្នុងដំណាក់កាលរុករកស្រាវជ្រាវ ។

ការបង់ថ្លៃបន្ថែមអាចនឹងត្រូវបានរៀបចំឡើងសម្រាប់គម្រោង ដែលមានអាយុកាលលើសពី៥(ប្រាំ)ឆ្នាំ ឬក្នុងដំណាក់កាលរុករកស្រាវជ្រាវ ។ ចំនួនសរុបទាំងអស់ដែលតម្រូវដោយការធានាផ្នែកហិរញ្ញវត្ថុ ត្រូវបង់នៅចុងឆ្នាំទី៥(ប្រាំ) នៃប្រតិបត្តិការគម្រោង ។

**មាត្រា៩០៨ ._** ទម្រង់បែបបទនៃការធានាផ្នែកហិរញ្ញវត្ថុ

ការធានាផ្នែកហិរញ្ញវត្ថុ អាចធ្វើឡើងជាទម្រង់នៃលិខិតឥណទាន ប័ណ្ណប៉ាតង់នៃការធានាមូលនិធិភារៈគ្រប់គ្រង ឬមូលនិធិជាសាច់ប្រាក់ ។ ម្ចាស់គម្រោង អាចស្នើឲ្យមានការផ្តល់ជាការធានារួមគ្នាមួយក្រៅពីការធានាផ្នែកហិរញ្ញវត្ថុ ។ ម្ចាស់គម្រោងអាចបង្ហាញថា ខ្លួនមានថវិកាគ្រប់គ្រាន់ដើម្បីនឹងធ្វើការបង់ថ្លៃជាអប្បបរមាក្នុងការអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការបិទគម្រោង ។

នៅក្នុងការកំណត់ថាការធានារួមគ្នាមួយមានលក្ខណៈសមស្រប ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចពិចារណាទៅលើសាវតាហិរញ្ញវត្ថុរបស់ម្ចាស់គម្រោង ភស្តុតាងនៃស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្នរបស់ម្ចាស់គម្រោង និងកត្តាផ្សេងៗទៀតដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ចាត់ទុកថាអាចយកមកអនុវត្តបាន ។

**មាត្រា៩០៩ ._** ការគ្រប់គ្រង និងការធានាផ្នែកហិរញ្ញវត្ថុ

ក្នុងករណីដែលការធានាផ្នែកហិរញ្ញវត្ថុ ត្រូវបានផ្តល់មកជាទម្រង់មូលនិធិភារៈគ្រប់គ្រង ឬមូលនិធិជាសាច់ប្រាក់ ចំនួនប្រាក់ទាំងនោះ ត្រូវដាក់ចូលទៅក្នុងគណនីដែលមានការប្រាក់ ដែលគ្រប់គ្រងដោយនីតិបុគ្គលឯករាជ្យមួយក្រៅពីម្ចាស់គម្រោង ។ បន្ទាប់ពីមានការបិទគម្រោងប្រកបដោយជោគជ័យហើយ នោះរាល់មូលនិធិដែលនៅសល់ ត្រូវប្រគល់ជូនដល់ម្ចាស់គម្រោងវិញ ។

ម្ចាស់គម្រោង ត្រូវធ្វើការចាត់តាំងឲ្យមានអ្នកឯកទេសផ្នែកវិនិយោគ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងនាមជានាយកគ្រប់គ្រងមូលនិធិ ដើម្បីទទួលខុសត្រូវក្នុងការថែរក្សាថវិកា និង ធានាថារាល់ប្រតិបត្តិការទាំងអស់មានការកត់ត្រាបានត្រឹមត្រូវ និងដាក់ឱ្យសាធារណជនអាចស្វែងរកបាន។

**មាត្រា៩១០ ._** លក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំរបាយការណ៍ និងសវនកម្ម

ម្ចាស់គម្រោងណាដែលតម្រូវឲ្យផ្តល់ការធានាផ្នែកហិរញ្ញវត្ថុដើម្បីទូទាត់ថ្លៃចំណាយសម្រាប់ការបិទ ការស្តារនីតិសម្បទា ការផ្តល់ដំណោះស្រាយ និងការស្តារឡើងវិញ ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវនៃការធ្វើសវនកម្ម និងការរៀបចំរបាយការណ៍ស្របតាមលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធស្តីពីគណនេយ្យ និងសវនកម្ម ។

ម្ចាស់គម្រោង ត្រូវធ្វើការពិនិត្យឡើងវិញជាប្រចាំឆ្នាំ និងធ្វើរបាយការណ៍អំពីការប៉ាន់ប្រមាណថ្លៃនៃការបិទគម្រោង ជូនដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ ការធ្វើការប៉ាន់ប្រមាណនេះត្រូវធ្វើឡើងដោយវិស្វករដែលមានវិញ្ញាបនបត្រ ។

ក្នុងករណីដែលរបាយការណ៍សវនកម្មប្រចាំឆ្នាំបង្ហាញថា មិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការធានាផ្នែកហិរញ្ញវត្ថុនោះទេ នោះម្ចាស់គម្រោងត្រូវជូនដំណឹងដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធដទៃទៀត ។

ម្ចាស់គម្រោង ត្រូវបំពេញរាល់លក្ខខណ្ឌតម្រូវដែលបានធ្វើបច្ចុប្បន្នភាព សម្រាប់ការធានាផ្នែកហិរញ្ញវត្ថុ ក្នុងរយៈពេល៣០(សាមសិប) ថ្ងៃ បន្ទាប់ពីមានការជូនដំណឹងខាងលើ ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានអាចតម្រូវឲ្យមានរបាយការណ៍ ឬឯកសារបន្ថែម ។

ក្នុងករណីដែលរបាយការណ៍សវនកម្មប្រចាំឆ្នាំបង្ហាញថា មានការលើសចំនួនក្នុងការធានាផ្នែកហិរញ្ញវត្ថុ ដែលតម្រូវដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន នោះក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានអាចស្នើក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យអនុញ្ញាតឲ្យបង្វិលថវិកាដែលលើសចំនួនទៅវិញបន្ទាប់ពីមានសំណើពីម្ចាស់គម្រោង ។

**មាត្រា៩១១ ._** លិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីនៃការគណនាតម្លៃនៃការបិទគម្រោង

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីការគណនាថ្លៃនៃការបិទគម្រោង បែបបទនៃការដាក់ពាក្យសុំ និងការឯកភាព លក្ខខណ្ឌតម្រូវសម្រាប់ការពិនិត្យ នីតិវិធីសម្រាប់ការផ្តល់ជូនវិញ និងការកាត់បន្ថយ ឬការលើកលែងផ្សេងៗ ។

**មាត្រា៩១២ ._** ការស្តារឡើងវិញនូវការខូចខាត និងការទទួលបានវិញនូវថ្លៃចំណាយ និងការចំណាយផ្សេងៗ

រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចអនុវត្តនូវការស្តារឱ្យដូចដើមវិញដែលចាំបាច់ លើការខូចខាតចំពោះធនធានរបស់ព្រះរាជាណាចក្រកម្ពុជា និងអាចទទួលបានវិញនូវតម្លៃខាតបង់ និងការចំណាយផ្សេងៗស្របតាមបទប្បញ្ញត្តិនានានៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ។

## ជំពូកទី៤
## បទប្បញ្ញត្តិផ្សេងទៀត

**មាត្រា៩១៣ ._** សហគ្រាសដែលផ្ដោតលើសន្តិសុខជាតិនៃព្រះរាជាណាចក្រកម្ពុជា

សហគ្រាសដែលពាក់ព័ន្ធបញ្ហាសន្តិសុខជាតិ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវគ្រប់គ្រងដោយនីតិបុគ្គលសាធារណៈ ។ នីតិវិធីនៃការបង្កើតសហគ្រាសដែលមានលក្ខណៈបែបនេះ ត្រូវស្របតាមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ។

**មាត្រា៩១៤ ._** ការបង្កើត សហគ្រាសដែលគ្រប់គ្រងដោយរដ្ឋ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយស្របតាម លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត អាចស្នើសុំបង្កើតសហគ្រាសដែលគ្រប់គ្រងដោយរដ្ឋ មានជាអាទិ៍ សហគ្រាសទាំងឡាយណាដែលផ្ដល់អំណាចទៅ អាជ្ញាធរថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចសម្រាប់គោលដៅគាំទ្រដល់គោលដៅនៃនិរន្តរភាព កិច្ចការពារបរិស្ថាន កិច្ចការពារជីវៈចម្រុះ និងការគ្រប់គ្រងសំណល់របស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៩១៥ ._** ធនាគារអភិរក្ស ឬកាត់បន្ថយ

ព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយមានកិច្ចសហការជាមួយធនាគារជាតិនៃកម្ពុជា និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចបង្កើតធនាគារអភិរក្ស ឬធនាគារកាត់បន្ថយមួយ ។

ព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចចុះកិច្ចសន្យារកស៊ីរួមគ្នា ស្របតាមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ដែលក្នុងនោះព្រះរាជាណាចក្រកម្ពុជាមានការគ្រប់គ្រងភាគច្រើន ។

ព្រះរាជាណាចក្រកម្ពុជា ត្រូវមានការគ្រប់គ្រងភាគច្រើន ទៅលើធនាគារអភិរក្ស ឬធនាគារកាត់បន្ថយ ។

## គន្ថីទី៩
## ការដោះស្រាយបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិ

## មាតិកាទី១
## នីតិវិធីដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ
## ជំពូកទី១
## នីតិវិធីដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈរដ្ឋប្បវេណី និងរដ្ឋបាល
## ផ្នែកទី១
## បណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៩១៦** ._ បណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណី ធ្វើឡើងក្នុងគោលដៅដើម្បីធានានូវសិទ្ធិក្នុងការទាមទារសំណងការខូចខាតផ្នែកសម្ភារៈ ផ្នែករូបរាងកាយ និងផ្លូវចិត្ត ។

ចំពោះបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងអាចប្រើប្រាស់សិទ្ធិដូចមានចែងក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា៩១៧** ._ បណ្តឹងអាជ្ញា

បណ្តឹងអាជ្ញា ធ្វើឡើងក្នុងគោលដៅដើម្បីធានាដល់សណ្តាប់ធ្នាប់សាធារណៈ ឬផលប្រយោជន៍សង្គមទូទៅ ដូច្នេះក្នុងករណីមានបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ឬការមិនអនុវត្តបទប្បញ្ញត្តិណាមួយដែលបំពាននឹងវិធាននៃក្រមនេះ ជនរងគ្រោះ ឬសាធារណជនទូទៅ មានសិទ្ធិធ្វើបណ្តឹងទៅតុលាការមានសមត្ថកិច្ចបាន ។

ចំពោះបែបបទ និងនីតិវិធីនៃការធ្វើបណ្តឹងអាជ្ញា ត្រូវអនុលោមតាមក្រមបរិស្ថាន និងធនធានធម្មជាតិ និងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា៩១៨** ._ បណ្តឹងប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

បណ្តឹងប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ធ្វើឡើងក្នុងគោលដៅដើម្បីប្រឆាំងនឹងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិដែលពាក់ព័ន្ធនឹងវិធានការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលរងគ្រោះ ឬសាធារណជនដែលរងផលប៉ះពាល់ដោយសារសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ អាចប្រើប្រាស់សិទ្ធិក្នុងការប្តឹងតវ៉ាដោយអនុលោមតាមក្រមនេះ ។

**មាត្រា៩១៩** ._ បណ្តឹងប្រឆាំងសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

បណ្តឹងប្រឆាំងសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ធ្វើឡើងក្នុងគោលដៅដើម្បីទាមទារសំណងការខូចខាតបរិស្ថាន ឬធនធានធម្មជាតិដែលកើតឡើងដោយសារបំពេញមុខងាររបស់មន្ត្រីរាជការសាធារណៈ ឬអាជ្ញាធរមានសមត្ថកិច្ចដែលទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ក្នុងការធ្វើសកម្មភាព ចំណាត់ការ ឬវិធានការលើសកម្មភាពបរិស្ថាន ឬការគ្រប់គ្រងធនធានធម្មជាតិដែលបង្កព្យសនកម្ម ឬបំពុលបរិស្ថាន ឬការបំពានសិទ្ធិ ឬផលប្រយោជន៍ណាដល់ភាគីរងផលប៉ះពាល់ ។

រូបវន្តបុគ្គល ឬនីតិបុគ្គល អាចប្រើប្រាស់សិទ្ធិក្នុងការដាក់ពាក្យបណ្តឹងដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ទៅអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការមានសមត្ថកិច្ចបាន ដោយអនុលោមតាមក្រមនេះ ។

**មាត្រា៩២០** ._ បណ្តឹងដែលមានគោលដៅការពារផលប្រយោជន៍សាធារណៈ

បណ្តឹងដែលមានគោលដៅការពារផលប្រយោជន៍សាធារណៈ ធ្វើឡើងក្នុងគោលដៅដើម្បីការពារផលប្រយោជន៍សាធារណៈ ប្រឆាំងនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ឬការមិនអនុវត្តបទប្បញ្ញតិដូចមានចែងក្នុងក្រមនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។

រូបវន្តបុគ្គល ឬនិតីបុគ្គលអាចប្រើប្រាស់សិទ្ធិក្នុងការដាក់ពាក្យបណ្តឹងដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ទៅតុលាការមានសមត្ថកិច្ច ឬស្ថាប័នមានសមត្ថកិច្ចដោយអនុលោមតាមក្រមនេះ ។

**មាត្រា៩២១** ._ បណ្តឹងជាយុទ្ធសាស្ត្រក្នុងការទប់ស្កាត់ការចូលរួមជាសាធារណៈ

បណ្តឹងជាយុទ្ធសាស្ត្រប្រឆាំងការចូលរួមជាសាធារណៈ ធ្វើឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គលក្នុងគោលដៅដើម្បីទប់ស្កាត់ ឬរារាំង ឬគៀបសង្កត់បណ្តឹងរបស់សាធារណជនទាំងឡាយដែលមានចេតនាទុច្ចរិតក្នុងការធ្វើសកម្មភាពបណ្តឹងដែលធ្វើឲ្យខូច កេរ្តិ៍ឈ្មោះ ឬខូចផលប្រយោជន៍ហិរញ្ញវត្ថុរបស់រូបវន្ត ឬនីតិបុគ្គលនោះ ។

## ផ្នែកទី២
## ភាគីនៃបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៩២២** ._ ភាគីដែលទទួលរងផលប៉ះពាល់

បុគ្គលដែលរងផលប៉ះពាល់ផ្ទាល់ ឬប្រយោលដោយបទល្មើសបរិស្ថាន និងធនធានធម្មជាតិមានសិទ្ធិដាក់ពាក្យបណ្តឹងទៅស្ថាប័ន ឬតុលាការមានសមត្ថកិច្ច ដើម្បីទាមទារសំណងការខូចខាត ឬសំណងជំងឺចិត្ត ដោយអនុលោមតាមក្រមនេះ និងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

បណ្តឹងនេះក៏អាចធ្វើឡើងដោយសហគមន៍ ដើម្បីប្រឆាំងនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ឬការមិនអនុវត្តបទប្បញ្ញត្តិដូចមានចែងក្នុងក្រមនេះ និងក្រមនីតិវិធីរដ្ឋវេណីជាធរមានបាន

ដែរតាមរយៈតំណាងរបស់ខ្លួន ។ អ្នកតំណាងសហគមន៍នេះត្រូវមានភស្តុតាង ដែលបញ្ជាក់ថាមានការប្រគល់សិទ្ធិត្រឹមត្រូវពីសហគមន៍ ។

**មាត្រា៩២៣** ._ សមាគមន៍ ឬអង្គការដែលមាននីតិសម្បទា

គ្រប់សមាគមន៍ ឬអង្គការដែលបានចុះបញ្ជី និងទទួលស្គាល់ដោយអាជ្ញាធរស្របច្បាប់ត្រឹមត្រូវនៃព្រះរាជាណាចក្រកម្ពុជា ទើបអាចប្រើប្រាស់សិទ្ធិក្នុងការធ្វើបណ្តឹងបរិស្ថាន និងធនធានធម្មជាតិទៅស្ថាប័ន និងតុលាការមានសមត្ថកិច្ច
បាន ។

បណ្តឹងរបស់សមាគមន៍ ឬអង្គការទាំងនេះ ត្រូវធ្វើឡើងក្នុងគោលបំណងដើម្បីទាមទារឲ្យមានការស្តារបរិស្ថានឡើងវិញ ឬទាមទារសំណងការខូចខាត ឬសំណងជំងឺចិត្តជូនជនរងគ្រោះ ឬសហគមន៍តែប៉ុណ្ណោះ ។

ក្នុងករណីដែលបណ្តឹងដែលធ្វើឡើងក្នុងគោលដៅដើម្បីទាមទារសំណងការខូចខាត ឬសំណងជំងឺចិត្ត ជូនជនរងគ្រោះ ឬសហគមន៍ ត្រូវមានមានភស្តុតាងបញ្ជាក់ថា បានទទួលការប្រគល់សិទ្ធិពីតំណាងសហគមន៍ ឬសហគមន៍ ។

**មាត្រា៩២៤** ._ ភាពអាចទទួលយកបាននៃបណ្តឹងរបស់សមាគមន៍ ឬអង្គការ

ក្នុងករណីដែលបណ្តឹងដែលធ្វើឡើងដូចមានចែងក្នុងមាត្រា៩១៦ខាងលើនេះ បណ្តឹងរបស់សមាគមន៍ឬ អង្គការទាំងនោះ អាចទទួលយកបាន លុះត្រាតែមានភស្តុតាងដែលបញ្ជាក់ថា បានទទួលការយល់ព្រមពីជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់នៃជននេះ ឬសហគមន៍ ឬតំណាងសហគមន៍នេះចំពោះការទាមទារសំណងផ្នែករដ្ឋប្បវេណី ។

ប៉ុន្តែក្នុងករណីដែលបណ្តឹងរបស់សមាគមន៍ ឬអង្គការដែលមានចែងក្នុងកថាខណ្ឌខាងលើនេះ អាចធ្វើទៅបានដោយពុំចាំបាច់មានភស្តុតាងដែលបញ្ជាក់ថា បានទទួលការយល់ព្រមពីជនរងគ្រោះ ឬសហគមន៍ ឬតំណាងសហគមន៍ឡើយ ប្រសិនបើបណ្តឹងនោះធ្វើឡើងក្នុងគោលដៅដើម្បីទាមទារឲ្យមានកិច្ចការពារបរិស្ថាន អភិរក្សជីវៈចម្រុះ ឬការស្តារបរិស្ថានឡើងវិញដើម្បីបម្រើផលប្រយោជន៍សាធារណៈទូទៅ ។

**មាត្រា៩២៥** ._ បណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ អាចប្រើប្រាស់សិទ្ធិក្នុងការធ្វើសកម្មភាពប្តឹងទាមទារសំណងការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ឬស្តារបរិស្ថានឡើងវិញ ឬប្តឹងប្រឆាំង ឲ្យមានការបញ្ឈប់សកម្មភាពណាមួយដែលបង្កផលប៉ះពាល់ ឬបំពុលបរិស្ថាន និងធនធានធម្មជាតិ ឬមិនអនុវត្តបទប្បញ្ញត្តិដូចមានចែងក្នុងក្រមនេះ ទៅស្ថាប័ន ឬតុលាការមានសមត្ថកិច្ចបាន ។

## ផ្នែកទី៣
## ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

**មាត្រា៩២៦** ._ គោលបំណងការដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិក្រៅប្រព័ន្ធតុលាការ មានគោលបំណងកំណត់អំពីវិធានដើម្បីដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈជារដ្ឋប្បវេណី និងរដ្ឋបាល ក្រៅប្រព័ន្ធតុលាការដោយស្ម័គ្រចិត្ត ។

**មាត្រា៩២៧** ._វិសាលភាពនៃការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិក្រៅប្រព័ន្ធតុលាការចំពោះបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ មានវិសាលភាពអនុវត្តលើវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈជារដ្ឋប្បវេណីទៅលើបណ្តឹងទាមទារដូចខាងក្រោម៖

ក-ការសងសំណងការខូចខាត ។

ខ-ការស្តារការខូចខាតបរិស្ថានឡើងវិញ ។

គ-ការកំណត់ពីវិធានការដើម្បីធានាថា នឹងមិនបង្កការបំពុលបរិស្ថាន ឬការធ្វើឲ្យខូចខាតបរិស្ថានសាជាថ្មីឡើងវិញដោយអ្នកបង្ក ។

ឃ-កំណត់វិធានការទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមានដែលកើតមានចំពោះបរិស្ថាន និងធនធានធម្មជាតិ ។

ង-ពុំមានវិសាលភាពអនុវត្តលើបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈព្រហ្មទណ្ឌ ដែលបានកំណត់ដោយក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀតឡើយ ។

ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដូចបានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់គណៈកម្មការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ និងគណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩២៨** ._ ការដោះស្រាយវិវាទប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

បណ្តឹងប្រឆាំងនឹងសេក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ដែលកើតចេញពីសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ក្រោមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និង

គ្រប់គ្រងធនធានផ្សេងទៀត ត្រូវស្ថិតក្រោមសមត្ថកិច្ចដោះស្រាយរបស់គណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន ។

**មាត្រា៩២៩** ._ គណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវបង្កើត និងរៀបចំដំណើរការប្រព្រឹត្តទៅនៃគណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិមួយដើម្បីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈជាបណ្ដឹងរដ្ឋប្បវេណីនៅសាលាឃុំ សង្កាត់របស់ខ្លួន ។

សមត្ថកិច្ចរបស់គណៈកម្មការសន្ធានកម្មនេះ ត្រូវកំណត់ដោយក្រមនេះ ។ ការរៀបចំថវិកាសម្រាប់ដំណើរការលើសេវាកម្មដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដោយសន្ធានកម្មនេះ ត្រូវកំណត់លិខិតបទដ្ឋានគតិយុតអន្តរក្រសួងរវាង ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួងមហាផ្ទៃ ។

**មាត្រា៩៣០** ._ សមត្ថកិច្ចរបស់គណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

គណៈកម្មការសន្ធានកម្មបបរិស្ថានថ្នាក់ឃុំ សង្កាត់ មានសមត្ថកិច្ចដូចខាងក្រោម៖

ក. ទទួលពាក្យបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិ ។

ខ.បញ្ជូនបន្តនូវបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ទៅកាន់អង្គភាព ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ឬគណៈកម្មាការជាតិដោះស្រាយវិវាទបរិស្ថាន ក្នុងករណីដែលបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិមិនអាចដោះស្រាយបាននៅដំណាក់កាលសន្ធានកម្មក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

គ. ផ្ដល់សេវាពិគ្រោះយោបល់វិវាទបរិស្ថាន និងធនធានធម្មជាតិ និងរក្សាការសម្ងាត់ ។

គ. ធ្វើការចុះពិនិត្យទីតាំងទំនាស់ ។

ឃ. ទទួលដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈរដ្ឋប្បវេណី ។

ង. ធ្វើការផ្សះផ្សាវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

ច. រៀបចំកិច្ចព្រមព្រៀងតាមការឯកភាពរបស់គូភាគីវិវាទ និងតាមដានការអនុវត្តកិច្ចព្រមព្រៀងសះជា ។

ឆ. រក្សាទុកកំណត់ហេតុ ឬឯកសារនៃដំណើរការរបស់គណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ដូចជាសំណុំបែបបទ កិច្ចព្រមព្រៀងសះជានានា ឬឯកសារពាក់ព័ន្ធផ្សេងៗទៀត ។

ជ. បញ្ជូនសំណុំរឿង និងកិច្ចព្រមព្រៀងសះជាទៅគណៈកម្មការជាតិដោះស្រាយវិវាទក្នុងករណីដែលគូភាគីមានវិវាទមិនអនុវត្តតាមកិច្ចព្រមព្រៀងសះជាដោយគណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ។

គណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ មិនអាចធ្វើការផ្សះផ្សាទៅលើបណ្តឹងបរិស្ថាន និងធនធានធម្មជាតិណាមួយដែលបាន ឬកំពុងដោះស្រាយដោយនីតិវិធីក្រោមច្បាប់ដែលនៅជាធរមានកន្លងមក បើទោះបីជាបណ្តឹងនោះស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់គណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិរបស់ខ្លួនក៏ដោយ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃនីតិវិធីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិរបស់គណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួងមហាផ្ទៃ ។

**មាត្រា៩៣១** ._ សមាសភាពនៃគណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

គណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ មានសមាសភាពសមាជិកចំនួន៣(បី)រូបដែលមាន១(មួយ)រូបជាប្រធានសម្រាប់ដឹកនាំនីតិវិធីនៃការដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ និង២(ពីរ)រូបជាសមាជិក ។ សមាជិក២(ពីរ)រូបត្រូវជ្រើសរើសដោយគូភាគីនៃវិវាទ ហើយសមាជិក២(ពីរ)រូបនេះជាអ្នកជ្រើសរើសសន្ធានការីម្នាក់ទៀតជាប្រធាន ។

នីតិវិធីនៃការការរៀបចំជ្រើសរើស និងធ្វើបញ្ជីឈ្មោះសន្ធានការីបរិស្ថាន និងធនធានធម្មជាតិត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៩៣២** ._ លក្ខណៈសម្បត្តិនៃសមាសភាពគណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

សមាសភាពនៃគណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

ក-អាយុចាប់ពី៣០ឆ្នាំឡើង ។

ខ-កម្រិតវប្បធម៌យ៉ាងតិចកម្រិតបឋមភូមិ ។

គ-មានសមត្ថភាព និងបទពិសោធន៍ការងារពាក់ព័ន្ធនៃបរិស្ថានយ៉ាងតិច២ឆ្នាំ ។

ឃ-មានភាពស្មោះត្រង់ សុចរិតភាព និងមិនលំអៀង ។

ង- រក្សាការសម្ងាត់ ។

គណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់នីមួយៗ អាចជ្រើសរើសអ្នកជំនាញការបច្ចេសទេសវិទ្យាសាស្ត្រមួយរូប ឬច្រើនធ្វើជាអ្នកប្រឹក្សាយោបល់ផ្នែកបច្ចេកទេស តាមការចាំបាច់អាស្រ័យតាមលក្ខណៈស្មុគស្មាញនៃវិវាទ ។ អ្នកជំនាញបច្ចេកទេសត្រូវបំពេញការងារត្រឹមតែតាមការស្នើសុំរបស់គណៈកម្មការសន្ធានកម្មបរិស្ថានថ្នាក់ឃុំ សង្កាត់ និងផ្តល់សេចក្តីសន្និដ្ឋានបច្ចេកទេសជូនគណៈកម្មការសន្ធានកម្មបរិស្ថាន និងភាគី តែប៉ុណ្ណោះ ។

នីតិវិធីនៃការជ្រើសរើស និងរៀបចំបញ្ជីឈ្មោះអ្នកជំនាញបច្ចេកទេសវិទ្យាសាស្ត្របរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា៩៣៣** ._ រយៈពេលនៃដំណើរការផ្សះផ្សារបស់គណៈកម្មការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

គណៈកម្មការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ មានរយៈពេលយ៉ាងយូរបំផុត ៤៥ (សែសិបប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីធ្វើដំណើរការផ្សះផ្សាវិវាទបរិស្ថាន និងធនធានធម្មជាតិ ។ រយៈពេលនេះអាចពន្យាពេលបាន ក្នុងករណីដែលគូភាគីវិវាទបានព្រមព្រៀង តាមការស្នើសុំ របស់គណៈកម្មការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ។

ក្នុងករណីដែលដំណើរការនៃការផ្សះផ្សារបស់គណៈកម្មការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់មិនអាចសម្រេចទៅបានក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌខាងលើនេះទេ គណៈកម្មការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ត្រូវបញ្ជូនបណ្តឹងនេះបន្តទៅគណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដើម្បីធ្វើចំណាត់ការបន្ត យ៉ាងយូរបំផុតក្នុងរយៈពេល២១ (ម្ភៃមួយ)ថ្ងៃនៃថ្ងៃធ្វើការ ។

**មាត្រា៩៣៤** ._ ការបញ្ចប់នៃដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានបញ្ចប់ដោយមូលហេតុដូចខាងក្រោម៖

ក- គូភាគីបានឯកភាពគ្នាបញ្ចប់នីតិវិធីនៃដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

ខ- ភាគីណាមួយមិនឯកភាព ឬសហការក្នុងការដោះស្រាយវិវាទតាមនីតិវិធីសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

គ- គូភាគីមិនអាចឈានដល់ការឯកភាពគ្នា លើវិវាទបរិស្ថាន និងធនធានធម្មជាតិក្នុងរយៈពេល៤៥ ថ្ងៃ ឬក្នុងរយៈពេលដែលបានពន្យាតាមការព្រមព្រៀងរបស់គូភាគី បានកន្លងផុតទៅ ។

ឃ- គូភាគីបានឯកភាពលើកិច្ចព្រមព្រៀង ជាលាយលក្ខណ៍អក្សរតាមការផ្សះផ្សារបស់គណៈកម្មការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ។

កិច្ចព្រមព្រៀងសះជារបស់គណៈកម្មការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ពុំចងកាតព្វកិច្ចផ្លូវច្បាប់ឡើយ ។

**មាត្រា៩៣៥** ._ ដំណោះស្រាយ

កិច្ចព្រមព្រៀងនីមួយៗដែលត្រូវបានផ្សះផ្សាដោយគណៈកម្មការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ដោយមានការឯកភាពពីភាគីចូលរួម ត្រូវបញ្ចូលចំណុចមួយចំនួនដូចខាងក្រោម៖

ក. កំណត់អំពីប្រាក់សំណងសម្រាប់ការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ។

ខ. កំណត់អំពីវិធីសាស្ត្រនៅក្នុងការស្តារបរិស្ថាន និងធនធានធម្មជាតិឡើងវិញនៃការខូតខាតដែលបានកើតឡើង ។

គ. កំណត់អំពីវិធានការដើម្បីធានាថា នឹងមិនមានគ្រោះថ្នាក់បន្ថែមទៀតទេទៅដល់បរិស្ថាន និងធនធានធម្មជាតិ ។

ឃ. កំណត់អំពីវិធានដើម្បីទប់ស្កាត់ការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ។

ការវាយតម្លៃការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុវត្តស្របតាមមាត្រា ១៩៤០នៃក្រមនេះ ។

**មាត្រា៩៣៦** ._ គណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ

គណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានបង្កើតដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ គណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាសេនាធិការនៅក្នុងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ លេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយរូប ឬច្រើនរូបជាជំនួយការតាមការចាំបាច់ ។

ការរៀបចំ និងប្រព្រឹត្តទៅនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តតាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

គណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិនេះ មានក្រុមប្រឹក្សាពីរដាច់ដោយឡែកពីគ្នា ។ ក្រុមប្រឹក្សាជាតិទី១ ដើរតួនាទីជាក្រុមសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិដែលទទួលបន្ទុកដោះស្រាយបណ្តឹង ឬវិវាទបរិស្ថាន និងធនធានធម្មជាតិដែលបញ្ជូនមកពីគណៈកម្មការសន្ទានកម្មថ្នាក់ឃុំ សង្កាត់ ក្រុមប្រឹក្សាជាតិ ទី២ ដើរតួនាទីជាក្រុមដោះស្រាយបណ្តឹងប្រឆាំង នឹងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ពាក់ព័ន្ធបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា៩៣៧** ._ ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួងបរិស្ថាន ។

សមាសភាពនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិខាងលើនេះ មានដូចខាងក្រោម៖

ក- មន្ត្រីជំនាញ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ជាប្រធាន ។

ខ- មន្ត្រីជំនាញក្រសួងពាក់ព័ន្ធពាក់ព័ន្ធនឹងវិវាទបរិស្ថាន និងធនធានធម្មជាតិ ជាសមាជិក ។

គ- ក្រុមអ្នកជំនាញបច្ចេកទេសវិទ្យាសាស្រ្ត តាមការចាំបាច់ ជាសមាជិក ។

ឃ- អង្គការសង្គមស៊ីវិលជាតិដែលធ្វើការពាក់ព័ន្ធបរិស្ថាន និងធនធានធម្មជាតិ តាមការចាំបាច់ ជាសមាជិក ។

សមាជិកនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ មានអាណត្តិ៥ (ប្រាំ) ឆ្នាំ ត្រូវបានតែងតាំងសាជាថ្មី លើកលែងតែមានការលាលែង មរណភាព ដកហូតតំណែងដោយកំហុសណាមួយដែលមានចែងក្នុងក្រមប្រតិបត្តិ និងបទបញ្ជាផ្ទៃក្នុង ។

**មាត្រា៩៣៨** ._ សមត្ថកិច្ចនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិមានសមត្ថកិច្ចដូចខាងក្រោម៖

ក-ដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលបានបញ្ជូនមកពីគណៈកម្មការសន្ទានកម្មបរិស្ថានថ្នាក់ឃុំ សង្កាត់ ។

ខ-មានសិទ្ធិអំណាចក្នុងការស៊ើបអង្កេត និងសាកសួរព័ត៌មានពាក់ព័ន្ធនឹងវិវាទ ។

គ-រៀបចំកិច្ចព្រមព្រៀងសះជាដោយមានការឯកភាពពីគូភាគី លើបណ្តឹងពាក់ព័ន្ធនឹងវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

ឃ-ពិនិត្យដោះស្រាយសំណើដោះស្រាយវិវាទរបស់ភាគីវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

ង-មានសិទ្ធិអំណាចបង្គាប់ឲ្យគូភាគីដាក់ ឬបង្ហាញឯកសារ ព័ត៌មានដែលពាក់ព័ន្ធនឹងចំណុចវិវាទ ។

ច-មានសិទ្ធិស្នើសុំជំនួយពីអ្នកជំនាញការផ្សេងៗពីក្រសួង ស្ថាប័ននានា ។

ឆ-មានសិទ្ធិស្នើសុំឲ្យមានការសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ជ-រៀបចំ និងបង្កើតបទបញ្ជាផ្ទៃក្នុង និងក្រមប្រតិបត្តិ ។

**មាត្រា៩៣៩** ._ លក្ខណៈសម្បត្តិនៃសមាជិកក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

សមាជិកនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

ក- អាយុចាប់ពី៣៥ (សាមសិប) ឆ្នាំឡើង ។

ខ- កម្រិតវប្បធម៌យ៉ាងតិចបរិញ្ញាបត្រ ។

គ- មានសមត្ថភាព និងបទពិសោធន៍ការងារពាក់ព័ន្ធនឹងវិស័យបរិស្ថានយ៉ាងតិច៥ (ប្រាំ)ឆ្នាំ ។

ឃ- មានភាពស្មោះត្រង់ សុចរិតភាព និងមិនលំអៀង ។

ង- រក្សាការសម្ងាត់ ។

**មាត្រា៩៤០ ._** រយៈពេលនៃដំណើរការផ្សះផ្សារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ មានរយៈពេលយ៉ាងយូរបំផុត ៦ (ប្រាំមួយ) ខែ ដើម្បីដំណើរការផ្សះផ្សាវិវាទ ដែលរយៈពេលនេះគិតចាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹង។

រយៈពេលដូចមានចែងក្នុងកថាខណ្ឌខាងលើនេះអាចពន្យាពេលបាន ដោយមានការព្រមព្រៀងពីគូភាគី តាមការស្នើសុំរបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន ។

ក្នុងករណីដែលដំណើរការនៃការផ្សះផ្សារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ មិនអាចសម្រេចទៅបានក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌខាងលើនេះទេ ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ឬគូភាគីអាចប្ដឹងតវ៉ាទៅ សាលាដំបូងដែលមានសមត្ថកិច្ចដើម្បីដោះស្រាយទៅតាមនីតិវិធីច្បាប់ជាធរមាន ។

**មាត្រា៩៤១ ._** ការបញ្ចប់ដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិរបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានបញ្ចប់ដោយមូលហេតុដូចខាងក្រោមៈ

ក-គូភាគីបានឯកភាពគ្នាបញ្ចប់នីតិវិធីនៃដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

ខ-ភាគីណាមួយមិនឯកភាព ឬសហការក្នុងការដោះស្រាយតាមនីតិវិធីសន្ទានកម្មបរិស្ថាន ។

គ-គូភាគីមិនអាចឈានដល់ការឯកភាពគ្នាលើវិវាទបរិស្ថាន និងធនធានធម្មជាតិក្នុងរយៈពេល៦ (ប្រាំមួយ)ខែ ឬក្នុងរយៈពេលដែលបានពន្យាពេលតាមការព្រមព្រៀងរបស់គូភាគីបានកន្លងផុតទៅ ។

ឃ-គូភាគីបានឯកភាពលើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរតាមការផ្សះផ្សារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន ។

កិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវចងកាតព្វកិច្ចផ្លូវច្បាប់ ។

**មាត្រា៩៤២ ._** ការចំណាយការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដោយគូភាគី

ក្នុងករណីដែលវិវាទបរិស្ថាន និងធនធានធម្មជាតិពាក់ព័ន្ធនឹងផលប្រយោជន៍បុគ្គលឯកជន គូភាគីនៃវិវាទត្រូវទទួលខុសត្រូវបន្ទុកលើការចំណាយចំពោះដំណើរការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិនេះ លើកលែងតែវិវាទនោះប្ដឹងឡើងដោយអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច ឬសាធា

ណាជនទូទៅដើម្បីការពារផលប្រយោជន៍សាធារណៈ ឬសហគមន៍ ដែលត្រូវប្រើប្រាស់មូលនិធិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិខាងលើ ។

នីតិវិធីនៃការកំណត់ប្រភេទចំណាយដែលត្រូវទូទាត់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង របស់ក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃ ។

**មាត្រា៩៤៣**._ ឯករាជ្យភាព និងអព្យាក្រឹត្យភាពនៃសន្ធានការីបរិស្ថាន

សន្ធានការីបរិស្ថាន និងធនធានធាម្មជាតិដែលបានទទួលការតែងតាំង ត្រូវបំពេញមុខងាររបស់ខ្លួនដោយឯករាជ្យ និងអព្យាក្រឹត្យ ក្នុងព្រំដែននៃវិសាលភាពសមត្ថកិច្ចរបស់ខ្លួន តាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា៩៤៤**._ កិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិ

កិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានទម្រង់លាយលក្ខណ៍អក្សរ និងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា៩៤៥**._ ការប្ដឹងជំទាស់ទៅនឹងកិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន

គូភាគីវិវាទ មានសិទ្ធិប្ដឹងជំទាស់ទៅតុលាការមានសមត្ថកិច្ច ដើម្បីឲ្យពិនិត្យឡើងវិញលើអង្គច្បាប់ និងនីតិវិធីលើកិច្ចព្រមព្រៀងសះជាដែលសម្របសម្រួលដោយក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិ ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពេលដែលដំណើរការសន្ធានកម្មបានបញ្ចប់ ។

ក្នុងករណីដែលគ្មានបណ្ដឹងជំទាស់ដែលធ្វើឡើងក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌខាងលើនេះទេ ត្រូវចាត់ទុកថាកិច្ចព្រមព្រៀងសះជានេះចូលជាស្ថាពរ ហើយមានតម្លៃដូចកំណត់ហេតុសះជាដែលក្លាយជាលិខិតអនុវត្តដោយបង្ខំតាមបញ្ញត្តិក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

**មាត្រា៩៤៦**._ ដំណោះស្រាយ

ក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិ ឬក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវជ្រើសរើសដំណោះស្រាយ និងវិធានការនានាដែលមានចែងក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិនេះ ។

ក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន ឬក្រុមប្រឹក្សាដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន ត្រូវពិចារណានូវជម្រើសជាអាទិភាព លើបញ្ហានៃការស្ដារ និងជួសជុលបរិស្ថានឡើងវិញ ។

**មាត្រា៩៤៧**._ អានុភាពនៃកិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិ

កិច្ចព្រមព្រៀងសះជារបស់ប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិ មានតម្លៃដូចកំណត់ហេតុសះជា ដែលក្លាយជាលិខិតអនុវត្តដោយបង្ខំតាមផ្លូវតុលាការដូចមានចែងតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ក្នុងករណីដែលភាគីវិវាទមិនបានអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងសះជាដោយស្ម័គ្រចិត្ត ។

**មាត្រា៦៤៨ ._** ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួងបរិស្ថាន ។

សមាសភាពនៃក្រុមប្រឹក្សាដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិខាងលើនេះ មានដូចខាងក្រោម៖

ក- រដ្ឋមន្ត្រីនៃទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង ជាប្រធាន ។

ខ- រដ្ឋមន្ត្រី ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬតំណាង ជាអនុប្រធាន ។

គ- រដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធពាក់ព័ន្ធនឹងវិវាទបញ្ហាបរិស្ថាន និងធនធានធម្មជាតិ ឬតំណាង ជាសមាជិក ។

ឃ- ក្រុមអ្នកជំនាញបច្ចេកទេសវិទ្យាសាស្ត្រ សម្រាប់ពិគ្រោះយោបល់បច្ចេកទេស តាមចាំបាច់ ឬតាមការស្នើសុំរបស់ក្រសួងពាក់ព័ន្ធ ជាសមាជិក ។

ង-សមាជិកផ្សេងតាមការចាំបាច់ អាស្រ័យតាមករណីវិវាទ ជាសមាជិក ។

សមាជិកនៃក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ មានអាណត្តិ៥(ប្រាំ)ឆ្នាំ ត្រូវបានតែងតាំងសាជាថ្មី លើកលែងតែមានការ លាលែង មរណភាព ដកហូតតំណែងដោយកំហុសណាមួយដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ឬដោយបញ្ញត្តិច្បាប់ហាមឃាត់ ។

**មាត្រា៦៤៩ ._** សមត្ថកិច្ចក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន

ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ មានសមត្ថកិច្ចត្រួតពិនិត្យ និងចេញសេចក្តីសម្រេចលើបណ្តឹងតវ៉ា ទៅនឹងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ដែលពាក់ព័ន្ធបរិស្ថាន និងធនធានធម្មជាតិ ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ អាចជាសេចក្តីសម្រេចបដិសេធ ឬលុបចោល ឬទទួលស្គាល់ ឬកែប្រែ ទៅនឹងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធានធម្មជាតិ ឬសម្រេចលើបណ្តឹងទាមទារសំណងខូចខាតបរិស្ថានរបស់ភាគីរងផលប៉ះពាល់ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។ សេចក្តីសម្រេចនេះត្រូវធ្វើឡើងជាទម្រង់លាយលក្ខណ៍អក្សរ និងមានបញ្ជាក់ហេតុផលឲ្យបានត្រឹមត្រូវតាមច្បាប់ ។

ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវចេញសេចក្តីសម្រេចរបស់ខ្លួនដែលមានរយៈពេលយ៉ាងយូរបំផុត ៩៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹងតវ៉ា ។

រយៈពេលដូចមានចែងក្នុងវាក្យខណ្ឌខាងលើនេះ អាចពន្យាពេលបានយ៉ាងយូរបំផុតមិនឲ្យលើសពី ៣(បី) ខែ ដោយមូលហេតុភាពស្មុគស្មាញនៃបច្ចេកទេសវិទ្យាសាស្ត្រនៃសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិនោះ ។

**មាត្រា៩៥០** ._ នីតិវិធីនៃការសម្រេចសេចក្តីរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

ការសម្រេចសេចក្តីរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើឡើងដោយឆ្លងកាត់សវនាការជាសាធារណៈ ។ ការសម្រេចសេចក្តីត្រូវធ្វើឡើងដោយមតិភាគច្រើនក្នុងចំណោមសមាជិកវត្តមាន ។ សមាជិកក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិត្រូវតែមានយ៉ាងតិច៣ (បី) រូប ឬច្រើនរូប ប៉ុន្តែត្រូវតែជាចំនួនសេស ដែលចូលរួមក្នុងការធ្វើសវនាការជាសាធារណៈអាស្រ័យទៅតាមករណីប្រភេទនៃបណ្តឹងលើសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិនីមួយៗ ដែលក្នុងនោះសមាជិកមកពីតំណាងគណៈរដ្ឋមន្ត្រីជាប្រធានដឹកនាំសវនាការជាសាធារណៈ ។

ការពិភាក្សាសម្រេចសេចក្តីរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើជាសម្ងាត់ ប៉ុន្តែការប្រកាសសេចក្តីសម្រេចរបស់ខ្លួនត្រូវធ្វើឡើងជាសាធារណៈ និងដោយមានសំអាងហេតុត្រឹមត្រូវនៅក្នុងសាលសវនាការសាធារណៈ ។

**មាត្រា៩៥១** ._ ការប្តឹងជំទាស់ប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

ប្រសិនបើគូភាគីវិវាទមិនយល់ព្រមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន ភាគីវិវាទមានសិទ្ធិប្តឹងជំទាស់ទៅសាលាដំបូងឲ្យពិនិត្យ និងសម្រេចឡើងវិញ ទៅតាមក្រមនីតិវិធីរដ្ឋប្បវេណីដែលមានជាធរមាន ឬនីតិវិធីរដ្ឋបាលជាធរមានក្នុងករណីមានច្បាប់នីតិវិធីរដ្ឋបាល ក្នុងរយៈពេល៣០(សាមសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីសេចក្តីសម្រេចនោះ ។

ក្នុងករណីគ្មានបណ្តឹងជំទាស់ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃខាងលើនេះ ត្រូវចាត់ទុកថាសេចក្តីសម្រេចនេះចូលជាស្ថាពរ ហើយមានអានុភាពអនុវត្តភ្លាម ។

**មាត្រា៩៥២** ._ កិច្ចសហការជាមួយគណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់កិច្ចសហការ សម្របសម្រួល និងផ្តល់ជំនួយដល់ការអនុវត្តតួនាទីរបស់គណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន ក្នុងករណីមានសំណើពីគណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៥៣**._ ឯករាជ្យភាព និងអព្យាក្រឹត្យភាពនៃក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន

សមាជិកនៃក្រុមប្រឹក្សជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិដែលត្រូវបានទទួលការតែងតាំង ត្រូវបំពេញមុខងាររបស់ខ្លួនដោយឯករាជ្យ និងអព្យាក្រឹត្យ ក្នុងព្រំដែននៃវិសាលភាពសមត្ថកិច្ចរបស់ខ្លួន តាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

ក្នុងករណីដែលសមាជិកណាដែលបំពានមុខងាររបស់ខ្លួនដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ហើយប្រព្រឹត្តអំពើណាមួយដែលខុសនឹងច្បាប់ជាធរមាន សមាជិកនោះត្រូវទទួលខុសត្រូវទណ្ឌកម្មរដ្ឋបាល និង/ឬព្រហ្មទណ្ឌទៅតាមប្រភេទនៃកំហុសដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ជាធរមាន ។

## ផ្នែកទី៤
## ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ក្នុងប្រព័ន្ធតុលាការ

**មាត្រា៩៥៤**._ តុលាការជំនាញបរិស្ថាន

ត្រូវបង្កើតឲ្យមានតុលាការជំនាញបរិស្ថាននៅសាលាដំបូងរាជធានី ខេត្ត និងសភាជំនាញបរិស្ថាននៅសាលាឧទ្ធរណ៍ និងតុលាការកំពូល ដើម្បីទទួលបន្ទុកដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ និងវិវាទប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៥៥**._ សមត្ថកិច្ចរបស់តុលាការជំនាញបរិស្ថាន

តុលាការជំនាញបរិស្ថានត្រូវចេញសេចក្តីសម្រេចចំពោះបណ្តឹងជំទាស់ដែលបញ្ជូនមកដោយក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិឬក្រុមប្រឹក្សាជាតិដោះស្រាយវិវាទប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ដោយយោងតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ឬនីតិវិធីរដ្ឋបាលជាធរមាន ក្នុងករណីមានច្បាប់នីតិវិធីរដ្ឋបាល ។

ប៉ុន្តែក្នុងករណីដែលបណ្តឹងពាក់ព័ន្ធវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានចរិកលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ ដែលកំណត់ដោយក្រមនេះ និងបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត ការដំណើរការនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌនេះត្រូវអនុលោមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

ការអនុវត្តនីតិវិធីក្នុងការដោះស្រាយបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន លើកលែងតែមានបទប្បញ្ញត្តិពិសេសដែលកំណត់ដោយក្រមនេះ ។

**មាត្រា៩៥៦**._ បណ្ដឹងជំទាស់ប្រឆាំងកិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

គូភាគី ឬសាធារណជនដែលមានគោលដៅការពារផលប្រយោជន៍សាធារណៈ ឬអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិប្ដឹងជំទាស់នឹងកិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន ឬក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ទៅតុលាការជំនាញបរិស្ថាននៃសាលាដំបូង ដើម្បីពិនិត្យឡើងវិញនូវអង្គច្បាប់ និងនីតិវិធី ។

បុគ្គលគ្រប់រូបដែលមិនពេញចិត្តសាលក្រមរបស់តុលាការជំនាញបរិស្ថាននៃសាលាដំបូង មានសិទ្ធិប្ដឹងឧទ្ធរណ៍នឹងសាលក្រម ទៅតុលាការជាន់ខ្ពស់បាន ។ ចំពោះបែបបទ និងនីតិវិធីនៃការប្ដឹង ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

**មាត្រា៩៥៧**._ សមត្ថកិច្ចពិនិត្យទិដ្ឋភាពច្បាប់របស់តុលាការជំនាញបរិស្ថាន

តុលាការជំនាញបរិស្ថានមានសមត្ថកិច្ចពិនិត្យទិដ្ឋភាពច្បាប់ដូចខាងក្រោម៖

ក-ការពិចារណា វិធានការនិងដំណោះស្រាយនានាដែលបានកំណត់ក្នុងក្រមនេះ ត្រូវបានបញ្ចូលក្នុងកិច្ចព្រមព្រៀងសះជា ។

ខ-ត្រូវពិចារណាលើការស្ដារ និងជួសជុលបរិស្ថាន និងធនធានធម្មជាតិជាអាទិភាព ។

គ-ដំណោះស្រាយ និងវិធានការនានា ត្រូវស្របនឹងគោលការណ៍ទូទៅដូចមានចែងក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ ។

ឃ-កម្មវត្ថុវិវាទបរិស្ថាន និងធនធានធម្មជាតិអាចដោះស្រាយតាមរយៈយន្តការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

ង-ខ្លឹមសារនៃកិច្ចព្រមព្រៀងសះជាបរិស្ថាន និងធនធានធម្មជាតិផ្ទុយនឹងសណ្ដាប់ធ្នាប់សារណៈ ទំនៀមទម្លាប់ល្អរបស់សង្គម និងបទប្បញ្ញត្តិច្បាប់ផ្សេងៗទៀត ។

ច-ពិនិត្យភាពត្រឹមត្រូវនៃនីតិវិធីនៃសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

ឆ-សង្គតិភាពទៅនឹងគោលនយោបាយសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៩៥៨**._ ការសម្រេចសេចក្ដីរបស់តុលាការជំនាញបរិស្ថាននៃសាលាដំបូង

តុលាការជំនាញបរិស្ថាននៃសាលាដំបូង ត្រូវចេញសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ ចំពោះកិច្ចព្រមព្រៀងសះជា របស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ឬសេចក្ដីសម្រេច

របស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិដោយសាលក្រមក្នុងរយៈពេលយ៉ាងយូរបំផុត ៣(បី)ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹង ។

រយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើនេះ មិនអាចពន្យាពេលបានឡើយ ។

**មាត្រា៩៥៩ .**_ បណ្ដឹងជំទាស់ប្រឆាំងសេចក្ដីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

គូភាគី ឬសាធារណជនដែលមានគោលដៅការពារផលប្រយោជន៍សាធារណៈ ឬអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិប្ដឹងជំទាស់ប្រឆាំងនឹងសេចក្ដីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថានទៅតុលាការជំនាញបរិស្ថាននៃសាលាដំបូង ដើម្បីពិនិត្យឡើងវិញអំពីនីត្យានុកូលភាពនៃសេចក្ដីសម្រេច ។

បុគ្គលគ្រប់រូបដែលមិនពេញចិត្តសាលក្រមរបស់តុលាការជំនាញបរិស្ថាននៃសាលាដំបូង មានសិទ្ធិប្ដឹងឧទ្ធរណ៍នឹងសាលក្រម ទៅតុលាការជាន់ខ្ពស់បាន ។ ចំពោះបែបបទ និងនីតិវិធីនៃការប្ដឹង ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

**មាត្រា៩៦០ .**_ សមត្ថកិច្ចពិនិត្យពីនីត្យានុកូលភាពនៃសេចក្ដីសម្រេច ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

តុលាការជំនាញបរិស្ថាន មានសមត្ថកិច្ចពិនិត្យលើបញ្ហានីត្យានុកូលភាពដូចខាងក្រោម៖

ក-សុពលភាពនៃសេចក្ដីសម្រេចរដ្ឋបាល មានជាអាទិ៍ សមត្ថកិច្ចចេញសេចក្ដីសម្រេច វិការៈនៃទម្រង់ ឬនីតិវិធីនៃការចេញសេចក្ដីសម្រេច ឬរំលោភអំណាច ។

ខ-ខ្លឹមសារជាសារវន្តនៃសេចក្ដីសម្រេចដែលរំលោភគោលការណ៍ទូទៅនៃច្បាប់រួមមាន ការរំលោភច្បាប់ ឬបទបញ្ញាផ្សេងៗ ការភ័ណ្ឌច្រឡំផ្លូវច្បាប់ អង្គហេតុ ឬមូលហេតុនៃការចេញសេក្ដីសម្រេច ជាអាទិ៍ ។

ការពិនិត្យនីត្យានុកូលភាពនៃ សេចក្ដីសម្រេច ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិដូចមានចែងក្នុងកថាខណ្ឌខាងលើនេះត្រូវ ស្របទៅនឹងបទប្បញ្ញត្តិនៃក្រមនេះ និងបទដ្ឋានគតិយុត្តផ្សេងៗ ។

**មាត្រា៩៦១ .**_ រយៈពេលប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

បណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងសារទុក្ខ ត្រូវធ្វើឡើងក្នុងអំឡុងពេល១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលបានការបញ្ជូនលិខិតសាលក្រម ឬសាលដីកា ។ នីតិវិធីនៃការដោះស្រាយបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសារទុក្ខ ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន លើកលែងតែមានបទប្បញ្ញត្តិពិសេសចែងក្នុងក្រមនេះ ។

**មាត្រា៩៦២ ._** បណ្ដឹងឧទ្ធរណ៍ នឹងសេចក្ដីសម្រេចរបស់តុលាការជំនាញបរិស្ថាននៃសាលាដំបូង

សាលាឧទ្ធរណ៍ ត្រូវចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ លើសាលក្រមតុលាការជំនាញបរិស្ថាននៃសាលាដំបូង ដោយសាលដីកា ក្នុងរយៈពេលយ៉ាងយូរបំផុត ៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹងឧទ្ធរណ៍ ។

រយៈពេលដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ មិនអាចពន្យាបានឡើយ ។

**មាត្រា៩៦៣ ._** បណ្ដឹងសារទុក្ខនឹងសាលដីការបស់សាលាឧទ្ធរណ៍

តុលាការកំពូល ត្រូវចេញសេចក្ដីសម្រេចលើលើបណ្ដឹងសារទុក្ខ លើសាលដីការបស់សាលាឧទ្ធរណ៍ដោយសាលដីកា ក្នុងរយៈពេលយ៉ាងយូរបំផុត ៩(ប្រាំបួន)ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹងសារទុក្ខ ។ រយៈពេល៩(ប្រាំបួន)ខែនេះ មិនអាចពន្យាបានឡើយ ។

សម្រាប់បណ្ដឹងដែលមានគោលបំណងទាមទារសំណងផ្នែករដ្ឋប្បវេណី ឬសំណងខូចខាតផ្នែកបរិស្ថាន និងធនធានធម្មជាតិ ឬបណ្ដឹងទាក់ទងនឹងវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ តុលាការកំពូល ត្រូវចេញសេចក្ដីសម្រេចចុងក្រោយ ដោយមិនបញ្ជូនត្រឡប់មក ឲ្យសាលាឧទ្ធរណ៍ ធ្វើចំណាត់ការឡើងវិញទៅ តាមនីតិវិធីដែលបានកំណត់ដោយក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាទេ លើកលែងតែ បណ្ដឹងពាក់ព័ន្ធនឹងធនធានធម្មជាតិ និងបរិស្ថាន នោះ មានចរិកលក្ខណៈព្រហ្មទណ្ឌ អាចបញ្ជូនត្រឡប់មកសាលាឧទ្ធរណ៍ឲ្យជំនុំជម្រះឡើងវិញ ។

**មាត្រា៩៦៤ ._** នីតិវិធីនៃបណ្ដឹងជាយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមជាសាធារណជន

រូបបុគ្គល ឬនីតិបុគ្គលដែលទទួលរងការប្ដឹងចោទប្រកាន់ដោយមិនត្រឹមត្រូវពីរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលធ្វើឲ្យរងផលប៉ះពាល់ដូចមានចែងក្នុងមាត្រា៩១៤ អាចដាក់ពាក្យបណ្ដឹងតបទាមទារសំណងរដ្ឋប្បវេណីទៅតុលាការមានសមត្ថកិច្ច ។

**មាត្រា៩៦៥ ._** លក្ខខណ្ឌនៃការទទួលយកបណ្ដឹងជាយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមជាសាធារណៈ

តុលាការជំនាញបរិស្ថាន ត្រូវត្រួតពិនិត្យលក្ខខណ្ឌនៃការទទួលយកបណ្ដឹងជាយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមជាសាធារណៈមានដូចខាងក្រោម៖

ក-សកម្មភាពនៃបណ្ដឹងតប មិនមានចេតនាក្នុងការបៀតបៀន ឬរារាំង ឬគៀបសង្កត់ដល់ការចូលរួមរបស់សាធារណជនលើសកម្មភាពបណ្ដឹង ។

ខ-គ្មានភស្តុតាងត្រឹមត្រូវ ឬច្បាស់លាស់ថាបណ្ដឹងរបស់សាធារណជនជាបណ្ដឹងដែលមានចេតនាបរិហារកេរ្តិ៍ ឬរារាំង ជ្រៀតជ្រែកដោយគំនិតទុច្ចរិតដល់ម្ចាស់បណ្ដឹងតប ។

តុលាការជំនាញបរិស្ថាន ត្រូវសម្រេចលើកបណ្ដឹងចោលដោយដីកាសម្រេចក្នុងករណីដែលបណ្ដឹងពុំគោរពតាម លក្ខខណ្ឌដូចចែងក្នុងកថាខណ្ឌខាងលើនេះ ។

ភាគីណាមិនសុខចិត្តនឹងសេចក្តីសម្រេចខាងលើនេះ មានសិទ្ធិប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីដីកាសម្រេច ។ ការសម្រេចលើបណ្តឹងឧទ្ធរណ៍របស់សាលាឧទ្ធរណ៍ បិទផ្លូវតវ៉ា ។

នីតិវិធីនៃការដោះស្រាយបណ្តឹងជាយុទ្ធសាស្ត្រប្រឆាំងការចូលរួមជាសាធារណៈ ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន លើកលែងតែបទប្បញ្ញត្តិដែលមានចែងជាពិសេសក្នុងក្រមនេះ ។

**មាត្រា៩៦៦** ._ នីតិវិធីនៃការអនុវត្តសេចក្តីសម្រេចរបស់តុលាការ

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងសងជាប្រាក់ ត្រូវអនុវត្តតាមនីតិវិធីនៃការអនុវត្តដោយបង្ខំដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

ការអនុវត្តសេចក្តីសម្រេចនៃនីតិវិធីចាត់ចែងរក្សាការពារ ត្រូវអនុវត្តតាមនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះការចាត់ចែងរក្សាការពារដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងសងជាប្រាក់ ជាការអនុវត្តដោយបង្ខំចំពោះសេចក្តីសម្រេចរបស់តុលាការដែលបង្គាប់ឲ្យប្រគល់វត្ថុបី ឬបង្គាប់ឲ្យធ្វើ ឬមិនធ្វើសកម្មភាពណាមួយ  ហើយត្រូវអនុវត្តទៅតាមនីវិធីវិធីអនុវត្តដោយបង្ខំដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។ ក្រៅពីនេះ អ្នកដែលមិនអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការ ត្រូវចោទប្រកាន់ និងផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី២
## នីតិវិធីដោះស្រាយបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលមានចរិកលក្ខណៈព្រហ្មទណ្ឌ
## ផ្នែកទី១
## នីតិវិធីនៃការស៊ើបអង្កេត ការស៊ើបសួរ ការចោទប្រកាន់ និងការជំនុំជម្រះ

**មាត្រា៩៦៧** ._ បទប្បញ្ញត្តិទូទៅ

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេត ការចោទប្រកាន់បទល្មើសបរិស្ថាន និងធនធានធម្មជាតិ លើកលែងតែក្នុងករណីដែលមានចែងជាពិសេសក្នុងផ្នែកនេះ ។

**មាត្រា៩៦៨** ._ នីតិវិធីនៃការស៊ើបអង្កេត  និងស៊ើបសួរ ការចោទប្រកាន់ និងការជំនុំជម្រះ

នីតិវិធីនៃការស៊ើបអង្កេត ការស៊ើបសួរ និងការជំនុំជម្រះ ត្រូវអនុវត្តតាមការក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន លើកលែងតែមានចែងជាពិសេសក្នុងក្រមនេះ ។

**មាត្រា៩៦៩** ._ចេតនាប្រព្រឹត្តបទល្មើសដោយចេតនាបរិស្ថាន និងធនធានធម្មជាតិ

ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ប៉ុន្តែក្នុងការចោទប្រកាន់បទល្មើសបរិស្ថាន និងធនធានធម្មជាតិ បទល្មើសមួយអាចកើតចេញពីលក្ខខណ្ឌដូចខាងក្រោម៖

ក-ចេទនាប្រព្រឹត្ត ឬបំណងប្រព្រឹត្ត ។

ខ-បានដឹងអំពីបទល្មើស ហើយគ្មានចាត់វិធានការទប់ស្កាត់ ។

គ-ការធ្វេសប្រហែស ឬខ្ជីខ្ជាក្នុងការបំពេញកាតព្វកិច្ចតាមច្បាប់កំណត់ ។

ឃ-មិនអនុវត្តតាមបទប្បញ្ញត្តិច្បាប់ ឬលក្ខខណ្ឌតម្រូវរបស់ច្បាប់ ឬបទបញ្ជាផ្សេងៗ ។

## ផ្នែកទី២
## ភស្តុតាងក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៩៧០** ._ ភស្តុតាងនៃបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលទាក់ទងផ្នែករដ្ឋប្បវេណី និង ព្រហ្មទណ្ឌ

ភស្តុតាជាមូលដ្ឋាននៃបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលទាក់ទងផ្នែករដ្ឋប្បវេណី និង ព្រហ្មទណ្ឌមានដូចខាងក្រោម៖

ក-ឯកសារ ។

ខ-កស្សិណសាក្សី ។

គ-វត្ថុនានា ។

ឃ-ការពន្យល់បកស្រាយ ។

ង-ការពិនិត្យផ្ទាល់របស់តុលាការ ។

**មាត្រា៩៧១** ._ ភស្តុតាងជាឯកសារ

ភស្តុតាងជាឯកសារមានដូចខាងក្រោម៖

ក- លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ កិច្ចព្រមព្រៀង វិញ្ញាបនបត្រផ្សេងៗ ។

ខ-របាយការណ៍នៃការត្រួតពិនិត្យផ្សេងៗ ។

គ-វិក័យបត្រ ។

ឃ-របាយការណ៍នៃការធ្វើការពិសោធន៍ ។

ង-ផែនទី ។

ច-រូបថត វីដេអូ ឬសំឡេង ។

ឆ-ផ្សេងៗ ។

**មាត្រា៩៧២** ._ ភស្តុតាងជាកស្សិណសាក្សី

ភស្តុតាងជាកស្សិនសាក្សីមានដូចខាងក្រោមៈ

ក-សាក្សីជាមនុស្សទូទៅ ។

ខ-សាក្សីជាអ្នកជំនាញ ។

គ-ផ្សេងៗ ។

**មាត្រា៩៧៣** ._ ភស្តុតាងជាវត្ថុដែលពាក់ព័ន្ធនឹងកម្មវត្ថុនៃវិវាទ

ភស្តុតាងជាវត្ថុដែលពាក់ព័ន្ធនឹងកម្មវត្ថុនៃវិវាទមានដូចខាងក្រោមៈ

ក-សំណាក ។

ខ-ផ្សេងៗ ។

**មាត្រា៩៧៤** ._ ភស្តុតាងជាការពន្យល់បកស្រាយ

ភស្តុតាងជាការពន្យល់បកស្រាយមានដូចខាងក្រោមៈ

ក-ដ្យាក្រាម ។

ខ-តារាងនានា ។

គ-ផ្សេងៗ ។

**មាត្រា៩៧៥** ._ ការពិនិត្យភស្តុតាងជាសម្ងហវិធី

ការពិនិត្យភស្តុតាងដោយសម្ងហវិធីដូចខាងក្រោមៈ

ក-ការអះអាងរបស់ភាគីនៃវិវាទ ។

ខ-ការអះអាងរបស់អ្នកជំនាញការបច្ចេកទេស ។

គ-ការអះអាងរបស់សាក្សី ។

ឃ-ការអះអាងរបស់មេធាវី ។

ង-ផ្សេងៗ ។

**មាត្រា៩៧៦** ._ ភស្តុតាងនៃបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិដែលទាក់ទងនឹងវិវាទរដ្ឋបាលបរិស្ថាននិងធនធានធម្មជាតិ

ភស្តុតាងនៃបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិដែលទាក់ទងនឹងផ្នែករដ្ឋបាលបិរស្ថាន និងធនធានធម្មជាតិមានដូចខាងក្រោមៈ

ក-សេចក្ដីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ។

ខ- ការអះអាងរបស់សាក្សី ។

គ- សេចក្តីសន្និដ្ឋានរបស់អ្នកជំនាញបច្ចេកទេស ។
ឃ- ការអះអាងរបស់ភាគីវិវាទនៃវិវាទ ។
ង- ផ្សេងៗ ។

**មាត្រា៩៧៧** ._ ការពិនិត្យភស្តុតាងក្នុងបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលមានចរិកលក្ខណៈរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

ចំពោះការពិនិត្យភស្តុតាងក្នុងបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលមានចរិកលក្ខណៈផ្នែករដ្ឋប្បវេណី និងផ្នែករដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុលោមតាមវិធានភស្តុតាងដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

ចំពោះការពិនិត្យភស្តុតាងក្នុងបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលមានចរិកលក្ខណៈព្រហ្មទណ្ឌ ត្រូវអនុលោមតាមវិធានភស្តុតាងដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា៩៧៨** ._ លក្ខខណ្ឌចាំបាច់នៃភស្តុតាងក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ

ភស្តុតាងក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានភស្តុតាងចាំបាច់ដាច់ខាត ជាសេចក្តីសន្និដ្ឋានរបស់ជំនាញបច្ចេកទេសវិទ្យាសាស្ត្រមកធ្វើជាមូលដ្ឋានក្នុងការពិចារណានិងសម្រេចសេចក្តី។

**មាត្រា៩៧៩** ._ ភស្តុតាងដែលរឹបអូសបាន

ភស្តុតាងដែលរឹបអូសបាន ត្រូវគ្រប់គ្រងដោយនីតិវិធីដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដូចបានកំណត់នៅក្នុងក្រមនេះ និងឧបករណ៍គតិយុត្តពាក់ព័ន្ធ ។ ភស្តុតាង ត្រូវមានការរក្សាទុកឲ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព នៅឯស្ថាប័នដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានបានឯកភាពឲ្យទទួលបន្ទុក ។

## ផ្នែកទី៣
## ការចាត់ចែងរក្សាការពារក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៩៨០** ._បទប្បញ្ញត្តិទូទៅ

នីតិនៃការចាត់ចែងរក្សាការពារ និងនីតិវិធីអនុវត្តរក្សាការពារត្រូវអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន លើកលែងតែមានបទប្បញ្ញត្តិពិសេសដែលមានចែងក្នុងក្រមនេះ ។

**មាត្រា៩៨១** ._ មូលដ្ឋាននៃការសម្រេចលើពាក្យសុំដីកាសម្រេចរក្សាការពារ

តុលាការចេញសេចក្តីសម្រេចលើពាក្យសុំចេញដីការក្សាការពារ ត្រូវផ្អែកលើ គោលការណ៍ទូទៅនៃក្រមបរិស្ថាន និងត្រូវ ពិចារណា ចំណុចដូចខាងក្រោម៖

ក-មានមូលដ្ឋានច្បាប់គ្រប់គ្រាន់បង្ហាញពីសិទ្ធិឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាពារ។

ខ-មានការទទួលរងការខូចខាតដែលមិនអាចស្តារ ឬជួសជុសឡើងវិញបាន អំពីអំពើដែលបានប្រព្រឹត្ត ។

គ-ផលប្រយោជន៍សាធារណៈធំជាងផលប្រយោជន៍ឯកជន ឬផលប្រយោជន៍រួម ឬសមូហភាពធំជាងផលប្រយោជន៍ឯកជន ។

**មាត្រា៩៨២** ._ រយៈពេលនៃការសម្រេចសេចក្តីរបស់តុលាការ

តុលាការជំនាញបរិស្ថាន ត្រូវសម្រេចលើពាក្យសុំចេញដីកាសម្រេចរក្សាការពារ ក្នុងរយៈពេលយ៉ាងយូរ៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ ។ ក្នុងករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចការពារ តុលាការជំនាញបរិស្ថាន ត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលគូភាគីបានទទួលលិខិតនីតិវិធីរបស់តុលាការចាប់មានអានុភាព ។

តុលាការនៃបណ្តឹងជំទាស់ ត្រូវសម្រេចលើបណ្តឹងជំទាស់នឹងដីកាសម្រេចលើពាក្យសុំតវ៉ា នឹងដីកាសម្រេចរក្សាការពារ ឬដីកាសម្រេចលើកចោលពាក្យសុំចេញដីកាសម្រេចរក្សាការពារ ក្នុងរយៈពេលយ៉ាងយូរបំផុត ២ (ពីរ)សប្តាហ៍ គិតចាប់ពីថ្ងៃដែលគូភាគីបានទទួលលិខិតនីតិវិធីរបស់តុលាការចាប់មានអានុភាព ។

**មាត្រា៩៨៣** ._ គោលការណ៍ការបញ្ជូន

នីតិវិធីនៃការបញ្ជូនត្រូវអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន លើកលែងតែមានចែងជាពិសេសក្នុងក្រមនេះ ។

ការបញ្ជូន ត្រូវធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ ក្នុងការកំណត់ពីវិធីនៃការបញ្ជូន ឬទីកន្លែងដែលត្រូវបញ្ជូន ហើយដែលចាត់ទុកថាមានអានុភាពតាមផ្លូវច្បាប់ថាគូភាគីបានទទួលដំណឹងអំពីនីតិវិធីតុលាការ ឬអ្នកដែលទទួលបានបន្ទុកនៃការបញ្ជូន ។

ទីកន្លែងជាអាសយដ្ឋានដែលជាលំនៅដ្ឋាន ឬទីសំណាក់ ឬទីស្នាក់ការ ឬទីកន្លែងអាជីវកម្មរបស់នីតិបុគ្គលដែលគូភាគីបានបញ្ជាក់នៅក្នុងឯកសារជាផ្លូវការក្នុងការដាក់ពាក្យសុំ ឬពាក្យបណ្តឹង ។

**មាត្រា៩៨៤** ._ ការដាក់ប្រាតិភោគ

តុលាការអាចសម្រេចឲ្យអ្នកដាក់ពាក្យសុំដាក់ប្រាតិភោគ ឬមិនដាក់ប្រាតិភោគ ដោយពិចារណាលើមូលហេតុដូចខាងក្រោម៖

ក- ពុំមានភស្តុតាង ឬមូលហេតុគ្រប់គ្រាន់ និងច្បាស់លាស់បង្ហាញពីទំហំនៃការខូចខាតបរិស្ថាន ឬផលប្រយោជន៍នៃភាគីដែលរងផលប៉ះពាល់ ។

ខ- លទ្ធភាពនៃធនធានសេដ្ឋកិច្ចរបស់ម្ចាស់បំណុល ។

គ- ឧត្តមភាពនៃកិច្ចការពារបរិស្ថាន ។

ឃ- កាលៈទេសៈផ្សេងៗទៀត ។

**មាត្រា៩៨៥** ._ បទប្បញ្ញត្តិដែលត្រូវអនុវត្តក្នុងរឿងបត្យាប័ន

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ត្រូវយកមកអនុវត្តក្នុង រឿងបត្យាប័នពាក់ព័ន្ធនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលមានចរិកលក្ខណៈព្រហ្មទណ្ឌ ។

**មាត្រា៩៨៦** ._ ជំនួយផ្នែកច្បាប់ទៅវិញទៅមក

ក្នុងករណីបទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈព្រហ្មទណ្ឌ អាជ្ញាធរតុលាការនៃព្រះរាជាណាចក្រកម្ពុជា អាចប្រគល់អំណាចឲ្យទៅអាជ្ញាធរខាងតុលាការមានសមត្ថកិច្ចនៃរដ្ឋបរទេសណាមួយ និងអាចទទួលអំណាចពីអាជ្ញាធរតុលាការនៃរដ្ឋបរទេសណាមួយតាមរយៈក្រសួងយុត្តធម៌ដើម្បីៈ

ក-ប្រមូលយកសក្ខីភាព ឬភាពចម្លើយដែលឆ្លើយតាមផ្លូវតុលាការ ។

ខ-ឲ្យដំណឹងពីលិខិតផ្សេងៗរបស់តុលាការ ។

គ-ធ្វើការឆែកឆេរ ឃាត់ទុក និងដកហូត ។

ឃ-ធ្វើការពិនិត្យវត្ថុ និងទីកន្លែង ។

ង-ផ្តល់ព័ត៌មាន និងវត្ថុតាង ។

ច-ផ្តល់ឯកសារកំណត់ហេតុជាច្បាប់ដើម ឬសេចក្តីចម្លងដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមនៃឯកសារ និងសំណុំរឿង ។

ឆ-បង្ហាញ ឬផ្តល់សាក្សី អ្នកជំនាញ ឬជនដទៃទៀត រាប់ទាំងជនជាប់ឃុំខ្លួនដែល យល់ព្រមជួយក្នុងការស៊ើបអង្កេត ឬយល់ព្រមចូលរួមក្នុងនីតិវិធី ។

ជ- កំណត់អត្តសញ្ញាណ ឬស្រាវជ្រាវរកធនធាន ទ្រព្យសម្បត្តិ បរិក្ខារ និងសម្ភារៈទាំងដែលបានមកពីការប្រព្រឹត្តបទល្មើសដោយចេតនា និងមធ្យោបាយបទល្មើស ។

ឈ-ដាក់ក្រោមវិធានការរក្សាទុកជាបណ្តោះអាសន្ននូវផលិតផល និងទ្រព្យសម្បត្តិដែលបានមកពីបទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលមានទាំងបរិក្ខារ សម្ភារៈដែលប្រើប្រាស់ ឬទុកសម្រាប់ប្រើប្រាស់ដើម្បី ប្រព្រឹត្តបទល្មើសដោយចេតនាបរិស្ថានដែលមានលក្ខណៈព្រហ្មទណ្ឌ ។

ញ-ចាត់ឲ្យអនុវត្តសេចក្តីសម្រេចដែលបញ្ជាឲ្យធ្វើការរឹបអូស ដកហូត ឬយកមកវិញនូវផលិតផល ទ្រព្យសម្បត្តិ បរិក្ខារ សម្ភារៈទាំងឡាយដែលបានមកពីការប្រព្រឹត្តបទល្មើសដោយចេតនាបរិស្ថាន ដែលមានលក្ខណៈព្រហ្មទណ្ឌ ។

ដ-បញ្ជាឲ្យធ្វើការរឹបអូសវត្ថុទាំងឡាយ ដែលមានចែងក្នុងចំណុចខាងលើ ។

ឋ- ឲ្យដំណឹងអំពីការចោទប្រកាន់តាមនីតិវិធីព្រហ្មទណ្ឌ ។

ឌ- សួរចម្លើយជនត្រូវចោទតាមនីតិវិធីព្រហ្មទណ្ឌ ។

ឈ- រកឲ្យឃើញ និងកំណត់អត្តសញ្ញាណសាក្សី និងជនសង្ស័យ ។

**មាត្រា៩៨៧ .**_ នីតិវិធីជំនួយផ្នែកច្បាប់ទៅវិញទៅមកផ្នែករដ្ឋប្បវេណី

នីតិវិធីនៃការអនុវត្តជំនួយផ្នែកច្បាប់ទៅវិញទៅមកផ្នែករដ្ឋប្បវេណី ត្រូវអនុវត្តតាមគោលការណ៍ទាំងឡាយដែលបានកំណត់ក្នុងសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី និងច្បាប់ជាតិជាធរមាន ។

## មាតិកាទី២
## មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ មន្ត្រីការពារបេតិកភណ្ឌ និងមន្ត្រីអធិការកិច្ចបរិស្ថាន
### ជំពូកទី១
### មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៩៨៨ .**_ សមាសភាពមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីរាជការសាធារណៈ ឬមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធដែលទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ រួមមាន មន្ត្រីទទួលបន្ទុកវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មន្ត្រីទទួលបន្ទុករបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មន្ត្រីទទួលបន្ទុកបង្ក្រាបបទល្មើសសត្វព្រៃ មន្ត្រីការពារបេតិកភណ្ឌ មន្ត្រីអធិការកិច្ចការបំពុលបរិស្ថានជាអាទិ៍ ដែលកំណត់ដោយក្រមនេះ និងច្បាប់ពិសេសផ្សេងទៀត ត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៨៩ .**_ នីតិវិធីក្នុងការទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

ដើម្បីទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍ ។ សម្បថមិនចាំបាច់ធ្វើសាជាថ្មីម្តងទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិនៅពេលក្រោយទៀត ។

បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត អន្តរក្រសួងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ និងក្រសួងយុត្តិធម៌ ។ ចំពោះរូបមន្តនៃពាក្យសម្បថ ត្រូវកំណត់ដោយក្រសួងយុត្តិធម៌ ។

**មាត្រា៩៩០ ._** បេសកកម្មមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីរាជការសធារណៈ ឬមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធដែលទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ មានបេសកកម្មដូចខាងក្រោមៈ

ក-ទទួលពាក្យបណ្ដឹងពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ។

ខ-ធ្វើការត្រួតពិនិត្យបទល្មើសពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ។

គ-ស្នើសុំព័ត៌មានពីអ្នកពាក់ព័ន្ធក្នុងប្រតិបត្តិការស៊ើបអង្កេតបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ។

ឃ-ធ្វើអធិការកិច្ចទីកន្លែងដែលសង្ស័យថាមានការប្រព្រឹត្តបទល្មើស បរិស្ថាន និងធនធានធម្មជាតិដោយចេតនា។

ង-រឹបអូសវត្ថុតាងនានាពាក់ព័ន្ធនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ។

ច-ស្នើសុំជំនួយពីអ្នកពាក់ព័ន្ធក្នុងប្រតិបត្តិការស៊ើបអង្កេតបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ។

ឆ-ធ្វើការស៊ើបអង្កេត និងបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ។

ជ-តាមដានជនសង្ស័យ ។

ឈ-ចាប់ខ្លួនជនល្មើស និងកសាងសំណុំរឿងពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិបញ្ជូនទៅតុលាការមានសមត្ថកិច្ច ។

ដ-ដាក់ពាក្យបណ្ដឹងទៅកាន់តុលាការ ។

ឋ-ដាក់ការពិន័យអន្តការណ៍ ។

ប្រតិបត្តិការរបស់មន្ត្រីរាជការសធារណៈ ឬមន្ត្រីរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា៩៩១ ._** សិទ្ធិអំណាចនៃការប្រើប្រាស់អាវុធ

មន្ត្រីរាជការសាធារណៈ ឬមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធដែលទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ដែលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិប្រើប្រាស់អាវុធ ក្នុងអំឡុងពេលប្រតិបត្តិការរបស់ខ្លួន ។

ការប្រើប្រាស់អាវុធ ត្រូវអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។

**មាត្រា៩៩២ ._** នីតិវិធីស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ

នីតិវិធីក្នុការកសាងសំណុំរឿងរបស់មន្ត្រីរាជការសាធារណៈ ឬមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

ទម្រង់ និងបែបបទ ក្នុងការធ្វើកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាងក្រសួងស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធនធម្មជាតិ និងក្រសួងយុត្តិធម៌ ។

**មាត្រា៩៩៣** ._ កាតព្វកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចសហការចំពោះការស៊ើបអង្កេតបទល្មើសបរិស្ថាន និងធនធានធម្មជាតិ

អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ត្រូវបង្កភាពងាយស្រួល ជួយសម្រួល និងជួយផ្តល់កម្លាំងសហការក្នុងការស្រាវជ្រាវ ត្រួតពិនិត្យបទល្មើស និងបង្ក្រាបបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ក្នុងករណីមានការស្នើសុំពីមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៩៤** ._ ការប្រើប្រាស់ឯកសណ្ឋានក្នុងការស៊ើបអង្កេតលើបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីរាជការសាធារណៈ ឬមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវមានប័ណ្ណសម្គាល់អត្តសញ្ញាណច្បាស់លាស់ នៅពេលចុះបំពេញបេសកកម្មក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៩៥** ._ សិទ្ធិរបស់រូបវន្តបុគ្គល និងសហគមន៍មូលដ្ឋាន

រូបវន្តបុគ្គល ឬសហគមន៍មូលដ្ឋាននានា មានសិទ្ធិចូលរួមក្នុងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដូចតទៅ៖

ក- ធ្វើការយាមល្បាតដោយមានការសហការពីរដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីនគរបាលយុត្តិធម៌ ឧទ្យានរក្ស ឬមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធនានា ។

ខ- ធ្វើការឃាត់ទុកជនល្មើសក្នុងបទល្មើសជាក់ស្តែង និងឃាត់វត្ថុតាងនៃបទល្មើស រួចបញ្ជូនទៅអាជ្ញាធរមូលដ្ឋាន ឬមន្ត្រីនគរបាលយុត្តិធម៌ ឬឧទ្យានរក្ស ឬមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធនានាដែលនៅជិតបំផុត ។

គ- ផ្តល់ភស្តុតាង របាយការណ៍ និងព័ត៌មានដទៃទៀតអំពីបទល្មើសពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ទៅឲ្យក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

ង-ផ្តល់ភស្តុតាង និងព័ត៌មានពាក់ព័ន្ធនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិទៅឲ្យព្រះរាជអាជ្ញា ។

## ផ្នែកទី១
## មន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា៩៩៦** ._ សមាសភាពមន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

សមាសភាពមន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថានមានៈ

- មន្ត្រីនៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។
- មន្ត្រីនៃមន្ទីរបរិស្ថានរាជធានី ខេត្ត ។

**មាត្រា៩៩៧** ._បេសកកម្មមន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌មានបេសកកម្មដូចខាងក្រោមៈ

១- ទទួលពាក្យបណ្តឹង ។

២- ត្រួតពិនិត្យបទល្មើស ។

៣- ធ្វើការស៊ើបអង្កេត បង្ក្រាបបទល្មើស ។

៤- កសាងសំណុំរឿងដែលពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីប្តឹងទៅតុលាការមានសមត្ថកិច្ច ។

ប្រតិបត្តិការ និងនីតិវិធីនៃកសាងសំណុំរឿងរបស់មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា៩៩៨** ._សមត្ថកិច្ចដែនដីនៃមន្ត្រីនគរបាលវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសមត្ថកិច្ចដែនដីទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នៃមន្ទីរបរិស្ថានរាជធានី ខេត្ត មានសមត្ថកិច្ចដែនដីនៅក្នុងមណ្ឌលរដ្ឋបាលរបស់ខ្លួន ។

ក្នុងករណីមានវិវាទសមត្ថកិច្ច ឬជាន់សមត្ថកិច្ចដែនដី រដ្ឋមន្ត្រីនៃ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានជាអ្នកសម្រេច ។

ការសម្រេចនេះបិទផ្លូវតវ៉ា ។

## ផ្នែកទី២
## មន្ត្រីនគរបាលយុត្តិធម៌នៃការប្រែប្រួលអាកាសធាតុ

**មាត្រា៩៩៩** ._ នីតិសម្បទានៃមន្ត្រីនគរបាលយុត្តិធម៌នៃការប្រែប្រួលអាកាសធាតុ

មន្ត្រីនគរបាលយុត្តិធម៌នៃការប្រែប្រួលអាកាសធាតុ ត្រូវផ្តល់នីតិសម្បទាដោយ លិខិតបទដ្ឋានគតិយុត្តរួមគ្នារវាងក្រសួងយុត្តិធម៌ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយនិរន្តរភាព ។

**មាត្រា១០០០** ._ សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌នៃការប្រែប្រួលអាកាសធាតុ

មន្ត្រីនគរបាលយុត្តិធម៌នៃការប្រែប្រួលអាកាសធាតុ ត្រូវអនុវត្តភារកិច្ច និងតួនាទីរបស់ខ្លួនទាក់ទងផ្នែកការប្រែប្រួលអាកាសធាតុ ដូចមានចែងក្នុងជំពូកទី១នៃមាតិកានេះ ។

**មាត្រា១០០១** ._ បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌នៃការប្រែប្រួលអាកាសធាតុ

ការបំពេញបេសកកម្ម និងការកសាងសំណុំរឿងពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ត្រូវអនុវត្តត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ផ្នែកទី៣
## មន្ត្រីនគរបាលយុត្តិធម៌នៃរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលកំណត់ ឬបង្កើតដោយថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ

**មាត្រា១០០២** ._ ការចាត់តាំងជាមន្ត្រីនគបាលយុត្តិធម៌ផ្នែកបរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិនៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ។

ការបំពេញបេសកកម្ម និងការកសាងសំណុំរឿងពាក់ព័ន្ធនឹងរបៀងអភិរក្សជីវៈចម្រុះ តំបន់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចមានចែងក្នុងបទប្បញ្ញត្តិទូទៅជំពូកទី២នេះ និងច្បាប់ពិសេសផ្សេងៗទៀតត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា១០០៣** ._ ការស៊ើបអង្កេតភ្លាមៗ

មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ នៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវចាត់វិធានការភ្លាមៗ ដើម្បីស៊ើបអង្កេតករណីណាមួយនៃបទល្មើសធនធានធម្មជាតិនៅក្នុងរបៀងអភិរក្សធនធានធម្មជាតិ តំបន់ការពារធម្មជាតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

**មាត្រា១០០៤** ._ លក្ខខណ្ឌតម្រូវសម្រាប់របាយការណ៍

នៅពេលអនុវត្តបេសកកម្មក្នុងការស៊ើបអង្កេតអំពីបទល្មើសដែលកើតឡើង នៅក្នុងរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និង មន្ទីរបរិស្ថានខេត្ត និងមន្ត្រីដទៃផ្សេងទៀតដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ផ្នែកបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើរបាយការណ៍អំពីការស៊ើបអង្កេតរបស់ខ្លួនអំពីបទល្មើសធនធានធម្មជាតិ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា១០០៥** ._ ភស្តុតាង

ភស្តុតាងនៃបទល្មើសធនធានធម្មជាតិ ទោះបីជាកើតឡើងនៅខាងក្នុងក្តី ឬខាងក្រៅក្តី នៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវដាក់បញ្ចូលនូវព័ត៌មានដូចខាងក្រោម ៖

ក- ការឈូសឆាយ ការបំផ្លិចបំផ្លាញ ការរំខាន ឬការធ្វើឲ្យខូចខាតចំពោះ ផល និងអនុផលនៃធនធានធម្មជាតិ ដែលជាភស្តុតាងជាក់ស្តែងនៃសកម្មភាពខុសច្បាប់ ។

ខ- ឧបករណ៍ និងមធ្យោបាយនៃការដឹកជញ្ជូន ដែលអាចត្រូវបានប្រើប្រាស់សម្រាប់ការប្រព្រឹត្តសកម្មភាពខុសច្បាប់ ។

គ -ឧបករណ៍ និងឯកសារកំណត់ត្រានានា ដែលបានប្រើប្រាស់នៅក្នុងធុរកិច្ចនៃការប្រព្រឹត្តបទល្មើស មានជាអាទិ៍ ទូរស័ព្ទ កំណត់ត្រាផ្នែកហិរញ្ញវត្ថុ និងកំណត់ត្រាធនាគារ ។

ឃ -ទ្រព្យសម្បត្តិដែលត្រូវបានពិចារណាថា ទំនងជាត្រូវបានទិញបានតាមរយៈការប្រព្រឹត្តបទល្មើស ។

ង- ឯកសារនានា ឬ សក្ខីកម្មផ្សេងទៀត ដែលផ្តល់ឲ្យដោយសាក្សីនៃសកម្មភាពខុសច្បាប់ ឬចេតនាក្នុងការប្រព្រឹត្តបទល្មើសបែបនេះ ។

ភស្តុតាងនានាដែលរឹបអូសជាបណ្តោះអាសន្នខាងលើនេះ ត្រូវគ្រប់គ្រងស្របតាមលិខិតបទដ្ឋានគតិយុត្តនានា ដែលបានកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ភស្តុតាងដែលចែងនៅក្នុងចំណុចខាងលើនេះ ត្រូវសម្រេចរឹបអូសចុងក្រោយដោយសេចក្តីសម្រេចតុលាការ ។

**មាត្រា១០០៦** ._ ការរឹបអូសទុកនូវការដឹកជញ្ជូនខុសច្បាប់

នៅក្នុងអំឡុងពេលនៃការដឹកជញ្ជូនផល និងអនុផលធនធានធម្មជាតិ អ្នកបើកបរមធ្យោបាយដឹកជញ្ជូននោះ ដោយគ្មានវត្តមានម្ចាស់នៅជាមួយ ត្រូវរឹបអូសទុកជាបណ្តោះអាសន្ន ដើម្បីជួយសម្រួលដល់ការស៊ើបអង្កេតជនល្មើស ។

**មាត្រា១០០៧** ._ ភស្តុតាងដែលរឹបអូសបាន

ភស្តុតាងដែលរឹបអូសបាន ត្រូវគ្រប់គ្រងស្របតាមនីតិវិធីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានស្របតាមក្រមនេះ ច្បាប់ពិសេសផ្សេងទៀត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

ភស្តុតាងត្រូវរក្សាដោយសុវត្ថិភាព និងត្រឹមត្រូវ ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬក្រសួង ស្ថាប័នពាក់ព័ន្ធនានាផ្សេងទៀតដែលទទួលបានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ មានសិទ្ធិបញ្ចេញ បំផ្លាញ ឬរក្សាទុក សម្រាប់ផលប្រយោជន៍សាធារណៈនូវផល និងអនុផលធនធានធម្មជាតិដែលរឹបអូសបាន ។

**មាត្រា១០០៨** ._ សត្វព្រៃដែលរឹបអូសបាន

សត្វព្រៃនៅរស់ដែលរឹបអូសបាន ត្រូវគ្រប់គ្រងស្របតាមនីតិវិធីរបស់ក្រុមការងារសង្គ្រោះសត្វព្រៃ និងត្រូវដោះលែងឲ្យបានកាន់តែឆាប់តាមដែលអាចធ្វើទៅបាន ទៅឲ្យមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬទៅឲ្យស្ថានីយ៍ដោះលែងសត្វព្រៃនានា ។

សាកសព ឬផ្នែកនានា នៃសត្វព្រៃដែលរឹបអូសបាន ត្រូវគ្រប់គ្រងស្របតាមក្រមនេះ អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធដទៃទៀត ។ សាកសព ឬផ្នែកនានានៃសត្វព្រៃដែលរឹបអូសបាន ត្រូវហាមឃាត់មិនឲ្យធ្វើការលក់ដូរឡើយ ។

ការរឹបអូស និងការគ្រប់គ្រងសត្វព្រៃដែលនៅរស់ សាកសព ឬផ្នែកនានានៃសត្វព្រៃ ជ័យភ័ណ្ឌ ឬវត្ថុផ្សេងទៀតដែលកើតចេញពីសត្វព្រៃ ត្រូវកត់ត្រាទុកឲ្យបានត្រឹមត្រូវ និងគោរពតាមលិខិតបទដ្ឋានគតិយុត្តស្ដីពីកិច្ចការពារ ការអភិរក្ស និងការគ្រប់គ្រងសត្វព្រៃ ។

**មាត្រា១០០៩** ._ សិទ្ធិអំណាចក្នុងការដាក់កម្រិតនានា

បុគ្គលិកនៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរបរិស្ថានខេត្ត និងបុគ្គលិកថ្នាក់ក្រោមនានា មានសិទ្ធិអំណាចក្នុងការដាក់កម្រិតលើសកម្មភាពនានារបស់បុគ្គលណាម្នាក់ ឬបញ្ឈប់ជាបណ្ដោះអាសន្ននូវសកម្មភាពរបស់ក្រុមហ៊ុនណាមួយ ដែលបានប្រព្រឹត្តបទល្មើសប្រឆាំងនឹងបទប្បញ្ញត្តិនៃមាតិកានេះ ឬបានរំលោភបំពានលើកិច្ចព្រមព្រៀងណាមួយ ។

**មាត្រា១០១០** ._ សិទ្ធិក្នុងការធ្វើបណ្ដឹង

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមិនយល់ស្របតាមសេចក្ដីសម្រេចណាមួយដែលធ្វើឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ នៅក្នុងការអនុវត្ត

អំណាចរបស់ខ្លួននៅក្រោមមាតិកានេះ មានសិទ្ធិក្នុងធ្វើបណ្តឹងជាលាយលក្ខណ៍អក្សរ ស្របតាមគន្ថីទី ៩ នៃក្រមនេះ ។

បណ្តឹងនានាដែលធ្វើឡើងនៅក្រោមមាតិកានេះ មិនត្រូវធ្វើឲ្យប៉ះពាល់ចំពោះសិទ្ធិអំណាច ឬ ទប់ស្កាត់ដំណើរការនៃការពង្រឹងការអនុវត្តច្បាប់របស់មន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន នៅក្រោមមាតិកានេះឡើយ ។

## ផ្នែកទី៤
## មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិចំពោះបទល្មើសសត្វព្រៃ

**មាត្រា១០១១** ._ ការពង្រឹងការអនុវត្តច្បាប់

មន្ត្រីដែលស្ថិតនៅក្រោមក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន មន្ទីរបរិស្ថាន និងក្រសួង ស្ថាប័នពាក់ព័ន្ធ និងដែលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ផ្នែកបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុវត្តបេសកកម្មរបស់ខ្លួនស្របតាមគន្ថីទី៩ នៃក្រមនេះ សម្រាប់បទល្មើសសត្វព្រៃ ដែលបាន កំណត់យក្រោមមាតិកានេះ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១០១២** ._ បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិចំពោះបទល្មើសសត្វព្រៃ

ការបំពេញបេសកកម្ម និងនីតិវិធីក្នុងការកសាងសំណុំរឿងរបស់មន្ត្រីនគរបាលយុត្តិធម៌ផ្នែកបរិស្ថាន និងធនធានធម្មជាតិចំពោះបទល្មើសសត្វព្រៃ ត្រូវអនុលោមតាមក្រមនេះ និងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា១០១៣** ._ វិធានការបន្ទាន់

មន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន មន្ទីរបរិស្ថានខេត្ត និងមន្ត្រីនគរបាលយុត្តិធម៌ផ្នែកបរិស្ថាន និងធនធានធម្មជាតិ ត្រូវចាត់វិធានការជាបន្ទាន់ដើម្បីធ្វើការស៊ើបអង្កេត និងបង្ក្រាបបទល្មើសសត្វព្រៃទាំងឡាយ និងវិធានការស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងក្រមនេះ និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន ។

**មាត្រា១០១៤** ._ ភស្តុតាង

ភស្តុតាងនៃបទល្មើសសត្វព្រៃ មានដូចតទៅ៖

ក-សត្វព្រៃដែលរស់ សត្វព្រៃដែលស្លាប់ បំណែកសត្វព្រៃ សត្វ ឬបំណែកនៃសត្វដែលបរបាញ់បាន និងវត្ថុធាតុនានានៃសត្វព្រៃ ។

ខ-ឧបករណ៍ និងមធ្យោបាយនានាដែលប្រើសម្រាប់ដឹកជញ្ជូនក្នុងបំណងប្រព្រឹត្តបទល្មើសដោយចេតនា មានជាអាទិ៍ សម្ភារៈដែលប្រើជាមធ្យោបាយដែលត្រូវបានហាមឃាត់សម្រាប់ការបរបាញ់ ។

គ-ឧបករណ៍ និងកំណត់ត្រានានាដែលបានប្រើក្នុងការធ្វើអាជីវកម្មសត្វព្រៃ មានជាអាទិ៍ ទូរស័ព្ទ របាយការណ៍ហិរញ្ញវត្ថុ និងរបាយការធានាគារ ។ល។

ឃ-ទ្រព្យសម្បត្តិដែលត្រូវបានរាប់ថា បានមកពីដំណាក់កាលនានានៃការប្រព្រឹត្តបទល្មើសសត្វព្រៃ ។

ង-ឯកសារ ឬសក្ខីកម្មរបស់សាក្សី ពាក់ព័ន្ធទៅនឹងសកម្មភាពខុសច្បាប់ ឬការប៉ុនប៉ងប្រព្រឹត្តបទល្មើសដោយចេតនាបែបណាមួយ ។

ភស្តុតាងនានាដែលរឹបអូសជាបណ្តោះអាសន្នខាងលើនេះ ត្រូវគ្រប់គ្រងស្របតាមជំពូកទី១១ នៃមាតិការនេះ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលបានកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ភស្តុតាងដែលចែងនៅក្នុងចំណុចខាងលើនេះ ត្រូវសម្រេចរឹបអូសចុងក្រោយដោយសេចក្តីសម្រេចតុលាការ ។

**មាត្រា១០១៥ .**_ នីតិវិធីនានាពាក់ព័ន្ធទៅនឹងភស្តុតាង

ភស្តុតាងពាក់ព័ន្ធនឹងសត្វព្រៃ រួមទាំង សត្វព្រៃដែលរស់ ត្រូវប្រគល់ជូនទៅអង្គភាពពាក់ព័ន្ធដែលទទួលបន្ទុកលើវិធានការអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរសត្វព្រៃ ។

**មាត្រា១០១៦ .**_ ភស្តុតាងដែលរឹបអូសបាន

រាល់ភស្តុតាងដែលរឹបអូសបាន ត្រូវធ្វើការគ្រប់គ្រងស្របតាមនីតិវិធីដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដូចមានចែងក្នុងគន្ថីទី៩ នៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ ។

ភស្តុតាងនានា ត្រូវរក្សាប្រកបដោយសុវត្ថិភាពដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬ នៅឯក្រសួង ស្ថាប័នដទៃដែលទទួលបានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ទទួលសិទ្ធិក្នុងកាលែង បំផ្លាញ និងរក្សាផល និងអនុផលធនធានធម្មជាតិដែលរឹបអូសបានសម្រាប់ជាប្រយោជន៍ដល់សាធារណជន ដោយមានរបាយការណ៍ច្បាស់លាស់ ។

**មាត្រា១០១៧ .**_ ការគ្រប់គ្រងសត្វព្រៃ ផលិតផលសត្វព្រៃ និងបំណែកសត្វ ដែលរឹបអូសបាន

រាល់ការរើបអូស និងការគ្រប់គ្រងសត្វព្រៃ ផលិតផលសត្វព្រៃ និងបំណែកសត្វព្រៃ ឬវត្ថុធាតុនៃសត្វព្រៃ ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តនៃមាតិកានេះ និង អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ហត្ថលេខី ។

**មាត្រា១០១៨** ._ ការហាមឃាត់ទៅលើសកម្មភាពមួយចំនួន

មន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរបរិស្ថានខេត្ត និងភ្នាក់ងារនានាដែលអនុវត្តបេសកកម្មក្នុងការស៊ើបអង្កេតបទល្មើសដូចមានចែងក្នុងគន្ថីទី៩ មានភារកិច្ចកំណត់ពីការហាមឃាត់ទៅលើសកម្មភាពនានារបស់រូបវន្តបុគ្គល ឬនីតិបុគ្គលជាបណ្ដោះអាសន្ន រហូតដល់នីតិវិធីនៃការស៊ើបអង្កេតបានដោះស្រាយចប់សព្វគ្រប់ ។

**មាត្រា១០១៩** ._ បណ្ដឹង

រូបវន្តបុគ្គល ឬនីតិបុគ្គលនានា ដែលមិនយល់ស្របទៅនឹងសេចក្ដីសម្រេចណាមួយរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចនានាដែលពាក់ព័ន្ធដូចមានចែងក្នុងក្រមនេះ ច្បាប់ពិសេសផ្សេងទៀត និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ក្នុងការអនុវត្តអំណាចរបស់ខ្លួនស្របតាមមាតិកានេះ មានសិទ្ធិក្នុងធ្វើបណ្ដឹងជាលាយល័ក្ខអក្សរ ស្របតាម គន្ថីទី៩ នៃក្រមនេះ ។

បណ្ដឹងនានាដែលធ្វើឡើងស្របតាមមាត្រានេះ មិនប៉ះពាល់ដល់សិទ្ធិអំណាច ឬរាំងដល់ដំណើរការនៃការអនុវត្តច្បាប់របស់មន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានក្រោមមាតិកានេះនោះឡើយ។

## ផ្នែកទី៥
## មន្ត្រីនគរបាលយុត្តិធម៌ការពារបេតិកភណ្ឌ

**មាត្រា១០២០** ._ មន្ត្រីនគរបាលយុត្តិធម៌ការពារបេតិកភណ្ឌ

មន្ត្រីនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈអាចត្រូវបានតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ផ្នែកបរិស្ថាន និងធនធានធម្មជាតិ ស្របតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ សមាសភាពមន្ត្រីនគរបាលយុត្តិធម៌ការពារបេតិកភណ្ឌរួមមាន៖

ក-មន្ត្រីដែលត្រូវបានតែងតាំងជាមន្ត្រីការពារបេតិកភណ្ឌ ។

ខ-មន្ត្រីរបស់មន្ទីរ ឬនាយកដ្ឋានរាជធានី ខេត្តរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា១០២១** ._ បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ការពារបេតិកភណ្ឌ

មន្ត្រីនគរបាលយុត្តិធម៌ការពារបេតិកភណ្ឌមានបេសកកម្ម និងតួនាទីដូចមានចែងក្នុងផ្នែកទី១ នៃក្រមមាតិកានេះ ។

នីតិវិធីនៃការកសាងសំណុំរឿងរបស់មន្ត្រីនគរបាលយុត្តិធម៌ផ្នែកការពារបេតិកភណ្ឌ ត្រូវអនុលោមតាមក្រម នីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា១០២២**._ បណ្តឹង

រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនយល់ស្របនឹងការសម្រេចចិត្តដែលធ្វើឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចនានាដែលពាក់ព័ន្ធដូចមានចែងក្នុងក្រមនេះ ច្បាប់ពិសេសផ្សេងទៀត និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតក្នុងការអនុវត្តអំណាចរបស់ខ្លួនក្រោមមាតិកានេះ មានសិទ្ធិដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរស្របតាមគន្ថីទី៩ នៃក្រមនេះ ។

បណ្តឹងណាដែលធ្វើឡើងក្រោមមាត្រានេះ មិនត្រូវប៉ះពាល់ទៅលើសិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកអនុវត្តច្បាប់ដើម្បី ទប់ស្កាត់ដំណើរការនៃការពង្រឹងការអនុវត្តស្របតាមមាតិកានេះ ឡើយ ។

## ជំពូកទី២
## មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១០២៣**._ ការតែងតាំងមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ត្រូវចាត់តាំងមន្ត្រីដោយឡែក ដើម្បីទទួលបន្ទុកកិច្ចការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងគ្រប់គ្រងធម្មជាតិ ស្របតាមក្រមនេះ ច្បាប់ពិសេសដោយឡែក និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា១០២៤**._ ឋានៈមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានឋានៈជាមន្ត្រីនគរបាលយុត្តិធម៌ស្របតាមក្រមនេះ ច្បាប់ពិសេសដោយឡែក និងលិខិតបទដ្ឋានគតិយុត្តដទៃទៀតផងដែរ ។ ក្រៅពីពីនេះ មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ មានភារកិច្ច និងតួនាទីជាមន្ត្រីអធិការកិច្ចបរិស្ថាន និងធម្មជាតិ

ធម្មតាដូចមានចែងក្នុងមាត្រា១០១៨ខាងក្រោម ។

**មាត្រា១០២៥** ._ ភារកិច្ច និងតួនាទីរបស់មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ មានភារកិច្ច និងតួនាទីដូចខាងក្រោមៈ

១- ធ្វើអធិការកិច្ចតាមដាន និងត្រួតពិនិត្យការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិក្រោមសមត្ថកិច្ចរបស់ខ្លួន ។

២- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការធ្វើអធិការកិច្ចដាក់ជូនថ្នាក់ដឹកនាំដើម្បីពិនិត្យ និងសម្រេច ។

៣- ចាត់វិធានការចាំបាច់ក្នុងករណីមានការបំពានក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

៤- ចេញបទបញ្ជានានាតាមការចាំបាច់ក្នុងករណីមានការគំរាមគំរាមកំហែងដល់បរិស្ថាន និងធនធានធម្មជាតិបានកើតឡើង ។

៥- ជូនដំណឹងដល់សាធារណជន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត ក្នុងករណីមានការគំរាមកំហែងធ្ងន់ធ្ងរដល់បរិស្ថាន និងធនធានធម្មជាតិ ។

ក្រៅពីភារកិច្ច និងតួនាទីដែលកំណត់ក្នុងក្រមនេះ មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុវត្តភារកិច្ច និងតួនាទីដូចមានចែងក្នុងច្បាប់ពិសេសដោយឡែក និងលិខិតបទដ្ឋានគតិយុត្តពាក់ពាន់នានាផងដែរ ។

**មាត្រា១០២៦** ._ កិច្ចសហការចំពោះការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ

ម្ចាស់គម្រោង ឬប្រតិបត្តិករ ឬស្ថាប័នពាក់ព័ន្ធនានា ត្រូវមានកាតព្វកិច្ចសហការជាមួយមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ក្នុងការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១០២៧** ._ ការប្រើប្រាស់ឯកសណ្ឋានក្នុងការស៊ើបអង្កេតលើបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានលិខិតអនុញ្ញាត និងពាក់ប័ណ្ណសម្គាល់អត្តសញ្ញាណច្បាស់លាស់ និងពាក់ឯកសណ្ឋាន នៅពេលចុះបំពេញភារកិច្ច និងតួនាទីរបស់ខ្លួន ។

## ផ្នែកទី២
## មន្ត្រីអធិការកិច្ចវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា១០២៨ ._** ការតែងតាំងមន្ត្រីអធិការកិច្ចវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវតែងតាំងមន្ត្រីអធិការកិច្ចវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធ្វើអធិការកិច្ចលើគម្រោង ឬប្រតិបត្តិការគម្រោង ឬទីតាំងដែលជាកម្មវត្ថុនៃការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា១០២៩ ._** ឋានៈមន្ត្រីអធិការកិច្ចវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

មន្ត្រីអធិការកិច្ចវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបានការតែងតាំងត្រឹមត្រូវ ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវមានឋានៈជាមន្ត្រីនគរបាលយុត្តិធម៌ ។

**មាត្រា១០៣០ ._** សិទ្ធអំណាចរបស់មន្ត្រីអធិការកិច្ចពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

មន្ត្រីអធិការកិច្ចវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន មានសិទ្ធិ អំណាចដូចខាងក្រោម៖

ក-ធ្វើអធិការកិច្ចតាមដាន និងត្រួតពិនិត្យការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន លិខិតបទដ្ឋានគតិយុត្តនានា កិច្ចសន្យាការពារបរិស្ថាន ស្តង់ដារ ផែនការគ្រប់គ្រងបរិស្ថាន និងលក្ខខណ្ឌតម្រូវផ្នែកបរិស្ថានដែលពាក់ព័ន្ធផ្សេងទៀត ។

ខ-ក្នុងករណីចាំបាច់ មន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អាចបង្គាប់ឲ្យម្ចាស់គម្រោងផ្អាកសកម្មភាពមួយផ្នែក ឬទាំងស្រុងជាបណ្តោះអាសន្ន ឬបិទទីតាំងជាបណ្តោះអាសន្ន ។

គ-ពិនិត្យកំណត់ត្រា ឯកសារ ទិន្នន័យអេឡិចត្រូនិកស្តីពីការគ្រប់គ្រងបរិស្ថាន និងកំណត់ត្រាដទៃទៀតស្តីពីគម្រោងអភិវឌ្ឍ និងការប្រតិបត្តិគម្រោង ។

ឃ-ស្តាប់ និងធ្វើកំណត់ហេតុស្តាប់ចម្លើយរបស់កម្មករ និយោជិត តំណាងម្ចាស់គម្រោង និងបុគ្គលពាក់ព័ន្ធនានា ។

ង-បង្គាប់ឲ្យកម្មករ និយោជិត អភិបាល អ្នកតំណាងស្របច្បាប់ និងភ្នាក់ងារនៃគម្រោងអភិវឌ្ឍ ផ្តល់នូវរាល់ព័ត៌មាន ឯកសារជាលាយលក្ខណ៍អក្សរ ផែនការ និងកំណត់ត្រាគ្រប់ប្រភេទដែលពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ។

ច-មានសិទ្ធិចុះឆែកឆេរទីតាំងគម្រោង និងចាប់យកវត្ថុតាង ក្នុងករណីដែលសង្ស័យថាមានអំពើល្មើសនឹងច្បាប់ ឬបទប្បញ្ញត្តិនានាស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ។

ជ-ជួបប្រជុំជាមួយប្រធានក្រុមប្រឹក្សាភិបាល តំណាងស្របច្បាប់ និងកម្មករ និយោជិតនៃគម្រោងយ៉ាងតិច ១ (មួយ) ឆ្នាំ ម្តង ដើម្បីធ្វើការវាយតម្លៃការអនុវត្តក្រមនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត ។

ឈ-ធ្វើកំណត់ហេតុផែកឆេរ និងចាប់យកវត្ថុតាងនានា ដើម្បីកសាងសំណុំរឿងនៃការប្រព្រឹត្តល្មើសនឹងច្បាប់នេះ ដើម្បីចាត់ការតាមនីតិវិធីជាធរមាន ។

## ផ្នែកទី៣
## មន្ត្រីការពារបេតិកភណ្ឌ

**មាត្រា១០៣១ .**_ មន្ត្រីការពារបេតិកភណ្ឌ

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវតែងតាំងមន្ត្រីការពារបេតិកភណ្ឌមួយរូប ប្រចាំរាជធានី ខេត្ត ។ មន្ត្រីការពារបេតិកភណ្ឌវប្បធម៌ ស្ថាប័នទទួលបន្ទុកវិស័យវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវពិគ្រោះយោបល់ជាមួយ អភិបាលរាជធានីខេត្ត ។

**មាត្រា១០៣២ .**_ ភារកិច្ចរបស់មន្ត្រីការពារបេតិកភណ្ឌ

មន្ត្រីការពារបេតិកភណ្ឌ ត្រូវប្រាស្រ័យទាក់ទងជាមួយរដ្ឋបាលរាជធានី ខេត្ត និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីការពារវត្ថុបេតិកភណ្ឌ និងផ្តល់ជំនួយក្នុងការអនុវត្តគន្លីនេះ ។

**មាត្រា១០៣៣ .**_ តួនាទី មុខងារ និងលក្ខណៈសម្បត្តិរបស់មន្ត្រីការពារបេតិកភណ្ឌ

តួនាទី មុខងារ និងលក្ខណៈសម្បត្តិរបស់មន្ត្រីការពារបេតិកភណ្ឌ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដែលកំណត់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មន្ត្រីការពារបេតិកភណ្ឌ អាចត្រូវធ្វើការជាមួយមន្ត្រីការពារបេតិកភណ្ឌរាជធានី ខេត្ត និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានដើម្បីការពារបេតិកភណ្ឌទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ មន្ត្រីការពារបេតិកភណ្ឌ អាចទទួលការតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ស្របតាមគន្លីនេះ និងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី៤
## មន្ត្រីអធិការកិច្ចការបំពុលបរិស្ថាន

**មាត្រា១០៣៤ ._** ការតែងតាំងមន្ត្រីអធិការកិច្ចការបំពុលបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវតែងតាំងមន្ត្រីអធិការកិច្ចការបំពុលបរិស្ថាន សម្រាប់ធ្វើអធិការកិច្ចលើប្រភពនៃការបំពុលបរិស្ថាន ។

មន្ត្រីត្រួតពិនិត្យការបំពុលបរិស្ថាន អាចធ្វើអធិការកិច្ចនៅក្នុងបរិវេណណាមួយក៏បាន ដើម្បីកំណត់ថាមាន ឬមិនមានអំពើល្មើសណាមួយទាស់ទៅនឹងលក្ខខណ្ឌតម្រូវសម្រាប់ការគ្រប់គ្រងសំណល់ ។

**មាត្រា១០៣៥ ._** ឋានៈមន្ត្រីអធិការកិច្ចការបំពុលបរិស្ថាន

មន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន ដែលទទួលបានការតែងតាំងត្រឹមត្រូវ ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវមានឋានៈជាមន្ត្រីនគរបាលយុត្តិធម៌ ។

**មាត្រា១០៣៦ ._** លក្ខណៈសម្បត្តិ និងការតែងតាំងមន្ត្រីអធិការកិច្ចការបំពុលបរិស្ថាន

មុនពេលតែងតាំងមន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវចេញលិខិតបទដ្ឋានគតិយុត្ត សម្រាប់៖

ក-កម្រិតអប្បបរមានៃការបណ្តុះបណ្តាល និងលក្ខណៈសម្បត្តិ ដែលបុគ្គលណាម្នាក់ត្រូវមាន ដើម្បីទទួលបានគុណសម្បត្តិជាមន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន និង

ខ-នីតិវិធីសម្រាប់ការចាត់តាំង ការត្រួតពិនិត្យ និងការតែងតាំងនូវមន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចអនុញ្ញាតឲ្យក្រសួង ស្ថាប័នទទួលបន្ទុកពាក់ព័ន្ធវិស័យ បរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ដែលទទួលខុសត្រូវសម្រាប់កិច្ចការពារបរិស្ថាននៅថ្នាក់ក្រុង និងថ្នាក់ក្រោមជាតិ ក្នុងការតែងតាំងមន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន ស្របតាមលក្ខខណ្ឌតម្រូវ នៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងច្បាប់ពិសេសផ្សេងទៀត ឬ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ។

**មាត្រា១០៣៧ ._** ការទទួលខុសត្រូវរបស់មន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន

មន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន មានសិទ្ធិអំណាចដូចខាងក្រោម៖

១- ចូលទៅក្នុងក្នុងបរិវេណនៃអាគារ គម្រោង ឬសកម្មភាព ឬប្រភពផ្សេងទៀតនៃការបំពុល ឬសំណល់ ហើយធ្វើអធិការកិច្ចលើបរិវេណនោះ ដែលរួមមាន បច្ចេកវិជ្ជាត្រួតពិនិត្យការបំពុល បច្ចេកវិទ្យាត្រួតពិនិត្យការគ្រប់គ្រងសំណល់ ឬវិធានការដទៃទៀត នៅក្នុងបរិវេណនោះ ។

២- ប្រមូល និងយកសំណាកនានានៃការបង្ហូរសំណល់រាវ ការបំភាយខ្យល់ ឬប្រភពជាសក្តានុពលដទៃទៀតនៃការបំពុល ដែលត្រូវធ្វើការពិសោធន៍នៅក្នុងមន្ទីរពិសោធន៍របស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬមន្ទីរពិសោធន៍ដទៃទៀតដែលទទួលស្គាល់ ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

៣- ប្រមូល និងថតឯកសារជារូបភាព ឬវីដេអូភាពយន្តនៃដំណើរការនានានៃបរិវេណអាគារ មានជាអាទិ៍ ប្រតិបត្តិការនៃប្រភពជាសក្តានុពលនៃការបំពុល ឬសំណល់ និងបច្ចេកវិទ្យា ឬវិធានការក្នុងការត្រួតពិនិត្យការបំពុល ឬសំណល់ និងបច្ចេកវិជ្ជា ឬវិធានការ ដែលត្រូវបានរៀបចំឡើងដើម្បីត្រួតពិនិត្យការបំពុលបែបនេះ ។

៤- មានសិទ្ធិពិនិត្យលើកំណត់ត្រា ការឯកភាព លិខិតអនុញ្ញាត របាយការណ៍ ឬឯកសារដទៃទៀតទាក់ទងនឹងការបំពុល សំណល់ បច្ចេកវិជ្ជាត្រួតពិនិត្យការបំពុល បច្ចេកវិទ្យាត្រួតពិនិត្យការគ្រប់គ្រងសំណល់ ឬវិធានការដែលតម្រូវឲ្យអនុវត្តនៅក្រោមក្រមនេះ ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ។

៥- សម្ភាសជាមួយម្ចាស់ ឬអ្នកទទួលខុសត្រូវ ដែលទទួលបន្ទុកចំពោះប្រតិបត្តិការលើបរិវេណអាគារ មានជាអាទិ៍ បុគ្គលនានាដែលទទួលខុសត្រូវចំពោះប្រតិបត្តិការនៃវិធានការ ឬបច្ចេកវិជ្ជាត្រួតពិនិត្យការបំពុល ឬវិធានការ ឬបច្ចេកវិទ្យាត្រួតពិនិត្យការគ្រប់គ្រងសំណល់របស់អាគារ និងបុគ្គលដទៃទៀតដែលស្ថិតនៅលើអាគារដែលចាត់ទុកថាជាការចាំបាច់ ។

៦- ចេញបទបញ្ជាកអនុម័តលើវិធានការកែតម្រូវ ប្រសិនបើមន្ត្រីអធិការកិច្ចការបំពុលបរិស្ថានរកឃើញថា សកម្មភាព ឬ ប្រតិបត្តិការណាមួយនៅលើអាគារដែលកំពុងតែរំលោភបំពានលើក្រមនេះ ឬរកឃើញថា បច្ចេកវិជ្ជាត្រួតពិនិត្យការបំពុល បច្ចេកវិទ្យាត្រួតពិនិត្យការគ្រប់គ្រងសំណល់ ឬវិធានការដទៃទៀតមិនមានដំណើរការ ឬប្រតិបត្តិការ ស្របតាមលិខិតអនុញ្ញាត ការអនុញ្ញាត ផែនការគ្រប់គ្រងបរិស្ថាន ឬកិច្ចសន្យាការពារបរិស្ថានដែលពាក់ព័ន្ធនោះទេ ដោយអាស្រ័យទៅតាមករណីដែលអាចកើតឡើង ។

**មាត្រា១០៣៨ .**_ នីតិវិធីនៃការធ្វើអធិការកិច្ចការបំពុលបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតនីតិវិធី ដែលមន្ត្រីអធិការកិច្ចបរិស្ថាន និងម្ចាស់ ឬប្រតិបត្តិករនៃអាគារ សកម្មភាព ឬគម្រោងដែលស្ថិតក្រោមការធ្វើអធិការកិច្ច ត្រូវអនុវត្តតាមដើម្បីចាប់ផ្តើម និងអនុវត្តការធ្វើអធិការកិច្ច ។

មន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន ត្រូវស្លៀកពាក់ឯកសណ្ឋានសម្គាល់ខ្លួន ដែលអាចកំណត់អត្តសញ្ញាណបានដោយងាយស្រួល និងត្រូវបង្ហាញអត្តសញ្ញាណរបស់ខ្លួនទៅកាន់ម្ចាស់ ឬប្រតិបត្តិករនៃអាគារ សកម្មភាព ឬ គម្រោង ដែលស្ថិតក្រោមការធ្វើអធិការកិច្ចមុនពេលអនុវត្តអធិការកិច្ចនោះ ។

មន្ត្រីអធិការកិច្ចការបំពុលបរិស្ថាន ត្រូវថែរក្សាទុកនូវឯកសារកំណត់ត្រានៃការធ្វើអធិការកិច្ចនីមួយៗ ដែលខ្លួនបានអនុវត្ត ។ កំណត់ត្រានៃការធ្វើអធិការកិច្ច ត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីការទទួលបានព័ត៌មាន នៃក្រមនេះ ។

**មាត្រា១០៣៩ ._** ការហាមឃាត់ក្នុងការបដិសេធចំពោះការចូលធ្វើអធិការកិច្ច

ទោះស្ថិតក្រោមកាលៈទេសៈណាក៏ដោយ ម្ចាស់ ឬប្រតិបត្តិករ នៃអាគារ សកម្មភាព ឬ គម្រោងដែលត្រូវស្ថិតក្រោមការធ្វើអធិការកិច្ច មិនអាចបដិសេធមិនឲ្យមន្ត្រីអធិការកិច្ចការបំពុលបរិស្ថានចូលទៅកាន់បរិវេណអាគារ អនុវត្តតាមនីតិវិធីក្នុងការធ្វើអធិការកិច្ចបាននោះទេ ។

**មាត្រា១០៤០ ._** សកម្មភាពដែលទទួលបានអនុញ្ញាត

ប្រសិនបើ នៅក្នុងអំឡុងពេលធ្វើអធិការកិច្ច មន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន រកឃើញនូវប្រភពនៃការបំពុល ឬសំណល់ ឬការខកខានមិនបានធ្វើប្រតិបត្តិការត្រឹមត្រូវនូវ បច្ចេកវិជ្ជាគ្រប់គ្រងការបំពុល ឬបច្ចេកវិទ្យាត្រួតពិនិត្យការគ្រប់គ្រងសំណល់ ឬ វិធានការដទៃទៀត ដែលអាចបង្កឲ្យមានការគំរាមគំរាមកំហែងចំពោះសុខភាពសាធារណៈ ទ្រព្យសម្បត្តិ បរិស្ថាន ឬធនធានធម្មជាតិ នោះមន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន ត្រូវមានសិទ្ធិអក្នុងការៈ

ក-ជូនដំណឹងភ្លាមដល់បុគ្គល ឬស្ថាប័នដទៃទៀត ដែលអាចប្រឈមនឹងការគំរាមកំហែងនោះ ។

ខ-បញ្ជាឲ្យម្ចាស់ ឬប្រតិបត្តិករនៃអាគារ ដែលត្រូវធ្វើអធិការកិច្ច អនុម័តយកភ្លាមៗនូវវិធានការកែតម្រូវ ដើម្បីធានាឲ្យបាននូវប្រតិបត្តិការដែលត្រឹមត្រូវនៃ បច្ចេកវិជ្ជា ឬវិធានការគ្រប់គ្រងការបំពុល ឬបច្ចេកវិទ្យាត្រួតពិនិត្យការគ្រប់គ្រងសំណល់ ឬវិធានការដទៃទៀតស្របតាមលក្ខខណ្ឌតម្រូវការគ្រប់គ្រងសំណល់ ឬបញ្ឈប់ការបំពុលនោះ ។

គ-បញ្ជាឲ្យម្ចាស់ ឬប្រតិបត្តិករនៃអាគារបញ្ឈប់ភ្លាមៗនូវប្រតិបត្តិការដែលបង្កឲ្យមានការបំពុល សំណល់ ឬការបំពានលើលក្ខខណ្ឌតម្រូវការគ្រប់គ្រងសំណល់ នៅក្នុងករណីដែលវិធានការកែតម្រូវភ្លាមៗដែលពាក់ព័ន្ធមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការកាត់បន្ថយការខូច

ខាត និងការបំពុល ឬសំណល់ដែលអាចបង្កឡើងចំពោះ សុខភាពមនុស្ស ទ្រព្យ ឬ បរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចបង្កើតនីតិវិធីដែលមន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន ម្ចាស់ និងប្រតិបត្តិករ នៃអាគារដែលត្រូវធ្វើអធិការកិច្ច ត្រូវគោរពតាម នៅពេលស្វែងរកឃើញនូវប្រភពនៃការបំពុល ឬការខកខានមិនបានធ្វើប្រតិបត្តិការត្រឹមត្រូវនូវ បច្ចេកវិជ្ជាគ្រប់គ្រងការបំពុល ឬវិធានការដទៃទៀត ឬការបំពានលើលក្ខខណ្ឌតម្រូវការគ្រប់គ្រងសំណល់ ដែលអាចបង្កឲ្យមានការគំរាមកំហែងចំពោះសុខភាពមនុស្ស ទ្រព្យ ឬបរិស្ថាន ។

**មាត្រា១០៤១** ._ របាយការណ៍វាយតម្លៃ

នៅក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ នៃការរកឃើញនូវប្រភពនៃការបំពុល ឬការខកខានមិនបានធ្វើប្រតិបត្តិការត្រឹមត្រូវនូវ បច្ចេកវិជ្ជាគ្រប់គ្រងការបំពុល ឬវិធានការដទៃទៀត ឬការបំពានលើលក្ខខណ្ឌតម្រូវការគ្រប់គ្រងសំណល់ ដែលអាចបង្កឲ្យមានការគំរាមកំហែងចំពោះបរិស្ថាន និងការចេញនូវបទបញ្ជាក្នុងការអនុម័តយកវិធានការកែតម្រូវ មន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន ត្រូវរៀបចំនូវរបាយការណ៍វាយតម្លៃការបំពុលអំពីការរកឃើញការបំពុលនោះ និងវិធានការបន្តបន្ទាប់ដែលត្រូវអនុវត្តដើម្បីដោះស្រាយការបំពុលនោះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានអាចបង្កើតនីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃការបំពុល ។ របាយការណ៍វាយតម្លៃការបំពុលទាំងអស់ ត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មាន នៃក្រមនេះ ។

**មាត្រា១០៤២** ._ ថ្លៃចំណាយសម្រាប់វិធានការកែតម្រូវ

ថ្លៃចំណាយពាក់ព័ន្ធនឹងសកម្មភាពណាមួយក្នុងការទទួលយកវិធានការកែតម្រូវដើម្បីកាត់បន្ថយជាអប្បបរមា គ្រប់គ្រង ឬបញ្ឈប់ នូវប្រភពនៃការបំពុល ឬសំណល់ណាមួយ ដែលត្រូវបានរកឃើញនៅក្នុងអំឡុងពេលនៃការធ្វើអធិការកិច្ច ជាការទទួលខុសត្រូវផ្តាច់មុខរបស់ម្ចាស់ និង/ឬប្រតិបត្តិករនៃអាគារ ។

ថ្លៃសំណាយដែលសមរម្យទាក់ទងនឹងការរៀបចំរបាយការណ៍វាយតម្លៃការបំពុលនៅក្រោមមាតិកានេះ ជាការទទួលខុសត្រូវរបស់ម្ចាស់ និង/ឬ ប្រតិបត្តិករនៃបរិវេណ/អាគារ ដែលត្រូវធ្វើរបាយការណ៍វាយតម្លៃការបំពុល ។

**មាត្រា១០៤៣** ._ សិទ្ធិក្នុងការដាក់សំណើ

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមិនពេញចិត្តចំពោះវិធានការណាមួយដែលធ្វើឡើងដោយមន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន អាចដាក់សំណើទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដើម្បីពិនិត្យនូវវិធានការនោះ ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ ក្រោយពីថ្ងៃចាត់វិធានការនោះមក ។

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវធ្វើការសម្រេចចិត្តដែលតម្រូវឲ្យលុបចោល កែសម្រួល ឬបញ្ជាក់អំពីវិធានការដែលត្រូវបានចាត់ដោយមន្ត្រីអធិការកិច្ចលើការបំពុលបរិស្ថាន និងត្រូវធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចនោះនៅក្នុងរយៈពេល៤០ (សែសិប)ថ្ងៃបន្ទាប់ពីទទួលបានសំណើនោះ ។

កំណត់ត្រាជាលាយលក្ខណ៍អក្សរនេះ ត្រូវរួមបញ្ចូលនូវមូលហេតុ ព័ត៌មាន និងទិន្នន័យដែលបង្កើតបានជាមូលដ្ឋាននៃការសម្រេចនោះ ។ កំណត់ត្រានេះត្រូវផ្តល់ទៅឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសំណើ និងត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបានស្របតាមបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មាននៃក្រមនេះ ។

ប្រសិនបើរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលធ្វើសំណើ មិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន រូបវន្តបុគ្គល ឬ នីតិបុគ្គលនោះ មានសិទ្ធិប្តឹងតវ៉ាស្របតាមបទប្បញ្ញត្តិនៃគន្ថីទី៩ នៃក្រមនេះ។

## មាតិកាទី៣
## ការស្តារឡើងវិញ និងសំណងលើការខូចខាតបរិស្ថាន
## ជំពូកទី១
## យន្តការវាយតម្លៃទំហំនៃការខូចខាតបរិស្ថាន

**មាត្រា១០៤៤**._ ការបង្កើតយន្តការសម្រាប់ការស្តារបរិស្ថានឡើងវិញ និងកំណត់ទំហំនៃសំណងការខូចខាត

នីតិវិធី និងបែបបទនៃបង្កើតយន្តការ ការវាយតម្លៃទំហំខូចខាតបរិស្ថាន ការស្តារបរិស្ថានឡើងវិញ និងការទូរទាត់សងការខូចខាតបរិស្ថាន និងការទូទាត់ការខូចខាតផ្នែកហិរញ្ញវត្ថុដែលកើតចេញពីការខូចខាតបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា១០៤៥**._ ការខូចខាតបរិស្ថាន

ការខូចខាតបរិស្ថាន មានជាអាទិ៍ការខូចខាត ឬការធ្វើឲ្យទ្រុឌទ្រោម ការបំផ្លាញ ការបាត់បង់ ការបង្អាក់ដល់ការប្រើប្រាស់នៃបរិស្ថាន ដែលក្នុងនោះមានធនធានធម្មជាតិ ទំនិញ និងសេវាកម្មធនធានធម្មជាតិ ។

**មាត្រា១០៤៦** ._ ការទទួលខុសត្រូវចំពោះការខូចខាតបរិស្ថាន

រូបវន្តបុគ្គល ឬនីតិបុគ្គលណា ដែលបានឃើញថា បានបង្កការខូចខាតបរិស្ថាន ឬការខូចខាតផ្នែកហិរញ្ញវត្ថុដែលកើតចេញពីការខូចខាតបរិស្ថាន ត្រូវទទួលខុសត្រូវក្នុងការស្តារបរិស្ថានឡើងវិញ និង/ឬត្រូវទូទាត់សំណងខូចខាត និង ការបាត់បង់ទាំងអស់ដែលបានកើតឡើង ។

**មាត្រា១០៤៧** ._ កាតព្វកិច្ចក្នុងការចែកចាយព័ត៌មាន

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ចនានា ជនជាតិដើមភាគតិច សង្គមស៊ីវិល នីតិបុគ្គល និង រូបវន្តបុគ្គលដែលរងផលប៉ះពាល់ទាំងអស់ ត្រូវចែកចាយព័ត៌មានបច្ចេកទេស ចំណេះដឹង ចំណាប់អារម្មណ៍ និងកង្វល់ដែលពាក់ពាក់ព័ន្ធទាំងឡាយ ដើម្បីសម្រួលដល់ការស្តារឡើងវិញពេញលេញ ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពសម្រាប់ការខូចខាតបរិស្ថាន ។

រាល់អ្នកពាក់ព័ន្ធនីមួយៗ ត្រូវចូលរួមក្នុងដំណើរការនៃការសម្រេចចិត្តទៅលើការស្តារឡើងវិញ និងសំណង ព្រមទាំងការអនុវត្តនូវការស្តារបរិស្ថានឡើងវិញ ។

## ជំពូកទី២
## ការទទួលខុសត្រូវ

**មាត្រា១០៤៨** ._ ការទទួលខុសត្រូវបរិស្ថានរបស់រូបវន្តបុគ្គល នីតិបុគ្គល និងមន្ត្រីនៃរដ្ឋាភិបាល

ការទទួលខុសត្រូវសម្រាប់សំណងផ្នែកបរិស្ថាន មិនតម្រូវឲ្យមានបង្ហាញពីធាតុចេតនា និងការដឹងនោះទេ ហើយត្រូវអនុវត្តការទទួលខុសត្រូវដូចខាងក្រោម ៖

ក- រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយដែលមិនបានធ្វើសកម្មភាព ឬការខកខានក្នុងការចាត់វិធានការដែលនាំឲ្យបង្កការខូចខាតដល់បរិស្ថាន ។

ខ- រាល់មន្ត្រីរាជការគ្រប់ស្ថាប័នមានសមត្ថកិច្ចគ្រប់កម្រិតដែលបំពេញការងារលើសពីសិទ្ធិអំណាចរបស់ខ្លួន ឬប្រព្រឹត្តផ្ទុយនឹងក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលនាំឲ្យបង្កការខូចខាតដល់បរិស្ថាន ។

**មាត្រា១០៤៩** ._ ឧបករណ៍គ្រោះថ្នាក់

រាល់ឧបករណ៍គ្រោះថ្នាក់  មានជាអាទិ៍ នាវា យានយន្ត យន្តហោះ មាស៊ីនអារឈើ រោងចក្រអារឈើ រថយន្តដឹកទំនិញ ឬឧបករណ៍ផ្សេងទៀតដែលត្រូវបានប្រើប្រាស់ក្នុងសកម្មភាពខុសច្បាប់

ហើយដែលនាំឲ្យខូចខាតដល់បរិស្ថាន ត្រូវរឹបអូស និងលក់ដើម្បី ប្រើប្រាស់ដល់ការស្តារបរិស្ថានឡើងវិញដែលទទួលរងការខូចខាត ។

**មាត្រា១០៥០** ._ ការទទួលខុសត្រូវនៃនីតិបុគ្គល

នាយក និងបុគ្គលិកនៃសាជីកម្មដែល ត្រូវទទួលខុសត្រូវលើសំណងផ្នែកបរិស្ថានដែលមានលក្ខណៈលក្ខណៈ និងទំហំដូចគ្នា ទៅតាមការទទួលខុសត្រូវរបស់នីតិបុគ្គលនោះ ដូចមានចែងក្នុងមាត្រា១០៥១ នៃក្រមនេះ ។

**មាត្រា១០៥១** ._ ការទទួលខុសត្រូវរបស់បុគ្គលដោយឡែកៗ

ក្នុងករណីមានបុគ្គលលើសពី ១ (មួយ) នាក់ដែលត្រូវទទួលខុសត្រូវក្រោមជំពូកនេះ បុគ្គលនីមួយៗ ត្រូវទទួលខុសត្រូវដោយឡែកៗលើសំណងការខូចខាតបរិស្ថានពេញលេញ ដោយមិនគិតអំពីទំហំជាក់ស្តែងនៃការរួមចំណែក របស់បុគ្គលនីមួយៗក្នុងការធ្វើឲ្យខូចខាតបរិស្ថានទាំងមូលនោះឡើយ ។

## ជំពូកទី៣
## កិច្ចការពារ និងករណីលើកលែងចំពោះកិច្ចការពារ

**មាត្រា១០៥២** ._ កិច្ចការពារ

រូបវន្តបុគ្គល ឬនីតិបុគ្គលមិនត្រូវទទួលខុសត្រូវ ឡើយ ក្នុងករណីដែល ៖

ក- ការខូចខាតបរិស្ថាន ត្រូវបានបង្កឡើងទាំងស្រុងដោយសារតែគ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរ ដែលមិនបានរំពឹងទុកមុន ឬសកម្មភាពនៃសង្គ្រាម ។

ខ- ការខូចខាតបរិស្ថាន ត្រូវបានបង្កឡើងទាំងស្រុងដោយសារតែទង្វើ ឬការខកខានរបស់តតិយជនក្រៅពីបុគ្គលិកនយោជិត ឬភ្នាក់ងាររបស់រូបវន្តបុគ្គល ឬនីតិបុគ្គលនោះ ។

គ- ការខូចខាតបរិស្ថាន ត្រូវបានបង្កឡើងទាំងស្រុងដោយសារតែសកម្មភាពដែលបានអនុញ្ញាត យ៉ាងច្បាស់លាស់ដោយច្បាប់ ។

ឃ- ការខូចខាតបរិស្ថាន ត្រូវបានបង្កឡើងទាំងស្រុងដោយសារតែសកម្មភាពដែលបានអនុញ្ញាត ជាពិសេស និងដែលបានពណ៌នាពីភាពជាក់លាក់ទាក់ទងនឹងប្រភេទ និងទំហំនៃការខូចខាតនៅក្នុងផែន- ការគ្រប់គ្រងបរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងឬ/វិញ្ញាបនបត្រនិងលិខិតអនុម័តទៅលើការ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា១០៥៣** ._ ករណីលើកលែងចំពោះកិច្ចការពារ

កិច្ចការពារដូចមានចែងក្នុងមាត្រា១០៥៥ នៃក្រមនេះ មិនត្រូវបានអនុវត្ត ឡើយ ក្នុងករណី៖

ក- សកម្មភាពដែលបង្កឲ្យមានការខូចខាតនោះ ត្រូវបានអនុវត្តដោយមានការរំលោភបំពានទាំងស្រុង ឬផ្នែកណាមួយនៃក្រមបរិស្ថាន ឬលិខិតបទដ្ឋានគតិយុត្តណាមួយផ្សេងទៀត ។

ខ- សកម្មភាពដែលបង្កឲ្យមានការខូចខាត ត្រូវបានធ្វើឡើងយោងតាមលក្ខខណ្ឌសម្បទាន អាជ្ញាប័ណ្ណ ឬការអនុញ្ញាតជាក់ស្តែងផ្សេងទៀតដែលត្រូវបានផ្តល់ឲ្យ មិនស្របតាមលិខិតបទដ្ឋានគតិយុត្តមានជាអាទិ៍ ការអនុញ្ញាតដែលចេញដោយមន្ត្រីដែលគ្មានសិទ្ធិក្នុងការផ្តល់ការអនុញ្ញាតនោះ ឬការខកខាន ក្នុងការបំពេញទៅតាមលក្ខខណ្ឌច្បាប់តម្រូវ មុនពេលចេញការអនុញ្ញាតជាដើម ។

គ- សកម្មភាពដែលនាំឲ្យមានការខូចខាតបរិស្ថាន ត្រូវបានពិនិត្យឃើញថា មានចំនួនទំហំ ឬប្រភេទខុសៗគ្នា ក្រៅពីការកំណត់ចំនួន និងការអនុញ្ញាតដែលបានកំណត់ជាក់លាក់នៅក្នុងផែនកា គ្រប់គ្រងបរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងឬ/ វិញ្ញាបនបត្រ និងលិខិតអនុម័តទៅលើការ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ឃ- ការខូចខាតដែលបង្កឡើងដោយសារការធ្វេសប្រហែស អំពើទុច្ចរិត ឬសកម្មភាពខុសច្បាប់  ក្នុងការអនុវត្ត ការធ្វើប្រតិបត្តិការ ឬការបំពេញសកម្មភាពដែលត្រូវបានអនុញ្ញាត ។

ង- សកម្មភាពទាំងឡាយដែលផ្ទុយទៅនឹងខចែង និងលក្ខខណ្ឌនៃលិខិតអនុញ្ញាត កិច្ចសន្យា ការអនុញ្ញាត ឬឯកសារពាក់ព័ន្ធទាំងឡាយផ្សេងទៀត ព្រមទាំងការខកខានមិនបានអនុវត្តសកម្មភាពជាក់លាក់នានា ដែលតម្រូវក្នុងលិខិតអនុញ្ញាត ។

## ជំពូកទី៤
## សំណងផ្នែកបរិស្ថាន

**មាត្រា១០៥៤** ._ សំណងផ្នែកបរិស្ថាន

សំណងផ្នែកបរិស្ថានដែលមានចែងក្នុងជំពូកទី២ នៃមាតិកានេះមានដូចតទៅៈ

ក- ថ្លៃពេញលេញក្នុងការស្តារបរិស្ថានឡើងវិញទៅកាន់លក្ខខណ្ឌដើមមុនពេលមានការខូចខាត ។

ខ- ថ្លៃពេញលេញសម្រាប់ការអនុវត្តការស្តារឡើងវិញបន្ថែមទៀតដែលគ្រប់គ្រាន់ដើម្បីធ្វើការទូទាត់នឹងការខូចខាតទាំងមូលដែលមិនបានទូទាត់សងដោយការស្តារឡើងវិញ ក្នុងចំណុច ក. ខាងលើ ។

គ- តម្លៃនៃទិដ្ឋភាពនៃបរិស្ថានដែលរងការខូចខាតដែលមិនអាចស្តារឡើងវិញបាន ក្នុងករណី ដែលការស្តារឡើងវិញត្រូវបានធ្វើឡើង ប៉ុន្តែផ្នែក ឬទិដ្ឋភាពមួយចំនួននៃបរិស្ថានដែលរងការខូចខាត មិនងាយក្នុងការស្តារឡើងវិញបាន ។

ឃ- តម្លៃអេកូឡូស៊ី ឬតម្លៃមនុស្ស ដែលបានបាត់បង់ដោយសារការខូចខាតបរិស្ថាន មិនអាចត្រូវ បានទូទាត់សងពេញលេញដោយសារកត្តាដែលមានក្នុងចំណុច ក. ខ. និងគ. ខាងលើព្រមទាំង បញ្ចូលនូវតម្លៃសេដ្ឋកិច្ចសរុប តម្លៃប្រើប្រាស់ផ្ទាល់ និងប្រយោល តម្លៃដែលមិនប្រើប្រាស់ មានជាអាទិ៍ តម្លៃ អត្ថិភាព ជម្រើស ប្រយោជន៍រួម កេរ្តិ៍ដំណែល ។

ង- ថ្លៃទាំងអស់ដែលត្រូវទទួលរងដោយដើមបណ្តឹងដែលប្តឹងដើម្បីធ្វើការទាមទារសំណងសម្រាប់ការជួសជុលបរិស្ថាន ដែលមានជាអាទិ៍ ថ្លៃ និងការចំណាយ ជាក់ស្តែងរបស់ក្រុមការងាររៀបចំផែនការស្តារឡើងវិញ ថ្លៃនៃការវាយតម្លៃសំណងនៃការស្តារឡើងវិញ ដូចជាថ្លៃបុគ្គលិក ថ្លៃធ្វើដំណើរ ថ្លៃសេវាកម្មតាមកិច្ចសន្យា ទាំងថ្លៃបច្ចេកទេសផ្លូវច្បាប់ ឬថ្លៃផ្សេងទៀត បូករួមទាំងថ្លៃទាំងអស់ដែលទទួលរងដោយភាគីចំពោះក្រុមការងាររៀបចំផែនការស្តារឡើងវិញ និងដំណើរការពិគ្រោះយោបល់ ។

ច- ថ្លៃពិនិត្យតាមដាន និងថ្លៃធានាឲ្យបាននូវភាពជោគជ័យនៃសកម្មភាពស្តារឡើងវិញ ដូចត្រូវ បានកំណត់ពីមុនរួចមកហើយ ។

ឆ- ថ្លៃទូទាត់សងសម្រាប់ការបាត់បង់មុខរបរ និងផ្នែកសេដ្ឋកិច្ចដែលបណ្តាលមកពីការខូចខាតបរិស្ថាន ។

ជ- ថ្លៃទូទាត់សងតាមរយៈការស្តារឡើងវិញ ឬលើការបាត់បង់ស្ថេរភាពនៃការប្រើប្រាស់បរិស្ថាន ។

ឈ- ការបាត់បង់ថ្លៃសុទ្ធនៃសួយសារ ប្រាក់ឈ្នួល កម្រៃនានា ឬការបាត់បង់ភាគហ៊ុននៃប្រាក់ចំណេញសុទ្ធដោយសារការខូចខាតនោះ ។

ញ- ការបាត់បង់ប្រាក់ចំណេញ ឬឱនភាពនៃសមត្ថភាពរកចំណូលដោយសារការខូចខាត ។

ដ- ថ្លៃសុទ្ធនៃការផ្តល់សេវាសាធារណៈដែលមានការកើនឡើង និងបន្ថែម ក្នុងការឆ្លើយតបទៅនឹងការខូចខាតបរិស្ថាន ។

ឋ- ប្រាក់ប្រដាប់ក្តី សោហ៊ុយ និងការចំណាយផ្សេងៗ ដែលកើតឡើងក្នុងដំណើរការនៃបណ្តឹង មានជាអាទិ៍ ប្រាក់បៀវត្សន៍ និងការចំណាយរបស់ដើមបណ្តឹង បុគ្គលិករបស់ពួកគេ សោហ៊ុយនិងការ- ចំណាយផ្សេងៗរបស់សាក្សី ថ្លៃមេធាវី អ្នកជំនាញការ ទីប្រឹក្សា ការសិក្សាផ្នែកបច្ចេកទេស ។

ឌ- ការខាតបង់សុទ្ធនៃប្រាក់ពន្ធ ឬចំណូលផ្សេងទៀតរបស់ស្ថាប័នរដ្ឋ ។

ឍ- ថ្លៃផ្តល់សេវាក្នុងការឃាមល្បាតដែលសមភាពទៅនឹងសេវាកម្មឃាមល្បាតនានាក្នុងអំឡុង ពេលនៃការចាប់ខ្លួន និងការកាត់ទោសទៅលើការរំលោភបំពាន ។

**មាត្រា១០៥៥** ._ លក្ខខណ្ឌតម្រូវក្នុងការស្តារឡើងវិញឲ្យបានលឿន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចចេញលិខិតបទដ្ឋានគតិយុត្តលម្អិតអំពីលក្ខខណ្ឌតម្រូវ និងនីតិវិធីក្នុងការស្តារឡើងវិញឲ្យបានលឿន ដែលត្រូវចែងពីថ្លៃនៃការស្តារឡើងវិញសម្រាប់ប្រភេទ នៃការខូចខាតជាក់លាក់ និងនីតិវិធីនៃការវាយតម្លៃដែលត្រូវបានជំរុញសម្រាប់ការបង្កើតប្រភេទ និងបរិមាណនៃការស្តារឡើងវិញដែលតម្រូវ ដើម្បីទូទាត់សងទៅលើប្រភេទជាក់លាក់នៃការខូចខាតនោះ ។

**មាត្រា១០៥៦**._ ភាគីក្នុងការទាមទារសំណង

ភាគីដែលអាចធ្វើការទាមទារសំណងលើការខូចខាតបរិស្ថាន រួមមានដូចតទៅ៖

ក- ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលរងផលប៉ះពាល់ ដូចមានចែងក្នុងមាត្រា១០៤៧ នៃមាតិកានេះ ត្រូវមានសិទ្ធិស្នើសុំថ្លៃសំណងលើការស្តារឡើងវិញ ដូចមានចែងក្នុងមាត្រា១០៤៧ ចំណុច ក. ខ. គ. ឃ. ង. ច. ជ. ឈ. ដ. ឋ. ឌ. និង ឍ. នៃមាតិកានេះ ។

ខ- អ្នកប្រើប្រាស់ធនធានធម្មជាតិដើម្បីចិញ្ចឹមជីវិតដែលរងការខូចខាត ទាំងសិទ្ធិទៅលើ ឬការគ្រប់គ្រងធនធានធម្មជាតិ ត្រូវមានសិទ្ធិស្នើសុំថ្លៃដូចមានចែងក្នុងមាត្រា១០៤៧ ចំណុច ឃ. ង. ឆ. ជ. ឈ. ញ. និង ឋ. នៃក្រមនេះដោយប្រើប្រាស់នីតិវិធីដូចមានចែងដូចមានចែងក្នុងគន្ថី៩នៃក្រមនេះច្បាប់ពិសេសដោយឡែកផ្សេងទៀង និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

គ- រូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយក៏ដោយ ត្រូវមានសិទ្ធិស្នើសុំថ្លៃ សំណងលើការស្តារឡើងវិញដូចមានចែងក្នុងមាត្រា១០៤៧ ចំណុច ក. ខ. គ. ឃ. ង. ច. និង ឋ. នៃមាតិកានេះលុះ ត្រាតែ៖

១- ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬអ្នកចាត់តាំងដែលមានការអនុញ្ញាត ខកខានក្នុងការបង្កើតក្រុមការងារផែនការស្តារឡើងវិញ ស្របតាមជំពូកទី ៥ នៃមាតិកានេះ ក្នុងរយៈពេល ៦ (ប្រាំមួយ)ខែ បន្ទាប់ពីព្រឹត្តិការណ៍នៃការខូចខាតបរិស្ថានបានកើតឡើង ឬ

២- ក្រុមការងាររៀបចំផែនការស្តារឡើងវិញត្រូវបានបង្កើត ប៉ុន្តែខកខានក្នុងការបំពេញការងារវាយតម្លៃសំណងលើការស្តារឡើងវិញក្នុងរយៈពេល១ (មួយ)ឆ្នាំ បន្ទាប់ពីការបង្កើត ។

៣- រូបវន្តបុគ្គល ឬនីតិបុគ្គលនោះ បានជូនដំណឹងទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានក្នុងគោលបំណង ស្នើសុំថ្លៃ សំណងលើការស្តារឡើងវិញ ។ ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន មិនបានឆ្លើយតបចំពោះសំណើអំពីការស្នើសុំថ្លៃសំណងស្តារបរិស្ថានឡើងវិញ ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃបន្ទាប់ពីបានជូនដំណឹងនេះទេ រូបវន្តបុគ្គល ឬនីតបុគ្គលដែលបានស្នើសុំនេះ អាច

អនុវត្តការងារវាយតម្លៃលើការស្តារបរិស្ថានឡើងវិញ និងអាចស្នើសុំថ្លៃសំណងស្តារបរិស្ថានឡើងវិញ ។

ឃ- ម្ចាស់កម្មសិទ្ធិ ឬម្ចាស់ភតិសន្យានៃអចលនទ្រព្យ ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនត្រូវមានសិទ្ធិស្នើសុំថ្លៃ ដូចមានចែងក្នុងមាត្រា១០៤៧ ចំណុច ច. ឆ. ឈ. ញ. និង ឋ. នៃក្រមនេះ ស្របតាមគន្ថីទី៩នៃក្រមនេះ ច្បាប់ពិសេស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ។

## ជំពូកទី៥
## ក្រុមការងាររៀបចំផែនការស្តារឡើងវិញ និងដំណើរការវាយតម្លៃសំណងការខូចខាត

**មាត្រា១០៥៧** ._ ក្រុមការងាររៀបចំផែនការស្តារឡើងវិញ

ករណីមានបណ្តឹងទាមទារឲ្យមានការជួសជុលដោយការស្តារបរិស្ថានឡើងវិញដូចមានចែងក្នុងមាត្រា១០៤៧ នៃក្រមនេះ ភាគីដែលមានសិទ្ធិធ្វើសកម្មភាពបណ្តឹង ដូចមានចែងក្នុងច្បាប់ពិសេសផ្សេងទៀត និងលិខិតបទដ្ឋានគតិយុត្ត មានសិទ្ធិលើកជាសំណើទៅកាន់ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដើម្បីបង្កើតនូវក្រុមការងារ រៀបចំផែនការស្តារឡើងវិញសម្រាប់គ្រោះថ្នាក់នោះ ។

**មាត្រា១០៥៨** ._ អ្នកចូលរួមដទៃទៀត

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬបុគ្គលដែលបានចាត់តាំង ត្រូវផ្តល់ឱកាសនានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ រូបវន្តបុគ្គល តំណាងអង្គការសង្គមស៊ីវិល ជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន និងបុគ្គលដទៃទៀត ដែលអាចរងការប៉ះពាល់ដល់ប្រយោជន៍ខ្លួន និងដែលមានជំនាញបច្ចេកទេស ក៏ដូចជាចំណេះដឹងសំខាន់ដល់ការវាយតម្លៃសំណងការខូចខាតចូលរួមជាសមាជិកនៃក្រុមការងាររៀបចំផែនការស្តារឡើងវិញ ។

**មាត្រា១០៥៩** ._ ការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មានបរិស្ថាន

ក្រុមការងាររៀបចំផែនការស្តារឡើងវិញ ត្រូវបំពេញការងាររបស់ខ្លួនឲ្យ ស្របតាមបទប្បញ្ញត្តិ ទូទៅ ស្តីពីការចូលរួមជាសារធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាននៃក្រមនេះ ។

**មាត្រា១០៦០** ._ ភារកិច្ច និងសិទ្ធិអំណាច

ភារកិច្ចនិងសិទ្ធិអំណាចរបស់ក្រុមការងាររៀបចំផែនការស្តារឡើងវិញ រួមមាន៖

ក- វាយតម្លៃពីបរិមាណធម្មជាតិ និងវិសាលភាពនៃការខូចខាតដោយប្រើព័ត៌មានដែលមានស្រាប់ ។ ស្របតាមការវាយតម្លៃនេះ ក្រុមការងារ ត្រូវកំណត់ថា ចំណាត់ការដូចខាងក្រោម ៖

១- ធ្វើបណ្តឹងទាមទាសំណងលើការខូចខាតពីបុគ្គលមួយ ឬច្រើន ដែលអាចត្រូវទទួលខុសត្រូវតាមជំពូកទី២នៃមាតិកានេះ ។

២- បំពេញតាមលក្ខខណ្ឌតម្រូវ និងនីតិវិធីនៃការស្តារឡើងវិញ ដូចមានចែងក្នុងមាត្រា១០៤៨ នៃក្រមនេះ ។

៣- ធ្វើការវាយតម្លៃពីសំណងការខូខាតសម្រាប់ធ្វើការស្តារឡើងវិញ ។

៤- អនុវត្តន៍ជម្រើសនៃចំណាត់ការសមទៅតាមស្ថានភាពជាក់លាក់នានានៃគ្រោះថ្នាក់ ឬការខូចខាត ។

ខ-បន្ទាប់ពីបានសម្រេចថាត្រូវរៀបចំធ្វើបណ្តឹងទាមទារឲ្យមានការជួសជុលបរិស្ថាន នោះក្រុមការងារ ចាំបាច់ត្រូវ៖

១- បង្កើតសេចក្តីថ្លែងការអំពីឆន្ទៈក្នុងការរៀបចំបណ្តឹងទាមទារការជួសជុលបរិស្ថានដែលក្នុងនោះត្រូវមានចុះអំពីព័ត៌មានសង្ខេបអំពីហេតុការ និងការខូតខាតនាពេលខាងមុខ ឬដែលបាន រំពឹងទុកជាមុន ។

២- កំណត់អំពីការអនុវត្តនូវសិទ្ធិអំណាចដូចមានចែងក្នុងមាត្រា១០៣០ ទាក់ទងទៅនឹងហេតុការណ៍ ។

៣- ធ្វើការជូនដំណឹងដល់ភាគីដែលទទួលខុសត្រូវ

គ- រៀបចំប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងបណ្តឹងទាមទារការស្តារឡើងវិញនាពេលខាងមុខ ។

ឃ- ពាក់ព័ន្ធទៅនឹងការរៀបបណ្តឹងទាមឲ្យមានការស្តារឡើងវិញ ស្របតាមចរិកលក្ខណៈនៃគ្រោះថ្នាក់ ឬការខូចខាតដល់បរិស្ថាន ក្រុមការងារត្រូវបំពេញតាមដំណាក់កាលដូចខាងក្រោម ដោយ ៖

១- កំណត់ពីអត្តសញ្ញាណ និងបរិមាណនៃការខូចខាត ។

២- កំណត់ពីលក្ខណៈនៃការស្តារឡើងវិញ និងឬដំណោះស្រាយដោយ/សំណងជាប្រាក់ដែលគិតទាំងសំណងការខូចខាតនាពេលខាងមុខផងដែរ ។

៣- បង្កើតការថ្លឹងថ្លែង និងការបង្ហាញពីទំនាក់ទំនងរវាងការខូចខាត និងសំណងបច្ចុប្បន្ន និងអនាគត ។

៤- បង្ហាញពីការស្តារឡើងវិញ និងឬ ជម្រើសនៃសំណងការ/ខូចខាត ប្រាក់ដែលគិតទាំងសំណងការខូចខាតនាពេលខាងមុខ ដែលពេញចិត្ត ។

ង- ប្រើប្រាស់ជំនាញ និងឯកទេសនៃសមាជិកក្នុងក្រុមការងារ និងក្រៅក្រុមការងាររៀបចំផែនការស្តារឡើង វិញ និងជំនួយផ្នែកបច្ចេកទេសទៅតាមតម្រូវការ ក្នុងគ្រប់ដំណោះស្រាយ និងការរៀបចំបណ្តឹងទាមទារ ។

ច- កំណត់ពីភាពសមរម្យនៃភាគីដែលទទួលខុសត្រូវនាពេលខាងមុខ ក្នុងការអនុវត្តការស្តារឡើងវិញដែល បានឯកភាព ។

ឆ- ជូនដំណឹងដល់ភាគីដែលអាចទទួលខុសត្រូវ ឲ្យចូលរួមក្នុងដំណើរការនៃការចរចារ អំពីការស្តារឡើង វិញ ដើម្បីផ្តល់ការទទួលខុសត្រូវតាមរយៈកិច្ចការស្តារឡើងវិញ ឬការបង់សំណងលើការខូចខាត ។

**មាត្រា១០៦១ .**_ នីតិវិធីបន្ថែម

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាចរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីដែលត្រូវបំពេញសម្រាប់ការវាយតម្លៃលើសំណងការខូចខាតសម្រាប់ការស្តារឡើងវិញ និងដែលមានសំណងការខូចខាតទាំងនោះទូទាត់ទៅតាមតំបន់ជាក់ស្តែងសម្រាប់ជាដំណោះស្រាយដល់ការខូចខាត ឬគ្រោះថ្នាក់ដែលសំខាន់ដល់បរិស្ថាន ។

## ជំពូកទី៦
## លក្ខខណ្ឌតម្រូវនៃការទូទាត់ និងការចរចារអំពីការស្តារឡើងវិញ

**មាត្រា១០៦២ .**_ ដំណើរការនៃកិច្ចចរចារអំពីការស្តារឡើងវិញ

ក្រុមការងាររៀបចំផែនការស្តារឡើងវិញ និងភាគីដែលអាចទទួលខុសត្រូវ ត្រូវចូលរួមក្នុងដំណើរការនៃកិច្ចចរចារអំពីការស្តារឡើងវិញ ដូចខាងក្រោម ៖

ក- ការជួបជាប្រចាំ ដើម្បីឈានដល់ការព្រមព្រៀងស្តីពីការស្តារឡើងវិញ និងការជួស/ជុល ។

ខ- ប្រើប្រាស់នីតិវិធីនៃការដោះស្រាយវិវាទដូចមានចែងក្នុងក្រមនេះ ។

គ- ការដោះដូរព័ត៌មានបច្ចេកទេស និងការប្រព្រឹត្តដោយបំណងសុចរិត ក្នុងការដោះស្រាយភាពផ្សេងពីគ្នា ស្របតាមគោលការណ៍ដែលបានកំណត់ក្នុងគន្ថីទី១ មាតិកាទី១ នៃក្រមនេះ ។

ឃ- ក្នុងករណីដែលភាគីទាំងឡាយបានឈានដល់ការព្រមព្រៀងដោះស្រាយវិវាទ ហើយ ប៉ុន្តែពុំទាន់មានការឯកភាព ទៅលើការជួសជុលដោយការស្តារឡើងវិញទាំងស្រុងនៅឡើយ ភាគីនៃផ្នែកដែលពុំទាន់បានដោះស្រាយ អស់នោះត្រូវដោះស្រាយចំពោះការទាមទារទាំងនោះ ដើម្បីទុកពេលគ្រប់គ្រាន់សម្រាប់ការស្តារឡើងវិញ និង/ឬ ការជួសជុលដែលត្រូវកើតឡើង ។

ង- ក្នុងករណីដែល ភាគីដែលត្រូវទទួលខុសត្រូវបានបដិសេធមិនព្រមចូលរួមដំណើរការដូចមានចែងក្នុងមាត្រា១០៥៣ ឬមិនបានចូលរួមដោយមានឆន្ទៈសុចរិតនៅក្នុងដំណើរការនៃកិច្ចពិគ្រោះយោបល់អំពីការស្តារឡើងវិញទេ ឬដំណើរការនីតិវិធីដែលបានកំណត់ដើម្បីឈានទៅរកដំណោះស្រាយលើការទទួលខុសត្រូវរបស់ខ្លួនទេ នោះភាគីដើមបណ្តឹងស្របតាម

មាត្រា១០៤៩ នៃមាតិកានេះត្រូវបន្តនីតិវិធីដោយកំណត់យកការជួសជុលទាន់ពេលវេលា និង/ ឬ ធ្វើការវាយតម្លៃលើការជួសជុលដោយការស្តារឡើងវិញតាមការចាំបាច់ ។

**មាត្រា១០៦៣**._ លក្ខខណ្ឌតម្រូវនៃកិច្ចព្រមព្រៀងសះជា

រាល់កិច្ចព្រមព្រៀងសះជា ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវស្របតាមច្បាប់ដូចខាងក្រោម៖

ក- កិច្ចព្រមព្រៀងសះជាដែលបានស្នើ ត្រូវជាព័ត៌មានដែលបើកចំហដើម្បីឲ្យសាធារណជនធ្វើការពិនិត្យ និងផ្តល់យោបល់សម្រាប់រយៈពេលយ៉ាងតិច៦០ (ហុកសិប)ថ្ងៃ ស្របតាមបទប្បញ្ញត្តិនៃការចូលរួមជាសាធារណៈនៃក្រមនេះ ។

ខ- បុគ្គលដែលបានចូលរួមក្នុងកិច្ចប្រជុំជាសាធារណៈ ដែលបានផ្តល់ធាតុចូល ឬមតិយោបល់ទៅកាន់ ក្រុមការងាររៀបចំផែនការស្តារឡើងវិញ ត្រូវទទួលបាននូវច្បាប់ចម្លងស្តីពីដំណោះស្រាយតាមដែលបានស្នើ ។

គ- ការផ្តល់ដំណឹងអំពីការព្រមព្រៀងដែលបានស្នើ ត្រូវបើកឲ្យសាធារណជនដឹងនៅគ្រប់ទីកន្លែងដែលរង ការប៉ះពាល់ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពី សិទ្ធិទទួលបានព័ត៌មាន នៃក្រមនេះ ។

ឃ- ក្នុងគោលបំណងរក្សានូវសិទ្ធិរបស់ដើមបណ្តឹង កិច្ចព្រមព្រៀងសះជាត្រូវដាក់បញ្ចូលនូវលក្ខខណ្ឌនៃ សិទ្ធិ មានជាអាទិ៍ សិទ្ធិក្នុងការធ្វើបណ្តឹងជំទាស់ ទៅនឹងចុងចម្លើយ ក្នុងគោលបំណង ទទួលបាននូវសំណងដោយការស្តារឡើងវិញបន្ថែម ក្នុងករណីឃើញមានលក្ខខណ្ឌថ្មី ឬមានព័ត៌មាន ដែលបញ្ជាក់ថា ការខូចខាតខុស ឬគ្រោះថ្នាក់ខុសទៅនឹងអ្វីដែលបានដឹងក្នុងពេលកំពុងចុះកិច្ចព្រមព្រៀងសះជា ។

ង- កិច្ចព្រមព្រៀងសះជា ត្រូវរាប់បញ្ចូលស្តង់ដារប្រតិបត្តិការការងារ និងការត្រួតពិនិត្យដែលត្រឹមត្រូវតាម បច្ចេកវិជ្ជា និងអេកូឡូស៊ី ក្នុងគ្រប់លក្ខខណ្ឌព្រមព្រៀងដែលភាគីទទួលខុសត្រូវបានព្រមបំពេញ សម្រាប់ ការស្តារឡើងវិញ។ ក្នុងករណីដែលអវត្តមាននៃរបកគំហើញជាក់លាក់ដែលបង្កើតឲ្យមាននូវលក្ខខណ្ឌសមរម្យ សម្រាប់ស្តង់ដារទាបជាង នោះស្តង់ដារទាំងនេះតម្រូវឲ្យប្រើប្រាស់ប្រភេទរុក្ខជាតិដើម ដែលសមស្របសម្រាប់ការដាំឡើងវិញ នូវសារពើរុក្ខជាតិ ក៏ដូចជាការអនុវត្តនូវការអង្កេតតាមដាន សម្រាប់រយៈពេលមិនតិចជាង៥ (ប្រាំ) ឆ្នាំ និងដាក់បញ្ចូលកាតព្វកិច្ចរបស់ភាគីទទួលខុសត្រូវ ក្នុងការបន្តទទួលរ៉ាប់រងចំពោះសកម្មភាពស្តារឡើងវិញ រហូតដល់ពេលស្តង់ដារនៃការអនុវត្តនោះត្រូវបានបំពេញ។ ការព្រមព្រៀង ក៏ត្រូវមានចែង អំពីលក្ខខណ្ឌតម្រូវសំរាប់ប្រតិបត្តិការ និងការធ្វើអធិការកិច្ចបន្ថែម ដែលបានកំណត់ ក្នុង ដំណើរការនៃការវាយតម្លៃអំពីសំណងដោយការស្តារឡើងវិញ។ រាល់ទិន្នន័យនៃអធិការកិច្ចដែលផលិតបាន នោះត្រូវបើកឲ្យសាធារណជនដឹងឮ។

ច- កិច្ចព្រមព្រៀងសះជា ត្រូវមានរៀបរាប់នៅក្នុងលក្ខខណ្ឌព្រមព្រៀងអំពីលក្ខខណ្ឌតម្រូវឲ្យភាគីដែលត្រូវ ទទួលខុសត្រូវផ្តល់ជាមូលនិធិ ឬរៀបចំឲ្យមានការយល់ដឹង និងការអប់រំ

ផ្នែកបរិស្ថាន នៅក្នុងតំបន់ដែលរង ការប៉ះពាល់ ស្របតាមព័ត៌មានអំពីការខូចខាតដែលបានរកឃើញ ។

ឆ- កិច្ចព្រមព្រៀងសះជាក៏ត្រូវដាក់បញ្ចូលផងដែរនូវលក្ខខណ្ឌបន្ថែម ដែលចាំបាច់តម្រូវឲ្យមានការស្តា ឡើងវិញទាំងស្រុងផងដែរ ។

## ជំពូកទី៧
## សិទ្ធិអំណាចនៃការចេញបទបញ្ជាផ្នែករដ្ឋបាល

**មាត្រា១០៦៤ .**_ ការកំណត់ហានិភ័យនៃគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន មានភារកិច្ចចេញបទបញ្ជាឲ្យភាគីដែលអាចទទួលខុសត្រូវ ផ្តល់ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុជាបន្ទាន់សម្រាប់ការងាររបស់ក្រុមការងារ រៀបចំផែនការស្តារឡើងវិញ និងការបង្កើតឲ្យមាននូវការវាយតម្លៃអំពីការជួសជុលដោយការស្តារឡើងវិញ ក្នុងករណីដែលការខូចខាតបរិស្ថានស្ថិតនៅក្នុងកម្រិតគ្រោះថ្នាក់ ។

**មាត្រា១០៦៥ .**_ ការកំណត់ពីតម្រូវការនៃសកម្មភាពជាបន្ទាន់

ក្រសួង ស្ថាប័នទទួលបន្ទុក វិស័យបរិស្ថានមានភារកិច្ចចេញ បញ្ជាឲ្យភាគីដែលទទួលខុសត្រូវប្រតិបត្តិលើវិធានការស្តារឡើងវិញជាកិច្ចសង្គ្រោះបន្ទាន់ ក្រោមការដឹកនាំរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន បន្ទាប់ពីរកឃើញថា តម្រូវឲ្យមានការទប់ស្កាត់ជាបន្ទាន់លើការខូចខាតបរិស្ថាន ឬដើម្បីជាសវាងពីការបាត់បង់ឱកាសសំខាន់ដល់ការស្តារឡើងវិញ ។

## ជំពូកទី៨
## សិទ្ធិអំណាចក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្នុងការប្រមូលថវិកាបង់ថ្លៃនៃការស្តារបរិស្ថានឡើងវិញ

**មាត្រា១០៦៦ .**_ ភាពចាំបាច់នៃការស្តារឡើងវិញ និងបង្គ្រប់ថ្លៃ និងចំណាយនានា

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន មានសិទ្ធិអនុវត្តន៍សកម្មភាពបណ្តឹងទាមទារសំណង និងថ្លៃចំណាយនានានសម្រាប់ការស្តារការខូចខាតដល់បរិស្ថានឡើងវិញ ពីភាគីដែលបង្កឲ្យខូចខាតបរិស្ថាន ។

**មាត្រា១០៦៧ .**_ ការបង់ថ្លៃ ឬការបង់សងវិញនូវថ្លៃ និងចំណាយដែលបានកើតឡើង

ថវិកាប្រមូលបានសម្រាប់ការបំពេញតួនាទីដូចមានចែងក្នុងមាតិកានេះ ដែលជាការចំណាយ និងការបង់សង វិញនូវថ្លៃ និងការចំណាយសម្រាប់ការវាយតម្លៃការជួសជុលបរិស្ថានដោយការស្តារ

ឡើងវិញ និងសកម្មភាពរបស់ ក្រុមការងាររៀបចំផែនការស្តារបរិស្ថាន ត្រូវបង់ជូនដោយផ្ទាល់ទៅកាន់ភាគីដែលបានធ្វើការចំណាយ ។

## មាតិកាទី៤
## ទោសប្បញ្ញត្តិ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១០៦៨ ._** ប្រភេទនៃទណ្ឌកម្ម

ប្រភេទនៃទណ្ឌកម្មដែលកំណត់ នៅក្នុងក្រមនេះ មានជាអាទិ៍ ការព្រមានជាលាយលក្ខណ៍អក្សរ ការលុបចោល ការផ្អាកការឯកភាព ឬលិខិតអនុញ្ញាត ការពិន័យអន្តរការណ៍ សំណងការខូចខាត និងទោសព្រហ្មទណ្ឌ។

**មាត្រា១០៦៩ ._** ការអនុវត្តទណ្ឌកម្ម

ការព្រមានជាលាយលក្ខណ៍អក្សរ ការផ្អាក ឬការលុបចោលនៃវិញ្ញាបនបត្រចុះបញ្ជី និងលិខិតអនុញ្ញាតពាក់ព័ន្ធដទៃទៀតគឺស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធដូចមានចែងក្នុងក្រមនេះ ។

ការពង្រឹងការអនុវត្តការពិន័យអន្តរការណ៍គឺស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដូចមានចែងក្នុងក្រមនេះ។

សំណងការខូចខាតចំពោះបរិស្ថាន និងធនធានធម្មជាតិក្រោមបទប្បញ្ញត្តិនៃក្រមនេះ ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ឬក្រសួងពាក់ព័ន្ធដទៃទៀត ដូចមានចែងក្នុងមាតិកាទី ៣ ស្តីពីការស្តារឡើងវិញ និងសំណងសម្រាប់កាខូចខាតបរិស្ថាន នៃក្រមនេះ។

**មាត្រា១០៧០ ._** ការពិន័យអន្តរការណ៍

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវមានសិទ្ធិក្នុងការអនុវត្តការពិន័យអន្តរការណ៍សម្រាប់បទល្មើសមួយក្រោមក្រមនេះ។

ការពិន័យអន្តរការណ៍ត្រូវបានអនុវត្តក្នុងករណីដែលជនល្មើសសារភាពថាមានកំហុស និងយល់ព្រមបង់ថ្លៃពិន័យអន្តរការណ៍ស្របតាមបទប្បញ្ញត្តិក្រោមក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។ ការបង់ថ្លៃពិន័យអន្តរការណ៍នាំឲ្យរលត់បណ្តឹងអាជ្ញា ។

ក្នុងករណីដែលជនល្មើសបដិសេធន៍មិនបង់ថ្លៃពិន័យអន្តរការណ៍ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាចដាក់ ពាក្យបណ្តឹង ទៅតុលាការ ដើម្បីទាមទារប្រាក់ពិន័យអន្តរការណ៍នោះបាន។

នីតិវិធី និងបែបបទស្តីពីពិន័យ អន្តរការណ៍ត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

**មាត្រា១០៧១ ._** ប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍

ប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ ពិន័យដោយតុលាកា ឬវត្ថុផ្សេងៗដែលតុលាកាបានសម្រេចឲ្យរឹបអូសជាសម្បត្តិរដ្ឋ ត្រូវបង់ចូលទៅក្នុងថវិការជាតិ។ ប្រាក់ចំណូលបែបនេះត្រូវបានប្រើផងដែរដើម្បីផ្តល់រង្វាន់ជូនមន្ត្រី និងប្រជាពលរដ្ឋដែលចូលរួមក្នុងសកម្មភាពពង្រឹងការអនុវត្តច្បាប់។

នីតិវិធីនៃការកំណត់ប្រាក់រង្វាន់ និងប្រាក់ពិន័យដែលត្រូវបង់ចូលថវិការជាតិ និងត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា១០៧២ ._** ការរំលោភបំពានទៅលើកាតព្វកិច្ចបញ្ចៀសការខូចខាតបរិស្ថាន

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលរំលោភបំពានបទប្បញ្ញត្តិនៃក្រមនេះ  បង្កឲ្យមានការខូចខាតបរិស្ថាន ឬប្រព្រឹត្តបទល្មើសបរិស្ថាន និងធនធានធម្មជាតិត្រូវផ្តន្ទាទោស  ថ្នាក់ទី៣ ឬទី៤  អាស្រ័យតាមអំពើប្រព្រឹត្ត និងកម្រិតព្យសនៈកម្មដែលបង្កការខូចខាតដល់បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១០៧៣ ._** ការអនុវត្តសកម្មភាពបណ្តឹងរដ្ឋប្បវេណី

ក្នុងករណីមានបណ្តឹង ព្រហ្មទណ្ឌស្របតាម ក្រមនេះ និងច្បាប់ពិសេសផ្សេងទៀត កំពុងដំណើរការនៅតុលាការមានសមត្ថកិច្ច  សកម្មភាពបណ្តឹងរដ្ឋប្បវេណីក្នុងការទាមទារសំណង ឬការស្តារឡើងវិញសម្រាប់ការខូចខាតបរិស្ថានប្រឆាំងទៅនឹងភាគីដែលបង្កការខូចខាតនៅតុលាការរដ្ឋប្បវេណីដោយឡែក នៅតែដំណើរដោះស្រាយទៅតាមនីតិវិធីរដ្ឋប្បវេណី ឬទៅតាមនីតិវិធីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដែលកំណត់ក្នុងក្រមនេះ ។

**មាត្រា១០៧៤ ._** ការស្តារបរិស្ថានឡើងវិញ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថានមានសិទ្ធិក្នុងការធ្វើសកម្មភាពបណ្តឹងទៅកាន់តុលាការ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីទាមទារសំណងការខូចខាត លើការស្តារបរិស្ថានឡើងវិញ ឬទ្រព្យសម្បត្តិសាធារណៈ ស្របតាមក្រមនេះ ។

**មាត្រា១០៧៥ ._** មន្ត្រីសាធារណៈដែលខកខានមិនបានបំពេញភារកិច្ច

មន្ត្រីសាធារណៈរូបណាដែលបំពានឬខកខានមិនបានបំពេញភារកិច្ចស្របតាមបទប្បញ្ញត្តិនៃក្រមនេះត្រូវទទួល ទណ្ឌកម្មរដ្ឋបាល និង/ឬការ ចោទប្រកាន់ពាក់ព័ន្ធផ្សេងទៀត ។

ជនសមគំនិត ឬផ្តើមគំនិតត្រូវទទួលទណ្ឌកម្មដូចគ្នានឹងជនល្មើសដែរ ។

**មាត្រា១០៧៦ ._** ទ្រព្យសម្បត្តិដែលត្រូវបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសដោយចេតនា

មន្ត្រីរាជការសាធារណៈ ឬមន្ត្រីកងកម្លាំងប្រដាប់អាវុធដែលទទួលខុសត្រូវលើការគ្រប់គ្រងទ្រព្យសម្បត្តិ មានជាអាទិ៍ ដី យានយន្ត និងទ្រព្យស្បត្តិផ្សេងទៀត ដែលបានប្រើប្រាស់ទ្រព្យសម្បត្តិទាំងនេះដើម្បីទទួលបានប្រាក់កម្រៃជើងពីបទល្មើសប្រព្រឹត្តបទល្មើសដោយចេតនា ត្រូវចាត់ទុកថាជាអ្នកញុះញង់ក្នុងការប្រព្រឹត្តបទល្មើសដោយចេតនា លើកលែងតែបុគ្គលនោះអាចបង្ហាញភស្តុតាងថាមិនបានគ្រប់គ្រងលើចារីប្រព្រឹត្តបទល្មើសដោយចេតនា និងលើទ្រព្យសម្បត្តិដែលប្រើប្រាស់ក្នុងបទល្មើសនោះទេ។

បុគ្គលដែលធ្វេសប្រហែស និងបានបោះបង់ចោលភារកិច្ច មិនត្រូវរួចផុតពីការទទួលទណ្ឌកម្មរដ្ឋបាលនោះឡើយ ។

**មាត្រា១០៧៧ ._** បទល្មើសដែលមិនតម្រូវឲ្យមានចេតនាប្រព្រឹត្ត

បទល្មើសព្រហ្មទណ្ឌស្របតាមក្រមនេះអាចកើតចេញ មកពីការខ្វះការប្រុងប្រយ័ត្ន ការធ្វេសប្រហែស ការព្រងើយកន្តើយ ឬការខកខានមិនបានបំពេញកាតព្វកិច្ច ដោយមិនសំដៅថា មានចេតនា ឬគ្មានចេតនាក្នុងការប្រព្រឹត្តបទល្មើសដោយចេតនាឡើយ។

សម្រាប់បទល្មើសប្រឆាំងនឹងបរិស្ថាន តម្រូវឲ្យមានភស្តុតាងនៃចេតនា លើកលែងតែមានចែងផ្សេងនៅក្នុងបទប្បញ្ញត្តិនៃ ក្រមនេះ។

**មាត្រា១០៧៨ ._** ការទទួលខុសត្រូវរបស់នីតិបុគ្គល

នីតិបុគ្គលត្រូវមានការទទួលខុសត្រូវចំពោះបទល្មើស ប្រឆាំងនឹងបរិស្ថាន និងធនធានធម្មជាតិដែលប្រព្រឹត្តឡើងដោយ ភ្នាក់ងារ ឬតំណាងរបស់នីតិបុគ្គល ក្នុងនាមផលប្រយោជន៍របស់នីតិបុគ្គល ។ ការទទួលខុសត្រូវរបស់នីតិបុគ្គល ត្រូវធ្វើឡើងតាមរយៈតំណាង ឬភ្នាក់ងាររបស់ខ្លួន ។

**មាត្រា១០៧៩ ._** ទោសបន្ថែមសម្រាប់បទល្មើសប្រឆាំងបរិស្ថានដោយរូបវន្តបុគ្គល

ប្រភេទទោសបន្ថែមដែលកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ត្រូវយកមកអនុវត្តផងដែរចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលប្រព្រឹត្តដោយរូបវន្តបុគ្គលដូចមានចែងក្នុងក្រមនេះ និងច្បាប់ពិសេសផ្សេងទៀត ។

**មាត្រា១០៨០ ._** ទោសបន្ថែមសម្រាប់បទល្មើសប្រឆាំងបរិស្ថានដោយនីតិបុគ្គល

ប្រភេទទោសបន្ថែម ត្រូវយកមកអនុវត្តចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលប្រព្រឹត្តដោយនីតិបុគ្គល មានដូចខាងក្រោម៖

ទោសបន្ថែមដូចខាងក្រោមត្រូវធ្វើឡើងសម្រាប់គ្រប់បទល្មើសប្រឆាំងនឹងបរិស្ថាន៖

ក- ការរំលាយនីតិបុគ្គល

ខ- ការលុបចោលលិខិតអនុញ្ញាត ឬសិទ្ធិអនុញ្ញាត

គ- ការផ្អាកលិខិតអនុញ្ញាត ឬសិទ្ធិអនុញ្ញាត

ឃ- ការលុបចោលវិញ្ញាបនបត្រឯកភាពការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ង- ការផ្អាកសម្បទានដីសេដ្ឋកិច្ចណាមួយ ឬសម្បទានដទៃទៀត

ច- ការលុបចោលសម្បទានដីសេដ្ឋកិច្ចណាមួយ ឬសម្បទានដទៃទៀត

ឆ- ការរឹបអូសបរិក្ខាពាក់ព័ន្ធនឹងបទល្មើស

ជ- ការរឹបអូសគ្រប់ផលចំណេញ ឬផលចំណេញនីមួយៗដែលកើតចេញពីបទល្មើស

ឈ- ការផ្សព្វផ្សាយបទល្មើស និងទោសទណ្ឌ។

ក្រៅពីទោសបន្ថែមដែលកំណត់ខាងលើនេះ ទោសបន្ថែមដែលមានចែងក្នុងក្រមព្រហ្មទណ្ឌជាធរមាន ត្រូវយកមកអនុវត្តផងដែរចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលប្រព្រឹត្តដោយនីតិបុគ្គលផងដែរ ។

**មាត្រា១០៨១** ._ ថ្នាក់នៃបទល្មើស

បទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលកំណត់ក្នុងក្រមនេះ ត្រូវ បែងចែក ជា៥ថ្នាក់ដូចខាងក្រោម៖

**បទល្មើសថ្នាក់ទី១** ត្រូវ ផ្តន្ទាទោសដាក់ពន្ធនាគារពី ពី១០ (ដប់)ឆ្នាំ ទៅ ៣០ (សាបសិប) ឆ្នាំ និងពិន័យជាប្រាក់ពី៤០០.០០០.០០០ (បួនរយលាន)រៀល ទៅ ៨០០.០០០.០០០ (ប្រាំបីរយលាន) ។

**បទល្មើសថ្នាក់ទី២** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី០៥ (ប្រាំ) ឆ្នាំ ដល់១០ (ដប់) ឆ្នាំ និង ត្រូវពិន័យជាប្រាក់ពី២០០.០០០.០០០ (បួនរយលាន)រៀល ទៅ ៤០០.០០០.០០០ (ប្រាំបីរយលាន)

**បទល្មើសថ្នាក់ទី៣** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ)ឆ្នាំ ទៅ ០៥ (ប្រាំ) ឆ្នាំ និង ពិន័យជាពិន័យជាប្រាក់ពី២០.០០០.០០០ (ម្ភៃ លាន)រៀល ដល់ ២០០.០០០.០០០ (ពីររយលាន)

**បទល្មើសថ្នាក់ទី៤** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៧ (ប្រាំពីរ)ថ្ងៃ ទៅ០១ (មួយ) ឆ្នាំ និង/ឬពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀល ដល់ ២០.០០០.០០០ (ម្ភៃលាន)

**បទល្មើសថ្នាក់ទី៥** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ) ថ្ងៃ ទៅ ០៦ (ប្រាំមួយ)ថ្ងៃ និង/ឬពិន័យជាប្រាក់ពី ២០.០០០ (ម្ភៃពាន់)រៀល ដល់ ២០.០០០.០០០ (ម្ភៃលាន លាន) ។

**មាត្រា១០៨២** ._ ការចាត់ចែងប្រាក់សំណង

ប្រាក់សំណងដែលបានមកពីការធ្វើសកម្មភាពបណ្តឹងផ្នែករដ្ឋប្បវេណី ត្រូវប្រើសម្រាប់ការស្តារឡើងវិញ និងការស្តារនីតិសម្បទានៃការខូចខាតដែលបង្កឡើងចំពោះបរិស្ថាននិងការស្តារឡើងវិញនៃជីវភាពរស់នៅរបស់សហគមន៍ណាមួយដែលរងការប៉ះពាល់ជាអវិជ្ជមាន ។

**មាត្រា១០៨៣** ._ លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រង និងការបែងចែកការខូចខាត

ក្រសួងទទួលបន្ទុកវិស័យបរិស្ថានត្រូវបង្កើត លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រង និងការចាត់ចែងលើប្រាក់សំណងការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១០៨៤** ._ អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណី

សិទ្ធិទាមទារសំណងការស្តារបរិស្ថានឡើងវិញ និងសំណងការខូចខាតផ្សេងៗ ត្រូវគិតអាជ្ញាយុកាលដូចខាងក្រោម៖

ក- ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដែលបានដឹងពីព្រឹត្តិការណ៍ដែលបង្កឲ្យ មានការខូចខាតបរិស្ថាន ឬពីថ្ងៃទទួលបានព័ត៌មានពីការបង្កឲ្យមានការជួសជុលបរិស្ថាន ឬ

ខ- ១០(ដប់)គិតចាប់ពីថ្ងៃដែលសកម្មភាព ឬហេតុការណ៍នៃការខូចខាតបិរស្ថានបានកើតឡើង ។

**មាត្រា១០៨៥** ._ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា

អជ្ញាយុកាលនៃបណ្តឹងអាជ្ញាពាក់ព័ន្ធនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិត្រូវអនុលោមតាម ក្រមព្រហ្មទណ្ឌដែលមានជាធរមាន។

បទល្មើសបរិស្ថាន និងធនធានធម្មជាតិជាប្រភេទបទល្មើសនិរន្តដែល អាជ្ញាយុកាល ត្រូវគិតចាប់ពីថ្ងៃរកឃើញបទល្មើស ។

## ជំពូកទី២
## បទល្មើសពាក់ព័ន្ធនឹងការចូលរួមជាសាធារណៈ

**មាត្រា១០៨៦** ._ ការរារាំងសិទ្ធិក្នុងការចូលរួមជាសាធារណៈ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៥ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលរារាំងសិទ្ធិក្នុងការចូលរួមជាសធារណៈដូចមានចែងក្នុងមាត្រា២១នៃក្រមនេះ ។

ប៉ុន្តែក្នុងករណីដែលអំពើរាំងនោះធ្វើឡើងដោយមន្ត្រីរាជការសាធារណៈ ឬមន្ត្រីរាជការមានសមត្ថកិច្ចដោយរំលោភអំណាច ឬប្រើប្រាស់សិទ្ធិដោយបំពាន ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ។

**មាត្រា១០៨៧** ._ អំពើរាំង ឬគំរាមកំហែងចំពោះការចូលរួមជាសាធារណៈ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ រាល់អំពើគំរាមកំហែង ឬសងសឹកតាមគ្រប់មធ្យោបាយនានារបស់រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលរារាំង ឬគំរាមកំហែង ចំពោះសកម្មភាពនៃការចូលរួមជាសាធារណៈដូចមានចែងក្នុងមាត្រា២២នៃក្រមនេះ ។ ប៉ុន្តែក្នុងករណីដែលអំពើរាំង ឬគំរាមកំហែងនោះ ប៉ះពាល់ដល់បូរណភាពរូបរាងកាយធ្ងន់ធ្ងរ ឬទ្រព្យសម្បត្តិត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី១ ប្រសិនបើអំពើប្រព្រឹត្តដូចមានចែងក្នុងកថាខណ្ឌខាងលើនេះធ្វើឲ្យបាត់បង់អាយុជីវិត ។

**មាត្រា១០៨៨** ._ ការបំពានចំពោះការចូលរួមជាសាធារណៈចំពោះជនជាតិដើមភាគតិច

ត្រូវផ្តន្ទាទោសពិន័យរដ្ឋបាល ជាការលុបចោល ឬ ការព្យួរនូវការចុះបញ្ជីពាណិជ្ជ ការព្យួរ ឬការលុបចោលនូវកិច្ចព្រមព្រៀងសម្បទាន ការលុបចោលនូវលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណផ្សេងៗទៀតចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនអនុវត្ត ឬមិនបំពេញកាតព្វកិច្ចដូចមានចែងក្នុងមាត្រា២៦ និងមាត្រា២៧ ។

**មាត្រា១០៨៩** ._ ការបង្ខិតបង្ខំចំពោះការតាំងទីលំនៅដោយបង្ខិតបង្ខំ

ត្រូវផ្តន្ទាទោសពិន័យរដ្ឋបាល ជាការលុបចោល ឬការព្យួរនូវការចុះបញ្ជីពាណិជ្ជកម្ម ការព្យួរ ឬការលុបចោលនូវកិច្ចព្រមព្រៀងសម្បទាន ការលុបចោលនូវលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណផ្សេងៗទៀតចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនអនុវត្ត ឬមិនបំពេញកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៣០ ។

ក្នុងករណីដែលអំពើបង្ខិតបង្ខំ ឬបណ្តេញចេញនោះ ធ្វើឡើងដោយហិង្សាដែលបង្កឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់បូរណភាពរូបរាងកាយ ឬទ្រព្យសម្បត្តិ ត្រូវផ្តន្ទាទោស ចំពោះបទល្មើសថ្នាក់ទី៣ ។ ប៉ុន្តែក្នុងករណីដែលអំពើបង្ខិតបង្ខំ ឬបណ្តេញចេញនោះធ្វើឲ្យបាត់បង់ អាយុជីវិត ឬពិការអចិន្ត្រៃយ៍ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី២ ។

**មាត្រា១០៩០** ._ កាតព្វកិច្ចក្នុងការបង្ហាញព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ

ត្រូវផ្តន្ទាទោសជាពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមិនអនុវត្តកាតព្វកិច្ចដូចមានចែងមាត្រា៣២នៃក្រមនេះ និង/ឬ ច្បាប់ និង/ឬ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៀតដែលចែងអំពីសិទ្ធិទទួលបានព័ត៌មាន ។ ក្នុងករណីដែល រូបវន្តបុគ្គល ឬនីតិបុគ្គលនៅតែបន្តប្រព្រឹត្តបទល្មើស ត្រូវពិន័យជាប្រចាំថ្ងៃមួយថ្ងៃ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា១០៩១** ._ កាតព្វកិច្ចផ្តល់ព័ត៌មានរបស់ម្ចាស់គម្រោង

ត្រូវផ្តន្ទាទោសជាពិន័យជាប្រាក់ក្នុងថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានផ្តល់ព័ត៌មានដោយម្ចាស់គម្រោងដូចមានចែងក្នុងមាត្រា៤០ ។ ក្នុងករណីដែលម្ចាស់គម្រោងនៅតែបន្តប្រព្រឹត្តបទល្មើស ត្រូវពិន័យជាប្រចាំថ្ងៃ មួយថ្ងៃ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា១០៩២** ._ បញ្ជីបរិស្ថានរដ្ឋ

ត្រូវផ្តន្ទាទោសជាពិន័យជាប្រាក់ក្នុងថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានផ្តល់បញ្ជីព័ត៌មាន រដ្ឋឲ្យសារធារណជនអាចស្វែងរកដូចមានចែងក្នុងមាត្រា៤២ ។

**មាត្រា១០៩៣** ._ បញ្ជីនៃលិខិតអនុញ្ញាត និងការឯកភាព

ត្រូវផ្តន្ទាទោសជាពិន័យជាប្រាក់ក្នុងថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានផ្តល់ឲ្យសារធារណជនអាចស្វែងរកនូវបញ្ជីនៃលិខិតអនុញ្ញាត និងការឯកភាព ដូចមានចែងក្នុងមាត្រា៤៦ ។

**មាត្រា១០៩៤** ._ បញ្ជីសវនកម្មបរិស្ថាន

ត្រូវផ្តន្ទាទោសជាពិន័យជាប្រាក់ក្នុងថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានផ្តល់ឲ្យសារធារណជនអាចស្វែងរកនូវបញ្ជីសវនកម្មបរិស្ថាន ដូចមានចែងក្នុងមាត្រា៤៩ ។

## ជំពូកទី៣
## បទល្មើសពាក់ព័ន្ធនឹងការវាយតម្លៃហានិភ័យ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា១០៩៥** ._ ការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ចំពោះអំពើប្រព្រឹត្តរបស់ទីប្រឹក្សារៀបចំរបាយការណ៍ហានិភ័យបរិស្ថាន ឬបុគ្គលណាដែលមានចេតនាឃុបឃិត ឬក្លែងបន្លំ ឬធ្វើការរៀបចំរបាយការណ៍មិនពិតដូចមានចែងក្នុងមាត្រា៧២ ។

**មាត្រា១០៩៦** ._ របាការណ៍វាយតម្លៃហានិភ័យ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានដាក់របាយការណ៍វាយតម្លៃហានិភ័យ ឲ្យសាធារណជនអាចស្វែងរកបានដូចមានចែងក្នុងមាត្រា៧៣ ។

**មាត្រា១០៩៧** ._ ការចូលរួមពីសំណាក់ស្ត្រី និងជនងាយរងគ្រោះ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនបានផ្តល់ឱកាសដល់ស្ត្រី កុមារ ជនពិការ ជនងាយរងគ្រោះ ក្រុមជនជាតិភាគតិច និងជនជាតិដើមភាគ

តិច ចូលរួមក្នុងកិច្ចដំណើរនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដូចមានចែងនៅក្នុងមាត្រា ៨៤ នៃក្រមនេះ ។

**មាត្រា១០៩៨ ._** អំពើរារាំង ឬមិនអនុញ្ញាតដល់មន្ត្រីអធិការកិច្ចវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី៥.០០០.០០០ (ប្រាំលាន) រៀង ទៅ១០.០០០.០០០ (ដប់លាន) រៀល ចំពោះម្ចាស់គម្រោងដែលបញ្ជា ឬបង្ខំឲ្យបុគ្គលិក ឬអ្នកនៅក្រោមឱវាទរបស់ខ្លួនធ្វើការរារាំង ឬមិនអនុញ្ញាតឲ្យមន្ត្រីនៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចូលធ្វើអធិការកិច្ច តាមបញ្ញត្តិនៃមាត្រា៩៩ នៃក្រមនេះ ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ។

ក្នុងករណីដែលអំពើនោះប្រព្រឹត្តដោយហិង្សាធ្វើឲ្យប៉ះពាល់ដល់បូរណភាពរាងកាយ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ។

ក្នុងករណីអំពើនោះប្រព្រឹត្តដោយហិង្សាបណ្តាលឲ្យបាត់បង់ជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ដល់ជនរងគ្រោះត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី១ ។

**មាត្រា១០៩៩ ._** អំពើមិនអនុវត្តតាមលក្ខខណ្ឌតម្រូវ

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ពីមន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះម្ចាស់គម្រោងទាំងឡាយណាដែលមិនអនុវត្តតាមលក្ខខណ្ឌតម្រូវ ដូចមានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ដូចមានចែងក្នុងមាត្រា១៣១នៃក្រមនេះ ។ ក្នុងករណីមិនរាងចាលត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល និង/ឬ ផ្អាកសកម្មភាពគម្រោង ។

ក្នុងករណីដែលមិនគោរពលក្ខខណ្ឌខាងលើ ហើយបណ្តាលឲ្យបាត់បង់ជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ត្រូវទទួលការផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ។ ការព្រមានជាលាយលក្ខណ៍អក្សរ មិនត្រូវអនុវត្តចំពោះករណីនេះឡើយ ។

ក្នុងករណីដែលមិនគោរពលក្ខខណ្ឌខាងលើ ហើយធ្វើឲ្យប៉ះពាល់ដល់ជីវិតសត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវសងសំណងខូចខាតតាមសមាមាត្រនឹងទំហំនៃការខូចខាត ។

ក្នុងករណីដែលការប៉ះពាល់ដែលចែងក្នុងកថាខណ្ឌទី៣ខាងលើមានលក្ខណៈធ្ងន់ធ្ងរ ម្ចាស់គម្រោងអាចទទួលរងទណ្ឌកម្មបន្ថែម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងអាចទទួលការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។

នីតិបុគ្គលអាចត្រូវប្រកាសឲ្យទទួលខុសត្រូវព្រហ្មទណ្ឌ និងទោសបន្ថែមតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ ។

**មាត្រា១១០០ ._** ការធ្វើសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោងបំពានការហាមឃាត់

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន)រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល និង/ឬ ផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ និងត្រូវជួសជុលស្តារការខូចខាត ដែលបានបង្កឡើងចំពោះម្ចាស់គម្រោងដែលបានប្រព្រឹត្តល្មើស នឹងមាត្រា១១៦នៃក្រមនេះ ។ ការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌខាងលើដោយអយ្យការ ត្រូវធ្វើឡើងតាមបណ្តឹងពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ក្នុងករណីដែលគម្រោងមិនទាន់មានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ បង្កផលប៉ះពាល់ជាអវិជ្ជមាន ដល់មនុស្ស សត្វ ទ្រព្យសម្បត្តិ បរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ និងត្រូវសងសំណងខូចខាតដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

ក្រៅពីទណ្ឌកម្មខាងលើ ម្ចាស់គម្រោងអាចទទួលរងទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងទោសបន្ថែមដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។

**មាត្រា១១០១ ._** ការធ្វើសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោងបំពានការហាមឃាត់ចំពោះការវាយតម្លៃហេតុប៉ះពាល់ឆ្លងដែន

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន)រៀល និង/ឬ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ និងត្រូវ ជួសជុល ស្តារការខូចខាតដែលបានបង្កឡើង ចំពោះម្ចាស់គម្រោងដែលបានប្រព្រឹត្តល្មើសនឹងមាត្រា១៣៧នៃក្រមនេះ ។ ការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌខាងលើដោយអយ្យការ ត្រូវធ្វើឡើងតាមបណ្តឹងពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

ក្នុងករណីដែលគម្រោងមិនទាន់មានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ បង្កផលប៉ះពាល់ជាអវិជ្ជមាន ដល់ មនុស្ស សត្វ ទ្រព្យសម្បត្តិ បរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ និងត្រូវសងសំណងខូចខាតតាមទំហំខូចខាតដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

ក្រៅពីទណ្ឌកម្មខាងលើ ម្ចាស់គម្រោងអាចទទួលរងទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងទោសបន្ថែមដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។

បទប្បញ្ញត្តិនៃមាត្រានេះត្រូវយកមកអនុវត្តនៅពេលដែលមានកិច្ចព្រមព្រៀងទ្វេភាគី ឬសន្ធិសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាហត្ថលេខី ។

**មាត្រា១១០២ ._** ដំណើរការសាងសង ឬប្រតិបត្តិការគម្រោងចំពោះគម្រោងមានស្រាប់ ឬកំពុងដំណើរការ

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល និង/ឬ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ និងត្រូវជួសជុល ស្តារការខូចខាត ដែលបានបង្កឡើង ចំពោះម្ចាស់គម្រោងដែលមានស្រាប់ ឬកំពុងដំណើរការដែលបានប្រព្រឹត្តល្មើសនឹងមាត្រា១១៨នៃក្រមនេះ ចាប់ពីច្បាប់នេះចូលជាធរមាន ។ ការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌខាងលើដោយអយ្យការ ត្រូវធ្វើឡើងតាមបណ្តឹងពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាន ។

ក្នុងករណីដែលគម្រោងមិនទាន់មានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ បង្កផលប៉ះពាល់ជាអវិជ្ជមានដល់មនុស្ស សត្វ ទ្រព្យសម្បត្តិ បរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ និងត្រូវសងសំណងខូចខាតតាមទំហំខូចខាតដែលកំណត់ដោយ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

ក្រៅពីទណ្ឌកម្មខាងលើ ម្ចាស់គម្រោងអាចទទួលរងទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងទោសបន្ថែមដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។

**មាត្រា១១០៣ ._** ការបំពានកាតព្វកិច្ចនៃការជូនដំណឹង

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះម្ចាស់គម្រោងដែលមិនបានអនុវត្តការជូនដំណឹងដូចមានចែងក្នុងមាត្រា១០២ នៃក្រមនេះ ។

**មាត្រា១១០៤ ._**អំពើក្លែងបន្លំ ឬលួចចម្លងទិន្នន័យ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះម្ចាស់គម្រោងដែលបានប្រព្រឹត្តអំពើក្លែងបន្លំទិន្នន័យ ឬលួចចម្លងទិន្នន័យអ្នកដទៃ ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និង/ឬ ពេញលេញ ដើម្បីទទួលបាននូវលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ ពេញលេញ ដូចមានចែងក្នុងមាត្រា១០៣ និង១០៤។

**មាត្រា១១០៥ ._** ការបំពានលើកិច្ចសន្យាការពារបរិស្ថាន

ម្ចាស់គម្រោង ត្រូវទទួលរងការព្រមានជាលាយលក្ខណ៍អក្សរពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានចំពោះការមិនគោរព ឬបំពានលើកិច្ចសន្យាការពារបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី២

នៃមាត្រា១០៦ នៃក្រមនេះ ។ ក្នុងករណីមិនរាងចាលត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

ម្ចាស់គម្រោងត្រូវទទួលរងការផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះការមិនគោរពកិច្ចសន្យាការពារបរិស្ថាន ហើយដែលការអនុវត្តគម្រោងនោះធ្វើឲ្យប៉ះពាល់ដល់ជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

ក្នុងករណីសកម្មភាព ឬគម្រោងខាងលើនោះ បង្កឲ្យប៉ះពាល់ដល់ជីវិតសត្វ ទ្រព្យសម្បត្តិ ឬបរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវសងសំណងខូចខាតឲ្យសមាមាត្រទៅនឹងទំហំនៃការខូចខាត ។

**មាត្រា១១០៦ ._** ការបំពាននឹងសេចក្តីសម្រេចបង្គាប់ឲ្យបង់ថ្លៃចំណាយ

ម្ចាស់គម្រោង ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរដោយបង្គាប់ឲ្យបង់ថ្លៃចំណាយដូចមានចែងក្នុងមាត្រា៨៦៦ មាត្រា៨៦៧ មាត្រា៨៦៨ និងមាត្រា៨៦៩ នៃក្រមនេះ ។

នៅក្នុងករណីដែលម្ចាស់គម្រោងមិនបានបង់ប្រាក់ ក្រោយពីទទួលការព្រមាននេះ ម្ចាស់គម្រោងត្រូវទទួលទណ្ឌកម្មជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ រួមទាំងពិន័យជាប្រាក់ចំនួន ៣ (បី) ដងនៃចំនួនទឹកប្រាក់ដែលត្រូវបង់ ។

**មាត្រា១១០៧ ._** ការខកខានមិនបង់ប្រាក់មូលនិធិបរិស្ថាននិងសង្គម និងមូលនិធិទាយជ្ជទានបរិស្ថាន

ម្ចាស់គម្រោងត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះការខកខានមិនបានបង់ប្រាក់ចូលមូលនិធិបរិស្ថាននិងសង្គម និងមូលនិធិទាយជ្ជទានបរិស្ថាន ដូចមានកំណត់នៅក្នុងមាត្រា៨៧០ និងមាត្រា៨៧៥ នៃក្រមនេះ ។

នៅក្នុងករណីដែលម្ចាស់គម្រោងមិនបានបង់ប្រាក់ ក្រោយពីទទួលការព្រមាននេះ ម្ចាស់គម្រោងត្រូវទទួលទណ្ឌកម្មជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ រួមទាំងពិន័យជាប្រាក់ចំនួន ៣ (បី)ដង នៃចំនួនទឹកប្រាក់ដែលត្រូវបង់ ។ ការដាក់ទណ្ឌកម្មនេះ ជាសមត្ថកិច្ចរបស់ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា១១០៨ ._**ការបំពានចំពោះការរៀបចំ និងបញ្ជូនរបាយការណ៍សង្កេតតាមដានបរិស្ថាន

ម្ចាស់គម្រោងត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ដោយបង្គាប់ឲ្យរៀបចំរបាយការណ៍អង្កេតតាមដានគម្រោង និងបញ្ជូនមកក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដូចមានកំណត់ក្នុងមាត្រា១៣៥ និងមាត្រា១៣៦ នៃក្រមនេះ ។ ក្នុងករណីដែលម្ចាស់គម្រោងមិនបានរៀបចំ និងបញ្ជូនរបាយការណ៍មក ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ក្រោយពីទទួលការព្រមាននេះទេ ម្ចាស់គម្រោងត្រូវទទួលទណ្ឌកម្មជាការពិន័យអន្តរការណ៍ ពី ២០.០០០.០០០(ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០(សែសិបលាន) រៀល ឬ ផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ ។

**មាត្រា១១០៩ .**_ ការបំពានចំពោះការបង់ប្រាក់ចំណាយដោះស្រាយវិវាទវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ក្នុងករណីដែលម្ចាស់គម្រោង មិនបង់ប្រាក់ចំណាយទាំងអស់ក្នុងការដោះស្រាយវិវាទ ទាំងក្នុងប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ ដូចមានកំណត់នៅក្នុងមាត្រា៨៦៧ កថាខណ្ឌទី៤ នៃក្រមនេះ ក្រសួងទទួលបន្ទុកបរិស្ថានមានសិទ្ធិសម្រេចផ្អាកសកម្មភាពគម្រោងជាបណ្តោះអាសន្ន ។

**មាត្រា១១១០ .**_ អំពើក្លែងបន្លំ ឬលួចចម្លងទិន្នន័យរបស់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬអ្នកជំនាញការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានចុះបញ្ជីស្របច្បាប់ ដែលទទួលស្គាល់ដោយក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដែលបានប្រព្រឹត្តអំពើក្លែងបន្លំទិន្នន័យ ឬលួចចម្លងទិន្នន័យអ្នកដទៃក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និង/ឬពេញលេញ ។

ទោសបន្ថែមដែលអាចត្រូវប្រកាស មានជាអាទិ៍ ការព្យួរបណ្តោះអាសន្នមិនឲ្យប្រកបវិជ្ជាជីវៈរយៈពេល ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ ឬការផ្អាកមិនឲ្យប្រកបវិជ្ជាជីវៈរយៈពេល ៥ (ប្រាំ) ឆ្នាំ ការលុបឈ្មោះពីបញ្ជីអ្នកជំនាញធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានជាសាធារណៈថ្នាក់ជាតិ និង/ឬ ថ្នាក់តំបន់ ។

**មាត្រា១១១១ .**_ ការប្រកបវិជ្ជាជីវៈរបស់ក្រុមហ៊ុនទីប្រឹក្សា ឬអ្នកជំនាញការវាយតម្លេហាតុប៉ះពាល់បរិស្ថានដែលមិនបានចុះបញ្ជី

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ ពី ៣០.០០០.០០០ (សាមសិបលាន) រៀល ទៅ ៦០.០០០.០០០(ហុកសិបលាន) រៀល ចំពោះក្រុមហ៊ុនទីប្រក្សា ឬអ្នកជំនាញការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលពុំទាន់បានចុះបញ្ជី ឬទទួលស្គាល់ដោយ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ហើយបានរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដាក់ជូន ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានដើម្បីទទួលបានការឯកភាព ស្របតាមមាត្រា១០៨ ។

ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចំពោះបទល្មើសថ្នាក់ទី៣ ។

**មាត្រា១១១២ .**_ ការបំពានសេចក្តីសម្រេចព្យួររបស់ក្រុមហ៊ុនទីប្រឹក្សា ឬអ្នកជំនាញការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ឬពិន័យអន្តរការណ៍ជាប្រាក់ពី ៣០.០០០.០០០ (សាមសិបលាន) រៀល ទៅ ៦០.០០០.០០០ (ហុកសិបលាន) រៀល ចំពោះក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬអ្នកជំនាញការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលការចុះបញ្ជីរបស់ខ្លួនត្រូវ

បានព្យួរតាមសេចក្តីសម្រេចរបស់ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ហើយនៅតែបន្តប្រកបវិជ្ជាជីវៈវាយតម្លៃហេតុប៉ះពាល់បរិស្ថានយកកម្រៃទៀត ។ ការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌខាងលើដោយអយ្យការ ត្រូវធ្វើឡើងតាមបណ្តឹងពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា១១១៣ ._** អំពើបំពាន ឬមិនបំពេញតួនាទីរបស់មន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាលចំពោះមន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ត្រីនគរបាលយុត្តិធម៌វាយតម្លៃហេតុប៉ះពាល់បរិស្ថានណាដែលប្រព្រឹត្តបំពាន ឬមិនបំពេញតួនាទីរបស់ខ្លួនដូចមានចែងក្នុងមាត្រា៩៩ និងមាត្រា៩៩២នៃក្រមនេះ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

**មាត្រា១១១៤ ._** អំពើឃុបឃិតក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ត្រូវផ្តន្ទាទោសក្នុងចំពោះបទល្មើសថ្នាក់ទី៣ ចំពោះមន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មន្ត្រីនៃមន្ទីរបរិស្ថានរាជធានី ខេត្ត និងមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធ ដែលបាន ឃុបឃិត និងចូលរួមរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមិនពិត ដោយចេតនា ដែលនាំឲ្យទទួលបានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ពីថ្នាក់ដឹកនាំ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។

**មាត្រា១១១៥ ._** ការហាមឃាត់ចំពោះមន្ត្រីអធិការកិច្ចវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) ចំពោះបុគ្គលណាដែលមានសិទ្ធិអំណាចក្នុងការសម្រេច ហើយមានចេតនាមិនសហការ មិនអនុញ្ញាត ឬគេចវេស ក្នុងការអនុញ្ញាតឲ្យមន្ត្រី នៃអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានចូលធ្វើអធិការកិច្ច តាមបញ្ញត្តិនៃមាត្រា៩៩ នៃក្រមនេះ ។

ក្នុងករណីដែលអំពើនោះប្រព្រឹត្តដោយហិង្សាធ្វើឲ្យប៉ះពាល់ដល់បូរណភាពរាងកាយ ត្រូវផ្តន្ទាទោសចំពោះបទល្មើស៣ ។

ក្នុងករណីអំពើនោះប្រព្រឹត្តដោយហិង្សាបណ្តាលឲ្យបាត់បង់ជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ដល់ជនរងគ្រោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចំពោះបទល្មើសថ្នាក់ទី១ ។

**មាត្រា១១១៦ ._**ការបំពានមុខងាររបស់មន្ត្រីរាជការ ឬពលរដ្ឋទទួលអាណត្តិដោយការបោះឆ្នោត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចំពោះបទល្មើសថ្នាក់ទី៣ ចំពោះមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ឬពលរដ្ឋទទួលអាណត្តិដោយការបោះឆ្នោត ដែលរំលោភលើសិទ្ធិ និងអំណាចរបស់ខ្លួនប្រព្រឹត្តអំពើ ជាអាទិ៍ ការសម្រួល ការធ្វើអន្តរាគមន៍ ការបិទបាំង ការរារាំង ឬការសមគំនិតជាមួយនឹងចារី ដើម្បី

ឧបត្ថម្ភគាំពារគម្រោងដែលមិនមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឲ្យគម្រោងដំណើរការទៅដោយខុសច្បាប់ ។

**មាត្រា១១១៧ ._** ការខកខានមិនបានធ្វើសវនកម្មបរិស្ថាន

ត្រូវផ្តន្ទាទោសចំពោះបទល្មើសទី៤ ចំពោះម្ចាស់គម្រោង ឬសកម្មភាពណាមួយដែលមិនបានធ្វើសវនកម្មបរិស្ថានណាមួយដូចមានចែងក្នុងមាត្រា១៩១ ។

**មាត្រា១១១៨ ._** ការរារាំងក្នុងអនុវត្តការធ្វើសវនកម្មបរិស្ថាន

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ នូវអំពើរារាំង ឬមិនអនុញ្ញាតឲ្យមន្ត្រីសវនកម្មបរិស្ថានចូលធ្វើសវនកម្ម ។

ក្នុងករណីដែលអំពើនោះប្រព្រឹត្តដោយហិង្សាធ្វើឲ្យប៉ះពាល់ដល់បូរណភាពរាងកាយ ត្រូវផ្តន្ទាចំពោះបទល្មើសថ្នាក់ទី៣ ។

ក្នុងករណីដែលអំពើនោះប្រព្រឹត្តដោយហិង្សាបណ្តាលឲ្យបាត់បង់អាយុជីវិត ឬពិការអចិន្ត្រៃត្រូវផ្តន្ទាទោសថ្នាក់ទី២ ។

**មាត្រា១១១៩ ._** ការខកខានមិនបានផ្តល់ព័ត៌មានដល់សាធារណៈ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការខកខានមិនបានដាក់របាយការណ៍សវនកម្មបរិស្ថានដូចមានចែងក្នុងមាត្រា១៩៤ ។

## ជំពូកទី៤
## បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន

**មាត្រា១១២០ ._** ការបំពានចំពោះសិទ្ធិក្នុងការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានអនុវត្តតាមបញ្ញត្តិនៃមាត្រា១៩៩ ។

**មាត្រា១១២១ ._** ការខកខានក្នុងការរៀបចំរបាយការណ៍ស្តីពីការអង្កេតតាមដាន និងវាយតម្លៃ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានអនុវត្តតាមបញ្ញត្តិនៃមាត្រា១៦៧ ។

**មាត្រា១១២២ ._** ការខកខានមិនផ្តល់ព័ត៌មានសម្រាប់បញ្ជីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានអនុវត្តតាមបញ្ញត្តិនៃមាត្រា១៧៩ ។

**មាត្រា១១២៣ .**_ ការខកខានមិនផ្សព្វផ្សាយបញ្ជីបច្ចេកវិជ្ជាដែលបានផ្ទៀងផ្ទាត់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានអនុវត្តតាមបញ្ញត្តិនៃមាត្រា២០១ ។

**មាត្រា១១២៤ .**_ ការខកខានមិនបានផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តលទ្ធកម្មប្រកបដោយនិរន្តរភាព

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានអនុវត្តតាមបញ្ញត្តិនៃមាត្រា២០៨ ។

**មាត្រា១១២៥ .**_ ការខកខានមិនដាក់របាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានអនុវត្តតាមបញ្ញត្តិនៃមាត្រា២១៨ ។

**មាត្រា១១២៦ .**_ គម្រោងអភិវឌ្ឍ កម្មវិធី និងផែនការសកម្មភាព

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានអនុវត្តតាមបញ្ញត្តិនៃមាត្រា២៣២ ។

ប៉ុន្តែក្នុងការដំណើរការគម្រោងអភិវឌ្ឍ កម្មវិធី និងផែនការសកម្មភាព ដោយពុំមានលិខិតអនុញ្ញាត អនុញ្ញាត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបង្កឲ្យមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គម ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ។

**មាត្រា១១២៧ .**_ ការខកខានមិនបានផ្តល់ព័ត៌មាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានអនុវត្តតាមបញ្ញត្តិស្តីពីការផ្តល់ព័ត៌មានដូចមានចែងក្នុងមាត្រា២៣៤ ។

**មាត្រា១១២៨ .**_ ការខកខានមិនបានផ្តល់ព័ត៌មាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានអនុវត្តតាមបញ្ញត្តិស្តីពីការផ្តល់ព័ត៌មានដូចមានចែងក្នុងមាត្រា២៤២ ។

**មាត្រា១១២៩ .**_ ការខកខានមិនបានវាយតម្លៃពីប្រសិទ្ធភាពនៃធនធាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានធ្វើការវាយតម្លៃពីប្រសិទ្ធភាពនៃធនធានដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា២៨៦ ។

**មាត្រា១១៣០ .**_ ការខកខានមិនបានចែកចាយជាសាធារណៈនូវព័ត៌មានអំពីរ៉ុល

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខាន មិនបានធ្វើការចែកចាយជាសាធាណៈនូវព័ត៌មានអំពីរ៉ុល និងគុណភាពអគ្គិសនីដែលបានផ្គត់ផ្គង់ ឬផ្តល់ទៅឲ្យបណ្តាញតចូលដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា២៧៩ ។

**មាត្រា១១៣១ .**_ ការខកខានមិនអាចឲ្យសាធារណជនអាចស្វែងរកនូវព័ត៌មាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនដាក់ឲ្យសាធារណជនអាចស្វែងរកបាននូវព័ត៌មានដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា២៩៤ ។

## ជំពូកទី៥
## បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃធនធានធម្មជាតិ

**មាត្រា១១៣២ .**_ ការបង្កឲ្យមានភ្លើងឆេះព្រៃនៅក្នុងរបៀបអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះអំពើដែលបង្កឲ្យមានភ្លើងឆេះព្រៃដូចមានចែងក្នុងមាត្រា៣៣២ ។

**មាត្រា១១៣៣ .**_ សកម្មភាពនេសាទដែលស្ថិតនៅក្នុងតំបន់ហាមឃាត់

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពនេសាទទាំងឡាយកើតឡើងនៅក្នុងតំបន់ហាមឃាត់ដូចមានចែងក្នុងមាត្រា៣៣៣ ។

**មាត្រា១១៣៤ .**_ សកម្មភាពដែលបង្កការខូចខាត ឬគ្រោះថ្នាក់បណ្តាលមកពីការទន្ទ្រានយកដីដោយខុសច្បាប់

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ចំពោះសកម្មភាពនៃការប្រមូល ការឈូសឆាយ ឬការធ្វើអាជីវកម្ម ការបំពុលនៅក្នុងតំបន់ដែលមានធនធានជីវៈចម្រុះដ៏មានតម្លៃ ដូចមានចែងក្នុងមាត្រា៣៣៤ ។

**មាត្រា១១៣៥ .**_ ការធ្វើការកែច្នៃ និងប្រត្តិបត្តការដែលត្រូវហាមឃាត់

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ចំពោះសកម្មភាពកែច្នៃផល និងអនុផលធនធានធម្មជាតិនិងប្រតិបត្តនៃការចាប់ចង ការចិញ្ចឹម ការស្តុក ការបង្កាត់ពូជ ការថែរក្សា ឬការចិញ្ចឹមសត្វព្រៃក្នុងគោលបំណងធ្វើពាណិជ្ជកម្ម ឬគោលបំណងក្រៅពីការអភិរក្សដទៃទៀតដូចមានចែងក្នុងមាត្រា ៣៣៥ ។

**មាត្រា១១៣៦ ._** ការហាមឃាត់ចំពោះការប្រមូលផលជ័រឈើ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពប្រមូលផលឈើនៅក្នុងតំបន់អភិរក្ស ឬតំបន់ប្រើប្រាស់ប្រកបដោយនិរន្តរភាព នៃរបៀងជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចមានចែងក្នុងមាត្រា៣៣៦ ។

**មាត្រា១១៣៧ ._** ការខកខានមិនឲ្យសាធារណជនអាចស្វែងរកបានចំពោះរបាយការណ៍អង្កេតតាមដានលើការអនុវត្តច្បាប់ និងយាមល្បាត

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនដាក់របាយការណ៍ស្តីពីការអង្កេតតាមការអនុវត្តច្បាប់ និងការយាមល្បាតឲ្យសាធាណជនអាចស្វែងរកបាន ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៣៣៩ ។

**មាត្រា១១៣៨ ._** ការខកខានមិនឲ្យសាធារណជនអាចស្វែងរកបាននូវឯកសារពាក់ព័ន្ធនឹងការគ្រប់គ្រងរួមគ្នា

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនដាក់ឯកសារពាក់ព័ន្ធ និងការគ្រប់គ្រងរួមគ្នាឲ្យសាធាណជនអាចស្វែងរកបាន ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៣៤៧។

**មាត្រា១១៣៩ ._** ការបំពានចំពោះកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា

ត្រូវផ្តន្ទាចំពោះបទល្មើសថ្នាក់ទី៤ ចំពោះអំពើទាំងឡាយណាដែលរំលោភបំពានលើកិច្ចព្រមព្រៀងរួមគ្នាដែលបង្កឲ្យមានការខូចខាត ដល់បរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៣៤៨ ។

ការចោទប្រកាន់ខាងលើនេះ មិនអាចឲ្យបុគ្គលដែលបំពាននោះរួចផុតពីការទទួលខុសត្រូវសំណាងផ្នែករដ្ឋប្បវេណី និងសំណងការខូចខាតឡើយ ។

**មាត្រា១១៤០ ._** ការការខកខានមិនឲ្យសាធារណជនអាចស្វែងរកបាននូវផែនការប្រើប្រាស់ប្រកបដោយនិរន្តរភាព

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនដាក់ផែការប្រើប្រាស់ប្រកបដោយនិរន្តរភាព ផែនការគ្រប់គ្រង និងរបាយការណ៍គ្រប់គ្រងព្រៃឈើ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៣៨៣ ។

**មាត្រា១១៤១ ._** ការខកខានមិនឲ្យសាធារណជនអាចស្វែងរកបាននូវបញ្ជីថ្នាក់ជាតិនៃប្រភេទសត្វព្រៃដែលរងការគំរាមកំហែង

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនដាក់បញ្ជីថ្នាក់ជាតិនៃប្រភេទសត្វព្រៃដែលរងការគំរាមកំហែងឲ្យសាធារណជនអាចស្វែងរកបាន ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤០៤ ។

**មាត្រា១១៤២ ._** ការហាមឃាត់ចំពោះការបរបាញ់សត្វព្រៃ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះអំពើបរបាញ់សត្វព្រៃដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤០៩ ។

**មាត្រា១១៤៣ ._** ការហាមឃាតចំពោះការបរបាញ់សត្វព្រៃក្នុងរបៀងអភិរក្សជីវៈចម្រុះ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះអំពើបរបាញ់សត្វព្រៃក្នុងរបៀងអភិរក្សជីវៈចម្រុះដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤១០ ។

**មាត្រា១១៤៤ ._** ការហាមឃាត់ចំពោះការសម្លាប់សត្វព្រៃដែលផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្ត

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះអំពើសម្លាប់សត្វព្រៃដែលផ្ទុយនឹងគោលការណ៍ណែនាំ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤១២ ។

**មាត្រា១១៤៥ ._** ការហាមឃាត់ការសម្លាប់ប្រភេទសត្វព្រៃក្រោមថ្នាក់ទី១ ថ្នាក់ទី២ ថ្នាក់ទី៣ និងថ្នាក់ទី៤

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះអំពើសម្លាប់សត្វព្រៃដែលនៅក្នុងថ្នាក់ទី១ និងថ្នាក់ទី២ដោយពុំមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤១៥ និងមាត្រា៤១៦ ។

**មាត្រា១១៤៦ ._** ការស្តារ និងគ្រប់គ្រងសត្វព្រៃដែលពុំមានដើមកំណើតនៅកម្ពុជា

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះអំពើស្តារ និងគ្រប់គ្រងសត្វព្រៃដោយពុំមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤១៧ ។

**មាត្រា១១៤៧ ._** ការចាប់សត្វព្រៃមកអភិរក្ស

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះអំពើចាប់សត្វព្រៃមកអភិរក្សដោយពុំមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤១៨។

**មាត្រា១១៤៨ ._** លិខិតអនុញ្ញាតចំពោះគ្រឹះស្ថានឧទ្យានសត្វព្រៃ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះការបង្កើតគ្រឹះស្ថានឧសទ្យានសត្វព្រៃ ដោយគ្មានលិខិតអនុញ្ញាតដែលគ្មានសុពលភាព ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤២១ ។

**មាត្រា១១៤៩ ._** ការហាមឃាត់ចំពោះការបរបាញ់ ការចាប់ ឬការប្រមូលសត្វពីព្រៃក្នុងថ្នាក់ទី១ ថ្នាក់ទី២ ថ្នាក់ទី៣ និងថ្នាក់ទី៤ ក្នុងគ្រឹះស្ថានឧស្យានសត្វព្រៃ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះអំពើបរបាញ់ ការចាប់ និងប្រមូលសត្វពីព្រៃក្នុងថ្នាក់ទី១ ថ្នាក់ទី២ ថ្នាក់ទី៣ និងថ្នាក់ទី៤ ក្នុងគ្រឹះស្ថានឧសទ្យានសត្វព្រៃ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤២២ និងមាត្រា៤២៣ ។

**មាត្រា១១៥០ ._** ការបរបាញ់ដោយពុំមានលិខិតអនុញ្ញាតចំពោះប្រភេទសត្វក្នុងថ្នាក់ទី៣ និងទី៤

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះអំពើបរបាញ់សត្វព្រៃដោយពុំមានលិខិតអនុញ្ញាតក្នុងប្រភេទសត្វក្នុងថ្នាក់ទី៣ និងទី៤ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤២៥ ។

**មាត្រា១១៥១ ._** សកម្មភាពដែលត្រូវហាមឃាត់

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះអំពើការជួញដូរ ការដឹកជញ្ជូន ការបញ្ជូន ការនាំចូល នាំចេញ ការនាំចេញបន្ត កាន់កាប់ លក់ ទិញ ផ្ទេរ ស្តុកទុក ផ្តល់ជាអំណោយ បរិភោគ ចិញ្ចឹម និងការប្រើប្រាស់តាមរូបភាពពាណិជ្ជកម្មនូវបំណែកសត្វ និងផលិតផលពីសត្វដទៃទៀត ដែលជាប្រភេទក្នុងថ្នាក់ទី១ ទី២ និងទី៣ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៣១ ។

**មាត្រា១១៥២ ._** សកម្មភាពដែលត្រូវហាមឃាត់ចំពោះសកម្មភាពរូបវន្តបុគ្គល និងនីតិបុគ្គល

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះអំពើទិញ ទទួល ឬធ្វើលទ្ធកម្មសត្វព្រៃរស់ ឬសត្វព្រៃ ដែលមានប្រភេទក្នុងថ្នាក់ទី១ ទី២ ឬ ទី៣ ឬបំណែកសត្វព្រៃ ឬសាច់សត្វដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៣២ ។

**មាត្រា១១៥៣ ._** ការមិនអនុលោមតាមអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិនៃប្រភេទសត្វព្រៃ និងរុក្ខជាតិដែលជិតផុតពូជ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះអំពើមិនអនុលោមតាមអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិនៃប្រភេទសត្វព្រៃ និងរុក្ខជាតិដែលជិតផុតពូជ ដូចមានចែងក្នុងមាត្រា៤៣៤ ។

**មាត្រា១១៥៤ ._** ការចុះបញ្ជីចំពោះការបង្កើតមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើមិនចុះបញ្ជីចំពោះការង្កើតមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៤៤ និងមាត្រា៤៤៦ ។

**មាត្រា១១៥៥ ._** ការហាមឃាត់ចំពោះការបង្ខាំងសត្វនៅក្រៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ កន្លែងបង្កាត់ពូជអភិរក្ស ឬគ្រឹះស្ថាន ឬឧទ្យានសត្វព្រៃ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការបង្ខាំសត្វចិញ្ចឹម នៃប្រភេទសត្វដូចកំណត់ក្នុងថ្នាក់ទី១ ថ្នាក់ទី២ និងថ្នាក់ទី៣ នៅក្រៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ កន្លែងបង្កាត់ពូជអភិរក្ស ឬគ្រឹះស្ថាន ឬឧទ្យានសត្វព្រៃដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៤៥ ។

**មាត្រា១១៥៦ ._** ការជូនដំណឹងចំពោះការផ្ទេរ និងការប្តូរទីតាំងប្រភេទសត្វដែលកំណត់ក្នុងថ្នាក់ទី១ និងថ្នាក់ទី២ និងមជ្ឈមណ្ឌលបង្កាត់ពូជ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការមិនបានជូនដំណឹងអំពីការផ្ទេរ និងការប្តូរទីតាំងនៃប្រភេទសត្វដែលកំណត់ក្នុងថ្នាក់ទី១ និងថ្នាក់ទី២ និងមជ្ឈមណ្ឌលបង្កាត់ពូជដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៥១ ។

**មាត្រា១១៥៧ ._** ការបោះបង់ចោលបំណែក សាច់ ឬវត្ថុតាំងលម្អ នៃសត្វព្រៃ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការបោះបង់ចោលបំណែក សាច់ ឬវត្ថុតាំងលម្អ នៃសត្វព្រៃដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៥២ ។

**មាត្រា១១៥៨ ._** ការហាមឃាត់ចំពោះបង្កើតកសិដ្ឋានចិញ្ចឹមសត្វព្រៃ ឬទីតាំងបង្កាត់ពូជសត្វព្រៃ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះការបង្កើតកសិដ្ឋានចិញ្ចឹមសត្វព្រៃ ឬទីតាំងបង្កាត់ពូជសត្វព្រៃដែលត្រូវហាមឃាត់ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៦៣ ។

**មាត្រា១១៥៩ ._** ការចិញ្ចឹមសត្វព្រៃដែលពុំមានក្នុងលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះអំពើចិញ្ចឹមសត្វព្រៃដែលមិនមានក្នុងលិខិតអនុញ្ញាត ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៦៤ ។

**មាត្រា១១៦០.**_ ការលក់ដូរសត្វព្រៃចិញ្ចឹម និងផលិតផលសត្វព្រៃ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះការលក់ដូរសត្វព្រៃចិញ្ចឹម និងផលិតផលសត្វព្រៃ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៦៧ ។

**មាត្រា១១៦១ .**_ ប្រតិបត្តិករនៃកសិដ្ឋានដែលអនុញ្ញាតចំពោះការផ្តល់ការថែទាំចំពោះសត្វព្រៃចិញ្ចឹម

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះប្រតិបត្តិករនៃកសិដ្ឋានដែលមិនបានផ្តល់ការថែទាំចំពោះសត្វព្រៃចិញ្ចឹម ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៧០ ។

**មាត្រា១១៦២ .**_ ការបណ្តោយឲ្យសត្វរបស់ខ្លួនរួច ឬគេចពីការបង្ខាំង ឬព្រលែងចូលទៅក្នុងព្រៃ

ត្រូវផ្តន្ទាទោសចំពោះទោសពិន័យក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃទាំងឡាយដែលបណ្តោយឲ្យសត្វរបស់ខ្លួនរួច ឬគេចពីការបង្ខាំង ឬព្រលែងចូលទៅក្នុងព្រៃឡើយ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៧១ ។

**មាត្រា១១៦៣ .**_ ការសម្លាប់ដោយអមនុស្សធម៌

ត្រូវផ្តន្ទាទោសចំពោះទោសពិន័យក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការសម្លាប់ដោយអមនុស្សធម៌ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៧២ ។

**មាត្រា១១៦៤ .**_ នីតិវិធី និងលិខិតបទដ្ឋានគតិយុត្តនៃការដឹកជញ្ជូន

ត្រូវផ្តន្ទាទោសចំពោះទោសពិន័យក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការដឹកជញ្ជូន រាល់សត្វព្រៃដែលត្រូវបង្ខាំង មិនស្របតាមនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តផ្លូវច្បាប់ ដែលបង្កើតដោយនាយកដ្ឋានសុខភាព និងផលិតកម្មសត្វ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៧៣ ។

**មាត្រា១១៦៥ .**_ កាតព្វកិច្ចរបស់ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ

ត្រូវផ្តន្ទាទោសចំពោះទោសពិន័យក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃដែលមិនបានអនុវត្តកាតព្វកិច្ចក្នុងការស្នើសុំលិខិតអនុញ្ញាតថ្មី និងលក្ខខណ្ឌតម្រូវនានា ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៧៥ ។

**មាត្រា១១៦៦ .**_ ការមិនឲ្យសាធារណជនស្វែងរកបាននូវទិន្នន័យនៃប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសចំពោះទោសពិន័យក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការមិនឲ្យសាធារណជនស្វែងរកបាននូវឯកសារ ទិន្នន័យ ឬព័ត៌មានបញ្ជីបច្ចុប្បន្ននៃប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៨៩ ។

**មាត្រា១១៦៧ ._** ការហាមឃាត់ចំពោះបំផ្លាញនិងការផ្លាស់ប្តូរទីជម្រក និងប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះការបំផ្លាញនិងការផ្លាស់ប្តូរជម្រកប្រភេទរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៩០ ។

**មាត្រា១១៦៨ ._** ការហាមឃាត់ចំពោះបំផ្លាញ ការប្រមូល ការប្រើប្រាស់ ការលក់ ជំនួញ ឬការដឹកជញ្ជូន រុក្ខជាតិដែលទទួលរងគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះការបំផ្លាញ ការប្រមូល ការប្រើប្រាស់ ការលក់ ជំនួញ ឬការដឹកជញ្ជូន រុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៩១ ។

**មាត្រា១១៦៩ ._** ការហាមឃាត់ចំពោះការប្រមូល ឬការបំផ្លិចបំផ្លាញនៃរុក្ខជាតិណាមួយនៅក្នុងច្រករបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះការប្រមូល ឬការបំផ្លិចបំផ្លាញនៃរុក្ខជាតិណាមួយនៅក្នុងច្រករបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៤៩២ ។

**មាត្រា១១៧០ ._** ការប្រើប្រាស់រុក្ខជាតិជាលក្ខណៈគ្រួសារ និងការប្រើប្រាស់ជាឱសថដោយពុំមានការអនុញ្ញាត

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះកាបំផ្លាញ ការប្រមូល ការប្រើប្រាស់ ការលក់ ជំនួញ ឬការដឹកជញ្ជូន រុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ ឬនិស្សន្ទវត្ថុ សម្រាប់ការប្រើប្រាស់ជាលក្ខណៈគ្រួសារ និងការប្រើប្រាស់ជាឱសថ ដោយពុំមានការអនុញ្ញាត ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា ៤៩៣ ។

**មាត្រា១១៧១ ._** ការប្រើប្រាស់រុក្ខជាតិដែលទទួលរងការគំរាមកំហែងដោយពុំមានការអនុញ្ញាត

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះការប្រើប្រាស់រុក្ខជាតិដែលទទួលរងគ្រោះថ្នាក់ក្នុងគោលបំណងវិទ្យាសាស្ត្រ ដោយពុំមានការអនុញ្ញាត ដូចមានចែងក្នុងបញ្ញត្តិ នៃមាត្រា៤៩៤ ។

**មាត្រា១១៧២ ._** ការមិនឲ្យសាធារណជនស្វែងរកបាននូវទិន្នន័យប្រព័ន្ធអេកូឡូស៊ី

ត្រូវផ្តន្ទាទោសចំពោះទោសពិន័យក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការមិនឲ្យសាធារណជនស្វែងរកបាននូវឯកសារ ទិន្នន័យ ឬព័ត៌មានបញ្ជីបច្ចុប្បន្ននៃប្រព័ន្ធអេកូឡូស៊ី ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា ៥០៣ ។

**មាត្រា១១៧៣ ._** ការមិនឲ្យសាធារណជនស្វែងរកបាននូវបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិរាតត្បាត

ត្រូវផ្តន្ទាទោសបទល្មើសថ្នាក់ទី៤ ចំពោះការមិនឲ្យសាធារណជនស្វែងរកបាននូវបញ្ជីថ្នាក់ជាតិស្តីពីប្រភេទរុក្ខជាតិរាតត្បាត ឬ ការនាំប្រភេទរុក្ខជាតិរាតត្បាតមកចូលទៅក្នុងបរិស្ថានធម្មជាតិ ឬ ទេសភាពកសិកម្ម ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៥០៧ ។

**មាត្រា១១៧៤ .**_ ការហាមឃាត់ចំពោះការឯកភាពលើសកម្មភាពដែលមិនដាក់បញ្ចូលនូវការពិចារណាអំពីផលប៉ះពាល់ដែលអាចកើតមានឡើង

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលអនុញ្ញាតមានសកម្មភាព ឬការអភិវឌ្ឍទាំងឡាយណាដែលកើតមាននៅក្នុងតំបន់ឆ្នេរ ដូចមានចែងក្នុងមាត្រា៥២០ ។

**មាត្រា១១៧៥ .**_ សកម្មភាពសាងសង់នៅតំបន់ឆ្នេរ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ចំពោះ រាល់សកម្មភាព ការសាងសង់ និងគម្រោងទាំងឡាយ ពាក់ព័ន្ធទៅនឹងអាជីវកម្មរ៉ែខ្សាច់ គម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលបង្កឲ្យមានការបាត់បង់ ឬការបំផ្លាញដល់វត្ថុធាតុ នៃតំបន់ឆ្នេរ ដូចមានចែងក្នុងមាត្រា៥២២ ។

**មាត្រា១១៧៦ .**_ ការមិនអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបំពានលក្ខខណ្ឌតម្រូវនៃការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ដូចមានចែងក្នុងមាត្រា៥២៣ ។

**មាត្រា១១៧៧ .**_ ការមិនឲ្យសាធារណជនស្វែងរកបាននូវទិន្នន័យ និងព័ត៌មានធនធានទឹក

ត្រូវផ្តន្ទាទោសពិន័យក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការមិនឲ្យសាធារណជនស្វែងរកបាននូវទិន្នន័យ និងព័ត៌មានធនធានទឹក ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៥៣៥ ។

**មាត្រា១១៧៨ .**_ សកម្មភាពដែលតម្រូវឲ្យមានការផ្តល់ការអនុញ្ញាត

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពទាំងឡាយ ដែលមិនមានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៥៦៩ ។

**មាត្រា១១៧៩ .**_ ការប្រកបសកម្មភាពអាជីវកម្មដោយពុំមានវិញ្ញាបនបត្រ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះការប្រកបសកម្មភាពអាជីវកម្មដោយពុំមានវិញ្ញាបនបត្រដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៥៩៩ ។

**មាត្រា១១៨០ ._** ការខកខានមិនធ្វើរបាយការណ៍ការងារលម្អិតទាក់ទងនឹងអណ្តូង

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការខកខានមិនធ្វើរបាយការណ៍ស្តីពីការងារលម្អិតនៃអណ្តូង ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៦០០ ។

**មាត្រា១១៨១ ._** ការអនុញ្ញាតចំពោះការផ្គត់ផ្គង់ និងប្រើប្រាស់ទឹក

ត្រូវផ្តន្ទាទោសបទល្មើសថ្នាក់ទី៤ ចំពោះការយក ការផ្គត់ផ្គង់ ឬ ការប្រើប្រាស់ទឹក ដោយគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦០៤ ។

## ជំពូកទី៦
## បទល្មើសពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌

**មាត្រា១១៨២ ._** កាតព្វកិច្ចរាយការណ៍ពេលដឹង ឬ ប្រទះឃើញដោយចៃដន្យនូវបេតិកភណ្ឌវប្បធម៌

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានដឹង ឬប្រទះឃើញដោយចៃដន្យនូវបេតិកភណ្ឌវប្បធម៌ ហើយមិនរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរដែនដី និងឬក្រសួង ស្ថាប័នមានសមត្ថកិច្ច/ ដូចមានចែងក្នុងមាត្រា៦៤៨ ។

**មាត្រា១១៨៣ ._** កាតព្វកិច្ចផ្អាកសកម្មភាពសាងសង់ និងជូនដំណឹងអំពីការរកឃើញសម្បត្តិបេតិកភណ្ឌ

ត្រូវផ្តន្ទាទោសចំពើបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនបានផ្អាកសកម្មភាពសាងសង់ និងមិនបានរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា៦៤៩ ។

**មាត្រា១១៨៤ ._** ការហាមឃាត់ចំពោះយកចេញ ឬបំផ្លាញបេតិកភណ្ឌ

ត្រូវផ្តន្ទាទោសចំពើបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានយកចេញ ឬបំផ្លាញចោលនូវវត្ថុបេតិកភណ្ឌណាមួយដែលមាននៅក្នុងទីតាំងដីកម្មសិទ្ធិឯកជន ដូចមានចែងក្នុងមាត្រា៦៥៣ ។

**មាត្រា១១៨៥ ._** ការខកខានមិនធ្វើកំណត់ត្រានិងថតរូបវត្ថុបេតិកភណ្ឌ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើការខកខានមិនបានធ្វើកំណត់ត្រា និងថតរូបវត្ថុបេតិកភណ្ឌ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៦៥៤ ។

**មាត្រា១១៨៦ .**_ ការមិនរាយការណ៍អំពីការប្រទះឃើញដោយចៃដន្យ ឬការបំផ្លាញវត្ថុបេតិកភណ្ឌ

ត្រូវផ្តន្ទាទោសពិន័យក្នុងបទល្មើសថ្នាក់ទី៣ ចំពោះអំពើមិនរាយការណ៍អំពីការប្រទះឃើញដោយចៃដន្យ ឬការបំផ្លាញវត្ថុបេតិកភណ្ឌ ដូចមានចែងក្នុងមាត្រា៦៥៥ ។

**មាត្រា១១៨៧ .**_ កាតព្វកិច្ចរាយការណ៍ចំពោះការប្រទះឃើញវត្ថុបេតិកភណ្ឌក្រោមទឹក

ត្រូវផ្តន្ទាទោសពិន័យក្នុងបទល្មើសថ្នាក់ទី៣ ចំពោះអំពើមិនរាយការណ៍ចំពោះការប្រទះឃើញវត្ថុបេតិកភណ្ឌក្រោមទឹក ដូចមានចែងក្នុងមាត្រា៦៥៨ ។

**មាត្រា១១៨៨ .**_ ការធ្វើឲ្យខូច ឬការបំផ្លិចបំផ្លាញ ឬ ការស្រង់ ឬរំខានបេតិកភណ្ឌវប្បធម៌ក្នុងទឹក

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះអំពើធ្វើឲ្យខូច ឬការរបំផ្លិចបំផ្លាញ ឬការស្រង់ ឬរំខានបេតិកភណ្ឌវប្បធម៌ក្នុងទឹក ដូចមានចែងក្នុងមាត្រា៦៥៩ ។

## ជំពូកទី៧
## បទល្មើសពាក់ព័ន្ធនឹងសំណល់ និងការបំពុល

**មាត្រា១១៨៩ .**_ ការធ្វើសកម្មភាពដែលនាំឲ្យបំពុលខ្យល់ ទឹក ឬដី

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានធ្វើសកម្មភាពណាមួយដែលនាំឲ្យមានការបំពុលខ្យល់ ឬទឹក ឬដី ដូចមានចែងក្នុងមាត្រា៦៨៥ ។

**មាត្រា១១៩០ .**_ ការដឹកជញ្ជូន គ្រប់គ្រង ស្តុកទុក ធ្វើប្រព្រឹត្តកម្ម ឬបោះបង់ចោលសំណល់

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានដឹកជញ្ជូន គ្រប់គ្រង ស្តុកទុក ធ្វើប្រព្រឹត្តកម្ម ឬបោះបង់ចោលសំណល់ណាមួយ ទោះក្នុងរូបភាពជាសារធាតុរឹង ឬរាវ ឬឧស្ម័ន ឬសារធាតុគ្រោះថ្នាក់ ឬសំណល់គ្រោះថ្នាក់ ដោយពុំស្របតាមលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៨៦ ។

**មាត្រា១១៩១ .**_ ការបង្កសកម្មភាពដែលនាំមានការបំពុលដោយសំឡេង ឬរំញ័រដែលលើសពីស្តង់ដារដែលអនុញ្ញាត

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបង្កសកម្មភាពណាមួយដែលនាំមាន ការបំពុលដោយសំឡេង ឬរំញ័រដែលលើសពីស្តង់ដារ ដូចមានចែងក្នុងមាត្រា៦៨៧ ។

**មាត្រា១១៩២ .**_ ការមិនអនុវត្តតាមលក្ខខណ្ឌនៃ លិខិតអនុញ្ញាត ឬការឯកភាព

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុង បទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិន គោរពតាមលក្ខខណ្ឌនានានៃលិខិតអនុញ្ញាត ឬការឯកភាព ដូចមានចែងក្នុងមាត្រា៦៨៨ ។

ប៉ុន្តែក្នុងករណីដែលអំពើមិនគោរពតាមលក្ខខណ្ឌនានានៃលិខិតអនុញ្ញាត ឬការឯកភាពខាងលើនេះបានបង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិ សត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី២ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនគោរពតាមលក្ខខណ្ឌនៃលិខិតអនុញ្ញាត ឬការឯកភាពខាងលើនេះបានបង្កឲ្យបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១១៩៣ .**_ ការដាក់ម៉ាកដែលនាំឲ្យច្រឡំលើសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានដាក់ម៉ាកដែលនាំឲ្យលើសារធាតុប្រកបដោយគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៧០៨ ។

**មាត្រា១១៩៤ .**_ ការហាមឃាត់ចំពោះសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានផលិត ប្រើប្រាស់ ឬចែកចាយសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុដែលត្រូវហាមឃាត់ ដូចមានចែងក្នុងមាត្រា៧០៩ ។

**មាត្រា១១៩៥ .**_ ការហាមឃាត់អំពីសំណនៅក្នុងថ្នាំពណ៌ និងឧបករណ៍សម្រាប់កុមារ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានប្រើប្រាស់សំណ ឬសមាសធាតុសំណក្នុងទឹកថ្នាំពណ៌ និងឧបករណ៍សម្រាប់កុមារ ដូចមានចែងក្នុងមាត្រា៧១០ ។

**មាត្រា១១៩៦ .**_ ការហាមឃាត់ចំពោះសារធាតុដែលមិនបានចុះបញ្ជី

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានផលិត កាន់កាប់ ប៉ះពាល់ រក្សាទុក ដឹកជញ្ជូន នាំចូល នាំចេញ ចែកចាយ ឬប្រើប្រាស់សារធាតុ រឺផលិតផលគ្រោះថ្នាក់ ដែលមិនទាន់បានចុះបញ្ជី ដូចមានចែងក្នុងមាត្រា ៧១៤ ។

**មាត្រា១១៩៧ .**_ ការហាមឃាត់ចំពោះការវេចខ្ចប់ដែលមិនត្រឹមត្រូវ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានរក្សាទុក នាំចេញ នាំចូល ឬធ្វើការចែកចាយនូវសារធាតុ រឺផលិតផលគ្រោះថ្នាក់ ដែលមិនបានវេចខ្ចប់ស្របតាមបទប្បញ្ញត្តិ និងលក្ខខណ្ឌនៃការចុះបញ្ជី ដូចមានចែងក្នុងមាត្រា៧១៥ ។

**មាត្រា១១៩៨ ._** ការហាមឃាត់ចំពោះការវេចខ្ចប់និងការផ្សព្វផ្សាយក្លែងក្លាយ ឬនាំឲ្យច្រឡំ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានវេចខ្ចប់ ឬផ្សព្វផ្សាយ អំពីផលិតផល ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលក្លែងក្លាយ ធ្វើឲ្យច្រឡំដែលពាក់ព័ន្ធតម្លៃ ចំនួន ធាតុផ្សំ សុវត្ថិភាព ឬការចុះបញ្ជីនៃផលិតផល ឬសារធាតុ ដូចមានចែងក្នុងមាត្រា៧១៦ ។

**មាត្រា១១៩៩ ._** សារធាតុដែលបង្កឲ្យមានច្រេះស៊ី ការរំលាយ ការរលាក ការធ្វើអុកស៊ីតកម្ម ឬរបួសស្នាម

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី២ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានប្រើប្រាស់អាស៊ីត ឧស្ម័ន ឬសារធាតុគីមីពុល ដែលអាចបង្កឲ្យមានការច្រេះស៊ី ការរំលាយ ការរលាក ការធ្វើអុកស៊ីតកម្ម ឬរបួសស្នាមនានា ដល់សុខភាព និងជីវិតរបស់មនុស្ស ដូចមានចែងក្នុងមាត្រា៧១៧ ។

**មាត្រា១២០០ ._** ការចុះបញ្ជីសម្រាប់ការកាន់កាប់រាល់ផលិតផល និងសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនបានចុះបញ្ជីតាមការកំណត់របស់ច្បាប់ សម្រាប់ការកាន់កាប់រាល់ផលិតផល និងសារធាតុប្រកបដោយគ្រោះថ្នាក់ ដើម្បីផលិត ចែកចាយ លក់ និងប្រើប្រាស់ ដូចមានចែងក្នុងមាត្រា៧១៨។

**មាត្រា១២០១ ._** កាតព្វកិច្ចក្នុងការផ្តល់ព័ត៌មានរបស់ផលិតករ ឬអ្នកនាំចូលសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះផលិតករ ឬអ្នកនាំចូលទាំងឡាយណាដែលនាំចូលសារធាតុគ្រោះថ្នាក់ ហើយមិនបានផ្តល់ព័ត៌មានទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដូចមានចែងក្នុងមាត្រា៩២១ ។

ក្នុងករណីដែលអំពើនៃការផលិត ឬការនាំចូលសារធាតុគ្រោះថ្នាក់ ដូចមានចែងក្នុងកថាខណ្ឌខាងលើ បានបង្កឲ្យមានព្យសនកម្មដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិ សត្វ ឬបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ។

**មាត្រា១២០២ ._** កាតព្វកិច្ចនៃការផ្តល់ព័ត៌មាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលមិនបានចែកចាយព័ត៌មានអំពីរបាយការណ៍ ទិន្នន័យសុវត្ថិភាព ការទប់ស្កាត់ និងការកាត់បន្ថយគ្រោះថ្នាក់ និងហានិភ័យដល់សុខភាព ដែលពាក់ព័ន្ធទៅនឹងគ្រប់សារធាតុគ្រោះថ្នាក់មុនធ្វើការចែកចាយ ឬលក់សារធាតុ ដូចមានចែងក្នុងមាត្រា៧២៦ ។

**មាត្រា១២០៣ ._** ការដឹកជញ្ជូនសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលមិនបានគោរពតាមបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូនសារធាតុ ឬផលិតផលគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៧២៧ ។

**មាត្រា១២០៤ ._** ការបំពានលក្ខខណ្ឌនៃការប្រើប្រាស់សារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុង បទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនគោរពតាមលក្ខខណ្ឌនានានៃការប្រើប្រាស់សារធាតុប្រកបដោយគ្រោះថ្នាក់ដូចមានចែងក្នុងមាត្រា៧២៨ ។

ប៉ុន្តែក្នុងករណីដែលអំពើមិនគោរពតាមលក្ខខណ្ឌនានាខាងលើនេះបានបង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិ សត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី២ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនគោរពតាមលក្ខខណ្ឌខាងលើនេះបានបង្កឲ្យបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១២០៥ ._** ការបោះបង់ចោលសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានដុតចោល ឬបោះបង់ចោលរាល់សារធាតុគ្រោះថ្នាក់ជាផ្នែក ឬជាដុំ ឬសំណល់គ្រោះថ្នាក់ទាំងឡាយ ចូលទៅក្នុងបរិស្ថាន ដោយគ្មានការអនុញ្ញាតដូចមានចែងក្នុងមាត្រា៧៣២ ។

ប៉ុន្តែក្នុងករណីដែលអំពើដុតចោល ឬបោះបង់ចោលរាល់សារធាតុគ្រោះថ្នាក់ជាផ្នែក ឬជាដុំ ឬសំណល់គ្រោះថ្នាក់ទាំងឡាយ ចូលទៅក្នុងបរិស្ថាន ដោយគ្មានការអនុញ្ញាត ខាងលើនេះបានបង្កឲ្យមានព្យសនៈកម្មកើតឡើងដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិ សត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី២ ។

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី១ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនគោរពតាមលក្ខខណ្ឌខាងលើនេះបានបង្កឲ្យបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១២០៦ ._** ភារកិច្ចគោរពតាមគោលបំណងនៃការស្រាវជ្រាវវិទ្យាសាស្ត្រ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលមិនបានគោរពតាមភារកិច្ចនៃការយកសារធាតុគ្រោះថ្នាក់មកធ្វើការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ដូចមានចែងក្នុងមាត្រា៧៣១ ។

**មាត្រា១២០៧ ._** ការយកសារធាតុគ្រោះថ្នាក់សម្រាប់ធ្វើជាផលិតផលអាហារ គ្រឿងកែសម្ផស្ស និងប្រដាប់ក្មេងលេង

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានប្រើប្រាស់សារធាតុគ្រោះថ្នាក់សម្រាប់ធ្វើជាផលិតផលអាហារ គ្រឿងកែសម្អស្ស និងប្រដាប់ក្មេងលេង ដែលអាចបង្កឲ្យមានគ្រោះថ្នាក់ដល់មនុស្សដូចមានចែងក្នុងមាត្រា៧៣០ ។

ប៉ុន្តែក្នុងករណីដែលការយកមកប្រើប្រាស់សារធាតុគ្រោះថ្នាក់សម្រាប់ធ្វើជាផលិតផលអាហារ គ្រឿងកែសម្ផស្ស និងប្រដាប់ក្មេងលេងខាងលើនេះបានបង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី២ ។

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី១ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលការយកមកប្រើប្រាស់សារធាតុគ្រោះថ្នាក់សម្រាប់ធ្វើជាផលិតផលអាហារ គ្រឿងកែសម្ផស្ស និងប្រដាប់ក្មេងលេងខាងលើនេះបានបង្កឲ្យមានព្យសនៈបាត់បង់អាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១២០៨ .**_ ការចុះបញ្ជីផលិតសារធាតុ ឬផលិតផលគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនបានចុះបញ្ជីផលិតសារធាតុ ឬផលិតផលគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៧៣៥ ។

**មាត្រា១២០៩ .**_ ការរៀបចំរបាយការណ៍ប្រចាំឆ្នាំជូនដល់ក្រសួង អំពីដំណើរការផលិតកម្ម ចំនួនធាតុផ្សំគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនបានរៀបចំរបាយការណ៍ប្រចាំឆ្នាំអំពីដំណើរការផលិតកម្ម អំពីចំនួនធាតុផ្សំគ្រោះថ្នាក់ អំពីបំណងនៃការប្រើប្រាស់ អំពីទីតាំងចែកចាយ ប្រព័ន្ធប្រព្រឹត្តកម្ម និងអំពីការបោះបង់ចោលសំណល់ វិធានការ និងផែនការសុវត្ថិភាព ដូចមានចែងក្នុងមាត្រា៧៣៦ ។

**មាត្រា១២១០ .**_ កាតព្វកិច្ចជូនដំណឹងអំពីគ្រោះថ្នាក់ដែលបង្កឡើងដោយសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនបានជូនដំណឹងភ្លាមៗដល់អាជ្ញាធរមានសមត្ថកិច្ច និងក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន និងត្រូវចាត់វិធានការសមរម្យ ស្របតាមផែនការទប់ស្កាត់ និងឆ្លើយតបក្នុងករណីសង្គ្រោះបន្ទាន់ ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថាន និងទ្រព្យសម្បត្តិ ដូចមានចែងក្នុងមាត្រា៧៣៨ ។

**មាត្រា១២១១ .**_ ការទទួលខុសត្រូវលើការខូចខាតដែលបង្កដោយសំណល់គ្រោះថ្នាក់ និងសំណល់រឹង

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបង្កើតសំណល់គ្រោះថ្នាក់ និងសំណល់រឹង ហើយបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា៧៤៣ ។

ប៉ុន្តែក្នុងករណីដែលការបង្កើតសំណល់គ្រោះថ្នាក់ និងសំណល់រឹងដូចមានចែងក្នុងកថាខណ្ឌខាងលើ បានបង្កឲ្យមានមានព្យសនៈបាត់បង់អាយុជីវិត ឬពិការអចិន្ត្រៃយ៍ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣។

**មាត្រា១២១២** ._ ការទទួលខុសត្រូវលើការស្តុកទុក ការគ្រប់គ្រង និងការបោះបង់ចោលសំណល់គ្រោះថ្នាក់

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបង្កើតសំណល់ ដូចមានចែងក្នុងមាត្រា៧៤៧ ។

ប៉ុន្តែក្នុងករណីដែលបង្កើតសំណល់ខាងលើនេះបានបង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី២ ។

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី១ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានបង្កើតសំណល់ខាងលើនេះបានបង្កឲ្យមានព្យសនកម្មបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១២១៣** ._ ការបញ្ចេញសារធាតុបំពុលដែលបង្កឲ្យមានការបំពុលធនធានទឹកលើដី ឬទឹកក្រោមដី

ត្រូវផ្តន្ទាទោសចំពើបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានការបញ្ចេញសារធាតុបំពុលដោយប្រភពបំពុលជាក់លាក់ ឬមិនជាក់លាក់ដែលបង្កឲ្យមានការបំពុលធនធានទឹកលើដី ឬទឹកក្រោមដីដូចមានចែងក្នុងមាត្រា៧៥៤ និងមាត្រា៧៥៥ ។

ប៉ុន្តែក្នុងករណីដែលការបញ្ចេញសារធាតុបំពុលដោយប្រភពបំពុលជាក់លាក់ឬមិនជាក់លាក់ដែលបង្កឲ្យមានការបំពុលធនធានទឹកលើដី ឬទឹកក្រោមដីខាងលើនេះបានបង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយសត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី២ ។

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី១ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានការបញ្ចេញសារធាតុបំពុលដោយប្រភពបំពុលជាក់លាក់ឬមិនជាក់លាក់ដែលបង្កឲ្យមានការបំពុលធនធានទឹកលើដី ឬទឹកក្រោមដី បានបង្កឲ្យមានព្យសនកម្មបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១២១៤** ._ កាតព្វកិច្ចធ្វើប្រព្រឹត្តកម្ម និងការបញ្ចេញសារធាតុបំពុល

ត្រូវផ្តន្ទាទោសចំពើបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនបានគោរពតាមកាតព្វកិច្ចក្នុងការធ្វើប្រព្រឹត្តកម្ម និងការបញ្ចេញសារធាតុបំពុលដូចមានចែងក្នុងមាត្រា៧៥៦ ។

ប៉ុន្តែក្នុងករណីដែលមិនបានគោរពតាមកាតព្វកិច្ចក្នុងការធ្វើប្រព្រឹត្តកម្ម និងការបញ្ចេញសារធាតុបំពុលខាងលើនេះបានបង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយសត្វ និងបរិស្ថាន ធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី២ ។

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី១ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនបានគោរពតាមកាតព្វកិច្ចក្នុងការធ្វើប្រព្រឹត្តកម្ម និងការបញ្ចេញសារធាតុបំពុលបានបង្កឲ្យមានព្យសនកម្មបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១២១៥ ._** ការបញ្ចេញសារធាតុបំពុលដែលបំពានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានបញ្ចេញសារធាតុបំពុលដែលបំពាននឹងលិខិតអនុញ្ញាតដូចមានចែងក្នុងមាត្រា៧៥៧ ។

ប៉ុន្តែក្នុងករណីដែលការបញ្ចេញសារធាតុបំពុលដែលបំពាននឹងលិខិតអនុញ្ញាតខាងលើនេះបានបង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយសត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី២ ។

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី១ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលការបញ្ចេញសារធាតុបំពុលដែលបំពាននឹងលិខិតអនុញ្ញាតបានបង្កឲ្យមានព្យសនកម្មបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១២១៦ ._** ការខកខានមិនបានជូនដំណឹងក្នុងករណីមានការរំលោភបំពានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលកាន់កាប់លិខិតអនុញ្ញាតហើយខកខានមិនបានជូនដំណឹងអំពីការរំលោភបំពាននឹងលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៧៦៣ ។

**មាត្រា១២១៧ ._** ការទទួលខុសត្រូវលើការខូតចខាតដែលបង្កឲ្យមានការបំពុលខ្យល់ពីប្រភពចល័ត និងអចល័ត

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបង្កឲ្យមានការបំពុលខ្យល់ពីប្រភពចល័ត និងអចល័ត ហើយបង្កឲ្យព្យសនកម្មដល់សុខភាពមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា៧៧៥ ។

ប៉ុន្តែក្នុងករណីដែលបង្កឲ្យមានការបំពុលខ្យល់ពីប្រភពចល័ត និងអចល័តដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ បានបង្កឲ្យមានព្យសនកម្មបាត់បង់អាយុជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ។

**មាត្រា១២១៨ ._** ការបញ្ចេញសារធាតុបំពុលខ្យល់លើសស្តង់ដារកម្រិត

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានបញ្ចេញសារធាតុបំពុលខ្យល់លើសស្តង់ដារកម្រិត ដូចមានចែងក្នុងមាត្រា៧៨០ ។

ប៉ុន្តែក្នុងករណីដែលការបញ្ចេញសារធាតុបំពុលខ្យល់លើសស្តង់ដារកម្រិត ខាងលើនេះបានបង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយ សត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី២ ។

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី១ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបញ្ចេញសារធាតុបំពុលខ្យល់លើសស្តង់ដារកម្រិតខាងលើនេះ បានបង្កឲ្យមានព្យសនកម្មបាត់បង់អាយុជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១២១៩ .**_ ការនាំចូល ការប្រើប្រាស់ និងការផលិតប្រភពអចល័ត ដែលលើសពីស្តង់ដារ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានការនាំចូល ការប្រើប្រាស់ និងការផលិតនូវយានយន្ត និងគ្រឿងចក្រ ដែលបញ្ចេញសារធាតុបំពុលខ្យល់ លើសពីស្តង់ដារអនុញ្ញាត ដូចមានចែងក្នុងមាត្រា៧៨១ ។

**មាត្រា១២២០ .**_ ការដាក់ពាក្យសុំលិខិតអនុញ្ញាតបំពោះការបញ្ចេញសារធាតុបំពុលខ្យល់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនបានដាក់ពាក្យសុំលិខិតអនុញ្ញាតបំពោះការបញ្ចេញសារធាតុបំពុលខ្យល់ ដូចមានចែងក្នុងមាត្រា៧៩៣ ។

ប៉ុន្តែក្នុងករណីដែលរូបវន្តបុគ្គល ឬនីតិបុគ្គលខាងលើនេះ នៅតែមានប្រតិបត្តិដោយពុំមានលិខិតអនុញ្ញាតក្រោយពេល ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានបានបដិសេធលើពាក្យស្នើសុំនៅ បានបង្កឲ្យមានព្យសនកម្មដល់បូរណភាពរូបរាងកាយមនុស្ស សត្វ ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី២ ។

ត្រូវផ្តន្ទាទោសថ្នាក់ទី១ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលខាងលើនេះ នៅតែធ្វើប្រតិបត្តិការរបស់ខ្លួនដោយពុំមានលិខិតអនុញ្ញាតក្រោយពេល ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានបានបដិសេធលើពាក្យស្នើសុំនៅ បានបង្កឲ្យមានព្យសនកម្មដល់អាយុជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១២២១ .**_ ភាពលើសកម្រិតនៃប្រភពអចល័តនៃ ការបញ្ចេញសារធាតុបំពុលខ្យល់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនបានជូនដំណឹងភ្លាម ដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានអំពីភាពលើកម្រិតនៃការបំភាយសារធាតុបំពុលខ្យល់ ដូចមានចែងក្នុងមាត្រា៧៩៩ ។

ប៉ុន្តែក្នុងករណីដែលរូបវន្តបុគ្គល ឬនីតិបុគ្គលខាងលើនេះ មិនបានជូនដំណឹងភ្លាម ដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានអំពីភាពលើកម្រិតនៃការបំភាយសារធាតុបំពុលខ្យល់ ហើយបានបង្ក

ឲ្យមានព្យសនកម្មដល់បូរណភាពរូបរាងកាយមនុស្ស និងសត្វ ត្រូវផ្ដន្ទាទោសចំពោះបទល្មើស ថ្នាក់ទី២ ។

ត្រូវផ្ដន្ទាទោសថ្នាក់ទី១ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលខាងលើនេះ មិនបានជូនដំណឹងភ្លាម ដល់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានអំពីភាពលើកម្រិតនៃការបំភាយសារធាតុបំពុលខ្យល់ បានបង្កឲ្យមានព្យសនកម្មដល់អាយុជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១២២២** ._ កាតព្វកិច្ចរាយការណ៍អំពីការបំពានលិខិតអនុញ្ញាត

ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយ ណាដែលមិនរាយការណ៍អំពីការបំពានលិខិតអនុញ្ញាតដែលអាចបង្កឲ្យមានគ្រោះថ្នាក់ដល់បរិស្ថាន ដូចមានចែងក្នុងមាត្រា៨០០ ។

**មាត្រា១២២៣** ._ ការធ្វើសំណាកនៃការបញ្ចេញដោយប្រភពអល័ត

ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយ ណាដែលមិនបានធ្វើសំណាកនៃការបំភាយនៃការបំពុលខ្យល់អល័ត ដូចមានចែងក្នុងមាត្រា៨០៣ ។

**មាត្រា១២២៤** ._ អំពើរារាំងមន្ត្រីអធិការកិច្ចការបំពុល

ត្រូវផ្ដន្ទាទោសចំពោះបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែល ដែលបានរារាំងមន្ត្រីអធិការកិច្ចការបំពុល ក្នុងការចូលធ្វើអធិការកិច្ចក្នុងបរិវេណ ឬអាគារនៃប្រភព បំពុល ដូចមានចែងក្នុងមាត្រា១០៣៨ ។

ប៉ុន្តែក្នុងករណីដែលរូបវន្តបុគ្គល ឬនីតិបុគ្គលខាងលើនេះ បានរារាំងមន្ត្រីអធិការកិច្ចបំពុលនៃ ប្រភពបំពុល ក្នុងការចូលធ្វើអធិការកិច្ចក្នុងបរិវេណ ឬអាគារ ហើយបានបង្កឲ្យមានព្យសនកម្មដល់ បូរណភាពរូបរាងកាយ ត្រូវផ្ដន្ទាទោសចំពោះបទល្មើសថ្នាក់ទី២ ។

ត្រូវផ្ដន្ទាទោសថ្នាក់ទី១ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលខាងលើនេះ រារាំងមន្ត្រីអធិការកិច្ច បំពុល ក្នុងការចូលធ្វើអធិការកិច្ចក្នុងបរិវេណ ឬអាគារនៃប្រភពបំពុល បានបង្កឲ្យមានព្យសនកម្មដល់ អាយុជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១២២៥** ._ ការបញ្ចេញសំឡេង និងរំញ័រដែលបំពានស្តង់ដារកម្រិត

ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយ ណាដែលមិនបានបង្កការបញ្ចេញសំឡេង និងរំញ័រតាមស្តង់ដារកំណត់ ដូចមានចែងក្នុងមាត្រា៨១៨ ។

**មាត្រា១២២៦** ._ ការបញ្ចេញសំឡេង និងរំញ័រ

ត្រូវផ្តន្ទាទោសចំពោះបទល្មើសថ្នាក់ទី៤ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែល ដែលបានបង្កការបញ្ចេញសំឡេង ឬរំញ័រ ហើយបង្កឲ្យប៉ះពាល់ដល់សុខភាពមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា៨១៦ ។

**មាត្រា១២២៧** ._ ការបញ្ចេញសំឡេង និងរំញ័រដែលបំពានបទបញ្ជារបស់មន្ត្រីត្រួតពិនិត្យការបំពុលបរិស្ថាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានបង្កការបញ្ចេញសំឡេង និងរំញ័រដែលបំពានបទបញ្ជារបស់មន្ត្រីត្រួតពិនិត្យការបំពុលបរិស្ថានដូចមានចែងក្នុងមាត្រា១០៣៨ ។

**មាត្រា១២២៨** ._ កាតព្វកិច្ចរាយការណ៍អំពីការបំពុលដែលប៉ះពាល់ដល់បរិស្ថាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនបានរាយការណ៍អំពីការបំពុលដែលប៉ះពាល់ដល់បរិស្ថាន ដូចមានចែងក្នុងមាត្រា៨២២ ។

**មាត្រា១២២៩** ._ កាតព្វកិច្ចរាយការណ៍អំពីការបំពុលដែលប៉ះពាល់ដល់បរិស្ថាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនបានដាក់បញ្ចូលនៅក្នុងបញ្ជីនៃឧស្សាហកម្ម ស្តីពីការបញ្ចេញសារធាតុបំពុលបរិស្ថាន ដូចមានចែងក្នុងមាត្រា៨៣៦ ។

## ជំពូកទី៨
## បទល្មើសពាក់ព័ន្ធវិធានការសេដ្ឋកិច្ច គណនី ថ្លៃ និងមូលនិធិផ្នែកបរិស្ថាន

**មាត្រា១២៣០** ._ ការមិនបង់ថ្លៃ និងបន្ទុកសេវាការពារបរិស្ថាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនបានបង់ថ្លៃ និងបន្ទុកសេវាការពារបរិស្ថាន ដូចមានចែងក្នុងមាត្រា៨៧៨ ។

ក្នុងករណីដែលរូបវន្តបុគ្គល ឬនីតិបុគ្គលខាងលើខកខានមិនបានបង់ប្រាក់ពិន័យតាមការកំណត់ក្នុងកថាខណ្ឌខាងលើនេះ ត្រូវពិន័យជាប្រាក់ប្រចាំថ្ងៃ២.០០០.០០០ (ពីរលាន)រៀល បន្ថែមនឹងប្រាក់ពិន័យខាងលើរហូតដល់បានបង់ប្រាក់ពិន័យគ្រប់ចំនួន ។

**មាត្រា១២៣១** ._ ការមិនបង់ប្រាក់ធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការបិទ ការស្តារនីតិសម្បទា ការផ្តល់ដំណោះស្រាយ និងការស្តារបរិស្ថានឡើងវិញ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនបានបង់ប្រាក់ធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការបិទ ការស្តារនីតិសម្បទា ការផ្តល់ដំណោះស្រាយ និងការស្តារឡើងវិញ ដូចមានចែងក្នុងមាត្រា៩០៦ ។

ក្នុងករណីដែលរូបវន្តបុគ្គល ឬនីតិបុគ្គលខាងលើខកខានមិនបានបង់ប្រាក់ធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការបិទ ការស្តារនីតិសម្បទា ការផ្តល់ដំណោះស្រាយ និងការស្តារឡើងវិញតាមការកំណត់ក្នុងកថាខណ្ឌខាងលើនេះ ត្រូវពិន័យជាប្រាក់ប្រចាំថ្ងៃ២.០០០.០០០ (ពីរលាន)រៀល បន្ថែមនឹងប្រាក់ពិន័យខាងលើរហូតដល់បានបង់ប្រាក់ពិន័យគ្រប់ចំនួន ។

**មាត្រា១២៣២ .**_ ការមិនរៀបចំដាក់បញ្ជូនរបាយការណ៍ និងសវនកម្ម

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិនបានបំពេញកាតព្វកិច្ចក្នុងការរៀបចំដាក់បញ្ជូនរបាយការណ៍ និងសវនកម្មទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ដូចមានចែងក្នុងមាត្រា៩១០ ។

## គន្ថីទី១០
## អន្តរប្បញ្ញត្តិ
## ជំពូកទោល
## អន្តរប្បញ្ញត្តិ

**មាត្រា១២៣៣ .**_ ការអនុវត្តបទប្បញ្ញត្តិនៃក្រមនេះ

បទប្បញ្ញត្តិនៃច្បាប់ពិសេស និងលិខិតបទដ្ឋានគតិយុត្តដោយឡែកដែលកំពុងនៅជាធរមាន នៅតែមានអានុភាពអនុវត្ត រហូតដល់បទប្បញ្ញត្តិនៃក្រមនេះចូលជាធរមាន ។

ក្រោយពេលក្រមនេះចូលជាធរមាន បទប្បញ្ញត្តិនៃក្រមនេះ មានអានុភាពអនុវត្តជាអាទិភាព ប្រសិនបើមានបទប្បញ្ញត្តិនៃច្បាប់ពិសេស និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលចែងផ្ទុយពីនោះ ។

បទប្បញ្ញត្តិនៃច្បាប់ពិសេស និងលិខិតបទដ្ឋានគតិយុត្តដោយឡែកដែលកំពុងនៅជាធរមាន នៅតែមានអានុភាពអនុវត្ត ដរាបណាបទប្បញ្ញត្តិថ្មីនៃក្រមនេះមិនទាន់ចូលជាធរមាន ។

**មាត្រា១២៣៤ .**_ ការអនុវត្តគោលការណ៍ទូទៅនៃក្រមនេះ

ជំពូកទី២ មាតិកាទី១ នៃគន្ថីទី១ដែលបញ្ញត្តិពីគោលការណ៍ទូទៅ ត្រូវយកអនុវត្តចំពោះបទប្បញ្ញត្តិនៃច្បាប់ពិសេសដោយឡែកពាក់ព័ន្ធនឹងការពារបរិស្ថាន និងគ្រប់គ្រប់គ្រងធនធាន ។

**មាត្រា១២៣៥ .**_ នីតិវិធី ដំណើរការ និងយន្តការផ្សេងៗនៃការអនុវត្តដែលមានស្រាប់

នីតិវិធីដំណើរការ និងយន្តការផ្សេងៗនៃការអនុវត្តដែលមានស្រាប់ទាក់ទងនឹងការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិនៅបន្តអានុភាពអនុវត្ត រហូតដល់នីតិវិធី ដំណើរការ និងយន្តការផ្សេងៗនៃការអនុវត្តថ្មី ដែលបង្កើតឡើងក្រោមបទប្បញ្ញត្តិនៃក្រមនេះបានបង្កើតឡើង ។

# គន្ថីទី១១
# អវសានប្បញ្ញត្តិ
## ជំពូកតោល
## អវសានប្បញ្ញត្តិ

**មាត្រា១២៣៦** ._ និរាករណ៍នៃបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធ

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងក្រមនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១២៣៧** ._ ការអនុវត្តក្រមនេះ

ក្រោយពីក្រមនេះចូលជាធរមាននៅទូទាំងប្រទេស ក្រមនេះត្រូវផ្សព្វផ្សាយរយៈពេល៦ (ប្រាំមួយ)ខែទើបអនុវត្ត លើកលែងតែបទប្បញ្ញត្តិស្តីពីសិទ្ធិនៃការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ ដែលត្រូវមានអានុភាពអនុវត្តភ្លាម ។

ក្រមនេះត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅ
ថ្ងៃទី...... ខែ....... ឆ្នាំ............ នាសម័យប្រជុំរដ្ឋសភាលើកទី.........
នីតិកាលទី........ ។

រាជធានីភ្នំពេញ ថ្ងៃទី........ ខែ............. ឆ្នាំ ២០១៧

**ប្រធានរដ្ឋសភា**